ក្រសួងអប់រំ យុវជន និងកីឡា

# បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍

១២



២០១៩

# អារម្ភកថា

ដើម្បីអភិវឌ្ឍប្រទេសកម្ពុជាឱ្យរីកចម្រើន បំពេញតម្រូវការទីផ្សារការងារ និងភាពរីកចម្រើនដែលវិវឌ្ឍជានិច្ចនូវវិស័យបច្ចេកវិទ្យាព័ត៌មាន ចាំបាច់ត្រូវបណ្តុះបណ្តាលធនធានមនុស្ស ពិសេស គឺសិស្សានុសិស្សឱ្យមានចំណេះដឹង និងបំណិនវិជ្ជាជីវៈច្បាស់លាស់អំពីគន្លងការងារដែលមានក្នុងវិស័យព័ត៌មានវិទ្យា។ ក្រសួងអប់រំ យុវជន និងកីឡាបានអភិវឌ្ឍគោលនយោបាយ និងយុទ្ធសាស្ត្រប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងការអប់រំនៅកម្ពុជា ព្រមទាំងឯកសារបណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ជាច្រើនសំដៅធ្វើយ៉ាងណាឱ្យគ្រូបង្រៀនមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន និងរៀន ប្រកបដោយគុណភាព និងបច្ចុប្បន្នភាពដូចបណ្តាប្រទេសក្នុងតំបន់។

សៀវភៅបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ថ្នាក់ទី ១២ នេះ ចងក្រងឡើងសម្រាប់ជាជំនួយដល់ការបង្រៀន និងរៀនតាមបែបបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ដើម្បីទទួលបានបំណិនទាក់ទងនឹងទីផ្សារការងារក្នុងវិស័យបច្ចេកវិទ្យា បំណិនបច្ចេកទេសកុំព្យូទ័រដែលចាំបាច់ បំណិនក្នុងការប្រាស្រ័យទាក់ទង ការត្រិះរិះពិចារណា ដោះស្រាយបញ្ហា ព្រមទាំងសម្រេចចិត្តបានត្រឹមត្រូវក្នុងការជ្រើសរើស វិជ្ជាជីវៈណាមួយសម្រាប់ការងារ និងបន្តការសិក្សានៅសាកលវិទ្យាល័យ ។

យើងខ្ញុំសង្ឃឹមថា សៀវភៅនេះ នឹងបានជាប្រយោជន៍សម្រាប់ការសិក្សាស្វែងយល់អំពីបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ព្រមទាំងជាវិភាគទានក្នុងការបង្រៀន និងរៀនឱ្យកាន់តែសុក្រឹត និងមានប្រសិទ្ធភាពខ្ពស់។

យើងខ្ញុំរីករាយរង់ចាំទទួលនូវមតិរិះគន់ស្ថាបនាពីសំណាក់លោក លោកស្រី និងមិត្តអ្នកអានទាំងអស់ ក្នុងន័យធ្វើយ៉ាងណាឱ្យឯកសារនេះកាន់តែល្អប្រសើរ បម្រើដល់ប្រយោជន៍រួម និងសង្គមជាតិ ។

**គណៈកម្មការនិពន្ធ**

# គណៈកម្មការគ្រប់គ្រង

១. ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន
២. លោកជំទាវ គឹម សេដ្ឋានី
៣. ឯកឧត្តម អ៊ឹម កុច
៤. លោកជំទាវ ទន់ សាអ៊ឹម
៥. ឯកឧត្តម ពុត សាមិត្ត
៦. លោក អេង គឹមលី

# គណៈកម្មការត្រួតពិនិត្យ

១. លោក សុក ថា
២. លោក អោ សៀម
៣. លោក អ៊ឹង ង៉ោហុក
៤. លោក ស៊ុន ប៊ុណ្ណា

# គណៈកម្មការនិពន្ធ

១. លោក ព្រំ វិបុល
២. លោក លឹម សុត្ថារិទ្ធ
៣. លោក ឈុំ វណ្ណធន
៤. លោក យ៉ង់ កំស៊ាន
៥. លោក កែល ភារុណ
៦. កញ្ញា សេង ស៊ីណែត

# អ្នកជំនួយបច្ចេកទេស

១. លោក ខេង ពិសិដ្ឋ
២. Mr. Javier Solá
៣. Mr. Jose Encinas
៤. Ms. Cathie McIntyre

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ៦៧៧ អយក. ប្រក ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១៦ ដើម្បីប្រើប្រាស់នៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅ។

# មាតិកា


អារម្ភកថា

## ជំពូកទី ១ - ការងារនៅក្នុងសម័យបច្ចេកវិទ្យា

មេរៀនទី ១ - ការពង្រីកព្រំដែនចំណេះដឹង
ផ្នែក ក - ការងារនៅក្នុងសង្គមព័ត៌មានវិទ្យា
ការណែនាំអំពីវគ្គសិក្សានេះ ........ ២
១. បរិស្ថានការងារនៅក្នុងប្រទេសកម្ពុជា ........ ៥
២. គន្លងការងារក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន ........ ៨
គោលការណ៍ណែនាំអំពីលំហាត់ ........ ១២
ផ្នែក ខ - ការប្រើប្រាស់បច្ចេកវិទ្យាឱ្យបានត្រឹមត្រូវ
៣. អ៊ីនធឺណិត ........ ១៣
៤. ភាពត្រឹមត្រូវ ការត្រិះរិះពិចារណា និង សេរីភាពក្នុងការនិយាយ ........ ១៤
៤.១. សេរីភាពការបញ្ចេញមតិ ........ ១៥
៥. ទំនាក់ទំនង ........ ១៦
៦. បណ្តាញសង្គម ........ ១៧
៦.១. គុណភាពនៃទំនាក់ទំនង ........ ១៩
៧. ការងារសហការ ........ ២០
៨. ទូរសព្ទ ........ ២១
មេរៀនទី ២ - បំណិនទំនាក់ទំនងក្នុងសម័យកាលឌីជីថល
ផ្នែក ក - ទម្រង់នៃទំនាក់ទំនង
១. បំណិនទំនាក់ទំនង ........ ២៩
១.១. ទំនាក់ទំនងដោយវាចា ........ ៣១
១.២. ទំនាក់ទំនងដោយមិនវាចា ........ ៣៣
២. ការយល់ពីអារម្មណ៍ និងត្រិះរិះពិចារណា ........ ៣៦
ផ្នែក ខ - បំណិនបច្ចេកវិទ្យាទំនាក់ទំនង និងកន្លែងធ្វើការ
៣. ការស្តាប់សកម្ម ........ ៤០
៤. ការផ្តល់ និងទទួលយកមតិយោបល់ ........ ៤៤
៥. ការបង្កើតក្រុម ........ ៤៦

## ជំពូកទី ២ - ប្រព័ន្ធ

មេរៀនទី ៣ - ការគ្រប់គ្រងប្រព័ន្ធ និងបណ្តាញ
ផ្នែក ក - ការងារផ្នែកគ្រប់គ្រងប្រព័ន្ធ និងបណ្តាញ
១. ការណែនាំអំពីការគ្រប់គ្រងប្រព័ន្ធ និងបណ្តាញ ........ ៥១
២. តម្រូវការការងារ ........ ៥៥
៣. បរិស្ថានការងារ ........ ៦០

# មាតិកា


## ជំពូកទី ៣ - ការសរសេរកូដកម្មវិធី

មេរៀនទី ៤ - ការអភិវឌ្ឍកម្មវិធីបច្ចេកវិទ្យា
ផ្នែក ក - ការងារនៅក្នុងផ្នែកសរសេរកូដកម្មវិធីបច្ចេកវិទ្យា
១. ការណែនាំអំពីការអភិវឌ្ឍកម្មវិធីបច្ចេកវិទ្យា ....... ៦៤
២. ការងារជាអ្នកអភិវឌ្ឍកម្មវិធី ....... ៦៦
២.១. បរិស្ថាន និងចរិតលក្ខណៈនៅក្នុងការងារផ្នែកសរសេរកូដកម្មវិធី ....... ៧២
ផ្នែក ខ - ការគិតតាមលំដាប់លំដោយ
៣. ការគិតតាមលំដាប់លំដោយ....... ៧៥
៤. គំនូសតាងលំហូរ ....... ៧៧

## ជំពូកទី ៤ - ការរចនា

មេរៀនទី ៥ - ការងារក្នុងការរចនារូបភាព
ផ្នែក ក - ការងារក្នុងការរចនារូបភាព
១. ការណែនាំអំពីការរចនារូបភាព ....... ៨៣
១.១. ទំនាក់ទំនងជារូបភាព និងការរចនារូបភាព ....... ៨៦
២. ការងារជាអ្នករចនារូបភាព ....... ៨៧
២.១. តម្រូវការការងារ ....... ៨៧
២.២. បរិស្ថានការងារ ....... ៩០
ផ្នែក ខ - គោលគំនិតសំខាន់ៗក្នុងការរចនារូបភាព
៣. របៀបផ្តល់ខ្លឹមសារត្រឹមត្រូវ ....... ៩៥
៣.១. ប្លង់ដែលបានរចនាយ៉ាងប្រសើរ ....... ៩៥
៣.២. សុខដុម....... ៩៧
៤. ពណ៌....... ៩៧
៤.១. ប្រភេទពណ៌ ....... ៩៨
៤.២. គ្រោងពណ៌ ប្រភេទ និងការប្រើប្រាស់ ....... ៩៩
៤.៣ គ្រោងពណ៌បង្គ្រប់ និងស្រដៀងគ្នា ....... ១០០
៥. ការចូលចិត្តផ្ទាល់ខ្លួន....... ១០០
មេរៀនទី ៦ - ការរចនាវេបសាយ
ផ្នែក ក - ការងារនៅក្នុងការរចនា និងថែទាំវេបសាយ
១. ការណែនាំអំពីការរចនា និងថែទាំវេបសាយ....... ១០៤
១.១. ហេតុអ្វីក្រុមហ៊ុនត្រូវការវេបសាយ....... ១០៨
១.២. លក្ខណៈនៃវេបសាយដែលមានប្រសិទ្ធភាព....... ១០៨
២. ការងារនៅក្នុងការរចនាវេបសាយ....... ១១១
២.១. បរិស្ថានការងារ ....... ១១៤
ផ្នែក ខ - អក្ខរកម្មមេឌា និងអ៊ីនធឺណិត

# មាតិកា


៣. អក្ខរកម្មមេឌា ........................................ ១២០
៣.១. ទម្រង់នៃមេឌា........................................ ១២០
៣.២. មាតិកា និងទម្រង់នៃព័ត៌មាន ........................................ ១២២
៤. បំណិនអក្ខរកម្មមេឌា ........................................ ១២២
៤.១. កសាងបំណិនអក្ខរកម្មមេឌាសម្រាប់អ្នកប្រើ ........................................ ១២៥
៤.២. កសាងបំណិនអក្ខរកម្មមេឌាសម្រាប់អ្នកបង្កើតមាតិកាព័ត៌មាន............ ១២៧

មេរៀនទី ៧ - ការអភិវឌ្ឍវេបសាយ

ផ្នែក ក - បណ្តាញឌីណាមិក

១. ទំព័របណ្តាញមិនប្រែប្រួល និងប្រែប្រួល ........................................ ១៣៤
១.១. ការរៀបចំរចនាសម្ព័ន្ធនៃព័ត៌មាន ........................................ ១៣៥
១.២. មូលដ្ឋានទិន្នន័យ ........................................ ១៣៦
១.៣. ទំព័របណ្តាញឌីណាមិក........................................ ១៣៧
១.៤. ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមជាវេបសាយឌីណាមិក........................ ១៤០
១.៥. ផែនទីជាវេបសាយឌីណាមិក ........................................ ១៤១
១.៦. ការផ្សាយពាណិជ្ជកម្មបែបឌីណាមិក........................................ ១៤១
២. ប្រព័ន្ធគ្រប់គ្រងមាតិកាព័ត៌មាន........................................ ១៤២
៣. កំណត់ហេតុបណ្តាញ និងវេបសាយ ........................................ ១៤៣

ផ្នែក ខ - ទំនាក់ទំនងឌីជីថល

៤. បុគ្គលិកលក្ខណៈនៃទំនាក់ទំនងឌីជីថល ........................................ ១៤៦
៥. ទំនាក់ទំនងជាសាធារណៈ និងបណ្តាញសង្គម ........................................ ១៤៨
៥.១. ភាពឯកជន និងការចែករំលែក........................................ ១៥០
៥.២. ទំនាក់ទំនងដោយគោរព និងទទួលខុសត្រូវ........................................ ១៥៣
៥.៣. គុណតម្លៃនៃពេលវេលារបស់អ្នក........................................ ១៥៦

មេរៀនទី ៨ - ការងារនៅក្នុងផ្នែកប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម

ផ្នែក ក - ការងារនៅក្នុងផ្នែកប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម

១. ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមជាផ្នែកវិជ្ជាជីវៈ ........................................ ១៦២
១.១. ទំនាក់ទំនង និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម........................................ ១៦៤
២. ការងារប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម ........................................ ១៦៥
២.១. តម្រូវការការងារ ........................................ ១៦៦
២.២. បរិស្ថានការងារ ........................................ ១៧០

ផ្នែក ខ - ការប្រើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមដោយប្រសិទ្ធភាព

៣. ការចូលរួមយ៉ាងសកម្មក្នុងទំនាក់ទំនងឌីជីថល ........................................ ១៧៤
៤. ទំនាក់ទំនងឌីជីថលតាមរយៈកំណត់ហេតុបណ្តាញ........................................ ១៧៧
៤.១. ធ្វើផែនការសម្រាប់កំណត់ហេតុបណ្តាញ ........................................ ១៧៧
៤.២. ការបង្កើតកំណត់ហេតុបណ្តាញ ........................................ ១៨០
៤.៣. ការផ្សព្វផ្សាយ និងបណ្តាញ........................................ ១៨៣

# មាតិកា

## ជំពូកទី ៥ - បំណិនបង្រៀន ការលក់ និងការងារ


មេរៀនទី ៩ - ការងារបង្រៀនកុំព្យូទ័រ
ផ្នែក ក - ការងារក្នុងការបង្រៀនកុំព្យូទ័រ
១. ការណែនាំអំពីការអប់រំ ICT ..... ១៩០
២. ការងារក្នុងការបង្រៀនកុំព្យូទ័រ ..... ១៩២
២.១. តម្រូវការការងារ ..... ១៩៣
២.២. បរិស្ថានការងារ ..... ១៩៧
ផ្នែក ខ - ប្រសិទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងវិស័យអប់រំ
៣. គរុកោសល្យ និងបច្ចេកវិទ្យាព័ត៌មាន ..... ២០២
៣.១. គោលវិធីគរុកោសល្យបង្រៀន ..... ២០៣
៣.២. ការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន ..... ២០៦
៤. ការវាយតម្លៃការសិក្សា ..... ២០៧
៥. បច្ចេកវិទ្យាក្នុងថ្នាក់រៀន ..... ២០៩
មេរៀនទី ១០ - បំណិនលក់កុំព្យូទ័រ និងការងារ
ផ្នែក ក - ការងារនៅក្នុងផ្នែកលក់ និងថែទាំកុំព្យូទ័រ
១. ការណែនាំអំពីទីផ្សារកុំព្យូទ័រ ..... ២១៦
១.១. ផលិតផល និងសេវាកម្ម ..... ២១៨
២. ការងារនៅក្នុងផ្នែកលក់កុំព្យូទ័រ ..... ២២០
៣. បរិស្ថានការងារនៅក្នុងហាងលក់កុំព្យូទ័រ ..... ២២៥
ផ្នែក ខ - ការជ្រើសរើសសាកលវិទ្យាល័យ
៤. សេចក្តីផ្តើម ..... ២២៨
៥. ការជ្រើសរើសសាកលវិទ្យាល័យសម្រាប់ជំនាញព័ត៌មានវិទ្យា ..... ២២៩
៦. អនុសាសន៍មួយចំនួន ..... ២៣៣
៧. សេចក្តីសន្និដ្ឋាន ..... ២៣៦

# មេរៀនទី

# ១

# ការពង្រីកព្រំដែនចំណេះដឹង

## នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពី៖

១. ការកំណត់វត្ថុបំណងរបស់មេរៀននេះ
២. បរិស្ថានការងារនៅប្រទេសកម្ពុជា ជាពិសេសទីផ្សារការងារសម្រាប់ជំនាញបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT)
៣. ជំនាញដែលនិយោជកចង់បានសម្រាប់និយោជិត
៤. បុគ្គលិកលក្ខណៈនៃការងារផ្សេងទៀតនៅក្នុងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។

# ផ្នែក ក - ការងារក្នុងសង្គមព័ត៌មានវិទ្យា

## ការណែនាំអំពីវគ្គសិក្សានេះ

យើងរស់នៅក្នុងសង្គមដែលពោរពេញដោយចំណេះដឹង និងការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិក ផ្សេងៗដើម្បីទាក់ទង ដំណើរការ និងផ្ទុកព័ត៌មាន។ សព្វថ្ងៃនេះមនុស្សភាគច្រើនមានទូរទស្សន៍ និង ទូរសព្ទចល័ត ហើយអ្នកខ្លះក៏មានកុំព្យូទ័រលើតុ ឬកុំព្យូទ័រយួរដៃសម្រាប់ប្រើនៅផ្ទះ។ ទោះបីអ្នកមិនទាន់ មានកុំព្យូទ័រផ្ទាល់ខ្លួនក៏ដោយ ក៏អ្នកចាំបាច់ត្រូវមានជំនាញ និងចំណេះដឹងមូលដ្ឋានអំពីកុំព្យូទ័រដែរ ព្រោះ ការងារភាគច្រើននៅក្នុងប្រទេសកម្ពុជាដែលមានសេដ្ឋកិច្ចកំពុងរីកលូតលាស់មួយនេះពឹងផ្អែកលើកុំព្យូទ័រ ជាពិសេសប្រសិនបើអ្នកចង់ធ្វើការនៅក្នុងស្ថាប័ន ឬនៅក្នុងក្រុមហ៊ុននោះ។

ការសិក្សាមួយនៅឆ្នាំ២០០៨ បានបង្ហាញថា សិស្សថ្នាក់ទី១២នៅក្នុងប្រទេសកម្ពុជាប្រមាណ ពាក់កណ្ដាលមានគម្រោងបន្តការសិក្សានៅសាកលវិទ្យាល័យ ខណៈដែលមានសិស្ស១៧%ទៀតមាន គម្រោងបន្តការសិក្សានៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ។ ពួកគេភាគច្រើនមិនមានគម្រោងបន្តការ សិក្សារបស់ខ្លួនឡើយដោយសារមិនមានលទ្ធភាពហិរញ្ញវត្ថុគ្រប់គ្រាន់ហើយភាគច្រើនមានគម្រោងស្វែងរក ការងារធ្វើសិន ទើបបន្តការសិក្សានៅសាកលវិទ្យាល័យនៅពេលពួកគេមានថវិកាគ្រប់គ្រាន់។

សម្រាប់អ្នកដែលមានគម្រោងបន្តការសិក្សានៅសាកលវិទ្យាល័យទាំងអស់ គឺមានសំណួរដូចៗគ្នា បានចោទសួរថា តើពួកគេគួរសម្រេចចិត្តចាប់យកអាជីពការងារបែបណា។ ១០%ក្នុងចំណោមនេះ គឺ អាណាព្យាបាលតែម្នាងជាអ្នកសម្រេច ហើយ៥៧% គឺបានសម្រេចដោយមានការចូលរួមរវាងសាមីខ្លួន និង អាណាព្យាបាល។ មានតែសិស្ស១៩% ប៉ុណ្ណោះដែលបានសម្រេចចិត្តជ្រើសយកមុខវិជ្ជា ដោយផ្អែកលើ ការយល់ដឹងរបស់ពួកគេអំពីទីផ្សារការងារ។

ការសម្រេចចិត្តជ្រើសរើសយកជំនាញសិក្សានៅសាកលវិទ្យាល័យ នឹងជះឥទ្ធិពលដល់ជីវិតរបស់ អ្នកទាំងមូល។ ការសម្រេចចិត្តដោយផ្អែកលើអ្វីដែលអ្នកបានគិត នឹងធ្វើឱ្យអ្នកមានភាពរីករាយនាពេល អនាគត។ អ្នកនឹងត្រូវធ្វើការយ៉ាងតិចប្រាំបីម៉ោងក្នុងមួយថ្ងៃ ហើយបើអ្នកមិនរីករាយជាមួយការងារទេ នោះជីវិតរបស់អ្នកនឹងមិនមានសេចក្ដីសុខ ឬទទួលបានជោគជ័យក្នុងការងារនោះឡើយ។



ពិភពលោកមានការផ្លាស់ប្ដូរយ៉ាងឆាប់រហ័ស មានការងារថ្មីៗជាច្រើនដែលពុំធ្លាប់មានពីមុនមក ត្រូវបានបង្កើតឡើង វាជាតថភាពមួយនៅក្នុងសម័យបច្ចេកវិទ្យាបច្ចុប្បន្ន។ មានឪពុកម្ដាយតិចតួចប៉ុណ្ណោះ ដែលអាចផ្ដល់យោបល់អំពីការងារក្នុងវិស័យដែលពួកគាត់មិនមានបទពិសោធន៍ ឬពុំបានធ្លាប់សិក្សា។ វាពិតជាសំខាន់ខ្លាំងណាស់ដែលថាសិស្សត្រូវតែមានចំណេះដឹងគ្រប់គ្រាន់ ក្នុងការសម្រេចចិត្តអំពីការងារផ្ទាល់ខ្លួនរបស់ពួកគេ។ អ្នកចាំបាច់ត្រូវសួរខ្លួនឯងនូវសំណួរមួយចំនួនដូចជា៖ “តើខ្ញុំចូលចិត្តអ្វី? តើអ្វីដែលសំខាន់សម្រាប់ខ្ញុំ? តើខ្ញុំនឹងត្រូវធ្វើការនៅទីណា? តើការងារអ្វីដែលខ្ញុំនឹកស្រមៃចង់ធ្វើនៅរយៈពេលប្រាំឆ្នាំក្រោយ ឬដប់ឆ្នាំក្រោយ?” ពេលអ្នកបញ្ចប់ការសិក្សានៅវិទ្យាល័យ អ្នកចាំបាច់ត្រូវមានផែនការមួយចំនួនសម្រាប់អនាគតរបស់ខ្លួន។ អ្នកអាចផ្លាស់ប្ដូរផែនការទាំងនោះបាន ប៉ុន្តែអ្នកត្រូវតែគិតឱ្យបានច្បាស់លាស់អំពីអ្វីដែលអ្នកចង់ធ្វើនាពេលអនាគត។ អ្នកត្រូវតែមានសុបិនអំពីអ្វីដែលអ្នកចង់បាន បន្ទាប់មកអ្នកចាំបាច់ត្រូវជំរុញសុបិនទាំងនោះឱ្យកើតឡើងដោយការចាប់ផ្ដើមធ្វើវា បើមិនដូច្នោះទេ ជីវិតរបស់អ្នកនឹងតែលតោល ហើយពេលវេលារបស់អ្នកនឹងកន្លងផុតទៅដោយឥតប្រយោជន៍។

*សិស្សក៏ចាំបាច់ត្រូវសម្លឹងមើលដោយយកចិត្តទុកដាក់ផងដែរ នូវការងារទាំងឡាយណាដែលជួយធ្វើឱ្យសេដ្ឋកិច្ចប្រទេសជាតិរឹងមាំ។ សម្រាប់សិស្សដែលបានជ្រើសរើសជំនាញដូចគ្នាខាងលើ វានឹងធ្វើឱ្យការងាររបស់ពួកគេរីកចម្រើនជាមួយសេដ្ឋកិច្ចរបស់ប្រទេសនោះ ហើយអាចទទួលបានជោគជ័យ និងការងារពិសេសទៀតផង។*

ស្ទើរតែពាក់កណ្ដាលនៃនិស្សិតនៅសាកលវិទ្យាល័យនៅកម្ពុជា គឺត្រូវបានបង្ខំចិត្តសិក្សាទៅលើមុខវិជ្ជាគណនេយ្យ-ហិរញ្ញវត្ថុ និងការគ្រប់គ្រង។ ការសិក្សាគឺសំខាន់ ប៉ុន្តែចំនួននិស្សិតដែលបញ្ចប់ការសិក្សាច្រើនជាងតម្រូវការការងារនៅក្នុងប្រទេស ជាហេតុធ្វើឱ្យនិស្សិតដែលបានបញ្ចប់ការសិក្សាទាំងនោះនឹងមានបញ្ហាក្នុងការស្វែងរកការងារដែលត្រូវជាមួយអ្វីដែលពួកគេបានរៀនចប់។ ម្យ៉ាងវិញទៀត ក្រុមហ៊ុនភាគច្រើនតែងព្យាយាមស្វែងរកអ្នកជំនាញព័ត៌មានវិទ្យា ដែលបានបណ្ដុះបណ្ដាលល្អ ក៏ដូចជាវិស្វករ និងអ្នកជំនាញបច្ចេកទេសផ្សេងទៀត។ ជាទូទៅក្រុមហ៊ុនធំភាគច្រើន បានជួលអ្នកជំនាញមកពីក្រៅប្រទេស ដើម្បីធ្វើការលើការងារដែលត្រូវការជំនាញបច្ចេកទេស ផ្នែកវិស្វករ និងព័ត៌មានវិទ្យា។ វាជាឱកាសល្អក្នុងការអប់រំ និងរៀបចំអ្នកជំនាញនៅកម្ពុជាឱ្យមានចំនួនគ្រប់គ្រាន់ក្នុងផ្នែកវិស្វករ និងព័ត៌មានវិទ្យា ដើម្បីបំពេញតាមតម្រូវការការងារ នៅខណៈពេលដំណាលគ្នានៃការធ្វើឱ្យសេដ្ឋកិច្ចជាតិប្រសើរឡើង។

មានកម្រិតសិក្សាមួយចំនួនដែលយើងត្រូវដឹង។ សម្រាប់និស្សិតដែលបញ្ចប់ការសិក្សា កម្រិតបរិញ្ញាបត្ររង គឺបានបញ្ចប់ការសិក្សារយៈពេលពីរឆ្នាំនៅមជ្ឈមណ្ឌលបច្ចេកទេស វិទ្យាស្ថាន ឬសាកលវិទ្យាល័យ។ ការបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្ររង គឺទទួលបានការអប់រំគ្រប់គ្រាន់ដើម្បីធ្វើការនៅក្នុងក្រុមហ៊ុនមួយចំនួន ប៉ុន្តែកម្រិតបរិញ្ញាបត្រគឺគេត្រូវការច្រើនជាង ដូច្នេះហើយបានជានិស្សិតភាគច្រើនដែលបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្ររង ត្រូវបន្តការសិក្សារបស់ខ្លួនទៅកម្រិតបរិញ្ញាបត្រទៀត។ ចំពោះនិស្សិតដែលបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យក្នុង កម្រិតបរិញ្ញាបត្រ ជាទូទៅគឺសិក្សារយៈពេលបួនឆ្នាំ។ ការសិក្សាថ្នាក់បរិញ្ញាបត្រជាទូទៅទទួលបានឱកាសការងារជំនាញច្រើនជាង។ និយោជកភាគច្រើនត្រូវការបុគ្គលិកកម្រិតទាបបំផុតបរិញ្ញាបត្រ ដើម្បីចូលបម្រើការងារ។ មានថ្នាក់សិក្សាកម្រិតខ្ពស់ ឬថ្នាក់ក្រោយឧត្ដមសិក្សា។ បរិញ្ញាបត្រជាន់ខ្ពស់ ឬអនុបណ្ឌិត គឺជាកម្រិតសញ្ញាបត្រដែលត្រូវបានបន្តការសិក្សាក្នុងរយៈពេលមួយ ឬពីរឆ្នាំបន្ថែមទៅលើមុខជំនាញជាក់លាក់ ឬដោយការអនុវត្តជំនាញ។ ខណៈដែលនិស្សិតមួយចំនួន បន្តការសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ភ្លាមៗបន្ទាប់ពីបញ្ចប់



បរិញ្ញាបត្រ ប៉ុន្តែមាននិស្សិតភាគច្រើនរកការងារធ្វើបីបួនឆ្នាំសិន ទើបបន្តការសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់របស់ខ្លួន។ ឧទាហរណ៍ជាក់ស្តែងមួយ គឺសម្រាប់អ្នកដែលសិក្សាកម្រិត បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម។ មនុស្សភាគច្រើនជ្រើសយកកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម បន្ទាប់ពីទទួលបានបទពិសោធន៍ជីវិតពិតនៅក្នុងពាណិជ្ជកម្ម។ បទពិសោធន៍របស់ពួកគេគឺហាក់បីដូចជាមេរៀនសម្រាប់ធ្វើឱ្យការងារកាន់តែជោគជ័យ។ កម្រិតសិក្សាខ្ពស់បំផុតគឺ បណ្ឌិត ឬ បណ្ឌិតទស្សនវិទ្យា។ មានមនុស្សតិចតួចប៉ុណ្ណោះដែលបានបន្តសិក្សាកម្រិតបណ្ឌិត ហើយជាទូទៅពួកគេត្រូវសិក្សាពេញម៉ោងរយៈពេលពីបី ទៅប្រាំមួយឆ្នាំ រួមជាមួយកម្រិតអនុបណ្ឌិត។ បេក្ខជនបណ្ឌិតត្រូវតែបញ្ចប់ការស្រាវជ្រាវពិតប្រាកដមួយ។ អ្នកស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ និងសាស្ត្រាចារ្យសាកលវិទ្យាល័យគឺជាមនុស្សក្នុងចំណោមអ្នកដែលបានបញ្ចប់ការសិក្សាកម្រិតបណ្ឌិត ព្រោះពួកគេបានពាក់ព័ន្ធក្នុងការសិក្សាស្រាវជ្រាវដែលតម្រូវឱ្យប្រើទម្រង់វិធីសាស្ត្រស្រាវជ្រាវកម្រិតខ្ពស់។ នៅមានកម្រិតសញ្ញាបត្រផ្សេងៗទៀតដូចជា មេធាវី ទន្តបណ្ឌិត និងវេជ្ជបណ្ឌិត ប៉ុន្តែពួកគេមិនពាក់ព័ន្ធក្នុងផ្នែកបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) ឡើយ តែទោះជាយ៉ាងណាជំនាញវិជ្ជាជីវៈទាំងនោះត្រូវបានទទួលឥទ្ធិពលដោយបច្ចេកវិទ្យាដែរ។

*បន្ថែមពីលើសញ្ញាបត្រ គឺនៅមានលិខិតបញ្ជាក់ ដែលនិយោជិតត្រូវមាន ដើម្បីធ្វើឱ្យការងាររបស់ពួកគេកាន់តែប្រសើរ។*

លិខិតបញ្ជាក់ការងារគឺបង្ហាញថាបុគ្គលនោះមានចំណេះដឹង បទពិសោធន៍ និងជំនាញក្នុងការបំពេញការងារជាក់លាក់មួយ។ ឧទាហរណ៍សម្រាប់ការងារសិក្សាក្នុងផ្នែកប្រព័ន្ធអភិវឌ្ឍកម្មវិធីកុំព្យូទ័រ ឬការរចនាក្រាហ្វិក ហើយសម្រាប់ជំនាញអភិវឌ្ឍខ្លះទៀតក៏ត្រូវបានផ្តល់នូវលិខិតបញ្ជាក់ដែរ។

ពេលសិស្សបន្តការសិក្សារបស់ខ្លួនបន្ទាប់ពីបញ្ចប់នៅវិទ្យាល័យ មានន័យថាពួកគេបានបើកឱកាសសម្រាប់អនាគត។ ពិតមែនហើយ ពួកគេត្រូវតែជាសិស្សពូកែ ព្រោះនៅតាមកន្លែងធ្វើការគឺសុទ្ធតែមានការប្រកួតប្រជែង ហើយជាពិសេសទៀតនោះសម្រាប់អ្នកដែលមានជំនាញខ្លាំងពូកែ គឺនឹងមានឱកាសខ្ពស់ជាងគេក្នុងការទទួលបានការងារ។ វាជាការពិតសម្រាប់វិស័យការងារដែលមានតម្រូវការខ្ពស់ ដូចជា ផ្នែកព័ត៌មានវិទ្យា (IT) ឬវិស្វករជាដើម។ ពេលនិស្សិតទទួលបានបរិញ្ញាបត្រនៅក្នុងផ្នែកការងារដែលមានតម្រូវការ ពួកគេនឹងមានឱកាសទទួលបានការងារល្អប្រសើរ ហើយប្រាក់បៀវត្សខ្ពស់ជាងបេក្ខជនដែលមិនមានសញ្ញាបត្រ ឬនិស្សិតដែលសិក្សាជំនាញមានតម្រូវការការងារទាប។ លិខិតបញ្ជាក់ការងារសម្រាប់អ្នកដែលមានបរិញ្ញាបត្រ គឺកាន់តែបន្ថែមតម្លៃឱ្យពួកគេថែមទៀត។ សម្រាប់អ្នកដែលមានសញ្ញាបត្រអនុបណ្ឌិត ឬបណ្ឌិត ជាទូទៅទទួលបានប្រាក់ចំណូលច្រើនជាងអ្នកដែលមានសញ្ញាបត្របរិញ្ញាបត្រ ជាពិសេសគឺនៅពីរបីឆ្នាំដំបូងនៃការងាររបស់ពួកគេ។

វត្ថុបំណងទីមួយរបស់វគ្គសិក្សានេះគឺ ណែនាំអ្នកទៅកាន់លទ្ធភាពការងារនៅក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងវត្ថុបំណងទីពីរគឺជួយអ្នកឱ្យបានយល់ច្បាស់អំពីរបៀបបន្តការសិក្សា និងការចាប់យកជំនាញបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។ មេរៀននេះនឹងណែនាំអ្នកអំពីការងារមួយ



ចំនួនដូចជា វិស្វករប្រព័ន្ធ ការសរសេរកូដកម្មវិធី ការរចនាក្រាហ្វិក ការរចនាវេបសាយ បណ្ដាញសង្គម ការបង្រៀនព័ត៌មានវិទ្យា ការលក់កុំព្យូទ័រ និងការជួសជុលថែទាំកុំព្យូទ័រ។ ពេលអ្នកបញ្ចប់វគ្គសិក្សានេះ អ្នកដឹងកាន់តែច្បាស់អំពីប្រភេទការងារ និងបរិស្ថានពាក់ព័ន្ធរបស់វា ហើយអ្នកទាំងអស់គ្នានឹងមានបំណងបន្តការសិក្សាផ្នែកបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ជាមិនខាន។

នៅក្នុងវគ្គនេះអ្នកនឹងទទួលបាននូវបទពិសោធន៍ អំពីប្រភេទការងារដែលអ្នកជំនាញបានជួបប្រទះរៀងរាល់ថ្ងៃ ហើយនឹងជួយឱ្យអ្នកសម្រេចគោលដៅបាន ប្រសិនបើអ្នកចូលចិត្តការងារនេះ។ នៅពេលសិក្សា អ្នកក៏នឹងបង្កើននូវសមត្ថភាពរបស់អ្នកផងដែរ អំពីការវិភាគស្ថានការណ៍ ដើម្បីធ្វើការសម្រេចចិត្តដោយខ្លួនឯង។ នៅក្នុងមេរៀននីមួយៗ អ្នកនឹងធ្វើការជាក្រុម ហើយអ្នកនឹងត្រូវបានស្នើឱ្យមើលទៅកាន់ស្ថានភាពជាក់ស្ដែង បន្ទាប់មកដោះស្រាយបញ្ហាជាមួយមិត្តនៅក្នុងក្រុម ដោយចែករំលែកគំនិតយោបល់ និងពិភាក្សាអំពីលទ្ធភាពដំណោះស្រាយ នៅមុនពេលធ្វើការសម្រេចចិត្ត និងចាប់ផ្ដើមអនុវត្ត។ ការចូលរួមក្នុងការពិភាក្សានេះ នឹងធ្វើឱ្យអ្នកទទួលបាននូវជំនាញថ្មីៗ ក៏ដូចជាការត្រៀមរៀបចំខ្លួនដើម្បីបន្តការសិក្សានៅសាកលវិទ្យាល័យ ក្នុងជំនាញព័ត៌មានវិទ្យា ឬជំនាញផ្សេងទៀត។

តាមរយៈការងារនៅក្នុងវគ្គសិក្សានេះ អ្នកនឹងអភិវឌ្ឍនូវជំនាញបច្ចេកទេស ទំនាក់ទំនង ការសិក្សាដោយខ្លួនឯង ការធ្វើផែនការ ហើយអ្នកនឹងស្គាល់ច្បាស់អំពីសមត្ថភាពរបស់ខ្លួនក្នុងការសម្រេចលទ្ធផលការងារ។ ទោះបីជាការងារដែលអ្នកបានសម្រេចចិត្តត្រូវទៅតាមចំណូលចិត្តរបស់អ្នកក៏ដោយ ក៏អ្នកចាំបាច់ត្រូវតែយល់អំពីជំនាញបច្ចេកវិទ្យាផ្សេងៗ នៅក្នុងបរិស្ថានការងាររបស់អ្នកដែរ។

# ១. បរិស្ថានការងារនៅក្នុងប្រទេសកម្ពុជា

កម្ពុជាទើបតែអាចមានលទ្ធភាពធ្វើឱ្យសេដ្ឋកិច្ចរបស់ខ្លួន មានស្ថិរភាពនៅទសវត្សរ៍ឆ្នាំ៩០ប៉ុណ្ណោះ បន្ទាប់ពីទទួលបានសន្តិភាពពេញលេញ។ អាជីវកម្មបានចាប់ផ្ដើមយ៉ាងឆាប់រហ័សមានដូចជាអាជីវកម្មលក្ខណៈគ្រួសារ និងការទិញលក់ដូរទំនិញជាដើម។ មិនយូរប៉ុន្មានក្រុមហ៊ុនធំៗក៏បានចាប់ផ្ដើមរីកដុះដាលយ៉ាងឆាប់រហ័សមានដូចជា ក្រុមហ៊ុនសេវាកម្មបណ្ដាញទូរសព្ទចល័តជាដើម។ អាជីវកម្មលក្ខណៈគ្រួសារតូចៗជាច្រើនបានពង្រីកខ្លួនទៅជាក្រុមហ៊ុនធំៗ ហើយមិនមែនគ្រប់គ្រងដោយសមាជិកគ្រួសារទៀតឡើយ គឺត្រូវបានគ្រប់គ្រងដោយអ្នកជំនាញវិជ្ជាជីវៈត្រឹមត្រូវ ហើយប្រាកដណាស់ថាអាជីវកម្មពួកគេនឹងរីកចម្រើននៅពេលអនាគត។

ក្នុងរយៈពេលប្រាំឆ្នាំកន្លងទៅនេះ កម្ពុជាមានការរីកចម្រើនយ៉ាងខ្លាំងផ្នែកព័ត៌មានវិទ្យា។ ស្តង់ដារនីយកម្មនៃការប្រើប្រាស់កុំព្យូទ័រភាសាខ្មែរ (យូនីកូដ) ត្រូវបានអនុវត្តនៅទូទាំងប្រទេស ព្រមទាំងបានបន្ថែមកម្មវិធីចាំបាច់ជាភាសាខ្មែរ ដើម្បីពន្លឿនការប្រើប្រាស់ទាំងនៅក្នុងស្ថាប័នរដ្ឋាភិបាល ក្រុមហ៊ុន និងអង្គការមិនមែនរដ្ឋាភិបាលនាទសវត្សរ៍ចុងក្រោយនេះ។

ជំហានសំខាន់បំផុតមួយក្នុងការប្ដូរពីអាជីវកម្មគ្រួសារខ្នាតតូច ទៅជាក្រុមហ៊ុនធំគឺការជួលបុគ្គលិក

ដែលមិនមែនជាសាច់ញាតិក្នុងគ្រួសារខ្លួន។ ទីផ្សារការងារត្រូវបានប្តូរពីការជ្រើសរើសមនុស្សចេញពីសមាជិកគ្រួសារដើម្បីកាន់តំណែងក្នុងអាជីវកម្ម ទៅជាការធ្វើគំរូអាជីវកម្មដែលបានរកមើលធនធានមនុស្សមកពីខាងក្រៅ។ ជាមួយគំរូថ្មីនៃការជួលបុគ្គលិក ជាទូទៅគឺចាប់ផ្តើមជាមួយការងារមូលដ្ឋាន ហើយពួកគេរំពឹងថានឹងបានឡើងតួនាទី នៅពេលដែលពួកគេទទួលបានបទពិសោធន៍ និងចំណេះដឹង។

និយោជកតែងជ្រើសនិយោជិតទាំងឡាយណាដែលមានសក្តានុពល និងអាចស្វ័យសម្រេចនូវការងារដែលពួកគេបានដាក់ឱ្យ ពួកគេត្រូវការនិយោជិតដែលអាចគិតបានត្រឹមត្រូវ អាចដោះស្រាយបញ្ហាបាន អាចផ្តល់មតិយោបល់ និងមានការវិនិច្ឆ័យល្អ។ ពួកគេត្រូវបានជួលដើម្បីជួយសម្រួលការងារអ្នកគ្រប់គ្រង ដូច្នេះអ្នកគ្រប់គ្រងអាចធ្វើការងារសំខាន់ផ្សេងទៀតនៅក្នុងក្រុមហ៊ុនបាន។ ខណៈដែលបុគ្គលិកថ្មីជាទូទៅត្រូវឆ្លងកាត់ការបណ្តុះបណ្តាល ហើយពួកគេរំពឹងថានឹងបានសិក្សាពីរបៀបធ្វើការងាររបស់ខ្លួនដោយពុំចាំបាច់មានចង្អុលបង្ហាញពីអ្នកគ្រប់គ្រងគ្រប់ពេលវេលាឡើយ។ និយោជិតត្រូវសិក្សាពីរបៀបធ្វើការសម្រេចចិត្តចំពោះការងារចាំបាច់ និងដោយម្ចាស់ការដោយខ្លួនឯង ដើម្បីសម្រួលឱ្យអ្នកគ្រប់គ្រងអាចផ្តោតអារម្មណ៍ទៅលើការងាររបស់ខ្លួនបានច្រើន។ ប្រសិនបើនិយោជិតជំនាញថ្មីមិនអាចសម្រេចការងារនេះបានរហ័សទេ ពួកគេនឹងមិនអាចធ្វើឱ្យក្រុមហ៊ុនទទួលបានលទ្ធផលដូចការរំពឹងទុកឡើយ។ ក្រុមហ៊ុនដឹងច្បាស់ណាស់អំពីនិយោជិតណាដែលមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារ។ មិនយូរប៉ុន្មាន និយោជិតណាដែលមិនអភិវឌ្ឍការទទួលខុសត្រូវ និងជំនាញរបស់ខ្លួន គឺមិនមានតម្លៃល្អសម្រាប់ក្រុមហ៊ុនឡើយ ហើយនៅទីបំផុតកិច្ចសន្យាការងាររបស់ពួកគេគឺនឹងត្រូវបញ្ចប់។

មេរៀននៅក្នុងកថាខណ្ឌខាងលើ គឺនិយាយអំពីចំណុចសំខាន់នៃជំនាញសម្រាប់និយោជិតដែលបានបញ្ចប់ការសិក្សាកម្រិតសាកលវិទ្យាល័យ ហើយមានសមត្ថភាពវិភាគស្ថានភាពស្វែងយល់ និងចេះសិក្សាពីរបៀបសម្រេចចិត្តរបស់ក្រុមហ៊ុន ហើយក្លាយទៅជានិយោជិតមានទំនុកចិត្តដែលអាចសម្រេចផ្នែកនៃការងាររបស់ខ្លួន ដោយមិនចាំបាច់មានការចូលរួមដ៏លើសលប់ពីប្រធានក្រុមហ៊ុន។

ជំនាញក្នុងការវិភាគ ការគិត ការសម្រេចចិត្ត រួមទាំងជំនាញទំនាក់ទំនង និងជំនាញធម្មជាតិរបស់ “មនុស្ស” ដូចជាអាចស្តាប់ និងដោះស្រាយទំនាស់ផ្សេងៗត្រូវបានគេហៅថា បំណិនទន់ ហើយពួកគេនឹងទទួលបានការសាទរពីនិយោជកយ៉ាងខ្លាំង ដូចគ្នាទៅនឹងប្រភេទជំនាញផ្សេងទៀត ដែលពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយការងាររបស់ខ្លួនដែរ។ ជំនាញបច្ចេកទេសសម្រាប់ការងារដែលបានផ្តល់ បូករួមនឹងសមត្ថភាពនិយាយភាសាអង់គ្លេស និងការប្រើប្រាស់កុំព្យូទ័រ ហៅថា បំណិនរឹង  វាជាតម្រូវការមូលដ្ឋានសម្រាប់ការងារជាច្រើន ប៉ុន្តែវាអាចនឹងមិនគ្រប់គ្រាន់សម្រាប់និស្សិតដែលបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ ដោយមិនបានអភិវឌ្ឍបំណិនទន់ឡើយ។

ស្ទើរតែគ្រប់ការងារទាំងអស់ សម្រាប់អ្នកដែលបានឆ្លងកាត់កម្រិតសាកលវិទ្យាល័យ គឺយ៉ាងហោចណាស់ត្រូវមានជំនាញចេះប្រើកម្មវិធីកុំព្យូទ័រមូលដ្ឋានដូចជា កម្មវិធីវាយអត្ថបទ កម្មវិធីសៀវភៅបញ្ជី និងកម្មវិធីធ្វើបទបង្ហាញជាដើម រួមទាំងចេះប្រើអ៊ីនធឺណិតផងដែរ។ អ្នកជំនាញវិជ្ជាជីវៈពិតប្រាកដទាមទារឱ្យមានចំណេះដឹងការងារនៃកម្មវិធីនៅក្នុងផ្នែកនោះ ឧទាហរណ៍ដូចជាកម្មវិធីគណនេយ្យ សម្រាប់គណនេយ្យករ ឬកម្មវិធីរចនាសម្រាប់អ្នករចនា

ក្រាហ្វិក។ នៅក្នុងការងារភាគច្រើនគឺតម្រូវឱ្យនិយាយភាសាបរទេសមានដូចជា ភាសាអង់គ្លេស បារាំង ឬចិន ឬយ៉ាងហោចណាស់ក៏ចេះភាសាទំនាក់ទំនងគ្នាដែរ។ ទាំងនេះគឺជា បំណិនរឹង ដែលជួយឱ្យអ្នកងាយស្រួលក្នុងការស្វែងរកការងារដែលអ្នកចង់បាន ប៉ុន្តែវាមិនគ្រប់គ្រាន់ដើម្បីធ្វើឱ្យការងាររបស់អ្នកជោគជ័យទាំងស្រុងឡើយ គឺអ្នកចាំបាច់ត្រូវមាន បំណិនទន់ ផងដែរ។

បំណិនទន់ត្រូវបានអភិវឌ្ឍតាមរយៈការអនុវត្ត និងបទពិសោធន៍។ អ្នកអាចពង្រឹងបំណិនទន់របស់អ្នកបានដូចគ្នានឹងការពង្រឹងសាច់ដុំរបស់អ្នកអញ្ចឹងដែរ ដោយការធ្វើលំហាត់អនុវត្តយ៉ាងទៀងទាត់។ ឧទាហរណ៍ ប្រសិនបើអ្នកខ្លាចក្នុងការធ្វើបទបង្ហាញទៅកាន់អ្នកស្ដាប់ អ្នកនឹងអាចដោះស្រាយបញ្ហាខ្លាចនោះបាន ដោយការចាប់យកឱកាសនិយាយនៅទល់មុខក្រុមមនុស្ស អនុវត្តបែបនេះយូរទៅៗ អ្នកនឹងក្លាយទៅជាអ្នកនិយាយក្នុងទីសាធារណៈដ៏ល្អ ឬអាចឥតខ្ចោះទៀតផង។ ការសិក្សាស្រាវជ្រាវបង្ហាញថា និយោជកភាគច្រើនគឺតែងពិចារណាទៅបំណិនទន់សំខាន់ៗ ដូចជា៖

- មានអត្តចរិតវិជ្ជមាន
- មានជំនាញទំនាក់ទំនងផ្ទាល់មាត់ និងដោយលាយលក្ខណ៍អក្សរ
- មានភាពរហ័សរហួន រួសរាយរាក់ទាក់
- មានគំនិតច្នៃប្រឌិត
- មានជំនាញទំនាក់ទំនងបុគ្គល និងការងារជាក្រុម
- ចេះសម្របខ្លួនតាមកាលៈទេសៈ
- មានទម្លាប់រៀនមួយជីវិត
- មានភាពស្មោះត្រង់ក្រមសីលធម៌ការងារល្អ និងភាពជឿជាក់

ខណៈដែលនិស្សិតបញ្ចប់ការសិក្សាជាច្រើននៅធ្វើការក្នុងអាជីវកម្មគ្រួសារ ប៉ុន្តែពួកគេភាគច្រើនក៏នឹងត្រូវការស្វែងរកការងារនៅក្នុងក្រុមហ៊ុនផ្សេងទៀតដែរ។ ដើម្បីមានភាពវៃឆ្លាតក្នុងជម្រើសការងារ និស្សិតត្រូវយល់ដឹងអំពីប្រភេទការងារដែលពួកគេចង់ធ្វើនៅពេលបញ្ចប់ការសិក្សា ហើយស្វែងយល់អំពីទីផ្សារការងារដែលមានតម្រូវការខ្ពស់។ វគ្គសិក្សានេះនឹងផ្ដល់ឱ្យអ្នកនូវព័ត៌មានចាំបាច់ដើម្បីធ្វើការសម្រេចចិត្ត ប្រសិនបើអ្នកចង់ចាប់យកជំនាញព័ត៌មានវិទ្យា។



# ២. គន្លងការងារក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន

និស្សិតព័ត៌មានវិទ្យាមិនចាំបាច់សម្រេចចិត្តអំពីឯកទេសឡើយ នៅអំឡុងពីរឆ្នាំដំបូងនៃការសិក្សា។ នៅឆ្នាំទីមួយ ពួកគេនឹងសិក្សាអំពីមូលដ្ឋានគ្រឹះទូទៅ ហើយនៅឆ្នាំទីពីរពួកគេនឹងសិក្សាអំពីមូលដ្ឋានគ្រឹះនៃព័ត៌មានវិទ្យា។ ប៉ុន្តែទោះជាយ៉ាងណាពួកគេចាំបាច់ត្រូវតែគិតពិចារណានៅអំឡុងពីរឆ្នាំដំបូងនេះ ថាតើការងារព័ត៌មានវិទ្យាអ្វីដែលពួកគេចង់ចាប់យកបន្ទាប់ពីបញ្ចប់ការសិក្សា។ ពួកគេគួរតែប្រើប្រាស់ពេលវេលានៅសាកលវិទ្យាល័យ ក្នុងការទទួលបានបទពិសោធន៍គ្រប់គ្រាន់ ដើម្បីងាយស្រួលក្នុងការស្វែងរកការងារដំបូងនៅក្នុងជម្រើសជំនាញព័ត៌មានវិទ្យារបស់ខ្លួន។

ជំនាញព័ត៌មានវិទ្យាមិនអាចគ្រាន់តែទៅសាលារាល់ថ្ងៃ ហើយស្តាប់គ្រូបង្ហាត់ប៉ុណ្ណោះទេ ប៉ុន្តែពួកគេត្រូវពឹងផ្អែកលើការអនុវត្តម្តងហើយម្តងទៀត ដើម្បីទទួលបានចំណេះដឹងជំនាញច្បាស់លាស់។ ដោយផ្អែកលើជំនាញដែលពួកគេចង់ចាប់យក និស្សិតចាំបាច់ត្រូវរកឱកាសដើម្បីអនុវត្តបំណិនបច្ចេកទេសរបស់ខ្លួន ដើម្បីទទួលបានបំណិនទន់ ដែលមិនយូរប៉ុន្មាន ពួកគេនឹងអាចអនុវត្តនៅក្នុងការងារជាក់ស្តែងរបស់ខ្លួនបាន។

ចំណុចខុសគ្នាចាំបាច់ដែលនិយោជកត្រូវមើលឃើញគឺរវាងបេក្ខជនដែលគ្រាន់តែទៅសាលា ហើយប្រឡងជាប់ និងបេក្ខជនដែលបានអនុវត្ត បានចុះធ្វើកម្មសិក្សា ឬបានបញ្ចប់គម្រោងផ្ទាល់ខ្លួន។ សម្រាប់បេក្ខជនក្នុងឧទាហរណ៍ទីពីរគឺនឹងទទួលបានការងារច្រើនជាង។ ចំពោះអ្នកដែលមិនមានបទពិសោធន៍ចាំបាច់ត្រូវស្វែងរកបទពិសោធន៍ និងការបណ្តុះបណ្តាលសំខាន់ៗ ហើយអភិវឌ្ឍបំណិនទន់ នៅពេលពួកគេធ្វើការនៅក្នុងក្រុមហ៊ុន។ វានឹងត្រូវប្រើពេលវេលាច្រើនដើម្បីឱ្យពួកគេអាចបង្កើតបានការងារគ្រប់គ្រាន់ ឆ្លើយតបទៅនឹងតម្លៃប្រាក់បៀវត្សរ៍ដែលក្រុមហ៊ុននឹងផ្តល់ឱ្យពួកគេ ហើយក្រុមហ៊ុននឹងចាំបាច់ត្រូវរៀបចំបុគ្គលិកដើម្បីបណ្តុះបណ្តាល និងណែនាំ ដែលជាបន្ទុកចំណាយផ្សេងទៀតរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនចង់បានតែបេក្ខជនណាដែលមានបទពិសោធន៍ខ្លះហើយប៉ុណ្ណោះ សម្រាប់បេក្ខជនដែលមានការយល់ដឹងអំពីកន្លែងធ្វើការ គឺសក្តិសមនឹងត្រូវបានជួល ហើយទទួលប្រាក់បៀវត្សរ៍ប្រសើរនៅក្នុងការងារដំបូងរបស់ពួកគេទៀតផង។

នៅក្នុងសៀវភៅនេះអ្នកនឹងសិក្សាអំពីការងារមួយចំនួននៅក្នុងជំនាញបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ក៏ដូចជាជំនាញដែលត្រូវបានប្រើនៅក្នុងការងារនីមួយៗ។ អ្នកមិនចាំបាច់ចងចាំនូវអ្វីដែលត្រូវធ្វើក្នុងការងារទាំងនេះឡើយ ប៉ុន្តែអ្នកត្រូវតែយល់ប្រសិនបើអ្នកពិចារណាចាប់យកជំនាញបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។ សេចក្តីពណ៌នាសម្រាប់ការងារមួយចំនួនដែលអ្នកនឹងសិក្សានៅឆ្នាំនេះ គឺត្រូវបានផ្តល់ជូនដូចខាងក្រោម៖

**វិស្វករប្រព័ន្ធ និងបណ្តាញ** គឺជាអ្នកមើលថែកុំព្យូទ័រគ្រប់ប្រភេទទាំងអស់ ដែលបានប្រើប្រាស់នៅក្នុងស្ថាប័ន កុំព្យូទ័រដែលបានប្រើដោយបុគ្គលិកនីមួយៗ សំខាន់បំផុតនោះគឺម៉ាស៊ីនមេដែលផ្ទុកទិន្នន័យទាំងអស់របស់ស្ថាប័ន បណ្តាញទំនាក់ទំនងទាំងឡាយដែលតភ្ជាប់កុំព្យូទ័រទៅវិញទៅមក និងអ៊ីនធឺណិត។ វិស្វករកំណត់រចនាសម្ព័ន្ធកុំព្យូទ័រ និងបណ្តាញ ហើយពួកគេគឺជំនាញខាងប្រព័ន្ធប្រតិបត្តិការ និងសន្តិសុខ។ ពួកគេអភិវឌ្ឍជំនាញដោះស្រាយបញ្ហាបានល្អ ហើយអាចទប់ទល់នឹងបញ្ហាប្រឈមផ្សេងៗដែលកើតមានឡើងនៅពេលបំពេញការងារ ដែលទាមទារដំណោះស្រាយបាន។ មានអ្នកខ្លះចាប់ផ្តើមពីការងារជាអ្នកជំនួយការកុំព្យូទ័រ ហើយបន្ទាប់មកពួកគេអាចត្រូវបាន

ដំឡើងតួនាទីទៅជាវិស្វករបណ្ដាញ ឬប្រព័ន្ធ ហើយក្រោយមកទៀតពួកគេអាចនឹងក្លាយទៅជានាយកផ្នែកព័ត៌មានវិទ្យាសម្រាប់ក្រុមហ៊ុនដ៏ធំទៀតផង។

**អ្នកអភិវឌ្ឍកម្មវិធី** គឺជាអ្នកបង្កើតកម្មវិធីទាំងឡាយដែលមាននៅក្នុងកុំព្យូទ័រ ឬទូរសព្ទទំនើប។ ពួកគេសិក្សាពីតក្កវិជ្ជានៃការបែងចែកបញ្ហាទៅជាជំហានតូចៗ និងពីរបៀបបំប្លែងជំហានទាំងនោះទៅជាពាក្យបញ្ជា ដែលនឹងត្រូវបានផ្ដល់ទៅឱ្យកុំព្យូទ័រតាមរយៈភាសាកម្មវិធី។ អ្នកអភិវឌ្ឍកម្មវិធីអាចធ្វើការដោយខ្លួនឯងសម្រាប់កម្មវិធីតូចៗ ឬជាផ្នែកនៃក្រុមដែលជាកម្មវិធីធំៗសម្រាប់ប្រើនៅក្នុងស្ថាប័ន អង្គការ ឬសម្រាប់លក់នៅលើទីផ្សារសាធារណៈ។ អ្នកអភិវឌ្ឍកម្មវិធីមានជំនាញវិភាគច្បាស់លាស់ ហើយដឹងពីរបៀបបែងចែកភារកិច្ចស្មុគស្មាញទៅជាកិច្ចការតូចៗ ដែលអាចសម្រេចបានយ៉ាងងាយស្រួល។ ពួកគេចាប់ផ្ដើមជីវិតការងារជាអ្នកអភិវឌ្ឍកម្មវិធី បន្ទាប់ពីបានក្លាយជាអ្នកវិភាគកម្មវិធីដែលរៀបចំកំណត់កិច្ចការសម្រាប់អ្នកអភិវឌ្ឍកម្មវិធី បន្ទាប់មកទៀតពួកគេអាចនឹងក្លាយទៅជាអ្នកគ្រប់គ្រងគម្រោង ដែលទទួលខុសត្រូវសម្រាប់គម្រោងទាំងមូលសម្រាប់ក្រុមអ្នកអភិវឌ្ឍ និងអ្នកវិភាគ។



**អ្នករចនាក្រាហ្វិក** គឺជាអ្នកប្រើប្រាស់កុំព្យូទ័រដើម្បីបង្កើតសម្ភារៈ ឬមេខាអេឡិចត្រូនិកគ្រប់ប្រភេទសម្រាប់ការបោះពុម្ព រួមមានផ្នែកនៃក្រាហ្វិករបស់វេបសាយជាដើម។ ពួកគេអភិវឌ្ឍជំនាញនៃការស្ដាប់អតិថិជនដោយយកចិត្តទុកដាក់ ដើម្បីយល់អំពីអ្វីដែលអតិថិជនចង់បាន និងរបៀបកំណត់លក្ខណៈដែលអតិថិជននឹងចូលចិត្ត។ អ្នករចនាក្រាហ្វិកអភិវឌ្ឍជំនាញសោភ័ណភាព យល់អំពីពុម្ពអក្សរ ពណ៌ និងការបែងចែកវត្ថុនៅលើទំព័រ ដែលនឹងត្រូវបានប្រើដើម្បីបង្កើតភាពទាក់ទាញ។ ពួកគេក៏ជំនាញផងដែរទៅលើការប្រើប្រាស់ឧបករណ៍រចនានៅក្នុងកុំព្យូទ័រ ដែលឧបករណ៍ទាំងនោះត្រូវបានពួកគេប្រើវាដើម្បីអភិវឌ្ឍ និងបង្កើតក្រាហ្វិក។ ពួកគេចាប់ផ្ដើមការងាររបស់ខ្លួនជាអ្នករចនាក្រាហ្វិកមូលដ្ឋាន ហើយបន្ទាប់ពីទទួលបានបទពិសោធន៍ ពួកគេអាចនឹងក្លាយទៅជានាយកក្រុមហ៊ុនរចនា ឬអាចជាម្ចាស់ក្រុមហ៊ុនរចនាផ្ទាល់ខ្លួនទៀតផង។

**អ្នករចនាវេបសាយ** គឺជាអ្នកអភិវឌ្ឍវេបសាយដែលមានសោភ័ណភាពទាក់ទាញ ហើយពួកគេរៀបចំរចនាសម្ព័ន្ធ ដើម្បីបង្កភាពងាយស្រួលដល់អ្នកទស្សនាដើម្បីចូលដំណើរការ។ អ្នករចនាវេបសាយត្រូវតែយល់អំពីគោលការណ៍មូលដ្ឋានទាំងអស់នៃការរចនា ហើយអនុវត្តទៅលើទំព័ររបស់វេបសាយ។ អ្នករចនាវេបសាយត្រូវតែយល់ពីរបៀបដែលអ្នកទស្សនាប្រើប្រាស់វេបសាយ ហើយត្រូវតែបង្កើតការស្វែងរកសាមញ្ញ ធ្វើដូច្នោះអ្នកទស្សនានឹងនៅមើលវេបសាយបានយូរ ហើយនឹងត្រឡប់មកទស្សនាឡើងវិញនៅពេលអនាគត។ អ្នករចនាវេបសាយចាំបាច់ត្រូវដឹងពីរបៀបកំណត់រចនាសម្ព័ន្ធព័ត៌មាន ដោយផ្អែកលើអាទិភាពរបស់ស្ថាប័ន និងទៅលើអ្វីដែលត្រូវបានផ្ដល់ជូនសម្រាប់អ្នកទស្សនា។ នៅពេលដំបូង ពួកគេចាប់ផ្ដើមការងារជាអ្នករចនាវេបសាយធម្មតា ហើយនៅពេលទទួលបានបទពិសោធន៍ជាអ្នករចនាវេបសាយ ពួកគេអាចនឹងក្លាយទៅជាអ្នកគ្រប់គ្រងគម្រោងសម្រាប់វេបសាយដ៏ធំ ដែលមានម៉ាស៊ីនស្វែងរក បណ្ដាញសង្គម ឬពួកគេអាចនឹងចាប់ផ្ដើមក្រុមហ៊ុនផ្ទាល់ខ្លួន។

**អ្នកជំនាញបណ្ដាញសង្គម** គឺជាជំនាញដែលទើបបានបង្កើតថ្មីនៅក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។ បណ្ដាញសង្គមបាននាំមកនូវវិធីសាស្ត្រ ផ្លាស់ប្ដូរថ្មីៗជាច្រើនសម្រាប់ការធ្វើជំនួញ។ នៅពេលដែលទំព័របណ្ដាញសង្គមទាក់ទាញអ្នកទស្សនាបានច្រើន វានឹងក្លាយទៅជាឧបករណ៍ដ៏មានប្រសិទ្ធភាពសម្រាប់ក្រុមហ៊ុន ដើម្បីផ្សាយពាណិជ្ជកម្មអំពីផលិតផលរបស់ខ្លួន មានទាំងការផ្សាយពាណិជ្ជកម្មធម្មតា ឬតាមរយៈវិធីសាស្ត្រវិស្វកម្មសង្គម ការបង្ហាញផលិតផលជំនួសឱ្យការផ្សាយពាណិជ្ជកម្មតាមរបៀបបុរាណ។ អ្នកជំនាញបណ្ដាញសង្គមដឹងពីឥរិយាបថរបស់អ្នកប្រើបណ្ដាញសង្គម និងដឹងពីរបៀបទាក់ទាញពួកគេចំពោះទំព័រ។ ការងារមូលដ្ឋានមួយនៅក្នុងផ្នែកនេះ គឺការធ្វើជាអ្នកគ្រប់គ្រងកំណត់ហេតុបណ្ដាញ ខណៈដែលអ្នកជំនាញសរសេរអត្ថបទជាអ្នកគ្រប់គ្រងតំបន់បណ្ដាញពិភាក្សា (កំណត់ហេតុបណ្ដាញ) សម្រាប់ក្រុមហ៊ុន ឬអង្គការដើម្បីផ្ដល់ព័ត៌មានសំខាន់ៗទៅដល់អតិថិជនរបស់ក្រុមហ៊ុន។ អ្នកតំណាងផ្នែកទីផ្សារបណ្ដាញសង្គមជំរុញផ្សព្វផ្សាយផលិតផលរបស់ក្រុមហ៊ុននៅលើបណ្ដាញសង្គម ហើយស្វែងរកឱកាសដើម្បីអភិវឌ្ឍអាជីវកម្មរបស់ក្រុមហ៊ុន។ ពេលពួកគេមានបទពិសោធន៍គ្រប់គ្រាន់ អ្នកតំណាងទីផ្សារអាចនឹងក្លាយទៅជាអ្នកគ្រប់គ្រងទីផ្សារបណ្ដាញសង្គម។




**គ្រូបង្រៀន** បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ គឺជាមនុស្សដែលចាំបាច់ទាំងនៅក្នុងស្ថាប័នរដ្ឋ និងឯកជន។ មានមុខតំណែងជាច្រើនត្រូវបានបើកចំហនៅតាមសាកលវិទ្យាល័យ និងមជ្ឈមណ្ឌលបណ្ដុះបណ្ដាលជំនាញព័ត៌មានវិទ្យា ក៏ដូចជានៅតាមសាលាមធ្យមសិក្សាឯកជននិងសាធារណៈ។ បន្ទាប់ពីទទួលបានកម្រិតបរិញ្ញាបត្រផ្នែកព័ត៌មានវិទ្យា គណិតវិទ្យា ឬរូបវិទ្យារួចមក ពួកគេអាចដាក់ពាក្យទៅកាន់វិទ្យាស្ថានជាតិអប់រំដើម្បីប្រឡងជ្រើសរើសគរុនិស្សិត ហើយសម្រាប់បេក្ខជនដែលបានជ្រើសរើស នឹងត្រូវសិក្សាមួយឆ្នាំបន្ថែមទៀតដើម្បីក្លាយជាគ្រូបង្រៀនមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍នៅថ្នាក់វិទ្យាល័យ។ គរុនិស្សិតផ្ដោតការសិក្សាទៅលើវិធីសាស្ត្របង្រៀន ហើយពួកគេនឹងរៀនជាពិសេសទៅលើវិធីសាស្ត្របង្រៀនមុខវិជ្ជាព័ត៌មានវិទ្យាសម្រាប់ថ្នាកទី១១ និងថ្នាក់ទី១២។ គ្រូចាំបាច់ត្រូវស្វែងយល់ និងអនុវត្តគរុកោសល្យ សិល្បៈ និងវិទ្យាសាស្ត្រដើម្បីឱ្យប្រាកដពីអ្វីដែលសិស្សនឹងសិក្សា និងអ្វីដែលគ្រូត្រូវបង្រៀន។

**អ្នកលក់គ្រឿងសម្ភារកុំព្យូទ័រ** គឺជាអ្នកធ្វើការសម្រាប់អាជីវកម្ម ឬក្រុមហ៊ុនធំៗដែលលក់ និងជួសជុលកុំព្យូទ័រ។ ការលក់កុំព្យូទ័រទាមទារឱ្យអ្នកលក់មានចំណេះដឹងខ្ពស់ចំពោះផ្នែកផ្សេងៗរបស់កុំព្យូទ័រ ក៏ដូចជាត្រូវដឹងផងដែរអំពីការប្រើប្រាស់ផ្នែកទាំងនោះដើម្បីផ្គុំបង្កើតកុំព្យូទ័រ ឱ្យត្រូវតាមតម្រូវការរបស់អតិថិជន។ ក្នុងករណីខ្លះ ការងារជាអ្នកលក់ ឬអ្នកបច្ចេកទេសចាំបាច់ត្រូវដំឡើងកុំព្យូទ័រដែលមានល្បឿនលឿន ខណៈដែលការងារផ្សេងទៀតទាមទារតម្រូវការសាមញ្ញជាងនោះ ហើយករណីខ្លះទៀតកុំព្យូទ័រចាំបាច់ត្រូវដំឡើងសម្រាប់ភារកិច្ចជាក់លាក់ ដោយមានគ្រឿងដំឡើងពិសេសៗ ឬល្អៗ។ បុគ្គលិកលក់ត្រូវតែចេះបញ្ចុះបញ្ចូលអតិថិជន ដើម្បីឱ្យទិញផលិតផលកុំព្យូទ័រពីក្រុមហ៊ុនរបស់ពួកគេ។ ការសិក្សាពីរបៀបលក់គឺជាបំណិនទន់ ដូចជាអ្នកលក់ត្រូវតែបង្កើតភាពទុកចិត្តជាមួយអ្នកទិញ។ ក្រុមហ៊ុនកុំព្យូទ័រក៏មានអ្នកបច្ចេកទេសជួសជុលកុំព្យូទ័រផងដែរ ដែលពួកគេជាអ្នកដំឡើង ឬជួសជុលកុំព្យូទ័រសម្រាប់អតិជន។ ពួកគេស្ទាត់ជំនាញខាងការដោះដូរ និងជួសជុលទាំងបញ្ហាផ្នែករឹង ផ្នែកទន់ដែលកើតមាននៅក្នុងកុំព្យូទ័រ។ ដែលទទួលបាន

បទពិសោធន៍ច្រើន អាចនឹងបើកហាងលក់កុំព្យូទ័រផ្ទាល់ខ្លួន ដែលការនេះពួកគេនឹងត្រូវដឹងពីរបៀបនាំចូល និងការទិញកុំព្យូទ័រ ហើយពួកគេក៏ត្រូវមានដើមទុនសម្រាប់ចាប់ផ្តើមជំនួញផងដែរ។

បច្ចេកវិទ្យាបានរីកចម្រើនយ៉ាងឆាប់រហ័ស ដែលវាពិបាកក្នុងការទប់បច្ចុប្បន្នភាពជាមួយការផ្លាស់ប្តូរ នៃឱកាសការងារ ក៏ដូចជាផលិតផលដែលបានអភិវឌ្ឍ។ កុំព្យូទ័រត្រូវបានផ្តល់ជូនក្នុងទំហំកាន់តែតូចទៅៗ រហូតដល់ចំណុចមួយដែលថាទូរសព្ទទំនើបបច្ចុប្បន្ន គឺជាកុំព្យូទ័រតូចដែលមានសមត្ថភាពស្រដៀងគ្នាទៅនឹងកុំព្យូទ័រលើតុដែរ។ តើនឹងមានអ្វីកើតឡើងជាបន្តទៀត? ប៉ុន្តែយើងដឹងច្បាស់ណាស់ថាវានឹងមានការអភិវឌ្ឍថ្មីជារៀងរាល់ឆ្នាំ។ យើងមានទូរសព្ទទំនើបដែលស្តើងបំផុត មានកម្មវិធីកម្សាន្តថ្មីៗ មានម៉ាស៊ីនបោះពុម្ពត្រីមាត្រ (3-D) គ្រូពេទ្យ មនុស្សយន្ត ឧបករណ៍លេងហ្គេមទំនើបៗ និងការបង្កើតថ្មីជាច្រើនដែលយើងមិនទាន់ដឹងនៅឡើយ ហើយមានខ្លះទៀតយើងមិនដែលដឹងសូម្បីតែគិតថាវាអាចកើតមានផង។ ការផ្លាស់ប្តូរដ៏ធំបំផុតនឹងចេញមកពីការកើនឡើងនៃការចូលប្រើព័ត៌មាន ដែលត្រូវបានគាំទ្រដោយអ៊ីនធឺណិតល្បឿនលឿន។ តើអ្នកត្រៀមខ្លួនរួចរាល់ហើយឬ សម្រាប់ទីផ្សារការងារនៅកម្ពុជាក្នុងសម័យកាលបច្ចេកវិទ្យានេះ?

# មេរៀនសង្ខេប

សិស្សទាំងអស់ត្រូវតែយកចិត្តទុកដាក់ក្នុងការសម្រេចចិត្ត អំពីការងារដែលពួកគេចង់ធ្វើនៅពេលអនាគត ក៏ដូចជាមុខជំនាញត្រូវសិក្សាដែរ បន្ទាប់ពីបញ្ចប់ថ្នាក់ទី១២។ ដើម្បីទទួលបានការសម្រេចចិត្តល្អ សិស្សចាំបាច់ត្រូវមានព័ត៌មានច្បាស់លាស់អំពីប្រភេទការងារ និងតម្រូវការការងារនាពេលអនាគត។ ដោយការអនុវត្តតាមមេរៀននេះ សិស្សនឹងអាចវាយតម្លៃបាន ប្រសិនបើពួកគេចង់ចាប់យកជំនាញដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។

នៅពេលសិក្សា សិស្សនឹងទទួលបាននូវការបណ្តុះបណ្តាលបច្ចេកទេសសម្រាប់ផ្នែកនៃការងាររបស់ខ្លួន។ ចំណេះដឹងនេះគឺមានសារៈសំខាន់ណាស់សម្រាប់ការងាររបស់ពួកគេ ប៉ុន្តែពួកគេក៏ត្រូវមានសមត្ថភាពពិតប្រាកដផងដែរ គឺបំណិនទន់ដែលត្រូវបានឱ្យតម្លៃខ្ពស់ដោយនិយោជក។ សមត្ថភាពទាំងនេះរួមមាន ការស្វែងយល់ភ្លាមៗទៅលើបរិស្ថានការងារ ការធ្វើការងារដោយម្ចាស់ការខ្លួនឯង ការមានគំនិតច្នៃប្រឌិត ភាពរហ័សរហួនរួសរាយរាក់ទាក់ មានទំនាក់ទំនងល្អ និងមានអត្តចរិតវិជ្ជមានចំពោះការងារ និងមិត្តរួមការងារ។

បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍មិនមែនជាការងារទោលឡើយ។ មានការងារពាក់ព័ន្ធផ្សេងទៀតជាច្រើនដែលត្រូវបានស្ថិតនៅក្នុងវិស័យនេះ។ ការងារនីមួយៗគឺមានចរិតលក្ខណៈផ្ទាល់ខ្លួនរបស់វាដូចជា បរិស្ថានការងារ បច្ចេកទេស និងបំណិនទន់។ ពេលសិក្សាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សិស្សចាំបាច់ត្រូវដឹងអំពីកិច្ចការទាំងអស់នោះ ហើយសម្រេចចិត្តអំពីការងារណាមួយដែលពួកគេចង់ធ្វើ។

# គោលការណ៍ណែនាំអំពីលំហាត់

## សេចក្តីណែនាំសម្រាប់លំហាត់នៅក្នុងមេរៀននេះ៖

អ្នកនឹងធ្វើការជាក្រុមជាមួយសិស្សផ្សេងទៀតនៅលើកុំព្យូទ័រមួយ។ ឈ្មោះរបស់ក្រុមគឺជានាមត្រកូលរបស់សមាជិកនីមួយៗ ដែលបំបែកដោយសញ្ញាដក ("-")។ ឧទាហរណ៍ ប្រសិនបើនាមត្រកូលរបស់សមាជិកនៅក្នុងក្រុមរបស់អ្នកមានឈ្មោះ ហេង, ផេង និងស៊ុន ដូច្នេះឈ្មោះក្រុមរបស់អ្នកគឺ "ហេង-ផេង-ស៊ុន" ។

ឥឡូវចូរបើកថតផ្ទៃតុរបស់អ្នក រួចបង្កើតថតថ្មីនៅក្នុងនោះដោយដាក់ឈ្មោះក្រុមរបស់អ្នក។ យើងនឹងហៅឈ្មោះថតនេះថាជា ថតក្រុម ហើយវានឹងត្រូវបានប្រើសម្រាប់វគ្គសិក្សានេះ ដើម្បីផ្ទុកនូវលទ្ធផលលំហាត់ទាំងអស់របស់អ្នក។

បន្ទាប់មកទៀត ពិភាក្សាសំណួរដែលបានសួរនៅក្នុងលំហាត់ រួចវាយចម្លើយរបស់អ្នកនៅក្នុងឯកសារ OpenOffice ដែលមានឈ្មោះថា លំ1.1 ដោយរក្សាទុកឯកសារនៅក្នុងថតក្រុមរបស់អ្នក រួចបិទថតផ្ទៃតុរបស់អ្នក។ អ្នកនឹងធ្វើដូចគ្នានេះសម្រាប់លំហាត់លើកក្រោយទៀត ដែលនឹងត្រូវបានរក្សាទុកនៅក្នុងថតក្រុមរបស់អ្នក។

## លំហាត់

### លំហាត់ ១

នៅក្នុងក្រុមរបស់អ្នក ពិភាក្សាអំពីការងារបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដែលបានបង្ហាញនៅក្នុងមេរៀននេះ។ ប្រើពេលប្រាំនាទីដើម្បីកំណត់អំពីបំណិនរឹង និងបំណិនទន់ដែលចាំបាច់សម្រាប់ការងារនីមួយៗ។ បង្កើតបញ្ជីមួយសម្រាប់បំណិនរឹង និងបញ្ជីមួយទៀតសម្រាប់បំណិនទន់។ វាយបញ្ចូលបញ្ជីទៅក្នុងឯកសារ លំ1.1 ។ កុំភ្លេចរក្សាទុកឯកសារនេះ។

## សំណួរត្រិះរិះ

១. តើវត្ថុបំណងសំខាន់នៃមេរៀននេះមានអ្វីខ្លះ?
២. តើនរណាជាអ្នកសម្រេចចិត្តក្នុងជ្រើសរើសជំនាញសិក្សានៅសាកលវិទ្យាល័យសម្រាប់អ្នក?
៣. តើអ្នកគួរតែធ្វើការសម្រេចចិត្តអំពីជំនាញដែលត្រូវសិក្សាដោយផ្អែកកត្តាអ្វីខ្លះ?
៤. តើជំនាញអ្វីខ្លះដែលនិយោជកចង់បានសម្រាប់និយោជិតរបស់ខ្លួន?
៥. តើប្រភេទការងារអ្វីខ្លះដែលផ្តល់នូវឱកាសល្អបំផុតសម្រាប់ការស្វែងរកការងារនៅពេលអនាគត?

# ផ្នែក ខ - ការប្រើប្រាស់បច្ចេកវិទ្យាឲ្យបានត្រឹមត្រូវ

## ៣. អ៊ីនធឺណិត

អ៊ីនធឺណិតគឺជាបណ្ដាញកុំព្យូទ័ររាប់សិបលានគ្រឿង ដែលបានតភ្ជាប់គ្នានៅជុំវិញពិភពលោក។ អ្នកប្រើប្រាស់អ៊ីនធឺណិតផ្ទុកព័ត៌មាននៅក្នុងកុំព្យូទ័រទាំងនោះ ហើយចែករំលែកវានៅពាសពេញពិភពលោក។ សេចក្ដីណែនាំអំពីអ៊ីនធឺណិត និងការរីកចម្រើនយ៉ាងឆាប់រហ័សរបស់វា គឺជាមូលដ្ឋានសម្រាប់ការផ្លាស់ប្ដូរសង្គមដ៏ចាំបាច់ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។

អ្នកដែលបានតភ្ជាប់អ៊ីនធឺណិត គឺអាចចូលមើលព័ត៌មានទាំងឡាយដែលបានដាក់ជាសាធារណៈ ជាហេតុធ្វើឱ្យអ៊ីនធឺណិតក្លាយទៅជាឧបករណ៍ដ៏មានឥទ្ធិពលបំផុតសម្រាប់ទំនាក់ទំនង និងជាឃ្លាំងផ្ទុកព័ត៌មានធំបំផុតដែលពុំធ្លាប់មាន។ អ៊ីនធឺណិតបានជួយសម្រួលដល់ការធ្វើពាណិជ្ជកម្ម ការសិក្សាអប់រំ និងប្រភេទទំនាក់ទំនងផ្សេងទៀត ដោយផ្ដល់នូវការចូលដំណើរការព័ត៌មានភ្លាមៗ ដែលកាលពីជិតម្ភៃឆ្នាំមុនត្រូវប្រើពេលយ៉ាងយូរទើបអាចរកបានព័ត៌មានដូចគ្នានោះ។ ការផ្សំបញ្ចូលគ្នានូវសេវាកម្មទាំងនេះ បានធ្វើឱ្យអ៊ីនធឺណិតក្លាយជាផ្នែកដ៏សំខាន់បំផុតសម្រាប់មនុស្ស និងបរិស្ថានការងារបច្ចុប្បន្ន។

សេវាកម្មចម្បងដែលអនុញ្ញាតឱ្យអ្នកប្រើអាចផ្ទុក និងស្វែងរកព័ត៌មាននៅលើអ៊ីនធឺណិតបានមានឈ្មោះថា World Wide Web (www) ។ វេបផ្សំឡើងពីបណ្ដុំព័ត៌មានផ្សេងគ្នាជាច្រើនហៅថាវេបសាយ។ វេបសាយ នីមួយៗត្រូវបានបង្កើតឡើងដោយបុគ្គល ឬស្ថាប័ន ហើយវាត្រូវបានរៀបរចនាសម្ព័ន្ធជាទំព័រ ហើយទំព័រនេះគឺជាផ្នែកសម្រាប់ផ្ទុកព័ត៌មានអំពីប្រធានបទជាក់លាក់។ វេបសាយ អាចមានទំព័រមួយ ឬច្រើន ហើយព័ត៌មានគឺផ្ទុកនៅលើទំព័រផ្សេងគ្នានៃវេបសាយដែលពាក់ព័ន្ធ ព្រោះព័ត៌មានទាំងអស់នោះត្រូវបានបោះពុម្ពផ្សាយដោយមនុស្ស ឬស្ថាប័នតែមួយ។ តាមរយៈវេបសាយ និងទំព័រទាំងនេះ អ៊ីនធឺណិតគឺជាអ្នកសម្រួលដល់ការចូលប្រើព័ត៌មាន ដែលបានចូលរួមដោយមនុស្ស អង្គការ-ស្ថាប័ន ឬក្រុមហ៊ុនផ្សេងៗ។ ព័ត៌មានដែលបានបញ្ចូលនៅលើវេបសាយទាំងនេះ គឺគ្របដណ្ដប់ទៅលើទស្សនៈស្ទើរតែទាំងអស់នៃចំណេះដឹងរបស់មនុស្ស ហើយវាត្រូវបានចូលប្រើយ៉ាងងាយស្រួលចេញពីកុំព្យូទ័រដែលបានតភ្ជាប់អ៊ីនធឺណិត ដោយប្រើខ្សែបណ្ដាញវ៉ាយហ្វាយ ឬបណ្ដាញទូរសព្ទចល័ត។ ពេលមនុស្សចូលប្រើអ៊ីនធឺណិតកុំព្យូទ័ររបស់ពួកគេក្លាយទៅជាបង្អួចមួយដែលបង្ហាញអំពីព័ត៌មាន និងទំនាក់ទំនងនៅទូទាំងពិភពលោក។



# ៤. ភាពត្រឹមត្រូវ ការត្រិះរិះគិត និងសេរីភាពបញ្ចេញមតិ

នៅពេលអ៊ីនធឺណិតផ្ទុកនូវព័ត៌មានត្រឹមត្រូវពិតប្រាកដក្នុងចំនួនដ៏ច្រើន ដែលបានបញ្ចូលដោយបុគ្គល ឬក្រុមហ៊ុនដែលចាប់អារម្មណ៍ពិតប្រាកដក្នុងការចែករំលែកទិន្នន័យនោះ វាក៏បានរួមបញ្ចូលផងដែរនូវគំនិតយោបល់ជាច្រើនដែលអាចទុកចិត្តបានថាជាព័ត៌មានពិតចេញពីអ្នកផ្សព្វផ្សាយ។ គំនិតយោបល់ជាព័ត៌មានត្រូវបានដាក់នៅលើអ៊ីនធឺណិត ដោយមនុស្សដែលមានជំនឿផ្ទាល់ខ្លួន ហើយជានិច្ចកាលមិនត្រូវបានចែករំលែកដោយអ្នកផ្សេងឡើយ។

ជាឧទាហរណ៍ មនុស្សជុំវិញពិភពលោកមានជំនឿសាសនាខុសៗគ្នា ហើយពួកគេជឿថាមានតែសាសនារបស់ពួកគេប៉ុណ្ណោះ ដែលជាសាសនាត្រឹមត្រូវ។ ពួកគេផ្សព្វផ្សាយព័ត៌មាននៅលើអ៊ីនធឺណិតដោយជឿជាក់ថាវាត្រឹមត្រូវ ប៉ុន្តែសម្រាប់មនុស្សដែលមានជំនឿសាសនាផ្សេង ឬមិនជឿសាសនាណាមួយនោះ នឹងគិតថាព័ត៌មាននេះគឺមិនត្រឹមត្រូវ។ ដូចគ្នាដែរចំពោះមនុស្សដែលមាននិន្នាការនយោបាយផ្សេងគ្នា គឺគេនឹងផ្សព្វផ្សាយព័ត៌មានដែលឆ្លុះបញ្ចាំងពីទស្សនៈរបស់ពួកគេចំពោះពិភពលោក ឬប្រទេសរបស់ពួកគេទៅតាមតែការយល់ឃើញរៀងៗខ្លួន។ សូម្បីតែពេលនិយាយពីរឿងវិទ្យាសាស្ត្រ មិនមែនមនុស្សទាំងអស់គ្នាសុទ្ធតែយល់ព្រមជាមួយទ្រឹស្តី ឬទស្សនៈណាមួយឡើយ។ ព័ត៌មានដែលបានផ្សព្វផ្សាយអំពីជំងឺដោយវេជ្ជបណ្ឌិតនៅអឺរ៉ុប គឺត្រូវទៅនឹងរោគសញ្ញាជាក់លាក់ដែលអាចមិនត្រឹមត្រូវសម្រាប់ប្រទេសកម្ពុជា ព្រោះដោយសារកត្តាតំបន់ភូមិសាស្ត្រនាំឱ្យវាបង្កើតជារោគសញ្ញាខុសៗគ្នា។



សូម្បីព័ត៌មានដែលដូចគ្នាបេះបិទ ក៏អាចត្រូវបានគេផ្សព្វផ្សាយ ឬយកមកបង្ហាញតាមបែបផ្សេងៗ ក្នុងគោលបំណងបង្កើតអារម្មណ៍ជាក់លាក់ដល់អ្នកអានព័ត៌មាននោះ។ ឧទាហរណ៍ នៅក្នុងព្រឹត្តិការណ៍មួយដែលគេដឹងឮថាមានអ្នកចូលរួម១០០នាក់ក្នុងក្រុមមួយ ប្រសិនបើអ្នកសរសេរចង់ផ្តល់ការចាប់អារម្មណ៍ថាមានតែមនុស្សពីរបីនាក់ចូលរួម នោះគាត់អាចនឹងសរសេរថា "មានមនុស្សមួយក្រុមតូចប្រមាណមិនដល់ ១០០ នាក់ទេ ដែលបានបង្ហាញវត្តមានចូលរួម"។ ផ្ទុយទៅវិញ ប្រសិនបើអ្នកសរសេរចង់បង្ហាញថាមានមនុស្សច្រើននាក់ចាប់អារម្មណ៍ក្នុងព្រឹត្តិការណ៍នោះ គេនឹងសរសេរថា "មានមនុស្សជាច្រើនបានបង្ហាញវត្តមានចូលរួម ហើយបន្ទប់ពោរពេញទៅដោយអ្នកចូលរួមយ៉ាងហោចណាស់ដល់ទៅ ១០០ នាក់ឯណោះ"។

នេះជាមូលហេតុដែលសៀវភៅសិក្សាគឺខុសពីព័ត៌មានលើបណ្តាញអ៊ីនធឺណិត វាត្រូវបានគេរំពឹងទុកដើម្បីបង្ហាញនូវព័ត៌មានពិតប្រាកដអំពីគំនិតយោបល់។ អ្នកប្រើប្រាស់អ៊ីនធឺណិតត្រូវតែពិនិត្យមើលព័ត៌មានទាំងអស់ដែលពួកគេអានប្រកបដោយការវិនិច្ឆ័យ ដោយធ្វើការស្វែងយល់ថាតើព័ត៌មានដែលពួកគេអាន ឆ្លុះបញ្ចាំងពីការពិត ឬគ្រាន់តែជាទស្សនៈរបស់បុគ្គលម្នាក់។ ដើម្បីធ្វើដូច្នេះបាន ដំបូងអ្នកត្រូវស្វែងរកប្រភពនៃព័ត៌មាន ថាតើអ្នកណាជាអ្នកផ្សព្វផ្សាយព័ត៌មាននោះ ហើយអ្វីជាគោលបំណងរបស់អ្នកផ្សព្វផ្សាយ ដើម្បីស្វែងយល់ថាតើព័ត៌មាននោះជាការប្រមូលផ្តុំនៃព្រឹត្តិការណ៍ជាក់ស្តែង ឬគ្រាន់តែជាការសម្តែងទស្សនៈយល់ឃើញរបស់បុគ្គល ឬជាការបកស្រាយព្រឹត្តិការណ៍ជាក់ស្តែង។ អ្នកប្រើអ៊ីនធឺណិតដែលមានបទពិសោធន៍ច្រើន តែងតែមើលប្រភពនៃព័ត៌មានផ្សេងៗនៅលើអ៊ីនធឺណិត ដែលជាព័ត៌មាន

ស្រដៀងគ្នា ហើយធ្វើការប្រៀបធៀប និងបង្កើតការយល់ឃើញផ្ទាល់ខ្លួនរបស់ពួកគេ នូវអ្វីដែលជាភាពពិតប្រាកដនៃព័ត៌មាននោះ។ ដំណើរការនេះត្រូវបានគេហៅថា ការបញ្ជាក់សុក្រឹតភាព ដែលមានន័យថាជាការកំណត់កម្រិតលម្អៀងនៃព័ត៌មាន។

វេបសាយនៅលើអ៊ីនធឺណិតភាគច្រើនផ្ទុកនូវព័ត៌មានដែលផ្សព្វផ្សាយដោយស្ថាប័នឯកជន ឬអង្គការព័ត៌មានទាំងនេះមិនត្រូវបានបញ្ជាក់ ឬពិនិត្យដោយមនុស្សផ្សេងទៀតឡើយ។ វេបសាយផ្សេងទៀតដូចជាសព្វវចនាធិប្បាយវិគីភីឌា (Wikipedia ) គឺអនុញ្ញាតឱ្យមនុស្សជាច្រើនចូលទៅធ្វើការនៅលើផ្នែកដូចគ្នានៃព័ត៌មាន ហើយមានអ្នកកែសម្រួលដើម្បីកំណត់អំពីទំនុកចិត្តនៃព័ត៌មាន និងធ្វើឱ្យប្រាកដថាព័ត៌មានគឺមានសុវត្ថិភាព។ ទោះបីជាដូច្នេះក្តី ព័ត៌មាននៅលើវិគីភីឌាមិនសុទ្ធតែមានសុក្រឹតភាពទាំងអស់ឡើយ។ វិគីភីឌាអនុញ្ញាតឱ្យអ្នកប្រើពិនិត្យមើលថាតើមានមនុស្សខុសគ្នាប៉ុន្មាននាក់ ដែលបានធ្វើការទៅលើផ្នែកនៃព័ត៌មានដែលបានផ្តល់ ហើយធ្វើឱ្យអ្នកប្រើអាចដឹងពីកម្រិតដែលអាចទុកចិត្តបាននៃព័ត៌មាននោះ។

អ្នកប្រើប្រាស់អ៊ីនធឺណិតត្រូវតែអភិវឌ្ឍវិធីសាស្ត្ររបស់ខ្លួន ក្នុងការកំណត់សុក្រឹតភាពព័ត៌មាននៅលើអ៊ីនធឺណិត ដើម្បីដឹងថាវាជាព័ត៌មានពិត ឬក្លែងក្លាយ។ ក្រៅពីការពិនិត្យប្រភពរបស់វា ពួកគេត្រូវតែប្រើគំនិត និងការពិចារណារបស់ខ្លួនដើម្បីស្វែងយល់នូវអ្វីដែលអាចកើតឡើងពិតប្រាកដ និងអ្វីដែលពិតជាមិនអាចកើតឡើង ឬមិនមែនជាការពិត។

> និយាយរួមគឺត្រូវពិនិត្យទៅលើគោលបំណងនៃប្រភពព័ត៌មានរបស់អ្នក រួចប្រើចំណេះដឹង និងសមត្ថភាពវិភាគរបស់ខ្លួន មុនពេលទទួលយកព័ត៌មាននោះថាពិត។

# ៤.១. សេរីភាពបញ្ចេញមតិ

រដ្ឋធម្មនុញ្ញនៃប្រទេសប្រជាធិបតេយ្យមួយចំនួន មានដូចជាប្រទេសកម្ពុជា ត្រូវបានចាត់ទុកថាជាប្រទេសដែលប្រជាពលរដ្ឋអាចមានសិទ្ធិបញ្ចេញមតិយោបល់របស់ខ្លួន ហើយវាជាសិទ្ធិមូលដ្ឋានដែលមិនអាចបដិសេធបាន។ យើងមានសេរីភាពក្នុងការបញ្ចេញមតិយោបល់ទាំងនៅក្នុងរឿងនយោបាយ និងសាសនា ក៏ដូចជាមតិយោបល់អំពីរឿងផ្សេងទៀតតាមរយៈការនិយាយស្តី ការសរសេរលិខិត ឬតាមរយៈអ៊ីនធឺណិត។ សិទ្ធិនេះត្រូវបានដាក់កម្រិតដោយសិទ្ធិពីរផ្សេងទៀតដែលប្រជាពលរដ្ឋទាំងអស់មានគឺៈ សិទ្ធិក្នុងការមិននិយាយកុហកដែលនាំឱ្យខូចកេរ្តិ៍ឈ្មោះ និងសិទ្ធិមិនប្រមាថមើលងាយ។ សិទ្ធិទាំងពីរនេះត្រូវបានការពារដោយច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ហើយនឹងត្រូវផ្តន្ទាទោសប្រសិនបើប្រព្រឹត្តល្មើសនឹងច្បាប់នេះ។ ការដាក់កម្រិតក៏អនុវត្តផងដែរចំពោះការកុហក ឬការប្រមាថមើលងាយដែលនាំឱ្យខូចកេរ្តិ៍ឈ្មោះស្ថាប័ន។

សិទ្ធិបញ្ចេញមតិយោបល់ត្រូវបានគេស្គាល់ថាជា សេរីភាពក្នុងការបញ្ចេញមតិ ។ វាគឺចាំបាច់ណាស់ក្នុងការដឹងនូវអ្វីដែលអនុញ្ញាតសម្រាប់ការបញ្ចេញមតិយោបល់ និងអ្វីដែលអាចក្លាយទៅជាការបំពានសិទ្ធិអ្នកដទៃ ការការពាររូបរាង និងកិត្តិយសផ្ទាល់ខ្លួនរបស់ពួកគេ។

វាពិតជាអាចធ្វើបាន នៅពេលដែលមនុស្សម្នាក់ចង់បញ្ចេញទស្សនៈយោបល់របស់ខ្លួន អំពីសកម្មភាពគណបក្សនយោបាយ ឬរដ្ឋាភិបាល ការបង្ហាញជំនឿរបស់ខ្លួនអំពីអ្វីដែលបានធ្វើថាតើត្រូវ ឬមិនត្រឹមត្រូវនោះ។ ទោះជាយ៉ាងណា ការចោទប្រកាន់ដោយផ្ទាល់ទៅលើបុគ្គល ឬស្ថាប័នអំពីរឿងអ្វីមួយថាជាបទល្មើសនាំឱ្យមានទោស លុះត្រាតែយើងមានភស្តុតាងផ្ទាល់ភ្នែក។ ឧទាហរណ៍យើងអាចនិយាយថាអ្វីមួយមិនល្អ ឬប្រាប់ដល់មនុស្សថាគួរ ឬមិនគួរធ្វើនូវអ្វីដែលយើងគិត ទាំងនេះជាគំនិតយោបល់របស់

*អ្នកប្រើប្រាស់អ៊ីនធឺណិតចាំបាច់ត្រូវវាយតម្លៃទៅលើ ពាក្យចចាមអារ៉ាមតាមរយៈអ៊ីនធឺណិតថា វាជាព័ត៌មានពិតប្រាកដ មុនពេលដែលពួកគេចែករំលែកបន្តទៅកាន់អ្នកដទៃ។ បើពួកគេមិនបញ្ជាក់ទេ ពួកគេអាចនឹងនិយាយកុហកដោយមានការភ័ន្តច្រឡំ និងដោយកំហុសតៗគ្នាតាមអ៊ីនធឺណិត ដោយផ្ទាល់មាត់ ឬដោយសំណេរ។*

យើង ហើយយើងបញ្ចេញមតិយោបល់ទាំងនោះដោយសេរី។ វាពិតជាខុសធ្ងន់ណាស់ដែលចោទប្រកាន់នរណាម្នាក់អំពីបទល្មើសដោយគ្មានភស្តុតាង ដូចជាការសម្លាប់មនុស្ស ហើយយើងនឹងធ្វើឱ្យខូចកេរ្តិ៍ឈ្មោះរបស់បុគ្គលនោះទៀតផង។

តាមផ្លូវច្បាប់ យើងទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន និងចំពោះព័ត៌មានដែលយើងចែករំលែក ហើយវាជាការទទួលខុសត្រូវផ្ទាល់ខ្លួនដើម្បីធ្វើឱ្យប្រាកដថា មតិយោបល់ដែលយើងបានបញ្ចេញគឺត្រឹមត្រូវ។ តាមពិតទៅសម្រាប់អ្វីមួយដែលអ្នកដទៃបានបង្ហាញថាពិត គឺវាចៀសមិនផុតពីការផ្ទៀងផ្ទាត់ឡើងវិញនៅមុនពេលចែករំលែកបន្តឡើយ។

សេរីភាពនៃការបញ្ចេញមតិ គឺជាមូលដ្ឋានគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ។ វាត្រូវបានប្រើប្រាស់ជាឧបករណ៍យ៉ាងទូលំទូលាយ និងដ៏មានឥទ្ធិពលសម្រាប់ការការពារគំនិតយោបល់របស់យើង។ យើងត្រូវតែរៀនប្រើប្រាស់វាឱ្យបានត្រឹមត្រូវដើម្បីសម្រេចគោលដៅរបស់យើង ហើយបញ្ជាក់នូវអ្វីដែលជាការពិត និងប្រុងប្រយ័ត្នចំពោះការចែករំលែកព័ត៌មានដែលគ្មានការបញ្ជាក់ច្បាស់លាស់។ ការផ្លាស់ប្តូរគំនិតដោយគ្មានការកុហក ឬការប្រមាថ គឺនាំឱ្យវាជាការពិភាក្សាដ៏មានប្រយោជន៍ដែលជួយឱ្យសង្គមមានការរីកចម្រើន។

មាត្រា៤១ នៃរដ្ឋធម្មនុញ្ញបានចែងថា

ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពខាងការប្រជុំ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ។

# ៥. ទំនាក់ទំនង

អ៊ីនធឺណិតមិនគ្រាន់តែអនុញ្ញាតឱ្យយើងទទួលបានព័ត៌មានប៉ុណ្ណោះទេ តែវាថែមទាំងជាឧបករណ៍ដ៏សំខាន់សម្រាប់ទំនាក់ទំនងរវាងបុគ្គល និងសង្គមទៀតផង។ តាមពិត ទំនាក់ទំនងនៅលើអ៊ីនធឺណិតគឺចម្លងឧបករណ៍ដែលមានរួចហើយ នៅមុនពេលបណ្តាញនេះបានកើតឡើង។ ឧបករណ៍ដំបូងក្នុងចំណោមឧបករណ៍ទាំងនេះគឺ អ៊ីមែល វាជាសំបុត្រអេឡិចត្រូនិកដែលដូចគ្នាទៅនឹងការផ្ញើសំបុត្រតាមរយៈប្រៃសណីយ៍ដែរ។ នៅពេលសារអ៊ីមែលត្រូវបានវាយបញ្ចូលដោយក្តារចុចកុំព្យូទ័រ ឬទូរសព្ទ វានឹងត្រូវបានផ្ញើដោយផ្ទាល់ទៅកាន់អ្នកទទួល ដោយមិនចាំបាច់សរសេរលើក្រដាសឡើយ ហើយវាទៅដល់អ្នកទទួលភ្លាមៗទៀតផង។

ដើម្បីអាចប្រើអ៊ីមែលបាន អ្នកប្រើនីមួយៗចាំបាច់ត្រូវមានអាសយដ្ឋានអ៊ីមែលរបស់ខ្លួន ដែលអាសយដ្ឋានអ៊ីមែលនេះដើរតួនាទីជាប្រអប់សំបុត្រ ហើយអនុញ្ញាតឱ្យអ្នកផ្សេងផ្ញើសារមក។ មិនមានមនុស្សណាម្នាក់នៅក្នុងពិភពលោកនេះ មានអាសយដ្ឋានអ៊ីមែលដូចគ្នាឡើយ។ ត្រូវដឹងថាអាសយដ្ឋាន

អ៊ីមែលរបស់មនុស្សម្នាក់ គឺផ្តល់នូវព័ត៌មានគ្រប់គ្រាន់ដើម្បីទាក់ទងទៅបុគ្គលនោះតាមរយៈអ៊ីមែល។

*សព្វថ្ងៃនេះអ៊ីមែល គឺជាឧបករណ៍ដ៏សំខាន់ សម្រាប់ទំនាក់ទំនង ពាណិជ្ជកម្មទាំងឡាយ។*

ក្រោយមកទៀត ទំនាក់ទំនងនៅលើអ៊ីនធឺណិតកាន់តែមានភាពស្មុគស្មាញឡើងៗ ឧបករណ៍ទំនាក់ទំនងថ្មីៗត្រូវបានអភិវឌ្ឍ ដើម្បីប្រើប្រាស់ឱ្យអស់លទ្ធភាពសម្រាប់ទម្រង់មេឌាថ្មីនេះ។ ចេញពីទំនាក់ទំនងរវាងម្នាក់ទៅម្នាក់តាមរយៈអ៊ីមែល វាបានវិវត្តទៅជាទំនាក់ទំនងបន្តគ្នាជាក្រុម ដែលឥឡូវនេះគឺអាចចែករំលែកជារូបភាព វីដេអូ និងព័ត៌មានបន្ថែមទៅលើអត្ថបទដែលបានសរសេរកាលពីមុន។

ការប្រើប្រាស់អ៊ីនធឺណិតត្រូវបានរៀបរចនាសម្ព័ន្ធជាសេវាកម្ម។ សេវាកម្មនីមួយបើកចំហផ្លូវដើម្បីស្វែងរកព័ត៌មាន ឬដើម្បីទំនាក់ទំនងជាមួយអ្នកដទៃ។ វេបសាយជាសេវាកម្មមួយដែលអនុញ្ញាតឱ្យយើងចែករំលែកព័ត៌មានជាមួយអ្នកផ្សេង ឬចូលប្រើព័ត៌មានទាំងឡាយដែលអ្នកដទៃបានផ្សព្វផ្សាយ។ អ៊ីមែលជាសេវាកម្មដែលត្រូវបានប្រើសម្រាប់ពាណិជ្ជកម្ម និងទំនាក់ទំនងរវាងមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។

នៅអំឡុងទសវត្សរ៍ចុងក្រោយនេះ មានសេវាកម្មថ្មីៗជាច្រើនបានកើតឡើង ហើយវាបានក្លាយទៅជាសេវាកម្មដ៏មានប្រជាប្រិយសម្រាប់អ្នកប្រើប្រាស់អ៊ីនធឺណិត។ សេវាកម្មទាំងនោះគឺបានជួយសម្រួលដល់ការផ្ទុក និងការចូលប្រើប្រាស់ប្រព័ន្ធព័ត៌មាន។ សេវាកម្មទាំងនោះមានដូចជា Flickr ឬ Instagram ជាដើមដែលអនុញ្ញាតឱ្យអ្នកប្រើផ្ទុករូបថតរបស់ខ្លួននៅលើអ៊ីនធឺណិត ហើយចែករំលែកជាមួយអ្នកដទៃ ដោយមិនភ័យខ្លាចក្នុងការបាត់បង់រូបភាពទាំងនោះឡើយ។ សេវាកម្មស្រដៀងគ្នានេះក៏មានដែរសម្រាប់វីដេអូ ពួកគេអាចផ្ទុកវីដេអូរបស់ខ្លួន រួចចែករំលែកជាមួយអ្នកដទៃបាន។ មានសេវាកម្មផ្សេងទៀតដែលអនុញ្ញាតឱ្យចែករំលែកឯកសារ ឬព័ត៌មានផ្សេងដែលបានផ្ទុកនៅក្នុងកុំព្យូទ័រ។

# ៦. បណ្តាញសង្គម

ប្រសិនបើយើងកំពុងចែករំលែកព័ត៌មាន ហេតុអ្វីត្រូវជាប់គាំងនៅត្រឹមរូបភាព ឬវីដេអូ? បណ្តាញសង្គមផ្តល់ឱ្យយើងនូវឱកាសដើម្បីចែករំលែកព័ត៌មានអំពីខ្លួនឯង និងពិនិត្យមើលព័ត៌មានពីមិត្តភ័ក្តិ ការកម្សាន្ត និងដំណឹងផ្សេងៗ បង្កើតបានជាផ្នែកដ៏ល្អនៃព័ត៌មានដែលគួរឱ្យចាប់អារម្មណ៍ និងចង់ទទួល។

តាមរយៈបណ្តាញសង្គមមានដូចជា Facebook, Google+, LinkedIn ឬ Twitter អ្នកប្រើអាចធ្វើការប្រាស្រ័យទាក់ទងជាមួយមិត្តភ័ក្តិ ក្រុមគ្រួសារ សហសេវិក ឬអ្នកដែលមានចំណាប់អារម្មណ៍ស្រដៀងគ្នា។ អ្នកប្រើអាចបង្កើតក្រុមមិត្តភ័ក្តិ ឬសហសេវិករបស់ខ្លួនបាន ហើយចែករំលែកព័ត៌មានជាមួយគ្នា បន្ទាប់មកពួកគេនឹងមើលឃើញនូវអ្វីដែលអ្នកផ្សេងបានចែករំលែក។ ព័ត៌មានដែលអាចចែករំលែកបានមានដូចជា សារជាអក្សរ រូបភាព បទចម្រៀង វីដេអូ គំនិតយោបល់ ឬតំណទៅកាន់ព័ត៌មានផ្សេងៗ។ អ្នកប្រើក៏អាចចែករំលែកមតិយោបល់ទៅលើព័ត៌មានណាមួយដែលមិត្តភ័ក្តិ ឬអ្នកនៅក្នុងក្រុមបានលើកយកមកពិភាក្សាបានផងដែរ។

តាមរយៈបណ្តាញសង្គមនេះដែរ វាបានផ្តល់នូវភាពងាយស្រួលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយមិត្តភ័ក្តិបច្ចុប្បន្ន និងអតីតមិត្តភ័ក្តិ ឬទំនាក់ទំនងការងារ ជូនដំណឹងពួកគេទាំងអស់គ្នាក្នុងពេលតែមួយអំពីអ្វីដែលយើងកំពុងធ្វើ ឬចែករំលែកចំណាប់អារម្មណ៍ និងរូបភាព។ នៅពេលដំណាលគ្នា យើងអាចតាមដាននូវអ្វីដែលអ្នកនៅក្នុងក្រុមទំនាក់ទំនងរបស់យើងកំពុងធ្វើ ប្រាស្រ័យទាក់ទងជាមួយពួកគេ មើលរូបភាពរបស់ពួកគេ និងស្វែងយល់អំពីចំណូលចិត្តរបស់ពួកគេ។

បណ្តាញសង្គមទាំងនោះ ត្រូវបានប្រើសម្រាប់ទំនាក់ទំនងផ្ទាល់ខ្លួន ឬទំនាក់ទំនងការងារ។ បណ្តាញសង្គមដូចជា Facebook ឬ Google+ ត្រូវបានបង្កើតឡើងដើម្បីរក្សាទំនាក់ទំនងផ្ទាល់ខ្លួន ហើយវាមិនបានរើសអើងពីប្រភេទព័ត៌មានដែលបានចែករំលែកជាមួយអ្នកផ្សេងឡើយ។

បណ្តាញសង្គម LinkedIn មានជំនាញខាងភ្ជាប់ទំនាក់ទំនងបែបវិជ្ជាជីវៈ ដែលព័ត៌មានគេចែករំលែកជាទូទៅ ច្រើនតែនិយាយអំពីបញ្ហាការងារ។ សម្រាប់មនុស្សមួយចំនួន Twitter គឺជាមធ្យោបាយប្រសើរបំផុតសម្រាប់ការបញ្ចេញមតិរបស់ខ្លួនជាសារខ្លីៗ និងដើម្បីរកមើលភ្លាមៗនូវអ្វីដែលបានកើតឡើងជាមួយអ្នកផ្សេង ឬព័ត៌មានដែលពួកគេចង់ដឹងដោយគ្មានអ្វីរារាំងឡើយ។

បណ្តាញសង្គមមានប្រព័ន្ធទំនាក់ទំនងផ្ទាល់ខ្លួន រវាងសមាជិកនីមួយៗ។ ក្រៅពីព័ត៌មានដែលអ្នកប្រើបានផ្សព្វផ្សាយដល់មិត្តភ័ក្តិ ឬទំនាក់ទំនងរបស់ខ្លួនឱ្យមើលឃើញ វាក៏អាចត្រូវបានប្រើដើម្បីផ្ញើសារបន្ទាន់ទៅកាន់នរណាម្នាក់ ឬផ្ញើសារដូចអ៊ីមែលដែរ ហើយនឹងត្រូវបានអានដោយអ្នកទទួល នៅពេលពួកគេតភ្ជាប់អ៊ីនធឺណិត។

នៅអំឡុងទសវត្សរ៍ចុងក្រោយនេះ ទម្លាប់ទំនាក់ទំនងរបស់យុវជនបានផ្លាស់ប្តូរយ៉ាងឆាប់រហ័សពីការផ្ញើសារខ្លីៗ SMS នៅក្នុងទូរសព្ទ ទៅជាការប្រើប្រាស់បណ្តាញសង្គម ពួកគេបានផ្លាស់ប្តូរពីការប្រាស្រ័យទាក់ទងជាមួយមិត្តភ័ក្តិ និងសហសេវិកដែលមានចំនួនកំណត់ មកជាការប្រាស្រ័យទាក់ទងក្នុងទ្រង់ទ្រាយធំដែលមានមនុស្សច្រើននាក់ ហើយពួកគេភាគច្រើនអាចមិនដែលស្គាល់គ្នាដោយ "ផ្ទាល់" ទៀតផង គឺដោយសារតែពួកគេបានចាត់ទុកគ្នាជា "មិត្តភ័ក្តិ" ក្នុងបណ្តាញសង្គម។ បណ្តាញសង្គមក៏បានជួយថែរក្សាទំនាក់ទំនងរវាងក្រុមគ្រួសារ និងអតីតមិត្តភ័ក្តិ "ពិត" ដែលមិនមានទំនាក់ទំនងគ្នាជាយូរណាស់មកហើយ។ និយាយរួម បណ្តាញសង្គមបានផ្លាស់ប្តូរទំនាក់ទំនងសង្គម ពីការស្គាល់មិត្តភ័ក្តិមួយក្រុមតូចទៅជាការស្គាល់មនុស្សច្រើន ហើយយើងអាចផ្សព្វផ្សាយនូវអ្វីដែលកើតឡើងក្នុងជីវិតរបស់យើងបានទៀតផង។



# ៦.១. គុណភាពនៃទំនាក់ទំនង

ការប្រើប្រាស់បណ្តាញសង្គម មានផលប៉ះពាល់ចំពោះអ្នកដែលប្រើវាញឹកញាប់ជាងអ្វីដែលពួកគេគិតទៅទៀត។ ពេលទាក់ទងជាមួយមនុស្សច្រើន ការប្រាស្រ័យទាក់ទងរបស់យើងគឺមិនដូចគ្នាទៅនឹងការប្រាស្រ័យទាក់ទងជាមួយមិត្តភ័ក្តិតិចតួចដែលនៅជុំវិញយើងនោះឡើយ ហើយគុណភាពទំនាក់ទំនងក៏ផ្លាស់ប្តូរដែរ។ ពេលយើងទាក់ទងដោយផ្ទាល់ជាមួយមិត្តភ័ក្តិពិតប្រាកដ ទំនាក់ទំនងរបស់យើងគឺមានលក្ខណៈផ្ទាល់ខ្លួនច្រើនជាង ហើយការផ្លាស់ប្តូរអារម្មណ៍ និងទស្សនៈយោបល់គឺមានលក្ខណៈស៊ីជម្រៅជាង។ ពេលយើងទាក់ទងតាមរយៈបណ្តាញសង្គម គឺយើងសរសេរ និងបញ្ចេញទស្សនៈ តិចជាងការសន្ទនាដោយផ្ទាល់។ ដូចយើងបានដឹងហើយថាមានមនុស្សជាច្រើននឹងអានមតិយោបល់របស់យើង។ ដូច្នេះយើងមិនអាចសម្តែងពីអារម្មណ៍ ឬទស្សនៈដោយបើកចំហដូចដែលយើងបានបញ្ចេញជាមួយមនុស្សម្នាក់បានឡើយ ពីព្រោះយើងខ្លាចក្រែងថា "មិត្តភ័ក្តិ" របស់យើងមួយចំនួននឹងមើលឃើញវាក្នុងផ្លូវអវិជ្ជមាន ហើយជាលទ្ធផលទំនាក់ទំនងរបស់យើងអាចឈានដល់ការបាត់បង់ ឬលែងមានន័យ។



វាពិតជាគ្រោះថ្នាក់ខ្លាំងណាស់ដែលអ្នកជឿថា បណ្តាញសង្គមអាចជំនួសមិត្តភ័ក្តិពិតប្រាកដបាននោះ។ ខណៈដែលទំនាក់ទំនងទៅកាន់មនុស្សច្រើនគឺមានតម្លៃ ប៉ុន្តែវានៅតែមិនងាយស្រួលដូចទំនាក់ទំនងរវាងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ឡើយ។ អ្នកប្រើប្រាស់បណ្តាញសង្គមមួយចំនួន តាមពិតបានផ្តាច់ខ្លួនចេញពីអ្នកដទៃរួចទៅហើយ ទោះបីជាពួកគេមាន "មិត្តភ័ក្តិ" ជាច្រើននៅលើបណ្តាញក៏ដោយ។ ឧទាហរណ៍សាមញ្ញមួយ ពេលយើងទៅកាន់ហាងកាហ្វេ ឬភោជនីយដ្ឋាន យើងឃើញក្រុមមិត្តភ័ក្តិជួបជុំគ្នា ប៉ុន្តែពួកគេមិនជជែកគ្នាទេ ពួកគេនៅស្ងៀមស្ងាត់ ហើយមើល Facebook ឬផ្ញើសារ SMS ឱ្យគ្នាទៅវិញទៅមក ឬអ្នកខ្លះមើលភាពយន្ត។ ពេលខ្លះពួកគេចែករំលែកនូវអ្វីដែលពួកគេកំពុងមើលជាមួយមនុស្សដែលនៅអង្គុយតុជាមួយគ្នា ប៉ុន្តែវាមិនដូចគ្នាទៅនឹងការពិភាក្សាដែលបង្កើតឡើងនៅក្នុងក្រុមដោយការសន្ទនាពិតប្រាកដឡើយ។ ខណៈដែលការប្រើប្រាស់បណ្តាញសង្គមកាន់តែសកម្មឡើង វាអាចនឹងមានឥទ្ធិពលអាក្រក់ នៅពេលដែលវាក្លាយជាមធ្យោបាយចម្បងដើម្បីទាក់ទងជាមួយអ្នកដទៃនោះ។ វាពិតជាមានសារៈសំខាន់ណាស់ក្នុងការថែទាំ និងបណ្តុះទំនាក់ទំនងផ្ទាល់ខ្លួនជាមួយអ្នកដែលនៅជុំវិញខ្លួនយើង។

*យុវជនចាំបាច់ត្រូវដឹងអំពីតុល្យភាពពេលវេលា ដែលត្រូវប្រើសម្រាប់ការប្រាស្រ័យទាក់ទងតាមរយៈបណ្តាញសង្គម និងពេលវេលាដែលត្រូវប្រើសម្រាប់ភាពឯកជន និងជីវិតរស់នៅជាក់ស្តែង។*

# ៧. ការងារសហការ

មានសេវាកម្មអាចប្រើបានជាច្រើននៅលើអ៊ីនធឺណិត ដែលសេវាកម្មមួយចំនួនគឺឥតគិតថ្លៃ ហើយសេវាកម្មខ្លះទៀតត្រូវបានបង្កើតឡើង ក្នុងគោលបំណងជំនួញ និងរកប្រាក់ចំណូល។ សេវាកម្មទាំងនេះគឺជួយឱ្យទំនាក់ទំនងអ្នកប្រើមានភាពប្រសើរឡើង ឬជួយបង្កើនផលិតភាពការងាររបស់ពួកគេ។

សេវាកម្មថ្មីៗដែលផ្តល់ដោយក្រុមហ៊ុនផ្សេងៗគ្នា បានកើតឡើងជាបន្តបន្ទាប់។ ប្រសិនបើវាត្រូវបានអ្នកប្រើចាប់អារម្មណ៍ ឬដឹងថាមានប្រយោជន៍ នោះវានឹងទទួលបានប្រជាប្រិយភាពយ៉ាងរហ័ស ប៉ុន្តែបើអ្នកប្រើគិតថាវាគ្មានប្រយោជន៍ ឬមានប្រយោជន៍សម្រាប់តែមនុស្សតិចតួច នោះវានឹងមិនរីកចម្រើនឡើយ ហើយវានឹងបរាជ័យដូចមុខជំនួញដែរ។

ក្រុមសេវាកម្មដ៏គួរឱ្យចាប់អារម្មណ៍មួយ ហើយគេនិយមប្រើកាន់តែច្រើននោះគឺ សេវាកម្មសហការ។

វិគីភីឌា

សព្វវចនាធិប្បាយសេរី

សេវាកម្មទាំងនេះ គឺជាវេបសាយដែលអនុញ្ញាតឱ្យអ្នកប្រើបន្ថែមព័ត៌មាន ទៅកាន់ប្រភពចំណេះដឹងជាសកល ធ្វើការរួមគ្នាដើម្បីប្រាកដថាពួកគេសម្រេចបានមាតិកាដ៏ល្អបំផុត។ ឧទាហរណ៍ សេវាកម្មដ៏ល្បីមួយឈ្មោះ វិគីភីឌា ជាវេបសាយដែលបានក្លាយទៅជាប្រភពព័ត៌មានដ៏ធំបំផុតនៅលើពិភពលោក។ ទំព័រនីមួយនៅក្នុងវិគីភីឌាគឺនិយាយអំពីប្រធានបទជាក់លាក់។ ទំព័រទាំងឡាយត្រូវបានបង្កើតឡើងដោយអ្នកស្ម័គ្រចិត្តដែលធ្វើការស្រាវជ្រាវអំពីវា ហើយបង្កើតបានជាមាតិកា។ អ្នកប្រើផ្សេងទៀតធ្វើការផ្ទៀងផ្ទាត់ បន្ថែម ឬកែសម្រួលព័ត៌មាននៅក្នុងមាតិកាទាំងនោះ។ ករណីដែលមិនមានការឯកភាពគ្នា អ្នកសម្របសម្រួលនឹងជួយដោះស្រាយបញ្ហា ឬលុបមាតិកានោះចេញ។ ជាលទ្ធផលគឺខ្លឹមសារចំណេះដឹងដ៏ធំធេងដែលអ្នកទាំងនោះបានផ្តល់ឱ្យ បានក្លាយជាប្រភពចំណេះដឹងដ៏សំខាន់នៅលើអ៊ីនធឺណិត។

សេវាកម្មសហការផ្សេងទៀតជួយនាំយកព័ត៌មានប្រភេទផ្សេងបញ្ចូលគ្នា។ វេបសាយសហការ www.openstreetmap.org ជាផែនទីដែលអនុញ្ញាតឱ្យអ្នកប្រើបញ្ចូលព័ត៌មានលម្អិតអំពីប្រទេស ឬទីក្រុងរបស់ពួកគេនៅក្នុងផែនទីពិភពលោក ហើយអ្នកប្រើទាំងអស់អាចរកមើល ប្រើប្រាស់ក្នុងគោលបំណងផ្ទាល់ខ្លួន ឬចែករំលែកទៅអ្នកផ្សេងបានដោយសេរីតាមតម្រូវការ។ ពួកគេអាចបញ្ចូលទីតាំងវិថី អគារប្រាសាទ ហាងទំនិញ សាលារៀន និងព្រំប្រទល់ផ្សេងៗជាច្រើនទៀត បង្កើតបានជាផែនទីពេញលេញមួយដែលមនុស្សទាំងអស់អាចប្រើប្រាស់ និងចែករំលែកទៅមនុស្សគ្រប់គ្នា។

កម្មវិធីផែនទីមួយទៀតដែលស្រដៀងគ្នានេះដែរគឺ ផែនទី Google។ ព័ត៌មានត្រូវបានបញ្ចូលដោយក្រុមការងារ Google និងតាមរយៈអ្នកប្រើដែលចង់ជួយ ឬអ្នកដែលចង់ឱ្យសាលារៀន វិថី ឬហាងទំនិញរបស់ពួកគេមាននៅលើផែនទី។ ក្រៅពីការបង្ហាញផែនទី សេវាកម្មនេះអាចត្រូវបានប្រើប្រាស់ដើម្បីស្វែងរកហាងទំនិញ ស្វែងរកទិសនាំផ្លូវទៅកាន់ទីកន្លែងដែលពួកគេចង់ទៅ ចេញពីទីតាំងដែលយើងកំពុងស្ថិតនៅ។ ផែនទី Google បានក្លាយទៅជាកម្មវិធីទូរសព្ទទំនើបដ៏មានប្រជាប្រិយភាព ហើយមនុស្សភាគច្រើនលែងប្រើផែនទីក្រដាសទៀតហើយ។




រូបភាពនៃវេបសាយ OpenStreetMap

គោលបំណងនៃសេវាកម្មភាគច្រើននៅលើអ៊ីនធឺណិត គឺដើម្បីរកប្រាក់ចំណូល។ ដូច្នេះពួកគេព្យាយាមផ្តល់សេវាកម្មល្អៗ ដើម្បីឱ្យអ្នកប្រើពេញចិត្ត រួចបង់ប្រាក់ឱ្យខ្លួន។ សេវាកម្មខ្លះគិតប្រាក់លើការប្រើប្រាស់ ដូចជាករណីកាសែតនៅលើបណ្តាញមួយចំនួន។ សេវាកម្មផ្សេងទៀតបង្កើតឡើងដើម្បីលក់ផលិតផល ដែលពិបាករកទិញផ្ទាល់នៅលើទីផ្សារ។ បណ្តាញសង្គម Google និងសេវាកម្មព័ត៌មានមួយចំនួនផ្សេងទៀតរកប្រាក់ចំណូលតាមរយៈការផ្សព្វផ្សាយពាណិជ្ជកម្ម ដែលភាគច្រើនអ្នកប្រើមិនមែនជាអ្នកបង់ថ្លៃចំណាយទេ។ អ្នកប្រើគ្រាន់តែមើលឃើញការផ្សព្វផ្សាយពាណិជ្ជកម្ម ដែលបានបង្ហាញនៅក្នុងទំព័រ Google, Facebook ឬ LinkedIn ប៉ុណ្ណោះ ហើយម្ចាស់ផ្សព្វផ្សាយពាណិជ្ជកម្មគឺជាអ្នកបង់ថ្លៃចំណាយសម្រាប់សេវាកម្មនេះ។

# ៤. ទូរសព្ទ

កាលពីមុនមានតែកុំព្យូទ័រប៉ុណ្ណោះដែលជាឧបករណ៍ ត្រូវបានប្រើដើម្បីចូលដំណើរការអ៊ីនធឺណិត ប៉ុន្តែបច្ចុប្បន្ននេះ ទូរសព្ទទំនើប ក៏ជាឧបករណ៍សម្រាប់ចូលប្រើអ៊ីនធឺណិតបានផងដែរ។ តាមពិតទូរសព្ទទំនើបគឺជាកុំព្យូទ័រតូចមួយ ដែលមានមុខងារជាទូរសព្ទ។ វាត្រូវបានបន្ថែមសមត្ថភាពកុំព្យូទ័រទៅលើសេវាកម្មសំឡេង ហើយលើសពីមុខងារជាទូរសព្ទ និងកុំព្យូទ័រ ទូរសព្ទទំនើបត្រូវបានបន្ថែមបច្ចេកវិទ្យាម៉ាស៊ីនថតរូបភាព និងវីដេអូ ឬសមត្ថភាពកំណត់ទីតាំងរបស់ទូរសព្ទដែលស្ថិតនៅកន្លែងណាមួយយ៉ាងច្បាស់លាស់។ ទូរសព្ទទំនើបជាកុំព្យូទ័រតូចមួយដែលនៅក្បែរខ្លួនយើងគ្រប់ពេលវេលា ហើយវាអាចឱ្យយើងតភ្ជាប់ទៅកាន់អ៊ីនធឺណិតមិនថានៅទីកន្លែងណាឡើយ។ លក្ខណៈទាំងនេះ បានធ្វើឱ្យទូរសព្ទទំនើបក្លាយជាឧបករណ៍ដ៏មានអនុភាព ក្នុងការចូលទៅប្រើប្រាស់សេវាកម្មរបស់អ៊ីនធឺណិតដែលយើងបានរៀបរាប់ពីមុនមក។

កាលពីដំបូង ទូរសព្ទទំនើបមានតម្លៃខ្ពស់ខ្លាំងណាស់ ប៉ុន្តែក្រោយមកតម្លៃរបស់វាក៏បានធ្លាក់ចុះ មនុស្សទូទៅមានលទ្ធភាពប្រើប្រាស់។ នៅចុងឆ្នាំ២០១៥ តាមស្ថិតិបង្ហាញថាទូរសព្ទមួយក្នុងចំណោមបីនៅកម្ពុជា គឺជាទូរសព្ទទំនើប។ វាច្បាស់ណាស់ថានៅពេលអនាគត ប្រជាពលរដ្ឋកម្ពុជាចំនួនច្រើនភាគរយនឹងប្រើប្រាស់ទូរសព្ទទំនើប។



ការតភ្ជាប់ទូរសព្ទទំនើបទៅកាន់អ៊ីនធឺណិត អាចត្រូវបានធ្វើឡើងតាមរយៈបណ្ដាញវ៉ាយហ្វាយដែលមាននៅជិតលោកអ្នក ឬតភ្ជាប់ដោយផ្ទាល់តាមរយៈប្រតិបត្តិករទូរសព្ទចល័ត ដែលវាអនុញ្ញាតឱ្យតភ្ជាប់អ៊ីនធឺណិតបានគ្រប់ពេលវេលា នៅពេលទូរសព្ទមានសេវា ដោយមិនចាំបាច់នៅក្បែរវ៉ាយហ្វាយហតស្ប៉ត (WiFi Hotspot) ឡើយ។

ដោយយោងតាមគុណសម្បត្តិទាំងនេះ មានន័យថាទូរសព្ទទំនើបកំពុងក្លាយទៅជាមធ្យោបាយដ៏ចម្បងសម្រាប់ការចូលប្រើប្រាស់អ៊ីនធឺណិតនៅកម្ពុជា។ ទោះជាដូច្នេះក្ដី មានប្រជាពលរដ្ឋកម្ពុជាតិចតួចប៉ុណ្ណោះដែលបានប្រើកុំព្យូទ័រ ហើយកុំព្យូទ័រមិនអាចប្រើបានគ្រប់កន្លែងឡើយ ដោយសារតែមិនមានចរន្តអគ្គិសនីគ្រប់គ្រាន់ ដែលជាហេតុធ្វើឱ្យទូរសព្ទទំនើបកាន់តែមានប្រជាប្រិយភាពថែមទៀត។ ការកើនឡើងនៃការប្រើប្រាស់ទូរសព្ទទំនើបដើម្បីចូលដំណើរការអ៊ីនធឺណិត ក៏ដោយសារតែវាចំណាយតិចជាងការប្រើកុំព្យូទ័រលើតុ ឬកុំព្យូទ័រយួរដៃ។

បច្ចេកវិទ្យាទូរសព្ទចល័តបានរីកចម្រើនយ៉ាងឆាប់រហ័សនៅកម្ពុជា។ ប្រជាពលរដ្ឋកម្ពុជាជាង ៩៣% មានទូរសព្ទផ្ទាល់ខ្លួនប្រើ ហើយប្រជាពលរដ្ឋស្ទើរតែទាំងអស់អាចប្រើប្រាស់ទូរសព្ទរបស់អ្នកជិតខាង ឬរបស់សាច់ញាតិខ្លួន។ ទូរសព្ទមានតម្លៃទាប ហើយចំណាយតិចបំផុតប្រចាំខែសម្រាប់ការធ្វើឱ្យលេខទូរសព្ទនៅដំណើរការក៏សមរម្យអាចទទួលយកបាន។ មិនដូចនៅប្រទេសផ្សេងឡើយ ការផ្ញើសារ SMS គឺជាមធ្យោបាយចម្បងនៃទំនាក់ទំនងតាមរយៈទូរសព្ទ ហើយការហៅជាសំឡេងបានក្លាយទៅជាការប្រើប្រាស់ដ៏លើសលប់នៅកម្ពុជា។

មូលហេតុចម្បងពីរសម្រាប់ភាពខុសគ្នានេះគឺថា ការហៅទូរសព្ទនៅប្រទេសកម្ពុជា មានតម្លៃទាបជាងការផ្ញើសារ SMS ហើយទូរសព្ទភាគច្រើនគឺមិនទាន់អាចផ្ញើ និងទទួលសារ SMS ជាភាសាខ្មែរបាននៅឡើយ។ ពេលខ្លះអ្នកប្រើវ័យក្មេងៗសរសេរសារ SMS ដោយប្រើអក្សរឡាតាំងតាមសូរសព្ទខ្មែរ ប៉ុន្តែមានតែមនុស្សមួយចំនួនតូចប៉ុណ្ណោះអាចអាន និងយល់បាន។




អ្នកប្រើភាគច្រើនកំពុងចាប់ផ្ដើមយល់ពីតម្លៃនៃទំនាក់ទំនងជាភាសាខ្មែរ ជាពិសេសទូរសព្ទទំនើបដែលប្រើប្រាស់សេវាកម្មទំនាក់ទំនងតាមអ៊ីនធឺណិតដើម្បីផ្ញើសារ។ ប្រភេទក្ដារចុចថ្មីក៏កំពុងត្រូវបានបង្កើតឡើងផងដែរ ដើម្បីជួយសម្រួលដល់ការវាយអក្សរខ្មែរ។

ការប្រើអ៊ីនធឺណិតតាមរយៈទូរសព្ទមានភាពងាយស្រួល ធ្វើឱ្យអ្នកប្រើទូរសព្ទទំនើបភាគច្រើនតែងតែតភ្ជាប់ទៅកាន់អ៊ីនធឺណិតបានជានិច្ច។ ការតភ្ជាប់ជាអចិន្ត្រៃយ៍នេះ គឺបើកចំហទម្រង់ទំនាក់ទំនងបែបថ្មីដែលអាចត្រូវបានប្រើសម្រាប់ទំនាក់ទំនងជាអត្ថបទសាមញ្ញដូចជាសារ SMS ឬអាចជាសារស្មុគស្មាញផ្សេងៗដូចជារូបភាព ឬវីដេអូជាដើម។ សេវាកម្មទាំងនេះសម្រួលដល់ទំនាក់ទំនងជាក្រុម ប្រសិនបើយើងចង់ផ្ញើសារទៅក្រុមមិត្តភ័ក្តិដែលយើងមានបំណងចង់ផ្ញើទៅ។ សេវាកម្មទាំងនេះឥតគិតប្រាក់ឡើយនៅពេលយើងបានភ្ជាប់អ៊ីនធឺណិត ដូច្នេះវាមិនមានការកំណត់ចំនួនសារដែលត្រូវផ្ញើ ឬត្រូវទទួលនោះទេ។

សេវាកម្មមួយចំនួនដូចជា Viber, Line, WhatsApp, ឬ Skype អនុញ្ញាតឱ្យយើងផ្ញើរូបភាព ឬវីដេអូដែលយើងបានថត។ សេវាកម្មខ្លះទៀតក្នុងចំណោមនេះ អនុញ្ញាតឱ្យយើងជជែកគ្នាតាមអ៊ីនធឺណិតដោយមិនចាំបាច់បង់ប្រាក់សម្រាប់ការហៅចេញឡើយ ឬប្រសិនបើការតភ្ជាប់អ៊ីនធឺណិតរបស់យើងមានល្បឿនលឿនគ្រប់គ្រាន់ គឺយើងអាចមើលឃើញមនុស្សដែលកំពុងជជែកជាវីដេអូបានទៀតផង។

ថ្វីបើទូរសព្ទផ្តល់ឱ្យយើងនូវឱកាសទំនាក់ទំនងភ្លាមៗក៏ដោយ ក៏យើងចាំបាច់ត្រូវដឹងអំពីពេលវេលាសមស្របដែលមិនគួរប្រើវាដែរ។ វាគួរតែត្រូវបានបិទនៅពេលដែលអ្នកកំពុងនៅក្នុងថ្នាក់រៀន ព្រោះអ្នកនឹងអាចផ្តោតអារម្មណ៍ទាំងស្រុងទៅលើមេរៀន។ វាក៏ជាការមិនគួរសមដែរ ដែលអ្នកនិយាយទូរសព្ទ ឬមើល Facebook នៅពេលដែលអ្នកកំពុងនៅជាមួយមិត្តភ័ក្តិផ្ទាល់នោះ។

ការប្រើអ៊ីនធឺណិតនៅលើទូរសព្ទមិនគ្រាន់តែសម្រាប់ទំនាក់ទំនងជាមួយមិត្តភ័ក្តិប៉ុណ្ណោះទេ គឺវាអាចឱ្យយើងចូលទៅកាន់ព័ត៌មាន និងសេវាកម្មផ្សេងៗបានភ្លាមៗទៀតផង។ យើងអាចប្រើប្រាស់វេបសាយនៅគ្រប់ពេលវេលាដើម្បីស្វែងរកព័ត៌មានជាក់លាក់ ឬសេវាកម្មផែនទីដូចជា Google ផែនទី ដើម្បីដឹងពីទីកន្លែងមួយចំនួន និងរបៀបចូលមើលកន្លែងទាំងនោះ។

ជាមួយទូរសព្ទ គឺអាចឱ្យយើងចូលមើលវីដេអូដែលបានផ្ទុកនៅលើសេវាកម្មមួយចំនួនដូចជា YouTube ឬកម្មវិធីទូរទស្សន៍ផ្សេងៗ។ តាមរយៈទូរសព្ទទំនើបដែលបានតភ្ជាប់អ៊ីនធឺណិត យើងគឺអាចចូលទស្សនាបណ្តាញសង្គមមួយចំនួនដូចជា Facebook ឬ LinkedIn ។ ទូរសព្ទបានក្លាយទៅជាឧបករណ៍ដ៏ចម្បងសម្រាប់ការចូលប្រើបណ្តាញសង្គម។ ដោយសារតែទូរសព្ទនៅជាប់ខ្លួនយើងជានិច្ច ដូច្នេះយើងអាចឆ្លើយតបជាមួយមិត្តភ័ក្តិគ្រប់ពេលវេលាដែលមានអ៊ីនធឺណិត។



YouTube លើអេក្រង់ទូរសព្ទ

សម្រាប់អ្នកដែលប្រើ ឬមានគម្រោងទិញទូរសព្ទទំនើប ពួកគេមានជម្រើសច្រើនទៅលើម៉ាក និងប្រព័ន្ធប្រតិបត្តិការ។ ប្រព័ន្ធប្រតិបត្តិការគឺជាអ្វីដែលកំណត់នៅលើអេក្រង់បង្ហាញរបស់ទូរសព្ទ និងកម្មវិធីដែលត្រូវបានប្រើជាមួយវា។

នៅឆ្នាំ២០០៥ ក្រុមហ៊ុន Apple បានបញ្ចេញទូរសព្ទទំនើបដែលមានឈ្មោះថា iPhone ។ ទូរសព្ទ iPhone ត្រូវបានបង្កើតឡើងជាឧបករណ៍ថ្មីសម្រាប់ការចូលប្រើអ៊ីនធឺណិត។ នៅឆ្នាំ២០០៨ ក្រុមហ៊ុន Google បានបញ្ចេញប្រព័ន្ធប្រតិបត្តិការមួយដែរឈ្មោះថា Android ហើយវាត្រូវបានប្រើដោយទូរសព្ទភាគច្រើន។ បច្ចុប្បន្នទូរសព្ទមានលក់នៅក្នុងប្រទេសកម្ពុជាដោយក្រុមហ៊ុនម៉ាកល្បីៗមួយចំនួនដូចជា Samsung, LG, ឬ HTC ប៉ុន្តែមិនដូចក្រុមហ៊ុន Apple ឡើយ ដែលប្រើប្រព័ន្ធប្រតិបត្តិការផ្ទាល់ខ្លួន




កម្មវិធី GPS សម្រាប់អេនដ្រយ

សម្រាប់តែទូរសព្ទរបស់ខ្លួនប៉ុណ្ណោះ ចំណែកឯក្រុមហ៊ុនផ្តល់ជាជំនួយដល់ក្រុមហ៊ុនផលិតទូរសព្ទដើម្បីរួមបញ្ចូលប្រព័ន្ធ Android នៅលើទូរសព្ទរបស់ពួកគេ។ ទូរសព្ទទំនើបថ្មីៗគឺមានកម្មវិធីដែលបានបញ្ចូលរួចស្រេចមួយចំនួន ហើយដែលក្នុងចំណោមទាំងនេះ គឺអនុញ្ញាតឱ្យវាអាចប្រើលក្ខណៈទាំងឡាយដែលមាននៅលើទូរសព្ទដូចជា ម៉ាស៊ីនថតសម្រាប់ថតជារូបភាពសន្លឹក ឬវីដេអូ កម្មវិធីអូឌីយ៉ូសម្រាប់ចាក់តន្ត្រី និងកម្មវិធីសម្រាប់បើកមើលរូបភាព ឬវីដេអូជាដើម។ ទូរសព្ទទំនើបភាគច្រើនគឺបានរួមបញ្ចូលឧបករណ៍មួយឈ្មោះ GPS ដែលអនុញ្ញាតឱ្យទូរសព្ទដឹងពីកន្លែងជាក់ដែលវាស្ថិតនៅ ហើយបង្ហាញទីតាំងនោះនៅលើអ៊ីនធឺណិត។ ជាមួយ GPS គឺអាចឱ្យយើងដឹងពីរបៀបដែលត្រូវធ្វើដំណើរចេញទីតាំងចាប់ផ្តើម ទៅកាន់គោលដៅ បង្កលក្ខណៈងាយស្រួលសម្រាប់អ្នកបើកបរដើម្បីដឹងផ្លូវ។ កម្មវិធីផ្សេងទៀតដែលតែងតែត្រូវបានរួមបញ្ចូលនោះគឺកម្មវិធីអ៊ីនធឺណិត វាជាកម្មវិធីដែលអនុញ្ញាតឱ្យអ្នករកមើល ឬស្វែងរកនៅលើអ៊ីនធឺណិត។

មានកម្មវិធីរាប់ពាន់ត្រូវបានអភិវឌ្ឍសម្រាប់ទូរសព្ទ ស្របតាមតម្រូវការអ្នកប្រើប្រាស់។ កម្មវិធីទាំងនោះភាគច្រើនមិនត្រូវបានបញ្ចូលនៅក្នុងទូរសព្ទនៅពេលដែលអ្នកទិញវាមកទេ ប៉ុន្តែយើងអាចទាញយកពីអ៊ីនធឺណិតបានយ៉ាងងាយស្រួល។ កម្មវិធីទាំងនោះភាគច្រើនគឺឥតគិតថ្លៃ ប៉ុន្តែមានកម្មវិធីផ្សេងទៀតតម្រូវឱ្យអ្នកទិញជាមុនទើបអាចទាញយកបាន។ ក្រុមហ៊ុនផលិតប្រព័ន្ធប្រតិបត្តិការរបស់ទូរសព្ទនីមួយៗបានកំណត់ទីតាំងដើម្បីឱ្យអ្នកប្រើប្រាស់ទាញយក និងដំឡើងកម្មវិធីដោយឥតគិតថ្លៃ ឬទិញកម្មវិធីដែលតម្រូវឱ្យបង់ប្រាក់។ ទីតាំងផ្ទុកកម្មវិធីទាំងនោះ ជាទូទៅមិនត្រូវបានចូលប្រើដោយកម្មវិធីអ៊ីនធឺណិតឡើយ ប៉ុន្តែវាត្រូវបានចូលប្រើដោយកម្មវិធីជាក់លាក់ ដែលបានបង្កើតដោយអ្នកអភិវឌ្ឍនៃប្រព័ន្ធប្រតិបត្តិការនោះ។ សម្រាប់ទូរសព្ទ iPhone កម្មវិធីគឺមានឈ្មោះថា App Store ហើយវាត្រូវបានដំឡើងរួចជាស្រេចនៅក្នុងទូរសព្ទ Apple ទាំងអស់។ ចំពោះទូរសព្ទប្រព័ន្ធប្រតិបត្តិការ Android កម្មវិធីមានឈ្មោះថា Play Store ។

ស្របពេលទូរសព្ទមានលក្ខណៈពិសេស និងកម្មវិធីទាំងនេះ គឺចាំបាច់ វានៅមានចំណុចសំខាន់មួយទៀតសម្រាប់ពលរដ្ឋខ្មែរ គឺទូរសព្ទត្រូវតែអាចវាយ និងបង្ហាញភាសាខ្មែរបានយ៉ាងត្រឹមត្រូវ។ បច្ចុប្បន្ននេះទូរសព្ទជាងពាក់កណ្តាលនៅប្រទេសកម្ពុជា គឺអាចផ្ញើ និងទទួលសារជាភាសាខ្មែរបាន ហើយចំនួននេះនឹងកើនឡើង នៅពេលដែលអ្នកប្រើមានទម្លាប់ជាមួយនឹងការប្រើប្រាស់អក្សរខ្មែរ។

## មេរៀនសង្ខេប

ការរីកចម្រើននៃអ៊ីនធឺណិតបានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងផ្នែកទំនាក់ទំនង ហើយបច្ចុប្បន្ននេះអ៊ីនធឺណិតគឺជាឧបករណ៍ទំនាក់ទំនងដ៏មានអានុភាពបំផុតដែលពុំធ្លាប់មាន។ ការសិក្សាពីរបៀបប្រើប្រាស់វាគឺមានសារៈសំខាន់សម្រាប់ពាណិជ្ជកម្ម ការសិក្សាអប់រំ ការស្រាវជ្រាវ និងសម្រាប់

មនុស្សដែលចង់ដឹង។ សេវាកម្មចម្បងដែលអនុញ្ញាតឱ្យអ្នកប្រើផ្ទុកព័ត៌មាននៅលើអ៊ីនធឺណិតគឺ World Wide Web វាត្រូវបានបង្កើតឡើងដោយវេបសាយជាច្រើន ហើយផ្ទុកព័ត៌មានដែលបានផ្សព្វផ្សាយដោយបុគ្គល ឬស្ថាប័ន។ ដោយសារអ្នកប្រើកុំព្យូទ័រ ឬទូរសព្ទអាចភ្ជាប់ទៅកាន់អ៊ីនធឺណិតបាន មនុស្សអាចចូលប្រើព័ត៌មានទាំងឡាយនៅទូទាំងពិភពលោកបាន។

ថ្វីត្បិតតែអ៊ីនធឺណិតផ្ទុកនូវព័ត៌មានពិតប្រាកដជាច្រើនក៏ដោយ ប៉ុន្តែក៏នៅមានរឿងរ៉ាវខ្លះមិនពិតដែរ ហើយគំនិតយោបល់ផ្ទាល់ខ្លួនត្រូវបានសម្តែងថាជាការពិត។ យើងត្រូវតែប្រើគំនិតសុភវិនិច្ឆ័យ ចំណេះដឹង និងបំណិនគិតដើម្បីកំណត់ថាវាជាព័ត៌មានពិត ឬក្លែងក្លាយ។ សេវាកម្ម វិគីភីឌា ជាវេបសាយដែលមានអ្នកចូលរួមជាច្រើនក្នុងការរៀបចំព័ត៌មាន ហើយត្រូវបានពេញនិយមក្នុងការស្វែងរកចម្លើយនៃព័ត៌មានដែលចង់បាន។ វេបសាយសហការវិគីភីឌា បច្ចុប្បន្នគឺជាសព្វវចនាធិប្បាយដ៏ធំបំផុតនៅលើពិភពលោក។ យើងចាំបាច់ត្រូវដឹងផងដែរអំពីអំណាច និងដែនកំណត់នៃសេរីភាពបញ្ចេញមតិ។ ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សិទ្ធិឱ្យយើងបញ្ចេញមតិយោបល់របស់ខ្លួនដោយសេរីទៅលើប្រធានបទណាមួយ ប៉ុន្តែយើងក៏មិនត្រូវធ្វើឱ្យប៉ះពាល់ដល់អ្នកដទៃដោយការនិយាយកុហក ឬធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់ពួកគេដែរ។ បណ្តាញសង្គមដូចជា Facebook, LinkedIn, Instagram ឬ YouTube គឺជាសេវាកម្មអ៊ីនធឺណិតពេញនិយមយ៉ាងពិសេស ហើយវាកំពុងផ្លាស់ប្តូរមធ្យោបាយទំនាក់ទំនងរបស់ក្រុមយុវវ័យ។ ពេលដែលទម្រង់នៃទំនាក់ទំនងថ្មីនេះមានគុណសម្បត្តិយ៉ាងច្រើន វាក៏នឹងអាចនាំឱ្យមានការប៉ះពាល់ផងដែរ ដូច្នេះយើងចាំបាច់ត្រូវផ្តល់តម្លៃឱ្យទំនាក់ទំនងជាមួយមិត្តភក្តិជាក់ស្តែង និងក្រុមគ្រួសារ ជាជាងទំនាក់ទំនងសើៗជាមួយមិត្តភក្តិ ដែលមិនធ្លាប់ជួបមុខគ្នានោះ។ ពេលដែលការទាក់ទងទៅកាន់មនុស្សច្រើនគឺមានគុណតម្លៃ ប៉ុន្តែវាមិនមានគុណភាពខ្ពស់ដូចទំនាក់ទំនងរវាងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ឡើយ។

បច្ចេកវិទ្យាទូរសព្ទចល័តនៅក្នុងប្រទេសកម្ពុជាបានរីកចម្រើនយ៉ាងឆាប់រហ័ស ហើយបច្ចុប្បន្ននេះមានប្រជាពលរដ្ឋខ្មែរជាច្រើនកំពុងប្រើទូរសព្ទទំនើប ដែលអាចចូលប្រើអ៊ីនធឺណិត និងអាចសរសេរអក្សរខ្មែរបាន។ ការលក់ និងការប្រើប្រាស់ទូរសព្ទទំនើបនឹងបន្តកើនឡើង ខណៈដែលតម្លៃរបស់វាបានធ្លាក់ចុះនោះ។

## លំហាត់

### លំហាត់ ២

ស្ថានភាពចំនួនប្រាំមួយដែលក្រុមរបស់អ្នកនឹងជួបនៅក្នុងលំហាត់នេះ គឺទាក់ទងទៅនឹងការប្រើប្រាស់បណ្តាញសង្គម។ នៅក្នុងស្ថានភាពនីមួយៗ អ្នកនឹងពិភាក្សាជាមួយក្រុម ហើយវិភាគអំពីសកម្មភាពអ្នកចូលរួម កំណត់ពីរបៀប និងមូលហេតុដែលនាំឱ្យប៉ះពាល់ដល់ពួកគេ និងអ្នកដទៃ បន្ទាប់មកវាយតម្លៃអំពីអ្វីដែលជាសកម្មភាពមិនត្រឹមត្រូវនាំឱ្យមានការប៉ះពាល់។ អ្នកគួរតែចំណាយពេលប្រហែលប្រាំនាទីដើម្បីវិភាគទៅលើស្ថានភាពនីមួយៗ ឆ្លើយសំណួរដោយសរសេរខ្លីៗអំពីគំនិតរបស់អ្នកចំនួនពីរបីប្រយោគ ហើយត្រៀមលក្ខណៈដើម្បីធ្វើបទបង្ហាញ ប្រសិនបើគ្រូតម្រូវឱ្យធ្វើ។

១ គឺជាថ្ងៃខួបកំណើតរបស់ឈុនឡេង។ គាត់មានមិត្តភ័ក្តិច្រើន ប៉ុន្តែគាត់មានប្រាក់តិចតួច ដូច្នេះគាត់អាចអញ្ជើញមិត្តភ័ក្តិរបស់គាត់បានតែបួននាក់ប៉ុណ្ណោះ ដើម្បីញ៉ាំអាហារ និងធ្វើពិធីខួបកំណើតនេះ។ សុផាតជាមិត្តមានសំណាងម្នាក់ក្នុងចំណោមមិត្តភ័ក្តិដែលឈុនឡេងបានអញ្ជើញ។ គាត់បានថតរូបមួយចំនួននៃកម្មវិធីដ៏តូចនោះ ហើយប្រកាសនៅលើ Facebook ដើម្បីឱ្យមិត្តភ័ក្តិទាំងអស់របស់ឈុនឡេងបានឃើញ។ មិត្តភ័ក្តិផ្សេងទៀតរបស់ឈុនឡេងឃើញ ហើយក៏ខឹងនឹងគាត់ ព្រោះគាត់មិនបានអញ្ជើញពួកគេ។ ពួកគេមិនបានដឹងថាគាត់គ្មានប្រាក់គ្រប់គ្រាន់ដើម្បីធ្វើពិធីធំដុំ និងអញ្ជើញពួកគេឡើយ។ ពួកគេខឹងគាត់ហើយសរសេរនូវពាក្យសម្ដីមិនល្អអំពីគាត់។

តើមានកំហុសអ្វីខ្លះ ?

២ វីរៈមានអារម្មណ៍មិនចង់ចូលសាលារៀនមួយថ្ងៃ។ គាត់ប្រាប់គ្រូថា គាត់មិនស្រួលខ្លួន ហើយចង់ទៅផ្ទះ។ គាត់បានទៅញ៉ាំអាហារជាមួយមិត្តភ័ក្តិរបស់គាត់នៅក្បែរមាត់ទន្លេយ៉ាងសប្បាយរីករាយ។ គាត់ថតរូបនៅពេលញ៉ាំនោះ ហើយប្រកាសនៅលើទំព័រ Facebook របស់គាត់។ នៅថ្ងៃបន្ទាប់ ពេលគាត់ចូលថ្នាក់រៀន គ្រូមានរូបភាពដែលវីរៈបានប្រកាសនៅលើ Facebook ... បន្ទាប់មកវីរៈត្រូវបានពិន័យឱ្យសម្អាតបង្គន់សាលារៀនពេញមួយសប្ដាហ៍។

តើមានអ្វីកើតឡើង ?

៣ សុភាពមានមិត្តភ័ក្តិជាង ១០០០នាក់នៅលើ Facebook ។ មិត្តភ័ក្តិភាគច្រើនគឺនាងមិនស្គាល់ឡើយ ព្រោះនាងព្រមទទួលសំណើអ្នកទាំងអស់ដែលបានស្នើសុំក្លាយជាមិត្តជាមួយនាងតាមរយៈបណ្ដាញ Facebook។ កាលពីសប្ដាហ៍មុនសុភាពបានប្រកាសនៅលើ Facebook ថានាងចង់លក់ម៉ូតូរបស់នាង ហើយនៅក្នុងការប្រកាសនោះ នាងបានដាក់បញ្ចូលផែនទីផ្លូវមកកាន់ផ្ទះរបស់នាង ដើម្បីឱ្យអ្នកដែលចង់ទិញមកមើលម៉ូតូដល់ទីកន្លែង។ ថ្ងៃនេះសុភាពទើបលក់ម៉ូតូដាច់ ហើយនាងនៅផ្ទះតែម្នាក់ឯង និងអផ្សុកខ្លាំងណាស់។ នាងបានប្រកាសនៅលើ Facebook ថានាងលក់ម៉ូតូបាន $១៥០០ ហើយនាងនៅផ្ទះម្នាក់ឯង ព្រោះឪពុកម្ដាយរបស់នាងនៅឆ្ងាយពីភ្នំពេញ។ នាងមិនបានដឹងថាក្នុងចំណោមមិត្តភ័ក្តិដែលនាងព្រមទទួលនៅលើ Facebook គឺជាចោរឡើយ។ នៅម៉ោងប្រមាណជា១០:០០ យប់ ចោរបានបើក Facebook ហើយអានការប្រកាស ឃើញថានាងមានប្រាក់ $១៥០០ ហើយនៅផ្ទះម្នាក់ឯងទៀត បន្តិចក្រោយមកចោរនោះក៏មកដល់ផ្ទះរបស់នាង រួចយកកូនកាំបិតភ្ជង់នាងប្លន់យកប្រាក់ទាំងអស់របស់សុភាព។ សំណាងដែរ ដែលមិនមានរឿងអ្វីផ្សេងទៀតកើតឡើងចំពោះនាង។

តើបញ្ហានេះចេញមកពីណា ? តើអ្នកមានយោបល់ដូចម្ដេចសម្រាប់ការប្រកាស ពេលដែលមាននរណាម្នាក់ចង់លក់របស់អ្វីមួយ ?

៤ គ្រាន់តែជាការកំប្លែង វណ្ណៈផ្ញើរូបភាពដែលគួរឱ្យខ្មាសអៀនមួយ គឺរូបដែលគាត់ពាក់អាវស្រ្តីទៅឱ្យមិត្តស្រីរបស់គាត់។ ពីរបីសប្ដាហ៍ក្រោយ គាត់សម្រេចចិត្តផ្លាស់ប្ដូរមិត្តស្រី ដែលធ្វើឱ្យមិត្តស្រីទីមួយរបស់គាត់មិនសប្បាយចិត្តជាខ្លាំង។ ជាការសងសឹក នាងបានបង្ហោះរូបថតដែលគួរឱ្យខ្មាសអៀននោះដើម្បីឱ្យមិត្តភ័ក្តិទាំងអស់របស់គាត់បានឃើញ រួមទាំងមិត្តស្រីថ្មី

របស់គាត់នោះផង គឺដើម្បីបញ្ជាក់ថាគាត់ប្រហែលជាចាកចេញពីនាង ដោយសារតែគាត់ជាមនុស្សខ្ជិល។

តើអ្នកណាមួយក្នុងចំណោមពួកគេ ដែលបានធ្វើរឿងមិនត្រឹមត្រូវ? ឬមួយទាំងពីរនាក់? ពេលអ្នកផ្ញើរូបភាពគួរឱ្យខ្មាសអៀន ឬរូបភាពលេចលើលេចក្រោមរបស់ខ្លួនឯងតាមរយៈអ៊ីនធឺណិត តើអ្នកមានការគ្រប់គ្រងដូចម្ដេច ប្រសិនបើមានបញ្ហាកើតឡើងនៅពេលអនាគត?

៥ ពិសិដ្ឋបានរកឃើញវេបសាយមួយនៅលើអ៊ីនធឺណិត ដែលមានសំណួរទាក់ទងនឹងការប្រឡងមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) នៅឆ្នាំនេះ។ គាត់មើលសំណួរ ហើយសិក្សាតែទៅលើសំណួរទាំងនោះប៉ុណ្ណោះ គាត់មិនមើល និងសិក្សាទៅលើសំណួរផ្សេងឡើយ។ ថ្ងៃប្រឡងមកដល់ សំណួរនៅក្នុងការប្រឡងជាក់ស្ដែងគឺខុសពីនោះ ព្រោះព័ត៌មានដែលបានបង្ហោះនៅលើអ៊ីនធឺណិតនោះ គឺជាព័ត៌មានមិនពិត ហើយទីបំផុតគាត់បានប្រឡងធ្លាក់។

ហេតុអ្វីបានជាពិសិដ្ឋប្រឡងធ្លាក់? តើអ្នកមានមតិយោបល់យ៉ាងណាសម្រាប់ពិសិដ្ឋ?

៦ សុភក្ដិបានអានវេបសាយរបស់គ្រូទាយមួយនៅលើអ៊ីនធឺណិត ដែលនិយាយថា មនុស្សប្រុសទាំងអស់មិនគួររៀបការឡើយនៅក្នុងឆ្នាំនេះ ព្រោះអ្នកដែលរៀបការនៅក្នុងឆ្នាំនេះ នឹងក្លាយទៅជាអ្នកក្រ ហើយមុំតូក៏ខូច គោក្របីក៏ឈឺ។ សុភក្ដិជឿលើគ្រូទាយនោះជាខ្លាំង ហើយប្រាប់ទៅមិត្តស្រីរបស់គាត់ថា គាត់មិនអាចរៀបការឆ្នាំនេះបានឡើយ។ មិត្តស្រីរបស់គាត់បានឆ្លើយតបថា នាងមិនអាចរង់ចាំក្នុងរយៈពេលមួយឆ្នាំទៀតបានទេ ហើយនាងក៏រកបានមិត្តប្រុសថ្មីដែលមិនជឿទៅលើការទស្សន៍ទាយនោះ រួចក៏រៀបការ រស់នៅជាមួយគ្នាយ៉ាងមានសុភមង្គល។ សម្រាប់សុភក្ដិ... គាត់មានសំណាងមិនល្អ ព្រោះគ្រូទាយមិនបានធ្វើបច្ចុប្បន្នភាពវេបសាយរបស់គាត់ ហើយនៅឆ្នាំបន្ទាប់គាត់ចូលទៅអាន ឃើញនៅមានការទស្សន៍ទាយដដែល... ហើយគាត់ក៏នៅតែមិនរៀបការដដែល។

ហេតុអ្វីបានជាសុភ័ក្ដិមិនបានរៀបការ? តើអ្នកយល់យ៉ាងណាចំពោះបញ្ហាសុភ័ក្ដិ?

## សំណួរត្រិះរិះ

១. តើអ៊ីនធឺណិតជាអ្វី ហើយវាបានផ្លាស់ប្ដូររបៀបទំនាក់ទំនងដូចម្ដេចខ្លះ?

២. តើអ្វីជា World Wide Web?

៣. ហេតុអ្វីបានជាយើងចាំបាច់ត្រូវអានដោយប្រុងប្រយ័ត្ន នូវព័ត៌មាននៅលើអ៊ីនធឺណិត និងការកំណត់អំពីប្រភពរបស់វា? ហេតុអ្វីបានជាសេរីភាពនៃការបញ្ចេញមតិសំខាន់?

៤. តើអ៊ីមែលសំខាន់ និងមានប្រយោជន៍នៅពេលណា?

៥. តើវិគីភីឌាជាអ្វី ហើយតើវាដំណើរការដូចម្ដេច?

៦. តើបណ្ដាញសង្គមអាចប៉ះពាល់ដល់ទំនាក់ទំនងពិតដូចម្ដេចខ្លះ? តើការប្រើប្រាស់អ៊ីនធឺណិតតាមរយៈទូរសព្ទទំនើប បានផ្លាស់ប្ដូររបត់សង្គមយើងដូចម្ដេចខ្លះ?

# មេរៀនទី ២

# បំណិនទំនាក់ទំនងក្នុងសម័យកាលឌីជីថល

## នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពីៈ

១. សារៈសំខាន់នៃទំនាក់ទំនងដោយវាចា និងមិនវាចាសម្រាប់ការបង្កើត និងការថែរក្សាទំនាក់ទំនង។

២. មូលហេតុចាំបាច់ដែលត្រូវដឹងអំពីរបៀបបកប្រែទំនាក់ទំនងដោយមិនវាចា។

៣. សារៈសំខាន់នៃការយល់ពីអារម្មណ៍ និងត្រិះរិះពិចារណា ។

៤. របៀបផ្តល់ និងទទួលមតិយោបល់ត្រឡប់។

៥. សារៈសំខាន់នៃជំនាញដោះស្រាយជំទាស់។

៦. ការកំណត់គុណភាពនៃក្រុមដែលមានប្រសិទ្ធភាពមួយ។

# ផ្នែក ក - ទម្រង់នៃទំនាក់ទំនង

## ១. បំណិនទំនាក់ទំនង



នៅក្នុងមេរៀននេះអ្នកនឹងតាមដានអំពីដំណើររឿងរបស់សិស្សម្នាក់ឈ្មោះ ចរណៃ មានអាយុ១៧ឆ្នាំ រៀននៅវិទ្យាល័យមួយក្នុងទីក្រុងភ្នំពេញ។ នាងកំពុងធ្វើការសម្រេចចិត្តអំពីជំនាញ ដែលត្រូវសិក្សានៅសាកលវិទ្យាល័យ ដើម្បីទទួលបានការងារនៅពេលអនាគត។ អ្នកនឹងអានអំពីការជួបប្រជុំរបស់នាងជាមួយ សុខ និងដួង ជាសិស្សពីរនាក់ដែលនាងបានស្គាល់កាលពីសិក្ខាសាលាមួយ។ អ្នកទាំងបីត្រូវបានជ្រើសរើសដោយនាយកសាលា ដើម្បីចូលរួមកម្មវិធីសិក្ខាសាលាចំនួនប្រាំថ្ងៃជាមួយអង្គការមិនមែនរដ្ឋាភិបាលមួយ (NGO)។ សិក្ខាសាលាមានឈ្មោះថា “ការស្ថាបនាអ្នកដឹកនាំអនាគត” ហើយត្រូវបានចូលរួមដោយសិស្សសាលាមកពីទូទាំងប្រទេសកម្ពុជា។

ក្នុងរយៈពេលបីសប្តាហ៍បន្ទាប់ សិស្សទាំងអស់ដែលបានចូលរួមកម្មវិធីពេលវិស្សមកាលនឹងត្រូវធ្វើបទបង្ហាញរយៈពេលពេញមួយថ្ងៃ។ ថ្ងៃនេះសិស្សទាំងបីនាក់ជួបប្រជុំគ្នានៅហាងកាហ្វេដើម្បីរៀបចំបទបង្ហាញដែលពួកគេនឹងត្រូវធ្វើជាមួយគ្នាសម្រាប់ព្រឹត្តិការណ៍នោះ។ ដួងនិយាយ “ឥឡូវនេះយើងដឹងហើយថាបទបង្ហាញរបស់យើងនឹងនិយាយអំពីបំណិនទំនាក់ទំនងដោយមិនវាចា ខ្ញុំគិតថាយើងគួរតែសម្រេចចិត្តឱ្យបានច្បាស់លាស់ ថាតើយើងនឹងជជែកអំពីបំណិននេះដូចម្តេចខ្លះ។ ខ្ញុំបានយកកុំព្យូទ័រយួរដៃរបស់ខ្ញុំមកដែរដើម្បីកត់ត្រា”។

សុខនិយាយ “ប្រសើរណាស់! ខ្ញុំបានគិតឃើញគំនិតមួយចំនួន។ ចុះបើយើងផ្តោតសំខាន់ទៅលើការបញ្ចេញទឹកមុខ កាយវិការ ក្រសែភ្នែកទាក់ទាញ និងការលើកដាក់សំឡេង តើអ្នកយល់យ៉ាងណាដែរ? វាគួរតែជាចំណុចដ៏ល្អសម្រាប់អ្នកទាំងអស់គ្នាពិនិត្យឡើងវិញ” ។

ចរណៃបន្ថែម “យើងអាចអភិវឌ្ឍសកម្មភាពដែលអ្នកទាំងអស់គ្នាចូលចិត្ត។ តើអ្នកនៅចាំទេថា យើងមានរឿងគួរឱ្យអស់សំណើចជាច្រើននៅពេលធ្វើសិក្ខាសាលា ពេលយើងព្យាយាមទំនាក់ទំនងដោយមិនប្រើពាក្យសម្តីនោះ?”

សុខឆ្លើយតបថា “វាគឺជាលំហាត់ដ៏គួរឱ្យភ្ញាក់ផ្អើលមែន” ។ ខ្ញុំនៅចាំថា យើងបានសើចយ៉ាងខ្លាំង នៅពេលដែលពិសិដ្ឋបានអនុវត្តចំលើសិក្ខាកាមដែលមានស្នេហានឹងគ្នា។ វាគួរឱ្យអស់សំណើចមែនទែន”។



ចរណៃញញឹម ហើយនិយាយថា "ពិតមែនហើយ នៅថ្ងៃនោះគាត់បានបញ្ជាក់យ៉ាងច្បាស់ថា សកម្មភាពអាចបង្ហាញច្បាស់ជាងពាក្យសម្ដីទៅទៀត" ។

ពួកយើងទាំងអស់ទាក់ទងគ្នាជារៀងរាល់ថ្ងៃ ប៉ុន្តែមានគ្នាយើងតិចតួចប៉ុណ្ណោះដែលបានសិក្សាពីរបៀបធ្វើឱ្យប្រសើរឡើងនូវបំណិនទំនាក់ទំនងបុគ្គល ឬរបៀបធ្វើជាអ្នកស្ដាប់ដ៏ពូកែម្នាក់។ បំណិនទាំងនេះអាចរៀនសូត្របាន ហើយចរណៃ និងសិស្សផ្សេងទៀតដែលបានចូលរួមសិក្ខាសាលាបានក្លាយទៅជាអ្នកទំនាក់ទំនងល្អប្រសើរជាងមុន។ ឥឡូវនេះដល់វេនអ្នកត្រូវសិក្សាអំពីបំណិនទំនាក់ទំនងដែលមានប្រសិទ្ធភាពហើយ។

យើងរស់នៅក្នុងសង្គមដែលពោរពេញទៅដោយចំណេះដឹង ហើយព័ត៌មានជាច្រើន គឺមានរួចស្រេចទៅហើយ។ មានមនុស្សមួយចំនួននិយាយថានេះជាសម័យកាលឌីជីថល សម័យកាលអេឡិចត្រូនិក សម័យកាលព័ត៌មាន ព្រោះចំនួនដ៏ច្រើននៃព័ត៌មាន គឺអាចមកដល់យើងភ្លាមៗតាមរយៈបច្ចេកវិទ្យាព័ត៌មាន។ ជាច្រើនឆ្នាំកន្លងទៅនេះ បច្ចេកវិទ្យាគឺបានផ្លាស់ប្ដូររបៀបទំនាក់ទំនងរបស់យើង។ ចំណែកឯមនុស្សអាចនឹងសរសេរសំបុត្រ អានសៀវភៅ ឬអានកាសែតដើម្បីទទួល និងផ្លាស់ប្ដូរព័ត៌មានក្នុងពេលអតីតកាល។ បច្ចុប្បន្ននេះពួកគេអាចប្រើអ៊ីមែល សារអត្ថបទ ការហៅទូរសព្ទ និងអ៊ីនធឺណិតធ្វើជាវិធីសាស្ត្រទំនាក់ទំនង។ មនុស្សជាច្រើននិយាយទៅកាន់គ្នាតិចជាងសរសេរប៉ុណ្ណោះ ប៉ុន្តែការសរសេរតែងតែជាសេចក្ដីព្រាង ហើយមិនអាចផ្ដល់នូវសារជាក់លាក់ល្អដូចដែលពួកគេចង់បានឡើយ។ ទំនាក់ទំនងល្អគឺជាមូលដ្ឋាននៃការទាក់ទងដែលជោគជ័យ។ យើងត្រូវមានជំនាញទំនាក់ទំនងបុគ្គលល្អ (បំណិនទន់) ក៏ដូចជាជំនាញបច្ចេកទេសផងដែរ (បំណិនរឹង) នៅក្នុងបរិស្ថានការងារ និងបរិស្ថានបុគ្គលប្រចាំថ្ងៃ។

នៅក្នុងសៀវភៅបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ថ្នាក់ទី១១ អ្នកបានសិក្សារួចហើយថា ទំនាក់ទំនង គឺជាដំណើរនៃការផ្ទេរព័ត៌មានពីស្ថាប័នមួយទៅស្ថាប័នមួយទៀតតាមរយៈទិន្នន័យ គំនិតយោបល់ ឬអារម្មណ៍។ ទម្រង់ទំនាក់ទំនងមានពីរគឺ៖ ទំនាក់ទំនង វាចា និងទំនាក់ទំនង មិនវាចា។ ទំនាក់ទំនងដោយវាចា អាចមានទាំងពាក្យសម្ដី និងពាក្យសរសេរ។ ជាឧទាហរណ៍គឺការនិយាយពាក្យថា "បាទ/ចាស" ឬ "ទេ" នៅពេលអ្នកឆ្លើយតបសំណួររបស់នរណាម្នាក់។ ទំនាក់ទំនងដោយវាចាអាចជាការនិយាយទល់មុខ តាមទូរសព្ទ តាមវិទ្យុ ទូរទស្សន៍ ឬតាមប្រព័ន្ធផ្សាយ (មេឌា) ផ្សេងទៀតដូចជាកាសែត អ៊ីមែល អ៊ីនធឺណិត ឬតាមបណ្ដាញសង្គមហ្វេសប៊ុក (Facebook)។ ទំនាក់ទំនងដោយមិនវាចា គឺជាអាកប្បកិរិយា ឬសកម្មភាពដែលមិនប្រើពាក្យសម្ដី វាមានដូចជាកាយវិការ ការបញ្ចេញទឹកមុខ ក្រសែភ្នែក លក្ខណៈរាងកាយ និងការលើកដាក់សំឡេង។ ឧទាហរណ៍នៃទំនាក់ទំនងដោយមិនវាចាមានដូចជាការញញឹម ឬការធ្វើមុខក្រញូវ។



# ១.១. ទំនាក់ទំនងដោយវាចា

អ្នកអាចស្គាល់មនុស្សជាច្រើនដែលនិយាយ ឬសរសេរមិនបានល្អ ជាពិសេសក្នុងចំណោមពួកគេដែលមិនមានឱកាសបញ្ចប់ការសិក្សានៅសាលា។ មិនមានអ្វីឆ្ងល់ទ្បើយដែលថាការអប់រំនៅតាមសាលារៀនសាធារណៈអាចធ្វើឱ្យជំនាញសរសេរ និងជំនាញនិយាយវាចាប្រសើរឡើងនោះ។ ថ្វីបើពួកគេបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យក៏ដោយ ក៏ពួកគេអាចមិនមែនជាអ្នកនិយាយ ឬជាអ្នកសរសេរដែលមានទំនុកចិត្តដែរ ព្រោះពួកគេមិនមានភាពប្រាកដអំពីភាសាដែលពួកគេនឹងត្រូវប្រើក្នុងទំនាក់ទំនងបែបវិជ្ជាជីវៈ ហើយការអនុវត្តអាចជួយពួកគេបានគឺ ពេលណាអ្នកអនុវត្តសរសេរកាន់តែច្រើន ការសរសេររបស់អ្នកគឺនឹងកាន់តែប្រសើរឡើងដែរ ហើយនៅពេលណាអ្នកមានទំនាក់ទំនងដោយប្រើសម្តីកាន់តែច្រើន អ្នកនឹងមានទំនុកចិត្តកាន់តែខ្លាំង។ ជាមួយទំនាក់ទំនងដោយវាចា អ្នកនឹងមានឱកាសចូលរួមក្នុងការសន្ទនា ការពិភាក្សា ការនិយាយក្នុងកិច្ចប្រជុំ ឬការធ្វើបទបង្ហាញជាដើម។ មនុស្សមួយចំនួនហាក់ខ្លាចការនិយាយក្នុងទីសាធារណៈ ទោះយ៉ាងណាសម្រាប់អ្នកដែលសម្រេចចិត្តពុះពារសេចក្តីខ្លាចនោះបាន ហើយចាប់យកឱកាសធ្វើបទបង្ហាញ គឺតែងតែបានក្លាយទៅជាអ្នកនិយាយដ៏ល្អឥតខ្ចោះ។

> *អ៊ីមែលបានក្លាយទៅជាមធ្យោបាយដ៏សំខាន់សម្រាប់សហសេវិកក្នុងការទំនាក់ទំនងគ្នានៅកន្លែងធ្វើការ បើទោះបីជាវាមិនអាចជំនួសទំនាក់ទំនងដោយជួបមុខផ្ទាល់ក៏ដោយ។*

ទម្រង់នៃទំនាក់ទំនងជាសំណេរមួយចំនួនដូចជាសារអត្ថបទ (SMS) និងអ៊ីមែលគឺជាសេចក្តីព្រាង ហើយតែងតែធ្វើឡើងដោយកាត់ៗ។ SMS គឺជាអត្ថបទសារដែលត្រូវបានផ្ញើ និងទទួលនៅលើឧបករណ៍ចល័ត ហើយបានប្រើទាំងនៅក្នុងការងារ និងផ្ទាល់ខ្លួន ជាពិសេសគឺយុវជន។ សារអ៊ីមែលជាទូទៅត្រូវបានផ្ញើចេញពីកុំព្យូទ័រទៅកុំព្យូទ័រ។ រវាងមិត្តភក្តិនិងមិត្តភក្តិវាគឺជាសារអ៊ីមែលធម្មតា ប៉ុន្តែសារអ៊ីមែលសម្រាប់កន្លែងធ្វើការគឺត្រូវមានលក្ខណៈផ្លូវការ និងជាទម្រង់ធុរកិច្ចច្រើនជាង។

ទំនាក់ទំនងជាសំណេរ គឺជាទម្រង់ទូទៅបំផុតសម្រាប់ការទាក់ទងធុរកិច្ច។ វា គឺចាំបាច់សម្រាប់អ្នកគ្រប់គ្រងក្នុងការអភិវឌ្ឍជំនាញទំនាក់ទំនងជាសំណេរឱ្យមានប្រសិទ្ធភាព និងលើកទឹកចិត្តតាមវិធីដូចគ្នាសម្រាប់បុគ្គលិករបស់ខ្លួន។ ភាពកើនឡើងនៃការប្រើប្រាស់បច្ចេកវិទ្យាដើម្បីគ្រប់គ្រង និងបញ្ជូនព័ត៌មាន គឺមានន័យថាជាការកើនឡើងនៃតម្រូវការ សម្រាប់សមាសភាគនៃជំនាញក្នុងការសរសេរ។ ដើម្បីសរសេរបានល្អ គឺលុះត្រាតែយើងមានការព្យាយាម ហើយយើងអាចក្លាយទៅជាអ្នកសរសេរល្អបាន តាមរយៈការធ្វើឱ្យប្រសើរទៅលើវាក្យសព្ទ និងវេយ្យាករណ៍ ដោយលៃតម្រូវវាទៅតាមអ្វីដែលបានរំពឹងទុកនៅក្នុងបរិស្ថានការងារធុរកិច្ច។ ដើម្បីបង្កើតការយល់ឃើញវិជ្ជមានសម្រាប់ការសរសេររបស់យើង យើងគួរតែសង្ខេប និងកំណត់វាឱ្យបានច្បាស់លាស់ ត្រូវទៅតាមប្រធានបទ ត្រូវតាមក្បួនវេយ្យាករណ៍ ពិនិត្យអក្ខរាវិរុទ្ធ និងសញ្ញាវណ្ណយុត្ត រក្សាសំឡេងវិជ្ជមាន និងសមស្របតាមអត្ថន័យ ចៀសវាងការប្រើភាសាស្និទ្ធស្នាលពេក និងគ្រាមភាសា។ ការឆ្លើយឆ្លងមិនសមរម្យគឺឆ្លុះបញ្ចាំងអំពីកង្វះខាតនៃការប្រុងប្រយ័ត្ន និងកង្វះខាតសមត្ថភាព ហើយបង្ហាញអំពីរូបភាពមិនល្អចំពោះខ្លួនឯង និងស្ថាប័នដែលយើងធ្វើការឱ្យនោះទៀតផង។

វាក៏ចាំបាច់ផងដែរក្នុងការអានឡើងវិញ នូវការងារទាំងអស់របស់យើងមុនពេលដាក់ស្នើ ឬបញ្ជូនវា។ សម្រាកបន្តិច រួចអានឡើងវិញ គឺជួយឱ្យអ្នកសរសេរអាចរកឃើញកំហុសនៃការសរសេរ នៅពេល

ដែលពួកគេមើលឡើងវិញ និងកែសម្រួលអត្ថបទរបស់ខ្លួន។ មនុស្សមួយចំនួនគិតថាសំណេរដែលល្អគឺជាសំណេរដែលប្រើនូវវាក្យសព្ទ និងគំនិតស្មុគស្មាញ ប៉ុន្តែតាមការពិតការរក្សាសារអត្ថបទឱ្យមានលក្ខណៈសាមញ្ញ គឺជាវិធីល្អបំផុតក្នុងការទំនាក់ទំនងដែលមានប្រសិទ្ធភាព។

> *ពាក្យដែលយើងសរសេរគឺតំណាងឱ្យខ្លួនយើង ដូច្នេះយើងចាំបាច់ត្រូវប្រាកដថាយើងកំពុងផ្ញើចេញនូវសារដែលត្រឹមត្រូវ។*

ពេលយើងសរសេរ យើងត្រូវបង្ហាញនូវអត្ថន័យពិតប្រាកដ និងសង្ខេបជាមួយនឹងការលើកដាក់សំឡេងសមរម្យ។ អត្ថបទដែលមានន័យមិនច្បាស់លាស់អាចនាំឱ្យមានការបកស្រាយខុស ហើយប្រសិនបើវាមិនច្បាស់ វានឹងក្លាយទៅជាសារអត្ថបទដែលគ្មានវត្ថុបំណង។ ឧទាហរណ៍ ប្រសិនបើមិត្តរបស់អ្នកផ្ញើសារមកថា "សង្ឃឹមថាជួបគ្នាក្រោយចេញពីសាលា" អ្នកអាចនឹងឆ្លើយតបថា "បានតើ! នៅម៉ោងប៉ុន្មាន?" បន្ទាប់មកប្រសិនបើមិត្តរបស់អ្នកមិនឆ្លើយតបវិញទេ អ្នកអាចនឹងមានអារម្មណ៍យល់ច្រឡំ ខឹង ហើយវាគឺប៉ះពាល់អារម្មណ៍របស់អ្នកទៀតផង។ សារដែលគ្មានវត្ថុបំណងគឺថាអ្នកមិនសំខាន់ ហើយពេលខ្លះមិត្តរបស់អ្នកមិនមានបំណងធ្វើឱ្យប៉ះពាល់អារម្មណ៍របស់ឡើយ នេះជាអ្វីដែលបានកើតឡើង។ មនុស្សគឺឆាប់ទទួលអារម្មណ៍ណាស់ ដូច្នេះយើងត្រូវមានការប្រុងប្រយ័ត្ននៅពេលទំនាក់ទំនងជាមួយពួកគេ។

ទំនាក់ទំនងជាសំណេរ គឺជាអត្ថន័យអចិន្ត្រៃយ៍នៃការទាក់ទង ព្រោះសំបុត្រ និងអ៊ីមែល គឺអាចត្រូវបានរក្សាទុក ហើយផ្តល់ជាកំណត់ត្រាសម្រាប់ធ្វើជាឯកសារយោង។ ដោយសារតែវានៅជាប់ជាអចិន្ត្រៃយ៍ ដូច្នេះអ្វីៗដែលអ្នកបានសរសេរពេលអ្នកមានអារម្មណ៍មិនល្អ អាចជះឥទ្ធិពលដល់ទំនាក់ទំនងការងារ ឬទំនាក់ទំនងផ្ទាល់ខ្លួនរបស់អ្នក។ ឧទាហរណ៍ នៅពេលអ្នកកំពុងខឹង យកល្អអ្នកគួរតែកុំទាន់សរសេរ និងផ្ញើសារ គឺត្រូវរង់ចាំរហូតដល់អ្នកត្រជាក់ចិត្តវិញ។ នេះជាការពិតជាមួយសារអ៊ីមែលដែលងាយនឹងមានការយល់ច្រឡំ ហើយឆ្លើយតបវិញយ៉ាងរហ័សនោះ។ ទំនាក់ទំនងស្ថាប័នជាច្រើនត្រូវបានបែកបាក់ដោយសារតែការឆ្លើយតបអ៊ីមែលប្រញាប់ប្រញាល់ពេក ហើយអ្នកផ្ញើគឺមានការស្តាយក្រោយជាខ្លាំង។ ការថែរក្សាទំនាក់ទំនងសហប្រតិបត្តិការគឺងាយស្រួលជាងការជួសជុលទំនាក់ទំនងដែលបានបែកបាក់។

ទំនាក់ទំនងដោយការនិយាយស្តី ឬទំនាក់ទំនងដោយវាចា គឺជាដំណើរនៃការបង្ហាញអំពីគំនិត ឬព័ត៌មានដោយការជជែកគ្នា។ វាពាក់ព័ន្ធនឹងការសួរសំណួរ ការពន្យល់អំពីគំនិត ឬព័ត៌មាន ឬការប្រាប់ទិសដៅ។ ឧទាហរណ៍អំពីទំនាក់ទំនងដោយវាចាជាផ្លូវការមួយគឺ ការសន្ទនាដោយជួបមុខផ្ទាល់ ឬតាមទូរសព្ទ និងការពិភាក្សាជាមួយគ្រួសារ ឬមិត្តភក្តិ។ ប្រភេទទំនាក់ទំនងដោយវាចាជាផ្លូវការច្រើនទៀតដូចជាការធ្វើបទបង្ហាញដែលបានរៀបចំ គ្រូបង្រៀននៅក្នុងថ្នាក់ និងសុន្ទរកថាសម្រាប់ពិធីផ្សេងៗ។ បច្ចេកវិទ្យា



កុំព្យូទ័រអាចធ្វើឱ្យវាផ្សំបញ្ចូលគ្នាបានរវាងវីដេអូ និងសំឡេងមនុស្សនៅឆ្ងាយពីគ្នា និងនៅកន្លែងផ្សេងគ្នា ហើយអាចមើលឃើញ និងនិយាយរកគ្នាទៅវិញទៅមកបានតាមរយៈសន្និសីទវីដេអូ ដោយប្រើកម្មវិធីមួយចំនួនដូចជា Skype ឬ Viber ។

មានស្ថានការណ៍ជាច្រើនដែលសមរម្យអាចឱ្យយើងជ្រើសយកទំនាក់ទំនងដោយវាចា ជាជាងការសរសេរអក្សរ។ ពេលដែលពេលវេលាមានកំណត់ ហើយត្រូវការពិភាក្សារហ័ស ទំនាក់ទំនងជួបមុខគ្នាផ្ទាល់ ឬតាមទូរសព្ទគឺជាវិធីល្អបំផុត។ ទំនាក់ទំនងដោយវាចាគឺមានភាពបត់បែនច្រើនជាង និងស្វាហាប់ជាងទំនាក់ទំនងជាសំណេរ ព្រោះអ្នកនិយាយអាចពិភាក្សាអំពីស្ថានការណ៍ សួរ និងឆ្លើយសំណួរបាន។ ទំនាក់ទំនងដោយវាចាជាទូទៅគឺជាវិធីដ៏ល្អបំផុតសម្រាប់ការដោះស្រាយការយល់ច្រឡំ ឬការផ្សះផ្សាការខ្វែងគំនិតគ្នា ព្រោះវាផ្ដល់នូវឱកាសដើម្បីជជែកគ្នាអំពីរឿងនោះ។ ដូចគ្នានេះដែរ ទំនាក់ទំនងដោយវាចាគឺជាមធ្យោបាយដើម្បីស្ថាបនាទំនាក់ទំនងមិត្តភាព ឬទំនាក់ទំនងផលិតកម្ម។ ពេលយើងនិយាយទល់មុខគ្នា យើងនឹងមានឱកាសទទួលបានអត្ថប្រយោជន៍ទាំងទំនាក់ទំនងដោយវាចា និងមិនវាចា។



# ១.២. ទំនាក់ទំនងដោយមិនវាចា

មានអ្នកស្រាវជ្រាវជាច្រើនបានបង្ហាញអំពីសារៈសំខាន់ នៃទម្រង់ទំនាក់ទំនងដោយមិនវាចារបស់សារ ដោយពួកគេអះអាងថា ច្រើនជាងពាក់កណ្ដាល និងរហូតដល់ទៅ៦៥%នៃព័ត៌មានត្រូវបានផ្លាស់ប្ដូរគ្នាតាមរយៈការសន្ទនាដោយភាសាកាយវិការ។ របៀបដែលអ្នកស្ដាប់ ការធ្វើចលនា ការសម្លឹងមើល និងការប្រតិកម្មតប គឺប្រាប់អ្នកដទៃថាតើអ្នកជាមនុស្សដែលមានទំនុកចិត្ត ឬមិនមានទំនុកចិត្ត និងថាតើអ្នកអាចស្ដាប់បានកម្រិតណា ប្រសិនបើអ្នកយកចិត្តទុកដាក់នោះ។ នៅពេលដែលភាសាមិនវាចារបស់ត្រូវគ្នាជាមួយពាក្យដែលអ្នកកំពុងនិយាយ នោះទំនុកចិត្ត ការប្រាស្រ័យទាក់ទង និងភាពច្បាស់លាស់នឹងត្រូវបានកើនឡើង ហើយប្រសិនបើវាមិនត្រូវគ្នាវិញ ភាពមិនទុកចិត្ត ភាពតានតឹង និងការយល់ច្រឡំនឹងត្រូវបានកើតឡើង។

អ្នកទំនាក់ទំនងដែលមានប្រសិទ្ធភាព គឺងាយក្នុងការចាប់បាននូវភាសាកាយវិការ និងតម្រុយមិនវាចារបស់អ្នកដទៃ។ ពួកគេក៏ប្រើប្រាស់ផងដែរនូវភាសាកាយវិការរបស់ខ្លួនដើម្បីពង្រឹងដល់សារអត្ថបទវាចារបស់ពួកគេ។ មនុស្សដែលមានជោគជ័យក្នុងជំនួញ ជាទូទៅគឺជាអ្នកទំនាក់ទំនងដែលមានប្រសិទ្ធភាព ព្រោះពួកគេបានសិក្សាពីរបៀប "អាន" ភាសាកាយវិការរបស់មនុស្ស ហើយប្រតិកម្មតបយ៉ាងត្រឹមត្រូវ។ ការទាក់ទងនៅក្នុងទំនាក់ទំនងដោយមិនវាចា គឺពង្រឹងដល់ទំនាក់ទំនងដោយវាចាឱ្យមានទំនុកចិត្ត និងការយល់ពីអារម្មណ៍ក្នុងកម្រិតខ្ពស់ ហើយពួកគេនឹងខ្លាំង ហើយអាចនឹងខ្លាំងបំផុតទៀតផង។

> ទំនាក់ទំនងដោយមិនវាចារបស់យើងនិយាយឮខ្លាំងជាងពាក្យដែលយើងនិយាយ។



តើកាយវិការនេះមានន័យដូចម្ដេច ? នៅសហរដ្ឋអាមេរិក វាមានន័យថាជ័យជំនះ ឬសន្តិភាព។

## កាយវិការ

កាយវិការ គឺជាចលនារបស់រាងកាយ ជាពិសេសក្បាល និងដៃដែលបញ្ជាក់អំពីគំនិត និងអត្ថន័យ។ យើងប្រើកាយវិការនៅពេលយើងបក់ដៃ ចង្អុល ឬស្វាគមន៍អ្នកដទៃ ពេលខ្លះយើងប្រើទំនាក់ទំនងដោយវាចាដំណាលគ្នាជាមួយកាយវិការ។ ឧទាហរណ៍ ការងក់ក្បាលរបស់យើងគឺជាកាយវិការមួយ បញ្ជាក់ថាយើងយល់ព្រម ឬចាប់អារម្មណ៍ទៅលើអ្វីដែលគេកំពុងនិយាយ។ អត្ថន័យ និងការបកប្រែនៃកាយវិការជាក់លាក់គឺខុសគ្នាទៅតាមវប្បធម៌នីមួយៗ អ្នកចាំបាច់ត្រូវយកចិត្តទុកដាក់លើវាឱ្យបានច្រើន ដើម្បីចៀសវាងការបកប្រែខុស ឬនាំឱ្យខូចកេរ្តិ៍ឈ្មោះ។ សព្វថ្ងៃពាណិជ្ជកម្មគឺមានលក្ខណៈជាសាកល ដូច្នេះកំហុសក្នុងការទាក់ទងតាមរយៈកាយវិការអាចប៉ះពាល់ និងធ្វើឱ្យបាត់បង់ឱកាសធ្វើពាណិជ្ជកម្មរបស់យើង។

## ការសម្ដែងទឹកមុខ

**ការសម្ដែងទឹកមុខ** គឺជាផ្នែកសំខាន់នៃទំនាក់ទំនង។ ទឹកមុខរបស់មនុស្សគឺសម្ដែងចេញយ៉ាងច្បាស់ដែលអាចឱ្យយើងវាយតម្លៃពីអារម្មណ៍ពិត ដោយមិនចាំបាច់ធ្វើអ្វីច្រើនឡើយ។ ចំណែកឯទម្រង់ផ្សេងទៀតនៃទំនាក់ទំនងដោយមិនវាចា គឺផ្អែកលើវប្បធម៌ ហើយការបញ្ចេញទឹកមុខមានលក្ខណៈជាសាកល។ ការបញ្ចេញទឹកមុខអំពីភាពសប្បាយរីករាយ ការមានទុក្ខព្រួយ ការមានកំហឹង ភាពភ្ញាក់ផ្អើល ក្ដីបារម្ភ និងភាពភ័យខ្លាចគឺដូចគ្នាសម្រាប់គ្រប់វប្បធម៌ទាំងអស់។ យើងអាចឃើញភាពជាក់ស្ដែងនៃសកម្មភាពទាំងនេះដូចជា "មុខញញឹម" ឬរូបសញ្ញាអារម្មណ៍នៅលើអ៊ីនធឺណិត ដែលមនុស្សប្រើវាសម្រាប់គ្រប់វប្បធម៌ទាំងអស់ដើម្បីបង្ហាញពីអារម្មណ៍ដូចគ្នា។

សូមមើលឧទាហរណ៍ខ្លះៗទាំងនេះ។ តើវាងាយស្រួល ឬលំបាកសម្រាប់អ្នកដឹងពីអារម្មណ៍បានត្រឹមត្រូវ ?



## ក្រសៃភ្នែកទាក់ទាញ

**ក្រសៃភ្នែកទាក់ទាញ** គឺជាប្រភេទពិសេសមួយនៃទំនាក់ទំនងដោយមិនវាចា។ វាគឺចាំបាច់ក្នុងការថែរក្សាលំហូរនៃការសន្ទនា និងការកំណត់អំពីការឆ្លើយតបរបស់អ្នកដទៃ។ នៅក្នុងទំនាក់ទំនងពាណិជ្ជកម្ម ក្រសៃភ្នែកគឺពិតជាសំខាន់ខ្លាំងណាស់ ព្រោះវាអាចបង្ហាញអំពីការចាប់អារម្មណ៍ ភាពធុញទ្រាន់ ឬការជំទាស់។ ក្រសៃភ្នែកល្អមានន័យថាជាការមើលទៅកាន់មនុស្សក្នុងរយៈពេលគ្រប់គ្រាន់ ដើម្បីឱ្យប្រាកដថាមនុស្សនោះកំពុងយកចិត្តទុកដាក់ និងយល់បាន។ វាគឺប្រើពេលប្រហែល១០វិនាទី ដោយមើលយ៉ាងពិតប្រាកដ ប៉ុន្តែបើយើងសម្លឹងដោយមិនដាក់ភ្នែកវិញ គឺយើងនឹងបំភ័យដល់អ្នកដទៃហើយ។ នៅក្នុងវប្បធម៌ខ្លះ ការសម្លឹងមើលដោយក្រសៃភ្នែកផ្ទាល់ ត្រូវបានចាត់ទុកថាជាភាពមិនសមរម្យនៅក្នុងសង្គម ជាពិសេសរវាងបុរស និងស្ត្រី ហើយវាគឺងាយប៉ះពាល់ ដូច្នេះយើងត្រូវតែដឹងអំពីវា។ នៅក្នុងការធ្វើបទបង្ហាញជាក្រុម វាគឺចាំបាច់ក្នុងការគ្រប់គ្រងក្រសៃភ្នែកទៅកាន់អ្នកទាំងឡាយដែលចូលរួមស្ដាប់។ វាគ្មិនចាំបាច់ត្រូវក្រឡេកមើលទៅកាន់មនុស្សនីមួយ ដូច្នេះគ្មាននរណាម្នាក់មានអារម្មណ៍ថានៅក្រៅឡើយ។ វាគ្មិនដែលមើលទៅ

ក្រៅ ឬឱនមុខចុះនៅពេលធ្វើបទបង្ហាញ ត្រូវបានគេគិតថាជាមនុស្សមិនគួរឱ្យទុកចិត្ត ឬខ្វះទំនុកចិត្តចំពោះខ្លួនឯង។ នេះជាមូលហេតុដែលអ្នកធ្វើបទបង្ហាញ គួរតែអានកំណត់ចំណាំនៅមុនពេលធ្វើបទបង្ហាញ។



## ឥរិយាបថរាងកាយ

**ឥរិយាបថរាងកាយ** សំដៅទៅលើរបៀបអង្គុយ ឈរ ដើរ ឬការងក់ក្បាល។ របៀបដែលយើងផ្លាស់ទី ឬធ្វើចលនាខ្លួនប្រាណរបស់យើង គឺផ្ដល់ជាសញ្ញាព័ត៌មានចំពោះអ្នកដទៃ។ ឧទាហរណ៍មនុស្សដែលដើរលឿន ហើយអង្គុយត្រង់ខ្លួន បញ្ជាក់ថាគាត់ជាមនុស្សដែលមានទំនុកចិត្ត និងគួរឱ្យជឿជាក់បាន ចំណែកឯមនុស្សដែលដើរយឺតៗ ហើយឱនស្មាគឺអាចបញ្ជាក់បានថាគាត់ជាមនុស្សកំសាក និងមិនគួរឱ្យទុកចិត្តឡើយ។ នៅក្នុងការសម្ភាសន៍ការងារ បេក្ខជនដែលមើលទៅគួរឱ្យមានទំនុកចិត្ត គឺនឹងត្រូវទទួលបានការងារច្រើនជាង។ ភាពមានទំនុកចិត្តលើខ្លួនឯងនេះហើយ គឺជាផ្នែកសំខាន់មួយដែលនាំឱ្យចរណៃត្រូវបានជ្រើសរើសជាអ្នកដឹកនាំសិក្ខាសាលា។ ឧទាហរណ៍ផ្សេងទៀតអំពីឥរិយាបថវិជ្ជមានដូចជាការសិក្សាចំពោះមុខ និងការនៅទល់មុខជាមួយមនុស្សដែលអ្នកកំពុងនិយាយជាមួយ ព្រោះវាបញ្ជាក់អំពីចំណាប់អារម្មណ៍ទៅលើអ្វីដែលពួកគេកំពុងនិយាយ។ ប្រសិនបើអ្នកនិយាយដោយឱបដៃ ឬអង្គុយនៅលើកៅអី អ្នកនឹងបង្ហាញថាអ្នកកំពុងមានអារម្មណ៍តានតឹង ចង្អៀតចង្អល់ ឬគ្មានទំនុកចិត្ត។ ហើយប្រសិនបើអ្នកឈរដោយយកដៃច្រត់ចង្កេះ នោះគេនឹងគិតថាអ្នកកំពុងខឹង ឬមិនយល់ស្របជាមួយពួកគេ។

## ការប៉ះ

**ការប៉ះ** គឺជាទម្រង់ដ៏មានអានុភាពនៃទំនាក់ទំនង។ យើងប៉ះមិត្តភ័ក្តិជិតស្និទ្ធរបស់យើង ប៉ុន្តែយើងមិនប៉ះសហសេវិករបស់យើងនៅកន្លែងធ្វើការឡើយ ព្រោះការប៉ះអាចជាឥរិយាបថមិនគួរសម។ ការប៉ះគឺជាទម្រង់ផ្សេងមួយទៀតនៃទំនាក់ទំនង ហើយវាខុសគ្នាទៅតាមវប្បធម៌នីមួយៗ។ នៅក្នុងវប្បធម៌ខ្លះ មនុស្សថើបថ្ពាល់គ្នាពេលជួបស្វាគមន៍ ខណៈដែលវប្បធម៌ផ្សេងពួកគេគឺចាប់ដៃ ហើយនៅក្នុងប្រទេសកម្ពុជាយើងអាចស្វាគមន៍គ្នាដោយសំពះ ជាជាងការប៉ះ។ បើអ្នកចង់បង្កើតមិត្តភាពអន្តរជាតិ ឬធ្វើការនៅក្នុងស្ថាប័នចម្រុះវប្បធម៌ អ្នកនឹងត្រូវសិក្សាអំពីអ្វីដែលសមរម្យទាំងនេះ។



ប្រសិនបើអ្នកមិនចង់ប៉ះ ឬប៉ះពីអ្នកដទៃ នោះអ្នកគឺត្រូវធ្វើ និងគោរពតាមគំរូស្វាគមន៍របស់អ្នកផ្ទាល់។ អ្នកមិនតម្រូវឱ្យថើប ឬថើបពីអ្នកដទៃឡើយ បើទោះបីជាវាត្រូវធ្វើ នៅក្នុងប្រទេសដែលអ្នកកំពុងទស្សនាក៏ដោយ។

### ការលើកដាក់សំឡេង

ការលើកដាក់សំឡេង គឺសំដៅទៅលើរបៀបនិយាយ មិនមែនត្រឹមតែពាក្យដែលយើងនិយាយនោះទេ។ មនុស្សស្តាប់យើងហើយកំណត់អំពីភាពជឿជាក់របស់យើង។ រយៈពេល ល្បឿន កម្រិតឮដែលយើងនិយាយ និងសំឡេងដូចជា "អ្ហា" ឬ "អ្ហូ" គឺសុទ្ធតែបញ្ជាក់ន័យ។ ការលើកដាក់សំឡេងរបស់មនុស្សអាចបង្ហាញអំពីភាពជឿជាក់ ភាពច្បាស់លាស់ កំហឹង ភាពអត់ធ្មត់ ឬសុឆន្ទៈ។ មនុស្សដែលប្រើការលើកដាក់សំឡេងស្រទន់ គឺទំនងជាមានជោគជ័យទាំងក្នុងការសិក្សា និងការងារច្រើនជាងមនុស្សដែលប្រើសំឡេងខ្លាំងៗ ហើយគ្មានការយកចិត្តទុកដាក់ ឬគ្មានទំនុកចិត្ត។

*ត្រូវចងចាំថាការលើកដាក់សំឡេងមិនត្រឹមត្រូវអាចនាំឱ្យខូចសារអត្ថបទរបស់យើង និងអាចប៉ះពាល់ដល់ទំនាក់ទំនងទៀតផង ចំណែកឯការលើកដាក់សំឡេងត្រឹមត្រូវវិញគឺធ្វើឱ្យមានភាពជឿជាក់ ទុកចិត្ត ហើយទំនាក់ទំនងកាន់តែមានភាពប្រសើរជាងមុន។*

អ្នកប្រហែលជាធ្លាប់ឮពាក្យថា "អ្នកនឹងមិនមានឱកាសលើកទីពីរដើម្បីធ្វើឱ្យមានចំណាប់អារម្មណ៍ដំបូងឡើយ"។ នេះមានន័យថាមនុស្សមានអារម្មណ៍មកលើយើងពេលពួកគេជួបលើកដំបូង ហើយពួកគេធ្វើការវាយតម្លៃ។ អ្នកនឹងធ្វើដូចគ្នានៅពេលដែលអ្នកត្រូវបានណែនាំឱ្យស្គាល់មនុស្សថ្មី។ ថ្វីបើទំនាក់ទំនងដោយវាចា និងមិនវាចាគឺសំខាន់ទាំងពីរ ប៉ុន្តែនៅក្នុងជំនួបលើកដំបូង ទំនាក់ទំនងដោយមិនវាចារបស់អ្នកដើរតួនាទីសំខាន់ជាង ទំនាក់ទំនងដោយវាចា។ ដើម្បីបង្កើតចំណាប់អារម្មណ៍លើកដំបូងវិជ្ជមាន អ្នកត្រូវស្លៀកពាក់ឱ្យបានសមរម្យ ក្រសែភ្នែកល្អ ញញឹម គិតវិជ្ជមាន យកចិត្តទុកដាក់ និងមានទំនុកចិត្តលើខ្លួនឯង។

ទំនាក់ទំនងដោយមិនវាចា និងភាសាកាយវិការគឺបង្ហាញពីអត្តចរិត។ អត្តចរិតបើកទូលាយគឺជាកត្តាគន្លឹះនាំទៅរកភាពជោគជ័យក្នុងជីវិត។ អាកប្បកិរិយារបស់អ្នកគឺសម្តែងចេញយ៉ាងច្បាស់នៅក្នុងទំនាក់ទំនងដោយមិនវាចា។ នៅពេលអ្នកស្វាគមន៍មនុស្សក្នុងផ្លូវវិជ្ជមាន ពួកគេក៏ឆ្លើយតបមកអ្នកវិញក្នុងផ្លូវវិជ្ជមានដែរ។ ពេលអ្នកបង្ហាញនូវភាពសាទរតាមរយៈកាយវិការ ការលើកដាក់សំឡេង និងការបញ្ចេញទឹកមុខ មនុស្សនឹងគិតវិជ្ជមានអំពីអ្នក។ អ្នកអាចសិក្សាដើម្បីគ្រប់គ្រងអាកប្បកិរិយា កែសម្រួលទំនាក់ទំនងដោយមិនវាចា និងភាសាកាយវិការរបស់អ្នក។ វាគឺចាំបាច់ដែលត្រូវផ្តោតអារម្មណ៍យ៉ាងពិតប្រាកដនៅក្នុងប្រធានបទរបស់អ្នក ជាជាងធ្វើពុតជាស្មោះត្រង់។ ភាសាកាយវិការនឹងបង្ហាញអំពីការពិត។

## ២. ការយល់ពីអារម្មណ៍ និងត្រិះរិះពិចារណា

មានហេតុផលជាច្រើនដែលនាំឱ្យយើងទាក់ទងគ្នា។ យើងចង់ចែករំលែកគំនិត ស្វែងរក និងផ្តល់ព័ត៌មាន បញ្ចុះបញ្ចូល បង្ហាញពីអារម្មណ៍ ឬបង្កើត និងស្ថាបនាមិត្តភាព។

មានមនុស្សមួយចំនួនហាក់មាននិស្ស័យពីធម្មជាតិជាមួយជំនាញទំនាក់ទំនងរបស់ពួកគេ។ អ្នកផ្សេងទៀតចាំបាច់ត្រូវអនុវត្ត និងសិក្សាបន្ថែម ដើម្បីក្លាយទៅជាអ្នកទំនាក់ទំនងប្រសើរ។

អ្នកស្រាវជ្រាវបានកំណត់ថាមានជំនាញទំនាក់ទំនងមួយចំនួន ដែលយើងចាំបាច់ត្រូវអភិវឌ្ឍដើម្បីក្លាយទៅជាអ្នកទំនាក់ទំនងឥតខ្ចោះ។ នោះគឺជំនាញក្នុង ការយល់ពីអារម្មណ៍ ការត្រិះរិះពិចារណា ការស្តាប់សកម្ម និង ការផ្តល់មតិត្រឡប់ដែលមានប្រយោជន៍ ។ នៅក្នុងផ្នែកនៃមេរៀននេះ អ្នកនឹងសិក្សាអំពីការយល់ពីអារម្មណ៍ និងការត្រិះរិះពិចារណា។ ការស្តាប់សកម្ម និងការផ្តល់មតិត្រឡប់ដែលមានប្រយោជន៍នឹងសិក្សានៅផ្នែកទីពីរនៃមេរៀន។

## ការយល់ពីអារម្មណ៍

ការយល់ពីអារម្មណ៍ គឺជាការដឹងពីអារម្មណ៍ ចែករំលែកបទពិសោធន៍ និងចេតនារម្មណ៍របស់អ្នកដទៃ។ មានន័យថាដាក់ជំនួសខ្លួនអ្នកទៅក្នុងស្ថានភាពរបស់អ្នកដទៃ ហើយស្វែងយល់វា ដូច្នេះអ្នកអាចពេញចិត្តចំពោះចំណុចទិដ្ឋភាព និងអារម្មណ៍របស់ពួកគេ។ ការយល់ពីអារម្មណ៍មិនមែនជាការស្វែងយល់ចិត្តនោះទេ វាទាមទារឱ្យយើងស្រមៃពីរបៀបដែលអ្នកដទៃដឹងពីអារម្មណ៍ចំពោះស្ថានការណ៍ដែលបានជួបប្រទះ។ អ្នកអាចបិទភ្នែករបស់អ្នក ហើយស្រមៃដោយត្រង់ថាយើងគឺជាអ្នកដទៃ។ ឧទាហរណ៍ ប្រសិនបើមិត្តរបស់អ្នកឈ្មោះសុថា មានការលំបាកចិត្តអំពីរឿងបាត់លុយ គឺយើងមិនមែនចូលទៅផ្តល់ដំបូន្មានឱ្យគាត់ឡើយ ជំនួសឱ្យការនេះ អ្នកគួរគិតថាតើអ្នកមានអារម្មណ៍បែបណា បើអ្នកស្ថិតក្នុងហេតុការណ៍របស់គាត់វិញ។ នៅពេលដែលអ្នកយល់អំពីកង្វល់របស់សុថា អ្នកអាចឆ្លើយតបយ៉ាងគួរសមថា "ខ្ញុំសូមចូលរួមសោកស្តាយផងដែលវាបានកើតឡើងចំពោះអ្នក" ។

*ការយល់ពីអារម្មណ៍គឺបង្កើតបាននូវសេចក្តីទុកចិត្ត ការគោរព និងពង្រឹងនូវទំនាក់ទំនងជាវិជ្ជមាន។*

## ការត្រិះរិះពិចារណា

ការត្រិះរិះពិចារណា គឺជាការគោរព ឬជាភាពគួរសមនៅក្នុងការប្រព្រឹត្ត និងការនិយាយស្តី។ មានន័យថាយើងផ្តល់តម្លៃឱ្យការរក្សាទំនាក់ទំនង ទោះបីជាយើងមិនយល់ព្រមក៏ដោយ។ នៅពេលយើងគ្រប់គ្រងពាក្យសម្តី និងអាកប្បកិរិយារបស់យើងបានល្អ យើងនឹងរកឃើញនូវចំណុចរួមក្នុងការពិភាក្សាអំពីបញ្ហាប្រឈម និងបញ្ហាផ្សេងទៀត។ នៅពេលដែលមនុស្សខ្វះការពិចារណា ពួកគេអាចនឹងស្តីបន្ទោសអ្នកដទៃ និយាយដើមអ្នកដទៃ ឬផ្ញើអ៊ីមែលដែលពួកគេមិនចង់បាន។ នៅពេលអ្នកឮរឿងមិនល្អអំពីអ្នកដទៃ យកល្អអ្នកគួរតែកុំចូលរួមពិភាក្សាទោះបីជាការពិភាក្សាដោយផ្ទាល់ តាមទូរសព្ទ ឬតាមអ៊ីមែលក៏ដោយ។ វាគឺចាំបាច់ក្នុងការអភិវឌ្ឍកេរ្តិ៍ឈ្មោះដើម្បីក្លាយទៅជាមនុស្សដែលមានការត្រិះរិះពិចារណា។ ឥរិយាបថចេះត្រិះរិះពិចារណាគឺបង្កើតបានជាទំនាក់ទំនងដែលជឿជាក់ និងមានទំនុកចិត្តទាំងនៅសាលា និងកន្លែងធ្វើការ។ ឧទាហរណ៍ដូចជាឥរិយាបថដែលអ្នកនិយាយថា "អរគុណ" ចំពេលវេលា និងការមិននិយាយកាត់អ្នកដទៃ។



# មេរៀនសង្ខេប

យើងរស់នៅក្នុងសង្គមដែលពោរពេញទៅដោយចំណេះដឹង ហើយជំនាញបច្ចេកវិទ្យា និងទំនាក់ទំនងអន្តរបុគ្គលគឺជាជំនាញចាំបាច់។ សម្រាប់ពួកយើងភាគច្រើន ត្រូវខិតខំប្រឹងប្រែងធ្វើឱ្យទំនាក់ទំនងមានប្រសិទ្ធភាព ទោះជាយ៉ាងណា ការសិក្សាដើម្បីមានទំនាក់ទំនងល្អនឹងផ្តល់ឱកាសឱ្យអ្នកក្នុងការធ្វើឱ្យប្រសើរទាំងទំនាក់ទំនងផ្ទាល់ខ្លួន និងទំនាក់ទំនងការងារ។ ពេលទំនាក់ទំនងរបស់អ្នកមានប្រសិទ្ធភាពកាន់តែខ្លាំងអ្នកក៏មានជោគជ័យក្នុងជីវិតកាន់តែច្រើនដែរ។

តាមការសិក្សាជំនាញ អ្នកចាំបាច់ត្រូវមានទំនាក់ទំនងដែលមានប្រសិទ្ធភាពទាំងវាចា និងមិនវាចា ហើយអ្នកនឹងអាចបង្ហាញគំនិតផ្ទាល់ខ្លួនរបស់អ្នកយ៉ាងច្បាស់លាស់ ព្រមទាំងយល់បានច្រើនអំពីព័ត៌មានដែលអ្នកដទៃបង្ហាញដល់អ្នក។ យើងអាចក្លាយទៅជាអ្នកទំនាក់ទំនងដោយវាចាដ៏ល្អបាន ដោយការអនុវត្តឱ្យបានច្រើនទៅលើជំនាញសរសេរ និងជំនាញនិយាយ។ ហើយយើងក៏អាចក្លាយទៅជាអ្នកទំនាក់ទំនងដោយមិនវាចាដ៏ល្អបានផងដែរ ដោយការសិក្សាដើម្បីគ្រប់គ្រង និងមើលកាយវិការ ការបញ្ចេញទឹកមុខ ក្រសៃភ្នែក ឥរិយាបថរាងកាយ ការប៉ះ និងការលើកដាក់សំឡេង។

មិនថាអ្នកកំពុងសរសេរ អាន និយាយ ឬស្តាប់នោះទេ អ្នកត្រូវតែធ្វើឱ្យប្រាកដថាសារអត្ថបទរបស់អ្នកត្រូវបានទាក់ទងដោយត្រឹមត្រូវ។ ការយល់ពីអារម្មណ៍ និងការត្រិះរិះពិចារណាគឺជាជំនាញទំនាក់ទំនងពីរដែលបង្កើតបាននូវទំនាក់ទំនងល្អប្រសើរ។

## លំហាត់

### លំហាត់ ១

១. អ្នកនឹងធ្វើការជាក្រុមដែលមានមនុស្សបីនាក់ដើម្បីស្វែងយល់ឱ្យបានប្រសើរ អំពីភាសាកាយវិការតាមរយៈការដើរតួ។

អ្នកនឹងដើរតួបីដងក្នុងស្ថានការណ៍មួយ ដែលការដើរតួម្តងៗត្រូវប្រើពេលពីរនាទី។ ពេលដើរតួម្តងៗ សមាជិកម្នាក់នៅក្នុងក្រុមនឹងពណ៌នាអំពីចំណាប់អារម្មណ៍ និងការងារកម្សាន្តរបស់គាត់។ សមាជិកទីពីរនឹងនៅទល់មុខសមាជិកទីមួយ ហើយមិនឆ្លើយតបដោយផ្ទាល់ឡើយ គឺនឹងប្រើទំនាក់ទំនងអវិជ្ជមានមិនវាចាតែប៉ុណ្ណោះដូចជា ក្រសៃភ្នែក ការគោះម្រាមដៃ ឬការឱបដៃ។ សមាជិកទីបីនឹងសង្កេតតាមដាន សួរសំណួរដូចខាងក្រោមក្នុងរយៈពេលពីរនាទី៖

ក) ចំពោះវាគ្មិន៖ តើអ្នកមានអារម្មណ៍ដូចម្តេចដែរ ពេលអ្នកនិយាយ។ តើអ្នកមានអារម្មណ៍មិនសប្បាយចិត្តដូចម្តេចខ្លះ?

ខ) ចំពោះអ្នកស្តាប់៖ តើវាលំបាកខ្លាំងឬ បានជាអ្នកមិនឆ្លើយតប ឬនិយាយទៅកាន់វាគ្មិន? តើអ្នកនឹងធ្វើអ្វីខ្លះ ប្រសិនបើនេះជាការសន្ទនាជាក់ស្តែង?

បន្ទាប់មកទៀតអ្នកនឹងប្តូរវេនគ្នាដើរតួ ដូច្នេះម្នាក់ៗនឹងមានឱកាសធ្វើជាវាគ្មិន អ្នកទំនាក់ទំនងមិនផ្ទាល់ និងអ្នកសង្កេតតាមដាន។

នៅពេលបានបញ្ចប់ការធ្វើលំហាត់ ចូរសរសេរសេចក្តីសង្ខេបនៃការសង្កេតតាមដានរបស់អ្នក ហើយជ្រើសរើសសមាជិកម្នាក់ដើម្បីប្រកាសវានៅក្នុងថតក្រុមរបស់អ្នក។

## លំហាត់ ២

អ្នកនឹងអនុវត្តការបញ្ចេញទឹកមុខដូចខាងក្រោមនៅក្នុងក្រុមរបស់អ្នក៖

| | | |
|---|---|---|
| ភ្ញាក់ផ្អើល | បារម្ភ | ភ័យខ្លាច |
| ស្អប់ខ្ពើម | ងឿងឆ្ងល់ | ការគ្មានយោបល់ |
| សប្បាយរីករាយ | រវើរវាយ | ការសម្លក់សម្លឹង |
| ក្រៀមក្រំ | ខឹង | ការអាម៉ាស់។ |

ផ្នែកទី១៖ សមាជិកទាំងអស់ប្តូរវេនគ្នាដើម្បីសាកល្បង ចំពោះការបញ្ចេញទឹកមុខដែលមានរាយដូចខាងលើ ចំណែកឯសមាជិកផ្សេងទៀតនឹងទស្សន៍ទាយអំពីទឹកមុខដែលនឹងបង្ហាញនីមួយៗ។ មិនចាំបាច់អនុវត្តតាមលំដាប់លំដោយទេ!

ផ្នែកទី២៖ បន្ទាប់ពីក្រុមរបស់អ្នកបានបញ្ចប់ ឆ្លើយនូវសំណួរដូចខាងក្រោម រួចប្រកាសចម្លើយនៅក្នុងថតក្រុមរបស់អ្នក។

ក ) តើការបញ្ចេញទឹកមុខអ្វីខ្លះដែលអ្នកបានអនុវត្ត ?

ខ ) តើការបញ្ចេញទឹកមុខណាមួយដែលងាយស្រួលបកប្រែជាងគេបំផុត ?

គ ) តើការបញ្ចេញទឹកមុខណាមួយដែលលំបាកបកប្រែបំផុត ?

## សំណួរត្រិះរិះ

១. ហេតុអ្វីបានជាទំនាក់ទំនងដោយវាចាសំខាន់សម្រាប់ប្រសិទ្ធភាពនៃការទាក់ទង ?

២. ហេតុអ្វីចាំបាច់យើងត្រូវដឹងពីរបៀបពិតប្រាកដនៃការបកប្រែទំនាក់ទំនងដោយមិនវាចា ?

៣. ចូររកឧទាហរណ៍មួយចំនួនអំពីទំនាក់ទំនងដោយមិនវាចា និងភាសាកាយវិការ។

៤. តើអ្វីជាការយល់ពីអារម្មណ៍ ហើយហេតុអ្វីបានជាវាសំខាន់ ?

៥. តើអ្វីជាឥរិយាបថត្រិះរិះពិចារណា ហើយហេតុអ្វីបានជាវាសំខាន់ ?

៦. តើជំនាញទំនាក់ទំនងដែលមានប្រសិទ្ធភាព អាចជួយឱ្យសិស្ស និងនិយោជិតមានការប្រសើរឡើងដូចម្តេចខ្លះ ?

# ផ្នែក ខ - បំណិនបច្ចេកវិទ្យាទំនាក់ទំនង

## ៣. ការស្តាប់សកម្ម

ជំនាញទំនាក់ទំនង និងជំនាញបច្ចេកទេស គឺជាជំនាញសំខាន់ពីរសម្រាប់បុគ្គលិកដើម្បីក្លាយខ្លួនទៅជានិយោជិតដ៏មានតម្លៃរបស់អង្គការ និងក្លាយទៅជាសមាជិកល្អនៅក្នុងក្រុម។ និយោជកត្រូវការនិយោជិតណាដែលដឹងពីរបៀបអនុវត្តការងារបច្ចេកទេស (បំណិនរឹង) ប៉ុន្តែពួកគេយល់ច្បាស់ពីសារៈសំខាន់ដែលត្រូវមានបុគ្គលិកដែលដឹង និងចេះប្រើបំណិនទំនាក់ដែលនឹងបង្កើតឱ្យមានទំនាក់ទំនងការងារសហការ និងធ្វើការជាក្រុម (បំណិនទន់)។ ពួកគេដឹងថានិយោជិតដែលមានជំនាញទាំងនេះ នឹងជួយបន្ថែមគុណតម្លៃដល់ពាណិជ្ជកម្មរបស់ពួកគេ។

យើងបានសិក្សារួចហើយអំពីទំនាក់ទំនងដោយវាចា និងមិនវាចា នៅក្នុងផ្នែកនេះយើងនឹងផ្តោតសំខាន់ទៅលើជំនាញទំនាក់ទំនងនៃការស្តាប់សកម្ម ការផ្តល់ និងការទទួលមតិយោបល់ និងទំនាក់ទំនងក្រុមដែលមានប្រសិទ្ធភាព។

ការស្តាប់គឺជាជំនាញដ៏សំខាន់មួយដែលអ្នកអាចធ្វើការអភិវឌ្ឍបាន។ កម្រិតល្អដែលអ្នកអាចស្តាប់បាន គឺមានឥទ្ធិពលយ៉ាងខ្លាំងចំពោះទំនាក់ទំនងរបស់អ្នកជាមួយអ្នកផ្សេង និងប្រសិទ្ធភាពការងាររបស់អ្នកនៅកន្លែងធ្វើការ។ យើងទាំងអស់ស្តាប់ក្នុងហេតុផលផ្សេងៗគ្នា ដូចជាយើងស្តាប់ដើម្បីយល់ ដើម្បីទទួលបានព័ត៌មានសម្រាប់ការងារ ឬដើម្បីការសិក្សា។ ការស្តាប់ហាក់មានភាពងាយស្រួលជាង សន្មតថាយើងគឺយល់ភាគច្រើននូវអ្វីដែលយើងបានឮ ហើយអ្នកដទៃក៏យល់យ៉ាងច្បាស់នូវអ្វីដែលយើងកំពុងនិយាយទៅកាន់ពួកគេដែរ។ ទោះយ៉ាងណា ការសិក្សាស្រាវជ្រាវមួយបានបង្ហាញថា មនុស្សភាគច្រើនអាចចងចាំបានភាគរយតិចប៉ុណ្ណោះ នូវអ្វីដែលពួកគេបានឮ ហើយបង្ហាញទៀតថាយើងខ្សោយក្នុងការយកចិត្តទុកដាក់ពេញលេញទៅកាន់អ្នកផ្សេងសម្រាប់រយៈពេលច្រើនជាងពីរ ឬបីនាទី។ យើងអាចសិក្សាដើម្បីក្លាយទៅជាអ្នកស្តាប់ដ៏ប្រសើរបានដោយការអភិវឌ្ឍ ជំនាញស្តាប់សកម្ម ។



**ការស្តាប់សកម្ម** គឺជាបច្ចេកទេសទំនាក់ទំនងដែលពាក់ព័ន្ធទៅនឹងការស្តាប់ ដោយយកចិត្តទុកដាក់ជាមួយវាគ្មិន ការនិយាយឡើងវិញ និងការប្រាប់ដល់វាគ្មិននូវអ្វីដែលអ្នកបានឮ ដើម្បីឱ្យប្រាកដថាអ្នកបានយល់យ៉ាងត្រឹមត្រូវ បន្ទាប់មកស្តាប់ម្តងទៀតសម្រាប់ការយល់ស្រប ឬការបញ្ជាក់ឱ្យកាន់តែច្បាស់។ ការស្តាប់សកម្មគឺលើសពីការឮទៅទៀត ការឮគឺគ្រាន់តែសមត្ថភាពខាងក្រៅដែលពាក់ព័ន្ធនឹងសំឡេងតាមរយៈត្រចៀករបស់យើងប៉ុណ្ណោះ។ ពេលយើងប្រើការស្តាប់សកម្ម គឺយើងផ្តោតអារម្មណ៍ទាំងស្រុងទៅលើអ្វីដែលពួកគេកំពុងនិយាយ មិនមែនគ្រាន់តែស្តាប់ឮសារប៉ុណ្ណោះទេ។ យើងត្រូវប្រើវិញ្ញាណទាំងអស់របស់យើង មិនមែនប្រើតែត្រចៀកមួយមុខនោះឡើយ យើងស្តាប់គ្រប់ពាក្យពេចន៍ដើម្បីយល់ពីអត្ថន័យស៊ីជម្រៅរបស់សារ។ យើងផ្តោតការយកចិត្តទុកដាក់ទាំងស្រុងចំពោះវាគ្មិន ហើយបង្ហាញការចាប់អារម្មណ៍របស់យើងដោយប្រើសារមិនវាចា ដូចជាក្រសែភ្នែក ការងក់ក្បាល ឬការញញឹមជាដើម

ហើយយើងផ្ដោតផងដែរទៅលើភាសាកាយវិការ និងការបញ្ចេញទឹកមុខរបស់គាត់។ ការស្ដាប់សកម្មទាមទារឱ្យមានការកំណត់ដាច់ដោយឡែកអំពីអារម្មណ៍ផ្ទាល់ខ្លួន និងការវិនិច្ឆ័យជាមុន ការស្ដាប់ដោយប្រុងប្រយ័ត្ន និងដោយយកចិត្តទុកដាក់ទាំងស្រុងទៅកាន់វាគ្មិន មុនពេលអភិវឌ្ឍគំនិតយោបល់របស់អ្នកចំពោះអ្វីដែលពួកគេបាននិយាយ។ ការបញ្ចេញមតិយោបល់របស់យើងគឺ ត្រូវធ្វើឡើងតែនៅពេលណាដែលយើងបានយល់យ៉ាងច្បាស់អំពីអ្វីគ្រប់យ៉ាងដែលវាគ្មិនបាននិយាយប៉ុណ្ណោះ ហើយមិនមែនជាការនិយាយកាត់ ឬជាការវិនិច្ឆ័យឡើយ។ យើងអាចផ្ដល់មតិយោបល់ផ្សេងៗដូចជា “សូមជួយប្រាប់បន្ថែម” ឬ “ស្ដាប់ទៅគួរឱ្យចាប់អារម្មណ៍មែន” ជាដើម។ ទាំងនេះគឺជាឃ្លាលើកទឹកចិត្តដើម្បីឱ្យវាគ្មិនបន្តការបង្ហាញរបស់ខ្លួនដោយគ្មានការរអាក់រអួល។ នៅពេលវាគ្មិនឃើញពីភាពរួសរាយ និងអាកប្បកិរិយាបើកទូលាយរបស់អ្នក ពួកគេនឹងមានអារម្មណ៍ល្អ និងកាន់តែងាយស្រួលក្នុងការទាក់ទងជាមួយអ្នក។

យើងអាចគិតអំពីពេលវេលាផងដែរ នៅពេលយើងកំពុងជជែកជាមួយនរណាម្នាក់ ហើយអាចប្រាប់គាត់ថាជារឿងដែលមិនគួរឱ្យចាប់អារម្មណ៍ទេ ហើយគាត់អាចនឹងត្រូវផ្លាស់ប្ដូរប្រធានបទ។ ការរំខានអាចកើតឡើងដោយសារក្រសែភ្នែក ឬការចាប់ផ្ដើមលេងទូរសព្ទ។ អាកប្បកិរិយាផ្សេងទៀតរបស់អ្នកស្ដាប់ដែលមិនល្អគឺ ការជជែកអំពីគំនិតយោបល់របស់ខ្លួនដោយមិនបានផ្ដល់នូវការបង្ហាញថា ពួកគេបានឮនូវអ្វីដែលវាគ្មិនបាននិយាយ។ ពេលបញ្ហាទាំងនេះកើតឡើង យើងនឹងមានអារម្មណ៍ថាវាលែងសំខាន់ ហើយវាអាចប៉ះពាល់ដល់អារម្មណ៍របស់យើងទៀតផង។




ម្យ៉ាងវិញទៀត នៅពេលដែលពួកគេស្ដាប់យើងនិយាយដោយសកម្មនោះ យើងនឹងមានអារម្មណ៍ថាគំនិត និងយោបល់របស់យើងគឺសំខាន់ និងមានតម្លៃ។ នៅកន្លែងធ្វើការ ការស្ដាប់សកម្មនាំមកនូវបរិយាកាសដ៏ប្រសើរ ហើយនាំឱ្យមានកំហុសតិចតួចទៀតផង។

យើងទាំងអស់គ្នាដឹងហើយថា យើងត្រូវស្ដាប់ដោយយកចិត្តទុកដាក់ នៅពេលយើងទាក់ទងជាមួយអតិថិជន ឬមនុស្សសំខាន់ផ្សេងទៀត ប៉ុន្តែយើងមិនចាំបាច់ស្ដាប់ដោយផ្ដោតខ្លាំងពេកទេ ពេលយើងស្ដាប់ទៅកាន់គ្រួសារ មិត្តភ័ក្តិ ឬអ្នកធ្វើការជាមួយគ្នានោះ។ យើងអាចធ្វើខ្លួនដូចជាមិនសូវខ្វល់ខ្វាយ ឬពេលខ្លះអាចធ្វើពុតដូចជាកំពុងស្ដាប់ ប៉ុន្តែការធ្វើបែបនេះគឺមិនផ្ដល់នូវការគោរពដល់មិត្តភ័ក្តិ ឬគ្រួសារឡើយ។

*មានតែការស្ដាប់ដោយយកចិត្តទុកដាក់ប៉ុណ្ណោះ ដែលនឹងបង្កើតបាននូវទំនាក់ទំនងដ៏ប្រសើរជាមួយមនុស្សដែលសំខាន់ចំពោះយើង។*

ការស្តាប់សកម្មគឺជាជំនាញ និងសកម្មភាពសម្បជញ្ញៈ ហើយវាតម្រូវឱ្យមានការខិតខំព្យាយាម។ អ្នកអាចក្លាយទៅជាអ្នកស្តាប់សកម្មបាន ដោយអនុវត្តតាមជំហានបួនដូចខាងក្រោម៖

១. **ការយកចិត្តទុកដាក់៖** អ្នកត្រូវសម្រេចចិត្តថាស្តាប់ បន្ទាប់មកផ្តោតយ៉ាងសំខាន់ទៅលើពាក្យពេចន៍ និងអត្ថន័យរបស់គាត់ សម្លឹងមើល ហើយបំបាត់ចោលនូវការរំខានអារម្មណ៍ទាំងឡាយ។ ការរំខានអារម្មណ៍ទាំងខាងក្នុង និងខាងក្រៅអាចប៉ះពាល់ដល់ការស្តាប់ និងការផ្ចង់អារម្មណ៍របស់អ្នក។

ការរំខានអារម្មណ៍ខាងក្រៅ អាចត្រូវបានបំបាត់ដោយកាយវិការ ឧទាហរណ៍ដូចជាទូរសព្ទ ទូរទស្សន៍ តន្ត្រី និងសំឡេងផ្សេងៗ។ ការរំខានអារម្មណ៍ខាងក្នុង គឺជាកង្វល់ដែលនៅក្នុងខួរក្បាលរបស់យើង។ ការរំខានអារម្មណ៍ខាងក្រៅគឺងាយស្រួលបំបាត់ជាងការរំខានអារម្មណ៍ខាងក្នុង។ ឧទាហរណ៍ អ្នកអាចដាក់ទូរសព្ទរបស់អ្នកក្នុងរបៀបស្ងាត់ ឬបិទទូរទស្សន៍ ឬស្វែងរកកន្លែងស្ងាត់ដើម្បីជជែក ប៉ុន្តែវាគឺពិបាកក្នុងការបញ្ឈប់ការគិតអំពីក្តីកង្វល់ ឬរឿងអ្វីមួយដែលយើងបានជិតជាប់ក្នុងអារម្មណ៍ហើយនោះ។



ជាមួយការរំខានអារម្មណ៍ខាងក្រៅ អ្នកត្រូវតែធ្វើការសម្រេចចិត្តផ្តោតទាំងស្រុងទៅលើអ្នកផ្សេង ហើយដោយមិនអនុញ្ញាតឱ្យអារម្មណ៍របស់អ្នកខ្វល់ខ្វាយអំពីរឿងផ្សេងឡើយ។ វាអាចលំបាកក្នុងការអនុវត្ត ហើយមនុស្សជាច្រើនត្រូវតែខិតខំសិក្សាអំពីរបៀបផ្តោតអារម្មណ៍ និងការអភិវឌ្ឍសមត្ថភាពដើម្បីបំបាត់ការរំខានអារម្មណ៍ខាងក្នុង។ ប្រសិនបើអ្នកធ្លាប់ត្រូវបានរំខានដោយផ្លាស់ប្តូរប្រធានបទពិភាក្សា នោះអ្នកអាចប្រាប់ទៅមនុស្សនោះថា គាត់បានអនុញ្ញាតឱ្យមានការរំខានអារម្មណ៍ខាងក្រៅ ហើយវាបង្អាក់ដល់ការផ្តោតអារម្មណ៍ស្តាប់របស់គាត់ហើយ។ វិធីសាស្ត្រមួយដែលអាចធ្វើឱ្យការផ្ចង់អារម្មណ៍របស់អ្នកប្រសើរឡើងបានគឺ ការព្យាយាមនិយាយពាក្យរបស់មនុស្សនោះឡើងវិញនៅក្នុងចិត្ត នៅពេលដែលពួកគាត់និយាយ។ វានឹងជួយធ្វើឱ្យមានការរឹងមាំដល់សាររបស់ពួកគេ ហើយអ្នកអាចនៅតែផ្តោតអារម្មណ៍បាន។

២. ស្តាប់ពាក្យពេចន៍របស់វាគ្មិន និងទំនាក់ទំនងដោយមិនវាចារបស់គាត់។ យកចិត្តទុកដាក់ចំពោះទំនាក់ទំនងមិនផ្ទាល់របស់អ្នកផងដែរ។ បង្ហាញថាអ្នកកំពុងផ្ចង់អារម្មណ៍ដោយមានទំនោរយ៉ាងខ្លាំង ហើយបង្អើតក្រសែភ្នែក។ ត្រូវចាប់អារម្មណ៍ដោយពិតប្រាកដទៅលើអ្វីដែលអ្នកផ្សេងបាននិយាយ។

៣. អនុញ្ញាតឱ្យវាគ្មិនទាក់ទងដោយគ្មានការរំខាន រហូតដល់គាត់បានបញ្ចប់។ ត្រឡប់ទៅកាន់គំនិត និងអារម្មណ៍ផ្ទាល់របស់អ្នក ប៉ុន្តែមិនត្រូវទៅដល់សេចក្តីសន្និដ្ឋានឡើយ រហូតដល់អ្នកផ្សេងបានបញ្ចប់ការពិភាក្សា ហើយអ្នកបានយល់យ៉ាងច្បាស់អំពីអ្វីដែលពួកគេចង់មានន័យ។ ប្រសិនបើអ្នកអនុញ្ញាតឱ្យមានការរំខានអារម្មណ៍ អ្នកនឹងមិនអាចស្តាប់បានចំពោះសារទាំងស្រុងឡើយ ហើយអ្នកអាចនឹងយល់ខុសអំពីអត្ថន័យ ហើយបង្ហាញថាអ្នកមិនកំពុងស្តាប់ពួកគេឡើយ ដោយការប្តូរទិសដៅនៃការសន្ទនា។

*តើអ្នកកំពុងស្តាប់ ឬអ្នកកំពុងរង់ចាំនិយាយ?*

៤. ផ្តល់មតិយោបល់ដោយសេចក្តីគោរព និងស្មោះត្រង់ មិនលម្អៀង។ សរសេរឡើងវិញនូវអ្វីដែលវាគ្មិនបាននិយាយ ហើយកុំបន្ថែមគំនិតថ្មី។ ការសរសេរឡើងវិញ មានន័យថាជាការអះអាងនូវការយល់ដឹងរបស់អ្នក ចំពោះអ្វីដែលវាគ្មិនចង់មានន័យ ដោយប្រើពាក្យពេចន៍ផ្ទាល់របស់អ្នក និងពាក្យពេចន៍ទូទៅតិចជាងអ្វីដែលវាគ្មិនបានប្រើ។ ការសរសេរឡើងវិញគឺដើម្បីធ្វើតេស្តកម្រិតយល់ដឹងរបស់អ្នក ចំពោះអ្វីដែលអ្នកបានឮ និងដើម្បីបង្ហាញថា អ្នកបានបកប្រែសារមូលដ្ឋានយ៉ាងត្រឹមត្រូវ។ មានទំនាក់ទំនងខុសជាច្រើនបានកើតឡើង ដោយសារតែអ្នកស្តាប់បកប្រែសារខុសពីអ្វី ដែលវាគ្មិនចង់មានន័យ។ ការសរសេរឡើងវិញគឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពដើម្បីសម្អាតការយល់ខុសណាមួយ។ ឧទាហរណ៍ វាគ្មិនអាចនិយាយថា "ខ្ញុំដូចជាមិនយល់អំពីឪពុករបស់ខ្ញុំសោះ។ ម្តងគាត់ប្រាប់ខ្ញុំថាឱ្យខំប្រឹងសិក្សា ហើយបន្តិចក្រោយមកគាត់និយាយថាឱ្យខ្ញុំប្រើពេលវេលាច្រើនដើម្បីជួយធ្វើការងារផ្ទះ"។ អ្នកស្តាប់អាចនឹងតបថា "ឪពុករបស់អ្នកកំពុងធ្វើឱ្យអ្នកវង្វេងហើយមែនទេ?" ហើយវាគ្មិនអាចនឹងឆ្លើយតបថា "ពិតមែនហើយ!" ម្យ៉ាងទៀតប្រសិនបើវាគ្មិននិយាយថា "ទេ! វាមិនមែនជាអ្វីដែលខ្ញុំចង់មានន័យទេ" បន្ទាប់មកអ្នកស្តាប់នឹងសួរបញ្ជាក់ទៀតថា "តើអ្នកចង់មានន័យដូចម្តេច?" ដូច្នេះអ្នកទាំងពីរយល់នូវសារដូចគ្នា។ បើយើងសរសេរឡើងវិញ ហើយបញ្ជាក់ឱ្យកាន់តែច្បាស់នោះ យើងនឹងមានកំហុស និងការយល់ច្រឡំតិចតួចប៉ុណ្ណោះ ហើយការទាក់ទងរបស់យើងក៏មានភាពប្រសើរដែរ។ បញ្ហានៃការយល់ច្រឡំគឺដោយសារតែអ្នកទាំងនោះមិនបានទាក់ទងគ្នា ហើយគិតថាពួកគេបានយល់អំពីគ្នាទៅវិញទៅមកយ៉ាងល្អ។ ពួកគេតែងតែយឺតពេលក្នុងការរកឃើញការយល់ច្រឡំ ពេលដែលមាននរណាម្នាក់ធ្វើនូវអ្វីមួយដែលពិតជាមិនបានរំពឹងទុកសម្រាប់អ្នកផ្សេង។ ពេលខ្លះការយល់ច្រឡំអាចត្រូវបានដោះស្រាយទៅតាមក្រោយ ប៉ុន្តែយកល្អគួរតែការពារកុំឱ្យវាកើតឡើង។



# ៤. ការផ្តល់ និងទទួលយកមតិយោបល់

តាមធម្មតាយើងប្រើពាក្យថា មតិយោបល់ ដើម្បីចង់បានព័ត៌មានដែលមានប្រយោជន៍ដែលយើងផ្តល់ឱ្យអ្នកណាម្នាក់ដើម្បីជួយឱ្យពួកគេធ្វើអ្វីមួយកាន់តែប្រសើរជាងអ្វីដែលពួកគេកំពុងតែធ្វើ។នៅក្នុងការប្រាស្រ័យទាក់ទង មតិយោបល់ មានន័យថាជាការផ្តល់ព័ត៌មានដែលជួយឱ្យមនុស្សផ្សេងដឹងថា យើងយល់ពីសាររបស់ពួកគេ និងវិធីដែលវាមានឥទ្ធិពលលើយើង។

មតិយោបល់ ត្រូវបានយល់ដឹងកាន់តែល្អក្នុងបរិស្ថានវិជ្ជាជីវៈ។ បន្ថែមលើអ្វីដែលជាអ្នកស្តាប់យកចិត្តទុកដាក់ និយោជិតដែលមានតម្លៃដឹងពីវិធី និងពេលវេលាដើម្បីផ្តល់មតិយោបល់ដែលសមស្របដល់សមាជិកក្រុមផ្សេងទៀត។ មតិយោបល់អាចជាទម្រង់វិជ្ជមាន ឬមតិយោបល់បែបស្ថាបនា។ មនុស្សភាគច្រើនសប្បាយនឹងទទួលមតិយោបល់វិជ្ជមាន ឬពាក្យសរសើរនៅពេលពួកគេត្រូវបានសម្តែងអំណរគុណដោយស្មោះត្រង់។ ប៉ុន្តែទោះជាយ៉ាងក៏ដោយ វាកាន់តែពិបាកក្នុងការផ្តល់មតិយោបល់នៅពេលយើងចង់ឱ្យមនុស្សម្នាក់ផ្លាស់ប្តូរ ឬកែប្រែអ្វីមួយ ហើយយើងត្រូវតែប្រើការប៉ិនប្រសព្វ និងភាពបើកទូលាយចំពោះស្ថានភាពទាំងនោះ។ វាអាចជាគ្រូបង្រៀនដោយប្រាប់សិស្សអំពីពិន្ទុមិនល្អលើក្រដាស និងព័ត៌មានណាមួយដែលគាត់ត្រូវរៀន ឬឪពុកម្តាយប្រាប់កូនរបស់គាត់អំពីកិច្ចការងារផ្ទះដែលមិនទាន់រួចរាល់ដូចអ្វីបានរំពឹងទុក ដោយផ្តោតលើវិធីដើម្បីកែលម្អ និងមិនត្រឹមតែប្រាប់កូនថាសកម្មភាពនោះមិនត្រឹមត្រូវទេ។ ការផ្តល់មតិយោបល់គឺមានការលំបាកសម្រាប់មនុស្សជាច្រើន ហើយពួកគេអាចគេចវេចមិនផ្តល់មតិយោបល់ពេលខ្លះខឹងជំនួសឱ្យការនិយាយពីបញ្ហាអ្វីមួយ។ វាមានសារៈសំខាន់ណាស់ដើម្បីរក្សាភាពសុខដុមក្នុងកន្លែងធ្វើការ ហើយការផ្ទុះកំហឹងអាចបំផ្លាញទំនាក់ទំនងដ៏សំខាន់។




នៅពេលយើងផ្តល់មតិយោបល់បែបស្ថាបនា យើងត្រូវមានការប្រុងប្រយ័ត្នមិនមែនជាការផ្តល់មតិយោបល់អវិជ្ជមានទេ។ វាជាគំនិតដ៏ល្អដែលត្រូវអធិប្បាយអំពីការងារដែលមនុស្សផ្សេងកំពុងតែធ្វើជាមុនសិន ហើយបន្ទាប់មកនិយាយអំពីផ្នែកដែលពួកគេត្រូវតែកែប្រែ ឬផ្នែកដែលពួកគេអាចកែលម្អ។ នៅពេលទទួលមតិយោបល់ វាមានសារៈសំខាន់ដែលមិនត្រូវទទួលតែមតិយោបល់រិះគន់ទេ ប៉ុន្តែជាព័ត៌មានដែលអ្នកនិយាយកំពុងផ្តល់ឱ្យយើងដែលអាចកែលម្អលទ្ធផលរបស់យើងបាន។ តម្លៃរបស់មតិយោបល់គឺថា វាជួយយើងឱ្យរៀនពីវិធីដែលអ្នកផ្សេងដឹងពីការងារ ឬឥរិយាបថរបស់យើង ដូច្នេះធ្វើឱ្យវាកាន់តែងាយស្រួលសម្រាប់យើង ដើម្បីសម្រួលតាមស្ថានភាពថ្មី អភិវឌ្ឍចំណេះដឹង ឬលើកកម្ពស់ការងាររបស់យើង។ វាមានសារៈសំខាន់សម្រាប់យើង ដើម្បីមើលមតិយោបល់ថាវិជ្ជមាន និងមានតម្លៃ។

យើងទាំងអស់អាចរៀនពីវិធីគ្រប់គ្រងអារម្មណ៍ និងពាក្យរបស់យើងនៅពេលត្រូវផ្តល់មតិយោបល់ស្ថាបនា។ សូម្បីតែអ្នកមិនមានបទពិសោធន៍ជាមួយនឹងបំណិននៅចំណុចនេះក៏ដោយ អ្នកអាចរៀនដើម្បីអភិវឌ្ឍបំណិនផ្តល់មតិយោបល់ដោយអនុវត្តវា។

ខាងក្រោមនេះជាសំណើមួយចំនួនអំពី

**វិធីផ្តល់មតិយោបល់ដើម្បីស្ថាបនា៖**

១. ជ្រើសពេលវេលា និងទីកន្លែងត្រឹមត្រូវ។ កុំផ្តល់មតិយោបល់នៅពេលអ្នកខឹង ឬមួម៉ៅ។ អ្នកក៏គួរតែផ្តល់មតិយោបល់ដើម្បីស្ថាបនាជាលក្ខណៈឯកជន ដូច្នេះមនុស្សមិនខ្មាសគេនៅមុខមនុស្សផ្សេង។

២. ផ្តោតលើស្ថានភាព មិនមែនផ្តោតលើមនុស្សទេ។ ប្រើពាក្យដែលប្រាប់អំពីស្ថានភាព ដូច្នេះអ្នកទទួលមិនមានអារម្មណ៍ថាជាលក្ខណៈវាយប្រហារផ្ទាល់ខ្លួន។

៣. មតិយោបល់ជាក់លាក់។ នៅពេលមតិយោបល់មានលក្ខណៈទូទៅពេក មនុស្សអាចមិនផ្លាស់ប្តូរ ពីព្រោះគាត់មិនយល់ពីការបរិយាយទូលំទូលាយពេក។ ជាឧទាហរណ៍ ប្រសិនបើគ្រូបង្រៀននិយាយថា "ខ្ញុំគិតថា អ្នកគួរតែលើកកម្ពស់បំណិនប្រាស្រ័យទាក់ទងរបស់អ្នក" អ្នកនឹងមិនដឹងជាក់លាក់ថាមានមានន័យយ៉ាងដូចម្តេចនោះទេ។ វានឹងកាន់តែប្រសើរសម្រាប់គ្រូបង្រៀននិយាយថា "ខ្ញុំសូមឱ្យអ្នកផ្តោតលើការមើលអ្នកចូលរួម នៅពេលអ្នកធ្វើបទបង្ហាញពេលក្រោយនៅក្នុងថ្នាក់រៀន។ អ្នកតែងតែមានសារៈសំខាន់ៗដើម្បីចែករំលែក។ នៅពេលអ្នកសម្លឹងមើលទៅក្រោម អ្នកបាត់បង់ទំនាក់ទំនងដោយប្រើខ្សែភ្នែក ហើយទំនាក់ទំនងដោយប្រើខ្សែភ្នែកគឺមានសារៈសំខាន់សម្រាប់ការប្រាស្រ័យទាក់ទងដែលល្អ។"

៤. ផ្តល់មតិយោបល់ភ្លាមៗបន្ទាប់ពីស្ថានភាពបានកើតឡើង។ ប្រសិនបើអ្នករង់ចាំយូរពេក មនុស្សអាចមិនចងចាំស្ថានភាព ហើយអ្នកអាចចងចាំវាមិនត្រឹមត្រូវដែរ។ មតិយោបល់គឺមានតម្លៃបំផុតនៅពេលវាត្រូវបានផ្តល់ឱ្យភ្លាមៗ។

៥. ផ្តល់សំណើមួយ ឬពីរអំពីវិធីកែលម្អ។ សំណើត្រូវតែជាក់លាក់ដែលអ្នកទទួលអាចទទួលយកបានដោយសមហេតុផល។ ជាឧទាហរណ៍ នៅក្នុងស្ថានភាពដែលគ្រូបង្រៀនស្នើឱ្យមានទំនាក់ទំនងដោយប្រើខ្សែភ្នែកអំឡុងពេលធ្វើបទបង្ហាញ គ្រូបង្រៀនអាចនិយាយថា "ខ្ញុំដឹងថា អ្នកមានអារម្មណ៍មិនស្រួលទេក្នុងការមើលភ្នែកមនុស្សដោយផ្ទាល់ នៅពេលអ្នកមានអារម្មណ៍ថាព្រួយបារម្ភ។ មានចំណុចមួយដែលដំណើរការគឺមើលក្តោងច្រមុះមនុស្ស។ មនុស្សនឹងគិតថាអ្នកកំពុងមើលភ្នែករបស់ពួកគេ សូម្បីតែពេលអ្នកមិនមើលក៏ដោយ។ អ្នកនឹងមានអារម្មណ៍មិនសូវព្រួយបារម្ភ នៅពេលអ្នកធ្វើបែបនេះ។"

*វាងាយក្នុងការរិះគន់អ្នកដទៃ ហើយយើងទាំងអស់មិនចង់ៗ។ មតិរិះគន់ស្ថាបនា គឺមិនមែនជាការរិះគន់អវិជ្ជមានទេ វាមានបំណងកសាងសមត្ថភាពជាជាងរកកំហុស។*

ការរិះគន់មានអត្ថប្រយោជន៍ក្នុងការជួយជំរុញអ្នកធ្វើការងាររបស់អ្នកកាន់តែល្អប្រសើរតាមការផ្តល់យោបល់ ទស្សនៈ និងការផ្តល់យោបល់ ពួកគេមិនកំពុងរិះគន់អ្នកដោយផ្ទាល់នោះទេ។

ខាងក្រោមនេះជាព័ត៌មានជំនួយអំពី របៀបទទួលបានមតិយោបល់ដែលមានអត្ថប្រយោជន៍។

១. ទោះបីបេះដូងរបស់អ្នកលោតលឿន តើអ្នកបានធ្វើឱ្យវាធូរស្រាលច្រើន ហើយអ្នកគិតអ្វីមួយដែលអាក្រក់នឹងកើតមានឡើង។ ចងចាំត្រូវផ្តោតទៅលើគំនិតវិជ្ជមានដែលជាគោលបំណងមតិយោបល់ក្នុងការជួយអ្នកធ្វើឱ្យប្រសើរឡើង។ រំលឹកខ្លួនអ្នកត្រូវស្ថិតនៅស្ងប់ស្ងាត់។

២. ប្រើជំនាញស្តាប់សកម្មរបស់អ្នក។

៣. ឆ្លើយសំណួរមួយចំនួនដោយស្មោះត្រង់។

៤. អនុញ្ញាតឱ្យអ្នកផ្សេងទៀតពិភាក្សាមុនពេលអ្នកសួរសំណួរ។

៥. កុំធ្វើការដោះសា ត្រូវផ្តល់ការពន្យល់។

៦. ស្វែងរកមធ្យោបាយក្នុងការធ្វើឱ្យការងារ ឬតរិយាបថរបស់អ្នកកាន់តែល្អប្រសើរ។ អ្នកអាចនិយាយថ្លែងអំណរគុណចំពោះអ្នកដែលផ្តល់មតិយោបល់ឱ្យអ្នក វាមិនមានន័យថាអ្នកយល់ព្រមជាមួយមនុស្សម្នាក់នោះទេ ប៉ុន្តែមានន័យថាវាគ្មិនបានខិតខំប្រឹងប្រែងចែករំលែកគំនិតរបស់ពួកគេ។ ម្នាក់នោះអាចជាមនុស្សស្វាហាប់។ អ្នកអាចនិយាយដូចជា "ខ្ញុំសូមថ្លែងអំណរគុណចំពោះការចំណាយពេលរបស់អ្នកក្នុងការពិភាក្សាជាមួយខ្ញុំ។"

# ៥. ការបង្កើតក្រុម

នៅក្នុងវគ្គសិក្សានេះ អ្នកនឹងសិក្សាអំពីអត្ថប្រយោជន៍នៃការធ្វើការងារជាក្រុមនៅកន្លែងធ្វើការ ជាពិសេសនៅក្នុងផ្នែកបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍។ ការស្តាប់សកម្ម ការផ្តល់ឱ្យ និងការទទួលបានមតិយោបល់ដែលមានអត្ថប្រយោជន៍ជាលក្ខណៈសំខាន់ពីរនៃសមាជិកក្រុម។ ការងារជាក្រុមទាមទារឱ្យសមាជិកត្រូវគិតដោយឯករាជ្យ វាមានន័យថាការសហការជាមួយសមាជិកផ្សេងៗទៀត និងគំនិតរបស់ពួកគេផងដែរ។ ការបង្កើតក្រុមទាមទារនិយោជិតម្នាក់ៗមានភាពជឿជាក់ និងទំនុកចិត្តចំពោះគ្នាទៅវិញទៅមក។ សមាជិកក្រុមត្រូវមានសេចក្តីគោរពគ្នាទៅវិញទៅមក និងសិក្សាស្វែងយល់អំពីជំនាញផ្សេងៗគ្នាដែលមានពីមុនៗនៃទំនាក់ទំនងឱ្យមានប្រសិទ្ធភាព។ គោលដៅជាមូលដ្ឋានរបស់ក្រុមគឺត្រូវមានទម្រង់សម្ព័ន្ធគោលដៅតែមួយ ការទទួលបានលទ្ធផលខ្ពស់នៃផលិតភាព និងការច្នៃប្រឌិតនៅកន្លែងធ្វើការ។ សារប្រយោជន៍ធំមួយនៃការងារជាក្រុមសម្រាប់និយោជកគឺថានិយោជិតរបស់ពួកគេ ជាធម្មតាមានការពេញចិត្តការងារខ្ពស់ និងការប្តេជ្ញាចិត្តចំពោះការងាររបស់ពួកគេជាងនិយោជិតដែលមិនធ្វើការជាក្រុម។ លទ្ធផលចំពោះបុគ្គលិកនេះស្នាក់នៅក្រុមហ៊ុនតែមួយរយៈពេលយូរ និងស្វែងរកប្រាក់ចំណេញច្រើនដល់ពាណិជ្ជកម្មទាំងនេះ។ នៅពេលក្រុមហ៊ុនត្រូវការផ្សព្វផ្សាយពាណិជ្ជកម្មជួល និងបណ្តុះបណ្តាលនិយោជិតថ្មី ការចំណាយរបស់ពួកគេគឺខ្ពស់ជាក្រុមហ៊ុនដែលមានស្ថិរភាពរយៈពេលវែង កម្លាំងការងារសមរម្យ។



នៅក្នុងស្ថាប័នមួយតម្លៃ និងការបញ្ជាក់មានសារៈសំខាន់ចំពោះការងារជាក្រុម មានមុខងារផ្សេងៗមួយចំនួន។ អ្នកដឹកនាំស្ថាប័នទាំងមូលគឺជាអ្នកនាំមុខ អ្នកត្រួតត្រា ហើយតាមធម្មតា អ្នកគ្រប់គ្រងគឺជាអ្នកដឹកនាំក្រុម និងនិយោជិតផ្សេងៗទៀតដែលជាសមាជិកក្រុម។ សមាជិកក្រុមអាចក្លាយជាអ្នកដឹកនាំក្រុមសម្រាប់គម្រោង ឬកិច្ចការជាក់លាក់ ទោះបីជាពួកគេមិនអាចអនុវត្តនៅក្នុងតួនាទីជាអ្នកត្រួតត្រាក៏ដោយ។

ខាងក្រោមជាគុណភាពដ៏សំខាន់នៃសមាជិកក្រុមដែលមានប្រសិទ្ធភាព។

១. **ការស្តាប់ដោយសកម្ម៖** សមាជិកក្រុមមួយត្រូវតែជាអ្នកស្តាប់ល្អម្នាក់ ដើម្បីយល់ដឹង និងពិចារណាពីគំនិត និងការយល់ឃើញរបស់អ្នកផ្សេងៗ ដោយមិនចាំបាច់ពិភាក្សារឿងរាល់គ្រប់ចំណុច។ ពួកគេត្រូវគោរពវិន័យខ្លួនឯង ដើម្បីស្តាប់ ហើយនិយាយ ដូច្នេះការពិភាក្សាអាចមានលទ្ធផលពេញលេញ។

២. **ទំនាក់ទំនងមានអត្ថប្រយោជន៍៖** ក្រុមមានប្រសិទ្ធភាពស្វែងចេញពីគំនិតដោយស្មោះត្រង់ច្បាស់លាស់ និងដោយសេចក្តីគោរពរបស់ពួកគេ។ ពួកគេកំពុងមានបំណងក្នុងការផ្តល់មតិយោបល់ដែលមានអត្ថប្រយោជន៍សម្រាប់ក្រុម។

៣. **ពិភាក្សាដោយបង្ហាញការគោរព៖** ការពិភាក្សាជាក្រុមល្អមួយ ជាសមាជិកក្រុមដែលមានអាកប្បកិរិយាសុភាពរាបសា និងការពិចារណា។ ពួកគេមានការយល់ដឹងគោលបំណងការងារ មានភាពរីករាយ និងមានវិជ្ជាជីវៈ។ ការពិភាក្សាក្រុមល្អមួយ ពួកគេត្រូវធ្វើការពិភាក្សារួមគ្នា។ ពួកគេត្រូវឱ្យតម្លៃ និងទទួលស្គាល់គំនិតល្អៗរបស់សមាជិកម្នាក់ៗ។

៤. **ការបង្ហាញពីការជឿទុកចិត្ត៖** សមាជិកក្រុមដែលមានទំនួលខុសត្រូវ និងអាចទុកចិត្តបានគឺពួកគេត្រូវចែករំលែកការងារ និងរក្សាការប្តេជ្ញាចិត្ត។ ពួកគេគឺស្របទៅតាម និងអនុវត្តតាមការងារ។

៥. **អ្នកចូលរួមដោយសកម្ម៖** អ្នកចូលរួមសមាជិកក្រុមសកម្មមួយជាក្រុមដែលធ្វើការប្រជុំ និងពិភាក្សា។ ពួកគេមានកិច្ចខិតខំប្រឹងប្រែង និងស្ម័គ្រចិត្តក្នុងការងារ។

៦. **ការបង្ហាញភាពបត់បែន៖** សមាជិកក្រុមល្អមួយដោះស្រាយជាមួយលក្ខខណ្ឌការផ្លាស់ប្តូរបានល្អប្រសើរ និងចេះសម្របទៅតាមស្ថានភាពការផ្លាស់ប្តូរ ជាពិសេសនៅក្នុងបរិស្ថានដែលប្រែប្រួលលឿននៃពិភពបច្ចេកវិទ្យាទំនើប។ ពួកគេពិចារណាទស្សនៈវិស័យផ្សេងៗដោយបើកចំហការយល់ដឹងដែលអាចធ្វើឱ្យការដោះស្រាយបញ្ហាបានល្អប្រសើរ។

៧. **ការងារជាអ្នកដោះស្រាយបញ្ហា៖** សមាជិកក្រុមមួយដោះស្រាយបញ្ហាដោយផ្អែកទៅលើក្រុម និងកិច្ចការដែលឆ្ពោះទៅរកដំណោះស្រាយ។ ពួកគេមិនស្វែងរកការស្តីបន្ទោសផ្សេងៗ និងមិនគេចវេះការដោះស្រាយបញ្ហា។ អ្នកចូលរួមក្រុមដែលមានប្រសិទ្ធភាពមានការដោះស្រាយបញ្ហាដោយបើកចំហសម្រាប់ការពិភាក្សា និងសហការជាមួយអ្នកផ្សេងក្នុងការស្វែងរកដំណោះស្រាយ។

សមាជិកក្រុមបង្កើតទម្លាប់ល្អៗជាមួយគ្នា ដើម្បីជំរុញកិច្ចសហការឱ្យកាន់តែល្អប្រសើរ។ សមាជិកក្រុមម្នាក់ៗត្រូវកំណត់គោលដៅរបស់ក្រុម ដើម្បីសម្រេចគោលដៅទាំងនេះ។ អ្នកគ្រប់គ្នានៅក្នុងក្រុមមានតួនាទី ហើយក្រុមនីមួយៗមានអ្នកដឹកនាំក្រុម ដែលការងារមិនមានជាបញ្ហាដោយម្នាក់ៗនោះទេ; តួនាទីរបស់អ្នកដឹកនាំគឺសម្របសម្រួលក្រុម ដូច្នេះការងារត្រូវបានធ្វើក្នុងមធ្យោបាយដែលក្រុមទាំងមូលគឺមានមោទនភាព។

# មេរៀនសង្ខេប

និយោជកតែងប្រាថ្នាចង់ឱ្យនិយោជិតរបស់ខ្លួនមានជំនាញបច្ចេកទេសសម្រាប់ការងារ ក៏ដូចជាជំនាញទំនាក់ទំនងល្អផងដែរ ព្រោះជំនាញទាំងពីរនេះគឺសំខាន់សម្រាប់ធ្វើឱ្យស្ថាប័នទទួលបានជោគជ័យ។ ជាមួយជំនាញទំនាក់ទំនងបែបប្រសិទ្ធភាព គឺវាអាចធ្វើឱ្យនិយោជិតក្លាយទៅជាសមាជិកក្រុម និងជាអ្នកដោះស្រាយបញ្ហាដ៏មានប្រសិទ្ធភាព។ ការស្តាប់សកម្មគឺជាបច្ចេកទេសទំនាក់ទំនងដ៏មានតម្លៃសម្រាប់កន្លែងធ្វើការ វាត្រូវបានធ្វើដោយផ្តល់នូវការផ្ចង់ស្មារតីទាំងស្រុងទៅកាន់វាគ្មិន និងដោយការយកចិត្តទុកដាក់ចំពោះទំនាក់ទំនងដោយវាចា និងមិនវាចារបស់ពួកគាត់ និងរបស់យើងផ្ទាល់។ ដើម្បីការពារកុំឱ្យមានការយល់ច្រឡំ យើងចាំបាច់ត្រូវប្រើជំនាញនៃការសរសេរឡើងវិញ និងការអះអាងបញ្ជាក់។ យើងក៏ចាំបាច់ត្រូវដឹងផងដែរអំពីពេលវេលាដែលត្រូវប្រើសំណួរបិទ និងសំណួរបើក ដើម្បីរក្សាលំហូរនៃការសន្ទនារបស់យើង។

មតិយោបល់គឺជាព័ត៌មានជាក់លាក់ និងមានប្រយោជន៍ ដែលត្រូវបានផ្តល់ជាច់ដោយឡែក ដើម្បីជួយឱ្យបុគ្គលនោះមានការអនុវត្តប្រសើរឡើង។ ការសិក្សាពីរបៀបផ្តល់ និងទទួលមតិយោបល់ស្ថាបនាគឺជាគន្លឹះដើម្បីធ្វើឱ្យជំនាញរបស់យើងប្រសើរឡើង និងមានប្រសិទ្ធភាពនៅកន្លែងធ្វើការ។ ការសិក្សាពីរបៀបទទួលមតិយោបល់ស្ថាបនា គឺជួយឱ្យយើងយល់ដឹងអំពីវិធីដែលអាចធ្វើឱ្យការងារមានភាពប្រសើរ ឬការផ្លាស់ប្តូរអាកប្បកិរិយារបស់យើង។ ការដឹងពីរបៀប និងពេលវេលាដែលត្រូវផ្តល់មតិយោបល់ ក៏សំខាន់ផងដែរសម្រាប់កន្លែងធ្វើការ។

និយោជិតត្រូវតែបានក្លាយទៅជាសមាជិកក្រុមដែលមានប្រសិទ្ធភាព។ ទាំងជំនាញនៃការស្តាប់សកម្ម និងជំនាញផ្តល់មតិយោបល់គឺមានសារៈសំខាន់សម្រាប់បង្កើតក្រុមដែលមានប្រសិទ្ធភាព។ ក្រុមត្រូវបានអភិវឌ្ឍគ្រប់ពេល និងដោយផ្អែកលើការគោរព និងការទុកចិត្តសមាជិកក្រុមផ្សេងទៀត។ នៅពេលដែលក្រុមអនុវត្តការងារល្អ បរិយាកាស និងគំនិតច្នៃប្រឌិតនៅកន្លែងធ្វើការគឺនឹងត្រូវបានធ្វើឱ្យប្រសើរឡើង។

# លំហាត់

## លំហាត់ ៣

អ្នកនឹងចូលរួមដើរតួក្នុងស្ថានភាពមួយនៅក្នុងក្រុមរបស់អ្នក ដែលការស្តាប់សំខាន់។

សមាជិកម្នាក់នៃក្រុមនឹងដើរតួជាបេក្ខជនដើម្បីចូលរួមសម្ភាសន៍ការងារ សម្រាប់មុខតំណែងអ្នកអភិវឌ្ឍផ្នែកទន់។ សមាជិកនោះត្រូវតែស្តាប់ដោយយកចិត្តទុកដាក់ នូវសំណួរទាំងឡាយ ហើយត្រូវតែយល់នូវអ្វីដែលនិយោជកចង់ដឹង បន្ទាប់មកឆ្លើយតបទៅវិញដោយសមរម្យ។ សមាជិកផ្សេងទៀតនឹងដើរតួជានិយោជក ហើយសមាជិកទីបីនឹងដើរតួជាអ្នកពិនិត្យតាមដាន និងកត់ត្រាចំណាំ។ ទាំងនិយោជក និងបេក្ខជនត្រូវតែជាអ្នកស្តាប់សកម្ម។

ទាំងនេះជាសំណួរដែលនិយោជកនឹងត្រូវសួរ៖

ក. ចូរប្រាប់ខ្ញុំអំពីខ្លួនអ្នក និងបទពិសោធន៍ការងាររបស់អ្នក?

ខ. ហេតុអ្វីបានជាអ្នកចង់ធ្វើការងារនេះ?

គ. ហេតុអ្វីបានជាយើងត្រូវជ្រើសរើសយកអ្នក?

ឃ. តើអ្វីជាចំណុចខ្លាំងរបស់អ្នក?

ង. តើអ្វីជាចំណុចខ្សោយរបស់អ្នក?

ច. អ្នកអាចបន្ថែមសំណួរផ្សេងៗទៀតរបស់អ្នកនៅទីនេះបាន

អ្នកនឹងត្រូវប្តូរវេនគ្នាដើម្បីដើរតួ។
អ្នកពិនិត្យតាមដាននឹងផ្តល់នូវមតិយោបល់ស្ថាបនា សម្រាប់ទាំង "និយោជក" និង "បេក្ខជន" នៅចុងបញ្ចប់នៃការសម្តែង ដោយអនុវត្តតាមជំហាននៃការផ្តល់មតិយោបល់ស្ថាបនា។

## សំណួរត្រិះរិះ

១. តើការស្តាប់សកម្មជាអ្វី? តើវាខុសគ្នាពីការឮដូចម្តេចខ្លះ?

២. តើជំហានទាំងបួនដើម្បីក្លាយទៅជាអ្នកស្តាប់សកម្មមានអ្វីខ្លះ?

៣. តើអ្វីជាការរំខានអារម្មណ៍ខាងក្រៅ? ចូរផ្តល់ឧទាហរណ៍។

៤. តើអ្វីជាការរំខានអារម្មណ៍ខាងក្នុង? តើហេតុអ្វីបានជាវាពិបាកក្នុងការបំបាត់?

៥. ហេតុអ្វីចាំបាច់ត្រូវដឹងអំពីរបៀបផ្តល់មតិយោបល់ស្ថាបនាបែបប្រសិទ្ធភាព?

៦. ហេតុអ្វីបានជាវាពិបាកក្នុងការទទួលមតិយោបល់ស្ថាបនាបែបអវិជ្ជមាន?

៧. ហេតុអ្វីបានជាក្រុមហ៊ុនផ្តល់តម្លៃឱ្យមនុស្សដែលជាសមាជិកល្អនៅក្នុងក្រុម?

៨. តើអ្វីជាចរិតលក្ខណៈរបស់សមាជិកក្រុមដែលមានប្រសិទ្ធភាព?

ជំពូកទី ២ | ប្រព័ន្ធ

# មេរៀនទី ៣

# ការគ្រប់គ្រងប្រព័ន្ធ និង បណ្តាញ

## នៅក្នុងមេរៀននេះអ្នកនឹងសិក្សាអំពី៖

១. ការកំណត់ និងយល់ដឹងពីមុខងាររបស់ប្រព័ន្ធ និងបណ្តាញ
២. ការយល់ដឹងពីជំនាញក្នុងការគ្រប់គ្រងបណ្តាញ ប្រព័ន្ធ និងបរិស្ថានការងារ
៣. ការស្គាល់ និងយល់ដឹងអំពីការអប់រំ បំណិនទំនាក់ទំនង គោលគំនិតបច្ចេកទេស និងលក្ខណសម្បត្តិផ្សេងៗត្រូវមានដើម្បីក្លាយជាអ្នកឯកទេសផ្នែកកុំព្យូទ័រ អ្នកគ្រប់គ្រងប្រព័ន្ធ វិស្វករប្រព័ន្ធ វិស្វករបណ្តាញ ឬអ្នកគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានអាជីព
៤. ការយល់ដឹងពីកុំព្យូទ័រផ្ទាល់ខ្លួន សមាសភាគរបស់វា និងការបញ្ជូនព័ត៌មានជាមួយគ្រឿងឧបករណ៍ខាងក្រៅ កុំព្យូទ័រផ្សេងៗ និងអ៊ីនធឺណិត
៥. ការយល់ដឹងពីគ្រឿងកុំព្យូទ័រផ្នែករឹងដើម្បីអាចសម្រេចចិត្តបានត្រឹមត្រូវក្នុងការទិញកុំព្យូទ័រសម្រាប់ការងារបានត្រឹមត្រូវ និងមានប្រសិទ្ធភាព។

# ផ្នែក ក-ការងារក្នុងផ្នែកគ្រប់គ្រងប្រព័ន្ធនិងបណ្ដាញ

## ១. ការណែនាំអំពីការគ្រប់គ្រងប្រព័ន្ធ និងបណ្ដាញ

ចរណៃកំពុងសិក្សាថ្នាក់ទី១២នៅវិទ្យាល័យ ពេលបញ្ចប់ការសិក្សានៅវិទ្យាល័យ នាងបានសម្រេចចិត្តបន្តការសិក្សារបស់នាងនៅសាកលវិទ្យាល័យ ប៉ុន្តែនាងមិនប្រាកដថាត្រូវសិក្សាជំនាញអ្វីនៅសាកលវិទ្យាល័យ ដែលអាចជួយនាងរកការងារធ្វើបានល្អនៅពេលអនាគត។ នាងចង់ដឹងពីការងាររបស់កុសលជាពូរបស់នាង ដែលជាអ្នកទទួលបន្ទុកផ្នែកកុំព្យូទ័រនៅក្នុងមន្ទីរពេទ្យដ៏ល្បីមួយ។ គាត់បានប្រាប់នាងអំពីការងារដែលចាប់អារម្មណ៍នៅកន្លែងធ្វើការរបស់គាត់ និងភារកិច្ចការងារផ្សេងៗរបស់បុគ្គលិក។ នាងចាប់អារម្មណ៍នឹងការងាររបស់ពូកុសល ហើយបន្តសួរគាត់ទៀតអំពីការងាររបស់គាត់។

ចរណៃសួរថា "តើកុំព្យូទ័រចំនួនប៉ុន្មានដែលពូបានជួសជុលក្នុងមួយថ្ងៃ?"។

កុសលឆ្លើយ "សំណួរល្អ! តាមពិតទៅ ពូមិនជួសជុលកុំព្យូទ័រដោយផ្ទាល់ទេ មានបុគ្គលិកផ្សេងទទួលបន្ទុកខាងហ្នឹង។ នៅមន្ទីរពេទ្យមានកុំព្យូទ័រប្រហែល ១២០ គ្រឿង ហើយពូ និងមិត្តរួមការងារមួយចំនួនដែលទទួលបន្ទុកលើរឿងនេះ ត្រូវប្រាកដថាកុំព្យូទ័រទាំងអស់ដំណើរការបានល្អសម្រាប់ការងារ។ កុំព្យូទ័រទាំងអស់ត្រូវតែភ្ជាប់គ្នាដើម្បីអាចចែករំលែកព័ត៌មានរវាងអ្នកប្រើ ឬដើម្បីអាចចូលទៅកាន់សេវាកម្មណាមួយ ដូចជា ការផ្ញើ និងទទួលអ៊ីមែល ឬប្រើកម្មវិធីកុំព្យូទ័រជាប្រព័ន្ធដើម្បីចុះឈ្មោះអ្នកជំងឺ និងរក្សាទុកព័ត៌មានរបស់ពួកគេ។ ឧទាហរណ៍ នៅពេលអ្នកទៅពិនិត្យជំងឺនៅមន្ទីរពេទ្យដដែលលើសពីម្ដង ពួកគេមានព័ត៌មានអំពីអ្នករួចហើយ ដូចជាកាលបរិច្ឆេទពិនិត្យចុងក្រោយ ប្រតិកម្មជំងឺណាមួយ ជំងឺពីមុនៗ ព្រមទាំងការថតកាំរស្មី X ឬលទ្ធផលធ្វើតេស្តឈាមជាដើម។ ព័ត៌មានទាំងនេះនឹងអាចប្រើបានសម្រាប់វេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកានៃមន្ទីរពេទ្យនោះក្នុងការស្វែងរកព័ត៌មានអំពីអ្នកជំងឺណាម្នាក់ ប៉ុន្តែមិនមែនគ្រប់គ្នាអាចចូលប្រើបានទេ ដោយសារព័ត៌មានរបស់អ្នកជំងឺត្រូវបានរក្សាជាការសម្ងាត់។

ចរណៃបានភ្ញាក់ផ្អើលនឹងអ្វីដែលពូកុសលបានរៀបរាប់ ហើយបានសួរកុសលថា "តើហេតុអ្វីបានចាំបាច់ត្រូវរក្សាព័ត៌មានរបស់អ្នកជំងឺជាការសម្ងាត់?"

"ពិតជាសំណួរល្អណាស់ ចរណៃ។ ឥឡូវពូពន្យល់ថាហេតុអ្វីត្រូវរក្សាទុកព័ត៌មានរបស់អ្នកជំងឺឱ្យមានសុវត្ថិភាព។ ការសម្ងាត់ ជាការការពារព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកណាម្នាក់ ឬស្ថាប័នណាមួយ។ ដូចជាព័ត៌មានសុខភាពរបស់អ្នកដែលអ្នកមិនចង់ឱ្យមិត្តរួមថ្នាក់ និងគ្រូរបស់អ្នកបានដឹង។ ដូចករណីអ្នកដាក់ពាក្យធ្វើការដែរ។ និយោជកប្រហែលអាចមិនជ្រើសរើស ឬជួលអ្នកបានទេ ប្រសិនបើគាត់ដឹងថាអ្នកមានបញ្ហាសុខភាព ព្រោះពួកគេគិតថាបុគ្គលនោះនឹង



ឈប់ញឹកញាប់ និងពិបាកជឿជាក់បាន។ ហើយប្រសិនបើអ្នកត្រូវបានជួលរួចហើយ អ្នកអាចមិនចង់ប្រាប់អ្នករួមការងាររបស់អ្នកឱ្យដឹងអំពីជីវិតផ្ទាល់ខ្លួនរបស់អ្នក លុះត្រាតែអ្នកសម្រេចប្រាប់ពួកគេឱ្យដឹង។ ស្ថាប័នផ្សេងៗ ដូចជាធនាគារ និងសាលារៀនក៏រក្សាទុកព័ត៌មានរបស់អ្នកជាសម្ងាត់ដែរ។

ពូកុសលក៏បានពន្យល់ប្រាប់ថា៖ "យើងរក្សាទុកព័ត៌មានរបស់អ្នកជំងឺទាំងអស់នៅក្នុងកុំព្យូទ័រម៉ាស៊ីនមេ។ កាលពីមុន វាងាយនឹងបាត់បង់ព័ត៌មានណាស់ ព្រោះព័ត៌មានទាំងអស់ត្រូវបានរក្សាទុកនៅលើក្រដាស។ ឥឡូវមានកុំព្យូទ័រដែលបានដំឡើងយ៉ាងពិសេសសម្រាប់រក្សាទុកព័ត៌មានលម្អិតផ្សេងៗ។ ព័ត៌មានត្រូវបានរក្សាទុកដោយបំប្លែងជាកូដដែលមើលមិនយល់ ហើយមានតែបុគ្គលដែលមានសិទ្ធិអនុញ្ញាតកម្រិតខ្ពស់ទើបអាចចូលមើលព័ត៌មាននោះបាន។ ហើយក៏មានកុំព្យូទ័រម៉ាស៊ីនមេផ្សេងៗដែលអាចប្រើដើម្បីផ្ទុកកម្មវិធីនានាដែលយើងអាចប្រើបាន ដើម្បីគ្រប់គ្រងម៉ាស៊ីនបោះពុម្ព និងគ្រឿងឧបករណ៍ផ្សេងៗ ឬដើម្បីគ្រប់គ្រងអ៊ីនធឺណិត និងសេវាកម្មអ៊ីមែល។ យើងថែទាំកុំព្យូទ័រម៉ាស៊ីនមេទាំងអស់នេះ និងប្រើប្រព័ន្ធការពារវាផងដែរ ដើម្បីជៀសវាងការវាយប្រហារដោយមេរោគ ឬអ្នកលួចព័ត៌មាន។

ចរណៃបាននិយាយថា "ខ្ញុំពិតជាមិនចង់ឱ្យអ្នកណាម្នាក់ដឹងព័ត៌មានផ្ទាល់ខ្លួនរបស់ខ្ញុំដោយគ្មានការអនុញ្ញាតពីខ្ញុំទេ ប៉ុន្តែខ្ញុំមិនដែលគិតអំពីនេះពីមុនមកទេ។ ពូពិតជាមានការងារដ៏សំខាន់មែន! តើពេលណាពូនាំខ្ញុំទៅសិក្សាស្វែងយល់នៅមន្ទីរពេទ្យដែលពូធ្វើការ?"

អ្នកប្រើភាគច្រើននៅក្រុមហ៊ុនតែងតែមានកុំព្យូទ័រប្រើប្រាស់ផ្ទាល់ខ្លួន ដែលពួកគេទាំងនោះមិនដឹងពីរបៀបដំឡើង និងជួសជុលវាឡើយ។ ម្យ៉ាងវិញទៀតកុំព្យូទ័រទាំងនេះអាចភ្ជាប់មកជាមួយនូវគ្រឿងឧបករណ៍អេឡិចត្រូនិកដូចជា ម៉ាស៊ីនបោះពុម្ព ឬស្កេនជាដើម ដែលអាចសម្រួលដល់ការងារ និងទំនាក់ទំនងរវាងបុគ្គលិកផ្សេងៗនៅក្នុងស្ថាប័ននោះ។ ជាមូលដ្ឋាន ប្រព័ន្ធកុំព្យូទ័រផ្សំឡើងដោយបណ្ដាញកុំព្យូទ័រ និងកុំព្យូទ័រម៉ាស៊ីនមេ។

នៅក្នុងបរិស្ថានការងារជំនួញ កុំព្យូទ័រត្រូវភ្ជាប់ទំនាក់ទំនងគ្នា និងរៀបចំរចនាសម្ព័ន្ធដើម្បីអាចប្រាស្រ័យទាក់ទងជាមួយគ្នាបាន អនុញ្ញាតឱ្យបុគ្គលិកបំពេញការងាររបស់ពួកគេបានយ៉ាងប្រសើរ។ ការកំណត់រចនាសម្ព័ន្ធបែបនោះត្រូវបានឱ្យឈ្មោះថា ប្រព័ន្ធកុំព្យូទ័រ និងមានការតភ្ជាប់រវាងកុំព្យូទ័រពីរ ឬច្រើនដែលបង្កើតជាបណ្ដាញមជ្ឈមណ្ឌលចែករំលែកព័ត៌មានរួមមួយ ជាឧបករណ៍ទំនាក់ទំនង និងគ្រឿងឧបករណ៍បន្ថែមផ្សេងៗទៀត ដូចជាម៉ាស៊ីនបោះពុម្ព ឬស្កេនជាដើម។ ការកំណត់រចនាសម្ព័ន្ធមានន័យថាជាការកែសម្រួលប្រព័ន្ធផ្នែករឹង និងកម្មវិធីកុំព្យូទ័រផ្នែកទន់តាមតម្រូវការជាក់លាក់ណាមួយរបស់ក្រុមហ៊ុន និងអ្នកប្រើ ធានាបានថាគ្រឿងកុំព្យូទ័រផ្នែករឹង និងកម្មវិធីកុំព្យូទ័រផ្នែកទន់ស្គាល់គ្នាអាចដំណើរការបានដូចការរំពឹងទុក។

*ការគ្រប់គ្រងប្រព័ន្ធ និងបណ្ដាញ គឺជាពាក្យដែលគេប្រើសម្គាល់ដំណើរការ និងការពិនិត្យមើលប្រតិបត្តិការគ្រឿងកុំព្យូទ័រផ្នែករឹង និងកម្មវិធីកុំព្យូទ័រផ្នែកទន់នៅក្នុងក្រុមហ៊ុន ឬកន្លែងធ្វើការមួយ។ វិជ្ជាជីវៈដែលប្រើនៅក្នុងការបំពេញការងារក្នុងវិស័យនេះត្រូវមានការបណ្ដុះបណ្ដាលបច្ចេកទេសផ្នែកប្រព័ន្ធព័ត៌មានវិទ្យា។*

នៅក្នុងក្រុមហ៊ុន នៅពេលដែលអ្នកប្រើសហការគ្នាលើគម្រោងរួមមួយ ពួកគេត្រូវការធ្វើការនៅលើឯកសារ និងថតដូចគ្នានៅពេលដំណាលគ្នា។ មធ្យោបាយជាមូលដ្ឋានដើម្បីសម្រួលដល់ការចែករំលែកនេះ គឺដើម្បីឱ្យអ្នកប្រើកុំព្យូទ័រផ្សេងៗអាចចូលប្រើឯកសារ ឬថតដែលបានចែករំលែកពីគ្រប់កុំព្យូទ័ររបស់អ្នកប្រើទាំងអស់។ កុំព្យូទ័រដែលបានរៀបចំជាពិសេសដែលអាចរក្សាទុកព័ត៌មានរបស់អ្នកប្រើ និងចែកចាយទៅអ្នកប្រើផ្សេងៗទៀតត្រូវបានគេហៅថា កុំព្យូទ័រម៉ាស៊ីនមេ។ កុំព្យូទ័រម៉ាស៊ីនមេទាំងនេះ ជាធម្មតាមានកម្រិតដំណើរការខ្ពស់ជាងកុំព្យូទ័រធម្មតា ព្រោះប្រសិនបើយើងប្រើកុំព្យូទ័រមិនល្អ នៅពេលដែលវាខូចនោះឯកសាររបស់បុគ្គលិកទាំងអស់នឹងត្រូវបាត់បង់។ ពេលខ្លះកុំព្យូទ័រម៉ាស៊ីនមេមានផ្នែកសំខាន់ស្ទួនគ្នាពីរ ឬបី ដើម្បីជៀសវាងពេលផ្នែកណាមួយខូចក៏វានៅតែអាចដំណើរការបាន។ ជាធម្មតា កុំព្យូទ័រម៉ាស៊ីនមេត្រូវបានរៀបចំសម្រាប់ការងារពិសេសៗ និងមានលក្ខណៈមុខងារជាក់លាក់តាមគោលបំណងរបស់អ្នកគ្រប់គ្រង កុំព្យូទ័រមេខ្លះប្រើសម្រាប់ធ្វើជាមជ្ឈមណ្ឌលផ្ទុកឯកសារ និងអាចប្រើជាមធ្យោបាយសម្រួលដល់ការប្រាស្រ័យទាក់ទងនានា។




អ៊ីនធឺណិតក៏ដំណើរការនៅលើកុំព្យូទ័រម៉ាស៊ីនមេដែរ។ ម៉ាស៊ីនមេបណ្ដាញ គឺជាកន្លែងដែលទំព័របណ្ដាញត្រូវបានរក្សាទុក និងត្រូវតែបើកដំណើរការ ២៤ ម៉ោងក្នុងមួយថ្ងៃជានិច្ចជាមួយនឹងការតភ្ជាប់អ៊ីនធឺណិត ដើម្បីអាចឱ្យអ្នកប្រើចូលទៅកាន់ព័ត៌មាននៅពេលណាក៏បានពីកន្លែងណាមួយនៅលើពិភពលោក។ ជាធម្មតា ម៉ាស៊ីនមេបណ្ដាញមានទីតាំងនៅតំបន់ជាក់លាក់មួយដែលធានាសុវត្ថិភាព និងមានការតភ្ជាប់អ៊ីនធឺណិតល្អជាពិសេស។



ក្រុមហ៊ុនខ្លះចែករំលែកព័ត៌មានអ្វីមួយដែលបុគ្គលិកត្រូវការក្នុងបណ្តាញឈ្មោះថា "អ៊ីនត្រាណិត - Intranet"។ អ៊ីនត្រាណិត គឺដូចជាអ៊ីនធឺណិតតូចមួយអញ្ចឹង ដែលអាចចូលប្រើបានដោយបុគ្គលិករបស់ក្រុមហ៊ុននោះតែប៉ុណ្ណោះ ដោយសារតែព័ត៌មានរបស់ពួកគេមិនត្រូវបានផ្សាយជាសាធារណៈ។ អ៊ីនត្រាណិតត្រូវការប្រភេទកុំព្យូទ័រម៉ាស៊ីនមេដូចគ្នាដែលអាចប្រើសម្រាប់អ៊ីនធឺណិតធម្មតា។

ម៉ាស៊ីនមេរក្សាទុកទិន្នន័យ ជាម៉ាស៊ីនទាំងឡាយណាដែលត្រូវបានប្រើដើម្បីរក្សាទុក ឬផ្ទុកព័ត៌មានរបស់ក្រុមហ៊ុន។ ម៉ាស៊ីនមេនេះត្រូវតែការពារសុវត្ថិភាពបំផុត ដែលក្រុមហ៊ុនអាចជឿជាក់លើម៉ាស៊ីនមេក្នុងការការពារឯកសារ និងរក្សាទុកព័ត៌មានសំខាន់ៗដោយមិនបារម្ភអំពីការបាត់បង់វា ឬអ្នកណាម្នាក់លួចវាបាន។ ម៉ាស៊ីនមេទាំងនេះជាធម្មតាត្រូវបានរក្សាទុកនៅក្នុងបន្ទប់មួយដែលចាក់សោសុវត្ថិភាពខ្ពស់ និងបំពាក់ដោយម៉ាស៊ីនត្រជាក់ ដើម្បីជៀសវាងសីតុណ្ហភាពប្រែប្រួលប៉ះពាល់ដំណើរការម៉ាស៊ីនមេ និងធូលីធ្វើឱ្យខូច ឬគាំង។

បណ្តាញកុំព្យូទ័រ គឺជាផ្នែកមួយនៃប្រព័ន្ធកុំព្យូទ័រដែលអនុញ្ញាតឱ្យកុំព្យូទ័រធ្វើការផ្លាស់ប្តូរទិន្នន័យ ចូលប្រើអ៊ីនធឺណិត និងប្រាស្រ័យទាក់ទងជាមួយអ្នកប្រើផ្សេងៗ (ឧ. ការប្រើអ៊ីមែល បណ្តាញសង្គមជាដើម)។ បណ្តាញផ្សំដោយការតភ្ជាប់រវាងកុំព្យូទ័រតាមរយៈខ្សែបណ្តាញ ក៏ដូចជាឧបករណ៍ដែលជាចំណុចតភ្ជាប់ខ្សែបណ្តាញទាំងអស់ និងសម្រួលដល់ការបញ្ជូនព័ត៌មានទៅវិញទៅមក។ ក្នុងករណីខ្លះ បណ្តាញរួមមានការប្រាស្រ័យទាក់ទងដែលមិនប្រើខ្សែ ដូចការប្រើរលកវិទ្យុដើម្បីផ្តល់ព័ត៌មានដែរ។ នេះជាការប្រើតភ្ជាប់ឥតខ្សែ (ហៅថាវ៉ាយហ្វាយ – WiFi) តាមរយៈកុំព្យូទ័រដែលបានតភ្ជាប់ទៅអ៊ីនធឺណិត។ បណ្តាញអាចប្រើបានទាំងមានខ្សែ និងឥតខ្សែ។

នៅពេលបណ្តាញមានទ្រង់ទ្រាយធំជាងបន្ទប់ ឬទីតាំងមួយ វាត្រូវបានឱ្យឈ្មោះថា "បណ្តាញទូរគមនាគមន៍"។ បណ្តាញទូរគមនាគមន៍ គឺសំដៅលើការផ្លាស់ប្តូរព័ត៌មានក្នុងរយៈចម្ងាយមួយ។ ជាទូទៅមានស្ថានីយបញ្ជូន និងទទួលច្រើននៅក្នុងបណ្តាញទូរគមនាគមន៍។ ឧបករណ៍ភ្ជាប់បណ្តាញរួមមានម៉ាស៊ីនមេ ស្វីត គ្រឿងផ្នែករឹងពិសេសផ្សេងៗ និងកន្លែងផ្ទុក។ បណ្តាញទូរសព្ទ គ្របដណ្តប់ពាសពេញផ្ទៃប្រទេស និងរាលដាលដល់មនុស្សភាគច្រើន ដែលជាបណ្តាញទូរគមនាគមន៍ដ៏ធំបំផុតមួយនៅលើពិភពលោក។ វាអនុញ្ញាតឱ្យយើងប្រាស្រ័យទាក់ទងគ្នាបានតាមរយៈសំឡេង និងសារខ្លី ប៉ុន្តែវាក៏អាចប្រើដើម្បីផ្ញើសារជារូបភាពតាមរយៈ MMS ជាបច្ចេកវិទ្យាដែលគេលែងសូវនិយមប្រើ។

បច្ចេកវិទ្យាផ្ទុកព័ត៌មានរួមមួយនៅលើម៉ាស៊ីនមេ ដែលមាននៅលើអ៊ីនធឺណិត ជំនួសឱ្យឱ្យការផ្ទុកលើឧបករណ៍ផ្ទុកក្នុងក្រុមហ៊ុន គេហៅថា "Cloud Computing"។ ដោយហេតុថាអ៊ីនធឺណិតបានក្លាយជាកន្លែងដ៏ពេញនិយមកាន់តែខ្លាំង ក្រុមហ៊ុនខ្លះលែងត្រូវការកុំព្យូទ័រម៉ាស៊ីនមេនៅក្នុងការិយាល័យរបស់ពួកគេទៀត ហើយ ពួកគេផ្ទុកព័ត៌មានរបស់ពួកគេទាំងអស់នៅក្នុងកុំព្យូទ័រម៉ាស៊ីនមេដែលស្ថិតនៅលើអ៊ីនធឺណិត ដែលអាចឱ្យពួកគេចូលទៅកាន់ព័ត៌មានរបស់ពួកគេតាមរយៈអ៊ីនធឺណិតបានគ្រប់ពេលនៅពេលដែលពួកគេត្រូវការ។ ពេលខ្លះ ម៉ាស៊ីនមេទាំងនេះនៅលើអ៊ីនធឺណិត បានក្លាយជាផ្នែកមួយនៃបណ្តាញរបស់ក្រុមហ៊ុន។

*អ៊ីនធឺណិតជាបណ្តាញទូរគមនាគមន៍មួយ ដែលភ្ជាប់ទំនាក់ទំនងរវាងកុំព្យូទ័ររាប់លានគ្រឿងជាមួយគ្នាពេញពិភពលោក ហើយវាអនុញ្ញាតឱ្យបញ្ជូនទៅវិញទៅមកគ្រប់ប្រភេទព័ត៌មាន ដែលរួមមានដូចជាសំឡេង សារ រូបភាព ឬវីដេអូ។ល។ នៅចុងឆ្នាំ ២០១៤ មានវេបសាយ ឬទំព័របណ្តាញជាង ១ ពាន់លាននៅលើអ៊ីនធឺណិត។*

# ២. តម្រូវការការងារ

## ការអប់រំ បំណិន និងបទពិសោធន៍

អាជីពការងារដែលមាននៅក្នុងផ្នែកជាអ្នកគ្រប់គ្រងប្រព័ន្ធ និងបណ្ដាញអាចមានតំណែង និងតួនាទីការងារខុសៗគ្នាទៅតាមបទពិសោធន៍ ភារកិច្ចការងារ និងទំនួលខុសត្រូវរបស់ពួកគេ។ តួនាទីការងារនៅក្នុងផ្នែកគ្រប់គ្រងប្រព័ន្ធមានដូចជា៖ អ្នកឯកទេសជំនួយផ្នែកកុំព្យូទ័រ អ្នកគ្រប់គ្រងប្រព័ន្ធ វិស្វករប្រព័ន្ធ វិស្វករបណ្ដាញ និងអ្នកគ្រប់គ្រងព័ត៌មានវិទ្យា។




- **អ្នកឯកទេសជំនួយផ្នែកកុំព្យូទ័រ៖** តួនាទីនេះជាចំណុចចាប់ផ្ដើមមួយនៅក្នុងអាជីពជាអ្នកគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ។ អ្នកឯកទេសជំនួយផ្នែកកុំព្យូទ័រជាអ្នកជំនាញដំឡើង ឬជួសជុលគ្រឿងឧបករណ៍កុំព្យូទ័រ និងធ្វើការថែទាំបណ្ដាញឱ្យដំណើរការជាទៀងទាត់ ប៉ុន្តែការងារភាគច្រើនរបស់ពួកគេ គឺចំណាយពេលជួយអ្នកប្រើធ្វើយ៉ាងណាឱ្យពួកគេប្រើកុំព្យូទ័របានស្រួល និងជួយកំណត់រចនាសម្ព័ន្ធកម្មវិធីតាមមធ្យោបាយដែលអ្នកប្រើចង់បាន។ អ្នកឯកទេសជំនួយផ្នែកកុំព្យូទ័រធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកប្រើដោយទាក់ទងផ្ទាល់ ឬតាមរយៈទូរសព្ទ និងអ៊ីមែលប្រសិនបើក្រុមហ៊ុននោះធំ ដើម្បីដោះស្រាយបញ្ហាគ្រឿងផ្នែករឹង និងកម្មវិធីផ្នែកទន់។ ការងាររបស់ពួកគេ រួមមានការថែទាំកុំព្យូទ័រកុំឱ្យមានមេរោគរំខានដោយដំឡើងកម្មវិធីប្រឆាំងនឹងមេរោគក្នុងគ្រប់កុំព្យូទ័រទាំងអស់នៅក្នុងស្ថាប័ន។ ការងារទាំងនេះមិនត្រូវការបទពិសោធន៍ពីមុនៗមក ឬកម្រិតវប្បធម៌បរិញ្ញាបត្រទេ ប៉ុន្តែអ្នកដាក់ពាក្យសុំការងារនេះភាគច្រើនបានបញ្ចប់ការសិក្សាខ្លះៗក្នុងផ្នែកកុំព្យូទ័រ អាចនៅសាលាបច្ចេកទេស ដើម្បីពួកគេអាចចាប់ផ្ដើមការងារជាមួយចំណេះដឹងខ្លះៗ និងអាចកសាងបំណិនរបស់ពួកគេដើម្បីក្លាយជាសមាជិកដ៏មានប្រយោជន៍របស់ក្រុមការងារ។

*កម្មវិធីកម្ចាត់មេរោគ គឺជាកម្មវិធីកុំព្យូទ័រដែលការពារកុំព្យូទ័ររបស់អ្នកដោយរកឃើញ ទប់ស្កាត់ និងលុបចេញកម្មវិធីដែលប៉ុនប៉ងដំណើរការដោយអ្នកមិនដឹង។ មេរោគកុំព្យូទ័របានបង្កើតឡើង និងអាចបំផ្លាញកុំព្យូទ័ររបស់អ្នក ដែលជាមូលហេតុអ្នកត្រូវការពារប្រឆាំងវាដាច់ខាត។*

អ្នកឯកទេសជំនួយផ្នែកកុំព្យូទ័រត្រូវតែមានគំនិតច្បាស់លាស់ទាក់ទងនឹងជំនាញដោះស្រាយបញ្ហា និងការងារកុំព្យូទ័រផ្សេងៗ។ ពួកគេត្រូវតែអភិវឌ្ឍទេពកោសល្យរបស់ខ្លួនដើម្បីរកឱ្យឃើញបញ្ហា និងចេះដោះស្រាយវាឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា។

បំណិនទំនាក់ទំនងសំខាន់ៗត្រូវមានបំណិនស្ដាប់ដោយប្រុងប្រយ័ត្នពីបញ្ហារបស់អ្នកប្រើ សួរសំណួរ ដើម្បីធ្វើការវិនិច្ឆ័យលើបញ្ហាឱ្យបានត្រឹមត្រូវ ទេពកោសល្យនិយាយ និងពន្យល់ឱ្យបានច្បាស់ ដើម្បីឱ្យអ្នកប្រើយល់ពីជំហានក្នុងការដោះស្រាយបញ្ហា ហើយអាចសរសេររបាយការណ៍បន្ទាប់ពីបានអនុវត្តការងារនីមួយៗ។ នេះជាការងារ "ជួបមុខ" និងរក្សាអាកប្បកិរិយាវិជ្ជមានជាមួយស្នាមញញឹមជានិច្ច ដែលនឹងជួយបង្កើនទំនាក់ទំនងល្អ និងស្និទ្ធស្នាលនៅកន្លែងការងារ។

មានតម្រូវការរូបវន្តមួយចំនួនដែលទាក់ទងនឹងការងារជាអ្នកឯកទេសជំនួយផ្នែកកុំព្យូទ័រ ពីព្រោះការលើកទុកដាក់ ឬយួរកុំព្យូទ័រ និងលុតក្រាបជាផ្នែកនៃការងារដំឡើង និងជួសជុលកុំព្យូទ័រ ប៉ុន្តែក៏មានការងារខ្លះផ្សេងៗដែលចាំបាច់ត្រូវការជំនួយពីអ្នកដៃរ ដូចជាការលើកទុកដាក់គ្រឿងសម្ភារៈធ្ងន់ៗ។ បំណិនផ្សេងៗដែលចាំបាច់សម្រាប់ការងារនេះមានដូចជាបំណិនដោះស្រាយបញ្ហា គំនិតច្បាស់លាស់ទាក់ទងនឹងការងារកុំព្យូទ័រ និងសមត្ថភាពជួសជុលម៉ាស៊ីនជាដើម។

ឱកាសដែលអាចឈានទៅមុខសម្រាប់ការងារទាំងនេះត្រូវការអ្នកដែលអនុវត្តការងារបានប្រសើរ និងមានបទពិសោធន៍ការងារ។ ភាគច្រើនត្រូវមានកម្រិតបរិញ្ញាបត្រពីសាកលវិទ្យាល័យ ដើម្បីអាចឈានទៅកម្រិតបន្ទាប់។

- **អ្នកគ្រប់គ្រងប្រព័ន្ធ៖** មនុស្សដែលនៅក្នុងមុខតំណែងនេះមានទំនួលខុសត្រូវក្នុងការថែទាំប្រព័ន្ធកុំព្យូទ័ររបស់ក្រុមហ៊ុន ឬស្ថាប័នមួយ ពួកគេជាអ្នកដាក់ការងារ និងគ្រប់គ្រងអ្នកឯកទេសជំនួយផ្នែកកុំព្យូទ័រ។ នៅក្នុងក្រុមហ៊ុនខ្លះ ពួកគេអាចទទួលខុសត្រូវក្នុងការគ្រប់គ្រងម៉ាស៊ីនមេផងដែរ និងរួមមានការដំឡើង ថែទាំ និងធ្វើបច្ចុប្បន្នភាពម៉ាស៊ីនមេ ក៏ដូចជាធ្វើការបម្រុងទុក (សុវត្ថិភាពចម្លង) ការពារទិន្នន័យពីការលួច ឬចារកម្ម និងធានាថាអ៊ីមែល និងបណ្ដាញផ្ទុកទិន្នន័យដំណើរការល្អ។ អ្នកគ្រប់គ្រងបណ្ដាញជួយសម្រួល និងធានាកន្លែងការងាររបស់បុគ្គលិកឱ្យធ្វើការឱ្យដំណើរការបានប្រសើរសម្រាប់គ្រប់គ្នា និងតភ្ជាប់កុំព្យូទ័រទាំងអស់ទៅកាន់ម៉ាស៊ីនមេរួមមួយ។

តំណែងនេះត្រូវការកម្រិតបរិញ្ញាបត្រ ឬសញ្ញាបត្រឯកទេសក្នុងផ្នែកដែលទាក់ទងដូចជាផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ, វិស្វករប្រព័ន្ធ ឬការគ្រប់គ្រងព័ត៌មានវិទ្យា។ អ្នកជំនាញជាច្រើនក្នុងតំណែងនេះមានសញ្ញាបត្រច្រើនសន្ទឹកសន្ធាប់។

សញ្ញាបត្រជាទូទៅត្រូវបានផ្ដល់ជូនដោយក្រុមហ៊ុនឯកជនដែលអ្នកទទួលគឺជាអ្នកឯកទេសលើប្រធានបទបច្ចេកទេសណាមួយ (ឧ. ការគ្រប់គ្រងលីនុច, ការគ្រប់គ្រងម៉ាស៊ីនមេ, ឬបណ្ដាញ Cisco) វាជាភស្តុតាងដែលបញ្ជាក់ថាពួកគេមានចំណេះដឹងគ្រប់គ្រាន់ និងចាំបាច់ក្នុងការអនុវត្តការងារដែលទាក់ទងនឹងបច្ចេកទេសជាក់លាក់ណាមួយ។

លក្ខណៈពិសេសដែលអ្នកគ្រប់គ្រងប្រព័ន្ធត្រូវមាន គឺពួកគេជាមនុស្សដែលរីករាយនឹងការងារអត់ធ្មត់ និងមានភាពបត់បែន។

ដើម្បីអនុវត្ត និងគ្រប់គ្រងការងារបច្ចេកទេសខាងលើ អ្នកគ្រប់គ្រងប្រព័ន្ធដែលល្អត្រូវតែមានបំណិនបច្ចេកទេស យល់ដឹងច្បាស់ពីគ្រឿងកុំព្យូទ័រផ្នែករឹង កម្មវិធីកុំព្យូទ័រផ្នែកទន់ និងឧបករណ៍កុំព្យូទ័រផ្សេងៗទៀត។ អំឡុងពេលសិក្សានៅសាកលវិទ្យាល័យ និង ក្រៅពីបង្កើនការយល់ដឹងអំពីការគ្រប់គ្រងប្រព័ន្ធ នៅកន្លែងធ្វើការ អ្នកគ្រប់គ្រងប្រព័ន្ធនឹងត្រូវអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈផ្សេងៗទៀត ដូចជាបំណិនភាពជាអ្នកដឹកនាំ ការគ្រប់គ្រងពេលវេលា និងបំណិនចាត់ចែងការងារ ព្រមទាំងសមត្ថភាពធ្វើការបានក្រោមសម្ពាធការងារ។ បំណិនទំនាក់ទំនងដែលអ្នកគ្រប់គ្រងប្រព័ន្ធត្រូវមានរួមមានជំនាញឯកទេសទាំងឡាយណាដែលជួយគាំទ្រអតិថិជន រួមទាំងសមត្ថភាពធ្វើការជាមួយគ្នា និងគ្រប់គ្រងលក្ខណៈបុគ្គលដែលលំបាក។

នៅក្នុងក្រុមហ៊ុនធំ ជាទូទៅអ្នកគ្រប់គ្រងប្រព័ន្ធត្រូវធ្វើតាមសេចក្ដីណែនាំដែលបានផ្ដល់ដោយវិស្វករប្រព័ន្ធ។

- **វិស្វករប្រព័ន្ធ៖** វិស្វករប្រព័ន្ធ គឺតំណែងជាអ្នកគ្រប់គ្រងដ៏សំខាន់នៅក្នុងផ្នែកកុំព្យូទ័រ។ វិស្វករប្រព័ន្ធជាអ្នករៀបចំប្រព័ន្ធកុំព្យូទ័រ ធ្វើការសម្រេចពីប្រភេទរចនាសម្ព័ន្ធកុំព្យូទ័រ សមាសភាគ កម្មវិធីកុំព្យូទ័រ និងបណ្ដាញ ដែលគួរប្រើនៅក្នុងការងារណាមួយ ផ្អែកលើសេវាកម្មដែលចាំបាច់ និងចំនួនអ្នកប្រើ។ វិស្វករប្រព័ន្ធផ្ដល់ការចង្អុលបង្ហាញដល់អ្នកគ្រប់គ្រងប្រព័ន្ធ និងណែនាំពួកគេលើការដំឡើង ថែទាំ និងធ្វើបច្ចុប្បន្នភាពឧបករណ៍។ វិស្វករប្រព័ន្ធរាយការណ៍ទៅប្រធានគ្រប់គ្រងផ្នែកបច្ចេកវិទ្យាព័ត៌មាន ជួយរៀបចំប្រព័ន្ធរបស់ស្ថាប័ន និងធ្វើតាមផែនការគម្រោងដែលបានរៀបចំដោយនាយកគ្រប់គ្រងផ្នែកព័ត៌មានវិទ្យា។ ផ្នែកដ៏សំខាន់នៃការទទួលខុសត្រូវរបស់វិស្វករប្រព័ន្ធលើការងារគ្រប់គ្រងប្រព័ន្ធ គឺជួយរៀបចំ និងធ្វើគម្រោងបណ្ដាញថ្មីដែលគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ជាក់លាក់មួយ។

វិស្វករប្រព័ន្ធត្រូវមានកម្រិតបរិញ្ញាបត្រផ្នែកព័ត៌មានវិទ្យា ឯកទេសវិស្វករប្រព័ន្ធកុំព្យូទ័រ និងត្រូវតែមានជំនាញច្រើនជាងអ្នកគ្រប់គ្រងប្រព័ន្ធ។ វិស្វករប្រព័ន្ធជាច្រើនមានកម្រិតវប្បធម៌ថ្នាក់អនុបណ្ឌិត និងសញ្ញាបត្រជំនាញផ្សេងៗទៀត។ ពួកគេត្រូវឆ្លងកាត់វគ្គសិក្សាលើមុខជំនាញដូចជាវគ្គគ្រប់គ្រងប្រព័ន្ធកម្រិតខ្ពស់ ឬសុវត្ថិភាពកុំព្យូទ័រ និងបណ្ដាញ។ ជាទូទៅ ពួកគេត្រូវមានបទពិសោធន៍យ៉ាងហោចណាស់ពី ៥ ទៅ ៧ ឆ្នាំជាអ្នកគ្រប់គ្រងប្រព័ន្ធ ឬមុខតំណែងស្រដៀងគ្នា មុនពេលផ្ដល់ការអនុញ្ញាតឱ្យដំឡើងតំណែងជាវិស្វករប្រព័ន្ធដែលខ្ពស់ជាងនេះ។



ក្នុងអំឡុងឆ្នាំនៃការទទួលបានបទពិសោធន៍ អ្នកធ្វើការទទួលបាននូវបំណិនសំខាន់ៗមួយចំនួន និងអភិវឌ្ឍខ្លួនឯងតាមរយៈការរៀនសូត្រពីគ្នាទៅវិញទៅមក បំណិនទាំងនេះរួមមានបំណិនបច្ចេកទេស និងអាចមានបំណិនដែលសំខាន់ទៀតដូចជា បំណិនអន្តរបុគ្គល។ វិស្វករប្រព័ន្ធត្រូវតែអាចប្រាស្រ័យទាក់ទងជាមួយមនុស្សទាំងអស់ដែលពាក់ព័ន្ធនឹងផ្នែករបស់ពួកគេ ដូចជាវិស្វករផ្សេងទៀត អ្នកប្រើ អតិថិជន អ្នកគ្រប់គ្រង និងរដ្ឋបាលផ្សេងៗ។ ដើម្បីអាចដោះស្រាយបញ្ហាផ្សេងៗដែលអាចកើតមានជាញឹកញាប់ វិស្វករប្រព័ន្ធត្រូវតែមានជំនាញស្តាប់ស្ទាត់ជំនាញ ការចេះយល់ពីតម្រូវការ និងការលើកទឹកចិត្តអ្នកផ្សេងៗ និងគ្រប់គ្រងទំនាស់។

ក្នុងនាមជាអ្នកដឹកនាំ វិស្វករប្រព័ន្ធត្រូវតែចេះថ្លឹងថ្លែងធ្វើការសម្រេចចិត្តផ្អែកលើការវិភាគស្ថានភាព ដែលមានបំណិនធ្វើការសម្រេចចិត្តខ្លាំងជាចាំបាច់។ ពួកគេត្រូវចេះប្រមូលព័ត៌មានឱ្យសព្វគ្រប់ជ្រុងជ្រោយ ថ្លឹងថ្លែងបញ្ហា ធ្វើការសម្រេចចិត្តអ្វីដែលសំខាន់ និងវាយតម្លៃសកម្មភាពផ្សេងៗដែលមានប្រយោជន៍ និងគុណវិបត្តិនានា មុនពេលធ្វើការសម្រេចចិត្តណាមួយ។

- **វិស្វករបណ្តាញ៖** នៅក្នុងក្រុមហ៊ុនខ្នាតតូចៗ វិស្វករប្រព័ន្ធ និងវិស្វករបណ្តាញអនុវត្តមុខងារប្រហាក់ប្រហែលគ្នាជាច្រើន ប៉ុន្តែក្រុមហ៊ុនខ្នាតធំៗវិញមុខងារទាំងពីរនេះ គឺខុសគ្នា។ វិស្វករបណ្តាញ គឺមានទំនួលខុសត្រូវសម្រាប់ការរចនា, រៀបចំ និងថែទាំបណ្តាញទំនាក់ទំនង។ វិស្វករបណ្តាញ គឺមានទំនួលខុសត្រូវសម្រាប់ផ្តល់ទិន្នន័យ ដែលរួមមានអ៊ីនធឺណិត និងអ៊ីនត្រាណិតប្រព័ន្ធទូរសព្ទ ឧបករណ៍ចល័ត និងមានទំនួលខុសត្រូវក្នុងការតភ្ជាប់បណ្តាញតូចៗ ជាមួយបច្ចេកវិទ្យាទំនាក់ទំនងបណ្តាញធំ ឬតាមផ្កាយរណប ដើម្បីបង្កើតបានជាបណ្តាញសកល។

វិស្វករបណ្តាញត្រូវការកម្រិតវប្បធម៌បរិញ្ញាបត្រក្នុងផ្នែកបច្ចេកវិទ្យាព័ត៌មាន ឬផ្នែកដែលទាក់ទង ក៏ដូចជាសញ្ញាបត្រក្នុងមុខជំនាញបណ្តាញច្បាស់លាស់មួយ។ វិស្វករបណ្តាញភាគច្រើនផ្លាស់ចូលធ្វើការនៅក្នុងមុខតំណែងនេះបាន បន្ទាប់ពីពួកគេមានបទពិសោធន៍ពី ៤ ទៅ ៧ ឆ្នាំឡើងទៅក្នុងការងារស្រដៀងគ្នានេះ។ និយោជកខ្លះស្វែងរកបុគ្គលិកដែលមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម ឬហៅថា MBA ក្នុងជំនាញព័ត៌មានវិទ្យា ព្រោះនេះជាមុខតំណែងជាអ្នកគ្រប់គ្រងនៅក្នុងក្រុមហ៊ុនមួយ។ វិស្វករបណ្តាញតែងតែជាអ្នកដឹកនាំការងារផ្សេងៗដែលទាក់ទងនឹងការបង្កើត និងថែទាំបណ្តាញ។

វិស្វករប្រព័ន្ធកំពុងរៀបចំផែនការបណ្តាញរបស់ក្រុមហ៊ុន។



Firewall គឺជាកញ្ចប់កម្មវិធី ឬឧបករណ៍ផ្នែករឹងដែលការពារគ្រប់កុំព្យូទ័រនៅក្នុងបណ្ដាញ ដោយពិនិត្យមើលព័ត៌មានទាំងអស់មកពីខាងក្រៅចូលក្នុងបណ្ដាញ ព្រមទាំងព័ត៌មានដែលចេញពីបណ្ដាញ។

ជាធម្មតា វិស្វករបណ្ដាញធ្វើការជាមួយក្រុមការងារដែលមានសមាជិកខ្លះធ្វើការទំនាក់ទំនងផ្ទាល់ជាមួយអតិថិជន។ ពួកគេត្រូវមានជំនាញស្ដាប់យ៉ាងស្ទាត់ជំនាញ ដើម្បីដឹងពីតម្រូវការរបស់អតិថិជន និងអ្វីដែលពួកគេមាន រួចអាចធ្វើការរៀបចំកំណត់រចនាសម្ព័ន្ធបណ្ដាញ និងគ្រោងតាមតម្រូវការរបស់អតិថិជន។ ពេលចាំបាច់ពួកគេក៏អាចពន្យល់បានពីលទ្ធផល និងផ្ដល់យោបល់អំពីការងាររបស់ពួកគេ។ ពេលខ្លះ វិស្វករបណ្ដាញគឺជាប្រធានក្រុមការងារ និងជាអ្នកដើរតួនាទីសំខាន់ក្នុងការលើកទឹកចិត្តក្រុមការងារផ្ដល់ជំនួយដល់អតិថិជនតាមលទ្ធភាពដែលអាចធ្វើបាន ក៏ដូចជាគ្រប់គ្រងទំនាស់ផ្សេងៗដែលអាចកើតមាន។

បំណិនបច្ចេកទេសចាំបាច់ត្រូវមានចំណេះដឹងបន្ថែមទាក់ទងនឹងប្រព័ន្ធកុំព្យូទ័រ និងបទពិសោធន៍ប្រើប្រាស់បច្ចេកវិទ្យាបណ្ដាញ គ្រឿងឧបករណ៍ និងប្រព័ន្ធប្រតិបត្តិការផ្សេងៗ។ វិស្វករបណ្ដាញក៏ត្រូវតែដឹងអំពីការប្រើប្រាស់កម្មវិធីកុំព្យូទ័រដើម្បីពិនិត្យមើលការប្រើប្រាស់បណ្ដាញ និងសុវត្ថិភាព ដូចជាជញ្ជាំងភ្លើង (Firewalls)។

ជំនាញផ្សេងៗ ត្រូវការជំនាញវិភាគសម្រាប់ស្វែងរកគុណវិបត្តិ និងផែនការធ្វើឱ្យប្រសើរឡើងចំពោះបណ្ដាញដែលស្មុគស្មាញ។ វិស្វករបណ្ដាញគួរតែមានសមត្ថភាពពូកែ និងជំនាញដោះស្រាយបញ្ហាល្អប្រសើរ។ ជាទូទៅវិស្វករបណ្ដាញរាយការណ៍ទៅអ្នកគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានដែលជាប្រធានគ្រប់គ្រងផ្នែកបច្ចេកវិទ្យាព័ត៌មាន។

- **ប្រធានគ្រប់គ្រងព័ត៌មានវិទ្យា៖** គឺជាអ្នកដែលទទួលខុសត្រូវខ្ពស់លើគ្រប់ដំណើរការប្រព័ន្ធកុំព្យូទ័រទាំងអស់នៅក្នុងស្ថាប័នមួយ ជាញឹកញាប់ត្រូវរាយការណ៍ទៅនាយកគ្រប់គ្រងទូទៅរបស់ក្រុមហ៊ុន/ស្ថាប័ននោះ។ ប្រធានគ្រប់គ្រងព័ត៌មានវិទ្យាធ្វើផែនការ ជួលបុគ្គលិក កំណត់ផែនការថវិកា និងចំណាយផ្សេងៗ ព្រមទាំងរៀបចំផែនការសម្រាប់ផ្នែកព័ត៌មានវិទ្យា។

ដើម្បីក្លាយជាអ្នកគ្រប់គ្រងព័ត៌មានវិទ្យា អ្នកត្រូវមានកម្រិតវប្បធម៌ទាបបំផុតត្រឹមបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ។ និយោជកជាច្រើនក៏ទាមទារឱ្យមានបរិញ្ញាបត្រជាន់ខ្ពស់ និងខ្លះទៀតរកមើលអ្នកដែលមានសញ្ញាបត្រ MBA ជាពិសេស។ ប្រធានគ្រប់គ្រងព័ត៌មានវិទ្យាជាច្រើនបានធ្វើការក្នុងផ្នែកនេះមានបទពិសោធន៍ពី ៨ ទៅ ១២ ឆ្នាំ ដោយចាប់ផ្ដើមពីការងារដំបូងជាអ្នកឯកទេសជំនួយផ្នែកកុំព្យូទ័រ ឬអ្នកគ្រប់គ្រងប្រព័ន្ធ រហូតដល់ក្លាយជាវិស្វករប្រព័ន្ធ ឬបណ្ដាញ និងចុងក្រោយក្លាយជាប្រធានគ្រប់គ្រងព័ត៌មានវិទ្យា។ ប្រធានគ្រប់គ្រងព័ត៌មានវិទ្យាបានទទួលការបណ្ដុះបណ្ដាលជាច្រើនលើជំនាញនេះ ហើយធ្វើការយ៉ាងសកម្ម និងខ្លាំងក្លា ដើម្បីឱ្យខ្លួនមានជំនាញគ្រប់គ្រាន់ដែលចាំបាច់សម្រាប់ទទួលតួនាទីជាប្រធានគ្រប់គ្រងព័ត៌មានវិទ្យាជាន់ខ្ពស់នេះ។ ក្រៅពីជំនាញ និងបទពិសោធន៍បច្ចេកទេសគ្រប់គ្រងព័ត៌មានវិទ្យា ប្រធានគ្រប់គ្រងព័ត៌មានវិទ្យាត្រូវមាន បំណិនអន្តរបុគ្គល និងគ្រប់គ្រង ដែលនឹងជួយពួកគាត់ឱ្យធ្វើការសហការបានយ៉ាងប្រសើរជាមួយបុគ្គលិកផ្នែកផ្សេងៗទៀតរបស់ក្រុមហ៊ុន/ស្ថាប័ន។ បំណិនគ្រប់គ្រងពេលវេលា និងស្ថាប័នឱ្យមានប្រសិទ្ធភាពក៏មានសារៈសំខាន់ណាស់សម្រាប់ប្រធានគ្រប់គ្រងព័ត៌មានវិទ្យា។

ប្រធានគ្រប់គ្រងព័ត៌មានវិទ្យាគួរតែរក្សាបច្ចុប្បន្នភាពដំណឹង ឬព័ត៌មានថ្មីៗ និងត្រូវតែអាចធ្វើការសម្រេចចិត្តផ្អែកលើការអភិវឌ្ឍបច្ចុប្បន្ននៅក្នុងសហគ្រាស។ ពួកគេអាចអភិវឌ្ឍសមត្ថភាព និងចំណេះដឹងរបស់ពួកគេបានប្រសើរឡើងដោយឆ្លងកាត់ការងារ និងការចូលរួមសិក្ខាសាលាផ្សេងៗ។ ប្រធានគ្រប់គ្រងព័ត៌មានអាចធ្វើការសម្រេចចិត្តអំពីថវិកា តម្រូវការការងារ និងបច្ចេកវិទ្យាថ្មី។

*អ្នកធ្វើការក្នុងផ្នែកគ្រប់គ្រងប្រព័ន្ធ និងបណ្តាញទាំងអស់ត្រូវបានលើកទឹកចិត្តយ៉ាងខ្លាំងក្លា ដើម្បីពង្រីកចំណេះដឹងតាមរយៈការចូលរួមសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលផ្សេងៗ*

# ៣ បរិស្ថានការងារ

ដោយសារចំនួន និងទំហំនៃក្រុមហ៊ុនដែលបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាមានការកើនឡើងយ៉ាងរហ័ស ព្រមទាំងកម្រិតបច្ចេកវិទ្យាដែលបានប្រើដោយនិយោជិតមានការប្រែប្រួល ការគ្រប់គ្រងប្រព័ន្ធ និងបណ្តាញកំពុងមានការកើនឡើង។ អ្នកគ្រប់គ្រងប្រព័ន្ធដែលជោគជ័យមានការងារស្ថិតស្ថេរយូរអង្វែង ដោយហេតុថាពួកគេអាចទទួលបានឱកាសរៀនសូត្រច្រើនពីការងារដែលពួកគេបានធ្វើ និងពង្រឹងសមត្ថភាពជាប្រចាំសម្រាប់ការងារទាំងឡាយរបស់ពួកគេ។

ជាធម្មតា បុគ្គលិកអង្គុយធ្វើការជាមួយគ្នានៅកន្លែងធ្វើការមួយ។ អ្នកគ្រប់គ្រងប្រព័ន្ធតែងតែធ្វើការជាក្រុម ដែលមានជំនាញតាមផ្នែកនីមួយៗ ដែលពួកគេអាចពិភាក្សាគ្នាជាមួយអ្នកដែលមានកម្រិតចំណេះដឹងខ្ពស់ ឬច្បាស់លាស់ជាង នៅក្នុងក្រុមបានយ៉ាងងាយស្រួលនៅពេលពួកគេដោះស្រាយបញ្ហាអ្វីមួយ។ ជាញឹកញាប់បំផុតដែលសមាជិកច្រើនធ្វើការរួមគ្នាដើម្បីដោះស្រាយបញ្ហាអ្វីមួយ។ វាអាចជាបរិស្ថានរៀនសូត្រពីគ្នាទៅវិញទៅមកក្នុងការងារប្រចាំថ្ងៃ ដែលក្លាយជាសកម្មភាពស្វ័យបណ្តុះបណ្តាលមួយជារៀងរាល់ថ្ងៃ។




អាកប្បកិរិយាមិនល្អ




អាកប្បកិរិយាល្អ

អ្នកឯកទេសជំនួយផ្នែកកុំព្យូទ័រ និងអ្នកគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រតែងតែមានទំនាក់ទំនងផ្ទាល់ជាមួយអ្នកប្រើកុំព្យូទ័រខាងក្នុង ឬខាងក្រៅស្ថាប័ន។ ការងាររបស់ពួកគេ គឺដើម្បីប្រាកដថាអ្នកប្រើទាំងអស់អាចប្រើកុំព្យូទ័ររបស់ពួកគេបានធម្មតាសម្រាប់ការងារដោយគ្មានបញ្ហា។ អ្នកណាម្នាក់ដែលអាក់អន់ចិត្ត ដោយសារកុំព្យូទ័ររបស់គាត់ដំណើរការមិនស្រួល ឬតែងតែខូចនោះ អ្នកឯកទេសជំនួយផ្នែកកុំព្យូទ័រ ឬអ្នកគ្រប់គ្រងប្រព័ន្ធត្រូវតែប្រើមិនត្រឹមតែជំនាញបច្ចេកទេសរបស់ពួកគេនោះទេ ពួកគេត្រូវតែចេះប្រើបំណិនសម្របសម្រួលការងារបានប្រសើរដើម្បីប្រាស្រ័យទាក់ទងជាមួយមនុស្សដែលមិនសប្បាយចិត្តនោះជួយពួកគេដោះស្រាយបញ្ហាដើម្បីឱ្យពួកគេធ្វើការងារបានស្រួល រក្សាបានបរិយាកាសការងារដោយក្តីសប្បាយរីករាយ និងជៀសវាងមានទំនាស់។

ពួកគេភាគច្រើនធ្វើការងារពេញម៉ោងក្នុងផ្នែកនេះ ប៉ុន្តែពួកគេមិនបានបែងចែកកាលវិភាគដូចគ្នានោះទេ។ តាមធម្មតា វិស្វករប្រព័ន្ធ វិស្វករបណ្តាញ និងប្រធានគ្រប់គ្រងព័ត៌មានវិទ្យាធ្វើការតាមកាលវិភាគកំណត់ពេញម៉ោងក្នុងមួយថ្ងៃ។ ដោយឡែកចំពោះអ្នកឯកទេសជំនួយផ្នែកកុំព្យូទ័រពួកគេអាចធ្វើការមានការប្តូរវេនច្រើនម៉ោងជាង និងមានការកំណត់កាលវិភាគការងារជូនពេលល្ងាច យប់ ចុងសប្តាហ៍ និងថ្ងៃឈប់សម្រាកទៀតផង។ ដោយហេតុថាអ្នកប្រើកុំព្យូទ័រត្រូវការជំនួយ ២៤ ម៉ោងក្នុង ១ សប្តាហ៍ អ្នកជំនួយផ្នែកកុំព្យូទ័រក៏ត្រូវមានពេលដែលអាចនឹងទទួលការហៅទូរសព្ទ ២៤ ម៉ោងក្នុងពេលដែលរវល់។

នៅក្នុងស្ថាប័នធំ អ្នកគ្រប់គ្រងប្រព័ន្ធត្រូវតែធ្វើការតាមកាលវិភាគបត់បែនមួយ ដើម្បីមើលការងារបន្ថែមលើអ្នកជំនួយបច្ចេកទេស ឬគ្រប់គ្រងម៉ាស៊ីនមេ និងគ្រឿងឧបករណ៍អេឡិចត្រូនិកផ្សេងៗផងដែរ។ ទោះបីនៅក្នុងស្ថាប័ននោះមិនទាមទារការងារប្តូរវេនសម្រាប់អ្នកគ្រប់គ្រងប្រព័ន្ធក៏ដោយ តែវាជាធម្មតាទៅហើយដែលការងារទាំងនេះត្រូវតែធ្វើការលើសម៉ោងដើម្បីប្រាកដថាប្រព័ន្ធកុំព្យូទ័រដំណើរការដោយរលូន។

## មេរៀនសង្ខេប

ស្ថាប័នប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រដើម្បីរក្សាទុកព័ត៌មាន រៀបចំ និងអាចរកបានយ៉ាងងាយស្រួល។ ក្រុមហ៊ុនធំមានអ្នកធ្វើការច្រើនផ្សេងៗគ្នាដែលជួយធ្វើផែនការ ដំឡើង និងថែទាំកុំព្យូទ័រ ក៏ដូចជាបុគ្គលិកដែលធ្វើការផ្ទាល់ខ្លួនជាមួយអ្នកប្រើ។

អ្នកធ្វើការដែលធានាច្បាស់លាស់ថា ក្រុមហ៊ុនមានកុំព្យូទ័រដំណើរការយ៉ាងរលូននោះ គឺជាអ្នកជំនួយផ្នែកកុំព្យូទ័រ អ្នកគ្រប់គ្រងប្រព័ន្ធ វិស្វករបណ្តាញ និងប្រធានគ្រប់គ្រងព័ត៌មានវិទ្យា។ អ្នកធ្វើការក្នុងមុខតំណែងទាំងអស់នេះត្រូវតែមានការអប់រំខ្ពស់ក្នុងផ្នែកការងាររបស់ពួកគេ មានបំណិនបច្ចេកទេសច្បាស់លាស់ និងត្រូវតែមានបំណិនទំនាក់ទំនងប្រសើរបំផុត។

# លំហាត់

## លំហាត់ ១

អ្នកចូលចិត្តធ្វើការលើផ្នែកបច្ចេកទេសក្នុងការដោះស្រាយបញ្ហាដំណើរការកុំព្យូទ័រ និងបានសម្រេចថា គោលបំណងការងាររបស់អ្នកនឹងក្លាយជាប្រធានគ្រប់គ្រងព័ត៌មានវិទ្យា។ អ្នកបានត្រៀមធ្វើការងារយ៉ាងម៉ត់ចត់ និងស្វាហាប់ ដើម្បីអាចផ្លាស់ទីឈានទៅមុខក្នុងមុខតំណែងខ្ពស់ដែលបានជ្រើសរើសនេះ។ អ្នកដឹងហើយថាមុខតំណែងដែលអ្នកជ្រើសរើសនេះត្រូវការពេលវេលាឆ្លងកាត់ពីមុខតំណែងជាអ្នកឯកទេសជំនួយផ្នែកកុំព្យូទ័រ ឬអ្នកគ្រប់គ្រងប្រព័ន្ធ ទៅវិស្វករប្រព័ន្ធ ឬវិស្វករបណ្ដាញ មុនពេលអ្នកឈានទទួលបានមុខតំណែងជាប្រធានគ្រប់គ្រងព័ត៌មានវិទ្យា។

ក. ចូរពិភាក្សាជាមួយក្រុមរបស់អ្នកអំពីគន្លងការងារដែលអ្នកនឹងត្រូវអនុវត្តតាមដើម្បីសម្រេចគោលបំណងរបស់អ្នក។ រួមមានការអប់រំ បទពិសោធន៍ និងបំណិនបច្ចេកទេស និងទំនាក់ទំនងដែលអ្នកនឹងទទួលបានអំឡុងពេលធ្វើការងារ ដើម្បីផ្លាស់ទីឈានទៅមុខតំណែងជាប្រធានគ្រប់គ្រងផ្នែកព័ត៌មានវិទ្យា។

ខ. ចូរពិភាក្សាបំណិនអ្វីដែលក្រុមរបស់អ្នកគិតថាពិបាកបំផុតក្នុងការទទួលបានវា។

គ. ពិភាក្សាក្នុងក្រុមរបស់អ្នក អ្វីដែលអ្នកអាចធ្វើបានអំឡុងពេលការងាររបស់អ្នកដើម្បីអភិវឌ្ឍបំណិនដែលលំបាកបំផុត។

ឃ. សរសេរសេចក្ដីសង្ខេបរបស់អ្នកនៅក្នុងឯកសារ និងរក្សាទុកក្នុងថតក្រុមរបស់អ្នក។

# សំណួរត្រិះរិះ

១. តើប្រព័ន្ធកុំព្យូទ័រគឺជាអ្វី?

២. តើចាំបាច់ត្រូវការជំនាញអ្វីខ្លះ ដើម្បីក្លាយជាអ្នកឯកទេសជំនួយផ្នែកកុំព្យូទ័រ?

៣. តើចាំបាច់ត្រូវការជំនាញអ្វីខ្លះ ដើម្បីក្លាយជាអ្នកគ្រប់គ្រងប្រព័ន្ធ?

៤. តើចាំបាច់ត្រូវការជំនាញអ្វីខ្លះ ដើម្បីក្លាយជាវិស្វករប្រព័ន្ធ?

៥. តើចាំបាច់ត្រូវការជំនាញអ្វីខ្លះ ដើម្បីក្លាយជាវិស្វករបណ្ដាញ?

៦. តើចាំបាច់ត្រូវការជំនាញអ្វីខ្លះ ដើម្បីក្លាយជាប្រធានគ្រប់គ្រងព័ត៌មានវិទ្យា?

៧. ហេតុអ្វីបានជាជំនាញទំនាក់ទំនងផ្ទាល់ខ្លួនមានសារៈសំខាន់សម្រាប់វិជ្ជាជីវៈទាំងនេះ?

ជំពូកទី ៣ | ការសរសេរកូដកម្មវិធី

# មេរៀនទី ៤

# ការអភិវឌ្ឍកម្មវិធីបច្ចេកវិទ្យា

## នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពី៖

១. ស្គាល់ពីការអភិវឌ្ឍកម្មវិធីកុំព្យូទ័រ ឬទូរសព្ទ និងយល់ដឹងបុគ្គលិកលក្ខណៈ និងគោលបំណងរបស់វា

២. យល់ដឹងការងារនៅក្នុងផ្នែកការអភិវឌ្ឍកម្មវិធីបច្ចេកវិទ្យា និងបរិស្ថានការងាររបស់វា

៣. កំណត់ និងយល់ដឹងពីការអប់រំ បំណិនប្រាស្រ័យទាក់ទង បំណិនបច្ចេកទេស និងលក្ខណៈសម្បត្តិផ្សេងៗដែលត្រូវការ ដើម្បីអាចធ្វើការបានក្នុងផ្នែកអភិវឌ្ឍកម្មវិធីបច្ចេកវិទ្យា

# ផ្នែក ក - ការងារក្នុងផ្នែកសរសេរកូដកម្មវិធី

## ១. ការណែនាំអំពីការអភិវឌ្ឍកម្មវិធីបច្ចេកវិទ្យា

ចរណៃនៅចាំបានថាពូរបស់នាងមានមិត្តភ័ក្តិធ្វើការនៅផ្នែកកុំព្យូទ័រ។ កុសលបានឱ្យនាងដឹងថា មិត្តរបស់គាត់ឈ្មោះភិរម្យបានសិក្សាជំនាញវិទ្យាសាស្ត្រកុំព្យូទ័រជាមួយគាត់នៅសាកលវិទ្យាល័យមួយ បន្ទាប់មកនាងក៏បានសម្រេចចិត្តជ្រើសរើសការងារនៅក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) ជាអ្នកអភិវឌ្ឍកម្មវិធី។

ដោយសារតែចរណៃមិនទាន់យល់ច្រើនអំពីវិស័យនោះ នាងក៏បានសួរសំណួរបន្ថែមទៅកាន់ពូរបស់នាង។ កុសលពន្យល់ថា “ភិរម្យបានជ្រើសយកជំនាញអភិវឌ្ឍន៍កម្មវិធី ពេលបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ ព្រោះនាងចូលចិត្តបង្កើតកម្មវិធីជាជាងធ្វើការជាមួយប្រព័ន្ធដូចជាខ្ញុំ” ។

ចរណៃចោទសួរថា “បង្កើតកម្មវិធី? ស្តាប់ទៅដូចជាលំបាកណាស់។ តើនាងអាចបង្កើតបានកម្មវិធីអ្វីខ្លះ?” ។

កុសលតបថា “បាទ ពេលនៅសាកលវិទ្យាល័យ យើងបានសិក្សាភាសាកម្មវិធីមួយចំនួន និងសិក្សាពីរបៀបសរសេរកម្មវិធីមូលដ្ឋានរបស់កុំព្យូទ័រ។ ក្រោយមកពេលភិរម្យចាប់ផ្តើមធ្វើការឱ្យក្រុមសរសេរកម្មវិធីទូរសព្ទ ការធ្វើតេស្តកម្មវិធីសម្រាប់កុំព្យូទ័ររបស់ពួកគេ និងការរកមើលកំហុស នាងក៏បានសិក្សាភាសាកម្មវិធីថ្មីៗបន្ថែម ដែលធ្វើឱ្យនាងអាចបង្កើតកម្មវិធីកុំព្យូទ័រស្មុគស្មាញដោយខ្លួនឯងបាន។ នាងបានក្លាយជាអ្នកជំនាញ ហើយឥឡូវនាងគ្រប់គ្រងក្រុមអ្នកអភិវឌ្ឍកម្មវិធី” ។

ចរណៃសួរថា “តើភិរម្យអាចនិយាយភាសាកម្មវិធីបានប៉ុន្មាន?”

កុសលសើច ហើយនិយាយថា “អ្នកមិនអាចនិយាយភាសាកម្មវិធីបានទេ វាគឺសម្រាប់តែសរសេរប៉ុណ្ណោះ។ វាមានសំណុំពាក្យបញ្ជាជាក់លាក់ដែលកុំព្យូទ័រអាចយល់បាន។ យើងសរសេរពាក្យបញ្ជានៅលើកុំព្យូទ័រ បន្ទាប់មកវានឹងដំណើរការតាមលំដាប់លំដោយម្តងមួយជំហានៗ។ ពាក្យបញ្ជាត្រូវតែសរសេរយ៉ាងត្រឹមត្រូវពិតប្រាកដ។ បើកុំព្យូទ័ររកឃើញថាមានកំហុស នោះវានឹងដំណើរការកម្មវិធីមិនត្រឹមត្រូវឡើយ“ ។



ការអភិវឌ្ឍកម្មវិធី គឺជាការផ្តល់ពាក្យបញ្ជាឱ្យកុំព្យូទ័រ បន្ទាប់មកវានឹងបង្ហាញនូវអ្វីដែលយើងចង់បាន។ ពាក្យបញ្ជាទាំងនេះត្រូវបានដាក់ក្នុងក្រុមមួយដែលមានឈ្មោះថា កម្មវិធីកុំព្យូទ័រ។ នៅពេលដែលទូរសព្ទទំនើបៗនាបច្ចុប្បន្នមានភាពស្រដៀងគ្នាយ៉ាងខ្លាំងជាមួយកុំព្យូទ័រ កម្មវិធីក៏ត្រូវបានសរសេរផងដែរសម្រាប់ទូរសព្ទ ដែលកម្មវិធីទាំងនេះត្រូវបានគេឱ្យឈ្មោះថា កម្មវិធីទូរសព្ទ។ ជាទូទៅ កម្មវិធីមួយគឺត្រូវតែមានភារកិច្ចជាក់លាក់ដើម្បីដំណើរការ ដែលវាអាចចាប់ពីភារកិច្ចសាមញ្ញបំផុត រហូតដល់ស្មុគស្មាញបំផុត។ ឧទាហរណ៍ដូចជាកម្មវិធីបង្ហាញម៉ោងនៅលើទូរសព្ទគឺជាកម្មវិធីសាមញ្ញ ឬកម្មវិធីលេងហ្គេមដែលមានក្រាហ្វិកបង្ហាញស្មុគស្មាញតាមជម្រើសអ្នកប្រើ ដែលចាត់ទុកថាជាកម្មវិធីកម្រិតខ្ពស់សម្រាប់អ្នកអភិវឌ្ឍកម្មវិធី។ កម្មវិធីទាំងឡាយដែលយើងប្រើប្រាស់នៅក្នុងកុំព្យូទ័រ ក៏ជាកម្មវិធីដែលមនុស្សបានបង្កើតឡើងដែរ។ កម្មវិធីវាយអត្ថបទ (OpenOffice Writer) គឺជាកម្មវិធីស្មុគស្មាញមួយ ដែលអនុញ្ញាតឱ្យអ្នកប្រើវាយបញ្ចូលអត្ថបទ ធ្វើទ្រង់ទ្រាយ រក្សាទុក និងអាចបោះពុម្ពបាន។ សៀវភៅបញ្ជីក៏ជាកម្មវិធីមួយដែរ ដែលអនុញ្ញាតឱ្យអ្នកប្រើវាយបញ្ចូលអត្ថបទ លេខ រូបមន្ត និងប្រភេទទិន្នន័យផ្សេងទៀត ហើយវាអាចគណនាតម្លៃនៃក្រឡានីមួយៗនៅរាល់ពេលបានបញ្ចូលទិន្នន័យថ្មី។ អ្វីៗគ្រប់យ៉ាងដែលយើងប្រើប្រាស់នៅក្នុងកុំព្យូទ័រ ឬទូរសព្ទទំនើបគឺជាកម្មវិធី រួមមានកម្មវិធីកំណត់ពេល កម្មវិធីផ្ញើ និងទទួលសារ (SMS) ឬកម្មវិធីទំនាក់ទំនងមានដូចជា Viber Line ឬ Facebook ជាដើម។




កម្មវិធីរៀបចំឯកសារអត្ថបទ OpenOffice Writer ។

ពាក្យបញ្ជាដែលអ្នកអភិវឌ្ឍផ្តល់ឱ្យកុំព្យូទ័រ ត្រូវតែមានទ្រង់ទ្រាយជាក់លាក់។ សំណុំទាំងស្រុងនៃពាក្យបញ្ជាដែលអាចប្រើបានជាមួយទ្រង់ទ្រាយរបស់វា ត្រូវបានគេហៅថា ភាសាកម្មវិធី។ មានភាសាកម្មវិធីខុសៗគ្នាជាច្រើន។ ភាសាដែលអ្នកអភិវឌ្ឍកម្មវិធីនឹងប្រើដើម្បីសរសេរកម្មវិធីជាក់លាក់ណាមួយ គឺវាអាស្រ័យលើគោលដៅនៃកម្មវិធី ប្រព័ន្ធប្រតិបត្តិការដែលវាដំណើរការ និងកត្តាជាក់លាក់ផ្សេងទៀតរបស់កម្មវិធី។ វាក៏អាចអាស្រ័យផងដែរទៅលើជម្រើសរបស់អ្នកអភិវឌ្ឍ ដូចជាអ្នកអភិវឌ្ឍខ្លះគាត់ស្ទាត់ជំនាញជាមួយភាសាណាមួយ ជាងភាសាផ្សេងទៀត។ ឧទាហរណ៍៖ ភាសាផ្សេងមួយនឹងត្រូវបានប្រើសម្រាប់តំបន់បណ្តាញ ជាជាងកម្មវិធីដែលដំណើរការនៅលើទូរសព្ទទំនើប។ នៅលើទូរសព្ទទំនើប ទាំងទូរសព្ទ Android និងទូរសព្ទ iOS ពួកវានីមួយៗសុទ្ធតែមានភាសាផ្ទាល់ខ្លួនរបស់វា ហើយពួកវាអាចនឹងមិនព្រមទទួលភាសាផ្សេងសម្រាប់ប្រព័ន្ធរបស់ខ្លួនទេ។ នៅក្នុងកុំព្យូទ័រគឺដូចគ្នា ការប្រើភាសាកម្មវិធីគឺអាស្រ័យលើប្រព័ន្ធប្រតិបត្តិការ និងប្រភេទនៃកម្មវិធី។

ពាក្យបញ្ជានៃកម្មវិធី គឺត្រូវសរសេរតាមលំដាប់លំដោយ មានន័យថាបន្តបន្ទាប់គ្នា។ កុំព្យូទ័រនឹងអនុវត្តពាក្យបញ្ជាទៅតាមលំដាប់លំដោយនោះ។ វានឹងមិនចាប់ផ្តើមពាក្យបញ្ជាបន្ទាប់ឡើយ ប្រសិនបើពាក្យបញ្ជាមុនមិនត្រូវបានបញ្ចប់។ ដោយសារតែល្បឿនកុំព្យូទ័រកាន់តែលឿន វាហាក់បង្ហាញថាសកម្មភាពបីបួនត្រូវបានដំណើរការក្នុងពេលតែមួយបង្ហាញលើអេក្រង់ ប៉ុន្តែតាមពិត ពាក្យបញ្ជាគឺត្រូវបានអនុវត្តម្តងមួយៗ។



ឧទាហរណ៍ ភាសាកូដកម្មវិធីមួយ

## ២. ការងារជាអ្នកអភិវឌ្ឍកម្មវិធី

កុសលប្រាប់ភិរម្យថា ក្មួយស្រីរបស់គាត់ឈ្មោះចរណៃចង់ស្វែងយល់បន្ថែមអំពីការសរសេរកូដកម្មវិធី បន្ទាប់មកភិរម្យក៏បានអញ្ជើញពួកគេឱ្យទស្សនាក្រុមហ៊ុនរបស់នាង។ ពេលពួកគេមកដល់ក្រុមហ៊ុន ចរណៃឃើញមានមនុស្សប្រហែល២០នាក់កំពុងធ្វើការនៅក្នុងបន្ទប់ធំមួយ ពួកគេម្នាក់ៗអង្គុយនៅមុខកុំព្យូទ័រ។  ចរណៃឆ្ងល់ថាតើពួកគេធ្វើការជាក្រុម ឬយ៉ាងណា។

កុសល និងចរណៃបានឃើញថា ភិរម្យកំពុងឈរក្នុងបន្ទប់ប្រជុំ។ នាងមើលទៅដូចជាគ្រូបង្រៀនអញ្ចឹង នាងគូរគំនូសព្រាងមួយចំនួននៅលើក្តារខៀន ហើយពន្យល់ទៅកាន់ក្រុមមនុស្សដែលកំពុងអង្គុយនៅទល់មុខនាង។ ពួកគេទាំងអស់បានស្តាប់យ៉ាងយកចិត្តទុកដាក់ ព្រមទាំងបានកត់ត្រាចំណាំទៀតផង។  ពួកគេបង្ហាញនូវការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះអ្វីដែលភិរម្យកំពុងនិយាយ។

ភិរម្យស្វាគមន៍ចរណៃ និងកុសល ហើយនិយាយថា “ខ្ញុំនឹងបញ្ចប់ការប្រជុំក្នុងរយៈពេលដប់នាទីទៀត។ សូមអង្គុយលេងនៅបន្ទប់ទទួលភ្ញៀវសិន។ អ្នកជំនួយការនឹងយកទឹកតែមកជូនអ្នកពិសា” ។

ពេលពួកគេកំពុងអង្គុយនៅលើកៅអីក្នុងបន្ទប់ទទួលភ្ញៀវ ចរណៃក្រឡេកមើលជុំវិញបន្ទប់ និងពេញចិត្តចំពោះការរចនាការិយាល័យយ៉ាងខ្លាំង ដែលមើលទៅមានភាពទាន់សម័យ។ នាងឃើញមានបន្ទប់ការិយាល័យជញ្ជាំងកញ្ចក់តូចធំមួយចំនួន អមដោយរុក្ខជាតិជាច្រើន ព្រមទាំងមានសិល្បៈរចនាដ៏ស្រស់ស្អាតនៅលើជញ្ជាំងទៀតផង។ ចរណៃនិយាយទៅកាន់ពូនាងថា៖ “ខ្ញុំចង់ធ្វើការនៅក្នុងការិយាល័យបែបនេះណាស់! វាគឺស្រស់ថ្លា ហើយមានពណ៌ធម្មជាតិទៀត ធ្វើឱ្យខ្ញុំមានអារម្មណ៍រីករាយមែនមែន” ។ កុសលញញឹមតប ហើយនិយាយថា “បាទ ក្រុមហ៊ុននេះជាកន្លែងធ្វើការដ៏ល្អ។ បុគ្គលិកតែងតែនៅធ្វើការ

យូរៗ ហើយប្រធានក្រុមហ៊ុនយល់យ៉ាងច្បាស់អំពីការផ្តត់ផ្គង់បុគ្គលិក។ រៀងរាល់ឆ្នាំក្រុមហ៊ុននេះតែងតែឈ្នះពានរង្វាន់ថាជាកន្លែងធ្វើការដ៏ប្រសើរបំផុត" ។ មកដល់ចំណុចនេះ ភិរម្យដើរចូលមកបន្ទប់ទទួលភ្ញៀវ ហើយស្វាគមន៍ចរណៃ និងកុសល។ នាងបាននិយាយថា "អរគុណសម្រាប់ការមកទស្សនាក្រុមហ៊ុនរបស់ខ្ញុំ។ ចរណៃ ពូរបស់អ្នកបានប្រាប់ខ្ញុំរួចហើយថា អ្នកចាប់អារម្មណ៍ក្នុងការសិក្សាជំនាញបច្ចេកវិទ្យាព័ត៌មានវិទ្យា (IT)។ សន្មតថាគាត់បានប្រាប់អ្នករួចហើយថា ខ្ញុំបានជ្រើសយកជំនាញអភិវឌ្ឍន៍កម្មវិធី ហើយបច្ចុប្បន្នខ្ញុំកំពុងធ្វើការជាអ្នកវិភាគកម្មវិធី។ សូមចូលទៅក្នុងការិយាល័យរបស់ខ្ញុំដើម្បីជជែកគ្នា។ ពេលដើរទៅកាន់ការិយាល័យ នាងបានឈប់នៅតាមចំណុចខ្លះ ហើយពន្យល់ថា "ដូចដែលអ្នកបានឃើញហើយ យើងមានក្រុមអ្នកអភិវឌ្ឍកម្មវិធីផ្សេងៗកំពុងធ្វើការជាមួយគ្នា។ យើងបានដាក់ការងាររបស់គម្រោងឱ្យពួកគេធ្វើ ហើយពួកគេសរសេរកម្មវិធីដោយប្រើប្រាស់ភាសាកុំព្យូទ័រជាក់លាក់" ។



ភិរម្យធ្វើការក្នុងការិយាល័យរួមជាមួយអ្នកវិភាគកម្មវិធីម្នាក់ទៀត។ មានតុការិយាល័យពីរដែលមានកុំព្យូទ័រ ក្រដាស និងក្តារខៀនធំមួយដែលពោរពេញទៅដោយការគូសវាស។ ចរណៃនិយាយ៖ "ការិយាល័យនេះមានសណ្តាប់ធ្នាប់ជាងការិយាល័យពូរបស់ខ្ញុំ។ មានតែវត្ថុបីបួនប៉ុណ្ណោះ ហើយមិនមានបន្ទប់ម៉ាស៊ីនមេទៀត។ ដូច្នេះបងភិរម្យ តើបងអាចពន្យល់ខ្ញុំអំពីការងាររបស់បងបន្តិចបានទេ?"

ភិរម្យតបថា៖ "មិនអីទេ! ខ្ញុំរីករាយនឹងប្រាប់។ ខ្ញុំជាមនុស្សម្នាក់ក្នុងចំណោមអ្នកវិភាគកម្មវិធីពីរនាក់នៅក្នុងក្រុមហ៊ុននេះ។ ភារកិច្ចចម្បងរបស់ពួកយើង គឺរកឱ្យឃើញអំពីប្រភេទកម្មវិធីដែលអតិថិជនត្រូវការ ដោយផ្អែកលើការជួបផ្ទាល់ និងការស្វែងយល់អំពីអាជីវកម្មរបស់ពួកគេ។ បន្ទាប់មក យើងក៏បំប្លែងតម្រូវការទាំងនោះទៅជាអនុគមន៍ដែលកម្មវិធីថ្មីអាចដំណើរការបាន ហើយយើងក៏ដាក់កិច្ចការនោះឱ្យអ្នកអភិវឌ្ឍកម្មវិធីធ្វើ។ អ្នកអភិវឌ្ឍកម្មវិធីមាននាទីជាអ្នកសរសេរកូដកម្មវិធីទៅតាមសេចក្តីណែនាំរបស់យើង។ ប្រធានរបស់យើង គឺអ្នកគ្រប់គ្រងគម្រោង ជាអ្នកកំណត់ និងធ្វើផែនការសម្រាប់ការងារដែលត្រូវធ្វើ កំណត់កាលបរិច្ឆេទផុតកំណត់ និងការជួលបុគ្គលិក។ បន្ទាប់មកបែងចែកបុគ្គលិកទៅជាក្រុមផ្សេងៗគ្នាផ្អែកលើឯកទេស និងជំនាញរបស់ពួកគេ។" ។

បន្ទាប់ពីជជែកគ្នាបានមួយសន្ទុះ ចរណៃបានសួរសំណួរចុងក្រោយថា៖ "តើអ្នកធ្វើការនៅទីនេះរាល់ថ្ងៃឬ?"




"ចាសខ្ញុំធ្វើការ៥ថ្ងៃក្នុងមួយសប្តាហ៍ ហើយជាធម្មតាគឺ៨ម៉ោងក្នុងមួយថ្ងៃ។ ប៉ុន្តែថ្ងៃខ្លះយើងត្រូវនៅយូរ ឬខំប្រឹងធ្វើជាងធម្មតា ព្រោះថ្ងៃផុតកំណត់ខ្លី ហើយយើងចង់បញ្ចប់ការងារឆាប់ៗផង។ ពេលខ្លះយើងអាចធ្វើការពីផ្ទះក៏បាន ព្រោះការងាររបស់យើងមិនទាមទារឱ្យត្រូវតែមានវត្តមាននៅការិយាល័យជាចាំបាច់នោះទេ" ។

ទាំងក្រុមហ៊ុន និងអង្គការ គឺតែងតែព្យាយាមធ្វើឱ្យការងាររបស់ពួកគេប្រសើរឡើង ដើម្បីធ្វើទៅបាន ពួកគេចាំបាច់ត្រូវគ្រប់គ្រងឱ្យបានប្រសើរនូវព័ត៌មានដែលពួកគេប្រើ។ ឯកសារលើក្រដាសដែលមានព័ត៌មានរបស់អតិថិជន ត្រូវតែវាយបញ្ចូលក្នុងកុំព្យូទ័រ ដើម្បីគ្រប់គ្រងព័ត៌មានទាំងនោះឱ្យបានប្រសើរតាមលក្ខណៈឌីជីថល ហើយអ្នកផ្សេងអាចចូលប្រើបានភ្លាមៗ ។ ការប្រើប្រាស់កុំព្យូទ័រដើម្បីគ្រប់គ្រងដំណើរការផលិតផល គឺដើម្បីឱ្យប្រាកដថាវាដំណើរការបានល្អ និងមានភាពស៊ីគ្នា។ ក្រុមហ៊ុននីមួយមានវិធីសាស្ត្រជាក់លាក់របស់ខ្លួនដើម្បីអនុវត្តកិច្ចការនេះ។ ពេលខ្លះក្រុមហ៊ុនអាចទិញ ឬប្រើដោយឥតបង់ថ្លៃនូវកម្មវិធីកុំព្យូទ័រដែលមានស្រាប់សម្រាប់ការវាយអត្ថបទ ការងារគណនេយ្យ ការរចនា ឬការងារផ្សេងទៀតដែលសាមញ្ញចំពោះក្រុមហ៊ុន។ ទោះយ៉ាងណាកម្មវិធីស្តង់ដារទូទៅមិនអាចដោះស្រាយបញ្ហាបានល្អឥតខ្ចោះឡើយ ដូច្នេះក្រុមហ៊ុនត្រូវតែមានកម្មវិធីដែលអភិវឌ្ឍឡើងថ្មីស្របតាមតម្រូវការរបស់ខ្លួន។ កម្មវិធីជាក់លាក់ដែលយើងអាចអភិវឌ្ឍបានមានដូចជា៖ កម្មវិធីសម្រាប់ផ្ទុកព័ត៌មានអ្នកជំងឺដែលត្រូវបានប្រើនៅក្នុងមណ្ឌលសុខភាព កម្មវិធីត្រួតពិនិត្យអណ្តូងទឹក ឬកម្មវិធីហៅទូរសព្ទទៅម្តាយទារក និងផ្ញើសារជាសំឡេងដែលបានថតទុកមុនជាមួយព័ត៌មាន ដែលពួកគេចង់ដឹងអំពីសុខភាពទារកជាដើម។

នៅពេលអង្គការដែលមានទំហំល្មមមួយចង់អភិវឌ្ឍកម្មវិធីរបស់ខ្លួន អ្នកគ្រប់គ្រងគម្រោង  ជាអ្នកទទួលខុសត្រូវចំពោះកិច្ចការនេះ គាត់ទទួលបន្ទុកជាអ្នកកំណត់ទំហំការងារ ស្វែងរកបុគ្គលិក និងអ្នកសរសេរកូដកម្មវិធីដែលប្រាកដថាអង្គការអាចប្រើប្រាស់បានក្នុងចំនួនពេលវេលាសមស្រប ទៅតាមប្រភេទកម្មវិធីដែលពួកគេចង់បាន។ អ្នកគ្រប់គ្រងគម្រោងនឹងវិភាគកម្មវិធីដាច់ដោយឡែក ឬស្នើសេវា វិភាគកម្មវិធី ដែលការងារនេះគឺត្រូវជជែកអំពីអ្នកប្រើពេលអនាគត និងរកឱ្យឃើញនូវអ្វីដែលពួកគេចង់បាន។ បន្ទាប់មកអ្នកវិភាគកម្មវិធីនឹងសរសេរតម្រូវការ ដែលពណ៌នាលម្អិតអំពីលក្ខណៈកម្មវិធីដែលគេចង់បាន។ តម្រូវការនឹងត្រូវបានផ្តល់ឱ្យទៅ អ្នកអភិវឌ្ឍកម្មវិធី ម្នាក់ដែលគាត់នឹងសរសេរសំណុំពាក្យបញ្ជាតាមរបស់អ្នកប្រើ។ នៅពេលសរសេរកម្មវិធីចប់វានឹងត្រូវបានធ្វើតេស្តសាកល្បង។ ប្រសិនបើមានកំហុស ឬមិនមានលទ្ធផលដូចការចង់បាន អ្នកអភិវឌ្ឍកម្មវិធីនឹងធ្វើការកែសម្រួលឡើងវិញ។ ពេលកម្មវិធីត្រូវបានបញ្ជូនដល់អតិថិជន វាគួរត្រូវបានថែទាំ និងធ្វើបច្ចុប្បន្នភាពដើម្បីកែកំហុស និងស្របតាមតម្រូវការអនាគត។ ទំនាក់ទំនងការផ្តល់ជូនតាមក្រោយជាទូទៅគឺរវាងអ្នកប្រើនិងអ្នកវិភាគកម្មវិធី។

ដូចអ្នកបានឃើញហើយថា វិជ្ជាជីវៈនៅក្នុងជំនាញសរសេរកូដកម្មវិធីកុំព្យូទ័រគឺ៖

## ១. អ្នកអភិវឌ្ឍកម្មវិធី

នេះជាជំហានដំបូងនៅក្នុងការងារសរសេរកូដកម្មវិធី។ អ្នកអភិវឌ្ឍកម្មវិធីត្រូវបានបណ្តុះបណ្តាលចំពោះការសរសេរកូដកម្មវិធីជាក់ស្តែង និងដោយប្រើភាសាកម្មវិធីមួយ ឬច្រើនទៀតផង។ពួកគេមានសមត្ថភាពអភិវឌ្ឍកម្មវិធីកុំព្យូទ័រទៅតាមពាក្យបញ្ជា និងតម្រូវការដែលបាន

ផ្តល់ឱ្យពួកគេដោយអ្នកវិភាគកម្មវិធី។ ពួកគេរចនាប្រព័ន្ធតម្រូវតាមការចង់បានរបស់អតិថិជន ហើយអាចផ្តល់យោបល់អំពីកម្មវិធីដែលធ្វើឱ្យប្រសើរដល់ប្រព័ន្ធដែលមានស្រាប់។

តំណែងអ្នកអភិវឌ្ឍកម្មវិធីគឺមានតម្រូវការច្រើនទាំងក្នុងស្ថាប័នឯកជន និងស្ថាប័នរដ្ឋ ដែលអាចទទួលបានប្រាក់បៀវត្សខ្ពស់។ ពួកគេមានការរីកចម្រើនយ៉ាងរហ័ស ហើយអាចផ្លាស់ប្តូរកន្លែងការងារបានយ៉ាងងាយស្រួលទៀតផង។

*តួនាទីទាំងអស់នេះ មានតម្រូវការខ្ពស់ និង ប្រាក់ខែច្រើន។*

បរិញ្ញាបត្របច្ចេកវិទ្យាព័ត៌មាន វិទ្យាសាស្ត្រកុំព្យូទ័រ ឬវិស្វករកម្មវិធី គឺជាកម្រិតអប្បបរមានៅឡើយទេ។ អ្នកគួរតែមានបរិញ្ញាបត្រពាក់ព័ន្ធមួយចំនួនទៀតដូចជា៖ គណិតវិទ្យា រូបវិទ្យា ឬវិស្វករ ព្រោះមុខវិជ្ជាទាំងនេះជាជំនួយយ៉ាងពិសេស ដើម្បីសម្រេចការងារសរសេរកម្មវិធីកុំព្យូទ័ររបស់អ្នកកាន់តែងាយស្រួល។ មានអ្នកអភិវឌ្ឍកម្មវិធីខ្លះគឺរៀនដោយខ្លួនឯងដោយមិនបានឆ្លងកាត់សាកលវិទ្យាល័យឡើយ ប៉ុន្តែពួកគេអាចអភិវឌ្ឍកម្មវិធីបានយ៉ាងល្អ។ ខណៈដែលការងារសម្រាប់អ្នកអភិវឌ្ឍកម្មវិធីកម្រិតដំបូងមានច្រើន ហើយអ្នកដែលមានបទពិសោធន៍គឺមានតម្លៃខ្ពស់ ចំណែកឯអ្នកអភិវឌ្ឍកម្មវិធីដែលមានបទពិសោធន៍ចាប់ពីពីរ ឬបីឆ្នាំឡើងទៅគឺនឹងទទួលបានប្រាក់បៀវត្សកាន់តែខ្ពស់។

អ្នកអភិវឌ្ឍកម្មវិធីត្រូវតែចេះជំនាញមួយចំនួនបន្ថែមទៀតទាំងពេលនៅរៀនសាកលវិទ្យាល័យ ឬនៅពេលបំពេញការងារយកបទពិសោធន៍ឯកទេសដូចជា៖

- ត្រូវចេះច្បាស់ភាសាកម្មវិធីយ៉ាងតិចមួយ៖ អ្នកអភិវឌ្ឍកម្មវិធីភាគច្រើនចេះភាសាកម្មវិធីច្រើនជាងមួយ ដោយសារតែភាសាកម្មវិធីភាគច្រើនស្រដៀងគ្នា ធ្វើឱ្យអ្នកអភិវឌ្ឍកម្មវិធីអាចសិក្សាភាសាពាក់ព័ន្ធផ្សេងទៀតបានយ៉ាងងាយស្រួល។ ឧទាហរណ៍ដូចជាភាសាកម្មវិធី និងជំនាញបច្ចេកទេសដែលកំពុងត្រូវការបច្ចុប្បន្នគឺ Java PHP និង C# ។ អ្នកអភិវឌ្ឍកម្មវិធីតែងតែរៀនដោយខ្លួនឯងនូវភាសាកម្មវិធីថ្មីៗ ដើម្បីអាចធ្វើកិច្ចការច្រើនប្រភេទបាន ហើយនិងបង្កើនតម្រូវការការងាររបស់ខ្លួនកាន់តែខ្ពស់។
- ខ្លាំងខាងការគិតតាមលំដាប់លំដោយ និងតក្កវិជ្ជា៖ អ្នកសរសេរកូដកម្មវិធីចាំបាច់ត្រូវសិក្សាឱ្យឃើញអំពីសកម្មភាពជាស៊េរី នៃជំហានតូចៗដែលកើតមានជាបន្តបន្ទាប់គ្នា។ ដោយធ្វើបែបនេះ ពួកគេនឹងអាចដំណើរការបានតាមលំដាប់លំដោយនូវកិច្ចការបង្កើតកម្មវិធីដែលពួកគេត្រូវធ្វើ។ ម៉្យាងវិញទៀតពួកគេចាំបាច់ត្រូវគិតដូចកុំព្យូទ័រដែរ ដោយធ្វើតាមសេចក្តីណែនាំមួយជំហានម្តងៗ។

*អ្នកអភិវឌ្ឍកម្មវិធីជាញឹកញាប់បង្រៀនខ្លួនឯងនូវភាសាកូដកម្មវិធីថ្មីៗ ដើម្បីអាចធ្វើការងារបានច្រើនប្រភេទ បង្កើនចំនួនការងារដែលពួកគេមានលក្ខណសម្បត្តិធ្វើបាន។*

- មានជំនាញដោះស្រាយបញ្ហាយ៉ាងឥតខ្ចោះ៖ បញ្ហាកើតឡើងជារៀងរាល់ថ្ងៃ នៅពេលយើងអភិវឌ្ឍកម្មវិធី។ រឿងតែមួយគត់គឺត្រូវរកឱ្យឃើញនូវបញ្ហា និងការអភិវឌ្ឍគំនិតអំពីរបៀបដោះស្រាយបញ្ហាដើម្បីទទួលបានលទ្ធផលតាមតម្រូវការ។ ការអប់រំផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រគឺជួយឱ្យសមត្ថភាពបុគ្គលប្រសើរឡើង អាចកំណត់បានអំពីស្ថានភាពបញ្ហា រួចស្វែងរកដំណោះស្រាយ ហើយវាក៏ផ្តល់នូវបទពិសោធន៍ក្នុងការដោះស្រាយបញ្ហាជាច្រើនផ្សេងទៀតដែរនៅក្នុងជីវភាពជាក់ស្តែង។

- ជំនាញខ្លាំងក្នុងការផ្ចង់អារម្មណ៍៖ អ្នកអភិវឌ្ឍកម្មវិធីធ្វើការទាក់ទងនឹងការគិតច្រើន និងការប្រមូលអារម្មណ៍។ ការដឹងអំពីរបៀបទប់ស្កាត់ភាពរំខានខាងក្រៅ និងការផ្តោតអារម្មណ៍គឺជួយឱ្យមានប្រសិទ្ធភាពការងារ។ ការមានបន្ទប់ដែលមានផាសុកភាព មានកៅអី តុ ឬតុការិយាល័យ និងភ្លើងបំភ្លឺសមរម្យ គឺដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្ចង់អារម្មណ៍របស់អ្នក។
- ការតស៊ូព្យាយាម៖ មានសុភាសិតមួយពោលថា "បើអ្នកមិនទទួលបានជោគជ័យនៅលើកដំបូងទេ អ្នកត្រូវព្យាយាមម្តងហើយម្តងទៀត" ។ នេះមានន័យថាកុំបោះបង់ចោលដោយងាយៗ គឺត្រូវតែតស៊ូព្យាយាម។ ពេលខ្លះអ្នកអភិវឌ្ឍកម្មវិធីវិលវល់ដោយសារបញ្ហាមួយ ហើយពួកគេត្រូវចំណាយពេលជាច្រើនម៉ោងដោយមិនបានធ្វើកិច្ចការចម្រើនទៅមុខឡើយ។ អ្នកខ្លះឃើញថាវាតានតឹងខ្លាំងពេក ក៏បោះបង់ការព្យាយាម។ ជាទូទៅការដោះស្រាយបញ្ហាគឺត្រូវការពេលវេលា ហើយអ្នកអភិវឌ្ឍកម្មវិធីត្រូវតែតស៊ូព្យាយាមអស់ពីចិត្តដើម្បីដោះស្រាយបញ្ហា។ នេះមានន័យថាពួកគេត្រូវតែអត់ធ្មត់ និងព្យាយាមបំផុតចំពោះភាពតានតឹង។
- អាកប្បកិរិយាការងារជាក្រុមវិជ្ជមាន៖ ការងារជាក្រុមមានន័យថាអ្នកចាំបាច់ត្រូវដឹងអំពីរបៀបរួបរួម និងការសហការជាមួយសមាជិកក្រុមរបស់អ្នក។ ពេលខ្លះអ្នកទទួលការណែនាំពីពួកគេ ហើយពេលខ្លះអ្នកជាអ្នកផ្តល់នូវសេចក្តីណែនាំដល់សមាជិកក្រុម ជួនកាលអ្នកចាំបាច់ត្រូវសហការជាមួយសមាជិកក្រុមផ្សេងទៀតផងដែរ។ អ្នកត្រូវតែព្យាយាមស្វែងយល់ពីតម្រូវការរបស់ពួកគេ លើកទឹកចិត្ត និងដោះស្រាយបញ្ហា។ ពេលអ្នកផ្តោតលើគោលដៅក្រុម ការបង្ហាញថាមពល ភាពសាទរ បង្កើតទំនុកចិត្តជាមួយអ្នកផ្សេង និងសិក្សាពីរបៀបផ្តល់យោបល់ប្រកបដោយការដឹងខុសត្រូវ នោះអ្នកផ្សេងនឹងចង់ចូលរួមជាមួយក្រុមរបស់អ្នក។ ការធ្វើជាប្រធានក្រុមមានន័យថា អ្នកត្រូវធ្វើការយ៉ាងប្រសើរជាមួយសមាជិកក្រុម ដើម្បីដោះស្រាយបញ្ហា និងបានសម្រេចគោលដៅក្រុម និងស្ថាប័ន។

## ២. អ្នកវិភាគកម្មវិធី

នេះជាផ្នែកទីពីរនៃការងារអ្នកសរសេរកូដកម្មវិធី។ អ្នកវិភាគកម្មវិធី គឺសិក្សាលើផ្នែកកម្មវិធី រៀបចំតម្រូវការកម្មវិធី និងឯកសារការបញ្ជាក់លម្អិត។ ពួកគេដឹកនាំអ្នកអភិវឌ្ឍកម្មវិធីដោយគ្រប់គ្រងទៅលើដំណើរការនៃការអភិវឌ្ឍកម្មវិធី។ ពួកគេមានជំនាញខាងការអភិវឌ្ឍកម្មវិធី ប៉ុន្តែមិនប្រាកដថាអាចសរសេរកូដកម្មវិធីដោយខ្លួនឯងបានទេ ព្រោះនេះជាការងាររបស់អ្នកអភិវឌ្ឍកម្មវិធី។ អ្នកវិភាគកម្មវិធីត្រូវតែប្រាកដថាតម្រូវការរបស់អ្នកប្រើប្រាស់ អតិថិជន និងនិយោជក គឺបានសម្រេចដោយជោគជ័យ ហើយពួកគេត្រូវតែមានជំនាញទំនាក់ទំនងយ៉ាងល្អឥតខ្ចោះ។ ពួកគេធ្វើការក្រោមការណែនាំរបស់អ្នកគ្រប់គ្រងគម្រោង។



អ្នកវិភាគកម្មវិធីត្រូវចេះជំនាញទាំងអស់របស់អ្នកអភិវឌ្ឍកម្មវិធី រួមទាំងបទពិសោធន៍ពីរបីឆ្នាំទៀតផង។ និយោជកផ្លាស់ប្តូរតម្រូវការរបស់ពួកគេទៅតាមរយៈពេលនៃបទពិសោធន៍ ប៉ុន្តែជាធម្មតារយៈពេលចាប់ពីបីទៅប្រាំមួយឆ្នាំ ត្រូវបានចាត់ទុកថាគ្រប់គ្រាន់

សម្រាប់ធ្វើជាអ្នកអភិវឌ្ឍកម្មវិធីបានហើយ។ និយោជកខ្លះទាមទារឱ្យមានកម្រិតវប្បធម៌អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ឬការគ្រប់គ្រងពាណិជ្ជកម្ម។ នៅអំឡុងពេលធ្វើការជាអ្នកអភិវឌ្ឍកម្មវិធី អ្នកវិភាគកម្មវិធីត្រូវតែធ្វើឱ្យប្រសើរឡើងនូវជំនាញមួយចំនួនដូចជា៖

- មានចំណេះដឹងខ្ពស់អំពីការសរសេរកម្មវិធី៖ វាគឺចាំបាច់ណាស់ថាអ្នកត្រូវចេះភាសាកម្មវិធីផ្សេងៗគ្នា ទាំងភាពខុសគ្នា និងភាពស្រដៀងគ្នាក្នុងចំណោមកម្មវិធីសំខាន់ៗដែលត្រូវប្រើដោយក្រុមហ៊ុនរបស់អ្នក។ អ្នកវិភាគកម្មវិធីត្រូវតែដឹងពីរយៈពេលដែលអ្នកសរសេរកម្មវិធីត្រូវប្រើ។
- ជំនាញទំនាក់ទំនងដ៏មានប្រសិទ្ធភាព រួមទាំងការគ្រប់គ្រងទំនាស់៖ អ្នកវិភាគកម្មវិធីចំណាយពេលជាច្រើនម៉ោងនៅក្នុងការិយាល័យ និងនៅមុខកុំព្យូទ័រ។ នៅអំឡុងពេលនេះពួកគេចាំបាច់ត្រូវទាក់ទងជាមួយអ្នកអភិវឌ្ឍកម្មវិធី អ្នកគ្រប់គ្រងគម្រោង ទាំងនៅពេលចាប់ផ្ដើម និងពេលបញ្ចប់ការអភិវឌ្ឍ ក៏ដូចជាការពិនិត្យនៅអំឡុងពេលអនុវត្តគម្រោងជាមួយអតិថិជនដែរ។ អ្នកវិភាគកម្មវិធីចាំបាច់ត្រូវពូកែទាំងជំនាញទំនាក់ទំនងជាលាយលក្ខណ៍អក្សរ និងដោយផ្ទាល់មាត់ ហើយពួកគេត្រូវតែមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងទំនាស់រវាងសមាជិកក្រុម។ ពួកគេត្រូវតែជាអ្នកស្ដាប់ដ៏ល្អ ហើយអាចបង្កើតសហប្រតិបត្តិការល្អនៅក្នុងក្រុម។

## ៣. អ្នកគ្រប់គ្រងគម្រោងកម្មវិធី

អ្នកគ្រប់គ្រងគម្រោងគឺជាមនុស្សដែលបានរៀបចំផែនការ និងដឹកនាំគម្រោងអភិវឌ្ឍកម្មវិធី។ ពួកគេទទួលបន្ទុកជាអ្នកសម្របសម្រួលក្រុមអ្នកអភិវឌ្ឍកម្មវិធី និងអ្នកវិភាគកម្មវិធី។ ពួកគេក៏ទទួលបន្ទុកផងដែរទៅលើការធ្វើឱ្យប្រាកដថា កម្មវិធីដែលបានអភិវឌ្ឍគឺពិតជាត្រឹមត្រូវទៅតាមអ្វីដែលបានសន្យាចំពោះក្រុមហ៊ុន ឬអតិថិជន។ ពួកគេទាក់ទងជាមួយអ្នកគ្រប់គ្រងជាន់ខ្ពស់នៃក្រុមហ៊ុន ដែលអាចសម្រេចចិត្តក្នុងវត្ថុបំណងនៃការសរសេរកម្មវិធី។ អ្នកគ្រប់គ្រងគម្រោង តែងតែទទួលខុសត្រូវលើការកំណត់ទំហំនៃគម្រោង ការជួល ឬការជ្រើសរើសបុគ្គលិក ការគ្រប់គ្រងថវិកាគម្រោង បង្កើត និងកំណត់កាលវិភាគ ដាក់ការងារ ដោះស្រាយបញ្ហាប្រចាំថ្ងៃ និងតាមដានដំណើរការរបស់ក្រុមតាមរយៈដំណាក់កាលនៃការអភិវឌ្ឍ និងការធ្វើឱ្យមានភាពប្រាកដទៅលើគុណភាពនៃផលិតផលសម្រេច។

ជាទូទៅអ្នកគ្រប់គ្រងគម្រោងកម្មវិធីត្រូវមានកម្រិតបរិញ្ញាបត្រ និងកម្រិតអនុបណ្ឌិតគឺត្រូវបានទាមទារ។ អ្នកវិភាគកម្មវិធីអាចនឹងត្រូវបានដំឡើងឋានៈទៅជាអ្នកគ្រប់គ្រងគម្រោង ពេលគាត់ទទួលបានសញ្ញាបត្រអនុបណ្ឌិតវិទ្យាសាស្ត្រកុំព្យូទ័រ ឬអនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម ហើយមានបទពិសោធន៍ការងារជាអ្នកអភិវឌ្ឍកម្មវិធីរយៈពេលពីបីទៅប្រាំឆ្នាំ។ បទពិសោធន៍គឺសំខាន់ ព្រោះ វាបានបង្កើតនូវជំនឿទុកចិត្តជាមួយសមាជិកក្រុមបច្ចេកទេស និងរៀបចំពួកគេបានប្រសើរសម្រាប់ការដោះស្រាយប្រតិកម្មរបស់អតិថិជន។ នៅអំឡុងពេលទទួលយកបទពិសោធន៍ ជំនាញដូចខាងក្រោមក៏នឹងត្រូវអភិវឌ្ឍ និងធ្វើឱ្យប្រសើរឡើងផងដែរ៖

- ត្រូវមានជំនាញគ្រប់គ្រងគម្រោងខ្លាំង៖ គោលដៅរបស់គម្រោងអភិវឌ្ឍន៍កម្មវិធីគឺដើម្បីផលិតផលិតផលទាន់ពេលវេលា ជាមួយថវិកាដែលបានបម្រុងទុក និងជាមួយសមត្ថភាពរំពឹងទុករបស់អតិថិជន។ វាពិតជាចាំបាច់ខ្លាំងណាស់សម្រាប់អ្នកគ្រប់គ្រងគម្រោងក្នុងការមានចំណេះដឹង ជំនាញ និងបទពិសោធន៍ដើម្បីដឹកនាំគម្រោង និងបញ្ចប់វាប្រកបដោយប្រសិទ្ធភាព។ សមត្ថភាពដែលបានទាមទារសម្រាប់អ្នកគ្រប់គ្រងគម្រោងរួមមាន ខ្លាំងខាង

ជំនាញបច្ចេកទេស ក៏ដូចជាជំនាញគ្រប់គ្រងរដ្ឋបាលដែរ គឺការកំណត់កាលវិភាគ ការបែងចែកបុគ្គលិកទៅតាមផ្នែកនីមួយៗរបស់គម្រោង ដាក់ការងារឱ្យក្រុម ធ្វើគម្រោងថវិកា និងការគ្រប់គ្រងក្រុម។ អ្នកគ្រប់គ្រងគម្រោងដែលមានប្រសិទ្ធភាពគឺមិនត្រឹមតែមានជំនាញបច្ចេកទេស និងចំណេះដឹងផ្នែកគ្រប់គ្រងរដ្ឋបាលប៉ុណ្ណោះទេ ពួកគេក៏ត្រូវមានជំនាញដឹកនាំ និងទំនាក់ទំនងផងដែរ។

- ខ្លាំងខាងជំនាញទំនាក់ទំនង៖ អ្នកពូកែទំនាក់ទំនង គឺអ្នកពូកែស្តាប់ ហើយមានជំនាញក្នុងការមើលមនុស្ស និងក្រុមតាមរយៈអាកប្បកិរិយា ការប្រព្រឹត្ត ភាពស្វាហាប់ សេចក្តីក្លាហាន និងលទ្ធផល។ អ្នកគ្រប់គ្រងគម្រោងខ្លាំងគឺជាមនុស្សដែលបង្កើតសេចក្តីទុកចិត្តរវាងសមាជិកក្នុងក្រុម ដោយរក្សាការបើកចំហចិត្តទទួលយកគំនិត យោបល់ថ្មី និងដោយការដឹងខុសត្រូវ។ ពួកគេមានសេចក្តីសម្រេចខ្ពស់នៅក្នុងលក្ខខណ្ឌស្ថានភាពគោលដៅ “ឈ្នះ-ឈ្នះ” និងមិនមាននរណាម្នាក់គិតថា “បរាជ័យ” ឡើយ។ អ្នកគ្រប់គ្រងគម្រោងជំនាញនឹងសួរសំណួរសមហេតុផល នឹងស្តាប់ដោយយកចិត្តទុកដាក់ ហើយនឹងបញ្ជាក់ការពន្យល់ច្បាស់លាស់ដើម្បីសម្រេចគោលដៅដំណោះស្រាយ “ឈ្នះ-ឈ្នះ” ។ អ្នកគ្រប់គ្រងគម្រោងចាំបាច់ត្រូវប្រើជំនាញទំនាក់ទំនងដើម្បីដោះស្រាយជាមួយមនុស្សគ្រប់ជាន់ថ្នាក់នៅក្នុងស្ថាប័ន រួមមានអ្នកគ្រប់គ្រងជាន់ខ្ពស់ ក៏ដូចជាអតិថិជនខាងក្រៅផងដែរ។

- ខ្លាំងខាងជំនាញដឹកនាំ៖ អ្នកដឹកនាំគឺជាមនុស្សដែលមានសមត្ថភាពបង្កើតក្រុមដើម្បីធ្វើការងាររបស់ពួកគេយ៉ាងអស់ពីសមត្ថភាព អនុវត្តគោលដៅគម្រោងដូចជាការងាររបស់ខ្លួន ហើយត្រូវបង្កើតអារម្មណ៍សហការនៅក្នុងក្រុម ជាមួយនឹងគោលដៅការងារប្រចាំថ្ងៃរបស់ពួកគេ។ អ្នកមិនអាចធ្វើជាអ្នកដឹកនាំពូកែបានដោយគ្មានទំនាក់ទំនងល្អបានឡើយ ជំនាញទាំងពីរនេះត្រូវតែនៅជាមួយគ្នា។ ការដឹកនាំជាឧទាហរណ៍គឺថាអ្នកដឹកនាំត្រូវធ្វើនូវអ្វីដែលពួកគេបាននិយាយ ហើយនិយាយនូវអ្វីដែលពួកគេត្រូវធ្វើ។ អ្នកត្រូវមានបទពិសោធន៍ច្រើនឆ្នាំដើម្បីក្លាយជាអ្នកដឹកនាំដ៏ខ្លាំងពូកែម្នាក់ ដូចជាអ្នកត្រូវមានទំនុកចិត្ត និងបទពិសោធន៍សិក្សាអំពីរបៀបដោះស្រាយបញ្ហានៅគ្រប់ស្ថានភាព ព្រមទាំងការចេះលើកទឹកចិត្តមនុស្សនៅក្នុងក្រុម។ មានមនុស្សខ្លះសមជាអ្នកពូកែដឹកនាំដោយធម្មជាតិតែម្តង ប៉ុន្តែយើងនៅតែអាចអភិវឌ្ឍជំនាញរបស់យើងបន្ថែម ដើម្បីក្លាយជាអ្នកដឹកនាំដ៏មានប្រសិទ្ធភាព។

# ២.១. បរិស្ថាន និងចរិតលក្ខណៈនៅក្នុងការងារផ្នែកសរសេរកូដកម្មវិធី

ការងារភាគច្រើនរបស់ អ្នកអភិវឌ្ឍកម្មវិធី គឺធ្វើការងារដាច់ដោយឡែក។ ពួកគេធ្វើការជាមួយកុំព្យូទ័រ ហើយបញ្ចប់ការងារដែលអ្នកវិភាគកម្មវិធីបានដាក់ឱ្យ។ ការអភិវឌ្ឍកម្មវិធីជាទូទៅគឺធ្វើការជាក្រុម ទោះបីជាអ្នកអភិវឌ្ឍនីមួយៗទទួលខុសត្រូវលើការសរសេរកូដកម្មវិធីផ្នែកផ្សេងគ្នាក៏ដោយ។ ការងារជាក្រុមគឺមានន័យថាពួកគេត្រូវប្រើភាសាកម្មវិធី និងឧបករណ៍ដូចគ្នា។ ប្រសិនបើនរណាម្នាក់មានបញ្ហាដែលមិនអាចដោះស្រាយបាន នោះវានឹងត្រូវបានចែករំលែកជាមួយសមាជិកក្រុម ដើម្បីស្វែងរកដំណោះស្រាយជាមួយគ្នា។ មិនត្រឹមតែមានទំនាក់ទំនងរវាងសមាជិកក្នុងក្រុមប៉ុណ្ណោះទេ ទីផ្សារការងារជាអ្នកសរសេរកូដកម្មវិធី

គឺត្រូវបានរកឃើញថាមានការប្រកួតប្រជែងខ្ពស់ ដូច្នេះប្រសិនបើនរណាម្នាក់ចង់ទទួលបានតំណែងល្អ គាត់ត្រូវតែមានសមត្ថភាព និងប្រសិទ្ធភាពការងារខ្ពស់ជាងអ្នកដទៃ។

ការងាររបស់អ្នកវិភាគកម្មវិធីភាគច្រើនគឺទំនាក់ទំនង៖ ត្រូវយល់ច្បាស់អំពីអ្វីដែលអ្នកប្រើចង់បាន ហើយអាចទំនាក់ទំនងជាមួយអ្នកអភិវឌ្ឍកម្មវិធីដើម្បីឱ្យពួកគេយល់ និងអភិវឌ្ឍកម្មវិធីឱ្យបានត្រឹមត្រូវ។ ពួកគេគួរតែដឹងពីរបៀប ស្តាប់ ទៅកាន់អ្នកប្រើដើម្បីឱ្យប្រាកដថាពួកគេបានយល់ច្បាស់ ១០០% នូវអ្វីដែលអតិថិជនចង់បាន បន្ទាប់មកបំប្លែងការចង់បានរបស់អតិថិជនដែលបានបញ្ជាក់នោះ ទៅជាសំណុំពាក្យបញ្ជាសម្រាប់អ្នកសរសេរកម្មវិធី។ ការងារមូលដ្ឋានរបស់ពួកគេគឺអភិវឌ្ឍសេចក្តីណែនាំលម្អិតពណ៌នាពីតម្រូវការរបស់អ្នកប្រើក្នុងលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីអភិវឌ្ឍកម្មវិធីចាំបាច់។ ពួកគេជាទីប្រឹក្សាទំនាក់ទំនងជាមួយអ្នកអភិវឌ្ឍកម្មវិធី ជាធម្មតាពួកគេធ្វើការនៅកន្លែងដូចគ្នា រកមើលនូវអ្វីដែលអាចត្រូវបានបញ្ចប់ និងអ្វីដែលមិនអាចត្រូវបានបញ្ចប់ និងដើរតួជាអ្នកតភ្ជាប់រវាងអ្នកប្រើជាមួយអ្នកអភិវឌ្ឍកម្មវិធី ដែលពេលខ្លះអាចនឹងត្រូវធ្វើដំណើរទៅកាន់ទីកន្លែងរបស់អតិថិជនទៀតផង។

អ្នកគ្រប់គ្រងគម្រោងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមទាំងមូល ព្យាយាមបង្កើតបរិយាកាសការងារល្អទាក់ទងនឹងគម្រោង លទ្ធផល និងមោទនភាពការងារ។ បរិយាកាសការងារតែងតែអាស្រ័យលើអាកប្បកិរិយា និងសមត្ថភាពរបស់អ្នកគ្រប់គ្រងគម្រោងក្នុងការដឹកនាំ និងទំនាក់ទំនង។ អ្នកគ្រប់គ្រងគួរតែអាចធ្វើដំណើរបានទៅកាន់ទីតាំងជាក់លាក់របស់អតិថិជន ឬទៅកាន់ប្រទេសផ្សេងៗ។

ជាទូទៅក្រុមអ្នកអភិវឌ្ឍកម្មវិធីគឺកើតឡើងពីក្រុមមិត្តភ័ក្តិ ដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នា ហើយពួកគេតែងតែជួយគ្រប់គ្រងការងារគ្នាទៅវិញទៅមក។

## មេរៀនសង្ខេប

ការអភិវឌ្ឍកម្មវិធីទូរសព្ទ និងកុំព្យូទ័រ គឺជាការបង្កើតកម្មវិធីដើម្បីឱ្យទូរសព្ទ ឬកុំព្យូទ័រធ្វើនូវអ្វីដែលយើងចង់បានជាក់លាក់។ កម្មវិធីដែលបានអភិវឌ្ឍអាចមានទំហំតូចសម្រាប់ការងារជាក់លាក់ណាមួយ ឬអាចមានទំហំធំដូចជាកម្មវិធីវាយអត្ថបទ ឬកម្មវិធីសៀវភៅបញ្ជី ដែលអនុញ្ញាតឱ្យអ្នកប្រើអាចធ្វើការងារបានយ៉ាងច្រើន។ កម្មវិធីត្រូវបានសរសេរនៅក្នុងសំណុំពាក្យបញ្ជា ដែលមានឈ្មោះថាភាសាកម្មវិធី។ មានភាសាកម្មវិធីរាប់រយ ដែលពួកវានីមួយៗគឺត្រូវគ្នាទៅនឹងស្ថានភាព ប្រព័ន្ធប្រតិបត្តិការ ឬប្រភេទនៃឧបករណ៍។ ក្រុមអភិវឌ្ឍកម្មវិធីត្រូវបានបង្កើតឡើងដោយអ្នកគ្រប់គ្រងគម្រោង អ្នកវិភាគកម្មវិធី និងអ្នកអភិវឌ្ឍកម្មវិធី។ អ្នកគ្រប់គ្រងគម្រោងសម្របសម្រួលគ្រប់ការងារទាំងអស់ គ្រប់គ្រងក្រុម កំណត់កាលវិភាគ ថវិកា និងធ្វើឱ្យប្រាកដថាការងារបានបញ្ចប់ទៅតាមផែនការ។ អ្នកវិភាគកម្មវិធីសិក្សាលម្អិតទៅលើអ្វីដែលអតិថិជន ឬអ្នកប្រើប្រាស់ចង់បានពីកម្មវិធី ហើយពួកគេអភិវឌ្ឍសេចក្តីបញ្ជាក់លម្អិតសម្រាប់កម្មវិធី ដែលនឹងត្រូវបានប្រគល់ឱ្យទៅក្រុមអ្នកអភិវឌ្ឍកម្មវិធី ដើម្បីសរសេរកម្មវិធីជាក់ស្តែង។ ការងារទាំងអស់នេះត្រូវតែធ្វើជាក្រុម ហើយត្រូវមានទំនាក់ទំនងគ្នាយ៉ាងល្អទៀតផង ក្រោមការដឹកនាំរបស់អ្នកគ្រប់គ្រងគម្រោង។

# លំហាត់

## លំហាត់ ១

អ្នកបានសម្រេចចិត្តថាគោលដៅការងាររបស់អ្នកគឺ ចង់ក្លាយជាអ្នកគ្រប់គ្រងគម្រោងកម្មវិធីនៅក្នុងក្រុមហ៊ុនធំមួយ។ អ្នកដឹងថាវាត្រូវប្រើពេលជាច្រើនឆ្នាំដើម្បីក្លាយជាអ្នកជំនាញម្នាក់ក្នុងអាជីពនេះ។ ពិភាក្សាសំណួរខាងក្រោមនៅក្នុងក្រុមរបស់អ្នក រួចប្រកាសវានៅក្នុងថតក្រុមរបស់អ្នក។

ក. ចូរពិភាក្សានៅក្នុងក្រុមរបស់អ្នក អំពីហេតុផលដែលនាំឱ្យក្រុមហ៊ុន ឬស្ថាប័នប្រើប្រាស់កម្មវិធីដែលបានរចនា និងអភិវឌ្ឍជាក់លាក់សម្រាប់ពួកគេ។ ហេតុអ្វីបានជាកម្មវិធីដែលបានអភិវឌ្ឍជាក់លាក់មានសារៈសំខាន់សម្រាប់ពាណិជ្ជកម្មរបស់ក្រុមហ៊ុន ឬស្ថាប័ននោះ?

ខ. ចូរពិភាក្សាជាមួយសមាជិកក្រុមថា តើកម្រិតសិក្សា បទពិសោធន៍ បច្ចេកទេស និងជំនាញទំនាក់ទំនងបែបណាដែលអ្នកត្រូវមានដើម្បីបានសម្រេចគោលដៅរបស់អ្នក គឺអ្នកគ្រប់គ្រងគម្រោងកម្មវិធី។

គ. នៅក្នុងក្រុមរបស់អ្នក ចូរពិភាក្សាអំពីជំនាញជាក់លាក់ដែលអ្នកគិតថាលំបាកបំផុតក្នុងការទទួលបាន ដើម្បីក្លាយជាអ្នកគ្រប់គ្រងគម្រោង។ ចូរពន្យល់ពីអ្វីដែលអ្នកអាចធ្វើដើម្បីអភិវឌ្ឍជំនាញ និងចំណេះដឹងដើម្បីសម្រេចគោលដៅការងាររបស់អ្នក។

# សំណួរត្រិះរិះ

១. តើអ្វីជាការអភិវឌ្ឍកម្មវិធី?

២. តើការងារដែលអាចធ្វើបានទាំងបីនៅក្នុងការអភិវឌ្ឍកម្មវិធីមានអ្វីខ្លះ?

៣. ហេតុអ្វីបានជាក្រុមហ៊ុន ឬស្ថាប័នចាំបាច់ត្រូវជួលអ្នកជំនាញដើម្បីធ្វើការអភិវឌ្ឍកម្មវិធី?

៤. តើចំណេះដឹង និងជំនាញបច្ចេកទេសអ្វីខ្លះដែលអ្នកអភិវឌ្ឍកម្មវិធីត្រូវតែមាន?

៥. តើអ្នកវិភាគកម្មវិធីធ្វើការងារអ្វីខ្លះ? តើគាត់ត្រូវយកព័ត៌មានមកពីណាដើម្បីសរសេរសេចក្ដីបញ្ជាក់លម្អិតអំពីការបង្កើតកម្មវិធី?

៦. តើអ្នកគ្រប់គ្រងគម្រោងធ្វើកិច្ចការអ្វីខ្លះ? ហើយតើពួកគេត្រូវមានជំនាញអ្វីខ្លះ?

៧. តើអ្នកគ្រប់គ្រងគម្រោងត្រូវមានវិជ្ជាជីវៈ និង ជំនាញទំនាក់ទំនងបុគ្គលចាំបាច់បំផុតអ្វីខ្លះ?

# ផ្នែក ខ - ការគិតតាមលំដាប់លំដោយ

## ៣. ការគិតតាមលំដាប់លំដោយ

នៅឆ្នាំ១៩០៣ លោក ហិនរី ហ្វដ (Henry Ford) ជនជាតិអាមេរិកបានបង្កើតក្រុមហ៊ុនផលិតរថយន្តមួយ។ ការផលិតរថយន្តត្រូវការពេលវេលាច្រើន ហើយអាចផលិតបានម្ដងមួយៗដោយក្រុមកម្មករ ពួកគេទាំងអស់គ្នាធ្វើការនៅលើផ្នែកផ្សេងៗនៃរថយន្តក្នុងពេលតែមួយ។ លោកហ្វដចង់ផលិតរថយន្តឱ្យបានច្រើន ហើយគាត់មានគំនិតអំពីការបង្កើតជាខ្សែសង្វាក់ផលិតកម្ម ដែលប្រតិបត្តិការនីមួយត្រូវបានធ្វើដោយកម្មករផ្សេងគ្នា។ រថយន្តត្រូវបានដំឡើងនៅតាមរោងចក្រ ហើយបានបន្ថែមផ្នែកផ្សេងៗម្ដងមួយៗរហូតដល់ការផលិតត្រូវបានបញ្ចប់។ ដើម្បីធ្វើកិច្ចការនេះ ជាដំបូងលោកហ្វដត្រូវមើលទៅកាន់រថយន្តទាំងមូល បន្ទាប់មកបែងចែកកិច្ចការផលិតទៅជាផ្នែកតូចៗ ហើយដាក់ប្រតិបត្តិការទាំងនេះតាមលំដាប់លំដោយ ធ្វើដូចនេះពួកគេអាចរៀបចំខ្សែសង្វាក់ផលិតកម្មទៅតាមលំដាប់លំដោយ ។ ក្នុងករណីខ្លះ វាមិនមានបញ្ហាដែលថាប្រតិបត្តិការណាត្រូវដំណើរការមុនឡើយ ប៉ុន្តែគាត់ត្រូវតែដាក់ប្រតិបត្តិការមួយក្នុងចំណោមប្រតិបត្តិការទាំងនោះ នៅមុនប្រតិបត្តិផ្សេងទៀតនៅក្នុងខ្សែសង្វាក់ផលិតកម្ម។ ឧទាហរណ៍ វាមិនមានសារៈសំខាន់អ្វីដែលថាកង់មុខ ឬកង់ក្រោយត្រូវដាក់មុននោះឡើយ ប៉ុន្តែដើម្បីបង្កើតខ្សែបន្ទាត់ផលិតកម្ម គាត់ត្រូវតែដាក់បញ្ចូលប្រតិបត្តិការមួយជាមុន ដូច្នេះប្រតិបត្តិការទាំងពីរនឹងត្រូវដំណើរការ។ ករណីខ្លះ វាគឺអាចធ្វើប្រតិបត្តិការច្រើនក្នុងពេលតែមួយ ព្រោះវាសន្សំសំចៃពេលវេលា ប៉ុន្តែនៅក្នុងការរចនា ពួកគេនៅតែមើលឃើញថា ប្រតិបត្តិការគឺដាច់ដោយឡែកពីគ្នា។ ឥឡូវនេះ លោកហ្វដបានចាប់ផ្ដើមជាមួយគំនិតរបស់គាត់ ក្រុមហ៊ុនផលិតរថយន្តមែសឺដេសបិនស៍ (Mercedes Benz) គឺបានកំពុងផលិតរួចទៅហើយនៅក្នុងប្រទេសអាល្លឺម៉ង់ ប៉ុន្តែអាចផលិតបានតិចជាង ១០០០ គ្រឿងប៉ុណ្ណោះក្នុងមួយឆ្នាំ។ ក្រុមហ៊ុនផលិតរថយន្តហ្វដបានចាប់ផ្ដើមផលិតនៅក្នុងឆ្នាំ១៩០៨។ ត្រឹមឆ្នាំ១៩១៤ ហ្វដអាចផលិតរថយន្តម៉ូដែល ធី ( Model T) បានចំនួន ២៥០.០០០គ្រឿងក្នុងមួយឆ្នាំ ហើយស្ទើរតែ ៥០០.០០០ គ្រឿងនៅត្រឹមឆ្នាំ១៩១៦។ ការបែងចែកភារកិច្ចតាមលំដាប់លំដោយ ធ្វើឱ្យការងារមានប្រសិទ្ធភាពបំផុត ហើយជាលទ្ធផលគឺអាចផលិតរថយន្តបានចំនួនយ៉ាងច្រើនក្នុងរយៈពេលខ្លីមួយ។



ក្រុមការងារដំឡើងរបស់ Henry Ford កំពុងបង្កើតរថយន្តម៉ាក Model-T Ford (ឆ្នាំ 1913)។

ខ្សែសង្វាក់ផលិតកម្មជាឧទាហរណ៍ដ៏ល្អនៃសកម្មភាពតាមលំដាប់ ឬម្តងមួយជំហានៗ ដែលត្រូវបានបង្កើតឡើងដោយ ការគិតតាមលំដាប់លំដោយ ។ វិធីសាស្ត្រចាត់ទុកបញ្ហាជាក្រុមកិច្ចការ ដែលចាំបាច់ត្រូវធ្វើ រៀបតាមលំដាប់លំដោយ និងដំណើរការពួកវាទាំងអស់តាមលំដាប់លំដោយត្រឹមត្រូវ បង្កើតបានជាដំណោះស្រាយបញ្ហា។ ដូចយើងបានឃើញហើយថា នៅចំណុចចាប់ផ្តើមនៃមេរៀននេះ កុំព្យូទ័រគឺធ្វើការតាមលំដាប់លំដោយ។ ពាក្យបញ្ជាសម្រាប់ពួកវា គឺត្រូវតែបានផ្តល់ឱ្យតាមលំដាប់លំដោយត្រឹមត្រូវ ហើយកិច្ចការត្រូវតែបានរៀបចំដោយប្រើ ការគិតតាមលំដាប់លំដោយ ។

អ្នកអភិវឌ្ឍកម្មវិធីទទួលកិច្ចការពីអ្នកវិភាគកម្មវិធី។ អ្នកវិភាគកម្មវិធីមិនបានខ្វល់ខ្វាយអំពីថាតើកិច្ចការត្រូវសរសេរជាកម្មវិធីចូលក្នុងកុំព្យូទ័រដោយរបៀបណាឡើយ ការងាររបស់ពួកគេគឺផ្តល់នូវព័ត៌មានលក្ខណៈកម្មវិធីដែលអ្នកប្រើប្រាស់ចង់បាន។ ឧទាហរណ៍ អ្នកវិភាគអាចនិយាយថា៖ “អ្នកប្រើចង់ឱ្យអេក្រង់ទូរសព្ទរបស់គាត់បង្ហាញប្រវត្តិនៃការហៅប្រាំដងដែលគាត់បានហៅចុងក្រោយ ហើយសម្រាប់ការហៅនីមួយៗគាត់ចង់ឱ្យបង្ហាញឈ្មោះ លេខទូរសព្ទ និងពេលវេលាដែលបានហៅ” ។ អ្នកវិភាគកម្មវិធីនឹងផ្តល់នូវការរចនាអេក្រង់ ដោយបញ្ជាក់ពីរបៀបដែលការហៅនីមួយៗត្រូវបង្ហាញ និងរបៀបដែលព័ត៌មាននឹងត្រូវបានចែកចាយនៅលើអេក្រង់។ បន្ទាប់មកអ្នកសរសេរកូដកម្មវិធីនឹងមើលទៅកាន់ធាតុនីមួយៗដែលនឹងត្រូវលេចឡើងនៅលើអេក្រង់ ហើយសរសេរកម្មវិធីដើម្បីបង្ហាញអេក្រង់បន្តបន្ទាប់។ អ្នកប្រើកម្មវិធីនឹងមិនដឹងថាធាតុទាំងឡាយត្រូវបានសរសេរជាបន្តបន្ទាប់គ្នាឡើយ ព្រោះទូរសព្ទដំណើរការលឿន ហើយធាតុទាំងអស់នៅលើអេក្រង់គឺត្រូវបានដំណើរការដោយប្រើពេលតែប៉ុន្មានវិនាទីប៉ុណ្ណោះ។ អ្នកប្រើមិនអាចមើលឃើញធាតុដែលបានសរសេរទាំងនោះដោយភ្នែកទទេបានឡើយ។



យើងប្រើការបង្ហាញអេក្រង់ជាឧទាហរណ៍ ប៉ុន្តែនេះគ្រាន់តែជាផ្នែកមួយនៃកិច្ចការរបស់កុំព្យូទ័រប៉ុណ្ណោះ។ កម្មវិធីចាំបាច់ត្រូវស្វែងរកទិន្នន័យដែលបានផ្ទុកនៅក្នុងកុំព្យូទ័រ ឬទូរសព្ទ បន្ទាប់មកធ្វើការគណនាលទ្ធផលដោយផ្អែកតាមទិន្នន័យនោះ រួចបង្ហាញព័ត៌មាន។ ដោយហេតុនោះហើយ ទើបចាំបាច់ត្រូវឱ្យអ្នកប្រើផ្តល់នូវការចង្អុលបង្ហាញអំពីប្រភេទព័ត៌មាន ឬលទ្ធផលជាក់លាក់ដែលពួកគេចង់បាន។ កិច្ចការទាំងអស់ត្រូវតែធ្វើតាមលំដាប់លំដោយ ទើបកម្មវិធីដំណើរការបានត្រឹមត្រូវ។

នៅពេលពួកគេចាប់ផ្តើមសរសេរកម្មវិធី អ្នកអភិវឌ្ឍកម្មវិធីជាទូទៅសរសេរអំពីលំដាប់នៃប្រតិបត្តិការដែលនឹងដំណើរការនៅក្នុងទូរសព្ទ។ វិធីសាស្ត្រទូទៅក្នុងការសរសេរលំដាប់នៃប្រតិបត្តិការទាំងនេះ គឺវាជាប្រភេទនៃក្រាហ្វិកដែលមានឈ្មោះថា គំនូសតាងលំហូរ ។

# ៤. គំនូសតាងលំហូរ

គំនូសតាងលំហូរគឺជាប្រភេទនៃគំនូសតាងបង្ហាញអំពីលំដាប់នៃព្រឹត្តិការណ៍ ដែលនឹងត្រូវដំណើរការនៅក្នុងកម្មវិធីកុំព្យូទ័រ។ គំនូសតាងលំហូរសាមញ្ញគឺគំនូសតាងដែលមាននៅក្នុងរូបភាពពន្យល់ទី៧.១ ដែលដំណើរការលេខ១ និងដំណើរការលេខ២ ចាំបាច់នឹងត្រូវប្រតិបត្តិ។ រូបភាពពន្យល់ទី៧.២ បង្ហាញអំពីគំនូសតាងលំហូរសាមញ្ញសម្រាប់ការផលិតរថយន្ត។ យើងអាចពិនិត្យឃើញថាវាមានតែភារកិច្ចបួនប៉ុណ្ណោះ ប៉ុន្តែក្នុងចំណោមភារកិច្ចនីមួយៗអាចត្រូវបានបែងចែកជាភារកិច្ចតូចៗបន្តទៀត។ ឧទាហរណ៍ សម្រាប់ភារកិច្ចដាក់បញ្ចូលកង់រថយន្តអាចត្រូវបានបែងចែកជាបួនជំហានផ្សេងទៀត ដែលជំហាននីមួយៗមានគំនូសតាងលំហូរផ្ទាល់ខ្លួនរបស់វា ដូចនៅក្នុងរូបភាពពន្យល់ទី៧.៣។ ការផលិតម៉ាស៊ីន និងការដាក់បញ្ចូលវាទៅក្នុងរថយន្តគឺអាចជាគំនូសតាងលំហូរដែលមានភារកិច្ចតូចៗរាប់រយនៅក្នុងនោះ។




រូបភាព ៧.១




រូបភាព ៧.២

គំនូសតាងលំហូរសម្រាប់កុំព្យូទ័រ គឺមានភាពស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងអ្វីដែលត្រូវធ្វើ ដើម្បីទទួលបានលទ្ធផល។

នៅខាងលើ យើងបានឃើញការប្រើប្រាស់គំនូសតាងលំហូរពីរដែលមានរូបរាងផ្សេងគ្នាៈប្រអប់រាងការ៉េគឺតំណាងឱ្យដំណើរការ ឬភារកិច្ច ហើយប្រអប់រាងពងក្រពើគឺតំណាងឱ្យចំណុចចាប់ផ្ដើម និងចំណុចបញ្ចប់នៃដំណើរការ។ យើងឃើញថាវត្ថុទាំងនោះត្រូវបានចងភ្ជាប់គ្នាដោយសញ្ញាព្រួញ នេះមានន័យថាភារកិច្ចដែលស្ថិតនៅចំណុចសញ្ញាព្រួញដើម ត្រូវតែដំណើរការមុនភារកិច្ចដែលស្ថិតនៅចំណុចសញ្ញាព្រួញចុងក្រោយ។ យើងអាចមានការប្រែប្រួលបន្តិចបន្តួចនៅលើគំនូសតាងលំហូរ នៅពេលដែលភារកិច្ចពីរត្រូវបានដំណើរការក្នុងពេលតែមួយ។ ឧទាហរណ៍ នៅក្នុងគំនូសតាងលំហូរខាងលើ សម្រាប់ភារកិច្ចដាក់បញ្ចូលកង់រថយន្ត យើងអាចមានភារកិច្ចពីរផ្សេងគ្នាទៀតគឺ ការដាក់បញ្ចូលកង់រថយន្តនៅផ្នែកខាងឆ្វេង និងការការដាក់បញ្ចូលកង់រថយន្តនៅផ្នែកខាងស្ដាំ ដូចមាននៅក្នុងរូបភាព ៧.៤។ ភារកិច្ចដែលពាក់ព័ន្ធជាមួយការដាក់បញ្ចូលកង់ទាំងសងខាង អាចត្រូវបានចាប់ផ្ដើមក្នុងពេលតែមួយបន្ទាប់ពីបញ្ចប់ការបាញ់ថ្នាំ ហើយដំណើរការនឹងបញ្ចប់ នៅពេលដែលការដាក់បញ្ចូលកង់ទាំងសងខាងត្រូវបានបញ្ចប់




រូបភាព ៧.៣




រូបភាព ៧.៤

តែប៉ុណ្ណោះ។ ពួកវាមិនចាំបាច់ត្រូវតែធ្វើនៅពេលដំណាលគ្នានោះទេ ប្រសិនបើមួយក្នុងចំណោមពួកវាចាប់ផ្ដើម ឬបញ្ចប់បន្ទាប់ពីភារកិច្ចផ្សេងទៀត នោះភារកិច្ចបន្ទាប់នឹងចាប់ផ្ដើមនៅពេលដែលភារកិច្ចចុងក្រោយត្រូវបានបញ្ចប់។

មកដល់ចំណុចនេះ យើងបានឃើញគំនូសតាងលំហូរផ្លូវតែមួយនៅក្នុងភារកិច្ច ដែលជានិច្ចកាលកើតឡើងនៅក្នុងលំនាំដូចគ្នា។ ដំណើរការរបស់គំនូសតាងលំហូរនឹងចាប់ផ្ដើមបង្ហាញនៅពេលអ្នកបន្ថែមធាតុថ្មី៖ ប្រអប់សម្រេចចិត្ត តាងដោយចតុកោណកែងស្មើ។ ប្រអប់សម្រេចចិត្តសួរសំណួរ ហើយដោយផ្អែកទៅតាមចម្លើយ គឺវានឹងបន្តលំហូរកាត់តាមផ្លូវណាមួយ ឬផ្លូវផ្សេង។







រូបភាព ៧.៦

នៅលើដំណើរការផលិតរថយន្តរបស់យើង វាអាចមានទីតាំងពីរសម្រាប់ការបាញ់ថ្នាំរថយន្ត មួយសម្រាប់បាញ់ថ្នាំពណ៌ខ្មៅ និងមួយទៀតសម្រាប់បាញ់ថ្នាំពណ៌ក្រហម។ មុនពេលបាញ់ថ្នាំ ការសម្រេចចិត្តបញ្ជាក់ថា បាញ់ថ្នាំពណ៌អ្វីមួយនឹងត្រូវបានធ្វើឡើង ហើយរថយន្តនឹងត្រូវបានបញ្ជូនទៅកាន់ទីតាំងបាញ់ថ្នាំយ៉ាងត្រឹមត្រូវ (មើលរូបភាព ៧.៦)។

រថយន្តហ្វដម៉ូដែលធី (Model T) មិនមានបញ្ហាដូចនេះទេ ព្រោះរថយន្តទាំងអស់គឺសុទ្ធតែពណ៌ខ្មៅ។ លោក ហិនរី ហ្វដ ធ្លាប់និយាយបែបកំប្លែងថា៖ “អតិថិជនអាចមានរថយន្តពណ៌ណាមួយដែលគាត់ចង់បានគឺពណ៌ខ្មៅ”។

សមត្ថភាពក្នុងការសម្រេចចិត្តគឺជាអ្វីដែលធ្វើឱ្យកុំព្យូទ័រឆ្លាត។

ឧបមាថាអ្នកកំពុងបង្កើតមនុស្សយន្តមួយដែលគ្រប់គ្រងដោយកុំព្យូទ័រ ហើយអ្នកចង់ប្រើមនុស្សយន្តឱ្យចេញដំណើរពីបន្ទប់ទទួលភ្ញៀវ ទៅកាន់ផ្ទះបាយនៅក្នុងផ្ទះរបស់អ្នក។ មានផ្លូវពីរដើម្បីទៅកាន់ផ្ទះបាយ




រូបភាព ៧.៧






រូបភាព ៧.៨

គឺផ្លូវកាត់ និងផ្លូវវាង។ បញ្ហាសម្រាប់ផ្លូវកាត់គឺថាពេលខ្លះទ្វារត្រូវបានបិទ។ ប្រសិនបើទ្វារបើក អ្នកចង់ឱ្យមនុស្សយន្តទៅតាមផ្លូវនោះ ហើយប្រសិនបើទ្វារបិទ គឺអ្នកត្រូវឱ្យមនុស្សយន្តទៅតាមផ្លូវវាង។ ផែនទីផ្ទះគឺដូចក្នុងរូបភាពពន្យល់ទី៧.៧ ហើយគំនូសតាងលំហូរដែលនឹងត្រូវសរសេរសម្រាប់មនុស្សយន្តគឺនៅក្នុងរូបភាពពន្យល់ទី៧.៨។ អ្នកអាចឃើញការរូការសម្រេចចិត្តនៅក្នុងគំនូសតាងលំហូរ ដែលករណីនេះសំណួរគឺ “តើទ្វារបិទឬបើក?” ហើយមានជម្រើសពីរដែលនឹងត្រូវប្រតិបត្តិ។ ការសម្រេចចិត្តអាចមានចម្លើយច្រើនជាងពីរ។ ក្នុងករណីនេះវាអាចមានទ្វារទីពីរសម្រាប់ផ្លូវវាងទៅកាន់ផ្ទះបាយ ហើយប្រសិនបើវាបិទ មនុស្សយន្តនឹងត្រូវបានបញ្ជាត្រឡប់ទៅកាន់ចំណុចចាប់ផ្តើមដើមវិញ ដូចនៅក្នុងរូបភាពពន្យល់ទី៧.៩។




រូបភាព ៧.៩

ការសម្រេចចិត្តអាចផ្អែកលើស្ថានការណ៍ដែលកុំព្យូទ័ររកឃើញទិន្នន័យបានផ្ទុករួចស្រេច ឬនៅក្នុងព័ត៌មានដែលវាសួរចេញពីកុំព្យូទ័រអ្នកប្រើ។ គំនូសតាងលំហូរបានប្រើរូបរាងផ្សេងដើម្បីបង្ហាញនូវចំណុចដែលបានផ្តល់ និងព័ត៌មានដែលបានសួរចេញពីអ្នកប្រើ (រូបភាពពន្យល់ទី៧.១០)។



រូបភាព ៧.១០




រូបភាព ៧.១១

គិតត្រឡប់ទៅឧទាហរណ៍អំពីការផលិតរថយន្តវិញ ពណ៌រថយន្តអាចត្រូវបានចោទសួរដោយនរណាម្នាក់ នៅមុនពេលធ្វើការសម្រេចចិត្តអំពីទីកន្លែងដែលត្រូវបញ្ជូនរថយន្តដើម្បីបាញ់ថ្នាំ (រូបភាពពន្យល់ទី៧.១១)។

ឧទាហរណ៍ជាច្រើនហើយ គឺយើងបានឃើញគំនូសតាងលំហូរដែលជានិច្ចកាលផ្លាស់ទីទៅមុខ ប៉ុន្តែវាក៏អាចបង្កើតការសម្រេចចិត្តដើម្បីត្រឡប់ទៅកាន់ផ្នែកខាងដើមនៃគំនូសតាងលំហូរបានដែរ។

ដូចនៅក្នុងឧទាហរណ៍នេះស្រាប់ សន្មតថាអ្នកនឹងសរសេរកូដកម្មវិធីដើម្បីបង្កើតម៉ាស៊ីនលក់ស្រាទំពាំងបាយជូរមួយនៅតាមផ្លូវ។ វាអាចសួរសំណួរ បន្ទាប់មកយកប្រាក់ រួចបញ្ចេញស្រាទំពាំងបាយជូរ ប៉ុន្តែវានឹងត្រូវលក់ឱ្យទៅមនុស្សដែលមានអាយុចាប់ពី២១ឆ្នាំ ឡើងទៅប៉ុណ្ណោះ។ ម៉ាស៊ីននឹងសួរអាយុអ្នកទិញស្រាទំពាំងបាយជូរ ប្រសិនបើអាយុគាត់ក្រោម២១ឆ្នាំ ម៉ាស៊ីននឹងមិនលក់ស្រាទំពាំងបាយជូរឱ្យឡើយ ហើយនឹងត្រឡប់ទៅចំណុចដើមវិញ រង់ចាំអ្នកទិញបន្ទាប់។ យើងអាចឃើញនៅក្នុងរូបភាពពន្យល់ទី៧.១២ ដែលមានតំណត្រឡប់ក្រោយពីរ មួយគឺពេលអតិថិជនមានអាយុក្រោម២១ឆ្នាំ វានឹងបញ្ជូនត្រឡប់វិញដោយសារតែការសម្រេចចិត្ត ប៉ុន្តែវានៅតែមានសញ្ញាព្រួញត្រឡប់ក្រោយ ព្រោះបន្ទាប់ពីលក់ស្រាហើយ ម៉ាស៊ីនត្រូវតែត្រឡប់ទៅចំណុចដើមវិញដើម្បីរង់ចាំអតិថិជនបន្ទាប់។ ដំណើរការមិនដែលបញ្ចប់ឡើយ។




រូបភាព ៧.១២

ឥឡូវនេះអត្ថន័យនៃ គំនូសតាងលំហូរ គួរតែបានបញ្ជាក់ច្បាស់ហើយ វាគឺជាក្រាហ្វិកតំណាងឱ្យដំណើរការដែលជំហាននីមួយៗរបស់វាត្រូវបានតាងដោយនិមិត្តសញ្ញាប្រអប់ខុសៗគ្នា ហើយផ្ទុកទៅដោយសេចក្ដីពណ៌នាខ្លីស្ដីអំពីដំណើរការ ឬការសម្រេចចិត្ត។ និមិត្តសញ្ញាគំនូសតាងលំហូរត្រូវបានតភ្ជាប់គ្នាដោយសញ្ញាព្រួញ ដែលបង្ហាញអំពីទិសដៅនៃលំហូរ។

គំនូសតាងលំហូរផ្ដល់នូវការបង្ហាញនិម្មិតរបស់បញ្ហា ឬដំណើរការ ជួយបញ្ជាក់ច្បាស់អំពីគំនិតដែលចាំបាច់ត្រូវកំណត់ និងប្រើប្រាស់នូវដំណើរការទាំងនោះ។ ពួកវាមិនត្រឹមតែប្រើនៅក្នុងការសរសេរកូដកម្មវិធីកុំព្យូទ័រប៉ុណ្ណោះទេ វាក៏ត្រូវបានប្រើផងដែរនៅក្នុងក្រុមហ៊ុនដើម្បីរៀបចំទម្រង់ការឯកសារ ដែលនិយោជិតនឹងអនុវត្តតាមគំនូសតាងលំហូរនោះ។

## មេរៀនសង្ខេប

ការគិតតាមលំដាប់លំដោយគឺជាសមត្ថភាពនៃការវិភាគភារកិច្ច និងបែងចែកវាទៅជាភារកិច្ចតូចៗ ប្រសិនបើភារកិច្ចមួយត្រូវបានបញ្ចប់បន្ទាប់ពីភារកិច្ចផ្សេងទៀតក្នុងលំដាប់លំដោយជាក់លាក់ វានឹងផ្តល់លទ្ធផលនៅក្នុងការបញ្ចប់ភារកិច្ចដើម។ កុំព្យូទ័រអាចអនុវត្តពាក្យបញ្ជាបានតែមួយប៉ុណ្ណោះក្នុងមួយពេល ដូច្នេះដើម្បីសរសេរកម្មវិធីលើវា អ្នកចាំបាច់ត្រូវបែងចែកភារកិច្ចទៅជាភារកិច្ចតូចៗតាមលំដាប់លំដោយ។ ការសិក្សាដើម្បីបែងចែកវាទៅជាភារកិច្ចតូចៗនេះ គឺសំខាន់បំផុតសម្រាប់អ្នកអភិវឌ្ឍកម្មវិធី។ លំដាប់នៃប្រតិបត្តិការត្រូវបានពណ៌នានៅក្នុង គំនូសតាងលំហូរ គឺជាក្រាហ្វិកពណ៌នាអំពីភារកិច្ចត្រូវធ្វើ និងលំដាប់ភារកិច្ចដែលនឹងត្រូវអនុវត្ត។ គំនូសតាងលំហូរក៏អនុញ្ញាតឱ្យដាក់ផងដែរនូវសេចក្តីពណ៌នារបស់ដំណើរការដែលទាមទារនូវការសម្រេចចិត្ត ការបង្ហាញផ្លូវនៃដំណើរការដែលនឹងត្រូវអនុវត្តដោយផ្អែកលើការសម្រេចចិត្តដែលបានកំណត់។ ក្នុងករណីខ្លះការសម្រេចចិត្តទាំងនេះអាចនាំទៅជំហានដើមនៃដំណើរការ ដែលត្រូវតែធ្វើឡើងវិញរហូតដល់លក្ខខណ្ឌពិតដែលបានផ្តល់ឱ្យ។

## សំណួរត្រិះរិះ

១. តើអ្វីជាការគិតតាមលំដាប់លំដោយ?
២. ចូររកឧទាហរណ៍ដែលបានប្រើការគិតតាមលំដាប់លំដោយ។
៣. តើអ្វីជាគំនូសតាងលំហូរ?
៤. តើមានប្រភេទធាតុខុសគ្នាអ្វីខ្លះ ដែលត្រូវបានប្រើនៅក្នុងគំនូសតាងលំហូរ?
៥. តើសញ្ញាព្រួញនៅក្នុងគំនូសតាងលំហូរមានន័យដូចម្តេច?
៦. តើប្រអប់រាងការ៉ូនៅក្នុងគំនូសតាងលំហូរមានន័យដូចម្តេច?
៧. ចូររកឧទាហរណ៍អំពីស្ថានភាពដែលសញ្ញាព្រួញ ត្រូវត្រឡប់ទៅជំហានដើមវិញនៅក្នុងគំនូសតាងលំហូរ។

# មេរៀនទី ៥

# ការងារក្នុងការរចនារូបភាព

## នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពីៈ

១. យល់ដឹងអំពីការរចនារូបភាព និងគោលបំណង
២. យល់ដឹងអំពីការងារក្នុងការរចនារូបភាព និងបរិស្ថានការងារទាក់ទងនឹងការរចនារូបភាព
៣. កំណត់ និងយល់ដឹងអំពីការអប់រំ បំណិនទំនាក់ទំនង បំណិនបច្ចេកទេស និងលក្ខណសម្បត្តិផ្សេងៗដែលត្រូវការដើម្បីក្លាយជាអ្នករចនារូបភាពដ៏ចំណាន
៤. យល់ដឹងអំពីការរៀបចំពណ៌ និងរបៀបប្រើវាក្នុងការរចនារូបភាព
៥. ពន្យល់អំពីសារៈសំខាន់នៃការសាកល្បងរចនារូបភាពផ្ទាល់ខ្លួន

# ផ្នែក ក - ការងារក្នុងការរចនារូបភាព

## ១. ការណែនាំអំពីការរចនារូបភាព

នៅពេលនេះចរណៃយល់ច្បាស់អំពីសារៈសំខាន់នៃការសម្ភាសន៍អ្នកដែលរៀនផ្នែកកុំព្យូទ័រ ឱ្យយល់អំពីវិជ្ជាជីវៈដែលនាងចូលចិត្ត និងអ្វីដែលនាងមានអារម្មណ៍ថាអាចធ្វើវាបាន ដើម្បីអាចធ្វើការសម្រេចចិត្តបន្តការសិក្សានៅសាកលវិទ្យាល័យ និង ជ្រើសរើសវិជ្ជាជីវៈ។ នាងទន្ទឹងរង់ចាំធ្វើការសម្ភាសន៍ជាមួយដានី ដែលជាមិត្តភ័ក្តិរបស់កុសល។ ដានីបានរៀនចប់សាកលវិទ្យាល័យឯកទេសផ្នែករចនារូបភាព និងកំពុងធ្វើការជាអ្នករចនារូបភាពជាន់ខ្ពស់មានបទពិសោធន៍រយៈពេល ៦ ឆ្នាំក្នុងក្រុមហ៊ុនទីផ្សារដ៏ធំមួយក្នុងទីក្រុងភ្នំពេញ។

ដានី និងចរណៃចំណាយពេលប៉ុន្មានម៉ោងជាមួយគ្នា ហើយដានីក៏បានបង្ហាញចរណៃនូវគម្រោងខ្លះដែលក្រុមហ៊ុនរបស់នាងបានធ្វើ។ ដានីនិយាយថា "ក្រុមហ៊ុនរបស់ខ្ញុំបានរចនាខិត្តប័ណ្ណផ្សព្វផ្សាយ រូបសញ្ញាសម្គាល់ក្រុមហ៊ុន ប័ណ្ណប្រកាស គម្របសៀវភៅ និងក៏មានការរចនាវេបសាយផងដែរ។ បុគ្គលិកទាំងអស់នៅទីនេះធ្វើការជាក្រុមតាមជំនាញផ្សេងៗគ្នា។

ចរណៃបានរៀបចំបញ្ជីសំណួរដើម្បីសួរដានី ហើយសំណួរដំបូងដែលនាងចាប់ផ្តើមសួរដានីនោះគឺថា តើដានីចាប់ផ្តើមចាប់អារម្មណ៍លើការរចនានេះនៅពេលណាដែរ។ ដានីឆ្លើយ "ខ្ញុំតែងតែរីករាយធ្វើអ្វីមួយដែលអ្នកផ្សេងចូលចិត្ត និងយល់ថាល្អ ហើយការគូររូបគឺជាទេពកោសល្យពីកំណើតរបស់ខ្ញុំ ជាមួយនឹងសារៈសំខាន់នៃការយល់ដឹងអំពីពណ៌ និងសោភ័ណភាព។ អំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ខ្ញុំបានទទួលចំណេះដឹងផ្នែកកុំព្យូទ័រដែលបានជួយខ្ញុំអភិវឌ្ឍ និងអនុវត្តជំនាញទាំងនេះបានប្រសើរជាងមុន។ យើងអាចធ្វើអ្វីៗបានយ៉ាងច្រើនជាមួយនឹងកុំព្យូទ័រ! ឥឡូវខ្ញុំអាចរៀបចំរូបភាពបានរហ័សជាងមុនឆ្ងាយណាស់ ប្រសិនបើគ្មានកុំព្យូទ័រទេនោះខ្ញុំនឹងត្រូវចំណាយពេលច្រើន និងបច្ចេកទេសកម្រិតខ្ពស់ផ្សេងៗដែលពិតជាមានការលំបាកសម្រាប់ខ្ញុំ។ ឥឡូវ ជាមួយកុំព្យូទ័រ ខ្ញុំអាចរចនារូបភាពបានប្រសើរជាមួយនឹងការងារបច្ចេកទេសតិចតួច។



ប៉ុន្តែខ្ញុំក៏ត្រូវអភិវឌ្ឍបំណិនទំនាក់ទំនងច្រើន ជាពិសេសបំណិនក្នុងការស្តាប់។ ខ្ញុំត្រូវយល់ដឹងបានប្រសើរនូវអ្វីដែលអតិថិជនរបស់ខ្ញុំចង់បាន ដើម្បីធ្វើឱ្យបំណងរបស់ពួកគេទទួលបាននូវអ្វីដែលពួកគេចង់បាន។ ខ្ញុំក៏បានសិក្សាអំពីវិធីសាស្ត្រ ល្អៗក្នុងការសហការ និងប្រាស្រ័យទាក់ទងជាមួយអ្នកធ្វើការជាមួយគ្នា ដើម្បីអាចធ្វើការជាមួយគ្នាបានដោយរលូន។

ដានីពន្យល់ចរណៃថា វាចាំបាច់ណាស់ដែលត្រូវធ្វើតាមក្រមសីលធម៌ ធ្វើវាដោយខ្លួនឯង មិនត្រូវលួចចម្លងស្នាដៃរចនារបស់គេដែលមានស្រាប់ទេ។ នាងបាននិយាយទៀតថា "ខ្ញុំទទួលបានការពេញចិត្តក្នុងការរចនាដែលខ្ញុំបានធ្វើវាសម្រាប់អតិថិជនរបស់ខ្ញុំ។ ការលួចស្នាដៃរចនារបស់អ្នកណាម្នាក់ គឺជារឿងមួយមិនសមរម្យ និងអសីលធម៌។ ហើយក្នុងនាមជាអ្នករចនាត្រូវមានទំនួលខុសត្រូវនូវអ្វីដែលខ្លួនបានធ្វើជានិច្ច។ ឧទាហរណ៍ យើងមិនត្រូវរចនាអ្វីមួយដែលមិនសមរម្យជារូបភាពឆ្លុះបញ្ចាំងពីភាពអវិជ្ជមានសម្រាប់កុមារ។"

ចរណៃបានឆ្លើយតបថា "ខ្ញុំយល់ថាវាមានសារៈសំខាន់ណាស់ ហើយខ្ញុំយល់ស្របចំពោះបញ្ហានេះ។ តើមានបំណិនបច្ចេកទេសអ្វីខ្លះដែលចាំបាច់ត្រូវដឹងក្នុងការងាររចនា?”

ដានីបានឆ្លើយតបថា "យើងធ្វើការច្រើននៅលើកុំព្យូទ័រ យើងត្រូវការជំនាញវាយអត្ថបទ និងចេះប្រើកម្មវិធីរចនារូបភាព។ ហើយខ្ញុំក៏មានឧបករណ៍គូសវាស ឬបន្ទះគូរឃ្យូរដៃដើម្បីគូសចំណាំគំនិតដែលខ្ញុំនឹកឃើញ។ តាមពិតទៅ ខ្ញុំចាប់ផ្តើមគូររូបនៅលើក្រដាសមុនខ្ញុំគូសវានៅលើកុំព្យូទ័រ។ នៅពេលដែលខ្ញុំត្រៀមរួចរាល់ហើយ ខ្ញុំចាប់ផ្តើមប្រើកុំព្យូទ័រសម្រាប់រចនា ខ្ញុំប្រើកម្មវិធីកុំព្យូទ័រប្រភេទ Adobe Suite តែក៏មានកម្មវិធីរចនាផ្សេងៗទៀតដែរដូចជា Corel Draw និង GIMP ដែលអាចប្រើជំនួសការងារទាំងអស់នេះបាន។ GIMP ជាកម្មវិធីកុំព្យូទ័រឥតគិតថ្លៃមួយដែលមានជាភាសាខ្មែរ និងជាជម្រើសប្រសើរបំផុតមួយប្រសិនបើអ្នកចង់បានកម្មវិធីកែសម្រួលរូបភាព។"



ចរណៃបញ្ចេញយោបល់ថា នាងមិនស្គាល់កម្មវិធីទាំងអស់នេះទេ ខណៈពេលនោះដានីបានប្រាប់ទៅនាងថា "កម្មវិធីទាំងនេះពិតជាមានសក្តានុពលណាស់ ហើយវាបានជួយបង្កើនល្បឿនការងាររចនារបស់ខ្ញុំយ៉ាងខ្លាំងជាងកាលដែលខ្ញុំគូរដោយប្រើខ្មៅដៃ។ អង្គុយចុះសិន ចរណៃ អនុញ្ញាតឱ្យខ្ញុំបង្ហាញឯងបន្តិចអំពីរបៀបបង្កើតខិត្តប័ណ្ណផ្សព្វផ្សាយរបស់ក្រុមហ៊ុនទេសចរណ៍មួយ។"

ដានី និងចរណៃមើលទៅកាន់អេក្រង់កុំព្យូទ័រដែលបង្ហាញអំពីខិត្តប័ណ្ណដែលផ្សព្វផ្សាយនៅលើអ៊ីនធឺណិត។ ដានីបង្ហាញចរណៃអំពីបច្ចេកទេសដែលអាចធ្វើការផ្លាស់ប្តូរ និងកែសម្រួលមួយចំនួន។ បន្ទាប់ពីមើលក្រដាសខិត្តប័ណ្ណដែលបានបោះពុម្ព នាងក៏បានសួរដានីសំណួរខ្លះ។ ចរណៃបានលាន់មាត់ "វ៉ាវ! នេះពិតជាការងារមួយដែលគួរឱ្យចាប់អារម្មណ៍សម្រាប់ខ្ញុំ។ ខ្ញុំចង់ស្វែងយល់បន្ថែមអំពីការរចនារូបភាព។ តើមានជំនាញអ្វីផ្សេងទៀតដែលខ្ញុំចាំបាច់ត្រូវរៀន?"

ដានីញញឹម ហើយនិយាយថា "ខ្ញុំរីករាយណាស់ដែលឯងចាប់អារម្មណ៍នឹងការងារនេះ។ បន្ថែមពីនេះទៀត គឺបំណិនប្រាស្រ័យទាក់ទងខ្លាំង សមត្ថភាពធ្វើការជាក្រុម និងចំណេះដឹងអំពីកម្មវិធីរចនារូបភាព ហើយក៏នៅមានជំនាញបន្ថែមខ្លះទៀតដែលនិយោជិតម្នាក់ៗត្រូវសិក្សាស្វែងយល់ ហើយជំនាញទាំងនោះអាស្រ័យលើការងារជាក់ស្តែងនៅក្នុងក្រុមហ៊ុន។"

ចរណៃបាននិយាយថា "អរគុណសម្រាប់ការជួយពន្យល់ខ្ញុំបន្ថែមអំពីការងារនេះដានី។ ខ្ញុំពិតជាកោតសរសើរចំពោះបងដែលចំណាយពេលវេលាច្រើនបង្ហាញខ្ញុំពីការងាររបស់បង និងឆ្លើយសំណួរខ្ញុំយ៉ាងក្បោះក្បាយ។ ឥឡូវខ្ញុំយល់បានប្រសើរណាស់អំពីការងាររចនារូបភាព។"

ប្រសិនបើអ្នកមានសារដែលអ្នកចង់ប្រាប់គេឱ្យដឹង អ្នកអាចសម្តែងវាចេញដោយខ្លួនឯងតាមរយៈការនិយាយ ឬបង្ហាញតាមរយៈអារម្មណ៍ដោយប្រើភាសាកាយវិការ។ អ្នកក៏អាចប្រើមធ្យោបាយដែលអាចមើលឃើញតាមរយៈការបង្ហាញជារូបភាព។ ក្រាហ្វិក គឺជារូបភាពដែលអាចមើលឃើញ និងត្រូវបានបង្កើតនៅលើផ្ទៃរាបស្មើមួយ ដូចជាក្រដាស ឬម៉ូនីទ័រកុំព្យូទ័រ។ ឧទាហរណ៍ដូចជាលិខិតអញ្ជើញអាពាហ៍ពិពាហ៍ដែលបានបោះពុម្ព ឬគម្របរូបថតនៅលើបណ្តាញសង្គម Facebook ជាដើម។ ការរចនារូបភាព គឺជាដំណើរការ និងសិល្បៈនៃការប្រាស្រ័យទាក់ទងតាមរយៈការបង្ហាញជារូបភាពដើម្បីជូនដំណឹង ឬប្រាប់ព័ត៌មានដល់អ្នកទទួលតាមរយៈរូបភាព ឬពាក្យជាលាយលក្ខណ៍អក្សរ។



# ១.១. ទំនាក់ទំនងជារូបភាព និងការរចនារូបភាព

គ្រប់មធ្យោបាយប្រាស្រ័យទាក់ទងពិតជាមានសារៈសំខាន់ដើម្បីយល់នូវខ្លឹមសារ។ពាក្យថាប្រាស្រ័យទាក់ទងដោយមើលឃើញសំដៅលើការចែករំលែក ឬផ្លាស់ប្តូរនូវគំនិតតាមរយៈអ្វីដែលមើលឃើញ។ នៅក្នុងមេរៀននេះ យើងផ្តោតសំខាន់លើបំណិនក្នុងការរចនារូបភាពសម្រាប់គោលបំណងពាណិជ្ជកម្ម ដូចជា ទីផ្សារ និងការលក់ផលិតផល។ អ្នករចនារូបភាពបង្កើតរូបភាពក្នុងបំណងធ្វើការផ្សព្វផ្សាយបោះពុម្ព ឬប្រើប្រាស់ក្នុងប្រព័ន្ធព័ត៌មានអេឡិចត្រូនិក។ ប័ណ្ណផ្សព្វផ្សាយពាណិជ្ជកម្ម ខិត្តប័ណ្ណ ប័ណ្ណប្រកាស រូបសញ្ញាសម្គាល់ក្រុមហ៊ុន វេបសាយ រូបថត និងការផ្សព្វផ្សាយពាណិជ្ជកម្ម គឺជាសមិទ្ធផលដែលបង្កើតឡើងដោយប្រើប្រាស់ការរចនារូបភាពដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់អតិថិជនគោលដៅ។

បច្ចុប្បន្ន ក្រាហ្វិកត្រូវបានបង្កើតឡើងដោយប្រើកម្មវិធីកុំព្យូទ័រ និងបច្ចេកទេសផ្សេងៗតាមកុំព្យូទ័រ។ អ្នករចនារូបភាពផ្សំសមត្ថភាពដ៏ប៉ិនប្រសប់របស់ពួកគេ និងចំណេះដឹងអំពីបច្ចេកវិទ្យាដើម្បីបង្កើតនូវផលិតផលដ៏គួរឱ្យចាប់អារម្មណ៍របស់ពួកគេ។

វាពិតជាមានអត្ថប្រយោជន៍ជាច្រើនក្នុងការប្រើប្រាស់ផលិតផលដែលមានការផ្សព្វផ្សាយខ្លឹមសារតាមរយៈការរចនាដ៏ទាក់ទាញ និងមានភាពងាយស្រួលយល់ពីអតិថិជន។ ឧទាហរណ៍ ដូចជាការរចនាអ្វីមួយដើម្បីពន្យល់ពីភាពសប្បាយរីករាយរបស់ក្មេង។ វាពិតជាមានភាពងាយស្រួល និងឆាប់រហ័សក្នុងការបង្ហាញរូបភាពក្មេងដែលរីករាយ ជាជាងប្រើប្រាស់អត្ថបទបរិយាយសុទ្ធសាធ។ អត្ថប្រយោជន៍មួយទៀតគឺថាការប្រាស្រ័យទាក់ទងតាមរូបភាពដែលមើលឃើញមានភាពងាយស្រួលយល់ជាង។ ការរចនារូបភាពដែលមានប្រសិទ្ធភាពអាចធ្វើឱ្យគេមើលទៅឆាប់យល់ជាងការប្រើពាក្យជាអត្ថបទសម្រាប់ព័ត៌មានដូចគ្នាដែលត្រូវចំណាយពេលស្វែងយល់ច្រើនជាង។ ឧទាហរណ៍ គិតអំពីស្លាកសញ្ញាចរាចរដែលបង្ហាញរូបភាពដំរី។ មនុស្សដែលឃើញរូបសញ្ញានេះអាចយល់បានថាផ្លូវនេះមានដំរីឆ្លងកាត់ ហើយស្លាកសញ្ញានេះមិនមានសរសេរពាក្យណាមួយឡើយ។ សារៈសំខាន់មួយទៀត គឺថារូបភាពតែងតែដក់ជាប់ក្នុងចិត្តរបស់យើងជាងការប្រើប្រាស់ពាក្យ។ ការស្រាវជ្រាវបានបង្ហាញថា មនុស្សយើងចងចាំរូបភាពប្រសើរជាងការប្រើពាក្យពេចន៍ដែលសរសេរ។



# ២. ការងារជាអ្នករចនារូបភាព

អាជីពការងាររចនាទាំងឡាយណាដែលមានភារកិច្ចចម្បងក្នុងការរចនារូបភាពដើម្បីប្រាស្រ័យទាក់ទង ឬផ្តល់ព័ត៌មានទាក់ទាញអតិថិជន ត្រូវបានគេហៅថា អ្នករចនារូបភាព ទោះបីពួកគេធ្វើការផ្ទាល់ខ្លួន ឬធ្វើការឱ្យក្រុមហ៊ុនក៏ដោយ។ អ្នករចនារូបភាពក្រៅម៉ោងការងារ គឺសំដៅលើអ្នកដែលធ្វើការជាអ្នករចនាដោយឯករាជ្យខ្លួនឯង។

អ្នករចនាទាំងឡាយណាដែលធ្វើការក្នុងផ្នែករចនានៃក្រុមហ៊ុនដ៏ធំមួយអាចត្រូវបានបែងចែកតួនាទីការងារជាបីដូចជា៖ អ្នករចនារូបភាពថ្មីថ្មោង (Junior Graphic Designer) អ្នករចនារូបភាពជាន់ខ្ពស់ (Senior Graphic Designer) និងនាយករចនាច្នៃប្រឌិត (Creative Director)។

## ២.១. តម្រូវការការងារ

### ការអប់រំ

នៅពេលចាប់ផ្តើមការងារជាអ្នករចនាថ្មីថ្មោង យ៉ាងហោចណាស់ក៏អ្នកត្រូវមានវិញ្ញាបនបត្រផ្នែករចនារូបភាពមួយពីសាលាបច្ចេកទេស តែទោះជាយ៉ាងណា អ្នករចនារូបភាពភាគច្រើនយ៉ាងហោចណាស់ក៏ទទួលបានបរិញ្ញាបត្រដែរ។ អ្នករចនារូបភាពត្រូវសិក្សាជំនាញវិចិត្រសិល្បៈដូចជា គំនូរ និងការផាត់ពណ៌ ព្រមទាំងចេះប្រើប្រាស់កម្មវិធីរចនារូបភាពដែលជាជំនួយចាំបាច់។ មានអ្នករចនារូបភាពដែលទើបតែចាប់ផ្តើម និងអ្នកដែលមានបទពិសោធន៍ការងារច្រើនបានក្លាយជាអ្នករចនារូបភាពដ៏ជំនាញ។ អ្នករចនារូបភាពដែលធ្វើការជាបុគ្គលិកក្រុមហ៊ុន ជាធម្មតាពួកគេធ្វើការជាក្រុមក្នុងផ្នែករចនាផ្សេងៗ ពួកគេមួយចំនួនក៏មានបទពិសោធន៍ការងារថ្មីថ្មោង និងខ្លះក៏ជាអ្នករចនាដ៏ស្ទាត់ជំនាញ ដែលមានបទពិសោធន៍យូរឆ្នាំក្នុងការងាររបស់ពួកគេ ដែលអាចយល់ដឹងពីគំនិតរចនាច្នៃប្រឌិតថ្មីៗ និងអ្វីដែលអតិថិជនចង់បាន។ ក្រុមការងាររចនាជាទូទៅដឹកនាំការងារដោយនាយករចនាច្នៃប្រឌិតដែលជាអ្នកផ្តល់នូវគំនិតចម្បងជាគន្លឹះថ្មីប្លែកដែលអាចប្រើសម្រាប់ការរចនា ហើយជាអ្នកទទួលបន្ទុកគម្រោងធំ និងចាត់ចែងការងារឱ្យក្រុមការងាររចនាធ្វើ។

អ្នកដែលមានអាជីវកម្មខ្លួនឯង ដែលហៅថា អ្នករចនារូបភាពក្រៅម៉ោងការងារ ពួកគេច្រើនធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនដើម្បីទទួលបានការងារលើគម្រោងជាក់លាក់ណាមួយក្នុងរយៈពេលណាមួយ។ អ្នករចនារូបភាពក្រៅម៉ោងការងារឯកទេសមានតួនាទីច្រើន ដែលរួមមានទាំងការគ្រប់គ្រងអាជីវកម្ម និងគ្រប់គ្រងការច្នៃប្រឌិតរចនាថ្មីៗ។

### បំណិន និងបទពិសោធន៍

គ្រប់អ្នករចនារូបភាពដែលជោគជ័យត្រូវតែមានការយល់ដឹងជ្រៅជ្រះអំពីសោភ័ណភាព និងការប្រើពណ៌ និងចាំបាច់ត្រូវអភិវឌ្ឍជំនាញច្នៃប្រឌិតថ្មីដែលមានភាពបត់បែនតាមការងារ និងការនិយមចូលចិត្តរបស់អតិថិជន។ ការច្នៃប្រឌិតមានភាពចាំបាច់ណាស់សម្រាប់ការងាររចនា ព្រោះវាជាការសកម្មភាពក្នុងការប្រឌិតអ្វីមួយឱ្យមានការយល់ឃើញត្រឹមត្រូវ និងប្រាកដតាមរយៈការរចនា និងរួមបញ្ចូលគំនិតថ្មីៗ។

ដោយឡែកបំណិនផ្នែកទំនាក់ទំនងរវាងបុគ្គលក៏មានសារៈសំខាន់ខ្លាំងណាស់ដែរ។ បំណិនទាំងនេះរួមមានបំណិនក្នុងការស្តាប់ ភាពអត់ធ្មត់ និងសមត្ថភាពធ្វើការដោយឯករាជ និងធ្វើការជាក្រុម។ អ្នករចនារូបភាពក៏ចាំបាច់ត្រូវចេះផ្តល់យោបល់ និងទទួលយកមតិត្រឡប់បែបស្ថាបនា។ នេះមានន័យថាពួកគេត្រូវតែមានការអង្កេត និងគំនិតអំពីការរចនាជាមួយអាកប្បកិរិយាវិជ្ជមាន ដោយមិននិយាយបែបរិះគន់ថាអ្វីមួយមិនល្អ ឬមិនត្រូវ ប៉ុន្តែត្រូវចេះផ្តល់នូវគំនិតយល់ឃើញល្អៗដើម្បីជួយកែលម្អវាឱ្យប្រសើរ។ ពួកគេក៏ត្រូវចេះទទួលយកមតិត្រឡប់ពីអ្នកផ្សេងដើម្បីស្ថាបនាគំនិតខ្លួនឯងឱ្យប្រសើរ។ បំណិនបន្ថែមពីនេះដែលចាំបាច់មានដូចជា សុក្រឹតភាព ការអាន និងកែសម្រួល ការយកចិត្តទុកដាក់ ការគ្រប់គ្រងពេលវេលា បំណិនសរសេរ និងការមើលដោយប្រសិទ្ធភាព និងបំណិនត្រិះរិះពិចារណា។

បំណិនបច្ចេកទេសដែលចាំបាច់ត្រូវមានចំណេះដឹងគ្រប់គ្រាន់ផ្នែកកុំព្យូទ័រកម្រិតខ្ពស់ និងធាតុសំខាន់ៗនៃការរចនារូបភាព។ ខណៈដែលអ្នករចនារូបភាពត្រូវដឹងអំពីរបៀបគូសវាសលើក្រដាសអំពីគំនិតដែលពួកគេនឹកឃើញ និងអនុវត្តការងារជាក់ស្តែងនៅលើកុំព្យូទ័រ។ កម្មវិធីកុំព្យូទ័រ Adobe គឺជាកម្មវិធីដែលគេនិយមប្រើដោយអ្នករចនារូបភាពទូទៅ និងអ្នករចនារូបភាពអាជីពត្រូវមានជំនាញមូលដ្ឋានដែលអាចយល់ដឹងអំពីការប្រើប្រាស់កម្មវិធីទាំងនេះ។ ដែលមានលក្ខណៈងាយយល់សម្រាប់មនុស្សគ្រប់គ្នា។

អ្នករចនារូបភាពត្រូវរៀនប្រើប្រាស់ធាតុជារូបភាពដើម្បីទាក់ទងជាខ្លឹមសារតាមរយៈការបោះពុម្ព និងបណ្តាញព័ត៌មានអេឡិចត្រូនិក។ ពួកគេនឹងត្រូវប្រើធាតុទាំងនេះដើម្បីរចនាខិត្តប័ណ្ណ ទស្សនាវដ្តី កាសែត វេបសាយ កញ្ចប់ពាណិជ្ជកម្ម ប័ណ្ណផ្សាយពាណិជ្ជកម្ម ប័ណ្ណប្រកាស និងទម្រង់នៃទំនាក់ទំនងជារូបភាពផ្សេងៗ។

និយោជក ឬភ្ញៀវដែលយល់ច្បាស់នឹងត្រូវការមើលគំរូការងាររបស់អ្នកដាក់ពាក្យ មុនពេលជួលអ្នកនោះ។ អ្នករចនារូបភាពត្រូវតែអភិវឌ្ឍឯកសារប្រវត្តិការងារដែលនឹងក្លាយជាតម្រូវការដ៏សំខាន់មួយជាប្រវត្តិរូបសង្ខេប ឬនាមប័ណ្ណរបស់ពួកគេ នៅពេលពួកគេធ្វើការណែនាំដល់និយោជក ឬអតិថិជន។ ឯកសារប្រវត្តិការងារពីមុនៗត្រូវបានចងក្រងមានទំហំធំដែលជាកន្លែងដាក់គំរូការងារល្អៗរបស់អ្នករចនា។ គំរូទាំងនោះត្រូវបានការពារខាងក្នុងដោយសំបកប្លាស្ទិកជានិច្ច។ ខណៈដែលឯកសារប្រវត្តិការងារពីមុនៗនៅតែត្រូវបានប្រើ និងយកទៅសម្ភាសន៍ការងារ បច្ចុប្បន្នឯកសារប្រវត្តិការងារត្រូវបានគេធ្វើជាលក្ខណៈឌីជីថល និងអាចត្រូវបានផ្តល់ឱ្យភ្ញៀវជាកញ្ចប់ស៊ីឌី ឬឌីវីឌី។ បន្ថែមពីនេះទៀត អ្នករចនាជាច្រើនមានវេបសាយដែលពួកគេបានដាក់បង្ហាញប្រវត្តិការងាររបស់ពួកគេ។ ជំហានក្នុងគន្លងការងារជាអ្នករចនាមានដូចខាងក្រោម៖

- **អ្នករចនារូបភាពថ្មីថ្មោង៖** អ្នកដែលមានមុខតំណែងនេះ ជាធម្មតាស្ថិតនៅកម្រិតដំបូងក្នុងក្រុមហ៊ុនរចនារូបភាព។ ពួកគេត្រូវតែចាប់ឱ្យបាននូវការអប់រំ បំណិន និងចរិតលក្ខណៈទាំងអស់ដែលបានរៀបរាប់ខាងលើ។
- **អ្នករចនារូបភាពជាន់ខ្ពស់៖** អ្នកដែលមានមុខតំណែងនេះ ជាធម្មតាមានបទពិសោធន៍ការងារចាប់ពី ៤ ឆ្នាំឡើងទៅនៅក្នុងក្រុមហ៊ុនរចនារូបភាព និងមានទំនួលខុសត្រូវច្រើនជាងមុខតំណែងជាអ្នករចនាថ្មីថ្មោង។ អ្នករចនាកម្រិតខ្ពស់តែងតែផ្តល់ដំបូន្មាន និងបង្ហាត់បង្ហាញដល់អ្នកចូលថ្មី ឬអ្នករចនាដែលមានកម្រិតទាប បង្កើតក្រុមការងារសម្រាប់គម្រោងជាក់លាក់។
- **នាយករចនាច្នៃប្រឌិត៖** ជាអ្នកដែលមានបទពិសោធន៍រចនារូបភាពយូរឆ្នាំដែលអាចមើលការងាររចនាគ្រប់ជ្រុងជ្រោយ ត្រួតពិនិត្យ និងកែលម្អការងារមួយចំនួន ព្រមទាំងធ្វើការស្នើដើម្បីកែលម្អ

រូបភាពរចនា។ នាយករចនាច្នៃប្រឌិតត្រួតពិនិត្យមើលការងារប្រធានក្រុមផ្នែកនីមួយៗ ជំរុញចិត្តឱ្យចង់ និងលើកទឹកចិត្តក្រុមការងារបង្កើតបរិស្ថានការងារជាក្រុមប្រសើរមួយ។ នាយករចនាច្នៃប្រឌិតជាអ្នករកឃើញការច្នៃប្រឌិតរបៀបថ្មី និងជាទូទៅគាត់ជាមនុស្សដែលជួបប្រជុំជាញឹកញាប់ជាមួយភ្ញៀវដើម្បីពិភាក្សាគំនិត និងធ្វើឱ្យគម្រោងសម្រេចបានតាមការរំពឹងទុករបស់ភ្ញៀវដែលចង់បាន។ នាយករចនាច្នៃប្រឌិតត្រូវតែមានជំនាញក្នុងការគ្រប់គ្រងមនុស្ស គម្រោង និងធនធាន និងត្រូវតែមានបំណិនអន្តរបុគ្គលច្បាស់លាស់។ នាយករចនាច្នៃប្រឌិតត្រូវតែបន្តការអប់រំផ្នែកការងាររបស់ពួកគេជានិច្ច ដើម្បីឱ្យមានភាពរីកចម្រើន និងវិវឌ្ឍជឿនលឿននៃក្រុមហ៊ុនរបស់ពួកគេ។

- **អ្នករចនារូបភាពធ្វើការក្រៅម៉ោងការងារ៖** ជាអ្នកដែលមានបទពិសោធន៍ការងារពីមុនយ៉ាងតិច ៥ ឆ្នាំជាអ្នករចនារូបភាព។ អ្នករចនាក្រៅម៉ោងការងារទទួលបន្ទុកគ្រប់ភារកិច្ចនៃជំនួញរបស់ពួកគេ ចាប់ពីការស្វែងរកអតិថិជនដែលត្រូវការគម្រោងរចនា បង្កើតការរចនាទាក់ទាញ ជួបជាមួយភ្ញៀវ បង់ប្រាក់ចំណាយផ្សេងៗ និងទទួលប្រាក់ចំណូល។ ជាធម្មតា អ្នករចនាធ្វើការក្រៅម៉ោងការងារបំពេញនូវភារកិច្ចសង្ខេបសម្រាប់អតិថិជនផ្សេងៗ ប៉ុន្តែនៅពេលចាប់ផ្តើមដំបូងប្រហែលមានពេលខ្លះមិនមានការងារធ្វើ ដូច្នេះអ្នករចនាធ្វើការក្រៅម៉ោងការងារត្រូវលៃលកសន្សំប្រាក់សម្រាប់ពេលនោះ។ អ្នករចនាធ្វើការក្រៅម៉ោងការងារខ្លះមានឯកទេសធ្វើការក្នុងផ្នែកជាក់លាក់ណាមួយ ដូចជា ផ្នែកបកប្រែកម្មវិធី ប្រឹក្សាគម្រោង សុខភាព ឬការងារសម្រាប់អង្គការក្រៅរដ្ឋាភិបាលមិនរកប្រាក់ចំណូល ឬជំនាញតាមផ្នែកបច្ចេកទេសដូចជា រចនាវេបសាយ ឬរូបសញ្ញាពាណិជ្ជកម្មក្រុមហ៊ុន។ អ្នកធ្វើការឯករាជជាច្រើនធ្វើការ និងភ្ជាប់ទំនាក់ទំនងជាមួយអ្នករចនាផ្សេងទៀតដើម្បីបង្កើតជាក្រុមលើគម្រោង និងរកប្រាក់កម្រៃអំពីគំនិតរបស់ពួកគេក្នុងទិសដៅរួមមួយ។



# ២.២. បរិស្ថានការងារ

ការងារនៅក្នុងមុខរបរអាជីពជាអ្នករចនារូបភាពមានការប្រកួតប្រជែងខ្លាំង។ ដើម្បីឈានទៅតំណែងខ្ពស់ក្នុងការងារនេះ វាពិតជាសំខាន់ណាស់ក្នុងការទទួលបានបទពិសោធន៍ និងអភិវឌ្ឍជំនាញថ្មីៗប្រឌិតថ្មី។ ផ្នែកដែលមានតម្រូវការទីផ្សារខ្ពស់នៃការរចនាគឺអ៊ីនធឺណិត ក៏ដោយសារចំនួនស្ថាប័នដែលចង់មានវេបសាយកំពុងតែកើនឡើង និងក្រុមហ៊ុនថ្មីកំពុងកើតឡើងឥតឈប់ឈរ ដែលត្រូវការអ្នករចនាដែលមានទេពកោសល្យ និងជំនាញច្បាស់លាស់។ ដើម្បីមានការទទួលស្គាល់ថាជាអ្នករចនាដែលជឿជាក់ មានសមត្ថភាព គុណភាពជាមួយវេបសាយ និងមុខងារផ្សេង វាពិតជាមានសារៈសំខាន់ណាស់ដើម្បីទទួលបានភាពជោគជ័យនៅក្នុងវិស័យដែលមានភាពរីកចម្រើននេះ។

អ្នករចនារូបភាពជាទូទៅច្រើនតែធ្វើការក្នុងក្រុមហ៊ុនដែលមានឯកទេសក្នុងការបោះពុម្ពផ្សាយ ទំនាក់ទំនងសាធារណៈ ឬក្រុមហ៊ុនផ្តល់សេវាកម្មដែលទាក់ទង ឬក្រុមហ៊ុនដែលធ្វើការឥតឈប់ឈរជាមួយការងាររចនាខ្លឹមសារជារូបភាព និងក្រុមការងារដែលធំគ្រប់គ្រាន់ក្នុងការជួលបុគ្គលិកបម្រើការងារផ្នែករចនារូបភាពសម្រាប់ពួកគេ។ អ្នករចនាអាចចែករំលែកការិយាល័យជាមួយអ្នករចនាផ្សេងទៀត និងតែងតែធ្វើការជាក្រុមក្នុងគម្រោងណាមួយ។ នៅក្នុងក្រុមការងាររចនា អ្នករចនានីមួយៗអាចធ្វើការផ្នែកណាមួយនៃក្រុមរចនាធំ ឬពួកគេអាចមានឯកទេសក្នុងចំណុចណាមួយនៃការរចនា។

អ្នករចនារូបភាពធ្វើការជាមួយកុំព្យូទ័រ និងត្រូវស្ទាត់ជំនាញប្រើប្រាស់កម្មវិធីរចនាដែលឯកទេស។ កម្មវិធី Adobe Photoshop និង CorelDraw ជាកម្មវិធីដែលគេនិយមប្រើសម្រាប់ការងាររចនារូបភាពដោយអ្នកជំនាញខាងរចនា។ តែទោះជាយ៉ាងណាក៏ដោយ វាក៏អាចធ្វើការងារបានជាច្រើនជាមួយកម្មវិធីឥតគិតថ្លៃជាភាសាខ្មែរឈ្មោះថា GIMP។

ជាធម្មតា អ្នករចនាព្រាងគំនិតរបស់ពួកគេនៅលើក្រដាស មុនពេលពួកគេយកទៅអនុវត្តនៅក្នុងកុំព្យូទ័រ។ ការងារត្រូវតែច្បាស់លាស់ ហើយអ្នករចនារូបភាពប្រើឧបករណ៍គំនូរ និងព្រាងដូចជា ក្តារគូសបន្ទាត់ រ៉ាព័តទ័រ (ឧបករណ៍វាស់មុំ) និងដែកឈាន។ អ្នករចនារូបភាពក៏ត្រូវរក្សាបច្ចុប្បន្នភាពជាមួយនិន្នាការចុងក្រោយ ពីព្រោះបច្ចេកវិទ្យា និងសក្តានុពលនៃជំនួញកំពុងតែផ្លាស់ប្តូរយ៉ាងលឿន។

អ្នករចនារូបភាពជាច្រើនធ្វើការខ្លួនឯង និងប្រកួតប្រជែងជាមួយអ្នករចនាផ្សេងទៀតសម្រាប់ការងារក្នុងផ្នែកនេះ។ ពួកគេមួយចំនួនមានបន្ទប់ស្ទូឌីយោនៅផ្ទះ ឬពួកគេមានការិយាល័យផ្ទាល់ខ្លួននៅផ្ទះ។ វាពិតជាមានការលំបាកក្នុងការចាប់ផ្តើមក្រុមហ៊ុនរចនា ប្រសិនបើអតិថិជនមិនធ្លាប់ស្គាល់ឈ្មោះអ្នករចនា ឬការងាររបស់ពួកគេ។ អ្វីដែលធ្វើឱ្យមាននោះ គឺអ្នករចនាផ្ទាល់ខ្លួនទទួលបានការណែនាំដោយអតិថិជនដែលពេញចិត្តនឹងស្នាដៃរបស់ពួកគេ។ ប្រសិនបើអ្នករចនាដែលធ្វើការផ្ទាល់ខ្លួនធ្វើការម្នាក់ឯង នោះពួកគេនឹងទទួលរ៉ាប់រងគ្រប់ការងារទាំងអស់នៅក្នុងគម្រោង។

បរិស្ថានការងារនៃអ្នករចនារូបភាពរួមមានក្រមសីលធម៌វិជ្ជាជីវៈដូចខាងក្រោម។ ក្រមសីលធម៌ជាគោលការណ៍ខាងសីលធម៌ដែលណែនាំពីអាកប្បកិរិយារបស់មនុស្ស និងសីលធម៌ទាំងនោះអាចមានទម្រង់ផ្សេងៗទៅតាមផ្នត់គំនិតគ្រួសារ វប្បធម៌ សង្គម និងសាសនា។ ក្រមសីលធម៌ណែនាំយើងឱ្យយល់អំពីសិទ្ធិ និងអ្វីដែលជាអាកប្បកិរិយាល្អ ឬមិនល្អ។ ក្រមសីលធម៌ក្នុងការងាររចនារូបភាពរួមមានការបដិសេធមិនឱ្យលួចចម្លងស្នាដៃអ្នកដទៃ ឬបំពានសិទ្ធិច្បាប់ចម្លង។ ឧទាហរណ៍ការលួចចម្លងស្នាដៃ ក្នុងការងាររចនារូបភាព គឺជាការលួចរូបសញ្ញាសម្គាល់ក្រុមហ៊ុនមួយ និងប្តូរតែពណ៌ និងឈ្មោះពាណិជ្ជកម្ម



នោះក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មសម្រាប់ក្រុមហ៊ុនផ្សេង។ ឧទាហរណ៍ការលួចច្បាប់ដើមនៃឯកសារខិត្តប័ណ្ណមួយដែលអ្នករចនាមួយបានបង្កើត បោះពុម្ព និងចែកចាយ។ ការលួចចម្លងច្បាប់ចម្លងអាចកើតឡើង ប្រសិនបើអ្នករចនារូបភាពផ្សេងទៀតបង្កើត និងបោះពុម្ពខិត្តប័ណ្ណផ្សព្វផ្សាយមួយដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងច្បាប់ដើម។

អ្នករចនារូបភាពត្រូវមានកម្រិតទំនាក់ទំនងសង្គមខ្ពស់។ ពួកគេតែងតែនិយាយជាមួយភ្ញៀវ សមាជិកក្រុមការងារ និងប្រធានផ្នែកជាប្រចាំ។ ពួកគេប្រាស្រ័យទាក់ទងជាមួយភ្ញៀវដោយជួបមុខផ្ទាល់ ឬតាមរយៈទូរសព្ទ ឬអ៊ីមែលជាប្រចាំថ្ងៃ។ ដើម្បីក្លាយជាអ្នករចនារូបភាពដ៏មានសក្តានុពល អ្នកត្រូវមានជំនាញទំនាក់ទំនងជាលាយលក្ខណ៍អក្សរ ដោយវាចា មិនវាចា និងប្រើប្រាស់រូបភាពជំនួយ។



# មេរៀនសង្ខេប

អ្នករចនារូបភាពប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នាក្នុងការបង្កើត និងផ្សំរវាងរូបភាព ពាក្យ និងសញ្ញា ដើម្បីប្រាស្រ័យទាក់ទងខ្លឹមសារជារូបភាពដែលមើលឃើញ និងងាយយល់។ ការរចនារូបភាពរួមមាន ការបង្កើតខិត្តប័ណ្ណ ប័ណ្ណប្រកាស និងរូបភាពសម្រាប់ពាណិជ្ជកម្មផ្សេង ក្នុងគោលបំណងបង្កើនការលក់ និងផ្សព្វផ្សាយការយល់ដឹងដល់អតិថិជន។ អ្នករចនារូបភាពដែលជំនាញត្រូវតែមានគំនិតច្នៃប្រឌិតខ្ពស់ អភិវឌ្ឍបំណិន និងសមត្ថភាពសិល្បៈផ្សេងៗ។ ជាធម្មតាយ៉ាងហោចណាស់ក៏ពួកគេត្រូវមានសញ្ញាបត្រពីសាលាបច្ចេកទេស ឬបរិញ្ញាបត្រក្នុងមុខជំនាញរចនាដើម្បីអាចធ្វើការនៅក្នុងផ្នែកនេះបាន។ អ្នករចនារូបភាពអនុវត្តជំនាញច្នៃប្រឌិតរបស់ពួកគេដោយប្រើកម្មវិធីកុំព្យូទ័រឯកទេសសម្រាប់គម្រោងរបស់ពួកគេ។ អ្នករចនារូបភាពអាចធ្វើការឱ្យក្រុមហ៊ុនរចនា ក្រុមហ៊ុនធំ ឬពួកគេអាចធ្វើការខ្លួនឯង។ នៅគ្រប់កម្រិតទាំងអស់ ពួកគេត្រូវមានបំណិនប្រាស្រ័យទាក់ទងល្អប្រសើរ និងត្រូវតែអាចធ្វើការដោយឯករាជក៏ដូចជាធ្វើការជាក្រុម។

# លំហាត់

## លំហាត់ ១

ធ្វើការបកស្រាយការយល់ឃើញរបស់អ្នកចំពោះរូបភាពជាក់ស្តែងមួយ បន្ទាប់មកអនុវត្តការយល់ឃើញនោះដោយការគូរជារូបភាពខ្សៀកនៅក្នុងក្រុមរបស់អ្នក។ អ្នកត្រូវធ្វើការងារនេះនៅលើក្រដាសជាជាងប្រើកុំព្យូទ័រ។ មើលសញ្ញាចរាចរទាំងនេះដែលអ្នកធ្លាប់បានឃើញនៅកម្ពុជា។

    

ក. នៅក្នុងក្រុមរបស់អ្នក សូមធ្វើការបកស្រាយ និងពន្យល់អត្ថន័យនៃរូបសញ្ញានីមួយៗ។ តើរូបសញ្ញាទាំងនេះចង់ពន្យល់ប្រាប់អ្នកអំពីខ្លឹមសារអ្វីដែរ?

ខ. នៅក្នុងក្រុមរបស់អ្នក សូមអនុវត្តការពន្យល់ជារូបភាពដោយបង្កើតរូបសញ្ញាចរាចរមួយ។ រូបសញ្ញានោះត្រូវធ្វើតាមអត្ថន័យ "ហាមស្ទូចត្រីនៅលើស្ពាន" ដោយមិនប្រើពាក្យពន្យល់ទេ។ សូមដាក់ស្នើរូបភាពនេះឱ្យគ្រូរបស់អ្នក។

## លំហាត់ ២

អ្នកបានសម្រេចថាគោលបំណងការងាររបស់អ្នកនឹងក្លាយជានាយករចនាច្នៃប្រឌិត។ អ្នកដឹងថា មុខតំណែងនេះត្រូវការបទពិសោធន៍ការងារច្រើនឆ្នាំ – ប្រហែលរហូតដល់ ១០ ឆ្នាំ ដើម្បីសម្រេចបានគោលដៅនេះ ហើយអ្នកត្រូវធ្វើការយ៉ាងលំបាកដើម្បីបំពេញគ្រប់តម្រូវការនេះដើម្បីសម្រេចគោលបំណងរបស់អ្នក។ នៅក្នុងក្រុមរបស់អ្នក ចូរពិភាក្សាសំណួរខាងក្រោម និងដាក់ចម្លើយរបស់អ្នកនៅក្នុងថតក្រុមរបស់អ្នក។

ក. ពិភាក្សានៅក្នុងក្រុមរបស់អ្នក តើការងារណាខ្លះដែលអ្នកនឹងត្រូវធ្វើតាមដើម្បីសម្រេចបានគោលដៅនេះ រួមមានការអប់រំ បទពិសោធន៍ និងបំណិនបច្ចេកទេស និងទំនាក់ទំនងដែលអ្នកត្រូវមានដើម្បីឈានដល់មុខតំណែងនាយកគ្រប់គ្រងការច្នៃប្រឌិតរចនា។

ខ. ពិភាក្សាពីបំណិនជាក់លាក់ដែលអ្នកក្រុមរបស់អ្នកគិតថាលំបាកក្នុងការទទួលបាន។ សូមពន្យល់។

គ. តើអ្នកគួរធ្វើអ្វីនៅក្នុងអំឡុងពេលធ្វើកិច្ចការងាររបស់អ្នកដើម្បីអភិវឌ្ឍបំណិនទាំងនេះដែលមានការលំបាកបំផុត?

## លំហាត់ ៣

អ្នកត្រូវបានប្រាប់ឱ្យបង្កើតស្លាកសញ្ញា សម្រាប់បិទនៅជញ្ជាំង ខាងក្រោយនៃបណ្ណាល័យសាលារបស់អ្នក។ រូបសញ្ញានឹងត្រូវធ្វើតាមខ្លឹមសារ "សូមរក្សាភាពស្ងៀមស្ងាត់" ដោយមិនប្រើពាក្យពន្យល់ជាច់ខាត។

ក. ចូរពិភាក្សាជាមួយសមាជិកក្រុមរបស់អ្នករកវិធីបង្ហាញជារូបភាពណាមួយដែលបញ្ជាក់ថា "សូមរក្សាភាពស្ងៀមស្ងាត់" ដោយមិនប្រើពាក្យពន្យល់។ គូរនៅលើក្រដាស អ្នកមិនត្រូវប្រើកុំព្យូទ័រដើម្បីរចនាគំនូរនេះផ្ញើជូនគ្រូរបស់អ្នកទេ។

ខ. គិតអំពីពណ៌ដែលអ្នកត្រូវប្រើ។ ហេតុអ្វីអ្នកជ្រើសរើសពណ៌ទាំងនោះ? សូមសរសេរចម្លើយរបស់អ្នក។

គ. ចូរពិភាក្សា ប្រសិនបើការបន្ថែមពាក្យអាចជួយអ្នកទស្សនាយល់ពីខ្លឹមសារដែលអ្នកចង់និយាយដែរឬទេ។

# សំណួរត្រិះរិះ

១. តើអ្វីជាការរចនារូបភាព?
២. តើអ្វីជាការងាររបស់អ្នករចនារូបភាព?
៣. តើកម្មវិធីកុំព្យូទ័រណាដែលអ្នករចនារូបភាពនិយមប្រើបំផុតសម្រាប់ការងាររចនា?
៤. តើការច្នៃប្រឌិតរចនាមានសារៈសំខាន់យ៉ាងណាចំពោះអ្នករចនារូបភាពដើម្បីទទួលបានជោគជ័យ?
៥. តើបំណិនទំនាក់ទំនង និងបច្ចេកទេសអ្វីខ្លះដែលត្រូវការចាំបាច់ដើម្បីក្លាយជាអ្នករចនារូបភាពដ៏ចំណាន?
៦. តើតួនាទីរបស់នាយកច្នៃប្រឌិតរចនាខុសពីអ្នករចនារូបភាពជាន់ខ្ពស់យ៉ាងដូចម្ដេចខ្លះ?
៧. តើអ្វីជាអ្នករចនារូបភាពក្រៅម៉ោងការងារ?

# ផ្នែក ខ - គោលគំនិតសំខាន់ៗក្នុងការរចនារូបភាព

## ៣. របៀបផ្តល់ខ្លឹមសារត្រឹមត្រូវ

ក្រុមហ៊ុនតែងតែជួលបុគ្គលិកផ្នែករចនារូបភាព ពីព្រោះពួកគេចង់បង្កើតការលក់ ឬផ្សព្វផ្សាយអំពីស្ថាប័នរបស់ពួកគេ។ គោលបំណងរបស់អ្នករចនាទាំងនេះគឺបង្កើតរូបភាពជាវិជ្ជមានតាមរយៈការរចនារបស់ពួកគេសម្រាប់ស្ថាប័ន ក៏ដូចជាផ្តល់ព័ត៌មានដល់អតិថិជនគោលដៅអំពីផលិតផលរបស់ក្រុមហ៊ុននោះ។ កិច្ចការដែលត្រូវធ្វើអាចរួមមានការបង្កើតរូបសញ្ញាក្រុមហ៊ុន នាមប័ណ្ណ ខិត្តប័ណ្ណផ្សព្វផ្សាយ ប័ណ្ណប្រកាស ការផ្សព្វផ្សាយពាណិជ្ជកម្មតាមកាសែត និងផលិតផលផ្សេងៗជាច្រើនទៀត។ វាសំខាន់ណាស់សម្រាប់ការរចនាដែលផ្តល់នូវខ្លឹមសារដែលគេចង់បានប្រកបដោយប្រសិទ្ធភាព ដើម្បីឱ្យអតិថិជនយល់ដឹងអំពីផលិតផលរបស់ក្រុមហ៊ុន និងភិនភាគបុគ្គលិកលក្ខណៈរបស់ពួកគេ។ ដើម្បីឱ្យមានប្រសិទ្ធភាព ខ្លឹមសារចាំបាច់ត្រូវតែច្បាស់លាស់ និងសាមញ្ញ។ នៅក្នុងមេរៀននេះ យើងនឹងស្វែងយល់អំពីសមាសធាតុដែលដើរតួនាទីយ៉ាងសំខាន់ដើម្បីប្រើប្រាស់ក្នុងការផ្តល់នូវខ្លឹមសារត្រឹមត្រូវ៖ ប្លង់រចនាដែលល្អប្រសើរ ភាពស៊ីគ្នា ពណ៌ និងការសាកល្បងផ្ទាល់ខ្លួន។

## ៣.១. ប្លង់ដែលបានរចនាយ៉ាងប្រសើរ

យើងត្រូវបានព័ទ្ធជុំវិញដោយការផ្សាយពាណិជ្ជកម្ម និងបដាដែលប្រើក្នុងបំណងទាក់ទាញចំណាប់អារម្មណ៍របស់យើង។ សូម្បីរូបសញ្ញាចរាចរនៅលើដងផ្លូវ និងប័ណ្ណប្រកាសនៅលើជញ្ជាំងត្រូវបានរចនាឡើងដើម្បីធ្វើឱ្យយើងចាប់អារម្មណ៍ភ្លាមៗ។ នៅក្នុងការរចនារូបភាព យើងត្រូវការប្លង់រចនាល្អប្រសើរដើម្បីប្រាប់ជាព័ត៌មានខ្លឹមសារដែលចង់បាន។




ប្លង់រូបភាព គឺជាកន្លែង ឬការរៀបចំធាតុដែលយើងអាចមើលឃើញនៅក្នុងការងារបង្ហាញជារូបភាព។

ប្លង់រូបភាពច្បាស់ទាក់ទាញចំណាប់អារម្មណ៍របស់យើងបានយ៉ាងងាយស្រួល ខណៈដែលការរចនាដែលពុំមានប្លង់ច្បាស់លាស់មិនធ្វើឱ្យចាប់អារម្មណ៍។ មូលហេតុចម្បងដែលរូបភាពមួយចំនួនមិនទាក់ទាញចំណាប់អារម្មណ៍ដោយសារតែប្លង់មិនស្អាត ឬអារម្មណ៍របស់យើងមិនផ្តោតលើខ្លឹមសារដែលចង់ផ្តល់។ ប្លង់ដែលមានប្រសិទ្ធភាពអាចនាំភ្នែកយើងទៅកន្លែងដែលអ្នករចនាចង់ប្រាប់ឱ្យដឹង។

មិនមែនធាតុ ឬផ្នែកទាំងអស់មានសារៈសំខាន់ដូចគ្នាចំពោះប្លង់នោះទេ ជាធម្មតាធាតុនីមួយៗ ធាតុខ្លះមានសារៈសំខាន់ជាងគេ។ អ្នករចនាចង់ឱ្យអ្នកមើលផ្តោតចំណាប់អារម្មណ៍លើធាតុ និងគំនិតសំខាន់នៅក្នុងប្លង់

ដែលជាផ្នែកសំខាន់ជាងគេនៃខ្លឹមសារ។ វាអាចធ្វើបានដោយរំលេច ឬធ្វើឱ្យទាក់ទាញនូវធាតុ ឬគំនិតទាំងអស់នោះ។

ការធ្វើឱ្យទាក់ទាញ ឬរំលេចមានន័យថាផ្ដល់សារៈសំខាន់ជាពិសេសចំពោះធាតុណាមួយ ដើម្បីធ្វើវាឱ្យលេចធ្លោ ឬទាក់ទាញចំណាប់អារម្មណ៍ចំពោះផ្នែកនោះ ដោយធ្វើវាឱ្យប្លែកពីធាតុផ្សេងៗនៅក្នុងប្លង់នោះ។ ការធ្វើឱ្យទាក់ទាញអាចត្រូវបានបង្កើតឡើងតាមរយៈបច្ចេកទេសជាច្រើន ដូចជាការធ្វើឱ្យធាតុច្បាស់ធំជាង ដោយប្រើពណ៌ច្បាស់កម្រិតខ្ពស់ ឬដោយការប្ដូររូបរាងជាម៉ូតផ្សេងៗ។

ប៉ុន្តែបើការធ្វើឱ្យច្បាស់ ឬរំលេចខ្លាំងពេក ប្លង់នោះនឹងពិបាកយល់ ហើយចំនួនគំនិតដែលចង់រំលេចច្រើនហួសហេតុពេកក្នុងប្លង់មួយអាចធ្វើឱ្យវាសំខាន់ដូចគ្នា ដែលមិនមានធាតុណាមួយរំលេចជាក់ច្បាស់សំខាន់ជាងគេទេ។ វាសំខាន់ត្រូវជ្រើសធាតុដែលត្រឹមត្រូវសម្រាប់រំលេចឱ្យច្បាស់ដើម្បីទាក់ទាញអ្នកមើល និងផ្ដល់ខ្លឹមសារបានយល់ច្បាស់ និងឆាប់រហ័ស។




រូបភាពនេះបង្ហាញប័ណ្ណប្រកាសពីរដែលប្រើមាតិកា និងធាតុដូចគ្នា ប៉ុន្តែរៀបចំតាមបែបផ្សេងគ្នា។ រូបភាពទី១ មើលទៅគ្មានការថ្លឹង និងរាយប៉ាយ វាជាប្លង់មួយមិនស្អាតដែលមិនធ្វើឱ្យចាប់អារម្មណ៍ និងពិបាកយល់។ ចំណែករូបភាពទី២ វិញមើលទៅមានការរៀបចំបានល្អ វាផ្ដល់នូវភាពសំខាន់ចំពោះធាតុនីមួយៗ (អ្នកគ្រូស្ថិតនៅខាងមុខ) និងធាតុផ្សេងៗទៀតត្រូវបានរៀបចំក្នុងទីតាំងសមរម្យ ដែលជំនួយដល់ការរចនាទាំងមូល។ លទ្ធផលគឺរូបភាពដែលទាក់ទាញចំណាប់អារម្មណ៍របស់អ្នក និងផ្ដល់នូវខ្លឹមសារដែលចង់បាន។

# ៣.២. សុខដុម

គោលគំនិតនៃសុខដុម គឺសំខាន់បំផុតទាំងសិល្បៈ តន្ត្រី និងរូបភាព។ នៅពេលយើងសប្បាយរីករាយជាមួយការស្ដាប់តន្ត្រី ពីព្រោះតន្ត្រីនោះធ្វើឱ្យយើងមានអារម្មណ៍ល្អ និងនាំឱ្យយើងមានការសប្បាយរីករាយ។ ប្រសិនបើយើងរីករាយនឹងបទចម្រៀងណាមួយ គឺដោយសារយើងចូលចិត្តឥទ្ធិពលនៃធាតុនីមួយៗរបស់វា ដូចជា សាច់ភ្លេង ទំនុកបទភ្លេង ទឹកដមសំឡេងរបស់អ្នកចម្រៀង សំឡេងឧបករណ៍ភ្លេង និងទំនុកនិពន្ធ។

ពាក្យសុខដុមនៅក្នុងការរចនារូបភាព គឺជាប្រសិទ្ធភាពនៃការធ្វើឱ្យពេញចិត្តតាមរយៈរូបភាពដែលមានការរួមផ្សំធាតុដែលទាក់ទងដើម្បីបង្កើតភាពស៊ីសង្វាក់គ្នា។ មានន័យថាធាតុរូបភាពត្រូវមានការថ្លឹងថ្លែងច្បាស់លាស់ និងត្រូវបានរៀបចំយ៉ាងប្រសើរដើម្បីបង្កើតអារម្មណ៍ដែលមានតុល្យភាពមួយ។

នៅពេលអ្នករចនារូបភាពបង្កើតការរចនាមួយសម្រាប់អតិថិជន អតិថិជនត្រូវតែមានអារម្មណ៍ថាផ្នែកទាំងអស់ត្រូវមានសុខដុម។ អ្នករចនាត្រូវចេះជ្រើសរើសពណ៌ច្បាស់លាស់ ទំហំអក្សរ និងចន្លោះទំនេរគ្រប់គ្រាន់ដើម្បីបង្កើតនូវប្លង់ដែលមានតុល្យភាពមួយ។ កត្តាដែលសំខាន់បំផុតនៅក្នុងប្លង់មានដូចជា៖ ពណ៌ ការតម្រៀប និងអត្ថបទ។

# ៤. ពណ៌

នៅពេលយើងបង្កើតប្លង់រូបភាពមួយ យើងអាចជ្រើសរើសពណ៌ដោយចៃដន្យណាមួយ ប៉ុន្តែប្រសិនបើយើងធ្វើដូច្នេះ លទ្ធផលនៃការលាយពណ៌អាចនឹងធ្វើឱ្យធុញទ្រាន់ ឬមិនសូវសម។ ម៉្យាងវិញទៀត ប្រសិនបើយើងចំណាយពេលជ្រើសគ្រោងពណ៌ដែលត្រឹមត្រូវ នោះប្លង់នឹងមានការទាក់ទាញ និងធ្វើឱ្យយើងរីករាយ។ បន្ទាប់មកយើងត្រូវមានសុខដុមផ្នែកពណ៌។ សុខដុមពណ៌ គឺជាពាក្យមួយដែលគេប្រើដើម្បីពិពណ៌នាអំពីការលាយពណ៌ដែលមានប្រសិទ្ធភាពធ្វើឱ្យរីករាយ និងការបង្ហាញរូបភាព។ សុខដុមពណ៌ធ្វើឱ្យអ្នកមើលទាក់ភ្នែក និងបង្កើតអារម្មណ៍ខាងក្នុងតាមលំដាប់ ថ្លឹងថ្លែងតាមរយៈការមើលរូបភាពនោះ។ នៅពេលអ្វីមួយមិនមានសុខដុមទេ វានឹងមិនធ្វើទាក់ទាញឱ្យមានការចាប់អារម្មណ៍រយៈពេលយូរទេ។ ពណ៌គឺជាផ្នែកមួយយ៉ាងសំខាន់នៅពេលយើងធ្វើការរចនាអ្វីមួយ។



# ៤.១. ប្រភេទពណ៌

យើងត្រូវបានព័ទ្ធជុំវិញដោយពណ៌គ្រប់កន្លែង។ ពណ៌ខ្លះអាចលាយបញ្ចូលគ្នាបានដើម្បីបង្កើតជាពណ៌ថ្មីផ្សេងមួយទៀត។ ការពិពណ៌នាខាងក្រោមអាចជួយឱ្យអ្នកស្វែងយល់បន្ថែមអំពីប្រភេទពណ៌នីមួយៗ៖

- **ពណ៌មេ៖** ក្រហម លឿង ខៀវ – ទាំងនេះជាពណ៌បីប្រភេទដែលមិនអាចលាយចូលគ្នា ឬបង្កើតថ្មីដោយលាយបញ្ចូលគ្នារវាងពណ៌ផ្សេង។ ពណ៌ផ្សេងៗទាំងអស់បានមកពីភាពលាំៗនៃពណ៌ទាំងបីនេះ។
- **ពណ៌បន្ទាប់បន្សំ៖** បៃតង ទឹកក្រូច ស្វាយ – ទាំងនេះជាពណ៌ដែលបង្កើតចេញពីការលាយពណ៌មេ។
- **ពណ៌លាយគ្នា៖** លឿង-ទឹកក្រូច ក្រហម-ទឹកក្រូច ក្រហម-ស្វាយ ខៀវ-ស្វាយ ខៀវ-បៃតង លឿង-បៃតង – ទាំងនេះជាពណ៌ដែលបង្កើតចេញពីការលាយរវាងពណ៌មេ និងពណ៌បន្ទាប់បន្សំ។ នេះជាហេតុដែលពណ៌នីមួយៗមានឈ្មោះពីរពាក្យ ដែលពាក្យដំបូងជាពណ៌មេ និងពាក្យបន្ទាប់ជាពណ៌បន្ទាប់បន្សំ។

ពណ៌ទាំងអស់នេះត្រូវបានដាក់ក្នុងរង្វង់កង់ៗ តាមលំដាប់នៃពណ៌ដែលត្រូវលាយ។ រង្វង់នេះឱ្យឈ្មោះថា កាំរង្វង់ស្ទង់ពណ៌។ វិចិត្រករ និងអ្នករចនានានាប្រើកាំរង្វង់ពណ៌នេះ (សូមមើលរូបភាព) ដើម្បីលាយ និងជ្រើសពណ៌។ សូមសិស្សានុសិស្សប្រើកាំរង្វង់ស្ទង់ពណ៌នេះដើម្បីស្វែងយល់អំពីសុខដុមនៃពណ៌។




កាំរង្វង់ស្ទង់ពណ៌

P ពណ៌មេ
S ពណ៌បន្ទាប់បន្សំ
T ពណ៌លាយគ្នា

# ៤.២. គ្រោងពណ៌ ប្រភេទ និងការប្រើប្រាស់

នៅក្នុងក្រុមតន្ត្រីរ៉ក់ ឧបករណ៍ភ្លេងត្រូវបានជ្រើសរើសដើម្បីបង្កើតជាសំឡេងភ្លេង។ នៅក្នុងប្លង់រូបភាពក៏មានលក្ខណៈដូចគ្នានេះដែរ ប៉ុន្តែសំដៅលើពណ៌។ ពណ៌ដែលប្រើនៅក្នុងការរចនានីមួយៗត្រូវបានជ្រើសរើសដើម្បីឱ្យត្រូវគ្នាល្អ។ គ្រោងពណ៌ គឺជាការជ្រើសពណ៌ដែលបានប្រើនៅក្នុងការរចនាដើម្បីបង្កើតជារចនាប័ទ្មផ្សេងៗ។

ជាទូទៅ គ្រោងពណ៌អាចដាក់ជាក្រុមពណ៌បីប្រភេទ គឺ៖ ក្តៅ ត្រជាក់ និងពណ៌ដែលស៊ីពណ៌គ្នា។ ពណ៌ក៏អាចធ្វើឱ្យយើងមានអារម្មណ៍សប្បាយរីករាយ ឬក្រៀមក្រំ វាអាចធ្វើឱ្យយើងខឹង ឬរំសាយ។ ក្នុងនាមជាអ្នករចនា វាសំខាន់ណាស់ត្រូវយល់អំពីចិត្តសាស្ត្រដែលទាក់ទងនឹងពណ៌អាចមានលើមនុស្ស ឬអតិថិជនគោលដៅរបស់អ្នក។ សូមសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់អំពីតើពណ៌មានផលប៉ះពាល់អ្វីខ្លះដល់អារម្មណ៍ផ្លូវចិត្ត និងអាកប្បកិរិយារបស់យើង។

ក្រហម ទឹកក្រូច និងលឿង ដែលនៅក្បែរគ្នានៅក្នុងកងរង្វង់ និងជាពណ៌ក្តៅទាំងអស់។ ពណ៌ក្តៅ អាចដាស់អារម្មណ៍របស់យើងឱ្យសប្បាយ ជឿជាក់ថាល្អ និងមានកម្លាំង។ ទោះជាយ៉ាងណាក៏ដោយពណ៌លឿង និងទឹកក្រូចអាចធ្វើឱ្យក្រហាយភ្នែកតិចតួច និងពណ៌ក្រហមអាចបង្កើនចិត្តចង់របស់មនុស្ស។




ពណ៌ត្រជាក់ រួមមានបៃតង ខៀវ និងស្វាយ។ ជាធម្មតា ពណ៌ត្រជាក់អាចធ្វើឱ្យស្ងប់ស្ងៀម និងធូរស្រាលចិត្ត ប៉ុន្តែក៏អាចប្រើបង្ហាញចេញពីភាពក្រៀមក្រំផងដែរ។ ពណ៌ស្វាយជានិច្ចកាលត្រូវបានប្រើដើម្បីជួយដល់ការច្នៃប្រឌិតផ្កាភ្លើង ដោយលាយគ្នារវាងពណ៌ខៀវ និងក្រហម។ ប្រសិនបើក្រុមហ៊ុនចង់បង្ហាញពីសុខភាពសម្ផស្ស ឬសុវត្ថិភាព ពួកគេនឹងប្រើពណ៌ទាំងនេះ។




ពណ៌កណ្តាល រួមមានខ្មៅ ប្រផេះ ស ពណ៌ដាំដែង និងត្នោត។ នៅក្នុងការរចនា ពណ៌ទាំងនេះត្រូវបានប្រើយ៉ាងប្រសើរសម្រាប់ផ្ទៃខាងក្រោយ។ នៅពេលប្រើពណ៌ភ្លឺ សូមប្រើពណ៌ខ្មៅ ប្រផេះ និងសធ្វើជាផ្ទៃខាងក្រោយ។ ប្រសិនបើអ្នកប្រើជាវាយនភាព នោះសូមប្រើពណ៌ដាំដែង និងត្នោតជាផ្ទៃខាងក្រោយ។



# ៤.៣. គ្រោងពណ៌បង្គុំ និងស្រដៀងគ្នា

ដូចដែលអ្នកអានថ្មីៗនេះ ជាទូទៅនៅក្នុងប្លង់វាមានសារៈសំខាន់ណាស់ដើម្បីទទួលបានសុខដុមដោយប្រើពណ៌ ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់អ្នកមើល។ គ្រោងពណ៌ដែលមានសុខដុមត្រូវប្រើពណ៌ដែលស្រដៀងគ្នា។ ជាធម្មតា ពណ៌ដែលស្រដៀងគ្នាមើលទៅមានការរីករាយរួម ពីព្រោះវាមានទំនាក់ទំនងជិតគ្នា។ យើងអាចរកពណ៌ដែលស្រដៀងគ្នាបានយ៉ាងងាយស្រួលដោយប្រើកាំរង្វង់ស្តង់ពណ៌ ព្រោះវាស្ថិតនៅជិតៗគ្នានៅលើរង្វង់កង់នោះ ដូចជាពណ៌ក្រហម-ទឹកក្រូច ឬខៀវ-បៃតង។



ទោះជាយ៉ាងណាក៏ដោយ វាមិនចាំបាច់ថា គ្រប់ពណ៌ត្រូវតែតម្រូវឱ្យមានសុខដុមនោះទេ។ ឧទាហរណ៍ នៅក្នុងការរចនាដែលមានអក្សរពណ៌ខ្មៅលើផ្ទៃខាងក្រោយពណ៌ស នោះពណ៌នឹងលែងជាសុខដុមហើយ ពួកគេមើលទៅផ្ទុយគ្នាស្រឡះ។ នៅលើកាំរង្វង់ស្តង់ពណ៌ ពណ៌ផ្ទុយ ឬបន្ថែមជាពណ៌ដែលដាច់ស្រឡះខុសពីគ្នា។ គ្រោងពណ៌បន្ថែម ឬបង្គុំបង្កើតនូវការមើលដែលរស់រវើក ជាពិសេសនៅប្រើពណ៌ផ្ទុកកម្រិតខ្ពស់។ ឧទាហរណ៍ ការប្រើពណ៌ក្រហម និងបៃតង ខៀវ និងទឹកក្រូច ឬលឿង និងស្វាយនៅក្នុងការងារដូចគ្នានឹងបង្កើតភាពផ្ទុយគ្នាខ្លាំង ហើយពណ៌ដែលផ្ទុយគ្នានោះនឹងបង្កើនកម្លាំងឱ្យគ្នាទៅវិញទៅមក។

# ៥. ការចូលចិត្តផ្ទាល់ខ្លួន

> *សោភ័ណភាពគឺជាផ្នែកនៃការសិក្សាពិសោធន៍ដែលទាក់ទងនឹងធម្មជាតិនៃសិល្បៈ ភាពស្រស់ស្អាត និងការចូលចិត្ត។*

វត្ថុដែលច្បាស់មានភាពស្រស់ស្អាតចំពោះមនុស្សម្នាក់ ប៉ុន្តែមិនស្អាតសម្រាប់អ្នកផ្សេង។ ឧទាហរណ៍ ស្រមៃថាយើងទៅហាងកាត់សក់ជាមួយមិត្តភ័ក្តិម្នាក់។ នៅពេលដែលកាត់សក់រួច អ្នកសម្លឹងមើលខ្លួនឯងនៅក្នុងកញ្ចក់ រួចហើយអ្នកមានការខកចិត្តដោយសារអ្នកមិនពេញចិត្តនឹងម៉ូតសក់ថ្មីនេះ។ នៅពេលមិត្តភ័ក្តិរបស់អ្នកប្រាប់អ្នកថា សក់ដែលអ្នកកាត់ស័ក្តិសមណាស់ និងមានភាពទាក់ទាញ អ្នកទទួលស្គាល់ថាយើងទាំងពីរនាក់មានការចូលចិត្តផ្ទាល់ខ្លួនខុសគ្នា។

ការចូលចិត្តផ្ទាល់ខ្លួន ជាការបញ្ចេញឱ្យឃើញនូវការជ្រើសរើស និងចំណង់ចំណូលចិត្តប្លែកៗគ្នារបស់បុគ្គល។ អ្វីដែលយើងចាត់ទុកថាជាសោភ័ណដែលធ្វើឱ្យមានភាពរីករាយ គឺផ្អែកលើប្រវត្តិរូបជាវប្បធម៌ ជាតិសាសន៍ សាសនា និងបទពិសោធន៍ជីវិត និងវាជាទស្សនៈយល់ឃើញផ្ទាល់ខ្លួនរបស់យើង។ អាហារ ភេសជ្ជៈ និងសម្លៀកបំពាក់ដែលយើងចូលចិត្ត ឧទាហរណ៍ ឆ្លុះបញ្ចាំងអំពីចំណូលចិត្តផ្ទាល់ខ្លួនរបស់យើង។ អ្នកផ្សេងទៀតអាចមិនចូលចិត្តដូចគ្នា។

អ្នករចនារូបភាពតែងតែមានការចូលចិត្តផ្ទាល់ខ្លួនរបស់ពួកគេនៅពេលពួកគេធ្វើការលើគម្រោងណាមួយ ហើយពួកគេមិនចូលចិត្តដូចគ្នានឹងអ្វីដែលអតិថិជនចង់បាន។ អ្នករចនាត្រូវធ្វើតាមមតិយោបល់របស់អតិថិជន ដែលមានចំណង់ចំណូលចិត្តផ្ទាល់ខ្លួនរបស់ពួកគេដែរ។ ការរចនាចាំបាច់ត្រូវបំពេញតាមតម្រូវការរបស់អតិថិជន និងមានអ្វីគ្រប់យ៉ាងដែលពួកគេចង់បាន។ ពេលខ្លះអ្នករចនានឹងត្រូវចរចាជាមួយអតិថិជនដើម្បីបញ្ចុះបញ្ចូលពួកគេឱ្យជឿជាក់លើអ្វីដែលពួកគេរចនា។ អ្នករចនារូបភាពអាចមានអារម្មណ៍មិនសូវល្អ ប្រសិនបើរូបភាពរចនារបស់ខ្លួនត្រូវបានបដិសេធ ទាមទារបំណិនគ្រប់គ្រងជម្លោះ ដើម្បីគ្រប់គ្រង និងធ្វើការសម្រេចចិត្តចុងក្រោយ។ ការរចនាដែលបានយល់ព្រមដោយអតិថិជននឹងមានបញ្ចូលទាំងការច្នៃប្រឌិតរបស់អ្នករចនា និងចំណង់ចំណូលចិត្តផ្ទាល់ខ្លួនរបស់អតិថិជន។

## មេរៀនសង្ខេប

ក្រុមហ៊ុនជួលអ្នករចនារូបភាពដើម្បីពង្រីកមុខជំនួញរបស់ពួកគេ ឬបង្កើនការយល់ដឹងជាសាធារណៈ។ នៅក្នុងការរចនារូបភាព វាសំខាន់ត្រូវផ្ដល់ខ្លឹមសារដែលគេចង់បាន ដើម្បីជួយឱ្យមុខជំនួញរីកដុះដាល។ ប្លង់ សុខដុម ពណ៌ ភាពស៊ីគ្នា និងចំណង់ចំណូលចិត្តបុគ្គលនីមួយៗនៅក្នុងការរចនាដែលពេញលេញ។ អ្នករចនារូបភាពនឹងប្រើចំណេះដឹង បំណិន និងការចូលចិត្តរបស់ពួកគេដើម្បីបង្កើតការរចនាដែលបំពេញតាមអ្វីដែលអតិថិជនចង់បាន និងត្រូវការ។

## លំហាត់

### លំហាត់ ៤

សូមមើលគំរូនៃគំនូរពីរខាងក្រោម។





ធ្វើការជាក្រុមសម្រេចចិត្តថាតើគំនូរមួយណាមានសោភ័ណភាពទាក់ទាញជាងចំពោះអ្នក និងហេតុអ្វី។ សូមសរសេរការពន្យល់របស់អ្នក និងប្រកាសវានៅក្នុងថតក្រុមរបស់អ្នក។

## លំហាត់ ៥

សូមមើលនៅ ជុំវិញអ្នក ពិនិត្យពិច័យសម្លៀកបំពាក់របស់អ្នក និងមិត្តភ័ក្តិរបស់អ្នក និងវត្ថុទាំងអស់នៅជុំវិញអ្នកដូចជា តុ កៅអី កុំព្យូទ័រ ជញ្ជាំង។ល។

សូមធ្វើការជាក្រុម សម្គាល់ពណ៌ទាំងអស់ដែលអ្នកឃើញ សរសេរពណ៌ទាំងអស់ និងកំណត់ពួកគេតាមប្រភេទ និងលក្ខណៈរបស់វា។ សូមប្រកាសលទ្ធផលរបស់អ្នកនៅក្នុងថតក្រុមរបស់អ្នក។

## សំណួរត្រិះរិះ

១. តើប្លង់ជាអ្វី?

២. តើសុខដុមជាអ្វី? សុខដុមពណ៌ជាអ្វី?

៣. តើអ្វីជាកាំរង្វង់ស្ទង់ពណ៌?

៤. តើអ្វីជាពណ៌មេទាំងបី?

៥. ចូរប្រាប់ឈ្មោះគំរូពណ៌ក្ដៅឱ្យបានពីរ។

៦. ចូរប្រាប់ឈ្មោះគំរូពណ៌ត្រជាក់ឱ្យបានពីរ។

៧. តើការចូលចិត្តផ្ទាល់ខ្លួនដើរតួនាទីយ៉ាងដូចម្ដេចនៅក្នុងការរចនា?

# មេរៀនទី ៦

# ការរចនាវេបសាយ

## នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពី៖

១. យល់ដឹងអំពីការរចនាវេបសាយ និងគោលបំណងរបស់វា
២. យល់ដឹងអំពីការងារនៅក្នុងការរចនា និងថែទាំវេបសាយ និងបរិស្ថានការងារ
៣. កំណត់ និងយល់ដឹងអំពីបំណិនបច្ចេកទេស ទំនាក់ទំនង អប់រំ និងលក្ខណសម្បត្តិផ្សេងៗដែលត្រូវការដើម្បីក្លាយជាអ្នកគ្រប់គ្រងវេបសាយ អ្នកបង្កើតវេបសាយ អ្នករចនាវេបសាយ ឬអ្នកគ្រប់គ្រងវេបសាយដោយប្រសិទ្ធភាព។

# ផ្នែក ក - ការងារក្នុងការរចនា និងថែទាំវេបសាយ

## ១. ការណែនាំអំពីការរចនា និងថែទាំវេបសាយ

ដានីបានណែនាំចរណៃឱ្យបន្តស្វែងរកការងារបច្ចេកវិទ្យាព័ត៌មានផ្សេងៗដោយស្វែងយល់អំពីការរចនាវេបសាយ។ ដានីបានហៅលីម ដែលជាមិត្តភ័ក្តិរបស់នាងកាលនៅសាកលវិទ្យាល័យ និងធ្វើការណាត់ជួបគ្នាជាមួយចរណៃ។ លីមធ្វើការនៅអង្គការក្រៅរដ្ឋាភិបាលមានឈ្មោះថា ABLE ហើយគាត់ទទួលបន្ទុកការរចនាវេបសាយរបស់ស្ថាប័នគាត់ និងធ្វើបច្ចុប្បន្នភាពវាជាប្រចាំ។

ដើម្បីរៀបចំសម្រាប់ការសម្ភាសន៍បានល្អ ចរណៃបានប្រើកុំព្យូទ័រនៅផ្ទះរបស់នាងដើម្បីរកមើលវេបសាយអង្គការរបស់គាត់។ នៅពេលនាងបានជួបលីម ចរណៃនិយាយថា "នៅពេលខ្ញុំចូលមើលវេបសាយរបស់លោក ខ្ញុំឃើញថាវាងាយស្រួលមើល និងរុករកព័ត៌មានណាស់។ ខ្ញុំតែងតែអាចរកតំណភ្ជាប់ដែលអាចនាំខ្ញុំទៅកាន់ព័ត៌មានដែលខ្ញុំចង់បាន។ វាមានភាពច្បាស់លាស់ និងខ្ញុំអាចទៅដល់ផ្នែកនៃព័ត៌មានណាមួយបានលឿន និងងាយស្រួល។"

> *ការចូលប្រើវេបសាយ គឺ វាដូចជាយើងទៅហាងទិញទំនិញអញ្ចឹង និងស្វែងរកទំនិញបានងាយស្រួល ជៀសវាងដើររកគ្រប់កន្លែង។*

លីមញញឹម និងនិយាយថា "អរគុណណាស់ចរណៃ។ ខ្ញុំចង់ឮពាក្យដូចនេះ ព្រោះថាគោលបំណងរបស់ខ្ញុំមួយ គឺធ្វើការរៀបចំម៉ឺនុយឱ្យមានរបៀប និងសាមញ្ញសម្រាប់អ្នកប្រើ។ វាដូចជាយើងទៅហាងទិញទំនិញអញ្ចឹង និងស្វែងរកទំនិញបានងាយស្រួល ជៀសវាងដើររកគ្រប់កន្លែង។ ចរណៃសើច ហើយឆ្លើយតបវិញថា "អូរគួរឱ្យចង់សើចដែរ! សប្តាហ៍មុនខ្ញុំបានទៅទិញទំនិញនៅហាង Atom និងរកមិនឃើញរបស់ក្មេងលេងដែលខ្ញុំចង់ទិញឱ្យក្មួយរបស់ខ្ញុំសោះ។ ខ្ញុំបានដើរចុះឡើង និងចាំបាច់ត្រូវសួរមនុស្សជាច្រើនដើម្បីប្រាប់ទីតាំង។ ខ្ញុំខាតមួយព្រឹកគ្រាន់តែរកកន្លែងទិញរបស់នោះ ហើយរកបានរបស់ក្មេងលេងដែលថ្លៃណាស់។"

"បាទ! ខ្ញុំមើលឃើញថាកញ្ញាយល់ពីតម្រូវការក្នុងការរុករកដែលងាយស្រួលហើយ។ យើងគិតថាអ្វីដែលងាយស្រួលនោះ គឺការធ្វើឱ្យប្រាកដថាអ្នកមើលងាយស្រួលចូលប្រើវេបសាយ និងរុករកព័ត៌មាន។ នោះត្រូវទាមទារមានព័ត៌មានដែលមានតម្លៃ និងការធ្វើវេបសាយឱ្យចាប់អារម្មណ៍ ដែលមានប្រយោជន៍ទាក់ទាញអ្នកទស្សនា និងធ្វើឱ្យពួកគេត្រឡប់មកមើលវេបសាយម្តងទៀត។"

ចរណៃនិយាយថា "ខ្ញុំបង្កើតបញ្ជីសំណួរខណៈដែលខ្ញុំបានកំពុងមើលវេបសាយ។ សំណួរដំបូងរបស់ខ្ញុំគឺថាតើមនុស្សអាចស្វែងយល់អំពី ABLE និងតើពួកគេអាចរកវេបសាយរបស់អ្នកបានយ៉ាងដូចម្តេច?

"អ្នកកំពុងសួរសំណួរដ៏សំខាន់មួយ។ មនុស្សម្នាដឹងអំពីយើងតាមរយៈទាំងជីវិតពិត និងតាមរយៈអ៊ីនធឺណិត។ ABLE មានតាំងពីឆ្នាំ ១៩៩៨ និងបានកសាងស្នាដៃយ៉ាងប្រសើរដោយការផ្តល់សេវាកម្មអប់រំ សុខភាព និងសង្គមដល់ប្រជាពលរដ្ឋដែលមានតម្រូវការសង្គម។ យើងមានសំណាងដោយឈ្មោះរបស់យើងត្រូវបានស្គាល់ ខណៈដែលបណ្តាញបានក្លាយជាមធ្យោបាយសម្រាប់ស្ថាប័នក្នុងការផ្តល់ព័ត៌មានអំពីអង្គភាពខ្លួនឯង។ ជាផ្នែកមួយនៃការងាររបស់ខ្ញុំ គឺដើម្បីប្រាកដថាវាមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋរកមើលព័ត៌មានអំពីស្ថាប័ន ដូចនៅកម្ពុជាយើងអាចស្វែងរក ABLE បានយ៉ាងលឿន

នៅលើអ៊ីនធឺណិត។ វាពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ប្រជាពលរដ្ឋកម្ពុជា និងអ្នកស្ម័គ្រចិត្តអន្តរជាតិដែលចង់ធ្វើការជាមួយយើងមួយ ឬពីរខែ។"

"តើ ABLE អាចរកអ្នកស្ម័គ្រចិត្តបានយ៉ាងដូចម្ដេច?" ចរណៃសួរ។

"ទាំងអង្គការសហប្រជាជាតិ និងកាកបាទក្រហមបានណែនាំអ្នកស្ម័គ្រចិត្តទាំងនេះឱ្យមើលវេបសាយរបស់យើង ហើយអ្នកស្វែងរកការងារអន្តរជាតិដែលរកមើលឱកាសការងារស្ម័គ្រចិត្តនៅកម្ពុជានឹងអាចរកយើងបានងាយស្រួល ដោយសារយើងធ្វើឱ្យច្បាស់ថាពាក្យ "អ្នកស្ម័គ្រចិត្ត", "ជនពិការ", និង "កម្ពុជា" លេចធ្លោច្បាស់នៅលើវេបសាយរបស់យើង ដូច្នេះការស្វែងរកតាម Google នឹងរកបានលឿនទៅវេបសាយរបស់ ABLE ។ អនុញ្ញាតឱ្យខ្ញុំបង្ហាញថាតើអ្នកស្ម័គ្រចិត្តអាចស្វែងរកព័ត៌មានបានយ៉ាងដូចម្ដេច។"

ចរណៃអង្គុយចុះ ហើយមើលទៅកាន់អេក្រង់កុំព្យូទ័រដ៏ធំនោះ។ លីមបានណែនាំចរណៃឱ្យចាប់ផ្ដើមនៅត្រង់ "ទំព័រដើម" ហើយបន្ទាប់មករកមើលពាក្យ "អ្នកស្ម័គ្រចិត្ត" នៅលើវេបសាយ ABLE។ នាងឃើញម៉ឺនុយធ្លាក់ចុះជាមួយប្រធានបទដូចជា ព័ត៌មានសម្រាប់អ្នកស្ម័គ្រចិត្ត, ដាក់ពាក្យថ្ងៃនេះ និងចំណុចចាប់អារម្មណ៍របស់អ្នកស្ម័គ្រចិត្ត។ លីមនិយាយថា "ខ្ញុំចង់ឱ្យឯងចំណាយពេលបន្តិចមើលត្រង់ ចំណុចចាប់អារម្មណ៍របស់អ្នកស្ម័គ្រចិត្ត ហើយបន្ទាប់មក ខ្ញុំសរសេរសកម្មភាពដោយការដឹងរបស់អ្នក។" លីមទុកឱ្យចរណៃនៅម្នាក់ឯងប្រហែល ៥ នាទីដើម្បីអានបទពិសោធន៍របស់អ្នកស្ម័គ្រចិត្តមុនៗ និងមើលវីដេអូអំពីភាពជាអ្នកស្ម័គ្រចិត្តនៅ August Festival School ។

នៅពេលចរណៃបញ្ចប់ នាងនិយាយទៅលីមថា "វាជាវីដេអូដ៏អស្ចារ្យ។ ខ្ញុំចង់ធ្វើជាអ្នកស្ម័គ្រចិត្តនៅ Festival School ឆ្នាំនេះ! មើលទៅដូចជាម្នាក់ៗសប្បាយរីករាយដល់ហើយ!"

លីមញញឹម និងឆ្លើយតបថា "នេះជាអ្វីដែលយើងចង់ផ្ដល់ឱ្យអ្នកស្ម័គ្រចិត្តដែលត្រៀមសម្រាប់ថ្ងៃខាងមុខបែបនេះ។ យើងសង្ឃឹមថាវីដេអូនឹងធ្វើឱ្យយុវជនរំភើបរីករាយយល់ថាវាសប្បាយយ៉ាងណា ដោយសារយើងមាន August Festival School នៅប្រាំមួយកន្លែងផ្សេងៗ ដែលអាចទទួលបានសិស្សប្រហែល ៧០០ នាក់ជាមួយតម្រូវការជាពិសេសរបស់ពួកគេ (កាយ ឬចិត្តវិកល) ហើយយើងត្រូវការអ្នកស្ម័គ្រចិត្តច្រើនបំផុត ១៥០ នាក់ដើម្បីជួយដល់បុគ្គលិកដ៏តិចតួចរបស់យើង។"






គេហទំព័រវេបសាយរបស់ ABLE

បន្ទាប់ចរណៃសួរលីមថា ហេតុអ្វីគាត់ពាក់ព័ន្ធនឹងការរចនារូបភាពនេះ។ លីមនិយាយថា "ដូច ដានីអញ្ចឹង ខ្ញុំរៀនមុខវិជ្ជាសំខាន់ក្នុងផ្នែករចនារូបភាពនៅសាកលវិទ្យាល័យ។ ខ្ញុំសម្រេចថាខ្ញុំចង់ធ្វើការឱ្យ ABLE ដោយសារខ្ញុំជឿជាក់លើអ្វីដែលពួកគាត់ធ្វើ។ ABLE បានចំណាយសម្រាប់កៅអីជនពិការរបស់ខ្ញុំ និងខ្ញុំបានចូលរួមកម្មវិធី August Festival School លើកដំបូងរបស់ពួកគេ។ ខ្ញុំតែងតែចូលចិត្តបង្កើតគម្រោងវីដេអូ និងសំឡេង ហើយខ្ញុំបានបង្កើតវេបសាយខ្លះៗឱ្យមិត្តភ័ក្តិរបស់ខ្ញុំ។ នៅពេល ABLE សួរថាតើខ្ញុំមានចំណាប់អារម្មណ៍ក្នុងការគ្រប់គ្រងវេបសាយរបស់ពួកគេទេ ខ្ញុំសម្រេចជ្រើសយកឱកាសនោះ។ អំឡុងពេលបីឆ្នាំចុងក្រោយ ខ្ញុំបានបង្កើនចំណេះដឹង និងជំនាញរបស់អ្នកដោយចូលរួមវគ្គសិក្សាអំពីការរចនា និងអភិវឌ្ឍវេបសាយ គ្រប់គ្រងមូលដ្ឋានទិន្នន័យ និងសរសេរកម្មវិធី។ នៅពេលទំនេរ ខ្ញុំបានបង្កើតកំណត់ហេតុបណ្ដាញសម្រាប់អ្នកអភិវឌ្ឍវេបសាយ ហើយយើងបានចែករំលែកគំនិត និងព័ត៌មានគ្នាទៅវិញទៅមក។ ឥឡូវខ្ញុំថែទាំកំណត់ហេតុបណ្ដាញនោះ និងអ្នកសរសេរកំណត់ហេតុបណ្ដាញមួយចំនួនបានក្លាយជាមិត្តភ័ក្តិរបស់ខ្ញុំ។ ខ្ញុំមានឱកាសបានជួបជាមួយពួកគេផ្ទាល់ ប៉ុន្តែអ្នកផ្សេងទៀតដែលនៅកន្លែងផ្សេងឆ្ងាយពីគ្នាលើពិភពលោកអាចគ្រាន់តែជាមិត្តភ័ក្តិ "និមិត្ត"។

"ហើយ ខ្ញុំក៏ចង់ប្រាប់ដែរថាស្ថាប័នជាច្រើន ការរចនាបណ្ដាញត្រូវបានធ្វើឡើងដោយមនុស្សដែលបានរៀនផ្នែករចនា ខណៈដែលការអភិវឌ្ឍបណ្ដាញត្រូវបានធ្វើឡើងដោយអ្នកសរសេរកម្មវិធី។

ABLE មានថវិកា និងបុគ្គលិកតិច ហើយខ្ញុំជាអ្នករចនាផង និងជាអ្នកអភិវឌ្ឍផង។ ភ្នាក់ងារបានផ្ញើវគ្គបណ្តុះបណ្តាល និងកម្មវិធីសិក្សាផ្នែកអភិវឌ្ឍបណ្តាញឱ្យខ្ញុំ ប៉ុន្តែក្នុងចិត្តខ្ញុំចូលចិត្តធ្វើជាអ្នករចនាច្រើនជាង។ យ៉ាងណាក៏ដោយខ្ញុំអាចអភិវឌ្ឍបានច្រើននូវអ្វីដែលត្រូវការចាំបាច់នៅ ABLE ។ បើខ្ញុំត្រូវការជំនួយបន្ថែម យើងមានអ្នកអភិវឌ្ឍធ្វើការក្រៅម៉ោងដែលនឹងធ្វើការអំពីគម្រោងជាក់លាក់អាចសួរគាត់បាន។"

*ក្នុងករណីជាច្រើន ការរចនាវេបត្រូវបានធ្វើឡើងដោយអ្នកដែលបានរៀនផ្នែកការរចនា ចំណែកឯការអភិវឌ្ឍវេបត្រូវបានបង្កើតឡើងដោយអ្នកសរសេរកម្មវិធី។ ទោះជាយ៉ាងណាវាងាយក្នុងការស្វែងរកអ្នកដែលបានរៀនក្នុងផ្នែក ទាំងពីរនេះ។*

ចរណៃនិយាយ "ល្អណាស់ដែលបានដឹងរឿងនេះ។ ខ្ញុំគិតថាលោកពិតជាចូលចិត្តការងាររបស់លោកមែន។"

ចរណៃអរគុណលីមដែលបានពន្យល់អំពីការងាររបស់គាត់ប្រាប់នាង និងបាននិយាយចុងក្រោយថា "ខ្ញុំពិតជាចាប់អារម្មណ៍នឹងការងារជាអ្នកស្ម័គ្រចិត្តនៅ August Festival School ខ្លាំងណាស់។ ខ្ញុំមានផែនការបញ្ចប់ការបំពេញបែបបទដាក់ពាក្យតាមអ៊ីនធឺណិតនៅផ្ទះយប់នេះ។"

"ពិតជាប្រសើរណាស់! ចរណៃ។ ខ្ញុំច្បាស់ថាអ្នកចូលរួមកម្មវិធីរបស់យើងនេះ នឹងរីករាយចែករំលែកសកម្មភាពរបស់ពួកគេជាមួយនាង ហើយនាងនឹងរៀនអ្វីៗជាច្រើនពីការងារនេះផងដែរ។"

វេបសាយគឺជាកន្លែងមួយនៅពាសពេញពិភពលោកដែលមានបណ្តុំនៃទំព័របណ្តាញដែលក្រុមហ៊ុន ឬបុគ្គលប្រើបង្ហាញពីជំនួញ ចំណាប់អារម្មណ៍ ឬគំនិតរបស់ពួកគេ។ ទំព័របណ្តាញគឺជាឯកសារនីមួយៗដែលអាចរួមមានរូបភាព, អត្ថបទ ឬមេឌាជាដើម។ វេបសាយនីមួយៗមានចំណុចចូលមេមួយដែលអាចចូលទៅកាន់បណ្តាញទំព័រព័ត៌មានផ្សេងៗទៀត។ ចំណុចចូលនេះជាធម្មតាគេហៅថាគេហទំព័រ ហើយយើងអាចចូលទៅកាន់វាបានដោយវាយឈ្មោះដែននោះ (អាសយដ្ឋានវេបសាយ) របស់ស្ថាប័ននោះ។ វេបសាយអាចមានតែមួយទំព័រ ឬវាអាចមានរាប់រយទំព័រដែលផ្ទុកព័ត៌មានផ្សេងៗគ្នា។

ការរចនាវេបសាយមានការអភិវឌ្ឍ និងរីកចម្រើននៅក្នុងវិស័យនេះ។ ចំនួនវេបសាយសរុបបានកើនឡើងពី ៥០០ វេបសាយក្នុងឆ្នាំ ១៩៩៣ ដល់ជាងមួយលានវេបសាយក្នុងឆ្នាំ ២០១៥។ មានវេបសាយថ្មីត្រូវបានដាក់ឱ្យប្រើប្រាស់ជារៀងរាល់ថ្ងៃ វាបង្កើតឱកាសជាច្រើនសម្រាប់មនុស្សអាចក្លាយជាអ្នករចនាវេបសាយអាជីព។



# ១.១. ហេតុអ្វីក្រុមហ៊ុនត្រូវការវេបសាយ

សព្វថ្ងៃ វេបសាយគឺជាកន្លែងដំបូងដែលមនុស្សអាចចូលមើលព័ត៌មានរបស់ក្រុមហ៊ុន ស្ថាប័ន ឬផលិតផល។ ព័ត៌មាន គឺងាយស្រួលចូលមើល អាចទុកចិត្តបាន និងមានបច្ចុប្បន្នភាព។ ក្រុមហ៊ុន និងស្ថាប័នជាច្រើន វេបសាយរបស់ពួកគេបានក្លាយជាមធ្យោបាយដ៏សំខាន់បំផុតដើម្បីឆ្លុះបញ្ចាំងរូបភាពរបស់ពួកគេ និងកសាងកិត្តិយស។ វេបសាយរបស់ពួកគេមិនត្រឹមតែប្រើសម្រាប់ផ្តល់ព័ត៌មានអំពីផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុនប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងអាចអញ្ជើញឱ្យមានការសាកសួរ និងផ្តល់លទ្ធភាពអាចទិញទំនិញនៅលើអ៊ីនធឺណិតបានផងដែរ។

*ក្រុមហ៊ុនខ្លះលែងមានហាងផ្ទាល់ទៀតហើយ និងពួកគេប្រើវេបសាយរបស់ពួកគេដើម្បីទំនាក់ទំនងជាមួយអតិថិជន និងលក់ផលិតផល ឬសេវាកម្មរបស់ខ្លួន។*

# ១.២. លក្ខណៈនៃវេបសាយដែលមានប្រសិទ្ធភាព

រាល់គោលគំនិតនៃការរចនារូបភាពដែលអ្នកបានរៀនកាលនៅមេរៀនទី ៥ និង ១០ អាចអនុវត្តសម្រាប់បង្កើតសម្ភារៈបោះពុម្ពផ្សាយ ឬរូបភាពដែលបង្ហាញនៅលើម៉ូនីទ័រកុំព្យូទ័រ។ ក្នុងករណីការរចនាវេបសាយ អ្នកមើលនឹងឃើញរូបភាពក្រាហ្វិកតែនៅលើម៉ូនីទ័រកុំព្យូទ័រ ឬនៅលើអេក្រង់ទូរសព្ទប៉ុណ្ណោះ។ វាជាការងាររបស់អ្នករចនាវេបសាយដើម្បីយល់ដឹង និងផ្តល់ខ្លឹមសារដែលក្រុមហ៊ុនមានបំណងបង្ហាញតាមរយៈវេបសាយរបស់ខ្លួន។ អ្នករចនានឹងផ្តល់ខ្លឹមសារនេះតាមរយៈរូបភាពដែលមើលឃើញ ផ្តល់ជូនព័ត៌មានដល់អ្នកមើលតាមរយៈពាក្យសរសេរ ឬរូបភាព។ ពេលខ្លះអូឌីយ៉ូ (សំឡេង ឬតន្ត្រី) និងវីដេអូត្រូវបានបន្ថែម និងត្រូវបានប្រើយ៉ាងញឹកញាប់នៅពេលបច្ចុប្បន្ន ខណៈដែលអ៊ីនធឺណិតអាចប្រើបានយ៉ាងលឿន ជួយផ្តល់ខ្លឹមសារព័ត៌មានបានប្រសើរតាមរយៈវេបសាយ។

*វេបសាយត្រូវបង្ហាញឱ្យមានភាពងាយស្រួលយល់ និងត្រូវតែកសាងទំនុកទុកចិត្តនិងភាពច្បាស់លាស់។*

នៅពេលផ្តល់ព័ត៌មានតាមរយៈវេបសាយ យើងអាចធ្វើដូចនេះបានតាមរយៈរូបភាព ឬអត្ថបទជាលាយលក្ខណ៍អក្សរ យើងមិនអាចប្រើឧបករណ៍ជំនួយណាមួយដែលយើងប្រើនៅក្នុងការប្រាស្រ័យទាក់ទងវាចា៖ ភាសាកាយវិការ, ការសម្តែងទឹកមុខ, ចលនាដងខ្លួន, កាយវិការ ឬខ្សែភ្នែកទាក់ទាញ។ ដូច្នេះ អ្នករចនាវេបសាយត្រូវតែមានភាពច្បាស់លាស់ក្នុងការជ្រើសរើសពាក្យពេចន៍ និងរូបភាពដោយប្រុងប្រយ័ត្ន។ វេបសាយត្រូវមានការបង្ហាញព័ត៌មានច្បាស់លាស់ ងាយស្រួលយល់ និងត្រូវតែកសាងទំនុកទុកចិត្ត និងមានភាពប្រាកដប្រជា។

វេបសាយដែលរចនាមិនបានល្អនឹងបង្កឱ្យមានភាពតានតឹង បាត់បង់ទំនុកទុកចិត្ត និងភាន់ច្រឡំ ដែលនឹងបង្កើតរូបភាពអវិជ្ជមានចំពោះស្ថាប័ន បណ្តាលឱ្យអ្នកមើលប្តូរទៅមើលវេបសាយផ្សេងជំនួសវិញ។




ឧទាហរណ៍ វេបសាយដែលរចនាមិនល្អពិបាកមើល

បច្ចុប្បន្ន ក្រុមហ៊ុន និងស្ថាប័នបង្ហាញរូបភាពរបស់ពួកគេ និងកសាងកិត្តិយសដ៏ទូលំទូលាយតាមរយៈវេបសាយរបស់ពួកគេ។ វេបសាយផ្តល់នូវព័ត៌មានអំពីផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុន ហើយក៏អាចផ្តល់លទ្ធភាពធ្វើការទិញទំនិញបានផងដែរនៅលើអ៊ីនធឺណិត។ ពាណិជ្ជកម្មតាមអេឡិចត្រូនិក គឺជាពាក្យដែលគេប្រើសំដៅលើប្រភេទនៃជំនួញណាមួយដែលអនុញ្ញាតឱ្យអតិថិជនទិញទំនិញ និងសេវាកម្មតាមអ៊ីនធឺណិត។ នៅលើវេបសាយពាណិជ្ជកម្មតាមអេឡិចត្រូនិក ជំនួញដូចជាគ្រឹះស្ថានជំនួញលក់រាយ និងធនាគារប្រើវេបសាយដើម្បីកសាងទំនុកទុកចិត្តជាមួយអតិថិជន និងបង្កើនការលក់ និងចំណូលរបស់ពួកគេ។ ពួកគេអាចធ្វើដូច្នេះបានដោយបង្កើតនូវវេបសាយដែលគួរឱ្យទុកចិត្ត មានកេរ្តិ៍ឈ្មោះ និងសុវត្ថិភាពខ្ពស់។

កេរ្តិ៍ឈ្មោះចង់សំដៅលើការធានាចំពោះអ្នកទស្សនាវេបសាយដែលធ្វើឱ្យមានយីហោល្បីរន្ទឺ និងដោយការគោរព ធ្វើការទូទាត់លើបណ្តាញងាយស្រួល ការបញ្ជាទិញនឹងអាចផ្តល់ជូនទាន់ពេល និងធានាថាមានការពេញចិត្ត។ សុវត្ថិភាព គឺចង់សំដៅលើការប្រើប្រាស់បណ្តាញដោយសុវត្ថិភាព។ ក្រុមហ៊ុនធ្វើជំនួញនៅលើអ៊ីនធឺណិតត្រូវតែរៀបចំប្រព័ន្ធការពារកុំព្យូទ័ររបស់ពួកគេពីការវាយប្រហារ ឬការចូលដោយគ្មានសិទ្ធិអនុញ្ញាត។ អតិថិជនត្រូវមានទំនុកទុកចិត្តថាព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានប័ណ្ណឥណទានរបស់ពួកគេមានសុវត្ថិភាព និងជាការសម្ងាត់ ហើយមិនមាននរណាម្នាក់អាចប្រើប្រាស់ទិន្នន័យដើម្បីលួចប្រាក់របស់ពួកគេ ឬ

ប្រើព័ត៌មាននោះប្រឆាំងជាមួយពួកគេ។ បច្ចុប្បន្ន មនុស្សជាច្រើនប្រើវេបសាយដើម្បីស្រាវជ្រាវក្រុមហ៊ុន និងផលិតផលមុនពេលពួកគេសម្រេចចិត្តទិញ ការមានវេបសាយដែលមានសុវត្ថិភាពអាចធ្វើឱ្យក្រុមហ៊ុនបង្កើននូវការទិញ/លក់របស់ខ្លួន។ ទោះបីក្រុមហ៊ុនតូចក៏អាចបង្ហាញឱ្យឃើញធំជាង សុវត្ថិភាពជាង ប្រសើរជាង និងមានភាពជោគជ័យជាង ប្រសិនបើក្រុមហ៊ុននោះមានវេបសាយដែលមានការរចនាដ៏ប្រសើរ។

*បច្ចុប្បន្ននេះមានមនុស្សប្រើវេបសាយដើម្បីស្រាវជ្រាវក្រុមហ៊ុន និងផលិតផល មុនពួកគេសម្រេចចិត្តទិញ។*

អត្ថប្រយោជន៍ចម្បងក្នុងការមានវេបសាយ គឺថាគេអាចចូលមើលព័ត៌មានបាន ២៤ ម៉ោង រៀងរាល់ថ្ងៃក្នុងមួយឆ្នាំ។ នេះមានន័យថាផលិតផលអាចដាក់លក់បានគ្រប់ពេល ហើយការលក់មិនកំណត់ពេលវេលាអាជីវកម្មរបស់ហាងនោះទេ។ ការលក់នៅលើអ៊ីនធឺណិតមានការកើនឡើងខ្លាំងណាស់ ដែលមនុស្សម្នាកាន់តែច្រើនឡើងប្រើមធ្យោបាយងាយស្រួលនេះដើម្បីទិញ/លក់នៅលើអ៊ីនធឺណិត និងមានតម្លៃសមរម្យ។ ហាងជាច្រើនកំពុងតែផ្តល់ផលិតផលរបស់ពួកគេលក់នៅលើអ៊ីនធឺណិតដើម្បីអាចប្រកួតប្រជែងជាមួយហាងផ្សេងៗ ព្រោះមានអ្នកទិញកាន់តែតិចទៅៗនៅហាងផ្ទាល់។ និន្នាការនេះមានភាពទូលំទូលាយ ឯនៅប្រទេសកម្ពុជាមានការកើនឡើងយ៉ាងខ្លាំងសម្រាប់ការទិញនៅលើអ៊ីនធឺណិតបែបនេះ។ ការប្រើប័ណ្ណឥណទាន ឬឥណពន្ធក៏មានការកើនឡើងដែរនៅកម្ពុជា ដូច្នេះវានឹងបង្កលក្ខណៈសម្រាប់ជំនួញបែបអេឡិចត្រូនិកមួយនៅកម្ពុជា។

ក្រៅពីវេបសាយពាណិជ្ជកម្មតាមអេឡិចត្រូនិកដែលអតិថិជនអាចធ្វើការទិញ ឬបង់ប្រាក់លើអ៊ីនធឺណិត ក៏មានប្រភេទវេបសាយជាច្រើនផ្សេងៗទៀតផងដែរ។ ទាំងនោះ រួមមានវេបសាយផ្ទាល់ខ្លួនជាធម្មតាគេប្រើដើម្បីចែកចាយព័ត៌មានអំពីប្រធានបទជាចំណាប់អារម្មណ៍របស់អ្នកប្រើ ឬដើម្បីបង្ហាញពីការងាររបស់ពួកគេ ក្នុងករណីការងារក្រៅម៉ោង។ វេបសាយរបស់ស្ថាប័នមិនរកប្រាក់កម្រៃត្រូវបានចូលមើលដោយអ្នកទស្សនាដែលត្រូវការព័ត៌មានអំពីគោលបំណងរបស់ស្ថាប័ននោះ រួមមានទាំងអាចធ្វើការបរិច្ចាគតាមបណ្តាញ ឬរបៀបធ្វើការស្ម័គ្រចិត្ត។ នៅពេលគោលបំណងនៃវេបសាយត្រូវបានសម្រេចហើយ អ្នករចនាវេបសាយអាចកំណត់គោលដៅអ្នកទស្សនាបានត្រឹមត្រូវ។



# ២. ការងារនៅក្នុងការរចនាវេបសាយ

ការងាររចនាវេបសាយ គឺនៅតែជាការងារដែលទាក់ទងគ្នា និងបន្តកើតឡើងជានិច្ច។ ការងារវិជ្ជាជីវៈដែលមានភារកិច្ចសំខាន់ក្នុងការបង្កើត ធ្វើបច្ចុប្បន្នភាព និងថែទាំវេបសាយ ដើម្បីផ្តល់ព័ត៌មានជាគំនិត គឺជាផ្នែកមួយនៅក្នុងការងាររចនាវេបសាយ។ ការងារវិជ្ជាជីវៈដែលទាក់ទងនឹងវេបសាយអាចជាការងារផ្ទាល់ខ្លួន ឬពួកគេអាចធ្វើការឱ្យក្រុមហ៊ុន ឬរដ្ឋាភិបាល។ មានមុខតំណែង និងការពិពណ៌នាការងារផ្សេងៗជាច្រើនដែលទាក់ទងនឹងការងារវិជ្ជាជីវៈជាអ្នករចនាវេបសាយ ហើយកំណើននេះនឹងបន្តកើនឡើងដោយសារវិស័យនេះមានការកើនឡើង និងរីកចម្រើនលូតលាស់។

ជាមួយគ្នានេះដែរ ក្រុមការងាររចនាវេបសាយអាចបង្កើត និងថែទាំវេបសាយមួយ ឬច្រើន។ នៅក្នុងក្រុមហ៊ុនធំ មានការងារដែលមានមុខតំណែងច្រើនផ្សេងៗគ្នាដែលធ្វើការលើទ្រង់ទ្រាយផ្សេងៗនៃវេបសាយ។ អ្នករចនាវេបសាយទាំងនោះដែលធ្វើការក្នុងផ្នែករចនាវេបសាយនៃក្រុមហ៊ុនធំនឹងអាចត្រូវបែងចែកជាបួនមុខតំណែងធំៗដូចជា៖ អ្នកគ្រប់គ្រងវេបសាយ អ្នករចនាវេបសាយថ្មីថ្មោង, អ្នករចនាវេបសាយជាន់ខ្ពស់ និងប្រធានគ្រប់គ្រងគម្រោងវេបសាយ។ ការងារទាំងនេះជានិច្ចកាលធ្វើការសហការជាមួយសមាជិកក្នុងផ្នែករចនារូបភាព និងផ្នែកព័ត៌មានវិទ្យា។ អ្នកអភិវឌ្ឍវេបសាយ មុខតំណែងទីប្រាំនៅក្នុងការងារនេះ ដែលត្រូវទទួលបន្ទុកបច្ចេកទេសទ្រង់ទ្រាយវេបសាយ ហើយជាធម្មតាត្រូវធ្វើការផ្ទាល់នៅក្នុងផ្នែកព័ត៌មានវិទ្យា។ នៅក្នុងស្ថាប័នពាណិជ្ជកម្មអេឡិចត្រូនិក ការងារវេបសាយក៏មានទំនាក់ទំនងគ្នាទៅវិញទៅមកយ៉ាងខ្លាំងជាមួយផ្នែកទីផ្សារ និងការលក់។

> *អ្នករចនាវេបសាយធ្វើការក្រៅ គឺជាអ្នកធ្វើការម្នាក់ដែលបើកដំណើរការ និងគ្រប់គ្រងក្រុមហ៊ុនដោយខ្លួនឯង។*

### ការពិពណ៌នាមុខតំណែងក្នុងការងាររចនាវេបសាយមានដូចខាងក្រោម៖

#### អ្នកគ្រប់គ្រងវេបសាយ

អ្នកគ្រប់គ្រងវេបសាយ គឺទទួលខុសត្រូវត្រួតពិនិត្យ និងថែទាំវេបសាយមួយ ឬច្រើនដើម្បីប្រាកដថាវេបសាយនោះបានភ្ជាប់លើអ៊ីនធឺណិត អាចប្រើមុខងារបានត្រឹមត្រូវ និងធានាថាអ្នកប្រើមានការពេញចិត្តនឹងអ្វីដែលមានលើអ៊ីនធឺណិតតាមរយៈការរចនានេះ។ អ្នកគ្រប់គ្រងវេបសាយ គឺជាអ្នកគ្រប់គ្រងម៉ាស៊ីនមេ ដែលពួកគេទទួលខុសត្រូវពិនិត្យមើលភាពត្រឹមត្រូវ និងដំណើរការល្អនៃម៉ាស៊ីនមេគ្រប់គ្រងបណ្តាញគ្រឿងផ្នែករឹង និងកម្មវិធីផ្នែកទន់។ អ្នកគ្រប់គ្រងវេបសាយត្រូវមានចំណេះដឹងបច្ចេកទេស និងត្រូវតែចេះជំនាញការសរសេរកូដដែលត្រូវការដោយក្រុមហ៊ុនឯកទេស ក៏ដូចជាត្រូវមានចំណេះដឹងអំពីរបៀបកំណត់រចនាសម្ព័ន្ធកម្មវិធីម៉ាស៊ីនមេគ្រប់គ្រងបណ្តាញដូចជាកម្មវិធី Apache និងភាសាកូដផ្សេងៗដូចជា JavaScript ជាដើម។ អ្នកគ្រប់គ្រងវេបសាយទាំងអស់ត្រូវចេះ HTML ដែលជាភាសាបានប្រើដើម្បីបង្កើតទំព័រវេបសាយ។

បំណិនបច្ចេកទេសផ្សេងៗទៀតដែលត្រូវការមានដូចជាកម្មវិធីសុវត្ថិភាពកុំព្យូទ័រ និងចំណេះដឹងអំពីសមាសធាតុ និងគោលគំនិតនៃការរចនា។ អ្នកគ្រប់គ្រងវេបសាយក៏ត្រូវតែយល់ដឹងអំពីជំនួញរបស់អតិថិជនដើម្បីប្រាកដថាវេបសាយអាចបំពេញបានតាមតម្រូវការរបស់ម្ចាស់វេបសាយ និងអ្នកទស្សនា។

បំណិនទំនាក់ទំនងដែលត្រូវការរួមមានសមត្ថភាពក្នុងការសរសេរបានល្អដើម្បីបង្កើត និងកែទំព័របណ្ដាញ និងឆ្លើយតបដោយជំនាញទៅនឹងអ៊ីមែលជាច្រើនដោយអ្នកប្រើប្រាស់។ ទោះបីអ្នកគ្រប់គ្រងវេបសាយតែងតែធ្វើការតែឯង ពួកគេក៏ចាំបាច់ត្រូវដឹងពីរបៀបធ្វើការជាក្រុម។ ពួកគេអាចចូលរួមក្នុងការពិភាក្សា និងទាក់ទងជាមួយទស្សនៈផ្សេងៗ ដើម្បីជាផ្នែកមួយនៃក្រុមដែលរួមចំណែកសហការក្នុងការរចនាវេបសាយ និងយុទ្ធសាស្ត្រគ្រប់គ្រងវេបសាយយូរអង្វែងទៀត។

## អ្នករចនាវេបសាយថ្មីថ្មោង

អ្នកដែលមានមុខតំណែងការងារនេះ គឺជាទូទៅនៅកម្រិតចូលដំបូងក្នុងក្រុមហ៊ុន និងទទួលខុសត្រូវការងារល្មមៗដូចជាលើមុខងារប្លង់ គ្រោងពណ៌ និងការរចនាទូទៅនៃវេបសាយ។ ពួកគេតែងតែចាប់ផ្ដើមការងារនៅកម្រិតនេះបន្ទាប់ពីពួកគេទទួលបានបរិញ្ញាបត្រ ដោយមិនចាំបាច់ក្លាយជាអ្នកគ្រប់គ្រងវេបសាយជាមុនទេ។ អ្នកគ្រប់គ្រងវេបសាយថ្មីថ្មោង អាចធ្វើការនៅក្នុងស្ថាប័នដូចជាក្រុមហ៊ុនរចនាវេបសាយ ទីស្នាក់ការកណ្ដាលនៃក្រុមហ៊ុនធំ ក្រុមហ៊ុនពាណិជ្ជកម្មអេឡិចត្រូនិក ឬស្ថាប័នមិនរកប្រាក់កម្រៃ ឬភ្នាក់ងាររដ្ឋាភិបាល។ អ្នកគ្រប់គ្រងវេបសាយថ្មីថ្មោងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមការងាររចនាដើម្បីអនុវត្ត និងពេលខ្លះផ្ដល់ជាគំនិត និងការរចនាដែលមានគុណភាព ដែលអាចជំរុញឱ្យមានអ្នកចូលមើលច្រើនចំពោះវេបសាយនោះ និងឧបករណ៍ចល័តរបស់អ្នកប្រើ។ បន្ថែមពីការដឹងខាងពុម្ពអក្សរ និងប្លង់ អ្នកគ្រប់គ្រងវេបសាយថ្មីថ្មោងត្រូវតែមានបំណិនរចនារូបភាពខ្លាំង ដែលអាចឱ្យពួកគេទទួលបន្ទុកការងារប្លង់ និងការរចនាវេបសាយ។ ពួកគេក៏ត្រូវតែយល់ដឹងការសរសេរកូដ HTML និងភាសាកូដច្បាស់លាស់ដូចជា JavaScript ជាដើម។

> *បំណិនប្រាស្រ័យទាក់ទងខ្លាំង ពិតជាមានសារៈសំខាន់ណាស់សម្រាប់ការងារជាអ្នករចនាវេបសាយ។ បំណិនទាំងនេះមានទាំងបំណិនសរសេរជាអក្សរខ្លាំង និងសន្ទនាវាចាខ្លាំង ដែលរួមមានការពិនិត្យលើភាពត្រឹមត្រូវ ការមើលដើម្បីកែសម្រួល និងចំណាប់អារម្មណ៍សេចក្ដីលម្អិត។*

អ្នករចនាវេបសាយថ្មីថ្មោងត្រូវតែហ្មត់ចត់ និងច្បាស់លាស់ជាមួយការងាររបស់ពួកគេ ព្រោះផលិតផលលើបណ្ដាញរបស់ពួកគេឆ្លុះបញ្ចាំងរូបភាពរបស់ក្រុមហ៊ុន។ បំណិនក្នុងការស្ដាប់ ការសម្ដែងចំណាប់អារម្មណ៍ និងភាពអត់ធ្មត់ និងសមត្ថភាពធ្វើការដោយមិនចាំបាច់គេប្រាប់បានធ្វើ និងការធ្វើការជាក្រុមក៏ជាបំណិនសំខាន់ខ្លាំងដែរសម្រាប់ការងារជាអ្នករចនាវេបសាយទាំងអស់។ បំណិនបន្ថែមពីនេះទៀតដែលចាំបាច់នោះ រួមមានការគ្រប់គ្រងពេលវេលា ការដោះស្រាយបញ្ហា និងការត្រិះរិះពិចារណា។

អ្នកដាក់ពាក្យសម្រាប់ការងារជាអ្នករចនាវេបសាយថ្មីថ្មោងក៏ចាំបាច់ដែលពួកគេត្រូវមានបទពិសោធន៍ខ្លះៗដែរដូចជាអ្នករចនារូបភាព ពួកគេត្រូវតែមានការរៀបចំសម្រាប់និយោជកនូវអ្វីដែលត្រូវការផងដែរ។ អ្នករចនាវេបសាយខ្លះបានសន្សំវិញ្ញាបនបត្រផ្នែករចនាវេបសាយ ប៉ុន្តែភាគច្រើនពួកគេបានបញ្ចប់បរិញ្ញាបត្រផ្នែករចនារូបភាព រចនាបណ្ដាញ និងពហុមេឌាមេឌាអន្តរសកម្ម ឬវិទ្យាសាស្ត្រកុំព្យូទ័រ ដើម្បីអាចរកការងារបាននៅក្នុងទីផ្សារការងារសព្វថ្ងៃ។

## អ្នករចនាវេបសាយជាន់ខ្ពស់

មនុស្សដែលមានមុខតំណែងនេះជាធម្មតាមានបទពិសោធន៍ការងារពី ៤ ទៅ ៧ ឆ្នាំក្នុងផ្នែករចនាវេបសាយ ហើយនឹងអាចមើលលើបំណិនទាំងអស់របស់អ្នករចនាថ្មីថ្មោង រួមទាំងមានចំណេះដឹង និងទំនួលខុសត្រូវបន្ថែម។ អ្នករចនាវេបសាយជាន់ខ្ពស់ផ្ដល់នូវគំនិត ការណែនាំ និងបង្ហាត់បង្រៀនដល់អ្នករចនាថ្មីថ្មោង ក្នុងគោលបំណងតម្រែតម្រង់ទិសក្នុងការបង្កើតការរចនាដែលអាចបំពេញបានតាមវត្ថុ

បំណងជំនួញយ៉ាងច្បាស់លាស់។ អ្នករចនាជាន់ខ្ពស់ក៏ធ្វើឱ្យប្រាកដថាវេបសាយកំពុងបង្ហាញព័ត៌មានច្បាស់លាស់ និងងាយស្រួលក្នុងការរុករក។ ពួកគេត្រូវតែយល់ដឹងច្បាស់ការប្រើប្រាស់កម្មវិធីកុំព្យូទ័រ ក៏ដូចជាគោលគំនិតនៃការរចនារូបភាពដើម្បីបង្កើតទំព័របណ្ដាញប្រកបដោយជោគជ័យ។

ការមានកម្រិតបរិញ្ញាបត្រពិតជាសំខាន់ ហើយអ្នករចនាវេបសាយជាន់ខ្ពស់ជាច្រើនមានកម្រិតសញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែកពាណិជ្ជកម្ម ការរចនាវេប ឬវិទ្យាសាស្ត្រកុំព្យូទ័រ។ ពួកគេបន្តការសិក្សាដោយការចូលរួមសិក្ខាសាលា និងវគ្គសិក្សាផ្សេងៗអំពីការរចនាវេបសាយ និងបណ្ដាញព័ត៌មានសង្គមនានា ដើម្បីមានភាពទាន់សម័យជាមួយសម័យកាលបច្ចុប្បន្ន។

## អ្នកគ្រប់គ្រងគម្រោងវេបសាយ

អ្នកគ្រប់គ្រងគម្រោងវេបសាយជាធម្មតាធ្លាប់ធ្វើជាអ្នករចនាវេបសាយពី ៥ ទៅ ៧ ឆ្នាំ មុនពេលផ្លាស់ទៅការងារក្នុងមុខតំណែងនេះ។ នោះមានន័យថាពួកគេមានបំណិនទាំងអស់ដែលត្រូវការដោយអ្នករចនាវេបសាយថ្មីថ្មោង ឬជាន់ខ្ពស់មុនពេលផ្លាស់ទៅមុខតំណែងជាអ្នកគ្រប់គ្រងនេះ។ ពួកគេមានបទពិសោធន៍គ្រប់គ្រងក្រុមការងាររចនាវេបសាយ និងត្រួតការងាររបស់អ្នកគ្រប់គ្រងវេបសាយ អ្នកអភិវឌ្ឍវេបសាយ និងអ្នករចនាវេបសាយ។ អ្នកគ្រប់គញ្ញវងគម្រោងវេបសាយពិនិត្យមើលការងាររបស់ក្រុមការងារ និងធ្វើការស្នើកែលម្អការរចនាវេបសាយ បំផុសគំនិតថ្មី និងលើកទឹកចិត្តក្រុមការងារដើម្បីបង្កើតការងារបានប្រសើរ។ ពួកគេក៏ត្រូវមានចំណេះដឹងគ្រប់គ្រាន់អំពីការសរសេរកូដវេបសាយ ផ្ដល់នូវការណែនាំដល់អ្នកអភិវឌ្ឍវេបសាយ និងត្រូវដឹងពីអ្វីដែលត្រូវរំពឹងថានឹងទទួលបានពីការងាររបស់ពួកគេ និងតើវាត្រូវចំណាយពេលប៉ុន្មានដែរ។

អ្នកគ្រប់គ្រងគម្រោងវេបសាយត្រូវជួបជាមួយអតិថិជនដើម្បីពិភាក្សាគំនិត និងប្រាកដថាគម្រោងអាចបំពេញតាមអ្វីដែលអតិថិជនចង់បាន។ ពួកគេត្រូវតែជាអ្នកជំនាញវាយតម្លៃពេលវេលាដែលភារកិច្ចនីមួយៗនឹងត្រូវចំណាយពេលលើវា និងតើវាត្រូវចំណាយអ្វីខ្លះ ព្រមទាំងមានជំនាញគ្រប់គ្រងក្រុមការងាររបស់ពួកគេតាមរយៈបំណិនបុគ្គលដ៏ប្រសើរ។

អ្នកគ្រប់គ្រងគម្រោងវេបសាយយ៉ាងហោចណាស់ក៏មានសញ្ញាបត្របរិញ្ញាបត្រ ភាគច្រើនក្នុងផ្នែករចនា ឬគ្រប់គ្រងគម្រោង និងភាគច្រើនមានបរិញ្ញាបត្រជាន់ខ្ពស់ ក្នុងផ្នែកដែលទាក់ទងដូចជាគ្រប់គ្រងជំនួញ ឬគ្រប់គ្រងគម្រោង។ ពួកគេត្រូវតែបន្តការអប់រំវិជ្ជាជីវៈរបស់ពួកគេដើម្បីឱ្យមានបច្ចុប្បន្នភាពសម្រាប់អ្វីដែលថ្មី ជាពិសេសបច្ចេកវិទ្យាទូរសព្ទ និងពពក។

## អ្នកអភិវឌ្ឍវេបសាយ

ដោយបន្ថែមទៅមុខងាររចនា ការបង្កើត និងថែទាំវេបសាយក៏ទាមទារជំនាញបច្ចេកទេសផងដែរ។ ការងារជំនាញនេះត្រូវបានផ្ដល់ដោយអ្នកអភិវឌ្ឍវេបសាយ។ អ្នកអភិវឌ្ឍវេបសាយ គឺជាអ្នកសរសេរកូដកម្មវិធីដែលមានជំនាញភាសាកូដ និងកម្មវិធីប្រើសម្រាប់វេបសាយ។ អ្នកអភិវឌ្ឍវេបសាយទទួលខុសត្រូវគ្រប់ទិដ្ឋភាពបច្ចេកទេសទាំងអស់នៃវេបសាយ។ ខណៈដែលបំណិនរបស់អ្នកអភិវឌ្ឍវេបសាយភាគច្រើនអាចត្រូវបានប្រើក្នុងប្រព័ន្ធណាក៏បាន ពេលខ្លះអ្នកអភិវឌ្ឍវេបសាយមានឯកទេសក្នុងប្រព័ន្ធបណ្ដាញមួយក្នុងចំណោមប្រព័ន្ធបណ្ដាញចម្បងពីរ (លីនុច ឬ ម៉ៃក្រូសូហ្វ) និងរៀនអំពីឧបករណ៍ និងភាសាកម្មវិធីនៃប្រព័ន្ធនោះ។ ប្រព័ន្ធប្រតិបត្តិការលីនុច គឺជាប្រព័ន្ធដែលគេនិយមប្រើបំផុតលើពិភពលោក។

> *អ្នកអភិវឌ្ឍវេបសាយ គឺជាអ្នកសរសេរកម្មវិធីដែលមានឯកទេសភាសាកូដ និងកម្មវិធីសម្រាប់អភិវឌ្ឍវេបសាយ។*

តាមលក្ខណៈបច្ចេកទេស ចាប់ពីពាណិជ្ជកម្មតាមអេឡិចត្រូនិករហូតដល់ការគ្រប់គ្រងមូលដ្ឋានទិន្នន័យ និងការយល់ដឹងរបៀបជួយឱ្យវេបសាយមានចំណាត់ថ្នាក់នៅក្នុងម៉ាស៊ីនស្វែងរកដោយកំណត់កូដតាមដាន ធ្វើការជាមួយអ្នកគ្រប់គ្រងវេបសាយ ឬអ្នកអភិវឌ្ឍវេបសាយ។

### អ្នករចនាវេបសាយធ្វើការក្រៅ

អ្នករចនាវេបសាយធ្វើការក្រៅគ្រប់គ្រងជំនួញរចនាបណ្ដាញរបស់ខ្លួន ពេលខ្លះធ្វើការលើគម្រោងរបស់ពួកគេ និងពេលខ្លះជួលអ្នកផ្សេងដើម្បីជួយពួកគេធ្វើការងារជាក់លាក់ណាមួយ។ ពួកគេទទួលបន្ទុកគ្រប់គ្រងផ្នែកទាំងអស់នៃជំនួញរបស់ពួកគេ ចាប់តាំងពីការស្វែងរកភ្ញៀវដែលចង់បានវេបសាយ បង្កើតការរចនាវេបសាយ ជួបជាមួយភ្ញៀវ ទូទាត់វិក្កយបត្រ និងប្រមូលប្រាក់ដែលត្រូវបង់។ អ្នករចនាធ្វើការក្រៅម៉ោងខ្លះមានឯកទេសក្នុងការបង្កើតវេបសាយសម្រាប់ពាណិជ្ជកម្មតាមអេឡិចត្រូនិក ចំណែកឯអ្នកផ្សេងអាចធ្វើការក្នុងផ្នែកជាក់លាក់ដូចជាស្ថាប័នមិនរកប្រាក់កម្រៃ ឬភ្នាក់ងាររដ្ឋាភិបាល។ អ្នករចនាវេបសាយធ្វើការក្រៅម៉ោងជាញឹកញាប់ធ្វើការមានទំនាក់ទំនងជាមួយអ្នករចនាផ្សេងៗដើម្បីប្ដូរគំនិត ឬសហការលើគម្រោង។ យើងផ្ដល់យោបល់ថា អ្នករចនាវេបសាយយ៉ាងហោចណាស់ត្រូវមានបទពិសោធន៍ប្រាំឆ្នាំធ្វើការជាមួយក្រុមហ៊ុនមុនពេលក្លាយជាអ្នករចនាវេបសាយក្រៅម៉ោង។

# ២.១. បរិស្ថានការងារ

ការងារនៅក្នុងមុខតំណែងវិជ្ជាជីវៈជាអ្នករចនា និងថែទាំវេបសាយ គឺមានការកើនឡើងនៅលើពិភពលោក ដែលមានវេបសាយកាន់តែច្រើនឡើងត្រូវបានបង្កើតឡើង ជាពិសេសទីផ្សារក្នុងប្រទេសកម្ពុជា។ ចំនួនស្ថាប័នដែលចង់មានវេបសាយក៏កំពុងកើនឡើងផងដែរ ពាណិជ្ជកម្មតាមអេឡិចត្រូនិកកំពុងរីកចម្រើនលូតលាស់ ហើយក្រុមហ៊ុនថ្មីៗត្រូវបានបង្កើតឡើងស្របពេលជាមួយគ្នានេះដែរ។ ការងារក្នុងផ្នែកវេបសាយដែលមានទេពកោសល្យតែងតែជាតម្រូវការ និងអាចស្វែងរកការងារបានយ៉ាងងាយស្រួល។ ភាពល្បីល្បាញដោយសារគុណភាពខ្ពស់ និងជាអ្នករចនាដែលអាចជឿទុកចិត្តជាមួយវេបសាយរបស់ពួកគេជាកត្តាសំខាន់ដើម្បីទទួលបានជោគជ័យក្នុងផ្នែកដែលរីកលូតលាស់នេះ ដោយមិន

កន្លែងធ្វើការនៅក្រុមហ៊ុនរចនា



គិតថាអ្នកស្ថិតនៅគន្លងការងារណាមួយឡើយ។ ដើម្បីឈានទៅរកតំណែងដែលខ្ពស់ក្នុងការងារនេះ វាចាំបាច់ត្រូវមានបទពិសោធន៍ ការពិនិត្យមើលការងាររបស់អ្នករចនាផ្សេងៗ ស្វែងរកពីពួកគេ និងបន្តអប់រំតាមរយៈការអភិវឌ្ឍវិជ្ជាជីវៈ ឬវិញ្ញាបនបត្រ។

អ្នករចនាវេបសាយជាញឹកញាប់ធ្វើការឱ្យក្រុមហ៊ុនដែលមានឯកទេសផ្នែកពាណិជ្ជកម្មអេឡិចត្រូនិក ស្ថាប័នផ្តល់សេវាកម្ម ឬភ្នាក់ងាររដ្ឋាភិបាល។ អ្នករចនាអាចចែករំលែកការិយាល័យជាមួយអ្នករចនាផ្សេងទៀត និងជាញឹកញាប់ពួកគេធ្វើការលើគម្រោងជាក្រុម។ នៅក្នុងក្រុមការងាររចនា អ្នករចនានីមួយៗអាចធ្វើការរួមគ្នាលើការរចនាទូទៅ ឬពួកគេមានឯកទេសក្នុងផ្នែកណាមួយនៃការរចនាវេបសាយ។ ការងារត្រូវបានធ្វើភាគច្រើននៅអំឡុងម៉ោងការងារ ពេលខ្លះការងារវេបសាយក៏អាចតម្រូវឱ្យធ្វើការយូរជាងម៉ោងការងារ ព្រោះត្រូវតម្រូវតាមពេលកំណត់។

ពេលខ្លះការរចនាត្រូវបានធ្វើឡើងរៀងៗខ្លួន ប៉ុន្តែវាមិនមែនជារឿងចម្លែកទេសម្រាប់ការចែករំលែកគំនិតរចនាសំខាន់ៗជាមួយក្រុមការងារដែលធ្វើការរួមគ្នាក្នុងការបំផុសគំនិត ដែលអ្នករចនានីមួយៗអាចស្នើគំនិត ឬបញ្ចេញមតិយោបល់អំពីគំនិតរបស់អ្នករចនាផ្សេងៗ ក្នុងបំណងបង្កើតការរចនាដែលប្រសើរមួយ ជាជាងអ្នករចនាម្នាក់បង្កើតផលិតផលមួយតែឯង។ សកម្មភាពទៅវិញទៅមករវាងអ្នករចនាអាចមានប្រសិទ្ធភាពខ្លាំងជាង ដោយការផ្សំគំនិតច្នៃប្រឌិតរវាងអ្នករចនាទាំងអស់។ នៅពេលគំនិតមូលដ្ឋានត្រូវបានបង្កើតឡើងដោយក្រុមការងារ នោះអ្នករចនាវេបសាយនីមួយៗនឹងត្រូវអភិវឌ្ឍ ដោយអនុវត្តតាមអ្វីដែលបានឯកភាពគ្នា។

អ្នកធ្វើការផ្នែកវេបសាយភាគច្រើនចំណាយពេលច្រើនបំផុតរបស់ពួកគេនៅមុខកុំព្យូទ័រ។ ខណៈដែលជំហានដំបូងពួកគេអាចចូលទៅដំណាក់កាលរចនាវេបសាយ ដោយគូសវាសអ្វីដែលចង់បង្ហាញលើវេបសាយនោះ ហើយផ្នែកនៃការងាររបស់ពួកគេភាគច្រើនត្រូវអនុវត្តតាមគំនិតដែលបានរចនានេះ ដោយប្រើឧបករណ៍ណាមួយក៏ដោយដែលមានដើម្បីបង្កើតវេបសាយដែលពួកគេបានរចនា។



ពិភពនៃការរចនាវេបសាយត្រូវមានការប្រកួតប្រជែង។ ភ្នាក់ងារ និងអ្នករចនាក្រៅម៉ោងតែងរកមើលអតិថិជន និងគម្រោងថ្មីជានិច្ច។ វាត្រូវចំណាយពេលក្នុងការកសាងកេរ្តិ៍ឈ្មោះ និងបង្កើតសៀវភៅគំរូវេបសាយដែលពួកគេបានបង្កើត ដែលពួកគេនឹងត្រូវប្រើវាដើម្បីទាក់ទាញអតិថិជនថ្មី។ ជានិច្ចកាលអ្នករចនាវេបសាយសុបិនធ្វើជាម្ចាស់ក្រុមហ៊ុនផ្ទាល់ខ្លួន ដែលពួកគេនឹងធ្វើជាអ្នកគ្រប់គ្រង និងអ្នកប្រឹក្សារចនាចម្បង។ ពេលខ្លះអ្នករចនាវេបសាយផ្លោះបានលឿនពីការធ្វើការខ្លួនឯងទៅជាអ្នកធ្វើការក្រៅម៉ោង ដោយមិនបាច់ត្រូវបង្កើតគំរូការងារដ៏ច្រើនសន្ធឹកសន្ធាប់ដើម្បីឱ្យគេទុកចិត្តលើពួកគេ ឬមានទំនាក់ទំនងច្រើនគ្រប់គ្រាន់ដើម្បីស្វែងរកការងារ។ ក្នុងករណីទាំងនេះពួកគេមិនអាចនៅតែបន្តធ្វើការក្រៅម៉ោងរយៈពេលយូរ និងជាធម្មតាពួកគេឈប់ការងារខ្លួនឯងដើម្បីធ្វើការឱ្យក្រុមហ៊ុនម្តងទៀត។ ពួកគេអាចនឹងព្យាយាមធ្វើការក្រៅម៉ោងម្តងទៀតពេលក្រោយ នៅពេលពួកគេបានត្រៀមរៀបចំខ្លួនបានប្រសើរហើយនោះ។ នៅពេលជំនួញបានកើតឡើង អ្នករចនាធ្វើការខ្លួនឯងដែលល្អតែងតែមានអតិថិជនដែលពេញចិត្តនឹងការងាររបស់ពួកគេបានណែនាំដល់អ្នកផ្សេងទៀត។

បរិស្ថានការងារជាអ្នករចនាវេបសាយ គឺជាជំហានដ៏លឿនជាមួយបរិយាកាសច្នៃប្រឌិតដែលគំនិតថ្មីត្រូវបានអភិវឌ្ឍឡើង និងឆ្លើយតបនឹងតម្រូវការបានឆាប់រហ័ស។ ខណៈដែលការងារខ្លះត្រូវមានការសាមគ្គីគ្នា អ្នកដែលធ្វើការផ្នែកវេបសាយត្រូវមានភាពសកម្មខ្ពស់នៅពេលពួកគេធ្វើការពិភាក្សាលើគម្រោង។ ពួកគេតែងនិយាយជាធម្មតាជាមួយអតិថិជន សមាជិកក្រុមការងារ និងអ្នកគ្រប់គ្រង។ ពួកគេប្រាស្រ័យទាក់ទងជាមួយអ្នកផ្សេងៗដោយផ្ទាល់ ឬតាមរយៈទូរសព្ទ ឬអ៊ីមែលជារៀងរាល់ថ្ងៃ។ បំណិនសរសេរជាលាយលក្ខណ៍អក្សរ សន្ទនាវាចា ប្រើកាយវិការ និងការផ្តល់ព័ត៌មានជារូបភាពត្រូវការជាចាំបាច់សម្រាប់បុគ្គលដើម្បីក្លាយជាអ្នកអាជីពការងារផ្នែកវេបសាយដ៏មានប្រសិទ្ធភាព។

## មេរៀនសង្ខេប

ការកើនឡើងយ៉ាងឆាប់រហ័ស ចាប់ពីទសវត្សឆ្នាំ ១៩៩០ បណ្តាញនេះបានក្លាយជាធនធានដ៏សំខាន់សម្រាប់ស្ថាប័ន ក្រុមហ៊ុន និងបុគ្គលក្នុងការបង្ហាញខ្លួនរបស់ពួកគេ ព្រមទាំងផលិតផលសេវាកម្មចំណាប់អារម្មណ៍ ឬគំនិតរបស់ពួកគេ។ ដោយមានវេបសាយជាងមួយលានក្នុងឆ្នាំ ២០១៥ វេបសាយនៅតែបន្តការកើនឡើងដូចជាក្រុមហ៊ុនថ្មីៗ និងស្ថាប័នប្រើវេបសាយដើម្បីឆ្លុះបញ្ចាំងរូបភាព និងលក់ផលិតផលរបស់ពួកគេ។ ក្រុមហ៊ុនជាច្រើនកំពុងផ្លាស់ប្តូរយ៉ាងខ្លាំងចំពោះមធ្យោបាយធ្វើអាជីវកម្មរបស់ពួកគេ ដោយសារតែកំណើននៃពាណិជ្ជកម្មតាមអេឡិចត្រូនិកដោយផ្តោតទៅលើការខិតខំប្រឹងប្រែងនៃពាណិជ្ជកម្មរបស់ពួកគេ តាមរយៈបណ្តាញជំនួសឱ្យពាណិជ្ជកម្មនៅហាងផ្ទាល់។ ខណៈពេលដែលកុំព្យូទ័រផ្ទាល់ខ្លួនដំបូងត្រូវបានរចនាឡើង វេបសាយជាច្រើនក៏បានរចនាឡើងផងដែរសម្រាប់ឧបករណ៍ចល័ត និងបានក្លាយជាមធ្យោបាយចម្បងក្នុងការចូលទៅប្រើប្រាស់អ៊ីនធឺណិត។

អ្នកជំនាញផ្នែកវេបសាយ គឺជាមនុស្សដែលបានអភិវឌ្ឍបច្ចេកទេសនានា និងជំនាញច្នៃប្រឌិត ដើម្បីជាសារសម្រាប់ការប្រាស្រ័យទាក់ទង តាមរយៈវេបសាយនៅលើវើលវ៉ាយវេប។ ពួកគេរួមបញ្ចូលទាំងអ្នករចនាបណ្តាញ នៅក្នុងផ្នែកនៃការរចនា មិនត្រឹមតែជាផ្នែកនៃវេបសាយដែលមានសោភ័ណភាពប៉ុណ្ណោះទេ ប៉ុន្តែក៏មានរបៀបប្រតិបត្តិការបណ្តាញ និងរបៀបសម្រាប់អ្នកមើលទាក់ទងវាផងដែរ។ អ្នកអភិវឌ្ឍន៍បណ្តាញធ្វើការងារបច្ចេកទេសច្រើនបំផុត សរសេរកម្មវិធីវេបសាយ និងការផ្តល់ការចូលដំណើរការទៅ

កាន់មូលដ្ឋានទិន្នន័យ។ អ្នកគ្រប់គ្រងវេបសាយដែលមានបទពិសោធន៍តិចតួចអាចថែទាំវេបសាយ ហើយពួកគេក៏អាចរចនា និងបង្កើតវេបសាយតូចៗបានផងដែរ។

បច្ចុប្បន្ន អ្នកជំនាញវេបសាយភាគច្រើនទទួលបានយ៉ាងហោចណាស់វិញ្ញាបនបត្រពីសាលាបច្ចេកទេស បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ឬផ្នែកដែលទាក់ទងដូចជាការរចនាវេបសាយដែលមានវិជ្ជាជីវៈ។ អ្នកគ្រប់គ្រងវេបសាយ អ្នកអភិវឌ្ឍន៍វេបសាយ អ្នករចនាវេបសាយ និងអ្នកគ្រប់គ្រងគម្រោងវេបសាយអាចធ្វើការងារឱ្យក្រុមហ៊ុនណាមួយដែលត្រូវការវេបសាយ ឬពួកគេអាចនឹងធ្វើការឱ្យខ្លួនឯង។

# លំហាត់

## លំហាត់ ១

អ្នកនឹងជួយចរណៃ បង្កើតផែនការទំព័របណ្ដាញថ្មីសម្រាប់កម្មវិធី ABLE’s August Festival School។ លីម គឺជាអ្នកជំនាញខាងរចនាវេបសាយ ហើយគាត់នឹងធ្វើការងារបច្ចេកទេសនេះ។ ការងារជាក្រុមរបស់អ្នក គឺពិភាក្សាគំនិត ហើយបន្ទាប់មកសម្រេចចិត្តពីមាតិកានៃទំព័រ ដែលមានតំណភ្ជាប់ទៅទំព័រព័ត៌មានអ្នកស្ម័គ្រចិត្តដ៏សំខាន់ និងកម្មវិធីស្ម័គ្រចិត្ត។ គោលបំណងនៃទំព័របណ្ដាញរបស់អ្នក គឺអំពាវនាវដល់ក្មេងជំទង់ និងមនុស្សពេញវ័យ ដើម្បីបញ្ចុះបញ្ចូលពួកគេឱ្យស្ម័គ្រចិត្តសម្រាប់កម្មវិធី August Festival School បន្ទាប់។ អ្នកស្ម័គ្រចិត្តត្រូវតែសន្យា យ៉ាងតិចបំផុតរយៈពេលមួយសប្ដាហ៍ ហើយអាចស្ម័គ្រចិត្តទាំងបួនសប្ដាហ៍។ ទីនេះជាព័ត៌មានបន្ថែមដែលអ្នកត្រូវដឹងមុនពេលដែលអ្នកពិភាក្សាអំពីគំនិតរបស់អ្នកស្ម័គ្រទំព័រនេះ៖




- កាលបរិច្ឆេទនៅថ្ងៃ ១-៣១ ខែសីហា, ថ្ងៃចន្ទ រហូតដល់ថ្ងៃសៅរ៍
- មួយ ឬពីរសប្ដាហ៍សម្រាប់អាយុ ៥-២៣ ឆ្នាំ។ ឥតគិតថ្លៃ
- ទាមទារការធានាពីវេជ្ជបណ្ឌិត។ ទាមទារពាក្យសុំ (មើលតំណ) សម្រាប់ការទទួលពាក្យចំពោះកម្មវិធី Festival School។
- ប្រភេទសកម្មភាព៖ លេងបាល់ ហែលទឹក ល្បែងកម្សាន្ត ច្រៀង រាំ ភាពយន្ត បន្ទប់កុំព្យូទ័រ អាន & ថ្នាក់គណិតវិទ្យា និទានរឿង ប្រណាំងកៅអីជនពិការ។
- ទីកន្លែង៖ ភ្នំពេញ (៣) បាត់ដំបង សៀមរាប កំពត ព្រៃវែង

ដើម្បីរៀបចំគំនិតរបស់អ្នកដែលនឹងភ្ជាប់ទៅទំព័រ "អ្នកស្ម័គ្រចិត្ត" ចម្បងរបស់លីម អ្នកត្រូវឆ្លើយសំណួរខាងក្រោម រួចត្រូវប្រាកដថាបានបញ្ចូលព័ត៌មាននោះ។ សូមធ្វើដោយភាពច្នៃប្រឌិត! មិនមែនមានចម្លើយ "ត្រឹមត្រូវ" តែមួយចំពោះសំណួរនីមួយៗទេ។ ចូរពិភាក្សាសំណួរខាងក្រោម និងប្រកាសចម្លើយទៅថតក្រុមរបស់អ្នក។

ក. ហេតុអ្វីយុវវ័យគួរដាក់ពាក្យធ្វើជាអ្នកស្ម័គ្រចិត្ត?

ខ. តើអ្នកណាគួរដាក់ពាក្យធ្វើជាអ្នកស្ម័គ្រចិត្ត? បំណិនអ្នកស្ម័គ្រចិត្តណាដែលមានតម្លៃសម្រាប់កម្មវិធី ABLE's August Festival School?

គ. ពិភាក្សាអំពីការរចនាយ៉ាងដូចម្តេច និងគូសព្រាងគេហទំព័រ "អ្នកស្ម័គ្រចិត្ត August" ដែលមានព័ត៌មានអំពីថាហេតុអ្វីអ្នកណាម្នាក់គួរធ្វើជាអ្នកស្ម័គ្រចិត្ត អ្នកណាអាចធ្វើជាអ្នកស្ម័គ្រចិត្ត និងរបៀបដាក់ពាក្យសុំធ្វើជាអ្នកស្ម័គ្រចិត្ត។ គោលបំណងនៃទំព័រនេះ គឺដើម្បីលើកទឹកចិត្តអ្នកស្ម័គ្រចិត្តឱ្យដាក់ពាក្យសុំ។ ការរចនា និងរូបភាព (កន្លែងដែលរូបភាពគួរស្ថិតនៅ និងពិពណ៌នាប្រភេទនៃរូបភាព) ដូចដែលអ្នកគិតថាចាំបាច់ជាជំនួយដល់ការលើកទឹកចិត្តនេះ។ តើពណ៌ណាដែលអ្នកផ្តល់យោបល់សម្រាប់ធ្វើជាផ្ទៃខាងក្រោយ និងអត្ថបទសម្រាប់ទំព័រ?

ឃ. ហេតុអ្វីវាមានសារៈសំខាន់ក្នុងការបញ្ចូលរូបភាព? តើការរចនារបស់អ្នកមានសមតុល្យហើយឬនៅ? តើប្រភេទការតម្រឹមអ្វីដែលអ្នកបានប្រើ?

## លំហាត់ ២

អ្នកបានសម្រេចចិត្តថាគោលបំណងការងាររបស់អ្នកគឺចង់ក្លាយជាអ្នកគ្រប់គ្រងគម្រោងវេបសាយ។ អ្នកដឹងច្បាស់ថា វានឹងចំណាយពេលច្រើនឆ្នាំសម្រាប់ការអប់រំ និងបទពិសោធន៍ដើម្បីសម្រេចបានគោលបំណងនេះ (--អាចប្រហែលជាង ១០ ឆ្នាំ--) ហើយអ្នកត្រូវត្រៀមធ្វើការខ្លាំងដើម្បីបំពេញតម្រូវការទាំងអស់នេះដើម្បីសម្រេចគោលបំណងរបស់អ្នក។ នៅក្នុងក្រុមរបស់អ្នក ចូរពិភាក្សាសំណួរខាងក្រោម និងប្រកាសចម្លើយទៅថតក្រុមរបស់អ្នក។

ក. ពិភាក្សានៅក្នុងក្រុមរបស់អ្នកអំពីគន្លងការងារណាដែលអ្នកចាំបាច់ត្រូវអនុវត្តតាមដើម្បីឈានដល់គោលដៅរបស់អ្នក។ រួមទាំងការអប់រំ បទពិសោធន៍ និងបច្ចេកទេស និងបំណិនប្រាស្រ័យទាក់ទងដែលអ្នកនឹងមានស្របតាមមធ្យោបាយដើម្បីអាចផ្លាស់ទីទៅមុខតំណែងជាអ្នកគ្រប់គ្រងគម្រោងវេបសាយ។

ខ. ពិភាក្សាពីបំណិនណាមួយដែលក្រុមរបស់អ្នកគិតថានឹងមានផលលំបាកបំផុតដើម្បីទទួលបានវា។ សូមពន្យល់។

គ. តើអ្នកគួរធ្វើអ្វីខ្លះនៅអំឡុងពេលការងារវិជ្ជាជីវៈផ្នែកវេបសាយរបស់អ្នកដើម្បីអភិវឌ្ឍបំណិនទាំងនោះដែលមានផលលំបាកបំផុត?

# សំណួរត្រិះរិះ

១. តើអ្វីជាវេបសាយ និងហេតុអ្វីបានជាក្រុមហ៊ុនត្រូវការវា?

២. ហេតុអ្វីក្រុមហ៊ុនត្រូវធ្វើឱ្យវេបសាយរបស់ពួកគេមានសុវត្ថិភាព?

៣. តើអ្នករចនាវេបសាយគួរធ្វើអ្វីខ្លះ ហើយបំណិនអ្វីដែលចាំបាច់សម្រាប់ពួកគេ?

៤. តើកម្មវិធីកុំព្យូទ័រអ្វីដែលគេនិយមប្រើបំផុតសម្រាប់ការរចនាវេបសាយ?

៥. ហេតុអ្វីការសរសេរកូដ និងបំណិនច្នៃប្រឌិតមានសារៈសំខាន់សម្រាប់អ្នករចនាវេបសាយដើម្បីទទួលបានជោគជ័យ?

៦. តើអ្វីជាបំណិនបច្ចេកទេស ទំនាក់ទំនង និងកម្រិតការអប់រំដែលចាំបាច់ត្រូវមានដើម្បីក្លាយជាអ្នកគ្រប់គ្រងវេបសាយ ការងារជាអ្នករចនាវេបសាយថ្មីថ្មោង ឬជាន់ខ្ពស់ដ៏មានប្រសិទ្ធភាព?

៧. តើអ្វីជាអ្នករចនាវេបសាយក្រៅម៉ោង?

# ផ្នែក ខ - អក្ខរកម្មមេឌា និងអ៊ីនធឺណិត

## ៣. អក្ខរកម្មមេឌា

អក្ខរកម្មជាមូលដ្ឋាន គឺជាសមត្ថភាពអាន និងសរសេរ រីឯអក្ខរកម្មមេឌា គឺជាសមត្ថភាពវិភាគ វាយតម្លៃ និងបង្កើតខ្លឹមសារតាមប្រភេទផ្សេងៗនៃមេឌា ដូចជាកាសែត ទស្សនាវដ្ដី ទូរទស្សន៍ វិទ្យុ ឬអ៊ីនធឺណិតជាដើម។ អក្ខរកម្មមេឌាក៏សំដៅលើបំណិនបច្ចេកទេសដែលអាចឱ្យយើងរៀបចំ និងបង្កើតមាតិកាដោយប្រើប្រាស់ទម្រង់ផ្សេងៗជាមធ្យោបាយដែលយើងនឹងប្រើប្រាស់។ បំណិនទាំងនេះអាចមានទាំងអត្ថបទសរសេរ ការរចនា និងការសរសេរស្គ្រីបសម្រាប់សំឡេង ឬវីដេអូ ឬថតរូបភាព ឬវីដេអូដែលល្អ។

មេឌាមានព័ត៌មាន និងផ្ដល់ព័ត៌មាន។ ព័ត៌មានមិនអាចចែករំលែកបានដោយមិនដាក់វានៅក្នុងទម្រង់ណាមួយដែលអាចទៅដល់អ្នកទស្សនាឡើយ ដំបូងព័ត៌មានត្រូវប្រែក្លាយជាអត្ថបទ សំឡេង វីដេអូ រូបភាព ឬបន្សំនៃធាតុទាំងនេះ។ ផលិតផលជាលទ្ធផលត្រូវបានគេស្គាល់ថាជាមាតិកា។ មាតិកាផ្សំឡើងដោយព័ត៌មានដែលបានទំនាក់ទំនង ទម្រង់នៃការបញ្ជូន និងរបៀបនៃការបង្ហាញព័ត៌មាននោះ។ អ្នកអភិវឌ្ឍមាតិកា គឺជាមនុស្សដែលជាអ្នករៀបចំខ្លឹមសារសម្រាប់ទម្រង់ផ្សេងៗនៃមេឌា។ អ្នកអភិវឌ្ឍមាតិការួមមានអ្នកយកព័ត៌មានអាជីព អ្នកនិពន្ធ អ្នកគ្រប់គ្រងវេបសាយ ឬរូបវន្តបុគ្គលដែលចង់ផ្សព្វផ្សាយព័ត៌មានវេបសាយ ឬកំណត់ហេតុបណ្ដាញ ពួកគេចាំបាច់ត្រូវមានបំណិនអក្ខរកម្មមេឌា ដើម្បីឱ្យព័ត៌មានបានទៅដល់អ្នកទស្សនា និងទទួលបានភាពទុកចិត្តនៅចំពោះព័ត៌មានដែលពួកគេបានផ្សព្វផ្សាយ។

*"ការអាន គឺដល់ខួរក្បាល លំហាត់ប្រាណដល់រាងកាយ។"*
- រីឆាត ស្ទៀល




## ៣.១. ទម្រង់នៃមេឌា

មធ្យោបាយ គឺជាទម្រង់នៃការផ្ទេរព័ត៌មានពីកន្លែងមួយទៅកន្លែងមួយ។ កាលពីមុន មនុស្សប្រើមេឌាតាមរយៈការបោះពុម្ព ដូចជាលិខិត កាសែត ទស្សនាវដ្ដី និងសៀវភៅ ជាមធ្យោបាយដើម្បីបញ្ជូនព័ត៌មាន។ ឥឡូវមនុស្សភាគច្រើនទម្លាប់ប្រើប្រាស់ទម្រង់ថ្មីនៃមេឌាអេឡិចត្រូនិកដែលប្រើបច្ចេកវិទ្យាអេឡិចត្រូនិកក្នុងការផ្ដល់ព័ត៌មាន ដែលរួមមានតន្ត្រីថតចម្លង ការផ្សាយតាមវិទ្យុ និងទូរទស្សន៍ ការហៅតាមទូរសព្ទចល័ត និងសារជាអត្ថបទជាដើម។

អ៊ីនធឺណិត គឺជាបច្ចេកវិទ្យាអេឡិចត្រូនិកចុងក្រោយមួយដែលអាចប្រើបានពីគ្រប់ឧបករណ៍បច្ចេកទេសផ្សេងៗដូចជាកុំព្យូទ័រ ឬទូរសព្ទដៃទំនើបជាដើម។ វាបាននាំមកនូវចំណាត់ថ្នាក់ថ្មីមួយក្នុងចំណោមមេឌាផ្សេងៗ អាស្រ័យលើរយៈពេលប្រើប្រាស់របស់វា។ កាសែត ទស្សនាវដ្ដី វិទ្យុ និងទូរទស្សន៍មានអាយុកាលយូរយារណាស់មកហើយ និងត្រូវបានគេហៅថាជាមេឌាបូរាណ ខណៈដែលអ៊ីនធឺណិតត្រូវបានគេហៅថាជាមធ្យោបាយសម័យថ្មី។ មេឌាបូរាណមានសមត្ថភាពអាចផ្សព្វផ្សាយដល់មនុស្សបានចំនួន

ច្រើន ប៉ុន្តែមិនសូវមាន ឬគ្មានអន្តរកម្មជាមួយអ្នកទស្សនាឡើយ។ ឥឡូវយើងនិយមប្រើពាក្យថា ប្រព័ន្ធផ្សព្វផ្សាយ សំដៅលើមធ្យោបាយទំនាក់ទំនងដែលទាក់ទងនឹងការបញ្ជូនព័ត៌មានទៅមនុស្សជាច្រើន។ ទម្រង់នៃមេឌាបូរាណទាំងអស់ ក៏ដូចជាអ៊ីនធឺណិត គឺជាមេឌាទ្រង់ទ្រាយទូលំទូលាយផ្សាយទៅមនុស្សច្រើនក្នុងពេលតែមួយ។ ទាំងអ៊ីនធឺណិត និងទូរសព្ទទំនើបបច្ចុប្បន្នមានសមាសធាតុអន្តរសកម្ម និងអាចស្វែងរក សមាសធាតុដែលមិនមាននៅក្នុងមេឌាបូរាណ។

មធ្យោបាយនីមួយៗមានចំណុចខ្លាំង និងចំណុចខ្សោយ។ ដំណឹងតាមទូរទស្សន៍អាចផ្សព្វផ្សាយអំពីព្រឹត្តិការណ៍ដោយប្រើវីដេអូដែលគួរឱ្យចាប់អារម្មណ៍ ប៉ុន្តែទាំងនេះអាចមើលបានតែនៅពេលដែលចាក់ផ្សាយប៉ុណ្ណោះ តែមិនប្រាកដថាចំពេលវេលាដែលអ្នកទស្សនាអាចមើលបានទេ។ វិទ្យុអាចផ្សាយដល់សហគមន៍ដែលទូរទស្សន៍ និងអ៊ីនធឺណិតមិនអាចផ្សាយដល់ ប៉ុន្តែព័ត៌មានត្រូវបានផ្សាយតាមពេលវេលាកំណត់ប៉ុណ្ណោះ។ អ៊ីនធឺណិតអាចផ្តល់ព័ត៌មានបានច្រើនគ្រប់ទម្រង់ គ្រប់ពេលវេលាដែលអ្នកប្រើចង់ទទួលបានវា និងបានបង្កើតឡើងដោយប្រភពព័ត៌មានផ្សេងៗជាច្រើន ប៉ុន្តែអ៊ីនធឺណិតអាចទៅដល់អ្នកប្រើក៏មានដែនកំណត់។

**រាត្រីមើលទូរទស្សន៍ជុំគ្រួសារ** | **ការប្រើអ៊ីនធឺណិត**



ជំនាញដែលចាំបាច់ងាយៗក្នុងការផ្សព្វផ្សាយព័ត៌មាននៅលើអ៊ីនធឺណិត និងការរីកចម្រើននៃបណ្តាញព័ត៌មានសង្គមបានបង្កើតបរិយាកាសដែលមនុស្សគ្រប់រូបអាចក្លាយជាអ្នកបង្កើតមាតិកាព័ត៌មាននៅលើអ៊ីនធឺណិត។ អ្នកបង្កើតមាតិកាព័ត៌មាននីមួយៗអាចផ្សព្វផ្សាយព័ត៌មានដែលអាចដល់មនុស្សជាច្រើន ដោយមិនចាំបាច់ត្រូវមានវគ្គបណ្តុះបណ្តាលជាក់លាក់ផ្នែកសារព័ត៌មាននោះឡើយ។ ផ្ទុយទៅវិញ អ្នកបង្កើតមាតិកាមេឌាបូរាណមានចំនួនកំណត់ ពួកគេភាគច្រើនទទួលបានការបណ្តុះបណ្តាលសម្រាប់វិជ្ជាជីវៈរបស់ពួកគេ។ ផ្នែកមួយចំនួននៃវិជ្ជាជីវៈទាំងនោះរួមមានអ្នកសារព័ត៌មាន អ្នកនិពន្ធ អ្នកសរសេរស្គ្រីប អ្នកថតរូប និងវិស្វករសំឡេង។

បរិមាណព័ត៌មានដែលអាចបញ្ជូនដោយប្រើមេឌាបូរាណអាស្រ័យលើចំនួនម៉ោងផ្សាយ ឬចំនួនទំព័រនៃកាសែតនោះ ខណៈដែលបរិមាណនៃព័ត៌មានដែលផ្តល់តាមរយៈអ៊ីនធឺណិតនៅមានកម្រិតនៅឡើយ ដែលផ្តល់ឱ្យអ្នកប្រើនូវការជ្រើសរើសប្រធានបទច្រើនក្នុងការផ្តល់ព័ត៌មានតាមតម្រូវការ។ បញ្ហាប្រឈមដែលអ្នកទស្សនាតែងតែជួបប្រទះនោះ គឺអំពីការស្វែងរកព័ត៌មានដែលទាក់ទងនឹងពួកគេ។

*មានចរន្តទិន្នន័យដែលបានបង្កើតជារៀងរាល់ថ្ងៃឥតឈប់ឈរនៅលើអ៊ីនធឺណិត។ វាមានបរិមាណច្រើនសន្ធឹកសន្ធាប់ណាស់ដែលយើងមិនអាចអានវាអស់ឡើយ។*

ប្រៀបធៀបទៅមេឌាបូរាណ ការផ្សព្វផ្សាយខ្លឹមសារនៅលើអ៊ីនធឺណិតមានតម្លៃថោកជាង និងរហ័សបំផុត។ អ្នកបង្កើតមាតិកាអាចផ្សព្វផ្សាយទស្សនៈ និងគំនិតរបស់ពួកគេអំពីជីវិតរស់នៅ នយោបាយ ឬទ្រឹស្តីវិទ្យាសាស្ត្រ ។ល។ ឥទ្ធិពលអ៊ីនធឺណិតបច្ចុប្បន្ន នៅលើវេបសាយមិនត្រឹមតែផ្តល់ព័ត៌មានដែលបានផ្សព្វផ្សាយដោយអ្នកនិពន្ធប៉ុណ្ណោះទេ ប៉ុន្តែក៏មានការផ្តល់មតិយោបល់ និងការពិភាក្សារបស់អ្នកអានផងដែរ។ ឥទ្ធិពលទៅវិញទៅមកនេះផ្តល់ឱ្យអ្នកប្រើនូវទស្សនៈជាច្រើនអំពីប្រធានបទណាមួយ ហើយពួកគេអាចជ្រើសរើសដោយសេរីនូវប្រធានបទមួយណាដែលពួកគេជឿទុកចិត្ត ទោះជាយ៉ាងណាក៏ដោយ ដោយសារគ្មានអ្នកគ្រប់គ្រងកែតម្រូវធ្វើឱ្យមានការបង្ហាញឡើងនូវពាក្យចចាមអារ៉ាម ពាក្យដែលគួរឱ្យស្អប់ និងព័ត៌មានមិនពិតដល់យើងថាជាព័ត៌មានដែលគួរឱ្យទុកចិត្តនៅលើអ៊ីនធឺណិត។

# ៣.២. មាតិកា និងទម្រង់នៃព័ត៌មាន

ទម្រង់ផ្សេងៗដែលអាចប្រើដើម្បីបង្ហាញខ្លឹមសារព័ត៌មានត្រូវបានគេហៅថា ទម្រង់នៃព័ត៌មាន ហើយវាជាអត្ថបទ រូបភាព សំឡេង និងវីដេអូ។ ផ្នែកដូចគ្នានៃព័ត៌មានអាចបំបែកជាផ្នែកផ្សេងៗជាច្រើននៃខ្លឹមសារ អាស្រ័យលើទម្រង់ព័ត៌មានដែលបានប្រើ និងគោលបំណង ព្រមទាំងសមត្ថភាពនៃអ្នកបង្កើតមាតិកា។ សារជាអត្ថបទត្រូវបានព្រាងយ៉ាងដូចម្តេច ឯកសារសំឡេងត្រូវបានបង្ហាញយ៉ាងដូចម្តេច ឬគុណភាពរូបភាពនៅក្នុងវីដេអូ ដែលនឹងជួយឱ្យយល់ខ្លឹមសារ និងទទួលយកខ្លឹមសារបាន។ ខណៈដែលមធ្យោបាយមេឌាបូរាណតែងត្រូវបានប្រើទម្រង់ទាំងនេះមួយ ឬពីរប៉ុណ្ណោះ (ឧ. អត្ថបទ និងរូបថតនៅក្នុងកាសែត) អ៊ីនធឺណិតអាចប្រើសមាសធាតុទាំងអស់នេះបញ្ចូលគ្នាបាន (ឧ. អត្ថបទ រូបថត វីដេអូ និងសំឡេង)។

ទូរទស្សន៍ វិទ្យុ កាសែត និងទស្សនាវដ្តីជាប្រភេទមេឌាដាច់ដោយឡែកពីអ៊ីនធឺណិត។ ការភ័យខ្លាចបាត់បង់ឥទ្ធិពល និងចំណូល មេឌាបូរាណក៏មានការប្រកួតប្រជែងស្វែងរកអ្នកមើលនៅលើអ៊ីនធឺណិតផងដែរតាមរយៈប្រភពព័ត៌មានផ្សេងៗ ដោយបង្កើតយុទ្ធសាស្ត្រទីផ្សារដើម្បីផ្តល់ព័ត៌មាន និងសេវាកម្មថ្មីៗនៅលើវេបសាយរបស់ពួកគេ ឬតាមរយៈកម្មវិធីណាមួយ។ គុណភាពនៃខ្លឹមសារព័ត៌មាននៅលើវេបសាយទាំងនេះ គឺស្រដៀងគ្នាទៅខ្លឹមសារមាតិកាព័ត៌មានអាជីពនៅក្នុងមេឌាបូរាណរបស់ពួកគេ។

*ទិន្នន័យនីមួយៗអាចបង្ហាញជាទម្រង់រូបវន្ត ឬលើអ៊ីនធឺណិត។*

# ៤. បំណិនអក្ខរកម្មមេឌា

តាមរយៈអ៊ីនធឺណិត ខ្លឹមសារព័ត៌មានពីអ្នកបង្កើតមាតិកាព័ត៌មានអាជីព និងមិនអាជីពគ្រាន់តែជាការចុចម្តងប៉ុណ្ណោះ។ យើងទាំងអស់គ្នាត្រូវការបំណិនអក្ខរកម្មមេឌាជាមូលដ្ឋានគ្រឹះដើម្បីអាចបកប្រែ យល់ដឹង និងបង្កើតព័ត៌មាន ការកម្សាន្ត និងអន្តរកម្មជាច្រើន។ មាតិកាព័ត៌មានជាញឹកញាប់កំណត់

ដោយប្រធានបទណាមួយដែលមនុស្សចាប់អារម្មណ៍ ប្រធានបទអាចមានដំណឹង ដូចជាការរញ្ជួយដីថ្មីៗបំផុតប្រទេសនេប៉ាល់ តន្ត្រីកម្សាន្តដូចជាការសម្តែងរបស់អ្នកចម្រៀងដែលពេញនិយម ព័ត៌មានបច្ចេកទេស ស្វែងរកការណែនាំ ឬពីវិធីប្រើថ្នាំណាមួយយ៉ាងដូចម្តេច។ មេឌាអាចមានឥទ្ធិពលលើការជឿជាក់របស់យើងតាមរយៈទម្រង់ព័ត៌មានជាទូទៅពិតនៅពេលដែលវាបង្ហាញពីព្រឹត្តិការណ៍ ឬភាពពិតប្រាកដ។ យើងត្រូវមានបំណិនវិភាគព័ត៌មានខ្លាំងដើម្បីបែងចែកភាពពិតពីទស្សនៈយល់ឃើញ ជំនឿ ឬពាក្យចចាមអារ៉ាម និងធ្វើការសម្រេចចិត្តផ្ទាល់ខ្លួនយើងអំពីអ្វីយើងត្រូវជឿ។ សារដែលយើងទទួលបានពីទម្រង់ផ្សេងៗនៃមេឌាតែងតែមានបំណងចង់ឱ្យយើងផ្លាស់ប្តូរទស្សនៈរបស់យើង។ ដូច្នេះយើងត្រូវពិនិត្យមើលព័ត៌មាន និងដំណឹងឱ្យបានច្បាស់លាស់ពីទីប្រភពជាច្រើន ពិគ្រោះគ្នាពីប្រភពផ្សេងៗ បើអាចធ្វើបាន។

ទោះបីជាអ្នកបង្កើតមាតិកាអាជីពបានទទួលការអប់រំជាអ្នកសារព័ត៌មានឯករាជ និងប្រកបដោយក្រមសីលធម៌រាយការណ៍ព្រឹត្តិការណ៍ពិតក៏ដោយ ពេលខ្លះមាតិកាព័ត៌មានក៏បានកែសម្រួលដោយទស្សនៈយល់ឃើញផ្ទាល់ខ្លួនរបស់អ្នកសរសេរ ឬតាមមធ្យោបាយដែលបញ្ជូនខ្លឹមសារនោះ។ នៅពេលព្រឹត្តិការណ៍ ឬភាពពិតត្រូវបានបង្ហាញដោយអ្នកបង្កើតមាតិកាព័ត៌មានផ្សេងៗគ្នា នោះខ្លឹមសារដែលបញ្ចូលអាចមានភាពខុសគ្នារវាងទស្សនៈ ឬគំនិតផ្សេងៗរបស់ពួកគេ។ ឧទាហរណ៍ អ្នកថតរូបអាចសម្រេចពីមនុស្ស និងវត្ថុណាដែលគួរឃើញនៅក្នុងរូបភាព ដកចេញ ឬដាក់ចូលនូវអ្វីមួយ ដូចជារូបភាពព្រឹត្តិការណ៍ដូចគ្នាអាចត្រូវបានថតផ្សេងគ្នាដោយអ្នកថតរូបដែលចង់ប្រាប់ពីសាច់រឿងតាមទស្សនៈរបស់ខ្លួន។



ខណៈដែលមេឌាបូរាណគួរមានអព្យាក្រឹត និងវត្ថុបំណងច្បាស់លាស់ ដោយមិនមានបន្ថែមទស្សនៈយល់ឃើញទាំងឡាយណាចំពោះព័ត៌មានដែលបានផ្សព្វផ្សាយ វាជាករណីកម្រមួយ ដែលពេលខ្លះភារកិច្ចនេះលំបាកសម្រេចបានណាស់។ ការសម្រេចថាដំណឹងគឺជាព្រឹត្តិការណ៍ពិត ឬមិនពិត ឬគួរបង្ហាញវាយ៉ាងដូចម្តេច អាស្រ័យលើគំនិត និងការវាយតម្លៃរបស់អ្នកកែសម្រួលនៃអង្គភាពមេឌានោះ។ អ្នកនិពន្ធ ពេលខ្លះច្របូកច្របល់ដោយការរងឥទ្ធិពលមនោគមវិជ្ជារបស់ម្ចាស់មេឌានោះ។ ប្រសិនបើអ្នកប្រើទទួលព័ត៌មានតាមរយៈតែទម្រង់មួយនៃមេឌាបូរាណ នោះគំនិត និងទស្សនៈយល់ឃើញរបស់បុគ្គលអាចមិនមានរងឥទ្ធិពលដោយសាច់រឿងដែលបានជ្រើស និងនរណាជាអ្នកពន្យល់វា។

ព័ត៌មានដែលបានផ្សព្វផ្សាយនៅលើអ៊ីនធឺណិតជានិច្ចកាលមិនបំពេញតាមស្តង់ដារវិជ្ជាជីវៈទេ ដោយសារវាគ្រាន់តែជាទស្សនៈយល់ឃើញរបស់អ្នកបង្កើតមាតិកាដែលលម្អៀង ឬមិនមានការបណ្តុះបណ្តាលច្បាស់លាស់។ ដោយសារបញ្ហានេះ អ្នកប្រើអ៊ីនធឺណិតចាំបាច់ត្រូវមានបំណិនអក្ខរកម្មមេឌាមូលដ្ឋានដើម្បីកំណត់បានថាព័ត៌មានណាដែលពួកគេអានឆ្លុះបញ្ចាំងពីការពិត និងទស្សនៈណាដែលជាព័ត៌មានមិនពិត។

ពេលខ្លះយើងមើលឃើញអ្វីដែលល្អជារបស់ពិត។ តាមធម្មតាគ្មាននរណាម្នាក់ធ្វើអ្វីមួយនៅលើអ៊ីនធឺណិតដោយមិនប្រាថ្នាចង់បានអ្វីនោះឡើយ។ ការសន្យាឱ្យរង្វាន់ ឬប្រាក់ ធម្មតាវាជាសារបន្លំឥតបានការ ដែលបានធ្វើឡើងដោយបុគ្គលក្នុងបំណងព្យាយាមលួចបន្លំអ្វីមួយពីយើងដូចជា៖ ប្រាក់, អាសយដ្ឋានអ៊ីមែល ឬពាក្យសម្ងាត់របស់យើង។ អ្នកគួរជៀសវាងការផ្តល់ជូនណាមួយដែលមិនទុកចិត្តអំពីការឱ្យប្រាក់ ឬឱ្យចុចចូលទៅកាន់អ្វីមួយដែលមានតម្លៃថ្លៃ។ ឧទាហរណ៍ប្រកាសក្នុង Facebook មួយដូចខាងក្រោម៖

**ទទួលបាន $20.000 យ៉ាងងាយស្រួល**



ទទួលបាន $20.000 ដោយក្លាយជាម្នាក់ក្នុងចំណោម ៣០០ នាក់ដំបូង គ្រាន់តែផ្តល់អាសយដ្ឋានអ៊ីមែលរបស់អ្នកក្នុងផ្នែកមតិយោបល់ខាងក្រោម។

**Like** - Bann Vouchheng ចូលចិត្តនេះ

ការផ្តល់ជូនហាក់ដូចជាមើលទៅល្អណាស់ថាជារឿងពិតប្រាកដ តាមពិតជារឿងបោកប្រាស់មិនពិតប៉ុណ្ណោះ។ បុគ្គលដែលប្រកាសផ្សាយជាក់ស្តែងចង់បានអាសយដ្ឋានអ៊ីមែលរបស់មនុស្សដែលចូលមើលទំព័រ Facebook របស់គេ ក្នុងបំណងដើម្បីបង្កឱ្យមានមេរោគវាយប្រហារកុំព្យូទ័ររបស់អ្នកទាំងនោះ ឬដើម្បីផ្ញើសារឥតបានការទៅពួកគេ។ អ៊ីមែលនឹងព្យាយាមលក់ផលិតផលអ្វីមួយដល់ពួកគេ ឬចង់បានអ្វីមួយផ្សេងពីពួកគេ ដូចជាពាក្យសម្ងាត់។ ទោះក្នុងករណីណាក៏ដោយ អ្នកត្រូវប្រាកដថាអ្នកដែលផ្តល់មតិតាមការប្រាប់នោះ នឹងមិនទទួលបានប្រាក់ 20.000 ដុល្លារ– ទោះបីពួកគេផ្តល់ព័ត៌មានរបស់ពួកគេក៏ដោយ។

មធ្យោបាយសំខាន់បំផុតដើម្បីការពារខ្លួនអ្នកពីការវាយប្រហារតាមរយៈសារឥតបានការ ព័ត៌មានមិនពិត ពាក្យបញ្ឆោត គ្រោងការណ៍ទុច្ចរិតណាមួយ អ្នកត្រូវមានការអប់រំ យល់ដឹងច្បាស់អំពីប្រភពនៃព័ត៌មាន។ តាមរយៈការរៀនបំណិនអក្ខរកម្មមេឌាមូលដ្ឋាន អ្នកនឹងត្រូវបង្កើតវិធីសាស្ត្រសួរដើម្បីកំណត់ ប្រសិនបើអ្វីដែលអ្នកអានឃើញ ឬឮជារឿងពិត។

**មើលដោយប្រុងប្រយ័ត្ន។ គិតឱ្យល្អិតល្អន់**



# ៤.១. កសាងបំណិនអក្ខរកម្មមេឌាសម្រាប់អ្នកប្រើ

បំណិនអក្ខរកម្មមេឌាទូទៅអាចអនុវត្តចំពោះមធ្យោបាយទាំងឡាយណា ដោយសារពួកគេទាក់ទងនឹងសំណួរដែលព័ត៌មានបានទទួលនិងព្យាយាមស្វែងរកប្រភពដែលអាចប្រើដើម្បីផ្ទៀងផ្ទាត់។ទោះជាយ៉ាងដូច្នេះក្តី ក៏មានបំណិនជាក់លាក់ជាច្រើនទៀតដែលអនុវត្តចំពោះមេឌាដែលអ្នកបានចូលប្រើ។ ឧទាហរណ៍ អ្នកអាចក្លាយជាអ្នកជំនាញក្នុងការស្វែងរកអ្វីមួយលើអ៊ីនធឺណិត ព្រោះអ្នកបានចូលប្រើកុំព្យូទ័រ និងចំណាយពេលច្រើនម៉ោងស្វែងរកប្រភពផ្សេងៗសម្រាប់ផ្នែកនៃព័ត៌មាន។ អ្នកអាចធ្វើឱ្យប្រសើរបំណិនរបស់អ្នកតាមរយៈការរៀនរបៀបវិភាគខ្លឹមសារព័ត៌មាន ទោះគេប្រើវាក្នុងទម្រង់បែបណាក៏ដោយ ដោយតែងតែឆ្លើយសំណួរអំពីខ្លឹមសារនោះ (អ្នកណា អ្វី ហេតុអ្វី ពេលណា កន្លែងណា របៀបណា) ដែលអាចជួយអ្នកយល់ប្រភពដើមនៃព័ត៌មាន។ កថាខណ្ឌខាងក្រោមបកស្រាយបន្ថែមអំពីសំណួរទាំងនោះ និងផ្តល់ឱ្យអ្នកនូវគំនិត និងឧបករណ៍សម្រាប់ពិនិត្យមើលវេបសាយ និងប្រកាសដែលគួរជឿជាក់បាន៖

**អ្នកណា**

ភាពជាអ្នកនិពន្ធ និងអ្នកទស្សនា (អ្នកណា) អ្នកណាជាអ្នកនិពន្ធខ្លឹមសារព័ត៌មាននេះ? តើអ្នកណាជាអ្នកទស្សនាគោលដៅ? តើមធ្យោបាយបានកំណត់អត្តសញ្ញាណអ្នកនិពន្ធមាតិកាព័ត៌មាននេះដែរឬទេ លក្ខណសម្បត្តិរបស់ពួកគេ និង ប្រសិនបើអាច ស្ថាប័នដែលបុគ្គលនោះធ្វើការ និងមនោគមវិជ្ជា និងគោលបំណងរបស់វា (ដូចជាការផ្តល់ដំណឹង, ការលក់ផលិតផល, ការផ្សព្វផ្សាយគំនិតនយោបាយ, ការផ្សព្វផ្សាយអំពីជំនឿសាសនា, ការការពារសិទ្ធិមនុស្ស ឬចែកចាយចំណេះដឹងផ្នែកវិទ្យាសាស្ត្រ)។ អ្នកគួរតែគិតពិចារណាផងដែរថាតើអ្នកសរសេរព័ត៌មានសម្រាប់អ្នកណា។ គិតអំពីថាអ្នកណាបានផលិត និងបង់ប្រាក់សម្រាប់ខ្លឹមសារព័ត៌មាន ក៏ដូចជាអ្នកណាជាអ្នកទស្សនាគោលដៅ ដែលអាចនាំអ្នកទៅជិតអ្វីដែលអាចឱ្យអ្នកកាត់សេចក្តីអំពីភាពគួរឱ្យជឿជាក់នៃព័ត៌មាននោះ។

**ហេតុអ្វី**

គោលបំណង (ហេតុអ្វី) ហេតុអ្វីអ្នកអភិវឌ្ឍបង្កើនខ្លឹមសារព័ត៌មាននេះ? តើអ្វីជាគោលបំណងនៃឯកសារ និងហេតុអ្វីវាត្រូវបានបង្កើតឡើង? គោលបំណងសាមញ្ញបំផុត គឺដើម្បីផ្តល់ព័ត៌មាន និងបញ្ចុះបញ្ចូល ឬដើម្បីកម្សាន្ត – ឬជាការផ្សំគ្នារវាងអ្វីទាំងបីនេះ។ គោលបំណងជាធម្មតានៃមេឌាបែបពាណិជ្ជកម្មគឺដើម្បីរកប្រាក់តាមរយៈការផ្សាយឈុតពាណិជ្ជកម្មខណៈដែលកំពុងបង្ហាញកម្មវិធីកម្សាន្ត ឬផ្តល់ព័ត៌មានអំពីប្រធានបទដែលអ្នកទស្សនាចាប់អារម្មណ៍ថាសំខាន់។ វីដេអូតាម YouTube ត្រូវបានបង្កើតឡើងដើម្បីកម្សាន្តដោយរកប្រាក់តាមរយៈការផ្សាយពាណិជ្ជកម្ម ឬការឧបត្ថម្ភ។ គោលបំណងនៃបណ្តាញមួយចំនួនធ្វើឡើងដើម្បីបញ្ចុះបញ្ចូលអ្នកអានអំពីគំនិតរបស់ពួកគេ ដែលអាចជារឿងនយោបាយ, សាសនា ឬផ្នែកនៃចលនាសង្គមក្នុងគោលបំណងផ្លាស់ប្តូរសង្គម។ គំនិតទាំងនេះត្រូវបានបង្ហាញថាជារឿងពិត ដូច្នេះអ្នកអានត្រូវតែស្វែងរកដោយប្រើការកាត់សេចក្តីផ្ទាល់ខ្លួនដើម្បីគិតពិចារណាថា ពួកគេយល់ព្រមជាមួយព័ត៌មានទាំងនោះ ឬមិនយល់ព្រម ដោយរកមើលប្រភពផ្សេងៗនៃព័ត៌មានដើម្បីបញ្ជាក់ព័ត៌មាននោះ។

**អ្វី របៀបណា**

ខ្លឹមសារព័ត៌មាន (អ្វី របៀបណា) ក្នុងករណីខ្លះ វាជាដំណឹងរបស់ស្ថាប័នដែលមានគោលបំណងផ្ទាល់ខ្លួនរបស់ពួកគេចំពោះព័ត៌មានបែបណាដែលត្រូវបង្ហាញ ដោយដាក់បញ្ចូលគំនិតរបស់ម្ចាស់ព័ត៌មាន

ចំពោះដំណឹងដែលជ្រើសរើស និងរបៀបដែលរឿងនៃដំណឹងទាំងនោះត្រូវបង្ហាញ។ អ្នកដែលមានអក្ខរកម្មមេឌានឹងសួរអំពីខ្លឹមសារព័ត៌មាន និងបំណងនៃខ្លឹមសារនោះ រួចសួរថាតើវាមានបង្កប់នូវពាណិជ្ជកម្ម ឬជាគំនិតរបស់អ្នកណាម្នាក់។

**កន្លែងណា ពេលណា**

បរិបទ (កន្លែងណា, ពេលណា) ស្វែងយល់ពេលណា, កន្លែងណា និងមូលហេតុដែលខ្លឹមសារព័ត៌មានត្រូវបានបង្កើត និងតើត្រូវចែករំលែកវាជាមួយអ្នកទស្សនាយ៉ាងណា ដោយផ្ដល់ឱ្យយើងនូវគំនិតប្រសើរបំផុតអំពីគោលបំណងរបស់វា និងតើវាអាចមានភាពលម្អៀងកម្រិតណា។

**ពិត ក្លែងក្លាយ**

ភាពគួរឱ្យជឿជាក់៖ បំណិនអក្ខរកម្មមេឌាសំខាន់បំផុត គឺការមានលទ្ធភាពវាយតម្លៃថាតើខ្លឹមសារព័ត៌មាននោះគួរឱ្យជឿជាក់ឬយ៉ាងណា។ តើវាបរិយាយអំពីព្រឹត្តិការណ៍ពិត ឬគ្រាន់តែជាទស្សនៈយល់ឃើញរបស់បុគ្គល? តើវាមានបំណងបញ្ចុះបញ្ចូលមនុស្សឱ្យធ្វើតាមគំនិតណាមួយដែរឬទេ? តើវាជាការផ្សាយពាណិជ្ជកម្ម? តើមានប្រភពនៃព័ត៌មាន ឬគំនិតនោះច្បាស់លាស់ទេ? សូមចងចាំថាការសរសេររៀបរាប់អំពីព្រឹត្តិការណ៍ពិតអាចបញ្ជាក់បានថាឃ្លាសរសេរនោះប្រើប្រាស់គុណនាម ឬគុណកិរិយា ដូចជា ប្រសើរ ស្អាត ល្អ តែងតែ មិនដែល និងឆ្ងាញ់ ដែលឆ្លុះបញ្ចាំងពីទស្សនៈយល់ឃើញរបស់បុគ្គល។ អ្នកអានអក្ខរកម្មមេឌាជានិច្ចកាលតែងតែពិនិត្យមើលប្រភពព័ត៌មានច្រើនដើម្បីអាចកំណត់បានថាព័ត៌មានជាការពិត ឬគ្រាន់តែជាទស្សនៈយល់ឃើញរបស់បុគ្គល និងតើអាចជឿវាបានដែរឬទេ។ ប្រសិនបើព័ត៌មាននោះចាសពេក វាអាចហួសសម័យ (គ្មានបច្ចុប្បន្នភាព) និងលែងសុក្រឹតទៀតហើយ។



# ៤.២. កសាងបំណិនអក្ខរកម្មមេឌាសម្រាប់អ្នកបង្កើតមាតិកាព័ត៌មាន

ដោយបន្ថែមលើបំណិនផ្សេងៗ អ្នកបង្កើតព័ត៌មានត្រូវសម្រេចថាបច្ចេកទេស និងមេឌាអ្វីត្រូវប្រើដើម្បីបង្ហាញឱ្យឃើញខ្លឹមសារព័ត៌មានរបស់ពួកគេថាពិតប្រាកដត្រឹមត្រូវតាមដែលអាចធ្វើបាន។ ក្នុងនាមជាអ្នកបង្កើតមេឌា និងអ្នកនិពន្ធ ពួកគេគួរតែវិភាគឱ្យបានល្អិតល្អន់អំពីបច្ចេកទេសជាអ្នកបង្កើតមាតិកាព័ត៌មានអាជីព និងអនុវត្តព័ត៌មានដែលពួកគេគិតថាមានសារៈសំខាន់បំផុតសម្រាប់បង្កើតមេឌាផ្ទាល់ខ្លួនរបស់ពួកគេ។ ដូចដែលអ្នកណាម្នាក់អាចរៀនរចនាលិខិតអញ្ជើញអាពាហ៍ពិពាហ៍ យើងទាំងអស់គ្នាក៏អាចរៀនអំពីការបង្ហាញខ្លឹមសារព័ត៌មានដោយបង្កើតរូបភាពដែលចាប់អារម្មណ៍ អត្ថបទដែលមានន័យ ឬវីដេអូដែលគេចូលចិត្ត។

អ្នកបង្កើតក៏ត្រូវតែចេះកំណត់ថាអ្នកណាម្នាក់នឹងជាអ្នកទស្សនាគោលដៅសម្រាប់មាតិកាព័ត៌មាននេះ ដោយយល់ថាមិនត្រូវបង្ហាញព័ត៌មានដូចគ្នានេះដល់មនុស្សគ្រប់គ្នាដែលមិនចង់ដឹងរឿងនេះទេ។ អ្នកបង្កើតប្រកបដោយប្រសិទ្ធភាពតែងតែដឹងថាមនុស្សនឹងបកស្រាយខ្លឹមសារព័ត៌មានអាស្រ័យតាមអាយុ វប្បធម៌ បទពិសោធន៍ និងអត្តចរិតរបស់ពួកគេ។ ឧទាហរណ៍ វេបសាយរបស់សាលាគួរតែត្រូវបានរចនា រៀបចំឡើងសម្រាប់បង្ហាញព័ត៌មានដល់អាណាព្យាបាលសិស្ស លោកគ្រូ/អ្នកគ្រូ និងប្រហែលសិស្សានុសិស្ស ប៉ុន្តែមិនមែនសម្រាប់មនុស្សទាំងអស់នោះទេ។

> *វេបសាយដែលមានប្រសិទ្ធភាពត្រូវតែភ្ជាប់ទំនាក់ទំនងអ្នកទស្សនាតាមរយៈទម្រង់ដែលបានប្រើក្នុងការផ្ដល់ព័ត៌មាន។*

ការរចនាវេបសាយប្រកបដោយប្រសិទ្ធភាពតែងតែមានការច្នៃប្រឌិតរចនារូបភាពច្រើនជាង និងមានរចនាសម្ព័ន្ធម៉ឺនុយនៃវេបសាយនោះ ហើយការរចនាត្រូវតែផ្សារភ្ជាប់អ្នកទស្សនាតាមរយៈទ្រង់ទ្រាយដែលបានប្រើដើម្បីផ្ដល់ព័ត៌មានដល់ពួកគេបានងាយស្រួលយល់។ នៅពេលដែលអ្នកទស្សនាចាប់អារម្មណ៍ ពួកគេអាចនឹងចំណាយពេលមើលវេបសាយរបស់យើងដោយជក់ចិត្ត។ នៅក្នុងបរិស្ថានជំនួញវិញ អ្នកគ្រប់គ្រងវេបសាយ, អ្នករចនា និងអ្នកបង្កើតមាតិកាតែងតែធ្វើការជាមួយគ្នាដើម្បីបង្កើតភាពទាក់ទាញ ការផ្ដល់ព័ត៌មានដែលគេមិនទាន់ដឹង និងមាតិកាព័ត៌មានដែលទាក់ទង ក្នុងគោលបំណងបង្កើនចំនួនអ្នកទស្សនាវេបសាយ និងមានអតិថិជនច្រើនឡើង។

តួនាទីសំខាន់បំផុតរបស់អ្នកគ្រប់គ្រងវេបសាយអាជីពម្នាក់ គឺធ្វើយ៉ាងណាទាក់ទាញអ្នកមើលច្រើនទៅវេបសាយរបស់គេ។ នៅពេលបង្ហាញលទ្ធផល ម៉ាស៊ីនស្វែងរកដូចជា Google, ឬ Bing ចង់បង្ហាញវេបសាយដំបូងដែលពួកគេគិតថាមានអ្នកមើលចូលចិត្តច្រើន។ ការបង្កើតវេបសាយតែងតែធ្វើឱ្យប្រសើរលើចំណាត់ថ្នាក់នៅក្នុងម៉ាស៊ីនស្វែងរក ហើយអ្នកគ្រប់គ្រងវេបសាយបង្កើតនូវកម្មវិធីតាមដាននៅក្នុងកូដ HTML របស់វេបសាយនោះដើម្បីបន្តរាប់ចំនួនអ្នកទស្សនាវេបសាយរបស់ពួកគេ។ ពាក្យគន្លឹះ ការបង្កើតទំព័រថ្មីៗ និងការប្រើពាណិជ្ជកម្មនៅលើទំព័រ គឺជាឧទាហរណ៍នៃកត្តាចំណាត់ថ្នាក់របស់ម៉ាស៊ីនស្វែងរកទាំងអស់។

**នៅឆ្នាំ ២០១៥ Google មានចំនួនស្វែងរកជាមធ្យម ៤០.០០០ ក្នុងមួយវិនាទី**



*អ្នកបង្កើតមាតិកាដែលមានក្រមសីលធម៌តែងតែស្រាវជ្រាវធ្វើឱ្យប្រាកដនៃព័ត៌មានដែលបង្ហាញថាជាព្រឹត្តិការណ៍ពិត។*

ភាពជឿទុកចិត្ត គឺសំខាន់ណាស់ក្នុងការទាក់ទាញអ្នកមើល។ អ្នកបង្កើតមាតិកាដែលមានក្រមសីលធម៌តែងធ្វើការស្រាវជ្រាវដើម្បីប្រាកដថាឃ្លាប្រយោគដែលបានបង្ហាញជារឿងពិតដែលឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍ពិត។ ទស្សនៈយល់ឃើញ គឺជាបញ្ហាផ្សេងមួយ ដោយសារទស្សនៈយល់ឃើញអាចបញ្ចេញបានដោយសេរី ដូច្នេះវាជាការសម្តែងចេញក្នុងនាមបុគ្គល និងជាទស្សនៈរបស់បុគ្គលដែលអាចមិនមែនជាការពិត។ អ្នកមើលនឹងសម្រេចចិត្តថាតើពួកគេត្រូវជឿជាក់ទស្សនៈទាំងនោះ ឬមិនជឿ។ កេរ្តិ៍ឈ្មោះត្រូវកសាងគ្រប់ពេល និងអ្នកបង្កើតមាតិកាព័ត៌មានដែលមានកេរ្តិ៍ឈ្មោះល្អចង់ឱ្យព័ត៌មានរបស់ពួកគេជាប្រភពព័ត៌មានដែលគួរឱ្យទុកចិត្តជាពិសេសពួកគេចង់ឱ្យអ្នកមើលត្រឡប់មកទស្សនាវេបសាយរបស់គេម្តងទៀត។ នៅពេលអ្នកបង្កើតមាតិកាព័ត៌មានបណ្តាញអនុវត្តបំណិនមេឌាមូលដ្ឋានបាន និងខិតខំធ្វើយ៉ាងណាឱ្យព័ត៌មានសុក្រឹត មានភាពត្រឹមត្រូវនិងភាពពិត អ្នកប្រើមេឌានឹងជឿទុកចិត្តវេបសាយនោះជាប្រភពព័ត៌មានដែលគួរឱ្យទុកចិត្ត ហើយនឹងមិនចាំបាច់ត្រូវផ្ទៀងផ្ទាត់ជាមួយប្រភពផ្សេងៗដើម្បីពិនិត្យភាពត្រឹមត្រូវនោះទេ។

គួរមានការពិចារណាក្រមសីលធម៌មួយផ្សេងទៀតចំពោះការលួចចម្លងស្នាដៃច្នៃប្រឌិតរបស់អ្នកផ្សេង។ គិតអំពីអ្វីមួយ ដែលអ្នកបានសរសេរ ឬរចនា និងអ្វីដែលអ្នកមានមោទនភាព។ ចម្រៀងស្នេហាមួយដែលអ្នកបានតែងនិពន្ធ ព័ត៌មានរាយការណ៍អំពីខ្លាឃ្មុំនៅកម្ពុជា ឬការថតរូបភាពជនជាតិអាមេរិកញ៉ាំអាពីងទាំងនេះជាព័ត៌មានដែលអ្នកចង់ទាមទារថាអ្នកជាអ្នកបង្កើតវា ឬជាម្ចាស់។ អ្នកប្រហែលជាមិនសប្បាយចិត្តនៅពេលអ្នកដឹងថាមានគេលួចចម្លងស្នាដៃ និងបានប្រើការច្នៃប្រឌិតរបស់អ្នកដោយគ្មានការអនុញ្ញាត។ ការរក្សាសិទ្ធិផ្តល់នូវភាពស្របច្បាប់ និងកម្មសិទ្ធិដែលទប់ស្កាត់អ្នកផ្សេងពីការលួចចម្លង ឬផ្លាស់ប្តូរការងាររបស់អ្នក និងតវ៉ាទាមទារថាជារបស់ដែលគេបង្កើត។ ប្រសិនបើអ្នកគ្រប់គ្រងវេបសាយចង់ប្រើប្រាស់មាតិកាព័ត៌មានដែលអ្នកបានបង្កើត វាអាចធ្វើដូច្នេះបាន លុះត្រាតែមានការស្នើសុំសិទ្ធិអនុញ្ញាតពីអ្នក ឬដាក់សម្គាល់ខ្ចីបញ្ជាក់ថាមាតិកាជារបស់អ្នក។ អ្នកបង្កើតមាតិកាព័ត៌មានទាំងអស់ត្រូវដឹងថាការកែប្រែការងាររបស់អ្នកណាម្នាក់តិចតួច រួចហើយតវ៉ាទាមទារថាវាជារបស់ខ្លួនអ្នកបង្កើត នោះជាការរំលោភបំពានច្បាប់រក្សាសិទ្ធិ។ អ្នកគ្រប់គ្រងវេបសាយ និងអ្នកបង្កើតមាតិកាព័ត៌មានផ្សេងៗមានកាតព្វកិច្ចត្រូវអនុវត្តតាមច្បាប់រក្សាសិទ្ធិ។

*អ្នកប្រហែលជាអាក់អន់ចិត្ត ប្រសិនបើអ្នកដឹងថាអ្នកណាម្នាក់បានលួចចម្លង និងប្រើភាពច្នៃប្រឌិតរបស់អ្នកដោយមិនបានសុំការអនុញ្ញាតពីអ្នក។*

អ្នកប្រហែលបានឃើញនិមិត្តសញ្ញានេះជាច្រើននៅលើវេបសាយ ឬឯកសារដែលបោះពុម្ព។ និមិត្តសញ្ញា © ឬសញ្ញារក្សាសិទ្ធិជាធម្មតាតំណាងឱ្យការរក្សាសិទ្ធិ និងវាផ្តល់ការការពារដល់អ្នកនិពន្ធ។

## មេរៀនសង្ខេប

យើងរស់នៅក្នុងបរិបទពហុមេឌា។ មេឌាបូរាណ អ៊ីនធឺណិត និងទូរសព្ទចល័ត ទាំងអស់ គឺជាទម្រង់នៃប្រព័ន្ធផ្សព្វផ្សាយចម្រុះ ផ្សាយទៅមនុស្សរាប់លាននាក់ក្នុងពេលតែមួយលើពិភពលោក។ ជារៀងរាល់ថ្ងៃយើងតែងតែជួបប្រទះព័ត៌មានទាំងឡាយណាដែលនាំមកឱ្យយើងតាមរយៈទម្រង់នៃពាក្យ រូបភាព និងសំឡេង។ អ៊ីនធឺណិត គឺជាមធ្យោបាយដ៏ធំបំផុតមួយក្នុងការពង្រីកការផ្សព្វផ្សាយព័ត៌មានដល់មនុស្សជាច្រើននៅក្នុងពិភពអ៊ីនធឺណិត ឬអាចកម្សាន្ត និងធ្វើសកម្មភាពទៅវិញទៅមកជាមួយគ្នាបានផងដែរ។

សារមេឌាត្រូវបានបង្កើតឡើងដោយអ្នកបង្កើតមាតិកាព័ត៌មាន។ បន្ថែមពីអ្វីដែលអ្នកបង្កើតមាតិកាព័ត៌មាននៃមេឌាបូរាណ បច្ចេកវិទ្យាសម័យបច្ចុប្បន្នអាចឱ្យមនុស្សគ្រប់គ្នាផ្សព្វផ្សាយវេបសាយ ឬអត្ថបទ រូបភាព សំឡេង ឬវីដេអូនៅលើអ៊ីនធឺណិត។ អ្នកប្រើអ៊ីនធឺណិតអាចស្វែងរកប្រធានបទ និងទស្សនៈផ្សេងៗដែលទូលំទូលាយបានប្រសើរជាងការផ្សាយនៅតាមទូរទស្សន៍ ឬវិទ្យុ ឬនៅតាមកាសែត និងទស្សនាវដ្ដីដែលបានបោះពុម្ព។ មានព័ត៌មានច្រើនណាស់ ដែលអាចពិត ឬមិនពិត បានបង្កើតឡើងនៅលើអ៊ីនធឺណិតដែលបានក្លាយជាច្រកមួយដ៏សំខាន់សម្រាប់អ្នកប្រើក្នុងការស្វែងរកព័ត៌មាន និងអភិវឌ្ឍបំណិនអក្ខរកម្មមេឌាមូលដ្ឋាន ដើម្បីក្លាយជាពលរដ្ឋដែលមានការអប់រំ និងទទួលបានព័ត៌មានច្បាស់លាស់។

បំណិនអក្ខរកម្មមេឌាអាចឱ្យអ្នកប្រើវាយតម្លៃភាពដែលគួរឱ្យទុកចិត្តបាននៃព័ត៌មាននៅលើអ៊ីនធឺណិតដោយសួរសំណួរអំពីអ្នកណា, អ្វី, ពេលណា, កន្លែងណា, យ៉ាងដូចម្ដេច និងមានគោលបំណងអ្វីក្នុងការផ្សព្វផ្សាយព័ត៌មានបែបនេះ។

សម្រាប់អ្នកគ្រប់គ្រងវេបសាយ និងអ្នកបង្កើតមាតិកា ការអនុវត្តបំណិនអក្ខរកម្មមេឌាទាក់ទងនឹងការយល់ដឹងអំពីការបង្ហាញព័ត៌មានដែលពាក់ព័ន្ធ និងការវាយតម្លៃអ្នកប្រើរបស់ពួកគេ ដែលបង្ហាញវាតាមគ្រប់ករណីនីមួយៗដែលជាការពិត៖ ព្រឹត្តិការណ៍ពិត ឬទស្សនៈ បន្ទាប់មកបង្កើតទំនុកទុកចិត្តចំពោះអ្នកអានព័ត៌មានរបស់ខ្លួន។ សម្រាប់អ្នកបង្កើតមាតិកាព័ត៌មាន វាពិតជាសំខាន់ណាស់ក្នុងការយល់ដឹងអំពីគោលបំណងនៃការរក្សាសិទ្ធិ និងការគោរព។



# លំហាត់

## លំហាត់ ៣

ជាអ្នកអក្ខរកម្មមេឌាម្នាក់ អ្នកត្រូវតែអាចស្គាល់ថាប្រយោគនៃព័ត៌មានណាមួយដែលពិតប្រាកដ ឬគ្រាន់តែជាទស្សនៈ ឬពិតខ្លះមិនពិតខ្លះ។ នៅពេលប្រយោគមានព័ត៌មានទាំងពិត និងទស្សនៈយល់ឃើញ វាគួរតែត្រូវបានចាត់ទុកជាថាជាទស្សនៈយល់ឃើញ។ ព្រឹត្តិការណ៍ពិតជាអ្វីដែលបានកើតឡើងមានពិតប្រាកដ ឬនៅតែស្ថិតមានជានិច្ច ឬអាចមានការបញ្ជាក់ដោយភស្តុតាងត្រឹមត្រូវ។ ទស្សនៈគ្រាន់តែជាអ្វីដែលយើងជឿជាក់ថាបានកើតឡើង អាចមាន ឬជាការពិត (ឧ. ថ្ងៃស្អែកអាចនឹងមានភ្លៀង)។ ពេលខ្លះប្រយោគអាចជាការរួមបញ្ចូលគ្នារវាងការពិត និងទស្សនៈ ដែលករណីខ្លះវាអាចត្រូវបានចាត់ទុកថាជាទស្សនៈយល់ឃើញរបស់បុគ្គល។

### ៣ក

រកមើលសន្លឹកប្រយោគទាំងអស់ដែលនៅខាងក្រោមនៅក្នុងមគ្គុទ្ទេសក៍ជំនួយរបស់អ្នក។ សូមអានប្រយោគនីមួយៗ និងសម្រេចចិត្តថាតើប្រយោគណាជាការពិត ឬទស្សនៈ។ អ្នកត្រូវតែធ្វើការឆ្លើយតបនៅលើសន្លឹកដោយចុចនៅលើប្រអប់ធីកដែលនៅបន្ទាប់ប្រយោគនីមួយៗអំពីការសម្រេចចិត្តរបស់អ្នក។ សូមរក្សាទុកសន្លឹកដែលអ្នកបំពេញរួចនៅក្នុងថតក្រុមរបស់អ្នក។

សេចក្តីណែនាំ៖ សម្រាប់តែមើលប៉ុណ្ណោះ។ កុំសរសេរវានៅក្នុងសៀវភៅនេះ។ សូមអានប្រយោគនីមួយៗ និងធ្វើការសម្រេចចិត្តថាវាជាការពិត ឬទស្សនៈ៖

១. វេបសាយអាចមានតែមួយទំព័រ ឬអាចមានរាប់រយទំព័រ។
២. វេបសាយត្រូវមានការថែទាំដែលចំណាយប្រាក់ច្រើន និងត្រូវធ្វើបច្ចុប្បន្នភាពជាញឹកញាប់។
៣. អ្នកគ្រប់គ្រងវេបសាយ គឺជាអ្នកគ្រប់គ្រងម៉ាស៊ីនមេ និងមានការងារងាយស្រួល។
៤. អ្នកដែលធ្វើការខាងវេបសាយត្រូវតែបញ្ចប់សញ្ញាបត្រពីសាកលវិទ្យាល័យដើម្បីអាចស្វែងរកការងារបាន។
៥. ការងាររចនាវេបសាយត្រូវការបំណិនទំនាក់ទំនងខ្លាំង។
៦. មេឌាបុរាណមានភាពងាយស្រួលជាង និងលឿនជាងដើម្បីអានព័ត៌មានជាងការប្រើអ៊ីនធឺណិត។
៧. ជា ស៊ុនជាណែត និងផុន គឿង គឺជាអ្នកសារព័ត៌មានដែលប្រើមេឌាដើម្បីបង្រៀនអំពីការប្រឆាំងអំពើហិង្សា និងសុខភាពល្អ។
៨. កូដ HTML គឺងាយស្រួលណាស់។
៩. កាសែត និងទស្សនាវដ្តី គឺជាមេឌាទ្រង់ទ្រាយធំអាចផ្ញើព័ត៌មានទៅមនុស្សច្រើនបានក្នុងពេលតែមួយ។
១០. ពេលខ្លះមាតិកាព័ត៌មានតាមអ៊ីនធឺណិតមានការចាប់អារម្មណ៍ ប៉ុន្តែខុស។

១១. មានតែមនុស្សដែលជាវិចិត្រករទេ ទើបអាចក្លាយជាអ្នកបង្កើតមាតិកា ព័ត៌មាន
១២. មនុស្សចំណាយពេលឥតប្រយោជន៍ច្រើនលើការប្រើប្រាស់ទូរសព្ទទំនើប។
១៣. ប្រជាជនកម្ពុជាមានទូរសព្ទចល័តច្រើនជាងកុំព្យូទ័រផ្ទាល់ខ្លួន។

## ៣ខ

នៅផ្នែកបន្ទាប់ សូមសរសេរប្រយោគមួយដែលជាការពិត និងមួយទៀតជាទស្សនៈសម្រាប់ប្រធានបទនីមួយៗខាងក្រោម៖ ទូរសព្ទចល័ត សិស្សានុសិស្ស វេបសាយ និងអ្នកបង្កើតមាតិកាព័ត៌មាន។

## លំហាត់ ៤

អ្នកនឹងស្នើសុំឱ្យធ្វើការវិភាគទំព័របណ្ដាញ និងឆ្លើយសំណួរស្ដីពីគុណភាព និងភាពជឿទុកចិត្តនៃព័ត៌មានដែលបានបង្ហាញ ក៏ដូចជាការផ្ដល់ទស្សនៈរបស់អ្នកអំពីគុណភាពនៃវេបសាយ។

## ៤ក

(សម្រាប់សិស្សដែលមានអ៊ីនធឺណិត)៖ នៅលើកុំព្យូទ័ររបស់អ្នក សូមចូលទៅគេហទំព័រគ្រូ www.krou.moeys.gov.kh បន្ទាប់មកជ្រើស __

ក) ធ្វើការវិភាគទំព័របណ្ដាញគំរូមួយ។ ចូរពិភាក្សានៅក្នុងក្រុមរបស់អ្នក និងបង្កើតបញ្ជីធាតុផ្សេងៗនៃទំព័របណ្ដាញ។ បែងចែកភាពខុសគ្នារវាងមាតិកាព័ត៌មានចម្បង និងព័ត៌មានបន្ថែម។

ខ) សូមមើលតារាងខាងក្រោម។ អ្នកអាចរកមើលតារាងនេះនៅក្នុងមគ្គុទ្ទេសក៍ជំនួយក្នុងផ្នែក .....។ នៅក្នុងក្រុមរបស់អ្នក សូមធ្វើការពិភាក្សាសំណួរនីមួយៗខាងក្រោម និងសរសេរចម្លើយរបស់អ្នកនៅក្នុងឯកសារដែលមាននៅក្នុងមគ្គុទ្ទេសក៍ជំនួយដែលបានផ្ដល់ឱ្យ។ បន្ទាប់ពីបញ្ចប់ សូមរក្សាវាទុកនៅក្នុងថតក្រោមរបស់អ្នក។

| |
|---|
| តើវាជាវេបសាយអាជីព និងអ្នកស្គាល់វាយ៉ាងដូចម្តេច ? |
| តើវេបសាយនេះជាកម្មសិទ្ធិរបស់អ្នកណា ? |
| តើម្ចាស់វេបសាយមានគោលបំណងអ្វីក្នុងការផ្តល់ព័ត៌មាននេះ ? |
| តើអ្វីជាវត្ថុបំណងនៃព័ត៌មាន ឬមានទស្សនៈដែលបាត់ ? |
| តើសម្រង់ព័ត៌មានមានប្រភពដែលទុកចិត្តដែរឬទេ ? |
| តើវាប្រើភាសាដែលអាចយល់បានដែរឬទេ ? |
| តើវាឆ្លើយតបសំណួរ (គន្លឹះ) សំខាន់ខាងក្រោមដែរឬទេ ?<br>• តើវានិយាយអំពីអ្វីដែរ ?<br>• តើពាក់ព័ន្ធអ្នកណាខ្លះ ហើយអ្នកណាជាអ្នកនិពន្ធ ?<br>• តើវាកើតឡើងនៅកន្លែងណា ?<br>• តើវាកើតឡើងពេលណាដែរ ?<br>• ហេតុអ្វីបានជាវាកើតឡើង ?<br>• តើវាកើតឡើងយ៉ាងដូចម្តេច ? |
| តើអ្នកចង់ដឹងអ្វីផ្សេងទៀតដែរឬទេ ? |

គ) សូមធ្វើការពិភាក្សានៅក្នុងក្រុមរបស់អ្នកថាតើសំណួរទាំងនេះអាចធ្វើឱ្យប្រសើរអក្ខរកម្មមេឌារបស់អ្នក និងអាចជួយអ្នកស្វែងយល់មាតិកាព័ត៌មានផ្សេងៗដូចជាអត្ថបទកាសែត ការផ្សាយតាមវិទ្យុ និងកម្មវិធីទូរទស្សន៍ផងដែរ។ សូមសរសេរប្រយោគសង្ខេបអំពីហេតុអ្វីអ្នកគិតថាអក្ខរកម្មមេឌាមានសារៈសំខាន់។ សូមរក្សាទុកប្រយោគនេះនៅក្នុងថតក្រុមរបស់អ្នក។

## សំណួរត្រិះរិះ

១. តើអ្វីជាអក្ខរកម្មមេឌា និងហេតុអ្វីវាសំខាន់ ?
២. សូមពន្យល់ពាក្យ មេឌាបោះពុម្ព មេឌាអេឡិចត្រូនិក មេឌាបូរាណ និងប្រព័ន្ធផ្សព្វផ្សាយចម្រុះ។ សូមឱ្យឧទាហរណ៍សម្រាប់មេឌានីមួយៗ។
៣. ហេតុអ្វីត្រូវមានស្ថានីយវិទ្យុ កាសែត និងទូរទស្សន៍ផ្សាយនៅលើអ៊ីនធឺណិត ?
៤. ចូរពន្យល់ហេតុអ្វីអ្នកត្រូវមានបំណិនអក្ខរកម្មមេឌាដើម្បីវាយតម្លៃវេបសាយ។
៥. ចូរអធិប្បាយអំពីឧទាហរណ៍បីនៃបំណិនសំណួរអក្ខរកម្មមេឌាសម្រាប់អ្នកប្រើ។
៦. កំណត់ឧទាហរណ៍បីនៃបំណិនអក្ខរកម្មមេឌាសម្រាប់អ្នកបង្កើតមាតិកាព័ត៌មាន។

ជំពូកទី ៤ | ការរចនា

# មេរៀនទី ៧

# ការអភិវឌ្ឍវេបសាយ

## នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពី៖

១. យល់ដឹងអំពីភាពផ្សេងគ្នារវាងទំព័របណ្ដាញមិនប្រែប្រួល (ស្ដាទិក) និងប្រែប្រួល (ឌីណាមិក) និងមូលហេតុដែលត្រូវមានទំព័រប្រែប្រួល

២. យល់ដឹងអំពីពុម្ពគំរូ និងមូលដ្ឋានទិន្នន័យ ព្រមទាំងរបៀបដែលវាផ្សំគ្នាដើម្បីបង្កើតវេបសាយភាគច្រើន

៣. យល់ដឹងអំពីអ្វីទៅជាប្រព័ន្ធគ្រប់គ្រងមាតិកាព័ត៌មាន និងតើវាជួយសម្រួលការងាររបស់អ្នករចនា និងអ្នកសរសេរកូដកម្មវិធីបានយ៉ាងដូចម្ដេច។

# ផ្នែក ក - បណ្ដាញឌីណាមិក

## ១. ទំព័របណ្ដាញមិនប្រែប្រួល និងប្រែប្រួល

វេបសាយត្រូវបានបង្កើតឡើងដោយទំព័របណ្ដាញដែលចែកចាយទៅអ្នកប្រើនៅពេលពួកគេស្នើសុំ ឬក៏តាមរយៈការចុចតំណដែលនាំទៅកាន់ទំព័រនោះ ឬនៅពេលអ្នកប្រើសរសេរអាសយដ្ឋានពេញលេញនៃទំព័របណ្ដាញនោះនៅក្នុងកម្មវិធីអ៊ីនធឺណិត។ ទំព័របណ្ដាញត្រូវបានសរសេរជាភាសាដែលគេហៅថា HTML ដែលពិពណ៌នារចនាសម្ព័ន្ធ និងប្លង់នៃទំព័រ ក៏ដូចជាមាតិកាព័ត៌មានដែលជួយក្នុងការបង្ហាញ (អត្ថបទ រូបភាព វីដេអូ ឬសំឡេង)។ នៅលើវេបសាយជាច្រើន ទំព័រ HTML ទាំងនេះត្រូវបានបង្កើតដោយអ្នករចនាវេបសាយ និងរក្សាទុករួចជាស្រេចនៅក្នុងម៉ាស៊ីនមេច្បាស់លាស់ ដោយហេតុថាវានឹងបង្ហាញនៅពេលអ្នកប្រើស្នើសុំវា។




នៅលើវេបសាយផ្សេងៗ ទំព័រទាំងនេះពិតជាមិនមានស្រាប់ទេមុនពេលពួកគេស្នើសុំ ទំព័រ HTML ត្រូវបង្កើតឡើង និងចែកចាយទៅអ្នកប្រើតាមរយៈវេបសាយនៅពេលវេលាដែលពួកគេស្នើសុំ។ ទំព័របណ្ដាញដែលមានស្រាប់រួចហើយ មុនពេលវាត្រូវបានស្នើសុំ ត្រូវបានគេឱ្យឈ្មោះថា ទំព័រមិនប្រែប្រួល (ស្ដាទិក) ខណៈដែលទំព័រត្រូវបានបង្កើតតាមតម្រូវ គេឱ្យឈ្មោះថា ទំព័រប្រែប្រួល (ឌីណាមិក)។

ហេតុអ្វីអ្នកណាៗចង់ប្រើទំព័រឌីណាមិក ជំនួសឱ្យការរៀបចំ និងរក្សាទុកទំព័រសម្រាប់ផ្នែកនីមួយៗនៃព័ត៌មានជាមុន?

ព័ត៌មានតែងតែផ្លាស់ប្ដូរគ្រប់ពេលវេលា ហើយវាមានសារៈសំខាន់ណាស់សម្រាប់ក្រុមហ៊ុនដើម្បីរក្សាទុកព័ត៌មានរបស់ពួកគេឱ្យមានភាពងាយស្រួលតាមដែលអាចធ្វើទៅបាន ដោយមិនចាំបាច់មានប្រភពព័ត៌មានដូចគ្នាច្រើននោះទេ។ វាជាករណីដែលក្រុមហ៊ុនផ្សព្វផ្សាយព័ត៌មានរបស់ពួកគេនៅលើអ៊ីនធឺណិត ហើយព័ត៌មានដែលពួកគេប្រើនោះក៏អាចផ្លាស់ប្ដូរបានផងដែរ ដូចជាតម្លៃនៃផលិតផល ប៉ុន្តែពេលខ្លះពួកគេក៏ភ្លេចផ្លាស់ប្ដូរវាផងដែរនៅលើអ៊ីនធឺណិត ដែលធ្វើឱ្យវាជាព័ត៌មានមិនប្រែប្រួល។ លទ្ធផល គឺថាពួកគេនឹងផ្ដល់ទិន្នន័យ ឬតម្លៃខុសនៅលើវេបសាយរបស់ពួកគេ។

មធ្យោបាយដែលត្រឹមត្រូវដើម្បីដោះស្រាយបញ្ហានេះ គឺត្រូវមានប្រភពមួយសម្រាប់ព័ត៌មានទាំងអស់ដូចជាបញ្ជីតម្លៃតែមួយ។ ទំព័របណ្ដាញដែលបង្ហាញព័ត៌មានអំពីផលិតផលនឹងមិនមានតម្លៃនៅលើទំព័រទេ ប៉ុន្តែវានឹងអានពីបញ្ជីតម្លៃរាល់ពេលដែលអ្នកទស្សនាវេបសាយស្នើសុំព័ត៌មានអំពីផលិតផលនេះ។ ទំព័របណ្ដាញនឹងបង្ហាញតម្លៃពិតប្រាកដជាមួយនឹងព័ត៌មានដែលនៅសល់អំពីផលិតផល។ ប្រសិនបើតម្លៃផ្លាស់ប្ដូរនៅក្នុងបញ្ជី នោះពេលក្រោយដែលអតិថិជនស្នើសុំព័ត៌មានអំពីផលិតផល វេបសាយនឹងផ្ដល់នូវតម្លៃដែលត្រឹមត្រូវ។ ប្រសិនបើទំព័រផលិតផលជាទំព័រមិនប្រែប្រួល (ស្ដាទិក) នោះអ្នកគ្រប់គ្រងវេបសាយនឹងត្រូវផ្លាស់ប្ដូរតម្លៃនៅលើទំព័របណ្ដាញរាល់ពេលដែលតម្លៃត្រូវបានផ្លាស់ប្ដូរ។ ទំព័រប្រែប្រួល (ឌីណាមិក) ធ្វើការផ្លាស់ប្ដូរព័ត៌មានដូចជាតម្លៃយ៉ាងងាយស្រួលជាង។

# ១.១. ការរៀបចំរចនាសម្ព័ន្ធនៃព័ត៌មាន

ព័ត៌មានដែលបានរក្សាទុកនៅក្នុងកុំព្យូទ័រអាចបែងចែកជាពីរប្រភេទផ្សេងគ្នា គឺៈ ព័ត៌មានដែលមានរបៀបរៀបរយ និងមិនមានរបៀបរៀបរយ។ ព័ត៌មានដែលមានរបៀបរៀបរយ គឺជាព័ត៌មានដែលបានរៀបចំទុកដាក់នៅក្នុងតារាង ឬរៀបចំជាបញ្ជីចំណុច ឬលេខរៀង។ ជាធម្មតា វាមានន័យថាព័ត៌មានដែលមានបុគ្គលិកលក្ខណៈដូចគ្នាត្រូវបានរៀបចំទុកដាក់ក្នុងផ្នែកដូចគ្នា។ ឧទាហរណ៍ ប្រសិនបើយើងរក្សាទុកព័ត៌មានអំពីមនុស្ស យើងនឹងរក្សាទុកបុគ្គលិកលក្ខណៈដូចគ្នាអំពីពួកគេ ដូចជា អាយុ ភេទ កន្លែងកំណើត ឬកម្រិតវប្បធម៌ជាដើម។ ដោយសារព័ត៌មាននេះមានប្រភេទដូចគ្នា នោះវាត្រូវបានរក្សាទុកនៅក្នុងតារាងដូចបង្ហាញខាងក្រោមនេះៈ

| | ភេទ | អាយុ | កម្រិតវប្បធម៌ | មកពី |
|---|---|---|---|---|
| សរ ចន្ទី | ស្រី | ៣៦ | បណ្ឌិតគណនេយ្យ | ភ្នំពេញ |
| សំ ពិសិដ្ឋ | ប្រុស | ៣៣ | បរិញ្ញាបត្រជាន់ខ្ពស់ | កណ្ដាល |
| កុក សោភ័ណ | ស្រី | ២៨ | បរិញ្ញាបត្រ | កំពង់ចាម |
| សុក សុខែម | ប្រុស | ៣២ | បរិញ្ញាបត្រ | កំពង់ស្ពឺ |

នៅក្នុងប្រភេទតារាងដូចនេះ បុគ្គលិកលក្ខណៈនីមួយៗដែលបានរក្សាទុកត្រូវបានគេហៅថា "វាល"។ នៅក្នុងតារាងខាងលើ វាល គឺមានដូចជា ភេទ អាយុ កម្រិតវប្បធម៌ និងកន្លែងកំណើត។ សំណុំនៃព័ត៌មានទាំងអស់ដែលបានរក្សាទុកអំពីកម្មវត្ថុ ឬបុគ្គលណាមួយ – បុគ្គលិកលក្ខណៈទាំងអស់ – ត្រូវបានគេស្គាល់ថាជា "កំណត់ត្រា"។ តារាងនេះមានកំណត់ត្រាសម្រាប់ សរ ចន្ទី កុក សោភ័ណ សំ ពិសិដ្ឋ និង សុក សុខែម។

ព័ត៌មានដែលមិនមានរបៀបរៀបរយ ត្រូវបានរៀបចំឡើងដោយផ្អែកនៃព័ត៌មានមិនអាស្រ័យឱ្យគ្នាដែលមិនមានទំនាក់ទំនងគ្នា និងមិនអាចរៀបចំជាតារាងបានទេ។ ឧទាហរណ៍ ឯកសារទាំងអស់នៅក្នុងកុំព្យូទ័រអាចមានប្រធានបទផ្សេងៗគ្នានៃព័ត៌មាន។ ឯកសារមួយអាចជាអត្ថបទអំពីការនេសាទ មួយផ្សេងទៀតអំពីរូបភាពកូនក្មេង និងមួយទៀតជាសៀវភៅបញ្ជីមួយអំពីប្រាក់ដែលចំណាយខែនេះ។ វាមិនមានអ្វីដែលអាចដាក់រួមគ្នាបានទេ ហើយព័ត៌មានដែលមានមិនអាចរៀបចំដាក់ជាតារាងបានទេ។

ឧទាហរណ៍ ប្រភេទឯកសារដែលបានរៀបរចនាសម្ព័ន្ធ



# ១.២. មូលដ្ឋានទិន្នន័យ

ព័ត៌មានដែលបានរៀបចំរចនាសម្ព័ន្ធជាតារាងអាចត្រូវបានរក្សាទុកនៅក្នុងឯកសារដ៏ធំមួយដែលមានឈ្មោះថា មូលដ្ឋានទិន្នន័យកុំព្យូទ័រ។ មូលដ្ឋានទិន្នន័យអាចមានតារាងព័ត៌មានផ្សេងៗជាច្រើន។

ក្រុមហ៊ុនប្រើប្រាស់មូលដ្ឋានទិន្នន័យដើម្បីរក្សាទុកព័ត៌មានអំពីអតិថិជនរបស់ពួកគេ ដើម្បីងាយស្រួលគ្រប់គ្រងបុគ្គលិកលក្ខណៈរបស់អតិថិជនផ្សេងៗ ដូចជាឈ្មោះ អាសយដ្ឋាន លេខទូរសព្ទ ឬរយៈពេលដែលពួកគេបានក្លាយជាអតិថិជន។ ក្រុមហ៊ុនតែងតែធ្វើការថែទាំមូលដ្ឋានទិន្នន័យជាញឹកញាប់អំពីធាតុទាំងអស់ដែលពួកគេលក់ រួមទាំងរូបថត តម្លៃ ទំហំ ឬទំនិញប៉ុន្មានដែលនៅក្នុងឃ្លាំង។

មូលដ្ឋានទិន្នន័យអាចមានទំហំតូច និងត្រូវបានប្រើដោយអ្នកប្រើនៅលើកុំព្យូទ័រដោយឡែកមួយ។ មូលដ្ឋានទិន្នន័យផ្សេងមានទំហំធំ អាចឱ្យអ្នកប្រើរាប់ពាន់ ឬលាននាក់បន្ថែមព័ត៌មានទៅកាន់វា ឬចូលដំណើរការព័ត៌មានដែលបានរក្សាទុកនោះ។ មូលដ្ឋានទិន្នន័យដ៏ធំត្រូវបានរក្សាទុកនៅលើម៉ាស៊ីនមេឯកទេសដែលអាចអាន ឬសរសេរទៅកាន់មូលដ្ឋានទិន្នន័យនៅកម្រិតល្បឿនលើសពី ១០.០០០ ផ្នែកនៃព័ត៌មានក្នុងមួយវិនាទី។



ទូសម្រាប់ម៉ាស៊ីនមេធំ

ខណៈដែលមូលដ្ឋានទិន្នន័យ គឺគ្រាន់តែជាឯកសារដែលមានទិន្នន័យ វាត្រូវការសំណុំនៃកម្មវិធីដែលអាចឱ្យអ្នកប្រើសរសេរ និងអានព័ត៌មានពីទ្រង់ទ្រាយខាងក្នុងពីមូលដ្ឋានទិន្នន័យ។ កម្មវិធីទាំងនេះត្រូវបានគេស្គាល់ថាជាប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យ។ ប្រព័ន្ធគ្រប់គ្រងមូលដ្ឋានខ្លះមានភាពសាមញ្ញ ដែលអ្នកប្រើទូទៅអាចប្រើបានជាឧបករណ៍មួយដ៏មានប្រសិទ្ធភាពនៃកុំព្យូទ័រផ្ទាល់ខ្លួនរបស់ពួកគេដោយមិនត្រូវចែករំលែកជាមួយអ្នកផ្សេង។ ប្រព័ន្ធផ្សេងទៀតមានភាពស្មុគស្មាញ ដែលត្រូវបានប្រើនៅលើអ៊ីនធឺណិតក្នុងម៉ាស៊ីនមេសាធារណៈ និងបានចែករំលែកដោយមនុស្សជាច្រើន ប្រព័ន្ធទាំងនេះត្រូវមានប្រសិទ្ធភាពយ៉ាងខ្លាំងណាស់ដើម្បីប្រាកដថាព័ត៌មានអាចអានបាន ស្វែងរកបាន ឬសរសេរបានភ្លាមៗ។

*ប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យដែលនិយមប្រើបំផុតនៅលើពិភពលោក គឺឈ្មោះថា MySQL ដែលជាកម្មវិធីឥតគិតថ្លៃ។ ក៏មានប្រព័ន្ធដែលល្បីល្បាញផ្សេងទៀតផងដែរ ដូចជា ORACLE ឬ My SQL ប៉ុន្តែវាមានតម្លៃថ្លៃ ត្រូវតែទិញអាជ្ញាប័ណ្ណទើបអាចប្រើបាន ហើយមានតែក្រុមហ៊ុនធំប៉ុណ្ណោះអាចលៃលកសម្រាប់ទិញវាប្រើបាន។*

# ១.៣. ទំព័របណ្ដាញឌីណាមិក

ឥឡូវ អ្នកបានដឹងហើយថាព័ត៌មានដែលមានរចនាសម្ព័ន្ធត្រូវបានរៀបចំរក្សាទុកបានយ៉ាងដូចម្ដេច យើងអាចត្រឡប់ទៅបណ្ដាញ និងមើលរបៀបដែលវេបសាយប្រើប្រាស់ព័ត៌មាននេះយ៉ាងដូចម្ដេច។

> ស្រមើស្រមៃក្រុមហ៊ុនចែកចាយម្ហូបអាហារដែលទិញ និងលក់ផលិតផល ២៤០ មុខផ្សេងៗគ្នា ហើយក្រុមហ៊ុនចង់ធ្វើការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលទាំងអស់នេះនៅលើអ៊ីនធឺណិត។ ផលិតផលនីមួយៗមានលេខយោងសម្គាល់មួយជាមួយរូបភាព អត្ថបទពិពណ៌នាខ្លីអំពីផលិតផល លេខផលិតផលដែលបានរក្សាទុកនៅក្នុងឃ្លាំង ផលិតផលប៉ុន្មានក្នុងមួយប្រអប់ ទំហំប្រអប់ និងព័ត៌មានទាំងឡាយផ្សេងទៀតដែលចាំបាច់។
>
> វាជាការស្មុគស្មាញសម្រាប់អ្នកអភិវឌ្ឍវេបសាយរបស់ក្រុមហ៊ុនដើម្បីបង្កើតទំព័របណ្ដាញមួយសម្រាប់ផលិតផលនីមួយៗ។ ពួកគេត្រូវបង្កើត និងមើលថែទាំទំព័រ ២៤០ ផ្សេងគ្នា។ រាល់ពេលដែលពួកគេផ្លាស់ប្ដូរតម្លៃ ឬព័ត៌មានខ្លះៗនៅក្នុងមូលដ្ឋានទិន្នន័យ ពួកគេត្រូវត្រឡប់ថយក្រោយវិញ និងធ្វើការផ្លាស់ប្ដូរព័ត៌មាននៅលើវេបសាយនៃផលិតផលនោះផងដែរ។

ដូចដែលបានរៀបរាប់ខាងលើ វេបសាយដែលទំនើបអាចដោះស្រាយបញ្ហាទាំងនេះបានដោយបង្កើតទំព័រដែលបង្កើតដោយស្វ័យប្រវត្តិនៅពេលអ្នកប្រើ ឬអតិថិជនស្នើសុំព័ត៌មាន។ ទំព័រទាំងនេះត្រូវបានបង្កើតឡើងដោយដាក់ពុម្ពគំរូ និងផ្នែកនៃព័ត៌មានដែលអ្នកប្រើចង់ឃើញជាមួយគ្នា។ ពុម្ពគំរូ គឺជាទំព័របណ្ដាញដែលមានការរចនាទំព័រពេញលេញ ប៉ុន្តែវាមិនមានផ្នែកនៃព័ត៌មានជាក់លាក់ដែលស្នើសុំដោយអ្នកប្រើទេ។ ផ្នែកនៃព័ត៌មានទាំងនេះត្រូវបានបន្ថែមនៅពេលទំព័រត្រូវបានបង្កើត។

*សព្វថ្ងៃ វេបសាយដែលផ្អែកលើពុម្ពគំរូកំពុងមានប្រជាប្រិយភាពខ្លាំង។ ដើម្បីបង្កើតវេបសាយដែលទាក់ទាញ និងជាអាជីព ត្រូវចំណាយប្រាក់ច្រើន។*

ដើម្បីបង្កើតទំព័រផលិតផលដោយស្វ័យប្រវត្តិ វេបសាយត្រូវមានជំហានដូចខាងក្រោម៖

- ចូលទៅកាន់មូលដ្ឋានទិន្នន័យដែលមានព័ត៌មានត្រូវបង្ហាញ។
- ពុម្ពគំរូដែលបង្ហាញរូបរាងទំព័រផលិតផល។ ពុម្ពគំរូរួមមានការពិពណ៌នានៃទំព័រជាក្រាហ្វិក កំណត់កន្លែងដែលធាតុ ឬផ្នែកនៃព័ត៌មាននីមួយៗគួរមានទីតាំងស្ថិតនៅ។ វាក៏រួមបញ្ចូលបញ្ជីនៃផ្នែកព័ត៌មានពីមូលដ្ឋានទិន្នន័យដែលត្រូវបញ្ចូលនៅក្នុងទំព័រ និងកន្លែងនៅក្នុងទំព័រដែលផ្នែកនៃព័ត៌មានទាំងនោះត្រូវមានទីតាំងស្ថិតនៅ។

យើងគួរមានពុម្ពគំរូទំព័រសាមញ្ញមួយដែលមើលទៅដូចខាងក្រោម។

## ក្រុមហ៊ុនចំណីអាហារដ៏អស្ចារ្យរបស់ខ្ញុំ

ទំព័របរិយាយពីផលិតផល

លេខកូដផលិតផល៖ 001




មីយើងរស់ជាតិសាច់មាន់

តម្លៃ៖ ២៥០០០៛
ចំនួនក្នុង១ប្រអប់៖ ២៥
ទំហំប្រអប់៖ 25x18x15

មូលដ្ឋានទិន្នន័យសម្រាប់ពុម្ពគំរូខាងលើអាចមានវាលទាំងនេះដូចខាងក្រោម៖

| ល.រ | សេចក្ដីពិពណ៌នា | រូបភាព | តម្លៃ | | ទំហំប្រអប់ |
|---|---|---|---|---|---|
| ០០១ | មីយើងរស់ជាតិសាច់មាន់ | noodlechicken.jpg | ២៥០០០៛ | ២៥ | 25x18x15 |
| ០០២ | មីយើងរស់ជាតិសាច់គោ | noodlebeef.jpg | ៣០០០០៛ | ៣០ | 40x25x12 |
| ០០៣ | មីយើងរស់ជាតិសាច់ជ្រូកចិញ្ច្រាំ | noodlepork.jpg | ២៦០០០៛ | ៣០ | 40x25x12 |
| ០០៤ | មីយើងរស់ជាតិពិសេស | specialnoodles.jpg | ៣៥០០០៛ | ២០ | 25x18x15 |

ប្រសិនបើអតិថិជនសុំមើលការពិពណ៌នាផលិតផលជាមួយលេខយោងផលលេខ ២ នោះប្រព័ន្ធនឹងចាប់យកពុម្ពគំរូ និងកំណត់ត្រាសម្រាប់លេខយោង ២ (ព័ត៌មាននៅក្នុងជួរដេកសម្រាប់លេខយោង ២) ហើយនឹងបង្កើតទំព័របណ្ដាញឌីណាមិកដែលបង្ហាញព័ត៌មានទាំងអស់ដូចខាងក្រោម។

## ក្រុមហ៊ុនចំណីអាហារដ៏អស្ចារ្យរបស់ខ្ញុំ

ទំព័របរិយាយពីផលិតផល

លេខកូដផលិតផល៖ 002




មីយើងរស់ជាតិសាច់គោ

តម្លៃ៖ ៣០០០០៛

ចំនួនក្នុង១ប្រអប់៖ ៣០

ទំហំប្រអប់៖ 40x25x12

ប្រសិនបើតម្លៃ ឬព័ត៌មានទាំងឡាណាផ្សេងទៀតត្រូវបានផ្លាស់ប្ដូរនៅក្នុងមូលដ្ឋានទិន្នន័យ ពេលក្រោយដែលអ្នកប្រើស្នើសុំទំព័រនេះ វានឹងបង្ហាញព័ត៌មានថ្មី ដូចដែលវាទាញចេញពីមូលដ្ឋានទិន្នន័យភ្លាមៗមុនពេលបង្ហាញទំព័រនេះ។

វេបសាយរបស់ក្រុមហ៊ុនដឹកជញ្ជូនធំៗដែលដឹកជញ្ជូនទំនិញឆ្លងកាត់ប្រទេសផ្តល់នូវគំរូផ្សេងៗគ្នានៃព័ត៌មានបែបឌីណាមិកដែលត្រូវបានប្រើ។ ក្រុមហ៊ុនដូចជា Cambodia's Express Mail Service (EMS) FedEx និង DHL មានមូលដ្ឋានទិន្នន័យធំដែលជាកន្លែងពួកគេរក្សាទុកព័ត៌មានអំពីកញ្ចប់នីមួយៗដែលពួកគេដឹកជញ្ជូន រួមមានទាំងទីតាំងកញ្ចប់ទៅដល់អំឡុងពេលដឹកជញ្ជូន។ កញ្ចប់ធ្វើដំណើរពីអេស្ប៉ាញមកភ្នំពេញអាចបញ្ជូនទៅអាល្លឺម៉ង់ជាដំបូង បន្ទាប់មកទៅបាងកក និងចុងបញ្ចប់មកដល់ភ្នំពេញ ដែលបន្ទាប់មកក្រុមហ៊ុនត្រូវបញ្ជូនវាទៅផ្ទះ ឬការិយាល័យអ្នកទទួល។ រាល់ពេលដែលកញ្ចប់មកដល់ ឬចេញដំណើរពីកន្លែងណាមួយ នោះវាត្រូវបានកត់ត្រានៅក្នុងមូលដ្ឋានទិន្នន័យ ដែលអាចឱ្យយើងដឹងអំពីទីតាំងដែលវានៅកន្លែងណា ឬដឹកជញ្ជូនដល់ណាហើយ។

ក្រុមហ៊ុនដឹកជញ្ជូនទាំងនេះក៏អាចឱ្យអតិថិជនរបស់ពួកគេដឹងថាកន្លែងណាកញ្ចប់របស់ពួកគេទៅដល់នៅពេលនីមួយៗ។ នៅពេលកញ្ចប់ចាប់ផ្ដើមដឹកជញ្ជូន វាត្រូវបានបន្ថែមទៅមូលដ្ឋានទិន្នន័យ និងត្រូវបានផ្ដល់លេខយោងផលិតផលដែលគេហៅថា លេខសម្គាល់តាមដាន។ អតិថិជនអាចចូលទៅវេបសាយរបស់ក្រុមហ៊ុននៅពេលណាមួយ រួចបញ្ចូលលេខកូដ និងមើលព័ត៌មានអំពីកញ្ចប់នោះ។

# ១.៤. ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមជាវេបសាយឌីណាមិក

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម គឺជាគំរូដ៏ល្អមួយនៃវេបសាយឌីណាមិក។ ទំព័របណ្ដាញទាំងអស់គឺមានបែបផែនឌីណាមិកនៅក្នុងវេបសាយដូចជា Facebook ដែលជាបណ្ដាញព័ត៌មានសង្គមសម្រាប់ទំនាក់ទំនងផ្ទាល់ខ្លួន និង LinkedIn ជាបណ្ដាញព័ត៌មានសង្គមសម្រាប់ទំនាក់ទំនងបែបការងារ។

យក Facebook ជាឧទាហរណ៍។ Facebook មានពុម្ពគំរូរចនាសម្រាប់បង្ហាញដំណឹង និងមតិយោបល់ដែលបានប្រកាសផ្សាយដោយមិត្តភ័ក្តិដែលជាម្ចាស់គណនីណាមួយ។ ប្រកាសព័ត៌មានទាំងអស់ គឺគ្រាន់តែជាផ្នែកនៃមូលដ្ឋានទិន្នន័យដ៏ធំមួយដែលមានដំណឹង និងមតិយោបល់។ នៅពេលអ្នកចូល Facebook នឹងបើកមើលប្រកាសព័ត៌មានណាចុងក្រោយគេដើម្បីបង្ហាញដល់អ្នកប្រើ ហើយបន្ទាប់មកវានឹងជ្រើសយកព័ត៌មានមួយចំនួន និងបង្កើតជាបញ្ជី។ បន្ទាប់មកបញ្ជីនៃប្រកាសនេះត្រូវបានបញ្ចូលគ្នាជាមួយពុម្ពគំរូ Facebook ដែលបង្ហាញរូបភាព ឬវីដេអូនៃប្រកាសនោះ រួមមានរូបភាពតូចរបស់អ្នកប្រើដែលបានប្រកាសផ្សាយវា ផ្នែកនៃព័ត៌មាន និងកន្លែងសម្រាប់មតិយោបល់ថ្មីក៏ដូចជាមតិយោបល់ដែលបានផ្ដល់រួចហើយដែរ។ នេះ គឺជាពុម្ពគំរូ ដែលត្រូវបានធ្វើឡើងម្ដងហើយម្ដងទៀតនៅលើទំព័រដូចគ្នា។ Facebook ជាពិសេស បានអភិវឌ្ឍវេបសាយដ៏ស្មុគស្មាញដែលបានបំពេញស្របតាមរចនាប័ទ្មរបស់វា និងជំនួញប្រកបដោយជំនាញពេញលេញ ក្នុងការបង្ហាញប្រកាសជាការកម្សាន្ត និងការបង្ហាញពាណិជ្ជកម្មដល់អ្នកប្រើ។

ទំព័រដើមរបស់អ្នកប្រើ Facebook



# ១.៥. ផែនទីជាវេបសាយឌីណាមិក

ផែនទីនៅលើអ៊ីនធឺណិត គឺជាឧទាហរណ៍មួយទៀតនៃវេបសាយឌីណាមិកដែលប្រែប្រួល។ មិនដូចគ្នានឹងក្រដាសទេ ដែលឈ្មោះ និងផ្លូវទាំងអស់ត្រូវបានសរសេររួចជាស្រេច រីឯផែនទីកុំព្យូទ័រមិនមែនគូរទុកជាមុននោះទេ។ ទីក្រុង ផ្លូវ ក្រុមហ៊ុនជំនួញ ឬតំបន់ទេសចរណ៍ដែលទាក់ទាញជាផ្នែកនៃមូលដ្ឋានទិន្នន័យដែលកំណត់យ៉ាងច្បាស់លាស់ទីតាំងដែលវាស្ថិតនៅ និងបុគ្គលិកលក្ខណៈសម្គាល់របស់វា។ នៅពេលផែនទីបង្ហាញនៅលើអេក្រង់កុំព្យូទ័រ អ្នកប្រើកំណត់ទំហំទីតាំងដែលត្រូវបង្ហាញ និងព័ត៌មានលម្អិតមួយចំនួនដែលពួកគេចង់ដាក់បង្ហាញដល់អ្នកមើល។ បន្ទាប់មកវេបសាយនឹងប្រមូលផ្តុំទិន្នន័យនេះដោយប្រើមូលដ្ឋានទិន្នន័យរបស់វា ដាក់បង្ហាញជាផែនទីដែលមានប្រភេទនៃព័ត៌មានទាំងអស់នេះ ដែលអ្នកប្រើអាចជ្រើសរើសបាន។




# ១.៦. ការផ្សាយពាណិជ្ជកម្មបែបឌីណាមិក

វេបសាយដែលមានអ្នកទស្សនាច្រើនរកប្រាក់បានតាមរយៈការបង្ហាញពាណិជ្ជកម្មដល់អ្នកទស្សនារបស់ពួកគេ។ ជាធម្មតាការផ្សាយពាណិជ្ជកម្មមិនត្រូវកំណត់ដោយមិនប្រែប្រួលទេ វេបសាយ នៅពេលបង្កើតទំព័រ វានឹងទៅទាញយកព័ត៌មានការផ្សាយពាណិជ្ជកម្មសមរម្យដែលចាំបាច់ត្រូវបង្ហាញនៅពេលនោះ។ មាតិកាព័ត៌មានពាណិជ្ជកម្ម គឺបង្ហាញអាស្រ័យតាមចំណាប់អារម្មណ៍អ្នកទស្សនា និងសកម្មភាពរបស់ពួកគេពីមុនៗ។ ឧទាហរណ៍ អ្នកដែលបានស្វែងរកតម្លៃកាមេរ៉ាតាមអ៊ីនធឺណិតអាចរកបានតាមរយៈការផ្សាយពាណិជ្ជកម្មរបស់ហាងលក់កាមេរ៉ា និងក្រុមហ៊ុនដែលពួកគេបានដាក់ឱ្យបង្ហាញនៅពេលអ្នកប្រើស្វែងរកក្រោយៗទៀត។ ម្ចាស់វេបសាយមិនចាំបាច់បារម្ភអំពីពាណិជ្ជកម្មណាមួយដែលត្រូវបង្ហាញនោះទេ ក្រុមហ៊ុនផ្សាយពាណិជ្ជកម្មនឹងត្រូវប្រាកដថាពួកគេផ្តល់ពាណិជ្ជកម្មដ៏ត្រឹមត្រូវសម្រាប់អ្នកប្រើ។

# ២. ប្រព័ន្ធគ្រប់គ្រងមាតិកាព័ត៌មាន

នៅពេលយើងចាប់ផ្ដើមរៀបចំវេបសាយដែលមានព័ត៌មានសម្បូរបែបផ្សេងៗគ្នា សូមបង្កើតទំព័រមួយ ឬច្រើនអំពីប្រធានបទនីមួយៗ ដែលយើងបញ្ចប់ការបង្កើតទំព័រច្រើនដែលស្រដៀងគ្នាក្នុងការរចនា។ វាពិតជាមានភាពងាយស្រួលជាងក្នុងការបង្កើតការរចនាទំព័រតែម្ដង ហើយបន្ទាប់មកចម្លងចំណងជើង អត្ថបទ និងរូបភាពសម្រាប់ទំព័រនីមួយៗ។ នេះត្រូវមានទំព័រឌីណាមិកដូចគ្នាដែលប្រើមូលដ្ឋានទិន្នន័យ ដែលអ្នកគួរមានតែវាលចំនួនបីប៉ុណ្ណោះ៖ <ចំណងជើង> <អត្ថបទ> និង <រូបភាព>។

| ល.រ | ចំណងជើង | អត្ថបទ | រូបភាព |
|---|---|---|---|
| ១ | តោ | Lions are large mammals that live in the savanna environments of Africa. They… | Lionpicture.jpg |
| ២ | ខ្លា | Tigers are large carnivorous mammals that live in different parts of Asia. They… | Tigerpicture.jpg |
| ៣ | សេះបង្កង់ | Zebras are African wild horses with black-and-white stripes and they... | Zebrapicture.jpg |

ដើម្បីជួយសម្រួលដល់ការអភិវឌ្ឍវេបសាយដែលមានទំព័រជាច្រើនជាមួយការរចនាស្រដៀងគ្នានោះ ចំនួន កម្មវិធីដែលគេហៅថា ប្រព័ន្ធគ្រប់គ្រងមាតិកាព័ត៌មានអាចប្រើបាន។ ប្រព័ន្ធគ្រប់គ្រងមាតិកាព័ត៌មាន (CMS) គឺជាកម្មវិធីកុំព្យូទ័រដែលជួយសម្រួលដល់ការបង្កើតវេបសាយដែលអនុញ្ញាតឱ្យអ្នកប្រើកំណត់ពុម្ពគំរូ ឬទំព័ររចនាមួយចំនួន ហើយបន្ទាប់មកបញ្ចូលព័ត៌មានដោយឡែកពីគ្នាដែលមាននៅលើវេបសាយ ដោយកំណត់យ៉ាងសាមញ្ញពុម្ពគំរូណាមួយនឹងត្រូវប្រើសម្រាប់ព័ត៌មានណាមួយ។ ពុម្ពគំរូ គឺគ្រាន់តែជាទំព័ររចនាមួយដែលអ្នកប្រើអាចកំណត់បានកន្លែងណាដែលត្រូវដាក់ចំណងជើង អត្ថបទសំខាន់ និងព័ត៌មានផ្សេងៗដែលនឹងត្រូវបញ្ចូល។

យើងអាចធ្វើបានក្នុងការបង្កើតវេបសាយបានលឿនបំផុតនៅពេលប្រើ CMS ។ CMS អាចឱ្យអ្នកប្រើជ្រើសក្នុងចំណោមការរចនាទំព័របណ្ដាញ ឬពុម្ពគំរូស្ដង់ដារជាច្រើន។ ជាមួយពុម្ពគំរូទាំងនេះ វាអាចធ្វើបានក្នុងការបញ្ចូលរូបតំណាង រូបភាព ឬព័ត៌មានមូលដ្ឋានផ្សេងៗរបស់អ្នកបានយ៉ាងងាយស្រួល។ ពេលក្រោយ វាក៏អាចធ្វើបានក្នុងការធ្វើឱ្យប្រសើរ ឬកំណត់លក្ខណៈការរចនាផ្ទាល់ខ្លួនដោយមិនចាំបាច់ផ្លាស់ប្ដូរមាតិកាព័ត៌មាន។

មានប្រព័ន្ធគ្រប់គ្រងមាតិកាព័ត៌មានឥតគិតថ្លៃជាច្រើន។ កញ្ចប់ CMS ដែលល្បីល្បាញនៅពេលនេះ គឺ Drupal Joomla និង WordPress ។ អ្នកផ្ដល់សេវាកម្មអ៊ីនធឺណិតតែងតែដំឡើងប្រព័ន្ធ CMS ដោយស្វ័យប្រវត្តិនៅពេលយើងទាក់ទងពួកគេដើម្បីបង្ហោះវេបសាយរបស់យើង មានន័យថា វេបសាយរបស់យើងបានដាក់សេវាកម្មរបស់ពួកគេសម្រាប់ចូលប្រើអ៊ីនធឺណិតបាន។ អ្នកណាក៏ដោយដែលមានព័ត៌មានចង់បង្ហាញ អាចចាប់ផ្ដើមវេបសាយបានងាយដោយប្រើប្រព័ន្ធ CMS នេះ។

> *ប្រព័ន្ធ CMS ជាធម្មតាមានសមត្ថភាពស្វែងរកដោយស្វ័យប្រវត្តិ ដែលអាចឱ្យអ្នកទស្សនាវេបសាយអាចរកព័ត៌មានទាំងឡាយណាបានដែលបានរក្សាទុកនៅក្នុងវេបសាយ។*




រូបភាពផ្ទាំងគ្រប់គ្រងព័ត៌មានអ្នកប្រើ Wrod Press

# ៣. កំណត់ហេតុបណ្តាញ និងវេបសាយ

ដើម្បីសម្រេចថាត្រូវប្រើប្រព័ន្ធ CMS មួយណា ជាដំបូង សំខាន់ត្រូវសម្រេចថាយើងចង់អភិវឌ្ឍអំពីអ្វី៖ វេបសាយសម្រាប់ក្រុមហ៊ុន ឬស្ថាប័ន វេបសាយផ្ទាល់ខ្លួន ឬគ្រាន់តែជាកំណត់ហេតុបណ្តាញ។ កំណត់ហេតុបណ្តាញ គឺជាកំណត់ហេតុបណ្តាញនៅលើអ៊ីនធឺណិតដែលបានសរសេរក្នុងទម្រង់ជាការសន្ទនាបែបការបញ្ចេញទស្សនៈផ្ទាល់ខ្លួន។ ក្នុងករណីជាច្រើន កំណត់ហេតុបណ្តាញតែងតែត្រូវបានប្រើដើម្បីបញ្ចេញទស្សនៈរបស់ម្ចាស់ ឬអំពីប្រធានបទជាក់លាក់ ដូចជាកីឡា សុខភាព កម្សាន្ត ឬចំណាប់អារម្មណ៍ផ្សេងៗដែលម្ចាស់អាចមាន និងចង់បង្ហាញឱ្យគេដឹងតាមរយៈកំណត់ហេតុបណ្តាញ។ បុគ្គលិកលក្ខណៈចម្បងរបស់កំណត់ហេតុបណ្តាញ គឺថាអត្ថបទមានលក្ខណៈសង្ខេប និងត្រូវបានរៀបចំតាមកាលបរិច្ឆេទផ្សព្វផ្សាយ ឬតាមប្រធានបទ។ វេបសាយ និងកំណត់ហេតុបណ្តាញ គឺមានធាតុដោយឡែកដាច់ស្រឡះពីគ្នា ប៉ុន្តែតាមបច្ចេកទេសវាជាវេបសាយដូចគ្នា ប៉ុន្តែរចនាសម្ព័ន្ធរបស់វាខុសគ្នាស្រឡះ ជាមួយពុម្ពគំរូផ្សេងគ្នា។ វេបសាយមានភាពខុសគ្នា ព្រោះវាមានបំណងបញ្ចូលព័ត៌មានទាំងអស់ដាក់បង្ហាញជាសាធារណៈដែលស្ថាប័នចង់បាន និងរៀបចំព័ត៌មានជារចនាសម្ព័ន្ធតាមមធ្យោបាយដែលអ្នកប្រើងាយស្រួលរកបានលឿនតាមដែលអាចធ្វើទៅបាន។

> អ្នកគ្រប់គ្រងវេបសាយត្រូវប្រាកដថាអ្នកទស្សនាអាចរកអ្វីដែលពួកគេចង់បានយ៉ាងលឿន ដើម្បីធ្វើឱ្យពួកគេពេញចិត្ត និងត្រឡប់មកទស្សនាវេបសាយនេះម្តងទៀត។

អ្នកនឹងសិក្សាបន្ថែមអំពីកំណត់ហេតុបណ្តាញ នៅមេរៀនទី ៨ ប៉ុន្តែការបែងចែកភាពខុសគ្នារវាងកំណត់ហេតុបណ្តាញ និងវេបសាយ នៅទីនេះពិតជាមានសារៈសំខាន់ណាស់ ព្រោះប្រព័ន្ធ CMS ដែលយើងប្រើសម្រាប់បង្កើតកំណត់ហេតុបណ្តាញ និងវេបសាយ គឺខុសគ្នា។ Drupal

និង Joomla គឺជាប្រព័ន្ធ CMS ដែលបានបង្កើតឡើង ជាក់លាក់សម្រាប់បង្កើតវេបសាយ ខណៈដែល WordPress ជាប្រព័ន្ធមួយដែលបង្កើតឡើងសម្រាប់ងាយស្រួលក្នុងការបង្កើតកំណត់ហេតុបណ្តាញ។ ជាធម្មតា កំណត់ហេតុបណ្តាញមានលក្ខណៈដែលអាចរកប្រកាសកំណត់ហេតុបណ្តាញបានងាយស្រួល ដែលត្រូវបានសរសេរនៅកាលបរិច្ឆេទជាក់លាក់ ដូចជាឧទាហរណ៍ដែលបានផ្តល់ខាងក្រោមនេះ៖

ឥឡូវ អ្នកបានយល់ដឹងហើយអំពីគោលគំនិតនៃពុម្ពគំរូ និងមូលដ្ឋានទិន្នន័យ វាងាយស្រួលយល់អំពីការងារជាអ្នកអភិវឌ្ឍវេបសាយ ដែលពាក់ព័ន្ធនឹងការបង្កើតមូលដ្ឋានទិន្នន័យ និងពុម្ពគំរូដើម្បីបង្កើតទំព័រដែលអ្នកទស្សនាវេបសាយបានស្នើសុំ។

## មេរៀនសង្ខេប

វេបសាយអាចមានទំព័រពីរប្រភេទ គឺ៖ ទំព័រឥតប្រែប្រួល (ស្តាទិក) ដែលត្រូវបានរៀបចំទុកជាមុនពេញលេញ និងផ្តល់ឱ្យអ្នកទស្សនាវេបសាយពេលណាដែលពួកគេស្នើ ឬមួយទៀតទំព័រឌីណាមិក ដែលត្រូវបានបង្កើតតែដើម្បីឆ្លើយតបដល់សំណើរបស់អ្នកទស្សនាសម្រាប់ព័ត៌មានដែលពួកគេចង់បានប៉ុណ្ណោះ។ វេបសាយឌីណាមិកស្វែងរកពុម្ពគំរូសម្រាប់ព័ត៌មាន ស្វែងរកមូលដ្ឋានទិន្នន័យ បញ្ចូលវាទៅក្នុងកន្លែងត្រឹមត្រូវនៅក្នុងពុម្ពគំរូ និងចុងបញ្ចប់ បង្កើតទំព័រដែលនឹងផ្តល់ព័ត៌មានដល់អ្នកប្រើ។ ឧទាហរណ៍ដ៏ច្បាស់លាស់មួយអំពីវេបសាយឌីណាមិក គឺវេបសាយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមដូចជា Facebook ដែលអាចរក្សាទុកប្រកាស និងមតិរបស់អ្នកប្រើទាំងអស់នៅក្នុងមូលដ្ឋានទិន្នន័យ។ នៅពេលអ្នកប្រើចូលក្នុងប្រព័ន្ធ Facebook ប្រើពុម្ពគំរូសាមញ្ញរបស់វា និងបំពេញព័ត៌មានក្នុងប្រកាស និងមតិនៃម្ចាស់គណនីរបស់មិត្តភ័ក្តិ បង្កើតទំព័រត្រឹមត្រូវ និងបង្ហាញវាដល់អ្នកប្រើងាយយល់។

ដើម្បីសម្របសម្រួលការងារក្នុងការអភិវឌ្ឍវេបសាយ ប្រព័ន្ធខ្លះដែលគេហៅថា ប្រព័ន្ធគ្រប់គ្រងមាតិកាព័ត៌មាន (CMS) ត្រូវបានបង្កើតដែលមិនទាមទារជំនាញខ្ពស់។ ប្រព័ន្ធទាំងនេះអាចឱ្យអ្នកប្រើបង្កើតវេបសាយ ឬកំណត់ហេតុបណ្តាញបានយ៉ាងឆាប់រហ័ស ដោយជ្រើសពុម្ពគំរូដែលពួកគេចង់ប្រើ និងបន្ទាប់មកបញ្ចូលព័ត៌មានដាច់ដោយឡែកពីគ្នា។ ប្រព័ន្ធបញ្ចូលវារួមគ្នាដើម្បីបង្កើតវេបសាយតាមបំណងមួយ។

## លំហាត់

### លំហាត់ ១

នៅក្នុងលំហាត់នេះ អ្នកនឹងស្វែងយល់អំពីភាពផ្សេងគ្នារវាងផ្នែកនៃទំព័របណ្តាញដែលប្រើពុម្ពគំរូ ឬការរចនា និងធាតុដែលជាឌីណាមិក ជាមួយព័ត៌មានដែលបានយកចេញពីមូលដ្ឋានទិន្នន័យ ឬប្រភពផ្សេងៗ។

ប្រសិនបើសាលារបស់អ្នកមានអ៊ីនធឺណិត សូមចូលក្នុងគណនី LinkedIn ឬ Facebook នៃក្រុមមួយ។ នៅក្នុងគណនីនោះ សូមចូលទៅទំព័រដើម កំណត់ និងពិភាក្សានៅក្នុងក្រុមរបស់អ្នក ថាធាតុណាមួយនៃទំព័រនោះជាផ្នែកនៃពុម្ពគំរូ និងផ្នែកណាជាឌីណាមិក ដែលបានយកចេញពីមូលដ្ឋានទិន្នន័យ ឬប្រភពផ្សេងៗ។ សូមពិចារណាក្រាហ្វិក និងការផ្សាយពាណិជ្ជកម្មក៏ដូចជាអត្ថបទ។ សូមបើកកម្មវិធី OpenOffice Writer រួចសរសេរបញ្ជីធាតុនៃពុម្ពគំរូ និងធាតុឌីណាមិកដែលអ្នកស្គាល់។ សូមរក្សាទុកឯកសារនៅក្នុងថតក្រុមរបស់អ្នកដោយដាក់ឈ្មោះថា លំហាត់ ១២ក.odt ។
ប្រសិនបើអ្នកមិនមានអ៊ីនធឺណិត សូមធ្វើលំហាត់ដូចគ្នានេះដោយប្រើរូបភាពនៃទំព័រ Facebook ដែលអ្នកអាចរកបាននៅក្នុងថត "ឯកសារវគ្គសិក្សា ICT ថ្នាក់ទី ១២"។

## លំហាត់ ២

នៅក្នុងទំព័រវេបសាយរបស់ក្រសួងអប់រំ យុវជន និងកីឡា (www.moeys.gov.kh) គឺត្រូវបានបង្កើតឡើងដោយប្រើប្រព័ន្ធគ្រប់គ្រងមាតិកាព័ត៌មាន (CMS)។

ប្រសិនបើអ្នកមានអ៊ីនធឺណិត សូមបើកទំព័រដើម និងទំព័រផ្សេងៗទៀត រួចមើលការរចនាវេបសាយនេះ និងកន្លែងដែលធាតុនីមួយៗត្រូវបានដាក់ក្នុងទំព័រ។ សូមកំណត់ ពិភាក្សា និងសម្រេច ប្រសិនបើវាបានប្រើពុម្ពគំរូខុសគ្នាសម្រាប់ទំព័រផ្សេងៗ។ អ្នកអាចមើល ជាឧទាហរណ៍ ប្រសិនបើទំព័រមានព័ត៌មានតែមួយប្រភេទ ឬក៏វាបង្ហាញព័ត៌មានបច្ចុប្បន្នភាពថ្មីៗ ឬធាតុឌីណាមិកផ្សេងៗ។ សូមពិពណ៌នាការរកឃើញរបស់អ្នកនៅក្នុងឯកសារដូចគ្នា លំហាត់១ និងរក្សាទុកវានៅទីតាំងដូចគ្នាលំហាត់ខាងលើ។ ប្រសិនបើអ្នកមិនមានអ៊ីនធឺណិត សូមធ្វើលំហាត់ដូចគ្នាដោយប្រើរូបភាពនៃទំព័រក្រសួងដែលអ្នកអាចរកបាននៅក្នុងថត "ឯកសារវគ្គសិក្សា ICT ថ្នាក់ទី ១២"។

## សំណួរត្រិះរិះ

១. តើទំព័របណ្ដាញស្ដាទិក និងឌីណាមិកខុសគ្នាដូចម្ដេចខ្លះ?
២. អ្វីទៅជាពុម្ពគំរូ និងតើពុម្ពគំរូមានអ្វីខ្លះ?
៣. តើអ្វីដែលអ្នករក្សាទុកខ្លះនៅក្នុងមូលដ្ឋានទិន្នន័យ?
៤. តើទំព័រប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមជាស្ដាទិក ឬឌីណាមិក? មូលហេតុអ្វីបានជាអ្នកគិតដូច្នេះ?
៥. តើអ្វីជាប្រព័ន្ធគ្រប់គ្រងមាតិកាព័ត៌មាន (CMS)? តើអ្នកត្រូវតែជាអ្នកអភិវឌ្ឍវេបសាយដ៏ជំនាញទើបអាចប្រើវាបាន? សូមពន្យល់។

# ផ្នែក ខ - ទំនាក់ទំនងឌីជីថល

## ៤. បុគ្គលិកលក្ខណៈនៃទំនាក់ទំនងឌីជីថល

ទំនាក់ទំនងឌីជីថល គឺជាទំនាក់ទំនងតាមរយៈឧបករណ៍អេឡិចត្រូនិកដូចជាទូរសព្ទ, កុំព្យូទ័រ ឬកុំព្យូទ័របន្ទះជាដើម។ ឧបករណ៍ដែលគេនិយមប្រើសម្រាប់ការប្រាស្រ័យទាក់ទងនេះ គឺកម្មវិធីអ៊ីមែល បណ្ដាញព័ត៌មានសង្គម ដូចជា Facebook, Twitter ឬ Google+ ឬកម្មវិធីផ្ញើសារភ្លាមៗ និងសន្និសីទជាវីដេអូ ដូចជាការប្រើកម្មវិធី LINE, Skype និង Whats app។ ខាងក្រោមនេះជាបុគ្គលិកលក្ខណៈជាក់លាក់ជាច្រើននៃទំនាក់ទំនងឌីជីថល៖

### វាមានភាពងាយស្រួល

បុគ្គលិកលក្ខណៈដ៏សំខាន់ គឺថាអ្នកអាចជ្រើសរើសពេលវេលា និងអ្នកណាដែលអ្នកចង់ទំនាក់ទំនង ទោះបីពួកគេស្ថិតនៅផ្នែកផ្សេងៗគ្នានៃពិភពលោកក៏ដោយ។ ឧទាហរណ៍ នៅម៉ោង ១០:០០ ព្រឹក នៅប្រទេសកម្ពុជា អ្នកអាចផ្ញើសារតាម Facebook ទៅមិត្តភ័ក្តិនៅប្រទេសអាល្លឺម៉ង់ ដែលទើបនឹងម៉ោង ៥:០០ ព្រឹកប្រទេសគេ។ មិត្តភ័ក្តិនោះ គាត់អាចពិនិត្យមើលសារនោះបន្ទាប់ពីគាត់ក្រោកពីដេក និងអាចឆ្លើយទៅអ្នកវិញបាននៅពេលណាក៏បានដែលវាងាយស្រួលសម្រាប់ពួកគេ។

### វាលឿនណាស់

បុគ្គលិកលក្ខណៈទីពីរនៃទំនាក់ទំនងឌីជីថល គឺថាវាលឿនខ្លាំងណាស់។ រាល់ការផ្លាស់ប្ដូរព័ត៌មានគ្រាន់តែចំណាយពេលមួយភ្លែតឆ្លងកាត់ពិភពលោកបានតែម្ដង តាមរយៈខ្សែកាបដែលដាក់នៅបាតសមុទ្រ។ ល្បឿននោះអាចល្អ និងមិនល្អ។ សារធ្វើដំណើរយ៉ាងលឿន ប៉ុន្តែពេលខ្លះយើងអាចសរសេរអ្វីមួយដែលយើងសោកស្ដាយនៅពេលក្រោយ។ អ្នកខ្លះឆ្លើយតបរួសរាន់ពេកដោយមិនបានបញ្ជាក់ និងពួកគេបញ្ជូនប្រតិកម្មរបស់ពួកគេជាពាក្យសម្ដី តែងតែបង្ហាញអារម្មណ៍ដូចជាខឹង និងកំហុសអក្ខរាវិរុទ្ធ។ ការសម្ដែងអារម្មណ៍អវិជ្ជមានអាចបំផ្លាញទំនាក់ទំនង និងកំហុសអក្ខរាវិរុទ្ធអាចធ្វើឱ្យអ្នកអានបែកអារម្មណ៍ និងអាចធ្វើឱ្យពួកគេយល់ខុស។ យកល្អត្រូវផ្អាកមួយភ្លែត និងគិតឡើងវិញមុនពេលសរសេរអ្វីមួយ ពិសេសនៅពេលអ្នកកំពុងមានអារម្មណ៍រំភើបចិត្ត។



### អន្តរកម្មជាធម្មតាសង្ខេប

បុគ្គលិកលក្ខណៈទីបីនៃទំនាក់ទំនងឌីជីថល គឺទំនាក់ទំនងដោយវាចាមានលប់លើទំនាក់ទំនងដោយមិនវាចា និងជាធម្មតា វាមានលក្ខណៈសង្ខេប មិនបង្ហាញពីអន្តរកម្មបុគ្គលដែលមានអត្ថន័យពេញលេញ និងច្រើនជាង។ នៅពេលយើងមានសកម្មភាពដោយជួបមុខគ្នាផ្ទាល់ យើងអាចឃើញកាយវិការ, ខ្សែភ្នែកទាក់ទាញ និងការសម្ដែងទឹកមុខរបស់មនុស្សផ្សេងៗដែលអាចបង្កើនការយល់ដឹងរបស់យើងកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។ ទំនាក់ទំនងតាមរយៈឧបករណ៍ឌីជីថល ជាទូទៅ

បានកំណត់ត្រឹមអេក្រង់ និងឧបករណ៍បំពងសំឡេងរបស់អ្នក ដោយផ្ដល់ឱ្យអ្នកនូវព័ត៌មានមានដែនកំណត់ដែលអាចប្រែអត្ថន័យ ដោយសារអ្នកត្រូវបានយកចេញពីទំនាក់ទំនងជាបុគ្គលជាក់ស្ដែង។

## ទិន្នន័យងាយរងគ្រោះ

បុគ្គលិកលក្ខណៈទីបួននៃទំនាក់ទំនងឌីជីថល គឺវាអាចចម្លង, ផ្លាស់ប្ដូរ ឬក៏ផ្សព្វផ្សាយឡើងវិញបាន។ សារនីមួយៗដែលអ្នកសរសេរ, មិត្តភ័ក្ដិនីមួយៗដែលអ្នកបន្ថែម និងមតិយោបល់ ឬរូបភាពនីមួយៗដែលអ្នកចែករំលែកត្រូវបានសរសេរកូដជាទិន្នន័យឌីជីថល និងបានរក្សាទុកនៅលើម៉ាស៊ីនមេនៃសេវាកម្មទាំងឡាយណាដែលអ្នកប្រើ ដូចជា Facebook ឬ LINE។ វាបង្ហាញបញ្ហាប្រឈមដ៏ធំធេងសម្រាប់ទំនាក់ទំនងឌីជីថលទាំងអស់។ អ្នកត្រូវដឹងថានៅពេលទិន្នន័យត្រូវបានផ្ទុកនៅលើអ៊ីនធឺណិត ទិន្នន័យនោះអាចត្រូវបានរកឃើញ ឬចម្លងពីកន្លែងណាមួយ។ ពាក្យ, រូបភាព ឬវីដេអូដែលអ្នកបានប្រកាសផ្សាយនឹងលែងស្ថិតក្រោមការត្រួតពិនិត្យរបស់អ្នកទៀតហើយ។

> *នៅពេលយើងនិយាយ ពាក្យរបស់យើងស្ថិតនៅមួយរយៈពេល តែបើយើងសរសេរវិញ ពាក្យរបស់យើងមានរហូត។*

## ងាយស្រួលមានភាពជិតស្និទ្ធជាមួយមនុស្ស

បុគ្គលិកលក្ខណៈទីប្រាំនៃទំនាក់ទំនងឌីជីថល គឺថាវាងាយស្រួលដែលស្ថិតនៅជាប់ជាមួយបុគ្គលនីមួយៗដែលមានចំណាប់អារម្មណ៍ដូចគ្នា និងមនុស្សដែលអ្នកមិនដែលបានជួប។ នេះជាមធ្យោបាយដើម្បីធ្វើសកម្មភាពទៅវិញទៅមក និងស្វែងយល់អំពីគំនិតថ្មីៗនៅពេលជាមួយគ្នា។ ឧទាហរណ៍ អ្នកអាចចូលរួមក្រុមក្នុងបណ្ដាញសង្គមដែលផ្ដោតអំពីកីឡា។ នៅពេលអ្នកបានចុះឈ្មោះជាមួយក្រុមនេះហើយអ្នកនឹងអាចមើលឃើញអ្វីដែលសមាជិកក្រុមបានប្រកាសផ្សាយ និងអ្នកអាចប្រកាសផ្សាយមតិយោបល់, រូបភាព និងវីដេអូអំពីប្រធានបទណាមួយបាន។ នៅពេលឆាប់ៗ អ្នក នឹងសម្គាល់ឃើញថា មនុស្សដែលមកពីកន្លែងផ្សេងៗនៅលើពិភពលោកក៏ជាសមាជិកនៃក្រុមនេះដែរ។ ទោះបីពួកគេប្រើភាសាផ្សេងៗគ្នាក៏ដោយ អ្នកនៅតែអាចប្រើកម្មវិធីផ្នែកបន្ថែមដើម្បីបកប្រែពាក្យទាំងនោះបានផងដែរ និងអាចយល់គ្នាបានផងដែរ។




ទំព័រដើមក្រុមអ្នកប្រើ LinkedIn ដ៏ធំនៅប្រទេសកម្ពុជា

## វាអាចធ្វើឱ្យយើងមិនខ្វល់ពីអ្នកដទៃនៅជុំវិញយើង

ចុងបញ្ចប់ បុគ្គលិកលក្ខណៈទីប្រាំមួយនៃទំនាក់ទំនងឌីជីថល គឺថាវាមានបំណងផ្លាស់ប្តូរបែបផែនជីវិតរស់នៅរបស់យើង។ យើងអាចក្លាយជាមនុស្សម្នាក់ដែលតែងតែនៅជាប់ជាមួយឧបករណ៍ឌីជីថលរបស់យើងដែលយើងលែងផ្តោតអារម្មណ៍គ្រប់គ្រាន់ទៅមនុស្ស និងសកម្មភាពដែលនៅជុំវិញយើង។ ឧទាហរណ៍ នៅហាងកាហ្វេ អ្នកប្រហែលឃើញមនុស្សកំពុងផ្ញើសារ ឬឆែកអ៊ីមែល ម្នាក់ៗដៃចុចទូរសព្ទ មិននិយាយរកគ្នា។ យើងត្រូវមានការយល់ដឹងជ្រៅជ្រះអំពីរបៀបដែលឧបករណ៍ឌីជីថលអាចធ្វើឱ្យយើង មិនផ្តោតសំខាន់លើសកម្មភាពបុគ្គលជាក់ស្តែងរវាងគ្នាទៅវិញទៅមក។



# ៥. ទំនាក់ទំនងជាសាធារណៈ និងបណ្តាញសង្គម

បណ្តាញសង្គម គឺជាឧបករណ៍ដ៏សំខាន់មួយសម្រាប់ផ្លាស់ប្តូរគំនិតគ្នា, ទទួលបានព័ត៌មាន និងអាចរក្សាភាពជិតស្និទ្ធជាមួយអ្នកប្រើផ្សេងៗនៅក្នុងបណ្តាញដូចគ្នា។ Facebook គឺជាបណ្តាញសង្គមដ៏មានប្រជាប្រិយបំផុតនៅប្រទេសកម្ពុជា និងនៅបណ្តាប្រទេសផ្សេងៗ ដែលមានគណនីបានចុះឈ្មោះជាង ១ពាន់លានលើសកលលោកនៅក្នុងឆ្នាំ ២០១៥។ បណ្តាញសង្គមមិនតែងតែជាឧបករណ៍ទំនាក់ទំនងឌីជីថលដែលត្រូវប្រើប្រសើរបំផុតនោះទេ ទោះជាយ៉ាងណាក៏ដោយ ព្រោះវាត្រូវបានផ្សាយជាសាធារណៈ និងសាធារណៈជនទូទៅមិនចាំបាច់ត្រូវដឹងអ្វីៗទាំងអស់អំពីអ្នកនោះទេ។ វាចាំបាច់ត្រូវប្រើឧបករណ៍ដ៏សមរម្យមួយតាមកាលៈទេសៈអាស្រ័យតាមកត្តាដូចជាភាពស្មុគស្មាញនៃសាររបស់អ្នក, អ្នកទទួល, ភាពឯកជន, កាលៈទេសៈ, ភាពបន្ទាន់ និងភាពចាំបាច់ត្រូវឆ្លើយតប។ ឧបករណ៍ខ្លះធ្វើបានភ្លាមៗ ដូចជាការជជែក ដែលឧបករណ៍ផ្សេងៗដូចជាអ៊ីមែល អាចមិនធ្វើភ្លាមៗក៏បាន។ ឧបករណ៍ខ្លះមានប្រវែងកំណត់ ឧទាហរណ៍ សារខ្លី SMS ឬ IM តាមរយៈទូរសព្ទត្រូវសរសេរឱ្យខ្លី។ ផ្សេងទៀត ដូចជាសារជាឯកជននៅលើ Facebook, អនុញ្ញាតឱ្យសរសេរវែងបានតាមចិត្ត។ ការហៅទូរសព្ទជានិច្ចកាលត្រូវបានគេគិតថារំខាន ចំណែកឯជាអត្ថបទប្រហែលមិនមែនជាអញ្ចឹង។ ទំនាក់ទំនងខ្លះមានលក្ខណៈជាឯកជន ដូចជាការហៅជាវីដេអូតាមរយៈកម្មវិធី Skype និងផ្សេងទៀតជាការផ្សព្វផ្សាយសាធារណៈ ដូចជាការប្រកាសផ្សាយនៅលើបណ្តាញសង្គម ដូចជា Facebook, LinkedIn ឬ Google+ ជាដើម។ តារាងខាងក្រោមផ្តល់ពីទិដ្ឋភាពសង្ខេបដើម្បីជួយអ្នកសម្រេចចិត្តជ្រើសរើសឧបករណ៍ដែលប្រសើរដើម្បីប្រើតាមកាលៈទេសៈ និងគោលបំណងជាក់លាក់។

■ ស័ក្តិសមណាស់ ■ ពេលខ្លះស័ក្តិសម ពេលខ្លះមិនស័ក្តិសម ■ មិនស័ក្តិសម

| | | មិនមែនសាធារណៈ | | | | សាធារណៈ |
|---|---|---|---|---|---|---|
| | | ការសន្ទនាផ្ទាល់ខ្លួន | សារខ្លី SMS ជាអត្ថបទ/IM | ការហៅតាមទូរសព្ទ | អ៊ីមែល | បណ្តាញសង្គម |
| ចរិត ៖ ភាពស្មុគស្មាញ | សាររបស់ខ្ញុំសង្ខេប | ស័ក្តិសមណាស់ | ស័ក្តិសមណាស់ | ពេលខ្លះស័ក្តិសម ពេលខ្លះមិនស័ក្តិសម | ស័ក្តិសមណាស់ | ស័ក្តិសមណាស់ |
| | សាររបស់ខ្ញុំមានបទពិសោធន៍ផ្ទាល់ខ្លួន | ស័ក្តិសមណាស់ | ពេលខ្លះស័ក្តិសម ពេលខ្លះមិនស័ក្តិសម | ស័ក្តិសមណាស់ | ស័ក្តិសមណាស់ | ពេលខ្លះស័ក្តិសម ពេលខ្លះមិនស័ក្តិសម |
| | សាររបស់ខ្ញុំគួរអាចដោះស្រាយជម្លោះបាន | ស័ក្តិសមណាស់ | មិនស័ក្តិសម | មិនស័ក្តិសម | មិនស័ក្តិសម | មិនស័ក្តិសម |
| អ្នកទស្សនា ៖ ទំនាក់ទំនង | ខ្ញុំទាក់ទងមិត្តភ័ក្តិ ឬគ្រួសារខ្ញុំ | ស័ក្តិសមណាស់ | ស័ក្តិសមណាស់ | ស័ក្តិសមណាស់ | ស័ក្តិសមណាស់ | ស័ក្តិសមណាស់ |
| | ខ្ញុំទាក់ទងមន្ត្រីរដ្ឋាភិបាល | ស័ក្តិសមណាស់ | មិនស័ក្តិសម | ស័ក្តិសមណាស់ | ស័ក្តិសមណាស់ | មិនស័ក្តិសម |
| | ខ្ញុំទាក់ទងមនុស្សដែលខ្ញុំមិនស្គាល់ | ពេលខ្លះស័ក្តិសម ពេលខ្លះមិនស័ក្តិសម | មិនស័ក្តិសម | មិនស័ក្តិសម | មិនស័ក្តិសម | ពេលខ្លះស័ក្តិសម ពេលខ្លះមិនស័ក្តិសម |
| បន្ទាន់ ៖ ត្រូវឆ្លើយ | វាបន្ទាន់មិនចាំបាច់ត្រូវឆ្លើយតប | ពេលខ្លះស័ក្តិសម ពេលខ្លះមិនស័ក្តិសម | ពេលខ្លះស័ក្តិសម ពេលខ្លះមិនស័ក្តិសម | ស័ក្តិសមណាស់ | ពេលខ្លះស័ក្តិសម ពេលខ្លះមិនស័ក្តិសម | ពេលខ្លះស័ក្តិសម ពេលខ្លះមិនស័ក្តិសម |
| | វាបន្ទាន់ត្រូវឆ្លើយតប | ស័ក្តិសមណាស់ | មិនស័ក្តិសម | ស័ក្តិសមណាស់ | មិនស័ក្តិសម | មិនស័ក្តិសម |
| | វាមិនប្រញាប់ | ស័ក្តិសមណាស់ | ស័ក្តិសមណាស់ | ស័ក្តិសមណាស់ | ស័ក្តិសមណាស់ | ស័ក្តិសមណាស់ |




ទំព័រដើមរបស់អ្នកប្រើ Google+

# ៥.១. ភាពឯកជន និងការចែករំលែក

សូមមើលស្ថានភាពជាមួយចរណៃ និងមិត្តភ័ក្តិរបស់នាង។



នៅព្រឹកមួយ ចរណៃជួបជាមួយមិត្តភ័ក្តិរបស់នាងឈ្មោះម៉ាលី និងចិន្តានៅហាងកាហ្វេ។ ចរណៃចង់ជជែក និងនិយាយគ្នាលេង ប៉ុន្តែចិន្តាហាក់ដូចជាចាប់អារម្មណ៍មើលតែទូរសព្ទរបស់នាង។ ចិន្តាអានសារពីឌីណា សិស្សប្រុសថ្មីនៅក្នុងថ្នាក់៖ "ចិន្តា, WKD2long, H2CUS ;-)" ហើយលាន់មាត់ថា, "ឌីណាសង្ឃឹមថាជួបខ្ញុំឆាប់ៗ។ គាត់ដូចជាគួរឱ្យចូលចិត្តណាស់!"

ចរណៃតបវិញភ្លាមៗថា "អ្នកគិតថាគាត់គួរឱ្យចូលចិត្តមែនទេ? តើអ្នកអាចដឹងថាគាត់ពិតជាយ៉ាងដូច្នេះមែន? អ្នកមិនស្គាល់គាត់ច្បាស់ផង ហើយនេះគ្រាន់តែជាសារខ្លីជាអក្សរកាត់សោះហ្នឹង!"

ចិន្តាឆ្លើយវិញថា "ប្រហែលហើយ ប៉ុន្តែម្សិលមិញនៅសាលាគាត់បានសួរខ្ញុំថាខ្ញុំចង់ធ្វើអ្វីដែរនៅចុងសប្តាហ៍នេះ ហើយគាត់បាននិយាយថារីករាយណាស់ដែលបានជួបខ្ញុំ។"

ចិន្តានិយាយថា "ខ្ញុំសង្ឃឹមថាវាជាការពិតចុះ ខ្ញុំបានបកស្រាយសារតាមមធ្យោបាយនេះ ហើយវាពិតជាមានន័យផ្សេង។ វាពិតជាលំបាកយល់ចិត្តមនុស្សដោយមិនបាននិយាយជាមួយគេផ្ទាល់។"

ចិន្តាបង្ហាញរូបភាពខ្លះពីគណនី Facebook របស់ឌីណា ហើយចរណៃក៏ភ្លាត់មាត់និយាយថា "តើគាត់ហ្នឹងពិតជាបានប្រកាសផ្សាយថាគាត់ចង់រកគ្នាចូលខារ៉ាអូខេជាមួយគាត់យប់នេះមែនទេ?"

ម៉ាលីបានលូកមាត់និយាយថា "គ្មានអ្វីទេ! អ្នកគួរឃើញពីអ្វីដែលចិន្តាប្រកាសផ្សាយរាល់ថ្ងៃ -- ព័ត៌មានលម្អិតផ្ទាល់ខ្លួនច្រើនពេកហើយ! ខ្ញុំគិតថានាងគួរគិតឱ្យបានល្អិតល្អន់មុនពេលប្រកាសផ្សាយព័ត៌មានឯកជនផ្ទាល់ខ្លួនច្រើនហួសហេតុពេក។"

ចិន្តាសួរថា "ហេតុអ្វីខ្ញុំគួរផ្លាស់ប្តូរ?"

ចរណៃ និងម៉ាលីមើលមុខគ្នា ហើយងក់ក្បាល។ ម៉ាលីនិយាយថា "ចិន្តា ការចែករំលែកព័ត៌មានផ្ទាល់ខ្លួនច្រើនពេកនៅលើបណ្តាញ Facebook គឺមិនមែនជារឿងល្អដែលត្រូវធ្វើនោះទេ។ អ្នកអនុញ្ញាតឱ្យមនុស្សដែលយើងមិនស្គាល់ក្លាយជាមិត្តភ័ក្តិតាម Facebook របស់អ្នក ហើយឥឡូវអ្នកកំពុងចែករំលែកព័ត៌មានផ្ទាល់ខ្លួនជាមួយពួកគេ។ ពួកគេអាចដឹងថាឯងនៅទីណានៅពេលឯងប្រកាសព័ត៌មាននោះ ហើយពួកគេដឹងកន្លែងដែលឯងរស់នៅ។ វាអាចមានអ្នកណាម្នាក់ប្លន់ឯង។"

"តើអ្នកពិតជាគិតថាខ្ញុំចែករំលែកច្រើនពេកមែនទេ? តើអ្នកគិតយ៉ាងដូចម្តេចដែរ?" ចិន្តាសួរ។



មាលីឆ្លើយតបថា "ខ្ញុំរីករាយនឹងបង្ហាញអ្នកអំពីមធ្យោបាយការពារភាពឯកជនរបស់អ្នក។ សូមធ្វើវានៅចុងសប្តាហ៍នេះ។"

បន្ទាប់មកមិត្តភ័ក្តិទាំងបីអង្គុយលើកៅអីនិយាយអំពីរឿងជីវិតរបស់ពួកគេ។

ក្រោយមកទៀត ចរណៃជិះកង់ទៅផ្ទះម៉ាលី និងពួកគេមើលប្រកាស Facebook របស់ចរណៃជាមួយគ្នា។ នៅប៉ុន្មានម៉ោងមុន ចរណៃបានប្រកាសផ្សាយការរចនារូបចតមួយសន្លឹកដែលមានបង្ហាញរូបភាពប្រវត្តិរូបរបស់ឪណានៅខាងឆ្វេង និងចិន្តាពាក់អាវក្រៅស្ទើងនៅខាងស្តាំ ផ្សារភ្ជាប់ទំនាក់ទំនងពួកគេដោយក្តីស្នេហា និងការសន្យាថា "ស្រឡាញ់គ្នាលុះក្ស័យ"។ ចរណៃនិយាយទៅកាន់មាលីថា "ឯងប្រហែលត្រូវជួបជាមួយចិន្តាឥឡូវហើយ។ វាមានពាក្យពេចន៍មួយចំនួនដែលនិយាយមិនសមរម្យអំពីនាងនៅលើ Facebook។"



ចរណៃ និងម៉ាលីមើលឃើញថាប្រកាសនេះត្រូវបានចែករំលែក និងផ្តល់មតិដោយអ្នកផ្សេងៗជាច្រើន។ មានមតិមកពីចាន់ណាក់ ជាមនុស្សមិនស្គាល់ ដែលវាយប្រហារចិន្តាដោយផ្តល់មតិខ្លាំងថា "ស្រមៃទៅ! មីនាង" ហើយមតិនោះទទួលបានការចូលចិត្តច្រើន។ ម៉ាលី និងចរណៃដឹងថាពួកគេត្រូវធ្វើអ្វីម្យ៉ាងបន្ទាន់ដើម្បីស្តារកេរ្តិ៍ឈ្មោះមិត្តភ័ក្តិរបស់នាង។

ដូចដែលចិន្តា និងមិត្តភ័ក្តិរបស់នាងដែរ អ្នកត្រូវត្រៀមខ្លួនសម្រាប់កត្តាប្រឈមនៃបច្ចេកទេសឌីជីថលបែបនេះ។ វាសំខាន់ដែលត្រូវដឹងអំពីរបៀបទំនាក់ទំនងយ៉ាងច្បាស់លាស់ និងដោយសុវត្ថិភាពដើម្បីជៀសវាងអន្ទាក់, ភាពអាម៉ាស់ ឬការយល់ខុសអំពីអ្វីមួយដែលយើងប្រកាសផ្សាយជាសាធារណៈ។

ភាពភ្លើតភ្លើនលើបណ្តាញសង្គមដោយការចែករំលែកព័ត៌មាន, បង្ហោះរូបភាព, ចូលចិត្ត និងផ្តល់មតិយោបល់ផ្ទេសផ្តាស។ យ៉ាងណាក៏ដោយ ពេលខ្លះអ្នកប្រើភ្លេចថាការផ្សាយជាសាធារណៈបែបនេះមានផលប៉ះពាល់អ្វីខ្លះ។ ស្រមៃមើលខ្លួនអ្នកនៅទីកន្លែងសាធារណៈដូចជា នៅផ្សារទិញអាហារ។ តើអ្នកគួរចែករំលែករឿងរ៉ាវឯកជនផ្ទាល់ខ្លួនរបស់អ្នកជាមួយមនុស្សគ្រប់គ្នានៅទីនោះដែរឬទេ? តើអ្នកគួរឱ្យអាសយដ្ឋាន ឬលេខទូរសព្ទរបស់អ្នកទៅពួកគេដែរឬទេ? តើរូបភាពបែបណាដែលអ្នកគួរបង្ហាញដល់ពួកគេ?

ដើម្បីការពារខ្លួនអ្នកពីអ្វីដែលមាននៅលើអ៊ីនធឺណិត និងមិននៅលើអ៊ីនធឺណិត វាសំខាន់ត្រូវស្វែងយល់ឱ្យបានដិតដល់អំពីសុវត្ថិភាព និងភាពឯកជននៃបណ្តាញសង្គម។ ភាពឯកជន ត្រូវបានកំណត់ថាជាលក្ខខណ្ឌកំណត់សេរីភាពពីការអង្កេត ឬរំខានដោយអ្នកផ្សេងៗ។ ជាក់ស្តែង វាមានន័យថាអ្នកមានសិទ្ធិគ្រប់គ្រងអ្វីដែលកើតឡើងជាមួយព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក។ Facebook និងបណ្តាញសង្គមផ្សេងៗទៀតអនុញ្ញាតឱ្យអ្នកប្រើកំណត់ភាពឯកជនរបស់ខ្លួនពួកគេ និងវាស្រេចតែអ្នកប្រើវា។ ភាពឯកជនត្រូវបានគេឱ្យតម្លៃខ្ពស់ ជាសិទ្ធិដែលការពារ និងជួយអ្នកជៀសវាងការរំលោភបំពាន, ឧក្រិដ្ឋកម្ម, ការបៀតបៀនភាពអាម៉ាស់ដោយអ្នកផ្សេងៗ។ ដាច់ខាត យើងមិនត្រូវប្រាប់អ្នកណាម្នាក់ថាយើងមានប្រាក់ច្រើននៅផ្ទះ យើងមិនត្រូវបង្ហាញខ្លួនអាក្រាតរបស់យើង និងយើងមិនត្រូវបញ្ចេញប្រាប់ឱ្យគេដឹងពីអារម្មណ៍វិជ្ជមាន និងអវិជ្ជមានរបស់យើងដល់អ្នកផ្សេងនោះទេ។ ឧទាហរណ៍ទាំងនេះជាទម្រង់ទាំងអស់នៃភាពឯកជន។

ជំនួយខាងក្រោមនឹងជួយអ្នកថែទាំភាពឯកជនរបស់អ្នកនៅលើ Facebook ឬបណ្តាញសង្គមផ្សេងៗ៖

- កែសម្រួលការកំណត់នៅក្នុងបណ្តាញសង្គមរបស់អ្នកដើម្បីត្រួតពិនិត្យព័ត៌មានអ្វីអំពីអ្នកត្រូវបានផ្សព្វផ្សាយ និងដើម្បីដឹងថាពេលណាគេបានដាក់ស្លាកឈ្មោះរបស់អ្នកនៅក្នុងរូបភាព និងដើម្បីប្រាកដថាគ្មានអ្នកណាម្នាក់អាចផ្សាយអ្វីមួយនៅលើកាលប្រវត្តិ (Timeline) របស់អ្នកដោយគ្មានការអនុញ្ញាតពីអ្នកទេ។ ផ្តល់សិទ្ធិឱ្យអ្នកអនុញ្ញាត ឬបដិសេធអ្វីដែលគេសរសេរនៅលើកាលប្រវត្តិរបស់អ្នក មុនពេលវាត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ យល់ដឹងអំពីរបៀបលុបស្លាកដែលមានឈ្មោះរបស់អ្នក ប្រសិនបើអ្នកមិនចង់ឱ្យគេផ្សាយវាជាសាធារណៈ។
- ខណៈដែលវាអាចជារឿង "អស្ចារ្យ" ដែលមានមិត្តភក្តិច្រើននៅលើបណ្តាញ Facebook ការទទួលយកអ្នកណាម្នាក់ដែលសុំធ្វើជាមិត្តភក្តិរបស់អ្នក មានន័យថាអ្នកកំពុងផ្តល់ព័ត៌មានអំពីខ្លួនអ្នកដល់មនុស្សដែលអ្នកមិនស្គាល់។ សូមសម្រេចចិត្តជ្រើសរើសមិត្តភក្តិដោយប្រុងប្រយ័ត្ន។
- កុំប្រកាសផ្សាយ ឬផ្ញើរូបភាពដែលអាចធ្វើឱ្យអ្នកអាម៉ាស់ ប្រសិនបើវាត្រូវបានឃើញដោយមនុស្សផ្សេងដែលអ្នកមិនបានផ្ញើវាទៅពួកគេនោះទេ។ នៅពេលអ្នកបានផ្ញើរូបថត អ្នកមិនដឹងច្បាស់ថាអ្នកណាម្នាក់នឹងចែករំលែកវា ឬប្រើវាយ៉ាងដូចម្តេច។ សូមធ្វើការប្រុងប្រយ័ត្នជាពិសេសជាមួយរូបភាពដែលអាចគេយកទៅប្រើដើម្បីបកស្រាយជាមាតិកាព័ត៌មានបែបផ្លូវភេទ។
- មុនពេលអ្នកប្រកាសផ្សាយអ្វីមួយសូមពិចារណាថាអ្នកអាចមានភាពសុខស្រួលកម្រិតណាជាមួយមនុស្សដែលកំពុងឃើញព័ត៌មាននេះ។ ប្រសិនបើអ្នកចង់ប្តឹងផ្តល់អ្នកណាម្នាក់សាលារៀន ឬប្រសិនបើអ្នកមានអារម្មណ៍អ្វីម៉្យាង វាមិនគួរត្រូវប្រកាសផ្សាយវាជាសាធារណៈទេ ព្រោះព័ត៌មាននោះអាចផ្សាយដល់មនុស្សដែលអ្នកកំពុងប្តឹងផ្តល់ និងអាចបង្កឱ្យអ្នកមានបញ្ហាធំ។ សូមពិចារណាដោះស្រាយបញ្ហាដោយផ្ទាល់តាមរយៈការសន្ទនាគ្នាវិញ ជាជាងផ្សាយវាលើអ៊ីនធឺណិតភ្លាមៗ។

សូមចងចាំថាក្រុមហ៊ុនតែងតែរកមើលប្រវត្តិរូបបេក្ខជនតាមបណ្តាញសង្គមដើម្បីរកមើលព័ត៌មានអំពីបេក្ខជន ឬបុគ្គលិកដែលដាក់ពាក្យធ្វើការនៅក្រុមហ៊ុនរបស់ពួកគេ។ ពួកគេអាចនឹងដកចេញបេក្ខជនដែលមិនបំពេញតាមស្តង់ដារ ឬលក្ខខណ្ឌជ្រើសរើសរបស់ក្រុមហ៊ុន ហើយបុគ្គលិកអាចនឹងត្រូវបណ្តេញចេញប្រសិនបើពួកគេប្រកាសផ្សាយព័ត៌មានដែលរំលោភបំពានគោលនយោបាយរបស់ក្រុមហ៊ុន។

បណ្តាញ Facebook និងបណ្តាញសង្គមទាំងអស់ផ្សេងទៀត មិនមែនពួកគេមានចិត្តសប្បុរសផ្តល់សេវាឥតគិតថ្លៃដល់អ្នកជាវនោះទេ ពួកគេជាក្រុមហ៊ុនជំនួញដែលរកប្រាក់ចំណេញតាមរយៈការផ្សាយពាណិជ្ជកម្ម និងទទួលប្រាក់ចំណាយសម្រាប់ហ្គេមដែលមាននៅលើបណ្តាញរបស់ពួកគេ។ ព័ត៌មានទាំងអស់ដែលពួកគេមានអំពីអ្នកប្រើរបស់ពួកគេត្រូវបានរក្សាទុកដាក់ និងគិតថាជាសម្បត្តិរបស់ពួកគេ។ វារួមមានទាំងព័ត៌មានផ្ទាល់ខ្លួនដូចជាអាសយដ្ឋាន, អាយុ, ចំណាប់អារម្មណ៍ និងអ្នកណាជាមិត្តភក្តិរបស់

អ្នក។ ក្រុមហ៊ុនបណ្ដាញសង្គមរកប្រាក់តាមរយៈការលក់ទិន្នន័យដែលបានរក្សាទុកនេះទៅឱ្យក្រុមហ៊ុនជំនួញផ្សេងទៀតដែលចាប់អារម្មណ៍វា ហើយពួកគេអាចប្រើវាដោយខ្លួនឯងសម្រាប់គោលបំណងទីផ្សារផ្សព្វផ្សាយ។ ឧទាហរណ៍ អ្នកតែងមើលឃើញពាណិជ្ជកម្មផ្សេងៗនៅក្នុងទំព័របណ្ដាញ Facebook របស់យើង នោះមានន័យថាម្ចាស់ពាណិជ្ជកម្មបានបង់ប្រាក់ឱ្យ Facebook ដើម្បីផ្សាយពាណិជ្ជកម្មនេះដល់អ្នកប្រើ Facebook នេះ។

# ៥.២. ទំនាក់ទំនងដោយគោរព និងទទួលខុសត្រូវ

មិនថាអ្នកកំពុងប្រើឧបករណ៍ ឬកម្មវិធីឌីជីថលណាទេ អ្នកគួរមិនត្រូវភ្លេចថាអ្នកកំពុងទំនាក់ទំនងជាមួយមនុស្សពិត និងមិនមែនជាតួអង្គក្នុងល្ខោននោះទេ។ ការប្រាស្រ័យទាក់ទងគ្នាដោយការគោរព និងទទួលខុសត្រូវមានភាពចាំបាច់ណាស់សម្រាប់ចែករំលែកគំនិត និងកសាងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពនៅលើអ៊ីនធឺណិត។ សូមធ្វើតាមអ្វីដែលមានតម្លៃ និងគុណប្រយោជន៍ ដូចជាព្រឹត្តិការណ៍ពិត ឬបទពិសោធន៍ដែលចាប់អារម្មណ៍ចំពោះអ្នក និងអ្នកផ្សេងៗ។ សូមកុំចែករំលែក ឬផ្សព្វផ្សាយព័ត៌មានដែលជាពាក្យចចាមអារ៉ាម, ភូតភរ ឬពិតពាក់កណ្ដាល និងកុំផ្សាយដល់អ្នកផ្សេងៗនូវមាតិកាព័ត៌មានដែលគ្មានន័យ និងគុណប្រយោជន៍អ្វីសោះ ដែលអាចបង្កទុក្ខទោសដល់យើង។

ទំនាក់ទំនងដោយការគោរព រួមមានការសរសេរនៅលើអ៊ីនធឺណិតចំពោះតែអ្វីដែលអ្នកមានបំណងនិយាយចំពោះមុខមនុស្សម្នាក់នោះ, សូមតែងតែនិយាយដោយការគោរពអ្នកដទៃ ដូចអ្វីដែលអ្នកចូលចិត្តឱ្យគេគោរពអ្នក និងពិនិត្យមើលថាភាសារបស់អ្នកមិនធ្វើឱ្យគេអាក់អន់ចិត្ត។ អ្នកអាចប្រើរូបសញ្ញាអារម្មណ៍ និងអក្សរកាត់ដើម្បីបញ្ជូនអត្ថន័យបន្ថែម ប្រសិនបើរបៀបរបបនៃការនិយាយរបស់អ្នកគួរឱ្យចង់សើច ឬកំប្លែង ឬធ្វើដោយមិនបានគិតមុន ដើម្បីប្រាកដថាការសរសេររបស់អ្នកមិនត្រូវបានបកស្រាយខុសជាការរិះគន់ ឬជេរប្រមាថ។

ទំនាក់ទំនងដោយការគោរពក៏ពាក់ព័ន្ធនឹងការការពារភាពឯកជនរបស់អ្នកដទៃផងដែរ ដោយមិនត្រូវប្រកាសផ្សាយព័ត៌មានអំពីពួកគេដោយមិនមានការអនុញ្ញាតនោះទេ។ ឧទាហរណ៍ អ្នកមិនគួរប្រកាសផ្សាយរូបភាពរបស់អ្នកដទៃ ឬឱ្យអាសយដ្ឋានអ៊ីមែលរបស់អ្នកណាម្នាក់ ឬព័ត៌មានផ្ទាល់ខ្លួនផ្សេងៗដោយមិនសុំការអនុញ្ញាតជាមុនទេ។



ជាអកុសល ពាក្យ និងរបៀបរបបនិយាយដែលស្តែងចេញដោយអវិជ្ជមាន, សម្តីដែលគួរឱ្យស្អប់ខ្ពើម និងការនិយាយសម្លុតគំរាមតាមអ៊ីនធឺណិត គឺជាផ្នែកដ៏ខ្មៅងងឹតនៃទំនាក់ទំនងឌីជីថល ដែលមិនគួរប្រព្រឹត្តឡើយ។ ហេតុអ្វីវាដូច្នេះ? នៅលើអ៊ីនធឺណិត មនុស្សមិនឃើញមុខគ្នាផ្ទាល់ ហើយអ្នកខ្លះធ្វើមិនដឹងជាមួយច្បាប់ និងសីលធម៌នៃអាកប្បកិរិយាសង្គមដែលបានឯកភាពគ្នា។ មានអារម្មណ៍គិតថាមិនស្គាល់ និងខុសដែលថាអ្វីគ្រប់យ៉ាងត្រូវបានអនុញ្ញាតនៅលើអ៊ីនធឺណិត ដែលធ្វើឱ្យមនុស្សខ្លះប្រកាសផ្សព្វផ្សាយ រួមទាំងមតិយោបល់ជាពាក្យពេចន៍ជេរប្រមាថ និងវាយប្រហារជាបុគ្គលតាមរយៈទំនាក់ទំនងឌីជីថលនេះ។

ការជេរប្រមាថតាមអ៊ីនធឺណិត គឺជាការប្រើបច្ចេកវិទ្យាព័ត៌មានដើម្បីជេរប្រមាថ ឬបៀតបៀន ធ្វើឱ្យអ្នកណាម្នាក់អាម៉ាស់មុខ ឬបង្កទុក្ខទោសដល់អ្នកណាម្នាក់ម្តងហើយម្តងទៀត និងដោយចេតនា។ ជាធម្មតាការជេរប្រមាថតាមអ៊ីនធឺណិតនេះមានគោលដៅចំពោះបុគ្គលណាមួយច្បាស់លាស់ ដែលជាញឹកញាប់ច្រើនតែកើតរវាងបុគ្គលិកនៅកន្លែងធ្វើការ ឬសិស្សនៅតាមសាលា និងអាចមានការផ្សាយពាក្យចចាមអារ៉ាម, ចែករំលែករូបថត ឬវីដេអូដែលធ្វើឱ្យខូចកេរ្តិ៍ឈ្មោះគេ ឬផ្ញើអ៊ីមែល ឬសារភ្លាមៗដែលគេមិនចង់បាន។ វាអាចមានទាំងការបន្លំធ្វើជាអ្នកណាម្នាក់នៅលើវេបសាយសង្គម។ អ្នកប្រព្រឹត្តិបទល្មើសតែងតែមើលងាយផលប៉ះពាល់នៃការបៀតបៀនរបស់ពួកគេ និងជនរងគ្រោះតែងតែមានអារម្មណ៍ឈឺចាប់ ឬភ័យខ្លាចចំពោះរឿងនេះ។ ការជេរប្រមាថ ឬសម្លុតអាចជាការទប់អារម្មណ៍មិនបានភ្លាមៗចែកចាយពេញបណ្តាញប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម និងធ្វើឱ្យខូចកេរ្តិ៍ឈ្មោះ។ អ្នកប្រព្រឹត្តិបទល្មើសជានិច្ចកាលមិនដឹងថាពួកគេនៅក្នុងបណ្តាញដែលអាចធ្វើឱ្យសកម្មភាពរបស់ពួកគេក្លាយជាបទឧក្រិដ្ឋកម្មដែលនឹងផ្តន្ទាទោស។ ដើម្បីជួយឱ្យទំនាក់ទំនងបណ្តាញសង្គមមានភាពត្រឹមត្រូវ ទាំងអស់គ្នាត្រូវមានការពាក់ព័ន្ធ។

ការសម្លុតគំរាមតាមអ៊ីនធឺណិតអាចបណ្តាលឱ្យជនរងគ្រោះមានរោគផ្លូវចិត្តយូរអង្វែង



ខាងក្រោមនេះជាដំបូន្មានខ្លះៗអំពីរបៀបដោះស្រាយការសម្លុតគំរាមតាមប្រព័ន្ធអ៊ីនធឺណិតដែលកើតមានជាមួយអ្នកផ្ទាល់៖

- **កុំឆ្លើយតប៖** កុំឆ្លើយតបនឹងការសម្លុតគំរាម ឬប្រាប់អារម្មណ៍របស់អ្នកឱ្យពួកគេដឹង។ ការសម្លុតគំរាមចង់បានព្រឹត្តិកម្មតប។ ប្រសិនបើ អ្នកមិនឆ្លើយតបអ្វីទៅពួកគេទេ ពួកគេអាចនឹងឈប់បន្តរករឿងអ្នក។
- **ទប់ស្កាត់អ្នកបៀតបៀន៖** ស្រាវជ្រាវរកមើលការកំណត់ភាពឯកជនរបស់អ្នក និងទប់ស្កាត់អ្នកបៀតបៀនទាំងឡាយណាពីការទាក់ទងអ្នក ឬមើលឃើញព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក។ ផ្លាស់ប្តូរការកំណត់គណនីរបស់អ្នក ដើម្បីកុំឱ្យអាសយដ្ឋាន, លេខទូរសព្ទ និងអ្វីអំពីអ្នកត្រូវបានផ្សាយចេញនៅលើអ៊ីនធឺណិត។ ផ្លាស់ប្តូរពាក្យសម្ងាត់របស់អ្នក ជាពិសេស ប្រសិនបើអ្នកណាម្នាក់បានប្រើគណនីផ្ទាល់ខ្លួនរបស់អ្នកបន្លំធ្វើជាអ្នក។
- **រាយការណ៍បញ្ហាដែលកើតឡើង** ទៅ Facebook ឬ បណ្តាញសង្គមណាមួយដែលអ្នកកំពុងប្រើ ដោយចូលទៅមុខងាររាយការណ៍ និងបំពេញបែបបទរាយការណ៍។ នៅពេលអ្នកបានរាយការណ៍បញ្ហាដែលកើតឡើងហើយ នោះបណ្តាញសង្គមអាចមានលទ្ធភាពត្រួតពិនិត្យតាមដានអ្នកប្រព្រឹត្តិបទល្មើស និងអាចបិទគណនីរបស់គេចោល ដោយសារការរំលោភបំពានលក្ខខណ្ឌ

ប្រើប្រាស់របស់បណ្តាញសង្គមនោះ។ បណ្តាញសង្គមក៏អាចលុបរូបភាពរបស់អ្នក ប្រសិនបើអ្នកមិនចង់បង្ហាញវានៅលើអ៊ីនធឺណិតទេ។ បន្ថែមពីនេះទៀត អ្នកអាចរាយការណ៍សកម្មភាពបៀតបៀននេះទៅមិត្តភ័ក្តិ, ឪពុកម្តាយរបស់អ្នក និងប៉ូលិស ដោយសារការបៀតបៀន គឺជាឧក្រិដ្ឋកម្មដែលអាចដាក់ពិន័យដោយច្បាប់ ជាពិសេស ប្រសិនបើមានការគំរាមកំហែងដោយហិង្សា ឬការលួងលោមចាប់ណាមួយ។

- **កត់ត្រាជានិច្ច៖** រក្សាទុកសារជាអត្ថបទ, ប្រកាស និងភស្តុតាងផ្សេងៗទាំងអស់ពីអ្នកបៀតបៀនទុកលើឧបករណ៍របស់អ្នក ដោយមិនកែច្នៃវា ដូច្នេះពួកគេអាចជួយអ្នក និងមានភស្តុតាងសម្រាប់ករណីនេះ ប្រសិនបើវាចាំបាច់។

គ្រោះថ្នាក់ដែលជាគោលដៅនៃការសម្លុតគំរាមតាមប្រព័ន្ធអ៊ីនធឺណិតអាចត្រូវបានកាត់បន្ថយតាមរយៈសកម្មភាពដោយប្រុងប្រយ័ត្ន នៅពេលប្រើទំនាក់ទំនងឌីជីថល។ ខាងក្រោមនេះជាវិធីសាស្ត្រមូលដ្ឋានខ្លះដែលត្រូវអនុវត្តតាមដើម្បីការពារខ្លួនអ្នក៖

- ពិនិត្យមើលប្រកាសរបស់អ្នកមុនពេលផ្ញើ។ ប្រសិនបើប្រកាសរបស់អ្នកអាចបណ្តាលឱ្យមានការឆ្លើយតបជាអវិជ្ជមាន សូមគិតឡើងវិញម្តងទៀតមុនពេលអ្នកចែករំលែក។ យកល្អកុំប្រកាសផ្សាយ ឬផ្តល់មតិយោបល់ ដែលអាចធ្វើឱ្យមានការយល់ខុស ឬផលវិបាកជាអវិជ្ជមាន។ មើលរបៀបរបបនៃការនិយាយរបស់អ្នក តើជាពាក្យសុជីវធម៌ដូចដែលអ្នកចង់និយាយដែរឬទេ។ កុំផ្ញើសារនៅពេលអ្នកមានអារម្មណ៍ខឹង ឬអារម្មណ៍ណាមួយ។
- ប្រយ័ត្នជាទីបំផុត អំពីការចែករំលែកព័ត៌មានផ្ទាល់ខ្លួន។ មានគេដឹងអំពីអ្នកកាន់តែច្រើនកាន់តែងាយស្រួលវាយប្រហារអ្នកនៅលើអ៊ីនធឺណិត និងក្រៅអ៊ីនធឺណិត។ ឧទាហរណ៍ សូមកុំដាក់ថ្ងៃកំណើតរបស់អ្នកនៅក្នុងប្រវត្តិរូបរបស់អ្នក ដើម្បីជៀសវាងការលួចអត្តសញ្ញាណ។
- ជៀសវាងការចែករំលែកអ្វីមួយអាសអាភាស និងផ្សាយចេញរូបថតអាសអាភាស។ នៅពេលអ្នកបានប្រកាសផ្សាយអ្វីមួយ អ្នកបាត់បង់ការគ្រប់គ្រងថាអ្នកណាអាចមើលចែករំលែក ឬកែច្នៃរូបថត។ មិត្តភាព និងទំនាក់ទំនងស្និទ្ធស្នាលមិនមែនតែងតែមានជានិច្ចទេ។ អតីតមិត្តភ័ក្តិអាចប្រកាសផ្សាយរូបភាព ឬវីដេអូផ្ទាល់ខ្លួនដែលអ្នកបានអនុញ្ញាតឱ្យពួកគេថតនៅពេលអ្នកទុកចិត្តពួកគេ។
- រក្សាទុកពាក្យសម្ងាត់របស់អ្នកសម្ងាត់បំផុត។ សូមជ្រើសរើសពាក្យសម្ងាត់ដែលខ្លាំងដែលមានប្រវែងតិចបំផុត ៨ តួអក្សរ និងគួរដាក់ឱ្យមានអក្សរលាយជាមួយលេខ និងសញ្ញា។ សូមកុំចែករំលែកពាក្យសម្ងាត់ជាមួយអ្នកផ្សេង ទោះបីពួកគេជាមិត្តភ័ក្តិជិតស្និទ្ធរបស់អ្នកក៏ដោយ។ សូមប្តូរពាក្យសម្ងាត់របស់អ្នក ប្រសិនបើអ្នកគិតថាអ្នកណាម្នាក់ផ្សេងអាចមានវា។
- កុំបិទភ្នែករបស់អ្នក។ គាំទ្រអ្នកណាម្នាក់ដែលជាគោលដៅ, ស្តាប់ និងផ្តល់ជំនួយ។ ត្រូវដឹងថាមនុស្សដែលឃើញអ្នកថា "ផ្សេង" តែងតែជាគោលដៅ។ សូមកុំចូលរួមនៅក្នុងនិយាយចំអន់លេងឥតប្រយោជន៍។ សូមធ្វើជាគំរូដ៏ល្អ។ ប្រសិនបើអ្នកជាមនុស្សម្នាក់ត្រូវបានគេសម្លុតគំរាម ត្រូវដឹងថានេះមិនមែនជាកំហុសរបស់អ្នកទេ។

*ប្រសិនបើមនុស្សគ្រប់រូប – ជាជនរងគ្រោះដូចជាចិន្តា អ្នកអង្កេតដូចជាចរណៃ និងមាលី និងអ្នកប្រព្រឹត្តិបទល្មើសឌីសាហាវដែលអាចក្លាយជាជនរងគ្រោះផងដែរនោះ – គួរតែរួមគ្នាប្រយុទ្ធប្រឆាំងនឹងពាក្យ ឬបែបបទនិយាយដែលអវិជ្ជមាន, សម្ដីដ៏គួរឱ្យស្អប់ និងការសម្លុតគំរាមតាមអ៊ីនធឺណិត, ការវាយប្រហារតាមអ៊ីនធឺណិតគួរតែត្រូវទប់ស្កាត់ ឬបញ្ឈប់។*

# ៥.៣. គុណតម្លៃនៃពេលវេលារបស់អ្នក

ការនិយមចូលចិត្តមួយនៃបណ្ដាញសង្គម គឺថាអ្នកប្រើតែងតែពិនិត្យមើលជានិច្ច ប្រសិនបើមានព័ត៌មានថ្មី ឬពួកគេឈប់មើលត្រង់ការជូនដំណឹង ដែលធ្វើឱ្យទូរសព្ទរបស់ពួកគេឮសំឡេងប៊ីប។ នេះធ្វើឱ្យពួកគេបាត់បង់នូវការប្រមូលអារម្មណ៍នៅពេលពួកគេធ្វើអ្វីមួយ។ នៅពេលពួកគេកំពុងធ្វើការ, កំពុងរៀន ឬបើកបរ វាសំខាន់ណាស់ក្នុងការផ្ដោតអារម្មណ៍របស់អ្នកទាំងអស់ទៅក្នុងសកម្មភាព។ វាជាការលំបាកក្នុងការផ្ដោតអារម្មណ៍នៅពេលអ្នកត្រូវបានរំខានរៀងរាល់ប៉ុន្មាននាទីម្ដងដោយអ្នកណាម្នាក់ដែលគ្មានការងារធ្វើទាក់ទងនឹងការងារ ឬការសិក្សារបស់អ្នក។

*ខ្ជះខ្ជាយ ពេលវេលា*

ការប្រើប្រាស់បណ្ដាញសង្គមអាចរំខានដល់សកម្មភាពប្រចាំថ្ងៃរបស់យើងទាំងអស់ កាត់បន្ថយផលិតភាពការងារ និងធ្វើឱ្យយើងឃ្លាតឆ្ងាយពីមនុស្សដែលជិតស្និទ្ធជាមួយយើង។ ជាមួយការផ្លាស់ប្ដូរគ្នានេះយើងទទួលបានព័ត៌មានជាច្រើនដែលមិនចាំបាច់ ប៉ុន្តែវាច្រើនតែជាការកម្សាន្ត។ នៅពេលយើងរំខានជីវិតរបស់យើងជាមួយការទទួលបានមកវិញនូវព័ត៌មានកម្សាន្តបែបនេះ ដែលជាព័ត៌មានដែលសីៗ យើងអាចនឹងបំផ្លាញការងាររបស់យើង, ការសិក្សា និងមិត្តភាព។ ទំនាក់ទំនងជាក់ស្ដែងត្រូវបានជំនួសដោយសារតិចតួចដែលថែទាំទំនាក់ទំនងជាមួយមិត្តភ័ក្តិ ឬអ្នកដែលស្គាល់តិចតួច ប៉ុន្តែយើងកម្រទាក់ទងអ្វីមួយពេញលេញណាស់។

ការប្រើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមញឹកញាប់ក៏អាចប៉ះពាល់ដល់របៀបដែលអ្នកផ្សេងៗមើលយើងយ៉ាងដូចម្ដេចដែរ។ នៅពេលថៅកែមើលឃើញថាបុគ្គលិករបស់គាត់កំពុងទំនាក់ទំនង ឬប្រើបណ្ដាញសង្គមក្នុងម៉ោងការងារ នោះនឹងប៉ះពាល់ដល់ការប្ដេជ្ញាចិត្តរបស់បុគ្គលិកចំពោះការងារ ធ្វើឱ្យបាត់បង់ឱកាសឡើងតំណែង ឬដំឡើងប្រាក់ខែដោយសាររឿងនេះ ឬក៏មិនអាចរក្សាការងារនេះផង។ ផលប៉ះពាល់ជាអវិជ្ជមានស្រដៀងគ្នានេះដែរកើតឡើងនៅពេលគ្រូឃើញសិស្សរបស់គាត់កំពុងប្រើទូរសព្ទក្នុងអំឡុងពេលថ្នាក់រៀន ឬនៅពេលសិស្សកំពុងធ្វើលំហាត់។

*ប្រសិនបើអ្នកចង់បាន ពេលវេលា អ្នកត្រូវតែអាច ធ្វើវាបាន។*

ការធ្វើឱ្យជីវិតមានតុល្យភាពទាមទារការលៃលកពេលវេលា និងចំណាប់អារម្មណ៍ចំពោះមនុស្ស និងអ្វីមួយដែលអ្នកឱ្យតម្លៃ។ ប្រសិនបើការទទួលបានអប់រំ គឺសំខាន់សម្រាប់អ្នក នោះអ្នកត្រូវតែផ្ដោតអារម្មណ៍នៅក្នុងថ្នាក់រៀន និងផ្ដោតលើការសិក្សារៀនសូត្រ។ ការងារក៏ដូច្នេះដែរ គឺទាមទារឱ្យអ្នកផ្ដល់ការចាប់អារម្មណ៍ពេញលេញចំពោះការងារដែលដាក់ឱ្យធ្វើ។ បន្ថែមពីនេះទៀត មិត្តភ័ក្តិរំពឹងថានៅពេលអ្នកនៅជាមួយពួកគេ អ្នកពិតជាកំពុងផ្ដោតអារម្មណ៍ខ្លាំងលើវា និងមិនធ្វើការផ្លាស់ប្ដូរសារឌីជីថលជាមួយអ្នកផ្សេងឡើយ។

ការចំណាយពេលច្រើនពេកនៅលើអ៊ីនធឺណិតអាចប៉ះពាល់ដល់យើងទាំងផ្លូវកាយ និងផ្លូវចិត្តផងដែរ។ ឧទាហរណ៍បញ្ហាដែលបង្កឡើងដោយការចំណាយពេលច្រើនពេកនៅលើអ៊ីនធឺណិត មានទាំងការខ្វះសកម្មភាពផ្លូវកាយ, ធ្វើឱ្យយើងធាត់, ដេកមិនគ្រប់គ្រាន់, រៀនខ្សោយនៅសាលា, ការឃ្លាតឆ្ងាយពីមិត្តភ័ក្តិ និងគ្រួសារ និងមានអារម្មណ៍តានតឹង ឬធុញថប់។

មានពេលវេលា មួយថ្ងៃមួយថ្ងៃធ្វើរឿងជាច្រើនដែលមានប្រយោជន៍ ប៉ុន្តែអ្នកអាចធ្វើវាទាំងអស់ប្រសិនបើអ្នកអាចលៃលកពេលវេលាដែលត្រូវការសម្រាប់វាបានដោយគ្មានការរំខាន។ ការប្រើឧបករណ៍ទំនាក់ទំនងឌីជីថលត្រូវតែប្រើនៅក្រៅម៉ោងដែលអ្នកទុកសម្រាប់សកម្មភាពសំខាន់។ ការកំណត់ពេលវេលាចូលប្រើក្នុងមួយថ្ងៃនឹងជួយអ្នកធ្វើឱ្យប្រសើរពេលវេលាដែលអ្នកត្រូវសិក្សា, ធ្វើការ ឬមានពេលកម្សាន្តជាមួយមិត្តភ័ក្តិដោយផ្ទាល់។ ការកំណត់ និងធ្វើតាមការកំណត់ទាំងនោះក៏នឹងអាចធ្វើឱ្យបទពិសោធន៍ប្រើប្រាស់បណ្តាញសង្គមរបស់អ្នកបានប្រសើរផងដែរ ដោយសារអ្នកនឹងផ្តោតការយកចិត្តទុកដាក់ពេញលេញចំពោះវានៅខណៈពេលនោះ។



កាត់បន្ថយការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិករបស់អ្នក និងចំណាយពេលវេលាជាមួយមិត្តភក្តិរបស់អ្នកជាប្រចាំ។

## មេរៀនសង្ខេប

ទូរសព្ទចល័ត និងកុំព្យូទ័របានពង្រីកឱកាសដ៏ប្រសើរមួយក្នុងការផ្លាស់ប្តូរព័ត៌មាន និងរក្សាទំនាក់ទំនងជាមួយមនុស្សនៅជុំវិញពិភពលោក និងនៅពេលណាក៏បាន។ ទំនាក់ទំនងឌីជីថលផ្តល់នូវឱកាសដ៏ច្រើនដើម្បីធ្វើឱ្យប្រសើរជំនាញ និងទំនាក់ទំនងផ្ទាល់ខ្លួន ប៉ុន្តែអ្នកប្រើត្រូវរៀនគ្រប់គ្រងវាឱ្យបានត្រឹមត្រូវ និងកាត់បន្ថយគ្រោះថ្នាក់នៃការយល់ខុស។ យើងក៏ត្រូវប្រាកដថា យើងជ្រើសរើសឧបករណ៍ដ៏ប្រសើរដើម្បីចែកចាយព័ត៌មាន។ បណ្តាញសង្គមដូចជា Facebook គឺមានការពេញនិយមខ្លាំងបំផុត និងផ្តល់គុណតម្លៃជាច្រើនសម្រាប់ទំនាក់ទំនង ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើមិនបានប្រើវាឱ្យបាន

ត្រឹមត្រូវទេ បណ្ដាញសង្គមអាចផ្សាយច្រើនលើសលប់នៃព័ត៌មានផ្ទាល់ខ្លួនរបស់យើង។

ការផ្ដល់ព័ត៌មានឯកជនច្រើនពេកអំពីខ្លួនយើងអាចនឹងងាយធ្វើឱ្យគេបៀតបៀន ឬសម្លុតគំរាមយើង ឬអាចឱ្យចៅកែយើងដឹងអំពីសកម្មភាពយើងក្នុងដំណាក់កាលពួកគេជ្រើសរើសបុគ្គលិក។ វាសំខាន់ណាស់ត្រូវការពារភាពឯកជន គិតមុនពេលផ្សាយ គោរពសិទ្ធិគ្នា និងមានវិធានការប្រឆាំងនឹងការប្រើពាក្យពេចន៍មិនសមរម្យ ឬអវិជ្ជមាន, សម្ដីដែលគួរឱ្យស្អប់ ឬការសម្លុតគំរាមតាមប្រព័ន្ធអ៊ីនធឺណិត។ យោងតាមឧបករណ៍ដែលបានប្រើ យើងទាំងអស់ត្រូវការទំនាក់ទំនងដោយការគោរព និងទទួលខុសត្រូវ ដោយតែងតែគិតពិចារណាជានិច្ចថាអ្នកនឹងតបតយ៉ាងដូចម្ដេច ប្រសិនបើអ្នកជាអ្នកទទួលវិញ។

ជាចុងបញ្ចប់ សំខាន់ណាស់ត្រូវប្រាកដថាទំនាក់ទំនងឌីជីថលមិនរំខានដល់ការងាររបស់យើង, ការសិក្សារបស់យើង ឬទំនាក់ទំនងផ្ទាល់ខ្លួនជាមួយមិត្តភ័ក្តិ និងគ្រួសារ។ យើងត្រូវលៃលកពេលវេលាឱ្យបានសមរម្យសម្រាប់ទំនាក់ទំនងឌីជីថល ដើម្បីថែទាំសុខភាពរបស់យើង និងទំនាក់ទំនងក្នុងជីវិតពិតប្រាកដរបស់យើងជាមួយមិត្តភ័ក្តិ និងគ្រួសារ។

## លំហាត់

### លំហាត់ ៣

អ្នកនឹងត្រូវធ្វើការជាមួយក្រុមរបស់អ្នកដើម្បីពិភាក្សាស្ថានភាពសម្លុតគំរាមតាមរយៈប្រព័ន្ធអ៊ីនធឺណិតពីរប្រភេទខាងក្រោម។ ការសម្លុតគំរាមតាមប្រព័ន្ធអ៊ីនធឺណិតតែងតែកើតឡើងញឹកញាប់បំផុតនៅលើអ៊ីនធឺណិត (ស្ថានភាព ក) ប៉ុន្តែវាអាចកើតមានជាមួយការហៅតាមទូរសព្ទ និងសារខ្លីជាអត្ថបទផងដែរ (ស្ថានភាព ខ)។ បន្ទាប់ពីពិភាក្សាស្ថានភាពទាំងនេះ សូមប្រកាសចម្លើយក្រុមរបស់អ្នកនៅក្នុងថតក្រុមរបស់អ្នក។

**ស្ថានភាព ក៖** ចងចាំទេ ឧទាហរណ៍អំពីចិន្ដា និងមតិយោបល់ជាអវិជ្ជមានដែលនាងទទួលបានបន្ទាប់ពីនាងប្រកាសរូបថតរបស់នាង និងឌីណាជាមួយពាក្យថា "ស្រឡាញ់គ្នាលុះក្ស័យ"។ ឥឡូវការងាររបស់អ្នក គឺត្រូវជួយចិន្ដាដោះស្រាយជាមួយមតិយោបល់ Facebook ដែលអវិជ្ជមាន និងបង្ហាញមធ្យោបាយដល់នាងដើម្បីបង្កើនកម្រិតភាពឯកជនរបស់នាងនៅលើប្រព័ន្ធផ្សព្វផ្សាយ។ ចិន្ដាទ្រហោយំ និងនិយាយថា "ខ្ញុំឆ្កួតមែនទែន។ មនុស្សគ្រប់រូបអាចមើលឃើញប្រកាសរបស់ខ្ញុំថា "ស្រឡាញ់គ្នាលុះក្ស័យ" ហើយខ្ញុំមិនដែលចង់ដាក់វាក្នុង Facebook ទេ។"

*i.* នៅក្នុងក្រុមរបស់អ្នក សូមធ្វើការស្នើដល់ចិន្ដាអំពីការប្រកាសនៅពេលក្រោយៗ។ តើអ្នកគួរប្រាប់នាងថាយ៉ាងដូចម្ដេចក្នុងនាមជាមិត្តភ័ក្តិដែលអាចធ្វើឱ្យនាងមានអារម្មណ៍ប្រសើរវិញ? ជាពិសេសសកម្មភាពអ្វីដែលចិន្ដាត្រូវធ្វើជាមួយប្រកាសនេះ?

*ii.* តើចិន្ដាអាចប្ដូរការកំណត់នៅក្នុង Facebook របស់នាងបានយ៉ាងដូចម្ដេច? តើការកំណត់អ្វីដែលអ្នកផ្ដល់យោបល់ឱ្យចិន្ដាផ្លាស់ប្ដូរ? (សូមមើលមគ្គុទ្ទេសក៍ជំនួយត្រង់ចំណុច ........ ការកំណត់ភាពឯកជន)

**ស្ថានភាព ខ៖** វិទ្ធិមានអាយុ ១៦ ឆ្នាំ និងមិនរឹងមាំ ព្រោះគាត់បានកើតមកមានម្រាមជើងខូចទ្រង់ទ្រាយ និងជើងគាត់ខ្លី។ គាត់ត្រូវបានគេចំអន់ និងហៅគាត់ថា "អាខ្វិន" តាំងពីគាត់នៅតូចម្លេះ។

ម្សិលមិញ និងថ្ងៃនេះគាត់បានទទួលសារជាអត្ថបទជាច្រើននិយាយអ្វីៗខ្លះដូចជា "អេ អាខ្ញិន។ ចង់ទៅលេងបាល់ទាត់អត់? អញភ្ញាល់ថាវាពិតជាសប្បាយ! និង "គ្មានស្រីៗណាចង់ធ្វើជាមិត្តស្រីឯងទេ។" ។ គាត់មិនប្រាប់អ្នកណាម្នាក់អំពីសារទាំងនេះទេ ប៉ុន្តែគាត់មានអារម្មណ៍បាក់ទឹកចិត្ត និងខឹង ហើយមិនដឹងថាត្រូវធ្វើយ៉ាងដូចម្ដេច។.

*i.* តើអ្វីជាភស្តុតាងដែលថានេះជាឧទាហរណ៍នៃការជេរប្រមាថតាមប្រព័ន្ធអ៊ីនធឺណិត?

*ii.* យកករណី រិទ្ធិជាឧទាហរណ៍ ចូរពិភាក្សាពីគុណវិបត្តិនៃទំនាក់ទំនងឌីជីថល និងសរសេរវាឱ្យបានបីចំណុច។

*iii.* ប្រសិនបើ រិទ្ធិ មករកអ្នកសម្រាប់ផ្ដល់យោបល់ជួយដោះស្រាយសារជាអត្ថបទបែបនេះ តើអ្នកគួរប្រាប់គាត់ថាយ៉ាងដូចម្ដេច?

## លំហាត់ ៤

សម្រាប់លំហាត់នេះ អ្នកនឹងមើលលើការកំណត់ភាពឯកជន ហើយនឹងត្រូវធ្វើការសម្រេចចិត្តអំពីពួកគេ។ យ៉ាងហោចណាស់សមាជិកក្នុងក្រុមម្នាក់ត្រូវតែមានគណនី Facebook ប្រសិនបើអ្នកមិនមានទេ សូមប្រាប់លោកគ្រូ/អ្នកគ្រូឱ្យរៀបចំក្រុមសាឡើងវិញដើម្បីឱ្យក្រុមនីមួយៗមានសមាជិកយ៉ាងហោចណាស់ម្នាក់មានគណនី Facebook ។ នៅពេលបញ្ចប់ សូមសរសេរសេចក្ដីសន្និដ្ឋានដោយសង្ខេបអំពីសកម្មភាពរបស់អ្នក (២ ទៅ ៤ ប្រយោគ) និងប្រកាសផ្សាយប្រយោគនោះដាក់ក្នុងចតក្រុមរបស់អ្នក ដោយដាក់ឈ្មោះថា ................។

ក – សម្រាប់សិស្សដែលមានអ៊ីនធឺណិតចូលទៅ Facebook។ មនុស្សម្នាក់នៅក្នុងក្រុមនឹងត្រូវចូលទៅគណនី Facebook របស់គេ ដោយប្រើពាក្យសម្ងាត់យ៉ាងសុវត្ថិភាព។ (សមាជិកផ្សេងៗនៅក្នុងក្រុមគួរតែងាកមុខចេញនៅពេលគេវាយពាក្យសម្ងាត់)។ ម្ចាស់គណនីនឹងត្រូវអនុវត្តតាមជំហានខាងក្រោម និងឆ្លើយសំណួរ។ សមាជិកផ្សេងនៅក្នុងក្រុមគួរតែអានជំហាននីមួយៗឱ្យឮយឺតៗ ដើម្បីឱ្យសមាជិកដែលអង្គុយនៅកុំព្យូទ័រដឹងថាអ្វីត្រូវធ្វើបន្ទាប់។ សមាជិកផ្សេងទៀតនៅក្នុងក្រុមធ្វើជាអ្នកអង្កេត និងអាចផ្ដល់ជាយោបល់ផ្សេងៗ។ សូមចុចលើរូបសញ្ញាកូនសោនៅជ្រុងខាងលើផ្នែកខាងស្ដាំនៃអេក្រង់ និងបន្ទាប់មកចុចលើ "ពិនិត្យភាពឯកជន"។

១. អានប្រកាសរបស់អ្នក។ សូមមើលការពន្យល់របស់ Facebook ។ សម្រេចចិត្ត ប្រសិនបើអ្នកចង់រក្សាការកំណត់បច្ចុប្បន្នរបស់អ្នក។ ប្រសិនបើអ្នកចង់ផ្លាស់ប្ដូរការកំណត់នេះ សូមធ្វើវាឥឡូវ។ បន្ទាប់ចុចលើ "ជំហានបន្ទាប់"។

២. អាន កម្មវិធីរបស់អ្នក។ មើលកម្មវិធីណាដែលអ្នកបានចូលជាមួយ Facebook។ កែសម្រួលប្រសិនបើអ្នកចង់ធ្វើការផ្លាស់ប្ដូរ។ លុបកម្មវិធីដែលអ្នកលែងចង់ប្រើ។ បន្ទាប់មកចុចលើ "ជំហានបន្ទាប់"។

៣. អាន ប្រវត្តិរូបរបស់អ្នក។ ពិនិត្យមើលឡើងវិញអ្នកណាដែលអាចមើលឃើញព័ត៌មានទំនាក់ទំនងអ៊ីមែលរបស់អ្នក, ថ្ងៃកំណើតរបស់អ្នក, ទីកន្លែងកំណើតរបស់អ្នក និងអ្វីដែលអ្នក

ចាប់អារម្មណ៍។ ប្រសិនបើអ្នកចង់កែសម្រួលប្រភេទទាំងនោះណាមួយ សូមចុចលើសញ្ញាព្រួញ និងធ្វើវាឥឡូវ។ បន្ទាប់មកសូមចុចលើ "ទំព័រអំពី"។

៤. សូមមើលនៅទិដ្ឋភាពសង្ខេប។ សម្រេចចិត្ត ប្រសិនបើអ្នកចង់ធ្វើការផ្លាស់ប្ដូរអ្វីមួយ ប្រសិនបើដូច្នោះមែន សូមធ្វើការផ្លាស់ប្ដូរវាឥឡូវ។

៥. ផ្លាស់ទីទៅប្រភេទផ្សេងបន្ទាប់។ (រំលងបញ្ជីមិត្តភ័ក្ដិ និងរូបថតរបស់អ្នកសម្រាប់ឥឡូវ បន្ទាប់មកពិនិត្យមើលវាពេលក្រោយក្នុងភាពឯកជន។)។ រមូរទៅកាន់ កីឡា, តន្ត្រី, ភាពយន្ត, កម្មវិធីទូរទស្សន៍ និងសៀវភៅ និងសម្រេចចិត្ត ប្រសិនបើអ្នកចង់ធ្វើការផ្លាស់ប្ដូរអ្វីមួយ។ ធ្វើការផ្លាស់ប្ដូរឥឡូវ។ ត្រឡប់ទៅសកម្មភាពនេះពេលក្រោយ ប្រសិនបើអ្នកសម្រេចចិត្តធ្វើការផ្លាស់ប្ដូរច្រើន ជាពិសេសដើម្បីពិនិត្យថាអ្នកមិនកំពុងចែករំលែកព័ត៌មានឯកជនច្រើនពេកទេ។

៦. ចាកចេញពីគណនី Facebook របស់អ្នក។

## សំណួរត្រិះរិះ

១. ពិពណ៌នាយ៉ាងហោចណាស់បីចំណុចពីភាពផ្សេងគ្នារវាងទំនាក់ទំនងដោយជួបមុខគ្នាផ្ទាល់ និងទំនាក់ទំនងឌីជីថល។

២. ហេតុអ្វីអ្នកគួរការពារភាពឯកជនរបស់អ្នកនៅក្នុងបណ្ដាញសង្គម? តើអ្វីជាពិសេសដែលអ្នកអាចធ្វើបានដើម្បីការពារភាពឯកជនរបស់អ្នកនៅលើអ៊ីនធឺណិត?

៣. ហេតុអ្វីអ្នកមិនគួរប្រកាសផ្សាយរូបថតផ្ទាល់ខ្លួនស៊ីជម្រៅ?

៤. តើអ្នកអាចទប់ស្កាត់ពាក្យពេចន៍ និងរបៀបរបបនិយាយជាអវិជ្ជមាន, សម្ដីដែលគួរឱ្យស្អប់ និងការជេរប្រមាថតាមប្រព័ន្ធអ៊ីនធឺណិតបានយ៉ាងដូចម្ដេច? សូមផ្ដល់ឧទាហរណ៍អំពីរបៀបដែលអ្នកអាចឆ្លើយតបនៅលើអ៊ីនធឺណិត និងក្រៅអ៊ីនធឺណិតចំពោះការជេរប្រមាថតាមអ៊ីនធឺណិត។

៥. ហេតុអ្វីសំខាន់សម្រាប់មនុស្សត្រូវមានអាកប្បកិរិយាដោយការគោរព និងដោយការទទួលខុសត្រូវនៅពេលពួកគេប្រើឧបករណ៍ទំនាក់ទំនងឌីជីថល?

៦. តើអ្វីជាគ្រោះថ្នាក់ទាំងបួននៃការចំណាយពេលច្រើនពេកនៅលើអ៊ីនធឺណិត?

ជំពូកទី ៤ | ការរចនា

# មេរៀនទី ៨

# ការងារនៅក្នុងផ្នែកប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម

## នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពី៖

១. កំណត់អ្វីទៅជាប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម និងស្វែងយល់អំពីបុគ្គលិកលក្ខណៈ និងគោលបំណងជាក់លាក់របស់វា

២. ស្វែងយល់អំពីការងារនៅក្នុងផ្នែកប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម និងបរិស្ថានការងាររបស់វា

៣. កំណត់ និងយល់អំពីការអប់រំ បំណិនទំនាក់ទំនង បំណិនបច្ចេកទេស និងលក្ខណសម្បត្តិផ្សេងៗដែលត្រូវមានដើម្បីអាចធ្វើការបានក្នុងផ្នែកប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននេះ

៤. ពន្យល់អំពីកំណត់ហេតុបណ្ដាញ កំណត់ហេតុបណ្ដាញតូចបំផុត សេវាកម្មកំណត់ហេតុបណ្ដាញ វិឌីភីឌា វេទិកាលើអ៊ីនធឺណិត និងវេបសាយសម្រាប់ចែករំលែករូបថត ឬវីដេអូ និងមធ្យោបាយដែលអាចបង្កើនឱកាសដល់បុគ្គលដើម្បីអាចចូលរួមយ៉ាងសកម្មនៅលើបណ្ដាញ

៥. ស្គាល់ និងពន្យល់ជំហានក្នុងការរៀបចំផែនការ បង្កើត និងផ្សព្វផ្សាយកំណត់ហេតុបណ្ដាញផ្ទាល់ខ្លួនប្រកបដោយប្រសិទ្ធភាព។

# ផ្នែក ក - ការងារក្នុងផ្នែកប្រព័ន្ធផ្សព្វផ្សាយសង្គម

## ១. ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមជាផ្នែកវិជ្ជាជីវៈ

លឹមមកពី ABLE រៀបចំឱ្យចរណៃ ម៉ាលី និងចិន្តា ជួបជាមួយមិត្តភ័ក្តិរបស់គាត់គឺ នីកា ដែលជាអ្នកវិភាគទិន្នន័យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម។

“សូមស្វាគមន៍! ខ្ញុំរីករាយណាស់ដែលដឹងថាអ្នកទាំងអស់គ្នាចាប់អារម្មណ៍នឹងការងារប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម" នីកាបាននិយាយ។

នីកាបាននាំសិស្សទៅកាន់តុរបស់គាត់ និងពន្យល់ប្រាប់ថា "ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមជាក់ស្តែងមិនមែនជាការងារទេ។ អ្នកមិនអាចទៅសិក្សាវានៅសាកលវិទ្យាល័យទេ តែខ្ញុំជឿជាក់ថា វានឹងមានសារប្រយោជន៍នៅថ្ងៃអនាគត។ ប៉ុន្តែកុំបារម្ភ ភាពរីកចម្រើនយ៉ាងឆាប់រហ័សនៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមបានបង្កើតការងាររាប់ពាន់នៅលើពិភពលោករួចហើយ។"

ពួកគេឃើញទូរសព្ទចល័តជាច្រើននៅលើអេក្រង់ម៉ូនីទ័ររបស់អ្នក។ គាត់និយាយថា "មើលនែ! ខ្ញុំកំពុងសាកល្បងកម្មវិធីទូរសព្ទចុងក្រោយរបស់យើង" ហើយគាត់យកទូរសព្ទឱ្យពួកគេម្នាក់មួយ។ ចិន្តា ម៉ាលី និងចរណៃចាប់ផ្តើមសាកល្បងទូរសព្ទទំនើបនោះ។ នីកាបានពន្យល់ប្រាប់ថា "កម្មវិធីថ្មីនេះអាចឱ្យអ្នកប្រើទំនាក់ទំនងគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ឬទំនាក់ទំនងជាក្រុមបាន ដោយអាចចែករំលែកអត្ថបទ រូបភាព សារជាសំឡេង និងវីដេអូក្នុងពេលដ៏ខ្លី។ សូមធ្វើការទស្សន៍ទាយសាកមើល ថាការងារអ្វីនៅពីក្រោយលទ្ធផលនេះ?"

“ការសរសេរកូដ?” ចិន្តាបានឆ្លើយ។

ចរណៃបន្ថែមថា "ប្រហែលជាមានអ្នករចនារូបរាង និងរបៀបចុចយ៉ាងស្រួលនេះហើយ។"

“បាទ! អ្នកទាំងពីរពិតជាឆ្លើយបានត្រឹមត្រូវណាស់។ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម មានមនុស្សដែលមានជំនាញក្នុងការសរសេរកូដកម្មវិធី ឬរចនាវេបសាយ ហើយពួកគេតែងតែធ្វើការជាក្រុម។ ឧទាហរណ៍៖ ខ្ញុំក៏ធ្វើការក្នុងផ្នែកក្រុមផ្នែក អភិវឌ្ឍកម្មវិធីថ្មីនេះដែរ ទោះបីខ្ញុំជាអ្នកវិភាគទិន្នន័យក៏ដោយ។ កម្មវិធីទូរសព្ទត្រូវធ្វើឡើង ដើម្បីបំពេញសេចក្តីត្រូវការរបស់អ្នកប្រើរាប់លាននាក់ ហើយយើងបានរក្សាបច្ចុប្បន្នភាពរបស់វា និងដាក់ឱ្យមនុស្សប្រើសាកល្បង។"



ម៉ាលីបានលាន់មាត់ថា៖ "ពិតជាអស្ចារ្យណាស់! មនុស្សអាចបង្កើតភាពច្នៃប្រឌិតនេះបាន និងនៅតែរក្សាគំនិត និងរចនាប័ទ្មចុងក្រោយដែលពួកគាត់ពេញចិត្ត!"

បន្ទាប់មកនីកាបានបើកកម្មវិធីបណ្ដាញសង្គមឈ្មោះថា Facebook YouTube និង Twitter នៅលើកុំព្យូទ័ររបស់គាត់ ខណៈនោះនារីៗបានដាក់ទូរសព្ទមួយឡែក។

"ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមបង្កើតនូវឱកាសជំនួញថ្មី ហើយវាកំពុងផ្លាស់ប្ដូរមធ្យោបាយដែលមនុស្សប្រាស្រ័យទាក់ទងគ្នា និងធ្វើអន្តរកម្មនៅលើបណ្ដាញអ៊ីនធឺណិត។ សូមមើលនេះ។"

នីកាបានចាប់ផ្ដើមបើកមើលវីដេអូតាម YouTube ដែលត្រូវបានបើកមើលដោយមនុស្សជាងមួយលានដង។ ចិន្តាញញឹម និងនិយាយថា៖ "ខ្ញុំស្គាល់ពួកគេទាំងនេះ។ ពួកគេពិតជាកំប្លែងមែន។ រាល់ថ្ងៃសុក្រ ពួកគេតែងតែផ្សាយវីដេអូខ្លីថ្មីមួយ ហើយមិត្តរបស់ខ្ញុំទាំងអស់ចូលចិត្តការសម្ដែងរបស់ពួកគេ។"




ចរណៃងឿងឆ្ងល់ថា ហេតុអ្វីនីកាអាចមើលវីដេអូខ្លីនេះ ហើយក៏បានសួរថា៖ "នីកា តើឯងបានន័យថាពួកគេទាំងនេះបង្កើតការងារជាមួយវីដេអូតាម YouTube របស់ពួកគេមែនទេ?"

"មែនហើយ ពួកគេបានរកលុយតាមវីដេអូរបស់ពួកគេមែន! នីកាឆ្លើយ។

"ប៉ុន្តែ អ្នកណាជាអ្នកបង់ប្រាក់ឱ្យពួកគេ?" ម៉ាលីសួរ។

"ពួកគេរកលុយបានតាមរយៈការផ្សាយពាណិជ្ជកម្ម ដូចជាសេវាកម្មអ៊ីនធឺណិតជាច្រើន។ រៀងរាល់ពេលមានមនុស្សមើលវីដេអូរបស់ពួកគេ នោះពួកគេអាចរកប្រាក់បានតិចតួចពីអ្នកផ្សាយពាណិជ្ជកម្មតាមរយៈការចុចមើលពាណិជ្ជកម្មដែលពួកគេឃើញនៅលើវីដេអូនោះ។ ពីព្រោះវេបសាយអាចមើលបានដោយមនុស្សរាប់លាននាក់ជារៀងរាល់ថ្ងៃ អ្នកប្រើទាំងនេះអាចប្រែក្លាយចំណូលចិត្តរបស់ពួកគេទៅជាពាណិជ្ជកម្មបានដោយបង្កើតខ្លួនឯងការងារតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម។"

"ពិតជាមិនគួរឱ្យជឿថាវាអាចធ្វើបានដូចនេះសោះ!" ចិន្តាលាន់មាត់។

នីកាបានបន្ថែមទៀតថា៖ "មែនហើយ ប៉ុន្តែវាមិនមែនកើតឡើងញឹកញាប់ពេកទេ។ ការងារទាំងអស់នេះផ្ដោតលើការទាក់ទាញចំណាប់អារម្មណ៍របស់អ្នកប្រើ។ នៅក្នុងផ្នែករបស់យើង យើងរកមើលមនុស្សដែលបង្ហាញមធ្យោបាយនៃការគិតមិនធម្មតា ដើម្បីឱ្យគំនិតរបស់ពួកគេលេចធ្លោដល់អ្នកប្រើរាប់លាននាក់។ ហើយម្នាក់ក្នុងចំណោមពួកគេអាចជាអ្នក!" នីកានិយាយដោយស្នាមញញឹម។

ចរណៃ និងមិត្តភ័ក្តិរបស់នាងសប្បាយចិត្តណាស់។ "អរគុណខ្លាំងណាស់ នីកា" ម៉ាលីនិយាយ។ "អ្នកពិតជាបានធ្វើឱ្យយើងយល់ច្បាស់តាមរយៈការបង្ហាញត្រួសៗអំពីការងារដែលមាននៅក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គមបច្ចុប្បន្ន។ ឥឡូវ យើងត្រូវគិតមើលជំនាញផ្ទាល់ខ្លួនរបស់យើង និងចំណាប់អារម្មណ៍ថាតើយើងអាចសម្រេចចិត្តជ្រើសរើសសិក្សាជំនាញអ្វី និងការងារអ្វីដែលយើងចង់ធ្វើ។"

# ១.១. ទំនាក់ទំនង និងប្រព័ន្ធផ្សព្វផ្សាយសង្គម

បច្ចុប្បន្នទំនាក់ទំនងកាន់តែច្រើនឡើងដែលត្រូវបានធ្វើឡើងតាមរយៈឧបករណ៍អេឡិចត្រូនិក បានប្រែក្លាយមធ្យោបាយដែលមនុស្សរាក់ទាក់គ្នា និងប្រាស្រ័យទាក់ទងគ្នា ក៏ដូចជាការប្រែក្លាយមធ្យោបាយដែលក្រុមហ៊ុនជំនួញផ្សព្វផ្សាយផលិតផល និងសេវាកម្មរបស់ពួកគេ។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម គឺជាការប្រមូលផ្ដុំមធ្យោបាយទំនាក់ទំនងនៅលើអ៊ីនធឺណិតដែលអាចឱ្យអ្នកប្រើប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកបាន។ ជាមួយនឹងមធ្យោបាយនៃប្រព័ន្ធផ្សព្វផ្សាយដូចជា Facebook Twitter LinkedIn និង YouTube ការប្រាស្រ័យទាក់ទងមានការវិវឌ្ឍប្រែប្រួលយ៉ាងឆាប់រហ័ស ជាពិសេសក្នុងចំណោមយុវជន។ វេបសាយប្រព័ន្ធផ្សព្វផ្សាយបានច្នៃប្រឌិតបែបថ្មីដែលមនុស្សអាចបង្កើតក្រុម ឬសហគមន៍ - ក្រុមមនុស្សដែលមានចំណាប់អារម្មណ៍ប្រហាក់ប្រហែលគ្នាលើរឿងអ្វីមួយ ហើយពួកគេទាំងនេះមិនដែលបានជួបមុខគ្នាផ្ទាល់ផង។

សម្រាប់អ្នកប្រើ បណ្ដាញសង្គមអាចមានទាំងគុណប្រយោជន៍ ទាំងបញ្ហាប្រឈម។ នៅពេលមនុស្សចូលប្រើ វាមានភាពងាយស្រួល និងលឿនក្នុងការផ្លាស់ប្ដូរគំនិតរវាងគ្នានឹងគ្នា រក្សាទំនាក់ទំនងជិតស្និទ្ធជាមួយគ្នា និងចូលរួមការសន្ទនានិមិត្ត។ អ្នកប្រើនីមួយៗអាចបង្កើត និងចែករំលែកសារ ទស្សនៈ និងចំណេះដឹងជាមួយអ្នកប្រើទ្រង់ទ្រាយធំ ទទួលមតិយោបល់ពីពួកគេ និងមានអារម្មណ៍បានភ្ជាប់ជាមួយសង្គម។



*ទីតាំងជារូបវន្ត ឬនិមិត្តទាំងឡាយណាដែលទាក់ទាញការចាប់អារម្មណ៍មនុស្សជាច្រើន ត្រូវបានគិតថាល្អសម្រាប់ជំនួញរបស់ក្រុមហ៊ុនដែលប្រាថ្នារកប្រាក់ចំណេញ និងរួមទាំងបណ្ដាញសង្គម។*

ក្រុមហ៊ុនអាចប្រើមធ្យោបាយលឿនក្នុងការផ្សព្វផ្សាយខ្លឹមសារព័ត៌មាននៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមដើម្បីផ្សព្វផ្សាយពាណិជ្ជកម្មផលិតផល និងសេវាកម្មរបស់ពួកគេបាន។ ក្នុងករណីខ្លះ បណ្ដាញសង្គមបានក្លាយជាមូលដ្ឋានជំនួញយ៉ាងពិតប្រាកដ ដូចជាក្រុមហ៊ុនដែលបង្កើតវីដេអូដ៏មានប្រជាប្រិយ និងអាចរកប្រាក់ចំណូលបានច្រើនក្នុងការផ្សព្វផ្សាយពាណិជ្ជកម្ម។ អ្នកប្រើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមខិតខំបង្កើតព័ត៌មានជាច្រើនអំពីខ្លួនឯង និងចំណាប់អារម្មណ៍ផ្ទាល់ខ្លួន ហើយព័ត៌មានទាំងនេះត្រូវបានប្រមូល និងរក្សាទុកនៅម៉ាស៊ីនមេនៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមនោះ។ ការវិភាគ និងលក់ព័ត៌មាន ក៏ជាទម្រង់ថ្មីមួយនៃជំនួញតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមផងដែរ។

ឱកាសទាំងអស់នេះបានបង្កើតផ្នែកជំនួញថ្មីរួមមួយនៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម និងជាមួយគ្នានេះដែរ ក៏មានចំនួនការងារជាច្រើនដែលបានបង្កើតឡើងជាផ្នែកនៃជំនួញទាំងនេះ។ ជំពូកនេះនឹងវិភាគការងារទាំងនេះ ក៏ដូចជាបំណិន និងចំណេះដឹងដែលត្រូវមានសម្រាប់អាចប្រើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមសម្រាប់គោលបំណងជំនួញបានដោយជោគជ័យផងដែរ។

# ២. ការងារប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម

ភាពរីកចម្រើនយ៉ាងលឿននៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមបានបង្កើតការងារជាច្រើនដល់អ្នកសរសេរកម្មវិធីដែលមានបទពិសោធន៍ (មេរៀនទី ៤) និងអ្នករចនាវេបសាយ (មេរៀនទី ៦ ផ្នែក ក)។ ពួកគេបង្កើត និងថែទាំប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមដែលអាចប្រើបានសម្រាប់កុំព្យូទ័រ និងទូរសព្ទដៃដោយភ្ជាប់ និងមានសកម្មភាពទៅវិញទៅមកជាមួយប្រព័ន្ធផ្សព្វផ្សាយទាំងនេះ។ ភាពជោគជ័យយ៉ាងសម្បើមនៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមក៏បានបង្កើតការងារជំនួញជាច្រើនដែលពាក់ព័ន្ធ។ ក្រៅពីអ្នកសរសេរកូដកម្មវិធី និងអ្នករចនាវេបសាយបានរៀបរាប់ខាងលើ តួនាទីទាំងនេះ គឺជាវិស័យការងារថ្មីនៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម៖ អ្នកគ្រប់គ្រងកំណត់ហេតុបណ្ដាញ អ្នកវិភាគទិន្នន័យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម អ្នកតំណាងទីផ្សារប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម និងអ្នកគ្រប់គ្រងទីផ្សារប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម។

- អ្នកគ្រប់គ្រងកំណត់ហេតុបណ្ដាញ
- អ្នកវិភាគទិន្នន័យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម
- អ្នកតំណាងទីផ្សារប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម
- អ្នកគ្រប់គ្រងទីផ្សារប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម

បន្ថែមពីនេះ ក្រុមហ៊ុនជាច្រើនណែនាំអ្នកតំណាងលក់ និងបុគ្គលិកបម្រើសេវាកម្មអតិថិជនឱ្យប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមសម្រាប់ការងាររបស់ពួកគេជាមធ្យោបាយក្នុងការទាក់ទងអតិថិជន។

# ២.១. តម្រូវការការងារ ការអប់រំ, បំណិន និងបទពិសោធន៍

ដោយសារជំនួញតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមនៅមានកម្រិតក្មេងខ្ចីនៅឡើយ មិនទាន់មានការអប់រំផ្លូវការណាមួយដែលបណ្ដុះបណ្ដាលមនុស្សឱ្យមានឯកទេសផ្នែកនេះនៅឡើយ។ សាកលវិទ្យាល័យតិចតួចបានចាប់ផ្ដើមផ្ដល់វគ្គសិក្សាផ្នែកប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម ប៉ុន្តែនៅពេលបច្ចុប្បន្ន ការអប់រំ និងបំណិនបានធ្វើឡើងអាស្រ័យតាមប្រភេទការងារដែលមាន ភាពចាំបាច់របស់ខ្លួន ផ្នែកជំនួញជាក់លាក់ និងទំហំរបស់ក្រុមហ៊ុន។ នៅក្នុងការងារទាំងនេះ បំណិនទីផ្សារ និងការយល់ដឹងអំពីអ្វីដែលអតិថិជន និងអ្នកប្រើត្រូវការ និងចង់បានមានភាពសំខាន់ណាស់ ដែលការងារ គឺពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងទៅវិញទៅមកជាមួយមនុស្ស។ ជាញឹកញាប់ការធ្វើការអាជីពនៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមបានបង្កើតបំណិនរបស់ពួកគេតាមរយៈបទពិសោធន៍ផ្ទាល់ខ្លួនអភិវឌ្ឍពួកគេដោយខ្លួនឯងលើជំនាញទីផ្សារ ឬការលក់ ការរចនារូបភាព ឬផលិតវីដេអូ។

## អ្នកគ្រប់គ្រងកំណត់ហេតុបណ្ដាញ

អ្នកដែលមានមុខតំណែងការងារនេះនឹងគ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពផ្នែកនៃវេបសាយដែលហៅថា កំណត់ហេតុបណ្ដាញ។ កំណត់ហេតុបណ្ដាញ គឺជាវេបសាយផ្ទាល់ខ្លួនមួយ ឬផ្នែកនៃវេបសាយដែលមានបែបផែននៃការសន្ទនាអនុញ្ញាតឱ្យអ្នកអានដឹងអំពីទស្សនៈផ្ទាល់ខ្លួនប្រធានបទណាមួយ ឬជំនួញណាមួយ។ អ្នកអានតែងតែអាចផ្ដល់មតិយោបល់លើប្រធានបទដែលបានផ្សាយ ហើយអ្នកគ្រប់គ្រងកំណត់ហេតុបណ្ដាញអាចឆ្លើយតបចំពោះមតិយោបល់ទាំងនោះនៅក្នុងទម្រង់អន្តរសកម្មទៅវិញទៅមករវាងគ្នា។ អ្នកគ្រប់គ្រងកំណត់ហេតុបណ្ដាញត្រូវបានជួលដោយក្រុមហ៊ុនដើម្បីពង្រីកសកម្មភាពលើបណ្ដាញរបស់ក្រុមហ៊ុននោះ និងបង្កើនចំនួនចូលមើលកាន់តែច្រើន។ ពួកគេនាំអ្នកប្រើប្រព័ន្ធព័ត៌មានតាមរយៈតំណទៅកាន់វេបសាយជំនួញដែលពាក់ព័ន្ធជាមួយព័ត៌មានអំពីផលិតផល និងសេវាកម្មរបស់ពួកគេ។ អ្នកគ្រប់គ្រងកំណត់ហេតុបណ្ដាញ គឺជាអ្នកជំនាញខាងបង្កើត និងភ្ជាប់មាតិកាព័ត៌មានគុណភាពខ្ពស់ដូចជា អត្ថបទ រូបភាព ក្រាហ្វិក ឬវីដេអូសម្រាប់ផ្សព្វផ្សាយតាមបណ្ដាញសង្គមផ្សេងៗ។



អ្នកគ្រប់គ្រងកំណត់ហេតុបណ្ដាញខ្លះចាប់ផ្ដើមដោយការសរសេរកំណត់ហេតុបណ្ដាញផ្ទាល់ខ្លួនហើយពួកគេក្លាយជាអ្នកជំនាញ និងឯកទេសតាមរយៈការងារពួកគេ។ អ្នកគ្រប់គ្រងកំណត់ហេតុបណ្ដាញខ្លះមានភាពល្បីល្បាញដោយសារការបង្កើតកំណត់ហេតុបណ្ដាញដែរបែបកំប្លែង ឬបង្ហាញវីដេអូ YouTube ប្រចាំសប្ដាហ៍។ បន្ទាប់ពីទទួលបានការទាក់ទាញអ្នកទស្សនាច្រើនហើយ អ្នកខ្លះបានប្រែក្លាយចំណូលចិត្តរបស់ពួកគេជាការងារផ្ទាល់ខ្លួន។

អ្នកគ្រប់គ្រងកំណត់ហេតុបណ្ដាញត្រូវតែមានបំណិនសរសេរយ៉ាងស្ទាត់ជំនាញដើម្បីផ្ដល់ព័ត៌មានដ៏សង្ខេបងាយយល់ និងជាទូទៅពួកគេត្រូវមានចំណេះដឹងកម្រិតបរិញ្ញាបត្រ (ប៉ុន្តែមិន

មែនគ្រប់គ្នានោះទេ)។ ក្នុងករណីនេះ ចំណេះដឹងកម្រិតបរិញ្ញាបត្រ គឺសំខាន់មិនមែនដោយសារប្រធានបទដែលសិក្សានោះទេ ប៉ុន្តែដោយសារមានការអប់រំខ្ពស់ធ្វើឱ្យអ្នកគ្រប់គ្រងកំណត់ហេតុបណ្ដាញអាចប្រាស្រ័យទាក់ទងបានប្រសើរ និងទទួលបានចំណេះដឹងជាសាកលបានប្រសើរ ដែលធ្វើឱ្យអ្នកគ្រប់គ្រងកំណត់ហេតុបណ្ដាញមានលទ្ធភាពអាចវាយតម្លៃប្រធានបទដែលគាត់សរសេរអំពីរឿងអ្វីមួយ។ អ្នកដែលមានកម្រិតបរិញ្ញាបត្រផ្នែកសារព័ត៌មាន ទំនាក់ទំនង ទំនាក់ទំនងសាធារណៈ រចនា វិចិត្រសិល្បៈ តន្ត្រី ប្រព័ន្ធផ្សព្វផ្សាយ ឬផ្នែកដែលពាក់ព័ន្ធ គឺសមរម្យសម្រាប់ការងារនេះ។

បំណិនបច្ចេកទេសដែលអ្នកគ្រប់គ្រងកំណត់ហេតុបណ្ដាញគួរមានដូចជា HTML និង CSS ប៉ុន្តែវាមិនប្រាកដថាចាំបាច់ត្រូវតែមានទេ ព្រោះការសរសេរកំណត់ហេតុបណ្ដាញកាន់តែមានភាពងាយស្រួល និងបង្កើត។ វាចាំបាច់ត្រូវមានការយល់ដឹងស៊ីជម្រៅអំពីប្រព័ន្ធព័ត៌មានសង្គម រួមទាំងការស្គាល់ និងចេះប្រើប្រាស់ប្រព័ន្ធព័ត៌មានសង្គម ជាពិសេស Facebook Twitter YouTube និង LinkedIn ដោយការភ្ជាប់កំណត់ហេតុបណ្ដាញទៅប្រព័ន្ធទាំងនេះជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការផ្សព្វផ្សាយព័ត៌មាន។ អ្នកគ្រប់គ្រងកំណត់ហេតុបណ្ដាញគួរតែមានចេះប្រើប្រាស់កម្មវិធីរចនា កម្មវិធីកែសម្រួលវីដេអូ និងរូបថត កម្មវិធីរចនាវេបសាយ និងប្រព័ន្ធគ្រប់គ្រងមាតិកាព័ត៌មាន។

*ចំណុចដែលចាប់អារម្មណ៍ដំបូង៖*

**BBC** *ភ្នាក់ងារព័ត៌មានជាភាសាអង់គ្លេស របាយការណ៍ដែលខុសអក្ខរាវិរុទ្ធ អាចបណ្ដាលឱ្យខាតបង់ការលក់នៅលើអ៊ីនធឺណិតអស់រាប់លានដុល្លារ។*

តាមក្រុមហ៊ុនធំៗ អាចមានអ្នកគ្រប់គ្រងកំណត់ហេតុបណ្ដាញម្នាក់ ឬច្រើននាក់ធ្វើការរួមគ្នាលើគម្រោងណាមួយ និងធ្វើការដោយឯករាជ្យលើគម្រោងផ្សេងៗ។ អ្នកគ្រប់គ្រងកំណត់ហេតុបណ្ដាញជានិច្ចកាលជាផ្នែកនៃក្រុមទីផ្សារ ដោយសារកំណត់ហេតុបណ្ដាញដែលសរសេរបានល្អអាចជួយទីផ្សារដោយរៀបរាប់ពីតម្រូវការ និងសេចក្ដីចង់បានរបស់អ្នកទស្សនាវេបសាយនោះ។

## អ្នកវិភាគទិន្នន័យប្រព័ន្ធផ្សព្វផ្សាយ

ការងារនៅក្នុងតួនាទីនេះ ធ្វើការប្រមូល សិក្សា រៀបចំ និងបកប្រែចំនួន ធ្វើការវាស់ស្ទង់ និងទម្រង់ផ្សេងៗនៃទិន្នន័យពីប្រភពប្រព័ន្ធផ្សព្វផ្សាយផ្សេងៗដើម្បីជួយក្រុមហ៊ុនធ្វើការសម្រេចចិត្តផ្នែកជំនួញ។ គ្រប់អ្នកប្រើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមទាំងអស់បង្កើតទិន្នន័យភ្លាមៗនៅពេលមានការផ្ទុកឡើង ចែករំលែក ឬផ្ដល់មតិយោបល់លើមាតិកាព័ត៌មាន។ អ្នកវិភាគជាធម្មតា គឺជាអ្នកស្រាវជ្រាវដែលដឹងច្បាស់អំពីទំនាក់ទំនងនៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកប្រើរបស់វា ក៏ដូចជាវិធីសាស្ត្រដ៏ប្រសើរដើម្បីធ្វើការវិភាគទិន្នន័យដែលបានបង្កើត។ គាត់ពិគ្រោះយោបល់ជាមួយអ្នកគ្រប់គ្រងអាជីវកម្ម រៀបចំយ៉ាងច្បាស់លាស់កម្រងសំណួរអំពីអាកប្បកិរិយា ឬបុគ្គលិកលក្ខណៈនៃអតិថិជន និងធ្វើការប្រមូល រៀបចំ និងបកប្រែព័ត៌មានស្ថិតិពីអ្នកប្រើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានា។ អ្នកវិភាគប្រមូលព័ត៌មាននេះទាំងអស់ ធ្វើការសន្និដ្ឋានអំពីអ្នកប្រើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម និងរៀបចំរបាយការណ៍ដែលនឹងជួយក្រុមហ៊ុនរបស់ពួកគេឱ្យរីកចម្រើនប្រសើរឡើងជាងនេះ។ ផ្នែកសំខាន់នៃការងាររបស់អ្នកវិភាគទិន្នន័យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម គឺធ្វើការបកប្រែចំនួនជាអត្ថបទដែលមនុស្សអាចយល់បាន។ ការទទួលបានអប់រំនៅសាកលវិទ្យាល័យគឺមានសារៈសំខាន់បំផុតសម្រាប់អ្នកធ្វើការផ្នែកនេះដែលភាគច្រើនយ៉ាងហោចណាស់ក៏មានបរិញ្ញាបត្រផ្នែកគណិតវិទ្យា គ្រប់គ្រងពាណិជ្ជកម្ម វិទ្យាសាស្ត្រកុំព្យូទ័រ ឬវិទ្យាសាស្ត្រសង្គម

(ឧទាហរណ៍៖ ចិត្តវិទ្យា ឬសង្គមវិទ្យា)។ តួនាទីនេះ ត្រូវការបំណិនផ្នែកស្រាវជ្រាវ និងបទពិសោធន៍ដែលអ្នកធ្វើការផ្នែកនេះជាធម្មតាបានទទួលសញ្ញាបត្រអនុបណ្ឌិត និងបណ្ឌិតតាមរយៈធ្វើការស្រាវជ្រាវសម្រាប់ប្រធានបទរបស់ពួកគេ។ នេះជាមូលហេតុដែលអ្នកវិភាគជោគជ័យបំផុតមានសញ្ញាបត្រអនុបណ្ឌិត ឬបណ្ឌិត។



អ្នកវិភាគទិន្នន័យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមមានការយល់ដឹងច្បាស់លាស់អំពីស្ថិតិ និងដឹងអំពីរបៀបស្វែងរក និងវិភាគព័ត៌មាន។ ពួកគេ ត្រូវតែមានសមត្ថភាពក្នុងកិច្ចការជំនួញ និងប្រើប្រាស់កម្មវិធីវិភាគទិន្នន័យ  និងត្រួតពិនិត្យតាមដានទិន្នន័យ។ អ្នកវិភាគទិន្នន័យដែលជោគជ័យ នឹងប្រើប្រាស់ព័ត៌មានដែលរកឃើញនៅក្នុងបរិមាណទិន្នន័យយ៉ាងច្រើន ដើម្បីផ្តល់ព័ត៌មានក្នុងការគ្រប់គ្រង។ ឧទាហរណ៍៖ ការវាស់ស្ទង់ផលប៉ះពាល់នៃយុទ្ធសាស្ត្រទីផ្សារនៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមនឹងជួយអ្នកដឹកនាំក្រុមហ៊ុនកំណត់បាននូវយុទ្ធសាស្ត្រទីផ្សារនៅថ្ងៃអនាគត។

អ្នកវិភាគទិន្នន័យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមចាំបាច់ត្រូវមានបំណិនទំនាក់ទំនងខ្លាំង ព្រោះពួកគេត្រូវតែអាចសរសេរបានត្រឹមត្រូវ និងនិយាយបានច្បាស់ ដែលអាចពន្យល់គំនិតស្មុគស្មាញដល់មនុស្សដែលមិនមានបទពិសោធន៍ផ្នែកស្ថិតិ។ ពួកគេត្រូវមានបំណិនសរសេរដើម្បីបកប្រែទិន្នន័យជាលេខទៅជារបាយការណ៍សរសេរដែលងាយយល់។ ពួកគេត្រូវតែមានទំនុកចិត្តអាចនិយាយបានល្អនៅមុខក្រុមមនុស្ស ដោយសារពួកគេត្រូវធ្វើបទបង្ហាញការរកឃើញរបស់ពួកគេជាញឹកញាប់ដល់ក្រុមមនុស្ស។

## អ្នកវិភាគទិន្នន័យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម

ចាំបាច់ត្រូវមានបំណិនអន្តរបុគ្គលល្អ ព្រោះពួកគេត្រូវមានទំនាក់ទំនងគ្នាទៅវិញទៅមកជាមួយអ្នកជំនាញផ្សេងៗនៅពេលធ្វើការស្រាវជ្រាវ ហើយពួកគេត្រូវតែដឹងអំពីរបៀបសួរសំណួរត្រឹមត្រូវ និងបកប្រែចម្លើយតាមរយៈបំណិនស្តាប់ដ៏សកម្ម។ នៅថ្នាក់ក្រុមហ៊ុន ពួកគេអាចធ្វើការជាក្រុមហ៊ុនជាមួយអ្នករចនាវេបសាយ អ្នកគ្រប់គ្រងកំណត់ហេតុបណ្តាញ និងអ្នកគ្រប់គ្រងទីផ្សារដើម្បីប្រាកដថាវេបសាយរបស់ក្រុមហ៊ុន និងវេបសាយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមអាចផ្តល់ព័ត៌មានតាមតម្រូវការ។ បំណិនផ្សេងៗដែលចាំបាច់អ្នកវិភាគទិន្នន័យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមត្រូវមានក៏រួមមានបំណិនស្តាប័នល្អ និងការយកចិត្តទុកដាក់លម្អិត។

## អ្នកតំណាងទីផ្សារប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម

តួនាទីអ្នកតំណាងទីផ្សារប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមទាក់ទងនឹងការចែករំលែក និងគ្រប់គ្រងមាតិកាព័ត៌មានជំនួសឱ្យក្រុមហ៊ុនតាមមធ្យោបាយប្រព័ន្ធផ្សព្វផ្សាយ។ ការងារនេះទាមទារការចំណាយពេលច្រើននៅលើបណ្តាញសង្គមដូចជា Facebook Twitter LinkedIn ឬ YouTube ប្រើប្រាស់កម្មវិធីវិភាគព័ត៌មានប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម និងទំនាក់ទំនងទៅវិញទៅមករវាងអ្នកប្រើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមផ្សេងៗ។

តួនាទីនេះមិនចាំបាច់ត្រូវការកម្រិតបរិញ្ញាបត្រពីសាកលវិទ្យាល័យណាមួយទេ ប៉ុន្តែក្រុមហ៊ុនជាច្រើនពេញចិត្តអ្នកដាក់ពាក្យដែលមានកម្រិតបរិញ្ញាបត្រនៅក្នុងផ្នែកផ្សព្វផ្សាយ ទីផ្សារ ឬទំនាក់ទំនង។ ជាទូទៅ ក្រុមហ៊ុនត្រូវការអ្នកតំណាងទីផ្សារប្រព័ន្ធផ្សព្វផ្សាយដែលមានបំណិនកុំព្យូទ័រ

ខ្ពស់ និងបទពិសោធន៍ពីមុនផ្នែកទីផ្សារ ឬការលក់ ក៏ដូចជាចំណេះដឹងអំពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម។

មាតិកាព័ត៌មានដែលព្រាងដោយអ្នកតំណាងទីផ្សារប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម ជាធម្មតាបានបញ្ចប់ដោយអ្នកជំនាញបច្ចេកទេសដែលប្រើការរចនាវេបសាយ កម្មវិធីកែសម្រួលវីដេអូ ឬរូបភាពដើម្បីបង្កើតអត្ថបទ រូបថត រូបភាព កំណត់ហេតុបណ្ដាញ និងវីដេអូដែលទាក់ទងកិច្ចការជំនួញ។ អ្នកតំណាងទីផ្សារប្រព័ន្ធផ្សព្វផ្សាយសហការជាមួយអ្នកជំនាញប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមផ្សេងៗក្នុងស្ថាប័នជាមួយគ្នា ភាគច្រើនជាមួយអ្នកគ្រប់គ្រងកំណត់ហេតុបណ្ដាញ។

បំណិនទំនាក់ទំនងសំណេរ និងដោយផ្ទាល់មាត់ប្រសើរ មានភាពចាំបាច់ដែលអាចក្លាយជាក្រុមការងារខ្លាំង ព្រោះអ្នកតំណាងទីផ្សារប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមធ្វើការរួមគ្នាជាមួយសមាជិកក្រុមផ្សេងៗ ចែកចាយគំនិត យោបល់ចូលរួមក្នុងផែនការទីផ្សារប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម។ ពួកគេត្រូវរាយការណ៍ទៅអ្នកគ្រប់គ្រងទីផ្សារប្រព័ន្ធផ្សព្វផ្សាយ។

បំណិនផ្សេងទៀតដែលត្រូវមាន រួមមានសមត្ថភាពផ្ដោតលើគោលដៅលក់ច្បាស់លាស់ បំណិនគ្រប់គ្រងពេលវេលា និងយល់ដឹងពីស្ថាប័ន ភាពប្រាស្រ័យគ្នា និងចំណាប់អារម្មណ៍យ៉ាងប៉ិនប្រសព្វ និងយល់ច្បាស់ពីតម្រូវការអ្នកប្រើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម។

## អ្នកគ្រប់គ្រងទីផ្សារប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម

គោលដៅរបស់អ្នកគ្រប់គ្រងទីផ្សារប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម គឺដើម្បីនាំឱ្យក្រុមហ៊ុន និងសាខារបស់ក្រុមហ៊ុនមានការចាប់អារម្មណ៍ពីអ្នកប្រើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម។ ពួកគេចង់លើកកម្ពស់ការយល់ដឹងអំពីក្រុមហ៊ុន បង្កើតការចាប់អារម្មណ៍ និងទាក់ទាញអតិថិជនថ្មី។ អ្នកគ្រប់គ្រងទីផ្សារទទួលខុសត្រូវរចនា និងធ្វើយុទ្ធនាការទីផ្សារតាមយុទ្ធសាស្ត្រដែលបានកំណត់សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម។ ពួកគេមានចំណេះដឹងខ្ពស់អំពីទីផ្សារ ការផ្សាយពាណិជ្ជកម្ម ទំនាក់ទំនងសាធារណៈ និងសេវាកម្មអតិថិជន និងចេះប្រើកម្មវិធីគ្រប់គ្រងអាជីវកម្ម។

អ្នកគ្រប់គ្រងទីផ្សារប្រព័ន្ធផ្សព្វផ្សាយត្រូវមានយ៉ាងហោចណាស់មានចំណេះដឹងកម្រិតបរិញ្ញាបត្រ និងមានបទពិសោធន៍ដែលទទួលស្គាល់ក្នុងផ្នែកទីផ្សារឌីជីថល និងកម្មវិធីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម។ សាខា ឬក្រុមហ៊ុនធំៗ ជានិច្ចកាលពេញចិត្តបេក្ខជនដែលមានសញ្ញាបត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម។ ជាទូទៅអ្នកដែលមានការងារនេះយ៉ាងហោចណាស់ក៏មានបទពិសោធន៍ការងារប្រាំឆ្នាំក្នុងផ្នែកទីផ្សារ និងសម្របសម្រួលយុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយពហុវិស័យ។ ពួកគេគ្រប់គ្រងការងារអ្នកតំណាងទីផ្សារប្រព័ន្ធផ្សព្វផ្សាយរបស់ស្ថាប័ន និងទទួលខុសត្រូវធ្វើផែនការ និងវាយតម្លៃយុទ្ធសាស្ត្រ និងសេវាកម្មពហុវិស័យ។ ពួកគេក៏មានទំនួលខុសត្រូវបណ្ដុះបណ្ដាលបុគ្គលិកថ្មីផងដែរ។

យីហោ គឺជានិមិត្តសញ្ញា ឬពាក្យសម្គាល់ឱ្យក្រុមហ៊ុន។ តើអ្នកស្គាល់សញ្ញានេះដែរឬទេ?

ទោះបីអ្នកគ្រប់គ្រងទីផ្សារប្រព័ន្ធផ្សព្វផ្សាយមានប្រវត្តិការងារបច្ចេកទេសជាអ្នកតំណាងទីផ្សារប្រព័ន្ធផ្សព្វផ្សាយត្រូវមានក៏ដោយ បំណិនទំនាក់ទំនងអន្តរបុគ្គលមានសារៈសំខាន់ជាងបំណិនកុំព្យូទ័រ។ នេះក៏ព្រោះអ្នកគ្រប់គ្រងទីផ្សារ គឺជាប្រធានក្រុមការងារដែលត្រូវការលើកទឹកចិត្តអ្នកផ្សេង។ បំណិនស្ដាប់ល្អ យល់ព្រម និងទទួលយកការរិះគន់ គ្រប់គ្រងជម្លោះ និងបង្កើតកិច្ចសហប្រតិបត្តិការក៏មានសារៈសំខាន់ណាស់ដែរ។ អ្នកគ្រប់គ្រងទីផ្សារតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមត្រូវតែចេះ

ថែទាំទំនាក់ទំនងការងារប្រកបដោយប្រសិទ្ធភាពខ្ពស់ និងចាំបាច់ត្រូវចេះចរចាជាមួយអ្នកផ្សេង ឬបញ្ចុះបញ្ចូលពួកគេឱ្យផ្លាស់ប្តូរគំនិត ឬឥរិយាបថរបស់ពួកគេ។

បំណិន និងឥរិយាបថដ៏មានប្រយោជន៍ផ្សេងទៀតដែលអ្នកគ្រប់គ្រងទីផ្សារប្រព័ន្ធផ្សព្វផ្សាយត្រូវមានដូចជា ការច្នៃប្រឌិត សុច្ឆរិតភាព ភាពបត់បែន ការត្រិះរិះពិចារណា ភាពមិនងាយលះបង់ និងការប្តេជ្ញាចិត្តដើម្បីរៀនជានិច្ច។

# ២.២. បរិស្ថានការងារ

ខណៈដែលប្រព័ន្ធផ្សព្វផ្សាយ គឺជាផ្នែកមួយនៃឧស្សាហកម្មដែលមានការរីកចម្រើនយ៉ាងលឿននោះ ការងារនៅក្នុងវិស័យវិជ្ជាជីវៈនេះ គឺមានភាពបត់បែន និងប្រកួតប្រជែងខ្លាំងផងដែរ។ អ្នកជំនាញផ្នែកប្រព័ន្ធផ្សព្វផ្សាយត្រូវតែមានការតាមដានដំណើរការ និងភាពប្រែប្រួលជាប្រចាំក្នុងផ្នែកកម្មវិធីដែលទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម។ បរិស្ថាននេះទាមទារអ្នកជំនាញដែលអាចបង្កើតគំនិតថ្មីជានិច្ច មានការចាប់អារម្មណ៍បន្តរក្សាបច្ចុប្បន្នភាព និងជាអ្នកដែលចូលចិត្តរៀនជំនាញ និងចំណេះដឹងថ្មីជានិច្ច។ ដោយហេតុថាប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមជាប្រព័ន្ធសកល នោះបេក្ខជនដែលជោគជ័យដែលមានចំណេះដឹង ជំនាញ និងបទពិសោធន៍ដែលប្រសើរអាចចូលរួមក្រុមការងារជាអន្តរជាតិ។

អ្នករចនា អ្នកសរសេរកម្មវិធី ឬអ្នកថែទាំប្រព័ន្ធ និងកម្មវិធីបណ្តាញផ្សព្វផ្សាយសង្គមអាចធ្វើការម្នាក់ឯង ឬធ្វើការជាក្រុម។ ពេលខ្លះធ្វើការដោយជួបគ្នានៅក្នុងការិយាល័យ និងខ្លះគ្រាន់តែជួបគ្នាដោយភ្ជាប់តាមមធ្យោបាយអេឡិចត្រូនិកផ្សេងៗ។ ក្រុមការងារផ្នែកនេះអាចជួបគ្នាតាមរយៈកម្មវិធី Skype ឬជួបនៅក្នុងការិយាល័យផ្ទាល់ដើម្បីចាប់ផ្តើមយុទ្ធនាការអភិវឌ្ឍគម្រោង និងវាយតម្លៃមាតិកាព័ត៌មាន និងលទ្ធផល។ គុណតម្លៃផ្នែកពាណិជ្ជកម្មនៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម គឺអាស្រ័យតាមកំណើនចំនួនអ្នកប្រើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម ក៏ដូចជាពេលវេលាដែលអ្នកប្រើចំណាយលើប្រព័ន្ធផ្សព្វផ្សាយនេះ។

> *ភ្នាក់ងារ គឺជាក្រុមហ៊ុនដែលផ្តល់នូវសេវាកម្មជាក់លាក់ដល់ក្រុមហ៊ុនផ្សេង ដូចជា ការរចនាវេបសាយ ការរៀបចំយុទ្ធនាការទីផ្សារ ឬជួយរកបុគ្គលិកសម្រាប់ក្រុមហ៊ុនផ្សេង។*

អ្នកជំនាញខ្លះធ្វើការរួមគ្នាជាមួយអ្នកផ្សេងនៅក្នុងភ្នាក់ងារផ្តល់សេវាកម្មសម្រាប់ក្រុមហ៊ុនដែលមិនមានអ្នកជំនាញផ្នែកប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមផ្ទាល់ខ្លួនរបស់ពួកគេ។ ការងារនៅក្នុងភ្នាក់ងារមានន័យថាការទទួលភារកិច្ចផ្សេងៗពីអតិថិជនច្រើន និងបំពេញតាមសំណើរបស់ពួកគេក្នុងអំឡុងពេលជាក់លាក់ណាមួយ។ ក្រុមហ៊ុនមានការងារគ្រប់គ្រាន់ និងថវិកាសម្រាប់ជួលអ្នកជំនាញប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម ។

អ្នកជំនាញដែលមានបទពិសោធន៍អាចធ្វើការដោយខ្លួនឯងជាអ្នកធ្វើការក្រៅម៉ោងដោយសេរី។ ប្រសិនបើពួកគេមានភាពល្បីល្បាញ និងទទួលបានការកោតសរសើរចំពោះការងារពួកគេនឹងបង្កើតជំនួញ និងអាចបង្កើតជាភ្នាក់ងារផ្ទាល់ខ្លួនផងដែរ។

ការងារនៅក្នុងឧស្សាហកម្មផ្នែកប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមអាចត្រូវចំណាយពេលវេលាច្រើននៅមុខកុំព្យូទ័រ។ ទោះបីជាពួកគេធ្វើការដោយឯករាជក៏ដោយ អ្នកជំនាញទាំងអស់នេះត្រូវតែធ្វើការជាក្រុមដោយសេចក្តីទុកចិត្តដើម្បីដឹកនាំ និងណែនាំអ្នកផ្សេងនៅពេលចាំបាច់។



## មេរៀនសង្ខេប

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម គឺជាវិស័យការងារថ្មីដែលមិនទាមទារមានកម្រិតបរិញ្ញាបត្រទេ នាពេលបច្ចុប្បន្ន។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមមានភាពរីកចម្រើន តែទោះជាយ៉ាងណាក្តីក៏ត្រូវការ បំណិនដែលមានស្រាប់ ក្នុងការទាក់ទាញអ្នកជំនាញពីផ្នែកសារព័ត៌មាន ឬទីផ្សារដើម្បីទទួលយកមុខ តំណែងជាអ្នកគ្រប់គ្រងកំណត់ហេតុបណ្តាញ អ្នកតំណាងទីផ្សារតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម ឬអ្នកគ្រប់គ្រងទីផ្សារតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម។ ផ្នែកនេះក៏ទាក់ទាញអ្នកស្រាវជ្រាវដែល មានបទពិសោធន៍ដើម្បីក្លាយជាអ្នកវិភាគទិន្នន័យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម។ អ្នកសរសេរកូដ កម្មវិធី និងអ្នករចនាវេបសាយជាច្រើនក៏បានចូលរួមក្រុមការងារប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមនៅក្នុង ភ្នាក់ងារ ឬក្រុមហ៊ុនធំផងដែរ។ អ្នកជំនាញផ្នែកប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមត្រូវប្រាកដថាក្រុមហ៊ុន ដែលពួកគេធ្វើការអាចប្រើប្រាស់ឥទ្ធិពលនៃប្រព័ន្ធផ្សព្វផ្សាយទាំងអស់ដើម្បីជួយគាំទ្រដល់ការលក់ និង ទីផ្សារផលិតផល និងសេវាកម្មរបស់ពួកគេ។ យោងតាមតម្រូវការឧស្សាហកម្ម កម្មវិធីសិក្សាផ្នែកប្រព័ន្ធ ផ្សព្វផ្សាយនឹងចាប់ផ្តើមដាក់ឱ្យសិក្សានៅតាមសាកលវិទ្យាល័យ និងកម្រិតសាកលវិទ្យាល័យអាចក្លាយជា តម្រូវការសម្រាប់តួនាទីការងារនេះ។

## លំហាត់

### លំហាត់ ១

ក្នុងលំហាត់នេះ អ្នកនឹងស្វែងយល់បន្ថែមអំពីដំណើរការនៃការតភ្ជាប់ទៅប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន សង្គម។ ហេតុអ្វីបានជាការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមមានការកើនឡើងនៅកម្ពុជា និងនៅ បណ្តាប្រទេសផ្សេងៗ? សូមមើលរូបភាពខាងលើ និងស្វែងយល់ការតភ្ជាប់រវាងតម្រូវការរបស់មនុស្សក្នុង ការប្រាស្រ័យទាក់ទង ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម កម្មវិធី និងអាជីវកម្ម។




ក. ពិភាក្សាចំណាប់អារម្មណ៍ដែលក្រុមហ៊ុន និងស្ថាប័នត្រូវមានប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម។ ហេតុអ្វីបានជាប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមមានសារៈសំខាន់សម្រាប់ជំនួញ? តើជំនួញអាចផ្តល់ឱ្យអ្នកប្រើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមនូវឥទ្ធិពលអ្វីខ្លះ? រៀបចំឱ្យបានច្បាស់នូវប្រយោគពីរទៅបួនដើម្បីឆ្លើយតបនឹងសំណួរទាំងនេះ និងផ្សាយវានៅក្នុងថតសិក្សារបស់អ្នក។

ខ. សូមប្រើក្រដាសសៀវភៅរបស់ប្អូនៗ បង្កើតប័ណ្ណប្រកាសព័ត៌មានមួយ។ សរសេរអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមនៅលើស្លាយមួយ និងកត្តាប្រឈមនៅស្លាយផ្សេង។ ជ្រើសរើសសមាជិកម្នាក់ក្នុងក្រុមរបស់អ្នកដើម្បីធ្វើបទបង្ហាញប័ណ្ណប្រកាសព័ត៌មានរបស់អ្នកដល់សមាជិកក្រុមផ្សេង។ សមាជិកក្រុមដំបូងគេនឹងត្រូវធ្វើបទបង្ហាញចំនួនពីរនាទីដើម្បីពន្យល់អំពីអត្ថប្រយោជន៍ និងសមាជិកក្រុមផ្សេងនឹងត្រូវពន្យល់ពីរនាទីដែរសម្រាប់កត្តាប្រឈម។

## លំហាត់ ២

អ្នកបានសម្រេចចិត្តថាគោលបំណងការងាររបស់អ្នក គឺនឹងក្លាយជាអ្នកវិភាគទិន្នន័យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមសម្រាប់សាជីវកម្មធំមួយ។ អ្នកដឹងហើយថាត្រូវការចំណាយរាប់ឆ្នាំដើម្បីក្លាយជាអ្នកជំនាញ។ នៅក្នុងក្រុមរបស់អ្នក សូមធ្វើការពិភាក្សាសំណួរខាងក្រោម និងប្រកាសផ្សាយចម្លើយទៅថតក្រុមរបស់អ្នក។

ក. ចូរពិភាក្សាជាមួយសមាជិកក្រុមរបស់អ្នកអំពីអ្វីជាការអប់រំ, បទពិសោធន៍ការងារ និងបំណិនប្រាស្រ័យទាក់ទង និងបច្ចេកទេសដែលអ្នកត្រូវមានដើម្បីសម្រេចបានគោលបំណងរបស់អ្នក។

ខ. នៅក្នុងក្រុមរបស់អ្នក ចូរពិភាក្សាបំណិនជាក់លាក់ ដែលអ្នកគិតថានឹងជាការលំបាកទទួលបានបំផុតដើម្បីក្លាយជាអ្នកវិភាគទិន្នន័យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម។ សូមពន្យល់។

គ. សាជីវកម្មធំជ្រើសរើសបុគ្គលិកដោយសម្រិតសម្រាំងបំផុត និងមានអ្នកដាក់ពាក្យចូលបម្រើការងារច្រើន។ តើបំណិន និងការអប់រំអ្វីខ្លះដែលអ្នកនឹងត្រូវមានដើម្បីអភិវឌ្ឍឱ្យលេចធ្លោពីអ្នកផ្សេងទៀត? តើអ្នកគួរធ្វើអ្វីខ្លះដើម្បីអភិវឌ្ឍបំណិន និងការអប់រំដើម្បីបំពេញគោលបំណងការងាររបស់អ្នក? (សាជីវកម្មធំៗនៅកម្ពុជារួមមានធនាគារពាណិជ្ជកម្ម ដូចជា ធនាគារអេស៊ីលីដា និង ANZ ឬស្ថានីយទូរទស្សន៍ធំៗ។)

## សំណួរត្រិះរិះ

១. តើអ្វីជាប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម និងតើវាខុសគ្នាយ៉ាងដូចម្ដេចជាមួយប្រព័ន្ធផ្សព្វផ្សាយផ្សេងៗយ៉ាងដូចម្ដេច?

២. តើការងារចំនួនបួន នៅក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គមមានអ្វីខ្លះ?

៣. តើហេតុអ្វីបានជាក្រុមហ៊ុន និងស្ថាប័នធ្វើការស្វែងរកអ្នកជំនាញឱ្យធ្វើការនៅក្នុងផ្នែកប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម?

៤. តើចំណេះដឹង និងបំណិនបច្ចេកទេសអ្វីខ្លះ ដែលអ្នកគ្រប់គ្រងកំណត់ហេតុបណ្ដាញត្រូវមាន?

៥. តើការងារអ្វីខ្លះដែលអ្នកវិភាគទិន្នន័យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមត្រូវធ្វើ? តើទិន្នន័យអ្វីខ្លះដែលពួកគេត្រូវវិភាគ និងមានគោលបំណងអ្វី?

៦. តើការងារអ្វីដែលអ្នកតំណាងទីផ្សារប្រព័ន្ធផ្សព្វផ្សាយត្រូវធ្វើ? តើបំណិនអ្វីខ្លះ ដែលពួកគេត្រូវមាន?

៧. តើការងារសំខាន់បំផុត និងបំណិនផ្ទាល់ខ្លួនអ្វីខ្លះ ដែលអ្នកគ្រប់គ្រងទីផ្សារប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមត្រូវតែមាន?

# ផ្នែក ខ - ការប្រើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម ដោយប្រសិទ្ធភាព

## ៣. ការចូលរួមយ៉ាងសកម្មក្នុងទំនាក់ទំនងឌីជីថល

បន្ទាប់ពីបានសិក្សាអំពីការងារនៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម ចរណៃដឹងថាមានមិត្តភ័ក្តិជាច្រើនខ្វល់ខ្វាយអំពីអនាគតរបស់ពួកគេ បារម្ភអំពីជីវិតបន្ទាប់ពីបញ្ចប់ការសិក្សានៅមធ្យមសិក្សា និងមានការតានតឹងពិបាកក្នុងការសម្រេចចិត្តជ្រើសរើសការងារអ្វី។ ផ្ទុយពីចរណៃ ពួកគេមិនសកម្មក្នុងការស្រាវជ្រាវជម្រើសរបស់ពួកគេទេ។ មានមិត្តភ័ក្តិជាច្រើនតែងតែស្នើសុំឱ្យចរណៃសរសេរពីអ្វីដែលចរណៃធ្លាប់ធ្វើការសម្ភាសន៍ជាមួយអ្នកជំនាញ និងចែករំលែកចំណេះដឹងថ្មីៗ។ នាងមានគិតថាការបញ្ចេញទស្សនៈ និងការបារម្ភអំពីអនាគតនឹងជាគុណតម្លៃដល់មនុស្សជាច្រើន មិនមែនចំពោះតែមិត្តភ័ក្តិរបស់នាងទេ។



នាងប្រាប់ដានីអំពីគំនិតក្នុងការចែករំលែកបទពិសោធន៍នៅក្នុងព្រឹត្តិការណ៍សាធារណៈដោយប្រើបច្ចេកវិទ្យាតាមអ៊ីនធឺណិត។ ដានីគាំទ្រនូវគំនិតរបស់ចរណៃ ។

"ខ្ញុំពិតជាចូលចិត្តភាពត្រេកអររបស់អ្នកខ្លាំងណាស់" ដានីនិយាយទៅកាន់ចរណៃ។ "ខ្ញុំគិតថាវាពិតជាប្រសើរណាស់ដែលអ្នកអាចប្រើពេលវេលាទំនេររបស់អ្នកជួយយុវជនស្វែងយល់ជម្រើសរបស់ពួកគេ។ ដូចដែលអ្នកបានដឹងហើយថា នៅពេលអ្នកមានព័ត៌មានដែលអ្នកផ្សេងអាចចាប់អារម្មណ៍ អ្នកអាចប្រើទំនាក់ទំនងឌីជីថលដើម្បីផ្តល់ព័ត៌មានដល់អ្នកទស្សនាបានយ៉ាងច្រើន ហើយវានឹងជួយឱ្យជំនាញរបស់អ្នកប្រសើរផងដែរ ក៏ដូចជាផ្តល់អត្ថប្រយោជន៍ដល់អ្នកក្នុងការងាររបស់អ្នក។"

បុគ្គលដែលសម្រេចចិត្តចូលរួមយ៉ាងសកម្មនៅលើបណ្តាញ ធ្វើការសម្រេចចិត្តផ្ទាល់ខ្លួនអំពីប្រធានបទអ្វីដែលត្រូវស្រាវជ្រាវ និងសរសេរអំពីការស្រាវជ្រាវនោះ? ដូចចរណៃអញ្ចឹង អ្នកខ្លះចង់ចែករំលែកចំណេះដឹង និងបទពិសោធន៍របស់ពួកគេ និងសង្ឃឹមថានឹងមានភាពស្និទ្ធស្នាលជាមួយអ្នកដទៃ។ អ្នកខ្លះចង់សម្តែងនូវគំនិត និងទស្សនៈរបស់ពួកគេជាសាធារណៈ ជ្រើសរើសប្រធានបទសង្គម ឬផ្ទាល់ខ្លួនដែលសំខាន់ចំពោះពួកគេ។ World Wide Web បច្ចុប្បន្ន អនុញ្ញាតឱ្យអ្នកប្រើចូលរួមនៅលើវេបសាយ និងកម្មវិធីផ្សេងៗជាច្រើន។ ឧទាហរណ៍ដូចបានបង្ហាញខាងក្រោម។

### កំណត់ហេតុបណ្តាញ

កំណត់ហេតុបណ្តាញ គឺជាវេបសាយដែលបង្កើតឡើងដោយបុគ្គល ឬក្រុមតូចមួយ ដែលមានទម្រង់អត្ថបទមិនផ្លូវការដែលគេហៅថាប្រកាសកំណត់ហេតុបណ្តាញ ដែលត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំជាមួយមាតិកាព័ត៌មានថ្មី។ ជាធម្មតាកំណត់ហេតុបណ្តាញមានអត្ថបទ

ព័ត៌មានខ្លីដែលបង្ហាញអំពីទស្សនៈយល់ឃើញ បទពិសោធន៍ និងចំណាប់អារម្មណ៍របស់អ្នកបង្កើតកំណត់ហេតុបណ្ដាញនីមួយៗ។ ប្រកាសកំណត់ហេតុបណ្ដាញជានិច្ចកាលមានការរួមបញ្ចូលគ្នានៃអត្ថបទ រូបថត វីដេអូ ឬអូឌីយ៉ូ។

នៅពេលកំណត់ហេតុបណ្ដាញត្រូវបានសរសេរដោយក្រុមមនុស្សមួយក្រុម វាដូចទៅនឹងទស្សនាវដ្ដីលើអ៊ីនធឺណិតដែរ។ ប្រសិនបើកំណត់ហេតុបណ្ដាញមានលក្ខណៈជាជំនួញឬអាជីវកម្ម នោះវាត្រូវបានប្រើសម្រាប់ផ្សព្វផ្សាយផលិតផល ផ្ដល់សេវាកម្ម ឬការអប់រំដល់អតិថិជន ឬចែករំលែកដំណឹងអំពីជំនួញ។ ទោះជាយ៉ាងណាក៏ដោយ កំណត់ហេតុបណ្ដាញភាគច្រើនត្រូវបានសរសេរដោយមនុស្សម្នាក់ ហើយវាច្រើនតែជារឿងបុគ្គល ឆ្លុះបញ្ចាំងពីលក្ខណសម្បត្តិបុគ្គល និងចំណាប់អារម្មណ៍របស់អ្នកសរសេរកំណត់ហេតុបណ្ដាញ។

## សេវាកម្មកំណត់ហេតុបណ្ដាញ

សេវាកម្មកំណត់ហេតុបណ្ដាញ គឺជាវេបសាយដែលអាចឱ្យអ្នកប្រើបង្កើត និងថែទាំកំណត់ហេតុបណ្ដាញ។ មានប្រភេទមូលដ្ឋានពីរនៃសេវាកម្មកំណត់ហេតុបណ្ដាញ៖ សេវាកម្មកំណត់ហេតុបណ្ដាញជាទម្លាប់ និងសេវាកម្មមីក្រូកំណត់ហេតុបណ្ដាញ។ សេវាកម្មកំណត់ហេតុបណ្ដាញដែលពេញនិយមបំផុតដូចជា WordPress និង Blogger ផ្ដល់នូវលក្ខណៈសម្បត្តិកំណត់ហេតុបណ្ដាញពេញលេញអាចឱ្យអ្នកបង្កើតប្រភេទប្រកាសជាច្រើន និងត្រួតពិនិត្យរូបរាងរបស់កំណត់ហេតុបណ្ដាញ និងមតិយោបល់ផ្សេងៗ។ ផ្ទុយទៅវិញ សេវាកម្មមីក្រូកំណត់ហេតុបណ្ដាញ កំណត់ទ្រង់ទ្រាយដែលមាតិកាព័ត៌មានរបស់អ្នកត្រូវបង្ហាញ និងអាចឱ្យអ្នកបង្កើតប្រកាសដែល

ខ្លី មានអត្ថបទ រូបភាព ឬតំណ អ្វីដែលអ្នកត្រូវធ្វើ គឺសរសេរប្រកាសរបស់អ្នក និងផ្ញើវា។ សេវាកម្មមីក្រូកំណត់ហេតុបណ្ដាញដ៏ល្បីល្បាញបំផុតលើពិភពលោក គឺ Twitter Tumblr និង Pinterest។ បណ្ដាញសង្គមដូចជា Facebook ក៏អាចប្រើបានសម្រាប់ចែករំលែកប្រកាស រូបថត ឬតំណតាមមីក្រូកំណត់ហេតុបណ្ដាញ ឬជំឡើងទំព័រគាំទ្រ Facebook ។

## វិគី

វិគី គឺជាកម្មវិធីបណ្ដាញមួយដែលអាចឱ្យអ្នកប្រើជាច្រើនបង្កើត រៀបចំ និងកែសម្រួលមាតិកាព័ត៌មានរបស់វា និងរៀបចំរចនាសម្ព័ន្ធក្នុងទម្រង់សហការមួយ។ វិគី ខុសពីកំណត់ហេតុបណ្ដាញត្រង់ថាមាតិកាត្រូវបានបង្កើតដោយគ្មានម្ចាស់ ឬអ្នកដឹកនាំ។ មាតិកាត្រូវបានសរសេររួមគ្នា និងធ្វើបច្ចុប្បន្នភាពដោយមនុស្សនៅជុំវិញពិភពលោកដែលមានចំណាប់អារម្មណ៍លើប្រធានបទណាមួយ។ អត្ថបទវិគីអាចប្រកាសដោយមនុស្សម្នាក់ ហើយបន្ទាប់មកត្រូវបានធ្វើឱ្យប្រសើរ ឬធ្វើបច្ចុប្បន្នភាពដោយអ្នកផ្សេងៗ។ ប្រព័ន្ធកម្មវិធីវិគី ដែលពេញនិយម និងល្បីល្បាញបំផុត គឺសព្វវចនាធិប្បាយសេរីដែលគេហៅថា វិគីភីឌា ដែលមនុស្សជាច្រើនកំពុងប្រើដើម្បីស្វែងរកចម្លើយចំពោះសំណួរដែលពួកគេរក។

## វេទិកាលើអ៊ីនធឺណិត

វេទិកាលើអ៊ីនធឺណិត គឺជាវេបសាយពិភាក្សានៅលើអ៊ីនធឺណិត ជាកន្លែងដែលអ្នកអាចធ្វើការសន្ទនាជាមួយអ្នកផ្សេងៗបាន។ វេទិកាលើអ៊ីនធឺណិតជានិច្ចកាល ផ្ដោតលើប្រធានបទជាក់លាក់មួយ

ដូចជា៖ បញ្ហាសុខភាព ដំបូន្មានផ្ទាល់ខ្លួន ឬជំនួយបច្ចេកទេសផ្សេងៗ។ អាស្រ័យលើកម្រិតដែលអ្នកប្រើអាចចូលបាន ឬការរៀបចំវេទិកា សារដែលបានប្រកាសនឹងត្រូវអនុញ្ញាតដោយអ្នកសម្របសម្រួលមុនពេលវាត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

វេបសាយសម្រាប់ចែករំលែករូបភាព ឬវីដេអូ៖ វេបសាយទាំងនេះ គឺជាសេវាកម្មបណ្ដាញដែលអនុញ្ញាតឱ្យអ្នកផ្ទុក និងបង្ហាញរូបភាព ឬវីដេអូឌីជីថលនៅលើអ៊ីនធឺណិត និងចែករំលែកជាឯកជន ឬសាធារណៈជាមួយអ្នកផ្សេងៗ។ វេបសាយចែករំលែករូបថតដ៏ពេញនិយម គឺកម្មវិធី Instagram ឬ Flickr រីឯ YouTube និង Vimeo គឺជាវេបសាយចែករំលែកវីដេអូដ៏ពេញនិយម។ អ្នកដែលចង់ចែករំលែកមាតិកាព័ត៌មាននៅលើវេបសាយទាំងនេះអាចបង្កើតគណនី និងជ្រើសជម្រើសការរក្សាសិទ្ធិផ្សេងៗដើម្បីសម្រេចថាតើអ្នកផ្សេងអាចប្រើប្រាស់ការងាររបស់ពួកគេបានកម្រិតណា។ ជាមួយសេវាកម្មទាំងអស់នេះ អ្នកប្រើអាចមានអ្នកតាមមើល ដែលត្រូវបានជូនដំណឹងដោយស្វ័យប្រវត្តិរាល់ពេលដែលអ្នកប្រើប្រកាសផ្សាយរូបភាព ឬវីដេអូថ្មី។ អ្នកណាក៏អាចផ្ដល់មតិយោបល់នៅលើរូបភាព និងវីដេអូ ហើយអាចឃើញមតិយោបល់ពីអ្នកផ្សេងៗ ដែលប្រែក្លាយវេបសាយទាំងនេះជាបណ្ដាញសង្គម។

ប្រភេទនៃសេវាកម្មដែលអ្នកប្រើអាចចែករំលែកចំណេះដឹង និងផ្លាស់ប្ដូរគំនិតយោបល់ជាមួយអ្នកផ្សេងៗបាន វាអាស្រ័យតាមប្រភេទមាតិកាព័ត៌មានដែលអ្នកចង់ចែករំលែក។ ប្រសិនបើអ្នកប្រើទ្រង់ទ្រាយផ្សេងៗ នោះអ្នកអាចប្រើសេវាកម្មជាច្រើន និងភ្ជាប់រវាងពួកគេ។ អ្នកអភិវឌ្ឍបណ្ដាញបានបង្កើតឧបករណ៍សម្រាប់ចូលរួមដោយសកម្មនៅលើបណ្ដាញ វាអាស្រ័យលើអ្នកក្នុងការប្រើឧបករណ៍ទាំងនេះដោយការទទួលខុសត្រូវ និងចែករំលែកមាតិកាដែលមានប្រយោជន៍ ដោយការបង្ហាញបទពិសោធន៍ផ្ទាល់ខ្លួន គុណតម្លៃ ចៀសវាងការបង្ហោះគំនិតដែលគ្មានព័ត៌មានច្បាស់លាស់ ប្រើប្រាស់ពាក្យអសុរោះ ឬការខ្សឹបខ្សៀវ ដែលទៅក្នុងការពិភាក្សាជាសាធារណៈដែលប៉ះពាល់ដល់អ្នកដទៃ។ ការប្រើបំណិនអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយមូលដ្ឋាន គឺសំខាន់ដូចការយល់ដឹងផ្ទាល់ខ្លួននៃព្រឹត្តិការណ៍ និងអ្វីមួយដែលគួរនិយាយ។ ការបង្កើតកំណត់ហេតុបណ្ដាញផ្ទាល់ខ្លួនអ្នក គឺជាមធ្យោបាយដែលបានរៀបចំមួយដើម្បីចូលរួមនៅក្នុងសង្គមឌីជីថលដោយផ្ដល់ចំណេះដឹង ឬការកម្សាន្តចំពោះអ្នកផ្សេងៗ បង្កើតបំណិនសរសេររបស់អ្នក និងក្លាយជាផ្នែកនៃសហគមន៍ដែលចែករំលែកចំណាប់អារម្មណ៍របស់អ្នក។ មីក្រូកំណត់ហេតុបណ្ដាញ និងការផ្ដល់មតិនៅលើបណ្ដាញសង្គម ក៏ជាទម្រង់នៃការចូលរួម ប៉ុន្តែវាមិនមានគុណតម្លៃដូចសរសេរលើកំណត់ហេតុបណ្ដាញទេ។ ជាទូទៅ ធាតុកំណត់ហេតុបណ្ដាញត្រូវបានធ្វើការស្រាវជ្រាវ និងសរសេរដោយប្រុងប្រយ័ត្នដោយអ្នកនិពន្ធ ដោយប្រាកដថាពួកគេផ្ដល់តម្លៃដល់អ្នកអាន។ ផ្នែកខាងក្រោមរៀបរាប់អំពីជំហានក្នុងការបង្កើតកំណត់ហេតុបណ្ដាញ។



# ៤. ទំនាក់ទំនងឌីជីថលតាមរយៈកំណត់ហេតុបណ្ដាញ

ប្រសិនបើអ្នកចង់បង្កើតកំណត់ហេតុបណ្ដាញ សូមអានកំណត់ហេតុបណ្ដាញដែលមានស្រាប់ជាមុនសិន ព្រោះវាអាចជាមធ្យោបាយចាប់ផ្ដើមមួយ។ អ្នកនឹងរកឃើញថាប្រភេទកំណត់ហេតុបណ្ដាញបែបណាដែលអ្នកចាប់អារម្មណ៍ តើកំណត់ហេតុបណ្ដាញអាចប្រើដើម្បីផ្ដល់ព័ត៌មានបានយ៉ាងដូចម្ដេច និងតើអ្វីដែលធ្វើឱ្យអ្នកគិតថាជាការកម្សាន្ត ឬចំណាប់អារម្មណ៍អ្វីមួយ។ កំណត់ហេតុបណ្ដាញត្រូវបានសរសេរដោយមនុស្សគ្រប់វ័យដែលមានបទពិសោធន៍ច្រើន។

## ៤.១. ធ្វើផែនការសម្រាប់កំណត់ហេតុបណ្ដាញ

នៅពេលចាប់ផ្ដើមកំណត់ហេតុបណ្ដាញថ្មី អ្នកប្រហែលជាគិតថាតិចតួចនៅពេលដំបូង ការចំណាយពេលរបស់អ្នកច្រើននឹងធ្វើឱ្យអ្នកមានអារម្មណ៍ជឿទុកចិត្តនៅគ្រប់ជំហាននៃដំណើរការ។

### ជំហាន ១៖ កំណត់គោលបំណងនៃកំណត់ហេតុបណ្ដាញរបស់អ្នក

ប្រសិនបើ អ្នកចង់ឱ្យទ្រឹស្ដីក្លាយជាការអនុវត្ត ដំបូងអ្នកគួរតែគិតពិចារណាដោយប្រុងប្រយ័ត្នអំពីអ្វីជាគោលបំណងរបស់អ្នក និងឆ្លើយសំណួរដូចខាងក្រោម៖

- តើអ្វីជាមូលហេតុចម្បងដែលធ្វើឱ្យអ្នកចង់ចាប់ផ្ដើមបង្កើតកំណត់ហេតុបណ្ដាញ? តើគោលបំណងអ្វីដែលអ្នកចង់សម្រេចបាន? គោលបំណង អាចជាអ្វីដែលសាមញ្ញដូចការចែករំលែកចំណាប់អារម្មណ៍របស់អ្នកលើព្រឹត្តិការណ៍ដែលបានកើតឡើងរៀងរាល់ថ្ងៃ ឬអ្វីដែលជាក់លាក់បំផុត ដូចជាការជួយសិស្សានុសិស្សជ្រើសរើសការងារដោយផ្ដល់នូវព័ត៌មានជាសាធារណៈអំពីការងារដែលមានសម្រាប់ពួកគេជ្រើសរើស ដូចដែលចរណៃចង់ធ្វើ។ ក្នុងករណីខ្លះ គោលបំណង គឺដើម្បីជួយសហសេវិក មិត្តភ័ក្ដិ និងអ្នកផ្សេងទៀតដែលមានបំណងរកប្រាក់ ដោយផ្ដល់នូវព័ត៌មាន ឬការកម្សាន្ត ខណៈដែលអ្នកអានក៏មើលឃើញពាណិជ្ជកម្មដែលបង្ហាញនៅក្នុងកំណត់ហេតុបណ្ដាញផងដែរ។
- តើប្រធានបទអ្វីខ្លះដែលអ្នកចាប់អារម្មណ៍? តើអ្នកផ្សេងចាប់អារម្មណ៍វាដែរឬអត់? តើព័ត៌មានដែលផ្សព្វផ្សាយអំពីប្រធានបទនេះត្រូវនឹងគោលបំណងដែលអ្នកបានកំណត់ដែរឬទេ?
- តើអ្នកណាជាអ្នកទស្សនាគោលដៅរបស់អ្នក? អ្នកណាដែលចង់អានកំណត់ហេតុបណ្ដាញរបស់អ្នក?
- តើចំណេះដឹង បទពិសោធន៍ និងបំណិនអ្វីដែលអ្នកមានអំពីប្រធានបទកំណត់ហេតុបណ្ដាញរបស់អ្នក និងកត្តាអ្វីខ្លះដែលអ្នកខ្វះខាត?

គោលបំណងសំខាន់របស់ចរណៃ គឺដើម្បីចែករំលែកការរៀនរបស់នាងអំពីការងារនៅក្នុងប្រទេសកម្ពុជាជាមួយមិត្តភ័ក្ដិរបស់នាង។ នាងក៏ មានបំណងឱ្យយុវវ័យដែលកំពុងស្វែងរកការងារតាមរយៈការអានកំណត់ហេតុបណ្ដាញរបស់អ្នក និងបង្កើតទំនាក់ទំនង ឬបណ្ដាញជាមួយអ្នកផ្សេងៗដែលមានស្ថានភាពតម្រូវការប្រហាក់ប្រហែលគ្នា បង្កើតសហគមន៍ឌីជីថលតាមរយៈកំណត់ហេតុបណ្ដាញរបស់នាង ពិភាក្សាការងារផ្សេងៗ និងធ្វើការសម្រេចចិត្តបានប្រសើរអំពីអ្វី

ដែលត្រូវសិក្សា ឬការងារដែលត្រូវបន្ត។ បណ្ដាញក្នុងករណីនេះគឺជាការតភ្ជាប់ទំនាក់ទំនងនៅលើអ៊ីនធឺណិតជាមួយមនុស្សផ្សេងៗដើម្បីផ្លាស់ប្ដូរព័ត៌មាន និងធ្វើឱ្យប្រសើរឡើងនូវចំណេះដឹង និងឱកាសការងារ ឬផ្ទាល់ខ្លួន។ ចរណៃមានរឿងច្រើនដែលត្រូវនិយាយ ហើយនាងដឹងថាតាមរយៈកំណត់ហេតុបណ្ដាញ នាងនឹងអាចផ្ដល់គំនិតរបស់នាងដល់អ្នកផ្សេងៗ ធ្វើឱ្យប្រសើរបំណិនសរសេរ និងបច្ចេកទេសរបស់នាងផងដែរ។

## ជំហាន ២៖ កំណត់ប្រធានបទរបស់អ្នក រកពាក្យគន្លឹះ និងជ្រើសចំណងជើង

កត្តាដ៏ធំមួយដែលនាំឱ្យមានភាពជោគជ័យនៅក្នុងកំណត់ហេតុបណ្ដាញរបស់អ្នក គឺត្រូវមានប្រធានបទសម្រាប់អ្នក និងអ្នកអានចាប់អារម្មណ៍គោលបំណងរបស់អ្នក។ វាត្រូវតែជាប្រធានបទដែលមានគុណតម្លៃសម្រាប់អ្នកអាន ទោះវាជាចំណេះដឹង ឬជាការកម្សាន្តក៏ដោយ។ ការជ្រើសរើសមាតិកាព័ត៌មានដ៏មានអត្ថន័យគឺសំខាន់ណាស់ ព្រោះវាអាចមានកំណត់ហេតុបណ្ដាញជាច្រើនដែលមានព័ត៌មានដូចគ្នា ហើយអ្នកត្រូវតែផ្ដល់គុណតម្លៃគ្រប់គ្រាន់សម្រាប់ការផ្សាយជាសាធារណៈរបស់អ្នកដល់អ្នកអានឱ្យប្រសើរជាងកំណត់ហេតុបណ្ដាញរបស់អ្នកដទៃ។ ប្រធានបទកំណត់ហេតុបណ្ដាញដ៏ពេញនិយម គឺអប់រំសុខភាព និងលំហាត់ប្រាណ ការធ្វើឱ្យប្រសើរខ្លួនឯង ចំណីអាហារ នយោបាយ គ្រួសារ និងការកម្សាន្ត។

នៅពេលយើងសម្រេចចិត្តចំពោះប្រធានបទកំណត់ហេតុបណ្ដាញហើយ សូមបង្កើតបញ្ជីប្រកាសដែលអាចត្រូវគ្នាជាមួយប្រធានបទរបស់អ្នក និងអ្វីដែលអ្នកត្រូវសរសេរ ស្របតាមចំណេះដឹងរបស់អ្នក និងព័ត៌មានដែលអ្នកអាចរកបាន។ ប្រសិនបើអ្នកលំបាកក្នុងការរិះរកគំនិត អ្នកប្រហែលអាចពិចារណា ឬកែតម្រូវប្រធានបទរបស់អ្នក។ អ្នកក៏អាចគិតសង្ខេបយ៉ាងខ្លីអំពីប្រធានបទរបស់អ្នកជាទិដ្ឋភាពជាក់ស្ដែង ឬជាប្រធានបទរងនៃប្រធានបទដើម ដើម្បីឱ្យមានភាពលេចធ្លោពីកំណត់ហេតុបណ្ដាញរបស់គេផ្សេង។

ក្នុងនាមជាអ្នកបង្កើតមាតិកាព័ត៌មាន អ្នកទទួលខុសត្រូវសម្រាប់ភាពត្រឹមត្រូវនៃមាតិកា



កំណត់ហេតុបណ្ដាញដ៏ល្បីល្បាញនៅកម្ពុជាអំពីការអប់រំ នយោបាយ ការរស់នៅ សេរីភាពសារព័ត៌មាន វប្បធម៌ និងរឿងរ៉ាវសង្គមនៅក្នុងប្រទេសកម្ពុជា។

ព័ត៌មានដែលអ្នកផ្សព្វផ្សាយ។ ប្រសិនបើអ្នកមានអារម្មណ៍ថាអ្នកខ្វះខាតចំណេះដឹងដែលទាក់ទងនឹងប្រធានបទ សូមកុំបោះបង់! ព្យាយាមទទួលបានចំណេះដឹងបន្ថែមដោយការស្រាវជ្រាវរកមើលពីប្រភពចំណេះដឹងផ្សេងៗ អានហើយអានទៀត និងបន្ថែមទៅអ្វីដែលអ្នកមានបទពិសោធន៍កន្លងមក។

ជំហានសំខាន់ផ្សេងមួយទៀតនៅក្នុងការធ្វើផែនការកំណត់ហេតុបណ្ដាញរបស់អ្នក គឺរកមើលពាក្យគន្លឹះ ដែលជាពាក្យ ឬឃ្លាជាក់លាក់ពិពណ៌នាអំពីប្រធានបទ និងខ្លឹមសារព័ត៌មានរបស់វា។ ពាក្យគន្លឹះទាំងនេះ គឺជាពាក្យដែលអ្នកប្រើអ៊ីនធឺណិតប្រើនៅពេលស្វែងរកព័ត៌មានអំពីប្រធានបទរបស់អ្នក។ ពាក្យគន្លឹះមានសារៈសំខាន់ធ្វើឱ្យអ្នកផ្ដោតនៅពេលអ្នកសរសេរ និងរៀបចំរចនាសម្ព័ន្ធប្រកាសកំណត់ហេតុបណ្ដាញរបស់អ្នក។ ដើម្បីរកពាក្យគន្លឹះសម្រាប់កំណត់ហេតុបណ្ដាញផ្ទាល់ខ្លួនរបស់អ្នក អ្នកអាចសួរមិត្តភ័ក្តិរបស់អ្នកឱ្យផ្ដល់ពាក្យ ពីប្រាំទៅដប់ពាក្យដែលពួកគេប្រើក្នុងការស្វែងរកកំណត់ហេតុបណ្ដាញរបស់អ្នក បន្ទាប់មកអ្នកតម្រៀបវាអាស្រ័យតាមភាពសំខាន់របស់វាដើម្បីរៀបចំរចនាសម្ព័ន្ធកំណត់ហេតុបណ្ដាញរបស់អ្នក។ មិត្តភ័ក្តិរបស់ចរណៃស្នើពាក្យមួយចំនួនដូចជា ការងារ កម្ពុជាសុបិនមុខរបរធ្វើការ ព័ត៌មាន ទំនាក់ទំនងបច្ចេកវិទ្យា និង ICT ជាពាក្យគន្លឹះ។ ពាក្យគន្លឹះក៏អាចជួយរកចំណងជើងសមរម្យដែលនឹងទាក់ទាញអ្នកទស្សនាដ៏មានសក្ដានុពលទៅកាន់កំណត់ហេតុបណ្ដាញ។ ចំណងជើងដែលល្អត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម។

- វារួមមានពាក្យគន្លឹះខ្លះៗ និងវាសង្ខេប និងងាយស្រួលយល់។
- វាស្របតាមប្រធានបទនៃកំណត់ហេតុបណ្ដាញ សូម្បីតែនៅមុនទំព័រកំណត់ហេតុបណ្ដាញដំបូងដែលលេចឡើងនៅលើអេក្រង់របស់អ្នក វាជំរុញចិត្តឱ្យអ្នកនោះអាចចាប់អារម្មណ៍ក្នុងការអានកំណត់ហេតុបណ្ដាញ។
- វាមិនមែនជាចំណងជើងដែលបានប្រើរួចហើយដោយអ្នកប្រើផ្សេង ឬជាសញ្ញាពាណិជ្ជកម្មដែលបានចុះបញ្ជីរួចហើយដោយអ្នកណាម្នាក់ផ្សេងនោះទេ។

មួយសប្ដាហ៍បន្ទាប់ពី ការលើកឡើងគំនិតជាច្រើន ចរណៃសម្រេចចិត្តជ្រើសរើសចំណងជើងរបស់នាងថា "ជម្រើសការងារនៅកម្ពុជា។" នាងបានជ្រើសយក WordPress ជាសេវាកម្មសម្រាប់បង្ហោះកំណត់ហេតុបណ្ដាញរបស់នាង និងចុះឈ្មោះនៅ www.wordpress.com ។ ឥឡូវ ចរណៃជាម្ចាស់អាសយដ្ឋានកំណត់ហេតុបណ្ដាញមួយ និងទោះបីវាមិនទាន់មានអ្វីក៏ដោយ នាងមានការរំភើបរីករាយយ៉ាងខ្លាំង។

## ជំហាន ៣៖ ជ្រើសកាលវិភាគពេលវេលារបស់អ្នក និងជ្រើសភាពឯកជន

តាមរយៈដានី ចរណៃដឹងថាវាងាយស្រួលធ្វើឱ្យលើកទឹកចិត្តអំពីការបង្កើតកំណត់ហេតុបណ្ដាញ និងប្រកាសនៅពេលចាប់ផ្ដើម ប៉ុន្តែក៏មានអ្នកប្រើកំណត់ហេតុបណ្ដាញជាច្រើនជួបបញ្ហាប្រឈមក្នុងការប្រកាសកំណត់ហេតុបណ្ដាញផងដែរ។ ឥឡូវ ចរណៃត្រូវការពេលពិចារណាថាតើនាងចង់ប្ដេជ្ញាចំពោះកំណត់ហេតុបណ្ដាញរបស់នាងដែរឬទេ។

នៅពេលអ្នកធ្វើផែនការកំណត់ហេតុបណ្ដាញរបស់អ្នក អ្នកត្រូវតែគិតអំពីការតាំងចិត្តផ្សេងៗរបស់អ្នកទាំងអស់ដែលរួមមាន៖ សាលារៀន គ្រួសារមិត្តភ័ក្តិជម្រើស និងចំណូលចិត្ត មុនសម្រេចចិត្តអំពីពេលវេលាដែលអ្នកនឹងគិតចំពោះការបង្កើតកំណត់ហេតុបណ្ដាញ។ ការបង្កើតកាលវិភាគប្រកាសផ្សាយ អាចជួយអ្នករកពេលវេលាសម្រាប់កំណត់ហេតុបណ្ដាញរបស់អ្នក។ សកម្មភាពឌីជីថលគឺជារឿងស្មុគ្រស្មាញ និងវាសំខាន់ត្រូវរកកាលវិភាគដែលធ្វើឱ្យកំណត់ហេតុបណ្ដាញជាកន្លែងមួយកម្សាន្ត។ ព្រោះចរណៃដឹងថាកំណត់ហេតុបណ្ដាញដែលមានការចូលមើលច្រើនញឹកញាប់

*អ្នកបង្កើតកំណត់ហេតុបណ្ដាញគួរតែគិតពិចារណាថាព័ត៌មានផ្ទាល់ខ្លួនកម្រិតណាដែលពួកគេគួរចែករំលែក និងថាតើពួកគេចង់ប្រើឈ្មោះពិត ឬឈ្មោះហៅក្រៅ។*

បំផុតត្រូវចំណាយពេលដ៏លំបាក និងអាចមានផលជាអវិជ្ជមានចំពោះគុណភាពនៃព័ត៌មាន នាងសម្រេចចិត្តប្រកាសផ្សាយព័ត៌មានពីរដងក្នុងមួយខែ។

ដោយសារការផ្សាយតាមរយៈកំណត់ហេតុបណ្ដាញគឺជាការផ្សាយជាសាធារណៈ នោះមនុស្សដែលអ្នកមិនស្គាល់ក៏នឹងឃើញប្រកាសរបស់អ្នកដែរ ហើយអ្នកគួរតែប្រុងប្រយ័ត្នអំពីការចែករំលែកព័ត៌មានលម្អិតផ្ទាល់ខ្លួននៅលើអ៊ីនធឺណិត។

# ៤.២. ការបង្កើតកំណត់ហេតុបណ្ដាញ

ការសរសេរកំណត់ហេតុបណ្ដាញ គឺខុសពីការសរសេរកំណត់ហេតុប្រចាំថ្ងៃ ឬសរសេរតែងសេចក្ដីនៅសាលារៀន ពីព្រោះកំណត់ហេតុបណ្ដាញអាចប្រើទ្រង់ទ្រាយព័ត៌មានដូចជារូបភាព ឬវីដេអូ មិនមែនគ្រាន់តែជាអត្ថបទប៉ុណ្ណោះទេ។ កំណត់ហេតុបណ្ដាញត្រូវមានការទាក់ទាញ និងរក្សាចំណាប់អារម្មណ៍របស់អ្នកអានដោយបង្កើតមាតិកាព័ត៌មានដែលគួរឱ្យចាប់អារម្មណ៍ និងមានអត្ថន័យពេញលេញ។ អ្នកបង្កើតកំណត់ហេតុបណ្ដាញគួរបង្កើតព័ត៌មានដែលមានលក្ខណៈជាការប្រាប់រឿងរ៉ាវអ្វីមួយ ដែលអាចផ្សារភ្ជាប់អារម្មណ៍អ្នកមើលឆ្លុះបញ្ចាំងពីមាតិកាដែលនឹងត្រូវបង្ហាញ។ អ្វីក៏ដោយដែលអ្នកសរសេរ តែងតែរក្សាទុកនូវខ្លឹមសារព័ត៌មាន និងគោលបំណងរបស់អ្នកក្នុងចិត្តជានិច្ច។

## ជំហានទី ១៖ ការសរសេរ

ការមានកំណត់ហេតុបណ្ដាញដែលសរសេរបានល្អ អានងាយយល់មិនទាមទារឱ្យគ្រប់ប្រកាសទាំងអស់ត្រូវតែស្នាដៃឯកនោះទេ ប៉ុន្តែវាទាមទារថាអ្នកត្រូវគិតមុនពេលប្រកាសផ្សាយ។ គន្លឹះ គឺដើម្បីបង្កើតអ្វីដែលប្លែកដើម្បីទាក់ទាញចំណាប់អារម្មណ៍អ្នកអាន។ អ្នកអានចូលចិត្តមើលការណែនាំតាមរយៈប្រធានបទ។ ដោយព្យាយាមនាំពួកគេឱ្យយល់មួយបន្ទាត់ម្ដង។ ប្រសិនបើគោលបំណងរបស់អ្នក គឺដើម្បីចែកចាយព្រឹត្តិការណ៍ពិត និងព័ត៌មាន នោះប្រកាសកំណត់ហេតុបណ្ដាញរបស់អ្នកគួរចាប់ផ្ដើមដោយផ្ដល់នូវចម្លើយចំពោះសំណួរសំខាន់បំផុតទាំងនេះ៖ អ្នកណា ? អ្វី ? កន្លែងណា ? ពេលណា ? បន្ទាប់មក អ្នកអាចសរសេរព័ត៌មានលម្អិតបន្ថែមទៀត រៀបរាប់អំពីអ្វីមួយបានកើតឡើងដោយរបៀបណា និងមូលហេតុអ្វី និងផលលំបាកដែលអាចកើតមាន។

ប្រសិនបើគោលបំណងរបស់អ្នក គឺដើម្បីចែករំលែកគំនិត ឬរៀបរាប់អំពីបទពិសោធន៍ក្នុងលក្ខណៈធ្វើឱ្យចាប់អារម្មណ៍ នោះអ្នកអាចប្រើវិធីសាស្ត្រប្រាប់រឿងរ៉ាវដែលបង្ហាញភស្តុតាងខ្លះៗ ទោះបីជាអ្នកមិនមែនជាអ្នកជំនាញរៀបរាប់រឿងក៏ដោយ។ សូមរៀបចំរចនាសម្ព័ន្ធប្រកាសរបស់អ្នកជាបីផ្នែកដូចខាងក្រោម៖

១. សេចក្ដីផ្ដើម៖ ពិពណ៌នាគំនិតរបស់អ្នក ឬព្រឹត្តិការណ៍ណាមួយដែលកើតឡើងជាហេតុធ្វើឱ្យអ្នកសរសេរប្រកាសកំណត់ហេតុបណ្ដាញ ហើយបន្ទាប់មកផ្ដល់ព័ត៌មានដើមខ្លះៗ។

២. ការទាក់ទាញចំណាប់អារម្មណ៍៖ ផ្ដល់ព័ត៌មានបន្ថែមដោយផ្ដល់នូវភាពពិតបន្ថែម សម្រង់សម្ដីតំណ ឬទស្សនៈ និងជ្រើសអ្វីទាំងឡាយដែលបង្កើនចំណាប់អារម្មណ៍អ្នកអាន។ ជំរុញទឹកចិត្តអ្នកអានទៅត្រង់ចំណុចដែលពួកគេចាប់អារម្មណ៍អំពីប្រធានបទរបស់អ្នក ហើយពួកគេចាប់ផ្ដើមគិតអំពីដំណោះស្រាយ និងការបញ្ចប់ដែលអាចកើតមានឡើង។

៣. សេចក្ដីសន្និដ្ឋាន៖ ជំរុញអ្នកអានឱ្យនៅជាមួយអ្នកនៅពេលអ្នកបង្ហាញគំនិតចុងក្រោយរបស់

អ្នក។ អ្នកអាចជំរុញពួកគេឱ្យចាប់ផ្តើមសកម្មភាពភ្លាមៗ ដូចជា "សរសេរឥឡូវ" ឬ "ចុចទីនេះ"។ អ្នកក៏អាចបញ្ចប់ជាមួយសំណួរដូចជា "តើអ្វីជាគំនិតផ្ទាល់ខ្លួនរបស់អ្នក? សូមប្រាប់យើងឱ្យដឹងនៅក្នុងមតិយោបល់។

## ជំហានទី ២៖ ធ្វើឱ្យប្រសើរនូវអ្វីដែលគួរអាន

កំណត់ហេតុបណ្តាញជានិច្ច ដូចជាអ្វីដែលបានរៀបរាប់ខាងក្រោមនេះ៖

- ចំណងជើង៖ ដើមរឿងដែលល្អ (ចំណងជើងប្រកាស) នឹងដាក់ ទាក់ទាញអ្នកទស្សនាឱ្យអានជានិច្ច។ ធ្វើឱ្យចំណងជើងរឿងមានឥទ្ធិពល និងប្រើពាក្យគន្លឹះរបស់អ្នកខ្លះៗ។ ឧទាហរណ៍៖ "ព័ត៌មានអំពីការងារ" មិនមែនមានឥទ្ធិពលដូច "សូមជ្រាប! ការងារដ៏ប្រសើរកំពុងរង់ចាំអ្នក!"
- ប្រកាសខ្លី៖ ធ្វើឱ្យប្រកាសខ្លីសមរម្យក្រោម ១០០០ ពាក្យ។ ដើម្បីកាត់បន្ថយប្រវែងប្រកាស អ្នកអាចបំបែកវាជាប្រកាសច្រើន និងកថាខណ្ឌខ្លីៗ។ នៅក្នុងពិភពឌីជីថល មនុស្សច្រើនមើលរហ័សលើវេបសាយ ជាពិសេសនៅពេលពួកគេកំពុងអាននៅលើឧបករណ៍ចល័តដូចជាទូរសព្ទដៃ ឬកុំព្យូទ័របន្ទះជាដើម។
- ការបំបែកអត្ថបទ៖ ប្រើមធ្យោបាយផ្សេងៗដើម្បីរៀបចំរចនាសម្ព័ន្ធអត្ថបទរបស់អ្នក។ ឧទាហរណ៍ អ្នកអាចប្រើបញ្ជីចំណុច ឬលេខរៀង។ មធ្យោបាយដ៏ប្រសើរផ្សេងមួយទៀត គឺទាញចំណាប់អារម្មណ៍ដោយបន្ថែមរូបភាព ដូចជារូបគំនូរ ឬរូបថតជាដើម។
- សូរសព្ទ៖ ជ្រើសសូរសព្ទ ឬពាក្យពេចន៍ក្នុងការនិយាយដែលអ្នកចង់ប្រើជាមួយអ្នកទស្សនាឱ្យបានសមរម្យ ទាំងវាជាផ្លូវការ អព្យាក្រឹត ដែលកំប្លែងល្អសើច ឬសិល្បៈនៃការសន្ទនា។ បែបបទអ្វីក៏ដោយដែលអ្នកជ្រើសរើស សូមប្រាកដថាវាស្របទៅតាមកំណត់ហេតុបណ្តាញ។
- ប្រាប់ឱ្យធ្វើសកម្មភាព៖ ការប្រាប់ឱ្យធ្វើសកម្មភាព គឺជាពាក្យណែនាំដែលអ្នកផ្តល់ឱ្យអ្នកអានដោយបញ្ជាក់យ៉ាងច្បាស់អំពីអ្វីដែលអ្នកចង់ឱ្យអ្នកអានធ្វើតាមបន្ទាប់ ដូចជាការស្នើឱ្យអ្នកអានផ្តល់មតិយោបល់ ចែករំលែកប្រកាសនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ឬចុចវេបសាយផ្សេងទៀត។ ការណែនាំអាចកើតមាននៅចំណុចណាមួយនៅក្នុងប្រកាសនៃកំណត់ហេតុបណ្តាញ ប៉ុន្តែជាធម្មតាវាមាននៅផ្នែកខាងចុងនៃប្រកាស។
- អំណានកែលម្អ៖ កំណត់ហេតុបណ្តាញដែលប្រសើរមានសំណេរ ដែលមានភាពកម្សាន្តសប្បាយនិងរំលេចអ្វីដែលគួរមើល។ នៅពេលអ្នកបានបញ្ចប់ការតែងប្រកាសកំណត់ហេតុបណ្តាញ សូមសម្រាកបន្តិច រួចបន្ទាប់មកត្រឡប់ទៅមើលវាម្តងទៀតដើម្បីកែលម្អវាពេលក្រោយ និងកែកំហុសទាំងឡាយណា។ សូមប្រាកដថា គួរតែប្រើប្រាស់កម្មវិធីពិនិត្យអក្ខរាវិរុទ្ធនៅក្នុងកំណត់ហេតុបណ្តាញរបស់អ្នក។ សំណេរដែលមិនល្អមានកំហុសអក្ខរាវិរុទ្ធ និងមិនច្បាស់លាស់អាចធ្វើឱ្យអ្នកអានបាត់ទំនុកទុកចិត្ត និងធ្វើឱ្យស្មារតីអ្នកអានមិនយល់ពីអ្វីដែលអ្នកត្រូវនិយាយ។




លក្ខណៈកម្មវិធីពិនិត្យអក្ខរាវិរុទ្ធក្នុងកម្មវិធី WordPress

## ជំហានទី ៣៖ ការបញ្ចូលរូបភាព វីដេអូ ឬសំឡេង

កំណត់ហេតុបណ្ដាញដែលមានទ្រង់ទ្រាយព័ត៌មានផ្សេងៗដូចជា រូបភាព វីដេអូ ឬ សំឡេង គឺមានភាពបង្ហាញចេញច្រើនជាងកំណត់ហេតុបណ្ដាញដែលមានតែអត្ថបទសម្រាប់អ្នកអាន។ រូបភាពដែលមើលឃើញ និងសំឡេងអាចធ្វើឱ្យកំណត់ហេតុបណ្ដាញរបស់អ្នករស់រវើក ពង្រឹងខ្លឹមសារព័ត៌មានរបស់អ្នកកាន់តែប្រសើរ ឬផ្ដល់ព័ត៌មាន និងទស្សនៈបន្ថែម ប៉ុន្តែអ្នកមិនគួរប្រើវាគ្រប់ករណីនោះទេ។ ត្រូវប្រាកដថារូបភាព វីដេអូ ឬសំឡេងច្បាស់លាស់ដែលអ្នកចង់ផ្សព្វផ្សាយរក្សាខ្លឹមសារព័ត៌មានសមរម្យ ហើយនេះជាគុណភាពល្អប្រសើរមួយ។




ការបន្ថែមរូបភាពនៅក្នុងកម្មវិធី WordPress.

រូបភាព វីដេអូ និងសំឡេងអាចបង្កើតឡើងដោយអ្នក ឬដោយអ្នកនិពន្ធផ្សេងទៀត។ ការប្រើទ្រង់ទ្រាយផ្ទាល់ខ្លួនរបស់អ្នកមានអត្ថប្រយោជន៍ខ្ពស់ ព្រោះអ្នកធ្វើឱ្យបំណិននៃការបង្ហាញចេញខ្លួនអ្នកតាមរយៈរូបភាពដែលមើលឃើញ ឬជាសំឡេងបានប្រសើរឡើង ហើយអ្នកជាមនុស្សម្នាក់ដែលកំណត់អត្ថន័យ និងកាន់កាប់ការរក្សាសិទ្ធិ។ ការបង្កើតទ្រង់ទ្រាយដោយខ្លួនឯងនឹងចំណាយពេលខិតខំប្រឹងប្រែងជាងការប្រើអ្វីដែលអ្នកនិពន្ធផ្សេងមានស្រាប់។

ប្រសិនបើអ្នកសម្រេចចិត្តប្រើរូបភាព វីដេអូ ឬសំឡេងពីអ្នកនិពន្ធផ្សេងៗ អ្នកគួរជ្រើសរើសតែការងារណាដែលអ្នកបង្កើត ឬម្ចាស់គេផ្ដល់សិទ្ធិអនុញ្ញាតឱ្យអ្នកប្រើ។ ជាធម្មតា ការផ្ដល់សិទ្ធិអនុញ្ញាតត្រូវបានផ្ដល់ឱ្យតាមរយៈការប្រកាសនៅលើវេបសាយរបស់អ្នកនិពន្ធដែលបញ្ជាក់ថារូបភាព ឬវីដេអូនោះអាចប្រើបាន ប្រសិនបើបំពេញតាមលក្ខខណ្ឌអាជ្ញាប័ណ្ណស្តង់ដារដែលបានកំណត់។ អាជ្ញាប័ណ្ណដែលល្បីល្បាញទាំងនេះត្រូវបានគេស្គាល់ថា Creative Commons copyright license (CC)។ ការងាររបស់តន្ត្រីករ អ្នកថតរូប អ្នកគូររូប និងអ្នកផលិតភាពយន្តដែលផ្ដល់សម្ភាររបស់ពួកគេក្រោមអាជ្ញាប័ណ្ណ CC គឺត្រូវបានប្រើនៅក្នុងកំណត់ហេតុបណ្ដាញក្រោមលក្ខខណ្ឌច្បាស់លាស់មួយ ដូចជាតែងតែដាក់ឈ្មោះអ្នកនិពន្ធជានិច្ច។ អ្នកអាចមើលប្រព័ន្ធកម្មវិធីជាច្រើនដែលផ្ដល់រូបភាពជាមួយអាជ្ញាប័ណ្ណ Creative Commons ដោយធ្វើការស្វែងរកតាមអ៊ីនធឺណិត។ ចរណៃបានសម្រេចចិត្តស្វែងរករូបភាពដើម្បីបញ្ជាក់នៅក្នុងប្រកាសកំណត់ហេតុបណ្ដាញរបស់នាង ហើយនាងបានរកឃើញរូបភាពដ៏ស្អាតដែលមានអាជ្ញាប័ណ្ណ CC នៅលើប្រព័ន្ធកម្មវិធីលើអ៊ីនធឺណិតឈ្មោះថា Flickr ។ ដូចចរណៃដែរ អ្នកក៏អាចស្វែងរករូបភាពដែលមានអាជ្ញាប័ណ្ណ CC ដោយបញ្ជាក់នៅក្នុងការស្វែងរករបស់អ្នកដោយប្រើម៉ាស៊ីនស្វែងរកដូចជា Google ឬ Yahoo ដោយប្រើការកំណត់ស្វែងរកកម្រិតខ្ពស់។

ខាងក្រោមនេះជាឧទាហរណ៍នៃអាជ្ញាប័ណ្ណ Creative Common ៖

### អាជ្ញាប័ណ្ណមិនរកប្រាក់ ឬមិនមែនជំនួញ

អាជ្ញាប័ណ្ណនេះអាចឱ្យអ្នកផ្សេងកែសម្រួល ផ្សព្វផ្សាយ និងបង្កើតឡើងលើការងាររបស់អ្នកដោយមិនធ្វើអាជីវកម្ម តែត្រូវផ្តល់កិត្តិយសឱ្យអ្នកបង្កើត។ ការងារថ្មីរបស់ពួកគេក៏ត្រូវតែមិនមែនដើម្បីជំនួញ។

# ៤.៣. ការផ្សព្វផ្សាយ និងបណ្ដាញ

អ្នកបង្កើតកំណត់ហេតុបណ្ដាញ អ្នកត្រូវរកដំណោះស្រាយដែលធ្វើឱ្យអ្នកទស្សនាគោលដៅរបស់អ្នកអាចស្គាល់និងរកកំណត់ហេតុបណ្ដាញរបស់អ្នកឃើញក្នុងចំណោមកំណត់ហេតុបណ្ដាញផ្សេងៗទាំងអស់នៅលើអ៊ីនធឺណិត។ អ្នកត្រូវធ្វើយ៉ាងណាដើម្បីផ្សព្វផ្សាយវានៅលើអ៊ីនធឺណិតនិងធ្វើឱ្យវាលេចឡើងនៅលើទំព័រលទ្ធផលស្វែងរកនៅពេលអ្នកប្រើស្វែងរកប្រធានបទរបស់អ្នក។ ដើម្បីឱ្យវាងាយស្រួលរក និងកំណត់ហេតុបណ្ដាញរបស់អ្នកមានគុណភាពខ្ពស់ គឺមានគន្លឹះពីរដើម្បីធ្វើឱ្យកំណត់ហេតុបណ្ដាញរបស់អ្នកមាននៅជុំវិញបណ្ដាញអ្នកប្រើអ៊ីនធឺណិតដែលមានចំណាប់អារម្មណ៍ប្រហាក់ប្រហែលគ្នា។ ដើម្បីរកមនុស្សដែលមានចំណាប់អារម្មណ៍ប្រហាក់ប្រហែល សូមអានកំណត់ហេតុបណ្ដាញរបស់អ្នក




ឧទាហរណ៍កំណត់ហេតុបណ្ដាញដែលមានតំណកំណត់ហេតុបណ្ដាញផ្សេងៗ នៅចំហៀង៖

ផ្សេង និងតាមដានតំណរបស់ពួកគេអានប្រកាសនៅក្នុងបណ្ដាញសង្គម និងក្នុងពេលដ៏ខ្លី អ្នកនឹងរកឃើញអ្វីដែលទាក់ទង និងខ្លឹមសារព័ត៌មានដែលចាប់អារម្មណ៍បានបង្កើតដោយអ្នកផ្សេងៗទៀត។ ទាក់ទងនៅក្នុងការពិភាក្សាជាមួយអ្នកបង្កើតកំណត់ហេតុបណ្ដាញផ្សេងៗដើម្បីធ្វើឱ្យពួកគេចាប់អារម្មណ៍អំពីអ្វីដែលអ្នកចង់និយាយ។ ប្រសិនបើអ្នកសរសេរប្រកាសកំណត់ហេតុបណ្ដាញរបស់អ្នកបង្កើតកំណត់ហេតុបណ្ដាញណាមួយ នោះអ្នកផ្សព្វផ្សាយកំណត់ហេតុបណ្ដាញរបស់ពួកគេបានដោយនិយាយរៀបរាប់វានៅក្នុងប្រកាសកំណត់ហេតុបណ្ដាញរបស់អ្នក ឬតាមរយៈការកំណត់បញ្ជីកំណត់ហេតុបណ្ដាញផ្សេងៗនៅក្នុងកំណត់ហេតុបណ្ដាញរបស់អ្នក។ បញ្ជីកំណត់ហេតុបណ្ដាញ គឺជាបញ្ជីនៃតំណទៅកាន់កំណត់ហេតុបណ្ដាញផ្សេងដែលអ្នកចង់ណែនាំទៅអ្នកអាន។ នៅពេលអ្នកភ្ជាប់ទៅកំណត់ហេតុបណ្ដាញរបស់អ្នកណាម្នាក់ ពួកគេអាចជ្រើសរើសភ្ជាប់មកកាន់កំណត់ហេតុបណ្ដាញរបស់អ្នកវិញ។ អ្នកសរសេរកំណត់ហេតុបណ្ដាញដែលស្គាល់អ្នកនឹងចែករំលែកចំណាប់អារម្មណ៍របស់អ្នកដើម្បីឱ្យគេអានប្រកាសកំណត់ហេតុបណ្ដាញរបស់អ្នក ហើយក៏អាចណែនាំវានៅដល់អ្នកផ្សេងៗផងដែរ។

ការចែករំលែកខ្លឹមសារព័ត៌មានដែលមានអត្ថន័យការផ្សព្វផ្សាយប្រកាសដែលចាប់អារម្មណ៍ ឬដាក់តំណដែលចាប់អារម្មណ៍នៅលើកំណត់ហេតុបណ្ដាញរបស់អ្នកនឹងធ្វើឱ្យអ្នកជាផ្នែកនៃសហគមន៍ឌីជីថលមានសកម្មភាពយ៉ាងសកម្ម។ ការក្លាយជាផ្នែកនៃបណ្ដាញធ្វើឱ្យអ្នកមានគំនិតចង់ចូលរួមក្នុងសង្គមតាមរយៈការផ្លាស់ប្ដូរទស្សនៈយោបល់ និងគំនិតជាមួយអ្នកផ្សេងៗ។ អ្នកក៏អាចប្រើឧបករណ៍ឌីជីថលផ្សេងៗដើម្បីពង្រីកបណ្ដាញរបស់អ្នក។ ឧទាហរណ៍៖ អ្នកអាចប្រកាសផ្សាយតំណទៅកំណត់ហេតុបណ្ដាញរបស់អ្នកនៅលើហ្វេកប៊ុកដើម្បីបង្កើតទំនាក់ទំនងជាមួយអ្នកអាន និងលើកទឹកចិត្តពួកគេដើម្បីបានអានប្រកាសកំណត់ហេតុបណ្ដាញថ្មីៗរបស់អ្នក។ ការសរសេរកំណត់ហេតុបណ្ដាញរបស់អ្នកសម្រាប់អ្នកទស្សនាដែលរំភើបរីករាយ និងបានផ្សារភ្ជាប់នឹងជាភាពសប្បាយរីករាយ ហើយក៏ផ្ដល់ឱ្យអ្នកក្លាយជាផ្នែកដ៏សកម្មនៃសង្គមបច្ចុប្បន្នជាមួយអ្វីដែលមានន័យក្នុងការនិយាយ។ ប៉ុន្មានខែក្រោយមកចរណៃបានស្ទាត់ជំនាញនឹងការចែករំលែកប្រកាសកំណត់ហេតុបណ្ដាញជាទៀងទាត់អំពីក្ដីសុបិនអនាគត និងជម្រើសការងារនៅក្នុងប្រទេសកម្ពុជា។ នាងបានបន្តបង្កើនអ្នកទស្សនារបស់នាងលើសពីមិត្តភក្ដិនៅសាលារៀនរបស់អ្នកដោយចែករំលែកប្រកាសកំណត់ហេតុបណ្ដាញរបស់នាងនៅលើហ្វេកប៊ុក ទទួលបានការចូលចិត្តយ៉ាងច្រើន។ នាងទទួលបានមតិឆ្លើយតបជាវិជ្ជមានយ៉ាងច្រើនពីយុវជននៅទូទាំងប្រទេសកម្ពុជា ក៏ដូចជាអ្នកមកពីកំណត់ហេតុបណ្ដាញផ្សេងៗ។ នាងពិតជាមានអារម្មណ៍ថានាងក្លាយជាសមាជិកសកម្មមួយនៅក្នុងសង្គមទាំងក្នុងជីវិតពិត និងឌីជីថល។

## មេរៀនសង្ខេប

នៅក្នុងយុគសម័យបច្ចេកវិទ្យាអ៊ីនធឺណិតបច្ចុប្បន្ន មនុស្សគ្រប់រូបអាចចូលរួមយ៉ាងសកម្មនៅលើអ៊ីនធឺណិតដោយប្រើប្រព័ន្ធកម្មវិធីឌីជីថល និងសេវាកម្មផ្សេងៗគ្នាមួយ ឬច្រើន សេវាកម្មកំណត់ហេតុបណ្ដាញ ឬមីក្រូកំណត់ហេតុបណ្ដាញ វិឌីភីឌា វេទិកាអ៊ីនធឺណិត ឬវេបសាយសម្រាប់ចែករំលែករូបភាព ឬវីដេអូ។ ឱកាសថ្មីទាំងនេះ អាចឱ្យអ្នកប្រើបញ្ចេញនូវគំនិតចំណាប់អារម្មណ៍ បទពិសោធន៍ និងទស្សនៈរបស់ពួកគេជាសាធារណៈ និងដើម្បីចែកចាយដល់សង្គម។ ការសរសេរកំណត់ហេតុបណ្ដាញ គឺជាមធ្យោបាយឌីជីថលដ៏ប្រសើរមួយដើម្បីសម្ដែងនូវទស្សនៈ និងផ្ដល់នូវចំណេះដឹងដល់អ្នកផ្សេងៗ។

កំណត់ហេតុបណ្ដាញដែលល្អគួរមានអត្ថន័យពេញលេញដល់អ្នកទស្សនា និងត្រូវតែមានការគ្រោងទុកដោយប្រុងប្រយ័ត្ន ផលិត និងផ្សព្វផ្សាយយ៉ាងសកម្ម។ អ្នកបង្កើតកំណត់ហេតុបណ្ដាញដ៏មានសក្ដានុពលគួរតែគិតអំពីគោលបំណង និងប្រធានបទកំណត់ហេតុបណ្ដាញ ហើយបន្ទាប់មកជ្រើសពាក្យគន្លឹះ និងចំណងជើងដ៏ត្រឹមត្រូវ។ ពួកគេនឹងត្រូវរៀបចំកាលវិភាគថាពេលណាគួរប្រកាសផ្សាយកំណត់ហេតុបណ្ដាញ ហើយនឹងសម្រេចចិត្តអំពីព័ត៌មានផ្ទាល់ខ្លួនអ្វីដែលត្រូវផ្សព្វផ្សាយ។ មានវិធីជាច្រើនដែលអាចប្រើដើម្បីទាក់ទាញការចាប់អារម្មណ៍អ្នកទស្សនា។ អ្នកបង្កើតមាតិកាព័ត៌មានអាចអនុវត្តបច្ចេកទេសដោយការប្រាប់រឿងរ៉ាវ ជ្រើសរើសចំណងជើងដែលល្អប្រសើរ ប្រកាសផ្សាយជាសារខ្លី បំបែកអត្ថបទឱ្យខ្លី និងមានខ្លឹមសារ ប្រើពាក្យពេចន៍នៃការសន្ទនាបានត្រឹមត្រូវប្រាប់ឱ្យធ្វើសកម្មភាព ឬបង្កប់ទម្រង់ព័ត៌មានផ្សេងៗដូចជារូបភាពជាដើម។ អ្នកកំណត់ហេតុបណ្ដាញអាចប្រើរូបភាព វីដេអូ ឬសំឡេងដែលបង្កើតខ្លួនឯង ឬពួកគេអាចបន្ថែមរូបភាពដែលបានបង្កើតដោយអ្នកផ្សេងដែលពួកគេទទួលបានសិទ្ធិអនុញ្ញាតប្រើប្រាស់វា។

# លំហាត់

## លំហាត់ ៣

អ្នកនឹងត្រូវវិភាគអំពីប្រកាសរបស់កំណត់ហេតុបណ្ដាញសម្រាប់លំហាត់នេះ។

សូមអានប្រកាសកំណត់ហេតុបណ្ដាញដូចខាងក្រោមនេះ រួចធ្វើការពិភាក្សាសំណួរនៅចុងបញ្ចប់ និងប្រកាសចម្លើយទៅក្នុងថតក្រុមរបស់អ្នក។ ប្រកាសកំណត់ហេតុបណ្ដាញនេះ គឺបានសរសេរឡើងដោយចរណៃ ហើយវាជាអត្ថបទទីបួនហើយដែលនាងបានសរសេរ។ វាមានប្រវែងប្រហែល ៣៤៨ ពាក្យ។

### របៀបបង្កើតបណ្ដាញតាមរយៈការសម្ភាសន៍



សប្ដាហ៍នេះ យើងនឹងជួបមនុស្ស និងកសាងបំណិនក្នុងការភ្ជាប់ទំនាក់ទំនងរបស់អ្នក។ អ្នកដឹងរួចហើយថាខ្ញុំបានសម្ភាសន៍អ្នកជំនាញ ICT ជាច្រើននាក់នៅក្នុងឆ្នាំនេះ ការជួបប្រជុំរបស់ខ្ញុំទាំងអស់បានកើតឡើងតាមរយៈបណ្ដាញ។ លទ្ធផលនៃការកសាងចំណេះដឹងរបស់ខ្ញុំ ខ្ញុំមានអារម្មណ៍ជឿជាក់អំពីការជ្រើសយកផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រជាប្រធានបទសិក្សារបស់ខ្ញុំនៅឯសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

អ្នកអាចសួរខ្លួនអ្នកថា "ក្នុងនាមជាយុវវ័យ បណ្ដាញទំនាក់ទំនងអាចជួយធ្វើឱ្យប្រសើរចំណេះដឹងរបស់ខ្ញុំ និងជួយខ្ញុំស្វែងរកឱកាសការងារបានយ៉ាងដូចម្ដេចខ្លះ?" ខាងក្រោមនេះជាគំនិតខ្លះៗ៖

- ប្រសិនបើអ្នកមានគំនិតខ្លះៗអំពីវិស័យការងារដែលអ្នកចង់បន្ត សូមធ្វើអ្វីដែលខ្ញុំបានធ្វើ និងសុំឱ្យណែនាំអ្នកដល់យុវវ័យដែលធ្វើការនៅក្នុងផ្នែកនោះ។ បន្ទាប់មកស្នើសុំសម្ភាសន៍ដើម្បីនិយាយជាមួយពួកគេផ្ទាល់។
- សុំចំណាយពេលប្រហែល ៣០ នាទីម្នាក់។ មកដល់មុនពេលបន្តិច វាជាការប្រសើរបើអ្នកត្រូវមកមុនពេលបន្តិច និងរង់ចាំជាជាងការមកដល់យឺតយ៉ាវ ។
- សូមសរសេរសំណួរខ្លះៗជាមុន ដើម្បីឱ្យការសម្ភាសន៍របស់អ្នកមានការរៀបចំជាមុន។ សូមសរសេរកំណត់ត្រាអំឡុងពេលប្រជុំ។ សំណួរខ្លះអាចមានដូចជា៖ តើអ្នកបានរៀបចំអ្វីខ្លះសម្រាប់ការងារនេះ ? តើអ្វីជាការទទួលខុសត្រូវចម្បងរបស់អ្នក ? តើអ្នកចូលចិត្តបំផុតចំពោះការងាររបស់អ្នក ? សូមប្រើសំណួរដែលទាមទារចម្លើយវែង ដើម្បីកុំឱ្យអ្នកគ្រាន់តែទទួលបានចម្លើយ "បាទ/ចាស" និង "ទេ"។ អ្នកចង់មានការសន្ទនា។
- បន្ទាប់មក សូមស្ដាប់ឱ្យប្រាកដ។ ផ្ដោតការយកចិត្តទុកដាក់លើអ្វីដែលពួកគេនិយាយជាជាងអ្វីដែលពួកគេជួយអ្នក។ សូមចាប់អារម្មណ៍ដោយក្ដីរីករាយ រាល់ចម្លើយដែលផ្ដល់។ ញញឹម!
- មុនពេលបញ្ចប់ សូមសួរថា "តើមាននរណាម្នាក់ដែលខ្ញុំគួរនិយាយទៅកាន់?" សំណួរនេះពិតជាល្អណាស់ ព្រោះវាអាចនាំឱ្យមានឱកាសសម្ភាសន៍បន្ថែមទៀត។
- នៅចុងបញ្ចប់ សូមអរគុណពួកគេ។ នៅពេលអ្នកត្រឡប់ទៅផ្ទះ សូមផ្ញើសារថ្លែងអំណរគុណតាមអ៊ីមែល ដោយនិយាយកោតសរសើរពួកគេដែលចំណាយពេលវេលាជាមួយអ្នក។

មិនត្រឹមតែតាមរយៈការជួបមុខផ្ទាល់បណ្ដោះទេ អ្នកក៏តែងតែអាចជួបមនុស្សនៅលើអ៊ីនធឺណិតផងដែរ។

- ពិនិត្យកំណត់ហេតុបណ្ដាញដែលសរសេរអំពីការងារផ្សេងៗ និងចូលរួមក្រុមការងារនៅលើអ៊ីនធឺណិត។ បង្កើតទំនាក់ទំនង។
- ក្លាយជាសមាជិកសកម្មនៃសហគមន៍ឌីជីថល។ អ្នកនឹងរកបានគំនិតជាច្រើននៅទីនោះ។
- ផ្ដល់មតិនៅលើកំណត់ហេតុបណ្ដាញផ្សេងៗ។ ប្រសិនបើអ្នកសរសេរអ្វីមួយមានអត្ថន័យ អ្នកនោះនឹងសរសេរមកអ្នកវិញ។

សូមចងចាំថា៖ មនុស្សគ្រប់រូបដែលអ្នកជួបមានអ្វីមួយដែលបង្រៀនអ្នក! អ្នកមិនដែលដឹងថាអ្នកណាដែលអាចជួយអ្នក ប្រសិនបើអ្នកមិនព្យាយាម!

## សំណួរ

១ ) តើអ្នកណាជាអ្នកទស្សនាគោលដៅរបស់ចរណៃ ?

២ ) តើអ្វីជាវត្ថុបំណងនៃប្រកាសនេះ ?

បន្ត >>

៣) សូមវិភាគចំណងជើង។ តើវាមានប្រសិទ្ធភាពដែរឬទេ? សរសេរចំណងជើងផ្សេង សម្រាប់កំណត់ហេតុបណ្ដាញនេះ។
៤) តើអ្នកអាចប្រាប់ពីអ្វីដែលចរណៃបានធ្វើផែនការប្រកាសផ្សាយ?
៥) តើរូបភាពបន្ថែមគុណតម្លៃទៅប្រកាសរបស់ចរណៃដែរឬទេ? សូមពន្យល់ ចម្លើយរបស់អ្នក។
៦) តើអ្នកបានរៀនអ្វីខ្លះពីប្រកាសកំណត់ហេតុបណ្ដាញនេះ?

## លំហាត់ ៤

នៅក្នុងលំហាត់នេះ អ្នកត្រូវធ្វើការជាមួយសមាជិកក្រុមរបស់អ្នកដើម្បីបង្កើតប្រកាស កំណត់ហេតុបណ្ដាញនៅក្រៅអ៊ីនធឺណិត។ ប្រកាសបានបញ្ចប់ខ្លះហើយ និងការងាររបស់អ្នកត្រូវ បញ្ចប់វា។

សូមអានប្រកាសកំណត់ហេតុបណ្ដាញខាងក្រោម ធ្វើការវិភាគវា និងរៀបចំវាដើម្បីផ្សព្វផ្សាយ។ ធ្វើការរួមគ្នាជាក្រុម និងរក្សាទុកចម្លើយរបស់អ្នកទៅថតក្រុមរបស់អ្នក ដោយដាក់ឈ្មោះថា លំហាត់ ១៣ខ.odt។

កំណត់ហេតុបណ្ដាញដែលប្រឌិតនេះត្រូវបានគេដាក់ឈ្មោះថា samsportfocus.com។ អ្នក កំណត់ហេតុបណ្ដាញដែលប្រឌិតនេះឈ្មោះ សម្បត្តិ។ ខាងក្រោមនេះ គឺជាអ្វីដែលសម្បត្តិបាន សរសេរ។

សួស្ដី! រកអ្នកចូលរួមលេងបាល់ទះជាមួយខ្ញុំនៅល្ងាចនេះ ឬចុងសប្ដាហ៍។ យើងអាច ចាប់ផ្ដើមបង្កើតក្រុមមួយ ឬខ្ញុំអាចចូលរួមក្រុមដែលបានកំពុងលេងរួចហើយ។

.......................................................................................................

សំណួរ

១) ជ្រើសចំណងជើងសម្រាប់ប្រកាសនេះ

២) ឆ្លើយសំណួរ អ្នកណា/អ្វី/កន្លែងណា/ពេលណា/របៀបណា ដើម្បីឱ្យអ្នកអានមាន ព័ត៌មានបន្ថែម ប្រសិនបើពួកគេចង់ផ្ដល់មតិយោបល់។

៣) សម្រេចចិត្តជ្រើសអ្នកទស្សនាគោលដៅ។ ឧទាហរណ៍ តើពួកគេជាភេទស្រី ឬប្រុស ឬតើវាមានបញ្ហាដែរឬទេ? តើចន្លោះអាយុប៉ុន្មានដែរ?

៤) ឥឡូវអ្នកបានដឹងឈ្មោះកំណត់ហេតុបណ្ដាញ ចំណងជើងប្រកាសនេះ និងអ្នកមាន ព័ត៌មានលម្អិតសម្រាប់ប្រកាស តើអ្វីជាពាក្យគន្លឹះទាំងប្រាំដែលអាចជួយអ្នកណាម្នាក់រក ឃើញកំណត់ហេតុបណ្ដាញជាក់លាក់នេះ?

៥) ឥឡូវសរសេរប្រកាសឡើងវិញជាមួយព័ត៌មានពី ១ ២ និង ៣ ។

## សំណួរត្រិះរិះ

១. តើអ្វីជាមូលហេតុពីរដើម្បីចូលរួមយ៉ាងសកម្មនៅក្នុងទំនាក់ទំនងឌីជីថល?

២. តើអ្វីជាកំណត់ហេតុបណ្ដាញ? តើអ្វីជាប្រកាសកំណត់ហេតុបណ្ដាញ និងបញ្ជីកំណត់ហេតុបណ្ដាញ? សូមពន្យល់ថាហេតុអ្វីបានជាគេបង្កើតកំណត់ហេតុបណ្ដាញផ្ទាល់ខ្លួនរបស់ពួកគេ។

៣. តើអ្វីសំខាន់ត្រូវចងចាំក្នុងចិត្តខណៈដែលកំពុងបង្កើតកំណត់ហេតុបណ្ដាញ? សូមផ្ដល់ឧទាហរណ៍។

៤. ហេតុអ្វីអ្នកប្រើដែលសកម្មត្រូវដឹងអំពីអាជ្ញាប័ណ្ណ Creative Commons?

៥. តើអ្នកកំណត់ហេតុបណ្ដាញអាចធ្វើការផ្សព្វផ្សាយកំណត់ហេតុបណ្ដាញរបស់ពួកគេបានយ៉ាងដូចម្ដេច? តើហេតុអ្វីបណ្ដាញមានសារៈសំខាន់?

ជំពូកទី ៥ |ការងារបង្រៀន លក់ និងការងារ

# មេរៀនទី ៥

# ការងារបង្រៀនកុំព្យូទ័រ

## នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពី៖

១. យល់ដឹងអំពីការងារបង្រៀន ICT និងគោលបំណងនៃការបង្រៀន ICT នៅវិទ្យាល័យនៅកម្ពុជា

២. កំណត់ និងយល់ដឹងកម្រិតវប្បធម៌ បំណិនបច្ចេកទេស បំណិនទំនាក់ទំនង និងលក្ខណសម្បត្តិផ្សេងៗដែលត្រូវការដើម្បីក្លាយជាគ្រូបង្រៀន ICT នៅសាលាមធ្យមសិក្សាចំណេះទូទៅដ៏មានប្រសិទ្ធភាព

៣. យល់ដឹងបរិស្ថានការងារ និងឱកាសការងារលើការបង្រៀនមុខវិជ្ជា ICT

# ផ្នែក ក - ការងារក្នុងការបង្រៀនកុំព្យូទ័រ

## ១. ការណែនាំអំពីការអប់រំ ICT

ឥឡូវ ចរណៃបានចាប់ផ្តើមកំណត់ហេតុបណ្តាញរបស់នាង នាងទទួលបានមតិយោបល់ និងសំណួរអំពីការរៀបចំខ្លួនសម្រាប់ការងារ។ សិស្សម្នាក់ឈ្មោះពេជ្រ បានសរសេរទៅចរណៃ។

New Tab

ពេជ្រ

2015 / October, 10

ខ្ញុំចង់ធ្វើជាគ្រូបង្រៀនម្នាក់នៅវិទ្យាល័យ ដែលបង្រៀនសិស្សអំពីរបៀបប្រើកុំព្យូទ័រ និងបច្ចេកវិទ្យាផ្សេងៗដែលពួកគេត្រូវការនាពេលអនាគត។ ខ្ញុំមានអាយុ ១៨ ឆ្នាំរៀនថ្នាក់ទី ១២ ។ តើខ្ញុំគួររៀបចំខ្លួនយ៉ាងដូចម្តេច?



ចរណៃ

2015 / October, 10

"ពិតជាគួរឱ្យចាប់អារម្មណ៍ណាស់ ពេជ្រ! ពួកយើងជាច្រើនមិនទាន់បានសម្រេចចិត្តជ្រើសរើសការងារអ្វីដែលយើងចង់ធ្វើនៅឡើយទេ! តើអ្នកបានសួរគ្រូបង្រៀន ICT របស់អ្នកទេថា គាត់អាចក្លាយជាគ្រូបង្រៀន ICT បានយ៉ាងដូចម្តេច? ខ្ញុំសូមណែនាំឱ្យអ្នកសួរគាត់។ រៀបចំសំណួរប្រមាណចំនួនប្រាំ ឬប្រាំមួយដែលអ្នកចង់សួរ និងធ្វើការណាត់ជួបជាមួយគាត់។"

ពេជ្រ

2015 / October, 17

មួយសប្តាហ៍ក្រោយមក ពេជ្រសរសេរត្រឡប់មកវិញ៖ "នេះជាគំនិតដ៏ល្អមែន! លោកគ្រូ ពិសិដ្ឋ ជាគ្រូបង្រៀនកុំព្យូទ័រខ្ញុំនៅថ្នាក់ទី ១១ កាលពីឆ្នាំមុន ហើយគាត់បាននិយាយថា គាត់រីករាយនឹងឆ្លើយតបនឹងសំណួររបស់ខ្ញុំ។ គាត់ក៏បានប្រាប់ខ្ញុំថា ខ្ញុំជាសិស្សល្អម្នាក់ក្នុងចំណោមសិស្សរបស់គាត់ ដែលធ្វើឱ្យគាត់ពេញចិត្តយ៉ាងខ្លាំង។ ឥឡូវនេះ ខ្ញុំកាន់តែច្បាស់មែនទែនហើយថា ខ្ញុំនឹងប្រាកដជាចង់ធ្វើជាគ្រូបង្រៀនកុំព្យូទ័រដ៏ល្អម្នាក់។"



ចរណៃ

2015 / October, 17

"ខ្ញុំរីករាយណាស់ដែលបានឮដូច្នេះ! សូមឱ្យអ្នកសំណាងល្អជាមួយការសិក្សានៅសាកលវិទ្យាល័យ និងការងារជាគ្រូបង្រៀនរបស់អ្នក។ តើអ្នកនឹងចូលរៀននៅសាកលវិទ្យាល័យណា? សូមបង្កើតសហគមន៍ជាកំណត់ហេតុបណ្តាញមួយរបស់យើងដើម្បីជួយអ្នកផ្សេងៗទៀតអំពីរឿងនេះ។"

ការអប់រំ គឺជាការវិនិយោគដ៏សំខាន់បំផុតដែលប្រទេសជាតិត្រូវការសម្រាប់ដំណើរអភិវឌ្ឍប្រទេសនាពេលអនាគត ហើយរាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់នូវសារៈសំខាន់នៃការអប់រំនេះ។ ក្រសួងអប់រំ យុវជន និងកីឡាមានតួនាទីពីរ ទីមួយគឺត្រូវរៀបចំសិស្សឱ្យទៅដល់គោលដៅចូលរួមក្នុងសង្គមប្រកបដោយជោគជ័យ និងក៏ត្រូវរៀបចំដើម្បីប្រាកដផងដែរថាប្រទេសជាតិមានធនធាន

មនុស្សដែលមានគុណភាពដែលចាំបាច់សម្រាប់អភិវឌ្ឍ ធ្វើទំនើបកម្ម និងអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា។

សម្រាប់គោលបំណងទីមួយ ការអប់រំសម្រាប់គ្រប់គោលបំណងផែនការដើម្បីប្រាកដថាប្រជាជនកម្ពុជាអាចទទួលបានការអប់រំដ៏ល្អបំផុត។ សម្រាប់គោលបំណងទីពីរក្រសួងត្រូវតែប្រាកដថាសិស្សទាំងអស់ដែលបញ្ចប់ការសិក្សាអាចចូលក្នុងទីផ្សារការងារយ៉ាងងាយស្រួលដោយមិនចាំបាច់ទទួលវគ្គបណ្តុះបណ្តាលបន្ថែមទៀតនៅពេលធ្វើការ។

*ការវិវត្តបច្ចេកវិទ្យាកំពុងតែផ្លាស់ប្តូរការងារ និងសង្គមកម្ពុជា ហើយកម្លាំងការងារនៅពេលអនាគតនឹងប្រកួតប្រជែងក្នុងពិភពដែលពឹងផ្អែកលើបច្ចេកវិទ្យា។*

បំណិនដែលទាមទារដើម្បីចូលក្នុងវិស័យការងារផ្សេងៗគឺកាន់តែខុសៗគ្នា ប៉ុន្តែវិស័យភាគច្រើនជាទូទៅនិយោជិតត្រូវប្រតិបត្តិក្នុងចំណេះដឹងសង្គមដែលគាំទ្រដោយឧបករណ៍បច្ចេកវិទ្យា កុំព្យូទ័រកំពុងក្លាយជាឧបករណ៍ប្រើប្រាស់ទូទៅមួយ។ ការសិក្សាអំពីវិធីប្រតិបត្តិបរិក្ខារកុំព្យូទ័រ និងបើកមធ្យោបាយផ្សេងៗទៀតសម្រាប់ការបណ្តុះបណ្តាលបច្ចេកវិទ្យា ព្រមទាំងវិស័យផ្សេងៗទៀតនៃការសិក្សា ឬការងារ។ ក្រសួងអប់រំ យុវជន និងកីឡា បានអភិវឌ្ឍផែនការគោលបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) ក្នុងវិស័យអប់រំ និងបានសម្រេចចិត្តដាក់បញ្ចូលមុខវិជ្ជាព័ត៌មានវិទ្យា និងសារគមនាគមន៍ (ICT) សម្រាប់ថ្នាក់ទី ១១ និងទី ១២ ក្នុងកម្មវិធីអប់រំវិជ្ជាជីវៈជម្រើស (EVEP)។ កម្មវិធី EVEP ព្យាយាមលើកកម្ពស់ការរៀបចំសិស្សសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬសាកលវិទ្យាល័យ ដោយផ្តល់ឱ្យពួកគេនូវគំនិតដ៏ច្បាស់ក្នុងវិស័យការងារដែលពួកគេបានជ្រើសរើស និងជួយពួកគេអនុវត្តបានក្នុងកន្លែងធ្វើការ ការប្រាស្រ័យទាក់ទង និងបំណិនកុំព្យូទ័រ។

សម្រាប់ការអប់រំចំណេះដឹងទូទៅ ក្រសួងផ្តោតលើការបង្កើនការរៀបចំ និងការផ្តល់ឱ្យសិស្សនូវបំណិនវិជ្ជាជីវៈផ្អែកលើ ICT ការតម្រង់ទិសការងារផ្អែក ICT និងបំណិនត្រៀមចូលសាកលវិទ្យាល័យផ្សេងៗទៀត។



រូបថត៖ ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

នៅថ្នាក់ឧត្តមសិក្សា ក្រសួងមានផែនការផ្តោតលើការប្រើប្រាស់កុំព្យូទ័រ ដោយបង្កើនការចូលប្រើប្រាស់ព័ត៌មានការស្រាវជ្រាវ និងបង្រៀនសិស្សឱ្យកាន់តែច្រើនថែមទៀតតាមរយៈការអប់រំពីចម្ងាយ ការរៀនមួយជីវិត និងការលើកកម្ពស់ការចែកចាយការស្រាវជ្រាវ ព្រមទាំងសម្ភារៈតាមមុខវិជ្ជាតាមរយៈវេបសាយដែលអាចចូលប្រើប្រាស់ឯកសារទាំងអស់នេះបាន។

ក្រសួងមានផែនការលើកកម្ពស់ការបណ្តុះបណ្តាលសមត្ថភាពគ្រូបង្រៀនដោយតាមរយៈការប្រើប្រាស់វីដេអូ និងសម្ភារៈពហុមេឌាជាសម្ភារៈគាំទ្រដល់ការអប់រំគ្រូ ផ្តោតសំខាន់សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ ក៏ដូចជាសម្រាប់ការអប់រំទូទៅផងដែរ។ សិក្ខាកាមជាគ្រូត្រូវបានបណ្តុះបណ្តាលអំពីវិធីលើកកម្ពស់ការបង្រៀនរបស់ពួកគេ និងបំណិនរដ្ឋបាលតាមរយៈការប្រើប្រាស់កុំព្យូទ័រ និងទម្រង់ ICT ផ្សេងៗទៀត។

# ២. ការងារក្នុងការបង្រៀនកុំព្យូទ័រ

ការបង្រៀន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន បានផ្ដល់ដល់វិទ្យាល័យ និងសាកលវិទ្យាល័យសាធារណៈ និងឯកជនជាច្រើនផងដែរ។ តម្រូវការគ្រូឧទ្ទេសទាំងក្នុងសាលាបច្ចេកទេស និងក្រុមហ៊ុនបណ្ដុះបណ្ដាលឯកជនដែលមានជំនាញដូចជា ការជួសជុល និងថែទាំកុំព្យូទ័រ ការគ្រប់គ្រងមូលដ្ឋានទិន្នន័យ និងការរចនា និងការអភិវឌ្ឍវេបសាយជាដើម។ ក្រុមហ៊ុនផ្នែកទន់ និង ផ្នែករឹង កុំព្យូទ័រ ត្រូវការគ្រូឧទ្ទេសដែលនិយាយភាសាខ្មែរ និងអាចបង្រៀនក្នុងវគ្គសិក្សាផ្សេងៗសម្រាប់ផលិតផលរបស់ពួកគេ។ សាកលវិទ្យាល័យរដ្ឋ និងឯកជន ត្រូវការសាស្ត្រាចារ្យដែលមានចំណេះដឹង និងបទពិសោធន៍ដើម្បីបង្រៀនវគ្គសិក្សាផ្សេងៗដូចជា វិទ្យាសាស្ត្រកុំព្យូទ័រ ការរចនាក្រាហ្វិក សន្តិសុខព័ត៌មាន និងការអភិវឌ្ឍផ្នែកទន់របស់កុំព្យូទ័រ សាកលវិទ្យាល័យទាំងនោះក៏ត្រូវការសាស្ត្រាចារ្យដែលមានសញ្ញាបត្រថ្នាក់បណ្ឌិត ដើម្បីដឹកនាំការស្រាវជ្រាវអំពីព័ត៌មានវិទ្យា និងសារគមនាគមន៍ ។

ចំណុចសំខាន់លើមេរៀននេះគឺជាការរៀបចំសម្រាប់បង្រៀនវគ្គ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ថ្នាក់ទី ១១ និង ១២នៅតាមសាលារៀនរដ្ឋក្នុងប្រទេសកម្ពុជា។ នៅទូទាំងប្រទេសកម្ពុជា វិទ្យាល័យមានប្រមាណ ៤៥៥ ក្នុងឆ្នាំ ២០១៥។ ចំនួនវិទ្យាល័យដែលមានបន្ទប់កុំព្យូទ័រសម្រាប់បង្រៀន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ កំពុងតែមានកើនឡើង។ រួមជាមួយនឹងតម្រូវការក្នុងការបង្កើនចំនួនកុំព្យូទ័រ គ្រូបង្រៀនបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ដែលបានទទួលការបណ្ដុះបណ្ដាល ត្រូវការចាំបាច់ដើម្បីបំពេញតម្រូវការនៃការដាក់បញ្ចូលមុខវិជ្ជា បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ជាមុខវិជ្ជាមួយនៅកម្រិតវិទ្យាល័យ។ លើសពីនេះទៀតមានសិស្សានុសិស្សច្រើនកំពុងចូលរៀន និងបញ្ចប់វិទ្យាល័យច្រើនជាងឆ្នាំមុនៗ ដែលនាំឱ្យមានតម្រូវការគ្រូបង្រៀនកាន់តែច្រើន។



# ២.១. តម្រូវការការងារ

## ការអប់រំ

ដើម្បីក្លាយជាគ្រូបង្រៀន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ នៅវិទ្យាល័យ គ្រូបង្រៀនត្រូវតែបញ្ចប់ថ្នាក់បរិញ្ញាបត្រខាងវិទ្យាសាស្ត្រកុំព្យូទ័រ បច្ចេកវិទ្យាព័ត៌មាន (IT) ឬមុខវិជ្ជាដែលទាក់ទងនៅកម្រិតសាកលវិទ្យាល័យ។ បន្ទាប់ពីបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ អ្នកដែលចង់ក្លាយជាគ្រូបង្រៀនត្រូវតែប្រឡងចូលរៀននៅវិទ្យាស្ថានជាតិអប់រំ (NIE)។ គរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំ នឹងសិក្សាបន្ថែមមួយឆ្នាំទៀតអំពីមុខវិជ្ជាគរុកោសល្យដូចជា វិធីសាស្ត្របង្រៀនបច្ចេកទេស និងយុទ្ធសាស្ត្រ ធ្វើបទបង្ហាញ បំណិនត្រិះរិះពិចារណា និងភាពជាអ្នកដឹកនាំ។ ពួកគេនឹងសិក្សាពីកម្មវិធីសិក្សាផងដែរដើម្បីថ្នឹកជាមួយនឹងសៀវភៅសិក្សាគោល និងទទួលបានបទពិសោធន៍អនុវត្តដែលចាំបាច់ក្នុងការបង្រៀន ICT ក្នុងបរិស្ថានថ្នាក់រៀនពិតប្រាកដ។

អំឡុងពេលសិក្សាមួយឆ្នាំនៅវិទ្យាស្ថានជាតិអប់រំ សិក្ខាកាមជាគរុនិស្សិត បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍  សិក្សាមុខវិជ្ជានេះលម្អិត ដូចជា ប្រព័ន្ធកុំព្យូទ័រ និងការតបណ្ដាញ ការថែទាំ និងជួសជុលកុំព្យូទ័រ កម្មវិធី និងប្រព័ន្ធប្រតិបត្តិការកុំព្យូទ័រទូទៅដែលពួកគេមិនធ្លាប់ដឹង (ដូចជា អ៊ូប៊ុនទូ) និងការប្រើប្រាស់អ៊ីនធឺណិត និងបណ្ដាញសង្គមសម្រាប់ការប្រាស្រ័យទាក់ទង និងការសិក្សាពីចម្ងាយ។ ពួកគេក៏នឹងសិក្សាមុខវិជ្ជាចំនួនពីរដែលពួកគេនឹងតម្រូវឱ្យបង្រៀននៅវិទ្យាល័យ គឺ វគ្គបំណិនវិជ្ជាជីវៈផ្អែកលើបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ថ្នាក់ទី ១១ និងការតម្រង់ទិសវិជ្ជាជីវៈសម្រាប់ការងារ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ សម្រាប់ថ្នាក់ទី ១២។  គរុនិស្សិត នឹងសិក្សាផងដែរអំពី ចិត្តគរុកោសល្យ ដែលជាបណ្ដុំវិធីសាស្ត្រដែលគ្រូបង្រៀនប្រើប្រាស់ដើម្បីប្រាកដថាសិស្សអាចរៀនពីអ្វីដែលគាត់កំពុងបង្រៀនយ៉ាងងាយស្រួល។



សម្រាប់ការបង្រៀនថ្នាក់ទី ១១ និង ១២ បំណិនគរុកោសល្យមានសារៈសំខាន់ជាងបំណិនបច្ចេកទេស។ ការសិក្សាពីបច្ចេកទេស សិស្សត្រូវធ្វើការអនុវត្តជាក្រុមពេលធ្វើការលើលំហាត់ការងាររបស់គ្រូបង្រៀនគឺជួយសិស្សឱ្យយល់ពីការងារ និងបរិស្ថាននៃសង្គមដែលសម្បូរដោយព័ត៌មាននេះ។ អំឡុងពេលការសិក្សារបស់ពួកគេ គរុនិស្សិតសិក្សាពីបច្ចេកទេស និងយុទ្ធសាស្ត្រដែលនឹងដឹកនាំសិស្សឱ្យអនុវត្តបំណិនដែលបានទទួលថ្មីៗក្នុងបរិបទជាក់ស្តែង ដោយធ្វើឱ្យថ្នាក់រៀនមានបរិយាកាសគួរឱ្យចាប់អារម្មណ៍។ គរុនិស្សិតក៏សិក្សាផងដែរអំពីវិធីមើលការរីកចម្រើនរបស់សិស្ស និងរៀបចំរបាយការណ៍សម្រាប់រដ្ឋបាលសាលារៀន។

## ជំនាញ និងបទពិសោធន៍

### បំណិនបច្ចេកទេសជាក់លាក់ដែលត្រូវមាន

ការបង្រៀន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ផ្តល់ឱកាសឱ្យប្រព័ន្ធអប់រំសាធារណៈរបស់កម្ពុជា ដាក់បញ្ចូលនូវបំណិនរឹង (Hard Skill) និងបំណិនទន់ (Soft Skill) ដែលជាប្រធានបទនៃការសិក្សា។ បំណិនរឹង គឺជាចំណេះដឹងវិជ្ជាជីវៈ និងជំនាញផ្សេងៗដែលអាចឱ្យយើងស្ទាត់ជំនាញក្នុងការងាររបស់យើង សម្រាប់គ្រូបង្រៀន ICT រួមមានចំណេះដឹងបច្ចេកទេសផ្នែកទន់ និងផ្នែករឹងរបស់កុំព្យូទ័រ ព្រមទាំងយល់ដឹងអំពីវិធីប្រើប្រាស់បំណិនទាំងនេះក្នុងបរិស្ថានការងារ។ បំណិនទន់ គឺជាបំណិនដែលអាចឱ្យយើងធ្វើការប្រកបដោយប្រសិទ្ធភាពដែលរួមមាន ឥរិយាបថប្រាស្រ័យទំនាក់ទំនង និងសង្គម សមត្ថភាពដើម្បីដឹកនាំសិស្សឱ្យរៀន និងបំណិនក្នុងការវិភាគព័ត៌មាន។ គ្រូបង្រៀន ICT ដែលប្រកបដោយប្រសិទ្ធភាពអនុវត្តបញ្ចូលគ្នាទាំងបំណិនរឹង និងបំណិនទន់ ដើម្បីជួយឱ្យសិស្សរៀនពីទស្សនាទាន និងបំណិនដែលចាំបាច់។

ទិដ្ឋភាពបច្ចេកទេសសម្រាប់ការបង្រៀន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ក្នុងប្រទេសកម្ពុជា បានដឹងយ៉ាងច្បាស់អំពីកម្មវិធីសិក្សារបស់ក្រសួង និងសៀវភៅសិក្សាគោល ថ្នាក់ទី ១១ និង ១២ ព្រមទាំងជាមួយនឹងសម្ភារៈផ្សេងៗទៀតដែលត្រូវការសម្រាប់បង្រៀនមុខវិជ្ជាទាំងនេះ។ គ្រូបង្រៀនត្រូវតែមានការយល់ដឹងឱ្យបានច្បាស់អំពីផ្នែកទន់ និងផ្នែករឹងដែលបានប្រើសម្រាប់បង្រៀន និងពិសេសជាងនេះទៀតគឺប្រព័ន្ធប្រតិបត្តិការ និងកម្មវិធីកុំព្យូទ័រជាភាសាខ្មែរដែលឥតគិតថ្លៃ ដែលត្រូវបានប្រើប្រាស់ក្នុងថ្នាក់រៀន ។ ប្រព័ន្ធប្រតិបត្តិការ និងកម្មវិធីទាំងនោះរួមមាន កម្មវិធីការិយាល័យភាសាខ្មែរ លីនុច កម្មវិធីអ៊ីនធឺណិត កម្មវិធីអ៊ីមែល។ គ្រូបង្រៀនក៏ត្រូវបានបំប៉នបំណិនក្នុងការប្រើប្រាស់កម្មវិធីធ្វើបទបង្ហាញ និងវាយអក្សរខ្មែរដោយប្រើតាមក្បួនស្តង់ដារយូនីកូដខ្មែរ។



## បំណិន និងចរិតលក្ខណៈរបស់គ្រូបង្រៀនចំណាន

យើងទាំងអស់គ្នាមានគ្រូបង្រៀនដែលធ្វើឱ្យការរៀនមានចំណាប់អារម្មណ៍ និងរីករាយ គ្រូបង្រៀនខ្លះទៀតប្រើវិធីសាស្ត្របង្រៀនរបស់ពួកគេគួរឱ្យធុញទ្រាន់បំផុត ធ្វើឱ្យសិស្សមិនចង់រៀន។ ដូច្នេះតើគ្រូបង្រៀនគួរមានបំណិនអ្វីខ្លះដើម្បីក្លាយជាគ្រូបង្រៀនដ៏ចំណាន ?បើអ្នកត្រូវបានសួរឱ្យកំណត់លក្ខណៈគ្រូបង្រៀនឆ្នើម អ្នកអាចមានគំនិតខ្លះៗអំពីលក្ខណសម្បត្តិ និងបំណិនទំនាក់ទំនងដូចរៀបរាប់ខាងក្រោម ។



១. ការប្តេជ្ញាចិត្ត៖ គ្រូបង្រៀនដែលចំណានបានប្តេជ្ញាចិត្តចំពោះការងាររបស់ពួកគេ និងចំពោះការអប់រំមនុស្សជំនាន់ក្រោយ។ ពួកគេដឹងថា ពួកគេមានការទទួលខុសត្រូវច្រើន ដើម្បីបង្រៀនសិស្សឱ្យពូកែមានចំណង់ការសិក្សាខ្ពស់ និងទទួលបានជោគជ័យក្នុងការសិក្សា។

២. ការរៀបចំ ៖គ្រូបង្រៀនដែលចំណានបានរៀបចំសម្រាប់ការងារទាំងការអប់រំក្នុងប្រព័ន្ធ ដែលចំណាយពេលច្រើនឆ្នាំដើម្បីបញ្ចប់ និងការរៀបចំមេរៀនសម្រាប់ការបង្រៀនរាល់ថ្ងៃ។ គ្រូបង្រៀនដែលបានរៀបចំយ៉ាងល្អ គឺជាគ្រូបង្រៀនដែលទទួលបានភាគជោគជ័យកាន់តែច្រើន។

៣. ការរៀបចំ និងធ្វើកិច្ចតែងការបង្រៀន៖ គ្រូបង្រៀនត្រូវតែរៀបចំកិច្ចតែងការមេរៀនឱ្យបានល្អ និងកំណត់ពេលវេលាឱ្យបានត្រឹមត្រូវជាប្រចាំ។ ជាទូទៅសិស្សនឹងខិតខំរៀនសម្រាប់គ្រូបង្រៀនដែលបានចំណាយពេលវេលាច្រើនដើម្បីធ្វើកិច្ចតែងការបង្រៀន។

៤. ភាពយុត្តិធម៌៖ គ្រូបង្រៀនដែលចំណាន យកចិត្តទុកដាក់សិស្សទាំងអស់ស្មើៗគ្នា និងមិនមានភាពលម្អៀងទេ។ គ្រូបង្រៀនមើលសិស្សម្នាក់ៗផ្សេងៗគ្នា ជាជាងមើលជាក្រុម។ បន្ថែមលើនេះទៀត គ្រូបង្រៀនដែលយុត្តិធម៌មិនបង្ហាញទស្សនៈផ្ទាល់ខ្លួនលើសិស្សទេ។ គាត់យកចិត្តទុកដាក់លើសិស្ស និងមានមោទនភាពលើសិស្សដែលជោគជ័យ និងយល់អំពីតម្លៃនៃការទទួលស្គាល់ និងការសរសើរដែលសមនឹងទទួលបាន។

៥. ការរៀបរាប់ពីរឿងរ៉ាវ៖  គ្រូបង្រៀនអាចគ្រប់គ្រងចំណាប់អារម្មណ៍របស់សិស្ស និងលើកកម្ពស់ការបង្រៀនដោយបង្រៀនមេរៀនតាមរយៈការរៀបរាប់ពីរឿងរ៉ាវអ្វីមួយ។ សិស្សចង់ដឹងអ្វីនឹងមានបន្ទាប់ទៀត និងកាន់តែមានទំនាក់ទំនងនៅពេលមានរឿងរ៉ាវមួយបានភ្ជាប់ជាមួយមេរៀន។ ជារឿយៗសិស្សក៏អាចទទួលព័ត៌មានបានកាន់តែប្រសើរនៅពេលពួកគេអាចភ្ជាប់គោលគំនិតជាមួយនឹងរឿងរ៉ាវ។ គ្រូបង្រៀនដែលបង្ហាញការវិនិច្ឆ័យក្នុងថ្នាក់រៀនអាចបន្ថែមថាមពលដល់មេរៀន។

៦. ការបើកទូលាយចំពោះសំណួរ៖ ដឹកនាំការពិភាក្សា និងលើកទឹកចិត្តឱ្យមានការសហការក្នុងចំណោមសិស្សដើម្បីជួយអភិវឌ្ឍបំណិនគិតពិចារណា។ គ្រូបង្រៀនដែលចំណាន ស្តាប់

សំណួររបស់សិស្សដោយយកចិត្តទុកដាក់ដោយមិនធ្វើការវិនិច្ឆ័យទេ។ ពួកគេស្វាគមន៍ពេលពួកគេមិនដឹងចម្លើយ និងផ្តល់ឱកាសដើម្បីរកចម្លើយ ឬឱ្យសិស្សឡើងផ្តល់ចម្លើយ។ គ្រូបង្រៀនដែលចំណានក៏ដឹងពីវិធីសួរសំណួរដែលត្រង់ និងច្បាស់ៗ។

៧. គំនិតច្នៃប្រឌិត និងចង់ដឹងចង់ឮ៖ គ្រូបង្រៀនដែលចំណានចង់ដឹងដោយខ្លួនពួកគេផ្ទាល់ និងបង្កើនការចង់ដឹងចំពោះបញ្ហាប្រឈមនៃសិស្សរបស់ពួកគេ។ គ្រូបង្រៀនដែលចំណានចូលចិត្តសាកល្បងអ្វីដែលថ្មី និងមិនប្រើឧទាហរណ៍ដដែលពីមួយឆ្នាំទៅមួយឆ្នាំ។ ពួកគេប្រើរបៀបបង្រៀនដែលបត់បែន និងកំណត់កិច្ចការដែលប្រឈម។ ដើម្បីដើរឱ្យទាន់ការផ្លាស់ប្តូរក្នុងសង្គម ពួកគេអាន ស្រាវជ្រាវ និងបន្តការអភិវឌ្ឍវិជ្ជាជីវៈរបស់ពួកគេ។ ពួកគេជឿជាក់លើការរៀនពេញមួយជីវិត និងតាមធម្មតាមានចំណាប់អារម្មណ៍ផ្សេងៗយ៉ាងទូលំទូលាយ។

៨. ចំណូលចិត្តបច្ចេកវិទ្យា៖ គ្រូបង្រៀនមុខវិជ្ជា បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ត្រូវតែធ្វើបច្ចុប្បន្នភាពជាមួយនឹងការអភិវឌ្ឍបច្ចេកវិទ្យាសម្រាប់ការបង្រៀន និងប្តេជ្ញាចិត្តប្រើប្រាស់វាក្នុងថ្នាក់រៀន ព្រោះថាពួកគេច្នៃប្រឌិត និងចង់ដឹង គ្រូបង្រៀនដែលចំណានចូលចិត្តរកមើលបច្ចេកវិទ្យាថ្មីៗ និងប្រើប្រាស់ឧបករណ៍ផ្សេងៗក្នុងថ្នាក់រៀន។ បំណិនមួយចំនួនត្រូវបានទាមទារពីគ្រូបង្រៀន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ បច្ចុប្បន្នរួមមាន៖ ការគ្រប់គ្រងមូលដ្ឋានទិន្នន័យ ចំណេះដឹងធ្វើបទបង្ហាញពីអេឡិចត្រូនិកការរកមើលលើបណ្តាញ វិធីដំឡើង និងប្រើប្រាស់កម្មវិធីកុំព្យូទ័រ និងឧបករណ៍ផ្សេងៗ និងមានបំណិនសរសេរកូដកម្មវិធីខ្លះៗ



៩. ការចេះអាណិតអាសូរ៖គ្រូបង្រៀនដែលចំណានគឺគួរឱ្យគោរព យកចិត្តទុកដាក់ចំពោះអ្នកដទៃ និងលើកទឹកចិត្តសិស្សឱ្យប្រឹងប្រែងរៀនសូត្រអស់ពីសមត្ថភាព។ គ្រូបង្រៀនដែលចេះអាណិតអាសូរ អាចដឹងថាសិស្សប្រឈមមុខនឹងបញ្ហាប្រឈមផ្សេងៗ និងព្យាយាមជម្នះឧបសគ្គក្នុងការរៀនសូត្ររបស់ពួកគេ។ គ្រូបង្រៀនដែលចេះអាណិតអាសូរតែងតែញញឹមសព្វាន ចិត្តល្អ និងអត់ធ្មត់។

១០. អ្នកគ្រប់គ្រងថ្នាក់រៀន៖ បន្ថែមលើការរៀបចំមេរៀន គ្រូបង្រៀនចាំបាច់ត្រូវវាយតម្លៃវឌ្ឍនភាពរបស់សិស្សម្នាក់ៗ និងរៀបចំរបាយការណ៍សម្រាប់នាយកសាលា។ គ្រូបង្រៀនដែលចំណានដឹងពីវិធីថែទាំ គ្រប់គ្រងក្នុងថ្នាក់រៀន ហើយពួកគាត់មិនប្រើការគំរាមកំហែងទេ។ ផ្ទុយមកវិញពួកគេអភិវឌ្ឍយុទ្ធសាស្ត្រមិនគំរាមកំហែងសម្រាប់បញ្ជាក់ក្រមសីលធម៌របស់សិស្សដែលមិនសមរម្យ។ យុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រដែលសំខាន់បំផុតគឺកុំធ្វើឱ្យសិស្សខ្មាសគេដោយចេតនាចំពោះមុខសិស្សផ្សេងៗទៀត។ នៅពេលសិស្សដឹងថាគ្រូយកចិត្តទុកដាក់លើពួកគេ និងគោរពពួកគេ ពួកគេនឹងគោរពគ្រូវិញដែរ។

គ្រូបង្រៀនអភិវឌ្ឍរបៀបបង្រៀនផ្ទាល់របស់ពួកគេរាល់ពេល។ គ្រូបង្រៀនថ្មីៗ ភាគច្រើនត្រូវ

ការការជួយគាំទ្រពីគ្រូបង្រៀនដែលមានបទពិសោធន៍ និងនាយកសាលារបស់ពួកគេ ដើម្បីរៀបចំរចនាសម្ព័ន្ធមេរៀន  យល់ដឹងពីការវាយតម្លៃ ការធ្វើរបាយការណ៍ និងវិធីដើម្បីបំពេញតម្រូវការដល់សិស្សម្នាក់ៗ។ ការស្រាវជ្រាវមួយចំនួនបង្ហាញថា ការចំណាយពេលបង្រៀនពីបួន ឬប្រាំឆ្នាំដើម្បីក្លាយជាគ្រូបង្រៀនដែលមានសមត្ថភាព និងទំនុកចិត្ត។ គ្រូបង្រៀនដែលចំណានមានបំណិន និងគុណភាពលាយបញ្ចូលគ្នាដូចបានពន្យល់ខាងលើ ហើយពួកគេបន្តតស៊ូដើម្បីទទួលបានលទ្ធផលល្អ។ ការស្រាវជ្រាវថ្មី បច្ចេកវិទ្យាថ្មី និងកម្មវិធីអប់រំថ្មីៗចេញមករៀងរាល់ឆ្នាំ គ្រូបង្រៀនដែលចំណានអនុវត្តអ្វីដែលថ្មីៗ។ ពួកគេជាគំរូសម្រាប់អ្វីដែលពួកគេចង់ឱ្យសិស្សក្លាយជាអ្នករៀនពេញមួយជីវិត។

# ២.២. បរិស្ថានការងារ

ពេលវេលាបង្រៀនដែលត្រូវការសរុបសម្រាប់គ្រូបង្រៀននៅវិទ្យាល័យគឺប្រមាណ ១៦ម៉ោងក្នុងមួយសប្តាហ៍ ហើយបង្រៀនពីរម៉ោងក្នុងមួយថ្នាក់ កាលវិភាគត្រូវបានរៀបចំឡើងដោយនាយកសាលា។ គ្រូបង្រៀនចំណាយពេលវេលានៅសល់ពីថ្ងៃធ្វើការរបស់ពួកគេរៀបចំមេរៀន កែកិច្ចការបង្រៀន វាយតម្លៃវឌ្ឍនភាពរបស់សិស្ស ជួបជាមួយអាណាព្យាបាលសិស្ស និងធ្វើរបាយការណ៍។

គ្រូបង្រៀនចង់ឱ្យសិស្សរបស់ពួកគេអភិវឌ្ឍទម្លាប់រៀនល្អ អាកប្បកិរិយាវិជ្ជមាន និងលើកទឹកចិត្តដើម្បីទទួលបានជោគជ័យ ប៉ុន្តែទាំងនេះគឺជាការគ្រប់គ្រងរបស់គ្រូបង្រៀនម្នាក់ៗ។ ទោះជាយ៉ាងណាក៏ដោយ គ្រូបង្រៀនដែលចំណានផ្តល់នូវបរិយាកាសល្អ អាកប្បកិរិយាវិជ្ជមានដើរតួដ៏សំខាន់។

គ្រូបង្រៀនចំណាយពេលវេលាធ្វើការភាគច្រើនជាមួយសិស្សរបស់ពួកគេ។ ខណៈដែលគ្រូបង្រៀនត្រូវថែទាំទំនាក់ទំនងល្អជាមួយសិស្ស ពួកគេក៏អាចអភិវឌ្ឍផងដែរតាមរយៈបច្ចេកទេសបង្រៀនល្អ និងការលើកទឹកចិត្ត ទំនុកទុកចិត្ត សេចក្តីគោរព និងការចង់រៀន។ គ្រូបង្រៀនធ្វើឥរិយាបថគំរូដែលសិស្សគួរអនុវត្តតាម។ នៅពេលសិស្សកត់សម្គាល់ឃើញថាគ្រូបង្រៀនគោរព និងបង្ហាញការយកចិត្តទុកដាក់ចំពោះពួកគេ ទំនាក់ទំនងរវាងសិស្ស និងគ្រូបង្រៀនត្រូវបានអនុវត្តដោយពេញចិត្ត។ សិស្សអាចបង្កើតទំនុកចិត្តដែលពួកគេអាចរៀន ទោះបីជាមុខវិជ្ជាដែលពិបាក។ ឧទាហរណ៍៖ នៅពេលគ្រូបង្រៀនបានបង្កើតបរិស្ថានសិស្សមជ្ឈមណ្ឌល សិស្សអាចទទួលស្គាល់ថាគេមិនយល់ពីទស្សនាទានមួយចំនួន ហើយគ្រូរបស់គេនឹងឆ្លើយតបតាមវិធីដែលជួយគាំទ្រ ធ្វើឱ្យសិស្សប្រឹងប្រែងរៀនសូត្រពីព្រោះពួកគេចង់ដឹង មិនមែនពីព្រោះគ្រូតម្រូវឱ្យធ្វើនោះទេ។ ម្យ៉ាងវិញទៀត បរិស្ថានក្នុងថ្នាក់រៀនត្រូវបានបង្កើតឡើងដោយទំនាក់ទំនងរបស់គ្រូដែលមានគុណភាពជាមួយសិស្ស។ ការរំពឹងទុកលើការងារប្រចាំថ្ងៃមួយចំនួនរួមមាន គ្រូបង្រៀនត្រូវតែមកបង្រៀនទៀងទាត់ និងមានការប្រុងប្រយ័ត្នល្អ រៀបចំកន្លែង



ការងារឱ្យបានរបៀប ស្ទៀកពាក់ឱ្យបានសមរម្យ សហការ និងផ្តល់ជំនួយ និងសរសេររបាយការណ៍ដែលចាំបាច់។ បន្ថែមលើនេះទៀតនាយកសាលា និងគណៈគ្រប់គ្រងសាលាផ្សេងៗទៀតត្រូវផ្តល់ការគាំទ្រដល់គ្រូបង្រៀន។ ការជួយគាំទ្រនោះរួមមាន ការលើកទឹកចិត្ត និងផ្តល់ឱកាស ព្រមទាំងការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់គ្រូបង្រៀនទាំងអស់ដើម្បីក្លាយជាអ្នកដឹកនាំ។ ការគាំទ្រផ្នែករដ្ឋបាលមួយទៀត គឺទទួលស្គាល់គ្រូបង្រៀន និងនាយកសាលាដែលលេចធ្លោ។

នៅសាលារៀនមួយចំនួន មានគ្រូបង្រៀនច្រើន រហូតដល់ ២០០ ឬ៣០០នាក់ ហើយនេះមានន័យថាត្រូវចែករំលែកការិយាល័យ ឬថ្នាក់រៀនជាមួយគ្រូបង្រៀនផ្សេង។ ការបង្កើតទំនាក់ទំនងល្អជាមួយមិត្តរួមការងារ និងចែករំលែកចំណេះដឹង ព្រមទាំងបទពិសោធន៍ជាមួយពួកគេគឺជាវិធីមួយដើម្បីរៀនពីគ្រូបង្រៀនផ្សេងៗទៀត។ ជាការពិតគ្រូបង្រៀនអាចដឹកនាំការអភិវឌ្ឍវិជ្ជាជីវៈ និងសិក្ខាសាលាបណ្តុះបណ្តាលសម្រាប់គ្រូបង្រៀនផ្សេងទៀតបានពីព្រោះពួកគេមានបទពិសោធន៍ និងការយល់ដឹងពីបញ្ហាផ្សេងៗ។ ពួកគេក៏ដឹងផងដែរថាវាមានសារៈសំខាន់ដើម្បីធ្វើឱ្យការរៀនកាន់តែមានន័យ និងចាប់អារម្មណ៍។ គ្រូបង្រៀនទាំងអស់ទទួលបន្ទុកមុខវិជ្ជាដូចគ្នាជួបគ្នាយ៉ាងហោចណាស់មួយខែម្តងដើម្បីផ្លាស់ប្តូរគំនិត និងសម្របសម្រួលការងាររបស់ពួកគេ។ នាយកសាលា ធ្វើការប្រជុំបុគ្គលិកទាំងអស់នៅពេលមានព័ត៌មានថ្មីត្រូវចែករំលែក ឬប្រធានបទផ្សេងៗត្រូវពិភាក្សា។ ការអភិវឌ្ឍ និងថែទាំបរិស្ថានការងារប្រកបដោយសុខដុម គឺជាធាតុដ៏សំខាន់ដើម្បីទទួលបានមិត្តរួមការងារដែលជោគជ័យ។ ការបង្កើតការគោរពក្នុងចំណោមគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលាលើកកម្ពស់បរិស្ថានការងារវិជ្ជមាន។ តាមដានការរៀនរបស់សិស្ស និងផ្តល់ដំបូន្មាន ព្រមទាំងលើកទឹកចិត្តក៏ជាកិច្ចការសំខាន់នៃការងាររបស់គ្រូបង្រៀនផងដែរ។ គ្រូបង្រៀន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ នៅវិទ្យាល័យតម្រូវឱ្យផ្តល់របាយការណ៍វាយតម្លៃសិស្ស និងចំណាត់ថ្នាក់ដល់គណៈគ្រប់គ្រងសាលាឱ្យបានទៀងទាត់។

គ្រូបង្រៀនកុំព្យូទ័រត្រូវបន្តធ្វើបច្ចុប្បន្នភាពបំណិនរបស់ពួកគេឱ្យទាន់សម័យជានិច្ចដោយបន្តការអភិវឌ្ឍខ្លួនឯង និងការស្រាវជ្រាវផ្ទាល់ខ្លួន។ ដោយសារតម្រូវការដើម្បីឱ្យទាន់នឹងសម័យកាលបច្ចេកវិទ្យា ក្រសួងបម្រុងទុកកុំព្យូទ័រ និងសម្ភារៈមួយចំនួនសម្រាប់គ្រូបង្រៀន ក៏ដូចជានៅលើទំព័រនៃការអប់រំអេឡិចត្រូនិច ដើម្បីធ្វើការស្រាវជ្រាវ និងរៀនដោយខ្លួនឯងនៅតាមសាលារបស់ពួកគេ។ គ្រូបង្រៀនក៏អាចប្រើសម្ភារៈផ្ទាល់ខ្លួនរបស់ពួកគេសម្រាប់ការរៀនដោយខ្លួនឯងបានផងដែរ។

នៅចុងបញ្ចប់ គ្រូបង្រៀនភាគច្រើនដឹងថាពេញចិត្តលក្ខខណ្ឌការងារពីព្រោះពួកគេរៀនគ្រប់គ្រងកាលវិភាគរបស់ពួកគេរាល់ពេល និងបង្កើតនីតិវិធីដែលដំណើរការសម្រាប់ពួកគេ។ ពួកគេនៅតែបានលើកទឹកចិត្តដោយមានភាពបត់បែន និងធ្វើឱ្យសិស្សរបស់ពួកគេទទួលបានជោគជ័យនៅពេលអនាគត។

តើអ្នកចង់ក្លាយជាគ្រូបង្រៀនទេ ? ប្រសិនបើអ្នកចង់បង្រៀនសិស្សនៅវិទ្យាល័យ វាមានសារៈសំខាន់ដែលអ្នកបង្ហាញភាពរីករាយ និងរៀនពីវិធីលើកទឹកចិត្តសិស្សឱ្យរៀនដោយខ្លួនឯង។ ជាមួយនឹងបទពិសោធន៍ អ្នកក៏អភិវឌ្ឍការយល់ដឹងច្បាស់អំពីបំណិនដែលពួកគេត្រូវការដើម្បីទទួលបានភាពជោគជ័យ។ ក្នុងនាមជាគ្រូបង្រៀន អ្នកមានទំនួលខុសត្រូវក្នុងការផ្តល់ការអប់រំដល់សិស្ស ហើយអ្នកត្រូវធ្វើឱ្យអស់ពីសមត្ថភាពដើម្បីណែនាំពួកគេឱ្យទទួលបានអនាគតប្រកបដោយផ្លែផ្កា។ ចំណេះដឹងបច្ចេកទេសរបស់អ្នកគឺសំខាន់ ប៉ុន្តែវាមិនសំខាន់ដូចឥរិយាបថដែលចង់ជួយសិស្សឱ្យទទួលបានជោគជ័យក្នុងជីវិតនោះទេ។

# មេរៀនសង្ខេប

គ្រូបង្រៀនគឺត្រូវបង្រៀន ជួយគាំទ្រ ពិនិត្យមើល និងកត់ត្រាវឌ្ឍនភាពរបស់សិស្ស។ ពួកគេក៏ត្រូវរៀបចំកិច្ចតែងការបង្រៀនជាមុនដោយអនុវត្តតាមសៀវភៅសិក្សាគោល និងគោលបំណងរបស់កម្មវិធីសិក្សានីមួយៗ ដោយប្រាកដថាកម្មវិធីសិក្សានឹងបញ្ចប់តាមកាលវិភាគ ហើយសិស្សរៀនពីសម្ភារៈទាំងនោះ។ ចំនួនគ្រូបង្រៀនមុខវិជ្ជា បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ នឹងកើនឡើង ដោយសារមានសាលារៀន និងបន្ទប់រៀនជាច្រើននឹងត្រូវបានបំពាក់ដោយកុំព្យូទ័រ និងការប្រើប្រាស់បច្ចេកវិទ្យាកាន់តែទូលំទូលាយក្នុងសាលារៀន។ នេះមានន័យថាឱកាសការងារថ្មីៗកំពុងតែបើកសម្រាប់វិស័យអប់រំបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។

គ្រូបង្រៀនមុខវិជ្ជា បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ នៅកម្រិតវិទ្យាល័យត្រូវតែបញ្ចប់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ឬផ្នែកដែលទាក់ទង និងសិក្សាមួយឆ្នាំបន្ថែមទៀតនៅវិទ្យាស្ថានជាតិអប់រំ ដើម្បីទទួលបានសញ្ញាបត្រជាផ្លូវការដែលចេញដោយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីចេញទៅបង្រៀនជាផ្លូវការ។ គ្រូបង្រៀន ទាំងអស់តម្រូវឱ្យអនុវត្តតាមកម្មវិធីសិក្សាដែលបានកំណត់ជាមុនដោយក្រសួងសម្រាប់បង្រៀន ICT ។ ការប្រើប្រាស់កម្មវិធីជាភាសាខ្មែរ ( កម្មវិធីការិយាល័យភាសាខ្មែរ OpenOffice, លីនុច អ៊ីនធឺណិត កម្មវិធីអ៊ីមែល ) ដែលតម្រូវឱ្យបង្រៀនមុខវិជ្ជា បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ដល់សិស្សនៅតាមវិទ្យាល័យ។

បច្ចេកវិទ្យាដែលបានប្រើប្រាស់សព្វថ្ងៃនឹងហួសសម័យ ហើយនឹងត្រូវបានជំនួសដោយបច្ចេកវិទ្យាថ្មីៗ និងគួរឱ្យចាប់អារម្មណ៍។ គ្រូបង្រៀន ICT ត្រូវតែដើរឱ្យទាន់សម័យកាលបច្ចេកវិទ្យា ដូច្នេះពួកគេអាចចែករំលែកចំណូលចិត្ត និងចំណេះដឹងជាមួយសិស្ស។

គ្រូបង្រៀនដែលចំណានអនុវត្តបន្សំនៃបំណិនទន់ និងបំណិនរឹងនៅក្នុងថ្នាក់រៀន។ គ្រូបង្រៀន ICT ត្រូវតែមានចំណេះដឹងអំពីមុខវិជ្ជារបស់គេ ហើយពួកគេក៏ត្រូវតែដឹងពីវិធីផ្ទេរចំណេះដឹងនោះឱ្យសិស្សផងដែរ។ គ្រូបង្រៀនដែលចំណានលើកទឹកចិត្តសិស្ស និងជួយឱ្យពួកគេអភិវឌ្ឍបំណិនសម្រាប់ទីផ្សារការងារនាពេលបច្ចុប្បន្ន។



# លំហាត់

## លំហាត់ ១

ចូរធ្វើការជាក្រុមដើម្បីពិភាក្សាអំពីសំណួរដូចខាងក្រោម ហើយដាក់ចម្លើយរបស់អ្នកក្នុងថតឯកសារក្រុមរបស់អ្នក។ កុំប្រើឈ្មោះរបស់គ្រូបង្រៀនពិតប្រាកដ។ អ្នកនឹងត្រូវធ្វើបទបង្ហាញដល់ក្រុមផ្សេងនៅពេលចុងបញ្ចប់។

ក. ចូរគិតអំពីគ្រូបង្រៀនដែលអ្នកពេញចិត្ត។ តើគ្រូបង្រៀនដែលពេញចិត្តមានគុណភាពអ្វីខ្លះ ?

ខ. ចូរធ្វើការជាក្រុម បង្កើតបញ្ជីដែលមានឧទាហរណ៍ជាក់លាក់ពី ៥ ដល់ ៧ នៃគុណភាពរបស់គ្រូបង្រៀនដែលចំណានរបស់អ្នក។

គ. ចូរបង្ហាញចម្លើយរបស់អ្នកដល់ក្រុមផ្សេង។

## លំហាត់ ២

អ្នកបានសម្រេចចិត្តថាគោលបំណងការងាររបស់អ្នក គឺត្រូវក្លាយជាគ្រូបង្រៀន ICT នៅសាលារៀនចំណេះទូទៅ។ អ្នកដឹងថាវាចំណាយពេលយ៉ាងហោចណាស់ប្រាំឆ្នាំដើម្បីបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ និងនៅវិទ្យាស្ថានជាតិអប់រំ។ ក្នុងក្រុមរបស់អ្នក ពិភាក្សាសំណួរខាងក្រោម ហើយដាក់ចម្លើយរបស់អ្នកក្នុងថតឯកសារក្រុមរបស់អ្នក។

ក. តើហេតុអ្វីបានជាអ្នកចង់ក្លាយជាគ្រូបង្រៀន ?

ខ. ចូរពិភាក្សាជាមួយសមាជិកក្រុមរបស់អ្នកអំពីអ្វីជាការអប់រំ បទពិសោធន៍ បច្ចេកទេស និងបំណិនប្រាស្រ័យទំនាក់ទំនងដែលអ្នកត្រូវការដើម្បីសម្រេចគោលបំណងរបស់អ្នក។ រួមទាំងគុណភាពបន្ថែមដែលត្រូវការ។

គ. នៅក្នុងក្រុមរបស់អ្នក ពិភាក្សាអំពីបំណិនជាក់លាក់ដែលអ្នកគិតថាពិបាកបំផុតក្នុងការទទួលយកដើម្បីក្លាយជាគ្រូបង្រៀនមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមនាគមន៍ ដែលចំណាន។ ចូរពន្យល់

# សំណួរត្រិះរិះ

១. តើអ្វីជាគោលបំណងនៃការបង្រៀន ICT នៅវិទ្យាល័យ?

២. តើមានកត្តាអ្វីខ្លះធ្វើឱ្យមានការរីកចម្រើនក្នុងការបង្រៀន ICT នៅវិទ្យាល័យក្នុងប្រទេសកម្ពុជា?

៣. តើតម្រូវឱ្យមានការអប់រំអ្វីខ្លះដើម្បីក្លាយខ្លួនជាគ្រូបង្រៀន ICT នៅវិទ្យាល័យ?

៤. តើមានបំណិនអ្វីខ្លះដែលត្រូវការសម្រាប់គ្រូបង្រៀន ICT នៅវិទ្យាល័យ?

៥. តើអ្វីខ្លះជាបំណិនប្រាស្រ័យទំនាក់ទំនង និងបំណិនទន់ផ្សេងៗទៀតដែលត្រូវការដើម្បីក្លាយជាគ្រូបង្រៀន ICT ដែលចំណាន?

៦. តើអ្វីជាបរិស្ថានការងារសម្រាប់គ្រូបង្រៀន ICT នៅវិទ្យាល័យ?

# ផ្នែក ខ - ប្រសិទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងវិស័យអប់រំ

## ៣. គរុកោសល្យ និងបច្ចេកវិទ្យាព័ត៌មាន

គ្រូបង្រៀនធ្វើការងារច្រើនក្រៅពីការបង្រៀន។ បន្ថែមលើការបង្រៀនជាក់ស្តែង គ្រូបង្រៀនដែលចំណានត្រូវតែធ្វើផែនការ និងរៀបចំមេរៀន, អនុវត្តវិន័យរបស់សាលា ជួបជាមួយឪពុកម្តាយសិស្ស ប្រាស្រ័យទំនាក់ទំនងយ៉ាងទៀតទាត់ជាមួយនាយកសាលា និងបុគ្គលិកផ្សេងៗទៀត, រៀបចំបញ្ជីវត្តមាន, ដាក់ពិន្ទុ និងវាយតម្លៃការរីកចម្រើនរបស់សិស្ស ព្រមទាំងចំណាយពេលវេលាផ្ទាល់ខ្លួនដើម្បីអភិវឌ្ឍចំណេះដឹង និងបំណិនថ្មីៗ។ សព្វថ្ងៃ អ្នកដែលចង់ចាប់អាជីពជាគ្រូបង្រៀនត្រូវតែមានសមត្ថភាពមិនត្រឹមតែលើមុខវិជ្ជាជំនាញរបស់ខ្លួនប៉ុណ្ណោះទេ ថែមទាំងត្រូវចេះគ្រប់គ្រងថ្នាក់រៀន ធ្វើការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព រក្សាទុកកំណត់ត្រា និងចំណេះដឹងបង្រៀនបច្ចេកវិទ្យា។

នៅពេលគ្រូបង្រៀននៅវិទ្យាល័យធ្វើកិច្ចតែងការបង្រៀន ពួកគេរៀបចំមេរៀនដែលផ្តល់ខ្លឹមសារមេរៀនទាក់ទឹងនឹងកម្មវិធីសិក្សាលម្អិតដែលបានកំណត់ ធ្វើឱ្យមានការសប្បាយរីករាយជាមួយគ្នាក្នុងការរៀន និងធ្វើឱ្យសិស្សមានទំនាក់ទំនងយ៉ាងសកម្មនៅក្នុងថ្នាក់រៀន។ គ្រូបង្រៀនប្រើជំនួយក្នុងការបង្ហាញផ្សេងៗ សៀវភៅ រឿងរ៉ាវផ្សេងៗ និងលំហាត់ដែលមានអន្តរកម្មដើម្បីបង្កើនការចូលរួមរបស់សិស្សក្នុងការរៀន ព្រមទាំងប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាដែលអាចជួយឱ្យសិស្សទទួលបានគោលគំនិតបច្ចេកទេសមួយចំនួននៅក្នុងមេរៀន។ ដោយសារតែបច្ចេកវិទ្យាបន្តអភិវឌ្ឍជាផ្នែកមួយនៃការរីកចម្រើនក្នុងវិស័យអប់រំ គ្រូបង្រៀនទាំងអស់នឹងតម្រូវឱ្យមានបំណិនបច្ចេកវិទ្យាសម្រាប់ស្រាវជ្រាវ និងជាជំនួយការបង្រៀន ទោះបីពួកគេមិនមែនជាគ្រូបង្រៀនកុំព្យូទ័រក៏ដោយ។

គ្រូបង្រៀនត្រូវតែចងចាំជានិច្ចថាបច្ចេកវិទ្យាមិនបញ្ជាក់ថាមានគរុកោសល្យល្អប្រសើរនោះទេ។ គ្រូបង្រៀនដែលបង្កើតបទបង្ហាញដែលគ្រាន់តែបង្ហាញពាក្យក្នុងសៀវភៅ ឬគ្រាន់តែអានអត្ថបទនេះក្នុងថ្នាក់ក៏កំពុងប្រើបច្ចេកវិទ្យាដែរ ប៉ុន្តែពួកគេមិនបន្ថែមតម្លៃគរុកោសល្យណាមួយដល់វាទេ។

អាកប្បកិរិយាមិនឱ្យសិស្សទទួលយកបាន



# ៣.១. គោលវិធីគរុកោសល្យបង្រៀន

គ្រូបង្រៀនអាចអនុវត្តបច្ចេកទេសគរុកោសល្យតាមរយៈគោលវិធីចំនួនបីចំពោះការរៀនរបស់សិស្ស គឺ៖ គោលវិធីផ្អែកលើចំណេះដឹង, គោលវិធីសិស្សមជ្ឈមណ្ឌល និងគោលវិធីផ្អែកលើការវាយតម្លៃ។

- ជាមួយនឹងគោលវិធីផ្អែកលើចំណេះដឹង ទស្សនាទានបច្ចេកទេស និងការអនុវត្តរបស់ពួកគេត្រូវបានបង្រៀនជាផ្នែកនៃបំណិនវិជ្ជាជីវៈជាក់លាក់ដែលសិស្សនឹងអាចអនុវត្តក្នុងស្ថានភាពជាក់ស្តែង។ ឧទាហរណ៍ សិស្សមិនត្រឹមតែត្រូវបានបង្រៀនអំពីរបៀបវាយអក្សរប៉ុណ្ណោះទេ ពួកគេត្រូវបានបង្រៀនឱ្យធ្វើសេចក្តីព្រាង និងបន្ទាប់មកធ្វើទ្រង់ទ្រាយលិខិតជាក់ស្តែងដោយអនុលោមតាមការប្រើប្រាស់ដែលបានទទួលយក។

  គោលវិធីនេះនឹងបង្កើតចំណេះដឹងដែលត្រូវបានភ្ជាប់ទៅនឹងបំណិនវិជ្ជាជីវៈជាក់ស្តែងដែលសិស្សអាចត្រូវបានប្រើប្រាស់ដោយផ្ទាល់ និងដោយឯករាជ្យក្នុងបរិស្ថានវិជ្ជាជីវៈ។ ការដឹងពីរបៀបវាយអក្សរ និងធ្វើទ្រង់ទ្រាយអត្ថបទគឺជាបំណិនមូលដ្ឋានដ៏ល្អ ប៉ុន្តែពួកវាមិនអាចត្រូវបានប្រើប្រាស់ទេ ប្រសិនបើសិស្សមិនដឹងពីរបៀបធ្វើរចនាសម្ព័ន្ធលិខិត ឬអ្វីជាទម្រង់លិខិតដែលគេទទួលយកបាន។

- គោលវិធីសិស្សមជ្ឈមណ្ឌល គ្រូបង្រៀនតាមរយៈបច្ចេកទេសចូលរួមរបស់សិស្សដើម្បីប្រាកដថាមានការចូលរួមច្រើនជាងការបង្រៀនពួកគេផ្ទាល់ សិស្សត្រូវប្រឹងប្រែងរៀនពីសកម្មភាពផ្សេងៗដែលពួកគេអនុវត្តចំណេះដឹងភ្លាមដែលពួកគេបានទទួល។ គោលវិធីនេះគឺជាគោលវិធីដ៏សំខាន់ដើម្បីរៀនពីសមត្ថភាពវិជ្ជាជីវៈ និងការប្រាស្រ័យទាក់ទង ព្រមទាំងគោលគំនិតបច្ចេកទេស។ សិស្សត្រូវតែបានផ្តល់លំហាត់ត្រឹមត្រូវ និងឧបករណ៍គ្រប់គ្រាន់ដើម្បី រៀនពីបំណិនបច្ចេកទេសដោយខ្លួនឯង។

  ដើម្បីបង្កើនការពិភាក្សា និងដោះស្រាយបញ្ហា សិស្សត្រូវតែធ្វើការដោយសហការគ្នាជាក្រុមដែលមានបីនាក់ (ជាការល្អ បើមិនដូច្នេះទេគឺពីរ ឬបួននាក់)។ គំនិតផ្សេងៗរបស់ពួកគេជួយពង្រឹងការរៀនរបស់អ្នកផ្សេង ឱ្យពួកគេទម្លាប់ស្តាប់គណិតរបស់អ្នកផ្សេងដើម្បីទទួលបានគំនិតថ្មីៗ។ នៅក្នុងក្រុម សិស្សក៏អាចជួយសិស្សផ្សេងទៀតឱ្យស្វែងយល់ពីវិធីអនុវត្តបំណិនបច្ចេកទេស។ ដោយអនុវត្តចំណេះដឹងតាមរយៈលំហាត់បង្កើតអត្រាចងចាំខ្ពស់ជាងការចងចាំដែលបង្កើតដោយការបង្រៀនក្នុងថ្នាក់។



គំនិតពីរប្រសើរជាងគំនិតមួយ គំនិតបីប្រសើរ
ជាងគំនិតពីរ

គោលវិធីផ្អែកលើការវាយតម្លៃ មានន័យថាសិស្សអនុវត្តកិច្ចការផ្សេងៗដែលអនុញ្ញាតឱ្យគ្រូបង្រៀនវាយតម្លៃថាតើពួកគេបានរៀនប៉ុន្មាន ហើយកិច្ចការទាំងនេះក៏អនុញ្ញាតឱ្យសិស្សវាយតម្លៃដោយខ្លួនពួកគេផងដែរ ថាតើពួកគេបានបញ្ចប់គោលបំណងលំហាត់ដែរឬទេ។ ការដែលអាចវាយតម្លៃដោយខ្លួនឯង អាចនាំឱ្យសិស្សធ្វើការវិនិច្ឆ័យថាតើពួកគេបានអនុវត្តល្អប៉ុនណា ដោយជួយឱ្យពួកគេសន្មតការទទួលខុសត្រូវសម្រាប់ការរៀនរបស់ពួកគេ។

បច្ចេកវិទ្យាអាចត្រូវបានប្រើប្រាស់ដើម្បីជួយគាំទ្រដល់គោលវិធីទាំងបីនេះចំពោះគរុកោសល្យ ដោយជួយឱ្យសិស្សធ្វើការជាមួយគ្នាយ៉ាងជិតស្និទ្ធ ចូលប្រើប្រាស់ធនធានដែលពួកគេត្រូវការដើម្បីធ្វើការលើគម្រោងផ្ទាល់ខ្លួនរបស់ពួកគេ និងកំណត់កិច្ចការដែលអាចឱ្យសិស្សវាស់វែងដោយខ្លួនពួកគេផ្ទាល់។ ICT គឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពដើម្បីផ្តល់ការអប់រំ និងលើកកម្ពស់ផលិតភាពបង្រៀន ដោយជួយទាំងគ្រូបង្រៀន និងសិស្សក្នុងការស្រាវជ្រាវ និងរៀនសូត្ររបស់ពួកគេ។ នៅក្នុងប្រទេសកម្ពុជា ភាគរយគ្រូបង្រៀននៅសាលាវិទ្យាល័យតិចតួចកំពុងប្រើប្រាស់ ICT ដើម្បីជួយគាំទ្រការបង្រៀនក្នុងថ្នាក់។



បណ្ដាសាលារៀនដែលមានបន្ទប់កុំព្យូទ័រផ្ដល់វគ្គសិក្សាពីកុំព្យូទ័ររួចហើយដោយអនុវត្តតាមកម្មវិធីសិក្សា ICT ដែលបានអនុម័តដោយក្រសួង ហើយតួលេខនឹងកើនឡើងព្រោះថាមានសាលារៀនច្រើនទៀតត្រូវបានបំពាក់ដោយបន្ទប់កុំព្យូទ័រ។ បន្ថែមលើការរៀបចំសិស្សសម្រាប់ទីផ្សារការងារសព្វថ្ងៃ កម្មវិធីសិក្សាត្រូវបានរៀបចំដើម្បីធ្វើតេស្តបំណិន ICT ខុសៗគ្នាជាច្រើន និងជួយសិស្សក្នុងការសម្រេចចិត្តប្រសិនបើពួកគេចាប់អារម្មណ៍នឹងការងារ ICT ដូចជា ជាមួយកម្មវិធីសិក្សាដែលអ្នកកំពុងតែសិក្សា។ ការប្រើប្រាស់បទបង្ហាញជាស្លាយប្រាកដថាការផ្ដល់មេរៀនគឺដូចគ្នា និងលើកកម្ពស់ការចងចាំដោយសារតែទិដ្ឋភាពមើលឃើញក្នុងការរៀន។ លំហាត់សម្រាប់សិស្សតាមបែបសហការត្រូវបានបញ្ចប់ដោយប្រើប្រាស់មគ្គុទ្ទេសក៍ធនធានអេឡិចត្រូនិក ឬការស្រាវជ្រាវលើអ៊ីនធឺណិតដើម្បីអនុវត្តបំណិនបច្ចេកទេសដែលទាមទារសម្រាប់លំហាត់មួយចំនួន។

មានផលិតផល និងកម្មវិធី ICT ជាច្រើនប្រភេទដែលមានទំនាក់ទំនងនឹងការអប់រំដូចជា អ៊ីនធឺណិត, អ៊ីមែល, កម្មវិធីបញ្ចាំងស្លាយជាមួយ LCD , ម៉ាស៊ីនបោះពុម្ព, ម៉ាស៊ីនស្កេន, កុំព្យូទ័រលើតុ និងកុំព្យូទ័រយួរដៃ, មេរៀនបង្ហាញលើទូរទស្សន៍, សន្និសីទពីចម្ងាយ, ស៊ីឌី/ឌីវីឌី និងក្ដារខៀនអន្តរកម្ម។ ការស្រាវជ្រាវមួយចំនួនបានបង្ហាញថាផលប្រយោជន៍របស់បច្ចេកវិទ្យាចំពោះគុណភាពអប់រំ បើតាមរបាយការណ៍បង្ហាញថាទាំងគ្រូបង្រៀន និងសិស្សប្រើប្រាស់បច្ចេកវិទ្យាគឺលើកកម្ពស់ការរៀនសូត្ររបស់ពួកគេ។ ICT មានសក្ដានុពលដើម្បីផ្លាស់ប្ដូរ, បង្កើន , លើកកម្ពស់បំណិន ដើម្បីលើកទឹកចិត្ត និងភ្ជាប់ទំនាក់ទំនងរបស់សិស្ស ដើម្បីជួយឱ្យមានទំនាក់ទំនងបទពិសោធន៍នៅសាលារៀនចំពោះការបង្រៀន និងជួយឱ្យមានការផ្លាស់ប្ដូរនៅក្នុងសាលារៀន។ ICT អាចត្រូវបានប្រើដើម្បីបំប្លែងព័ត៌មានទៅជាចំណេះដឹង និងលើកកម្ពស់គុណភាពបង្រៀន និងរៀនរបស់សិស្ស។


ឧបករណ៍បញ្ចាំងស្លាយ

ក្ដារខៀនអន្តរកម្ម





ការរៀនពីចម្ងាយ និងការរៀនតាមអ៊ីនធឺណិត ត្រូវ ប្រើប្រាស់កុំព្យូទ័រដើម្បីអាចផ្តល់ការអប់រំដោយផ្ទាល់ ចំពោះសិស្សដែលមិនមានវត្តមាននៅក្នុងថ្នាក់រៀន ការរៀនទាំងនេះផ្តល់ផលប្រយោជន៍ចំពោះមនុស្សដែលមានផលលំបាក ដូចជាមនុស្សពិការដែលចង់បង្កើនចំណេះដឹង បំណិន និងឱកាសការងារ។ ឧទាហរណ៍ សិស្សនៅវិទ្យាល័យដែលមិនមានមធ្យោបាយធ្វើដំណើរទៅសាលារៀនដោយសារតែជិះលើកៅអីរុញអាចរៀននៅផ្ទះបាន ប្រសិនបើនៅផ្ទះមានកុំព្យូទ័រ។ ការរៀនតាមអ៊ីនធឺណិតក៏ផ្តល់ទីតាំងធ្វើតេស្តដែលពីកន្លែងផ្សេងៗបានផងដែរ សិស្សអាចធ្វើតេស្តពីកន្លែងណាមួយដែលមានអ៊ីនធឺណិត។

ICT ក៏អាចត្រូវបានប្រើប្រាស់ដើម្បីលើកកម្ពស់ការរៀនដោយលើកទឹកចិត្ត និងភ្ជាប់ទំនាក់ទំនងរបស់សិស្សក្នុងដំណើរការរៀនតាមរយៈបច្ចេកទេសផ្សេងៗ។ បច្ចេកវិទ្យាកុំព្យូទ័រត្រូវបានបង្ហាញថាមានប្រសិទ្ធភាព ក្នុងការអប់រំ និងក្នុងការអភិវឌ្ឍបំណិនភាសាសរសេររបស់សិស្ស។ វាជាបច្ចេកវិទ្យាមួយដែលបង្កើតអត្រារៀនសូត្រដែលអាចធ្វើឱ្យគ្រូបង្រៀនតិច ហើយអ្នករៀនអាចរៀនបានច្រើន។

# ៣.២. ការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន

ដូចអ្នកជំនាញវិជ្ជាជីវៈផ្សេងៗទៀតដែរ គ្រូបង្រៀនត្រូវបន្តការសិក្សាអំពីមុខវិជ្ជារបស់ពួកគេដើម្បីទទួលបានភាពជោគជ័យ ការបណ្តុះគំនិត និងទទួលបានបំណិន និងចំណេះដឹងថ្មីៗជានិច្ច។ ការប្រើប្រាស់ ICT ជាពិសេសជួយគាំទ្រសកម្មភាពអប់រំពីចម្ងាយ អាចបន្ថែមតម្លៃយ៉ាងច្រើនចំពោះការបណ្តុះបណ្តាលរបស់ពួកគេ។ នៅកន្លែងដែលមានហេដ្ឋារចនាសម្ព័ន្ធ ឱកាស ដើម្បីបង្កើតសហគមន៍គ្រូបង្រៀនដែលរៀនតាមអ៊ីនធឺណិតក៏មានដែរ។ សហគមន៍រៀនបែបនេះបើកផ្លូវ និងផ្តល់អំណាចដល់សិក្ខាកាមជាគ្រូ និងគ្រូបង្រៀនបច្ចុប្បន្នចែករំលែកបទពិសោធន៍ កម្មវិធីសិក្សា សម្ភារៈសិក្សា កំណត់សម្គាល់ក្នុងមេរៀន និងដើម្បីបង្កើតគម្រោងបែបសហការ។ ICT អាចត្រូវបានអនុវត្តយ៉ាងហោចណាស់លើបរិបទបណ្តុះបណ្តាលចំនួនបីគឺ៖ ការបណ្តុះបណ្តាលមូលដ្ឋាន, ធ្វើឱ្យប្រសើរឡើង និងបង្កើនបំណិនគរុកោសល្យ និងចំណេះដឹងលើខ្លឹមសារ និងការអភិវឌ្ឍវិជ្ជាជីវៈឥតឈប់ឈរ។

នៅក្នុងប្រទេសកម្ពុជា ហេដ្ឋារចនាសម្ព័ន្ធ ICT និងការតភ្ជាប់នៅតែមានកម្រិតសម្រាប់គ្រូបង្រៀនដើម្បីដើរឱ្យទាន់សម័យកាលបច្ចេកវិទ្យា ហើយក្រសួងអប់រំ យុវជន និងកីឡាទទួលស្គាល់អំពីតម្រូវការដើម្បីបន្តអភិវឌ្ឍចំណេះដឹង និងបំណិនរបស់គ្រូបង្រៀន។ នៅសាលារៀនមិនមានបន្ទប់កុំព្យូទ័រ គ្រូបង្រៀនអាចស្វែងយល់អំពី ICT ដោយចូលរួមសិក្ខាសាលា ឬសន្និសីទ ឬដោយរៀនវគ្គនេះនៅសាកលវិទ្យាល័យ ឬរៀនតាមអ៊ីនធឺណិត។ ហេដ្ឋារចនាសម្ព័ន្ធរបស់កម្ពុជា- សេវាកម្មដែលអនុញ្ញាត, ជួយទ្រទ្រង់ ឬបង្កើនជីវភាពរស់នៅនឹងពង្រីកឡើង ហើយនឹងផ្តល់មធ្យោបាយសម្រាប់គ្រូបង្រៀន និងសិស្សចូលប្រើប្រាស់ ICT កាន់តែច្រើន។

# ៤. ការវាយតម្លៃការសិក្សា

តើសិស្សរៀនបានគ្រប់គ្រាន់ហើយឬនៅ? តើគ្រូបង្រៀនអាចប្រាប់បានដោយវិធីណា? កម្មវិធីសិក្សាគរុកោសល្យ និងការវាយតម្លៃត្រូវតែបានរៀបចំឡើងដើម្បីឆ្លើយតបនឹងសំណួរទាំងពីរនោះ។ កម្មវិធីសិក្សាកំណត់សម្ភារៈដែលត្រូវសិក្សា គរុកោសល្យ គឺជាវិធីសាស្ត្របានប្រើសម្រាប់បង្រៀន ហើយការវាយតម្លៃគឺជាដំណើរការកំណត់ចំណេះដឹង និងបំណិនដែលសិស្សត្រូវមាន។ ទម្រង់ការវាយតម្លៃជាផ្លូវការសាមញ្ញបំផុតពីរដែលយកមកប្រើ គឺការវាយតម្លៃកំពុងរៀន និងការវាយតម្លៃលទ្ធផលបញ្ចប់។ ទម្រង់ទាំងពីរនេះគឺសំខាន់សម្រាប់វាស់វែងការរៀនសូត្ររបស់សិស្ស។

## ការវាយតម្លៃលទ្ធផលបញ្ចប់

ការវាយតម្លៃបញ្ចប់ គឺជាមធ្យោបាយទូទៅដើម្បីវាស់វែងលទ្ធផលរបស់សិស្សលើការធ្វើតេស្ត និងប្រឡង។ លទ្ធផលត្រូវបានវាស់វែងជាពិន្ទុ ឬភាគរយ។ ការប្រឡងតាមកុំព្យូទ័រមានជម្រើសច្រើន ឬសំណួរខុសត្រូវច្រើន ដែលអាចធ្វើដោយសិស្សម្នាក់នេះជាឧទាហរណ៍នៃការវាយតម្លៃលទ្ធផលបញ្ចប់។ ជាក្បួនទូទៅ ការផ្តោតលើការវាយតម្លៃលទ្ធផលបញ្ចប់គឺត្រូវវាយតម្លៃការរៀនសូត្ររបស់សិស្សនៅចុងបញ្ចប់មេរៀន ឬចុងបញ្ចប់នៃការបង្រៀនដោយប្រៀបធៀបសំណួរ និងចម្លើយជាមួយស្តង់ដារមួយចំនួន។ លទ្ធផលរបស់សិស្សត្រូវបានវាស់វែងតាមពេលវេលាជាក់លាក់សម្រាប់ធ្វើរបាយការណ៍ និងសម្រាប់ដាក់ពិន្ទុសិស្សតាមចំណាត់ថ្នាក់។ ការវាយតម្លៃលទ្ធផលបញ្ចប់ គឺជាទម្រង់ប្រកួតប្រជែងការសិក្សា ព្រោះសិស្សត្រូវខិតខំរៀនដើម្បីទទួលបានពិន្ទុខ្ពស់បំផុតតាមដែលអាចធ្វើបាន។

## ការវាយតម្លៃពេលកំពុងរៀន

ការវាយតម្លៃពេលកំពុងរៀន គឺជាដំណើរការដែលកំពុងកើតឡើង និងដោះស្រាយ។ លំហាត់ដែលអ្នកបញ្ចប់ក្នុងកម្មវិធីសិក្សាគឺជាឧទាហរណ៍នៃការវាយតម្លៃកំពុងរៀន។ អ្នកធ្វើការជាក្រុម ហើយគ្រូរបស់អ្នកអាចសង្កេតមើលការងាររបស់អ្នកបាន ក្នុងករណីជាច្រើនអ្នកអាចវាយតម្លៃវឌ្ឍនភាពផ្ទាល់របស់ខ្លួនឯង ដោយយល់ដឹងដោយខ្លួនឯងក្នុងមុខវិជ្ជាណាមួយដែលអ្នកត្រូវកែលម្អ។ ជាក្បួនទូទៅ ការផ្តោតលើការវាយតម្លៃពេលកំពុងរៀន គឺត្រូវពិនិត្យតាមដានការរៀនសូត្ររបស់សិស្ស ពិនិត្យមើលរបៀបដែលដំណើរការរៀនកំពុងអនុវត្តសម្រាប់សិស្សម្នាក់ៗ និងកំណត់មុខវិជ្ជាសម្រាប់កែលម្អ។ ការវាយតម្លៃពេលកំពុងរៀនត្រូវបានប្រើដើម្បីកែលម្អជាពិសេសចំពោះកិច្ចការរបស់សិស្សដែលបានព្យាយាមពីមុន ព្រោះថាគ្រូបង្រៀនអាចកំណត់ និងឆ្លើយតប បានយ៉ាងរហ័សចំពោះតម្រូវការសិស្ស។ ពីព្រោះសិស្សពាក់ព័ន្ធដោយផ្ទាល់ក្នុងការៀនទាំងអស់គ្នា និងវាយតម្លៃដោយខ្លួនពួកគេផ្ទាល់ ការវាយតម្លៃពេលកំពុងរៀន គឺជាទម្រង់រៀនសូត្របែបសហការនៃការវាយតម្លៃ។ វាមិនសូវប្រាកដដូចការវាយតម្លៃលទ្ធផលបញ្ចប់ទេ។

គ្រូបង្រៀនអាចបង្កើតសំណួរខ្លីៗ ការធ្វើតេស្ត និងទម្រង់វាយតម្លៃផ្សេងៗទៀតដោយប្រើប្រាស់កម្មវិធីកុំព្យូទ័រ។ កម្មវិធីមួយចំនួនគឺឥតគិតថ្លៃសម្រាប់គ្រូបង្រៀន ហើយកម្មវិធីមួយចំនួនតម្រូវឱ្យទិញ។ គ្រូបង្រៀនក៏អាចរកគំរូសំណួរសម្រាប់ការវាយតម្លៃពេលកំពុងរៀន និងការវាយតម្លៃលទ្ធផលបញ្ចប់លើអ៊ីនធឺណិតបានផងដែរ និងបន្ទាប់អាចជួយបង្កើតកិច្ចតែងការបង្រៀន និងរៀបចំសម្រាប់គរុកោសល្យ និងកម្មវិធីសិក្សា។

សិស្ស ទាំងអស់មិនមែនរៀនតាមវិធីដូចគ្នា ឬពេលវេលាដូចគ្នាទេ ហើយការវាយតម្លៃផ្សេងៗនឹងផ្តល់ឱ្យគ្រូបង្រៀននូវកម្មវិធីផ្សេងៗដើម្បីបំពេញតម្រូវការអប់រំសម្រាប់សិស្សម្នាក់ៗ សកម្មរបស់សិស្សម្នាក់ៗ, ជាដៃគូ, ក្រុមតូច និងក្រុមធំផ្តល់នូវប្រភពព័ត៌មានជាច្រើនសម្រាប់វាយតម្លៃ។ ដោយផ្តល់សកម្មភាពចម្រុះគ្នា ពេលខ្លះជាមួយការវាយតម្លៃលទ្ធផលបញ្ចប់ និងពេលខ្លះទៀតជាមួយការវាយតម្លៃពេលកំពុងរៀន គ្រូបង្រៀនត្រូវបណ្តុះបណ្តាលយ៉ាងល្អដើម្បីកំណត់ភស្តុតាងនៃការរៀនសូត្ររបស់សិស្ស។



# ៥. បច្ចេកវិទ្យាក្នុងថ្នាក់រៀន

ការរៀបចំផែនការសម្រាប់ការប្រើប្រាស់ ICT ប្រកបដោយប្រសិទ្ធភាពក្នុងការអប់រំទាមទារការយល់ដឹងពីសក្តានុពលរបស់បច្ចេកវិទ្យាដើម្បីបំពេញគោលបំណងអប់រំផ្សេងៗគ្នានិងបន្ទាប់មកសម្រេចចិត្តថាគោលបំណងណាមួយក្នុងចំណោមគោលបំណងទាំងនេះត្រូវបន្ត។ ការសម្រេចចិត្តនេះប៉ះពាល់នឹងជម្រើសបច្ចេកវិទ្យា និងស្ថានភាពប្រើប្រាស់សម្រាប់ការអប់រំ។ វាមានសារៈសំខាន់ដែលត្រូវចងចាំថាមិនមែនបច្ចេកវិទ្យាសំខាន់ទាំងស្រុងទេ ប៉ុន្តែគោលបំណងអប់រំគឺសំខាន់ជាងគេ។ បច្ចេកវិទ្យាក្នុងការអប់រំមានសារៈសំខាន់ជួយផ្លាស់ប្តូរបទពិសោធន៍បង្រៀនតាមបែបបច្ចេកវិទ្យាថ្មី និងផ្តល់ឱកាសល្អឱ្យសិស្សអភិវឌ្ឍបំណិនបច្ចេកទេស និងត្រិះរិះគិតរបស់ពួកគេ។

កាលពីមុន ជម្រើសការប្រើបច្ចេកវិទ្យាក្នុងការអប់រំនៅមានកម្រិត បរិក្ខាមានតម្លៃថ្លៃ និងត្រូវមានអ្នកបច្ចេកវិទ្យាជំនាញទើបអាចប្រើវាបាន។ សព្វថ្ងៃនេះបានផ្លាស់ប្តូរយ៉ាងឆាប់រហ័ស សិស្សបានឃើញមធ្យោបាយផ្សព្វផ្សាយផ្សេងៗរាល់ថ្ងៃ ហើយពួកគេពេញចិត្តនឹងការប្រើប្រាស់បច្ចេកវិទ្យាដែលបានកើនឡើងនេះក្នុងថ្នាក់រៀន។

បច្ចេកវិទ្យាបានប្រើប្រាស់ក្នុងការអប់រំ គឺជាបន្សំនៃផ្នែករឹង និងផ្នែកទន់ មធ្យោបាយផ្សព្វផ្សាយ និងប្រព័ន្ធផ្តល់។ នៅក្នុងមេរៀននេះ យើងនឹងមើលបច្ចេកវិទ្យាដែលត្រូវបានប្រើប្រាស់សាមញ្ញបំផុតក្នុងវិស័យអប់រំ៖

## ក. កម្មវិធីកុំព្យូទ័រសម្រាប់ធ្វើបទបង្ហាញ

កម្មវិធីកុំព្យូទ័រសម្រាប់ធ្វើបទបង្ហាញជួយគ្រូបង្រៀនបង្កើត និងបង្ហាញរូបភាព ឬធាតុផ្សេងៗ ដើម្បីជួយគាំទ្រដល់ការបង្រៀនរបស់ពួកគេ។ ការធ្វើបទបង្ហាញអាចរួមមាន អត្ថបទ, រូបភាព, សំឡេង ឬវីដេអូ។ កម្មវិធីប្រភេទនេះត្រូវបានប្រើប្រាស់ញឹកញាប់ក្នុងការធ្វើបទបង្ហាញផ្នែកពាណិជ្ជកម្ម ហើយគ្រូបង្រៀន ICT ប្រើប្រាស់វាយ៉ាងទៀងទាត់នៅពេលមានធនធាន។ មានកម្មវិធីសម្រាប់ធ្វើបទបង្ហាញពេញនិយមជាច្រើនដូចជា កម្មវិធីការិយាល័យពិព័រណ៍ ជាកម្មវិធីឥតគិតថ្លៃដែលត្រូវបានបកប្រែជាភាសាខ្មែរពេញលេញ។ កម្មវិធី Microsoft PowerPoint និងកម្មវិធី Keynote របស់ក្រុមហ៊ុនអេបផល (Apple) ក៏ជាកម្មវិធីសម្រាប់ធ្វើបទបង្ហាញដ៏ល្អផងដែរ ប៉ុន្តែពួកវាមិនមានជាភាសាខ្មែរទេ។ កម្មវិធីការិយាល័យពិព័រណ៍ ជាភាសាខ្មែរត្រូវបានបង្រៀនតាមសាលារៀន និងត្រូវបានប្រើប្រាស់ដោយរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាក្រុមហ៊ុនឯកជនផ្សេងៗទៀត។

គ្រូបង្រៀនដឹងថាការបង្ហាញរូបភាពជំនួយនៅពេលបង្រៀន គឺធ្វើឱ្យការរៀនកាន់តែល្អ និងចាប់អារម្មណ៍។ ជាមួយកម្មវិធីពិព័រណ៍ គ្រូបង្រៀនអាចបង្កើតស្លាយសាមញ្ញៗសម្រាប់ផ្តល់ខ្លឹមសារមេរៀនបានកាន់តែច្បាស់លាស់ និងទូលំទូលាយ។ ពួកគេអាចបង្កើតបទបង្ហាញជាពហុមេឌាដោយប្រើប្រាស់រូបភាព បែបផែនពិសេស និងចលនាបន្ថែមលើអត្ថបទ សៀវភៅបញ្ជី និងរូបថត។

បទបង្ហាញតាមធម្មតាត្រូវបានផ្តល់ឱ្យសិស្សដោយប្រើប្រាស់ឧបករណ៍បញ្ចាំងស្លាយ LCD។ បើសិនជាមិនមានឧបករណ៍បញ្ចាំងស្លាយក្នុងថ្នាក់រៀន សិស្សអាចមើលបទបង្ហាញនៅលើអេក្រង់

ម៉ូនីទ័រកុំព្យូទ័ររបស់ពួកគេនៅពេលគ្រូបង្ហាញមេរៀន។ សិស្សដែលចេះរបៀបប្រើប្រាស់កម្មវិធីវាយអត្ថបទអាចរៀនពីមូលដ្ឋានគ្រឹះនៃវិធីរៀបចំបទបង្ហាញបានយ៉ាងឆាប់រហ័ស។



## ខ) វើលវ៉ាយវេប (WWW)

បង្កើនការចូលប្រើប្រាស់អ៊ីនធឺណិតនៅសាលារៀនផ្តល់ឱកាសឱ្យគ្រូបង្រៀនចូលប្រើប្រាស់ធនធានព័ត៌មានដ៏ សំខាន់ៗ(បោះពុម្ព, ក្រាហ្វិក, រូបថត, សំឡេង និងវីដេអូ) ដែលពួកគេអាចប្រើដើម្បីបង្កើតចំណេះដឹង និងរៀបចំថ្នាក់រៀនរបស់ពួកគេ។ ធនធានឥតគិតថ្លៃនៅលើអ៊ីនធឺណិតរួមមាន កិច្ចតែងការបង្រៀន សន្លឹកកិច្ចការ កម្មវិធីពហុមេឌាអន្តរកម្ម និងសំណួរធ្វើតេស្ត។ ធនធានជាភាសាខ្មែរមានការកើនឡើងច្រើន ប៉ុន្តែសម្ភារៈដែលអាចប្រើប្រាស់ភាគច្រើនជាភាសាអង់គ្លេស។



សិស្សអាចប្រើប្រាស់អ៊ីនធឺណិតដើម្បីរកមើលព័ត៌មាន សិក្សាស្រាវជ្រាវបន្ថែមលើមុខវិជ្ជាបច្ចុប្បន្នរបស់ពួកគេ។ គ្រូអាចជួយឱ្យពួកគេចេះរកមើលព័ត៌មាន និងធនធានដែលពួកគេចង់បានដោយខ្លួនឯង ជួយរៀបចំពួកគេសម្រាប់ទីផ្សារការងារបច្ចុប្បន្ននៅក្នុងសង្គមព័ត៌មានវិទ្យា។ អ៊ីនធឺណិតក៏ត្រូវបានប្រើប្រាស់នៅសាកលវិទ្យាល័យដើម្បីចែករំលែកមេរៀន និងសម្ភារសិក្សាផ្សេងៗជាមួយសិស្ស។ នៅកម្រិតសាកលវិទ្យាល័យ សាស្ត្រាចារ្យចែករំលែកបទបង្ហាញក្នុងថ្នាក់រៀនតាមរយៈអ៊ីនធឺណិតដល់សិស្សជាញឹកញាប់ ព្រមទាំងបញ្ជីឯកសារយោងដែលសិស្សអាចប្រើប្រាស់បានក្នុងការសិក្សាស្រាវជ្រាវ។

## គ. សន្និសីទតាមវីដេអូ

សន្និសីទតាមវីដេអូគឺជាការតភ្ជាប់វីដេអូបន្តផ្ទាល់រវាងមនុស្សដែលស្ថិតនៅទីកន្លែងផ្សេងគ្នា និងពេលខ្លះក៏ពាក់ព័ន្ធការផ្ញើសារអត្ថបទ ឬចែករំលែកអេក្រង់កុំព្យូទ័រផងដែរ។ ការធ្វើសន្និសីទតាម

វីដេអូត្រូវបានប្រើប្រាស់ញឹកញាប់ក្នុងការប្រាស្រ័យទាក់ទងផ្នែកពាណិជ្ជកម្មជាលក្ខណៈអន្តរជាតិ ដូច្នេះ មនុស្សមិនចាំបាច់ត្រូវចេញពីការិយាល័យដើម្បីមកប្រជុំទេ។ វាក៏ត្រូវបានប្រើប្រាស់ផងដែរក្នុងសាកលវិទ្យាល័យដើម្បីអនុញ្ញាតឱ្យសិស្សចូលរួមក្នុងថ្នាក់ដែលធ្វើឡើងនៅទីកន្លែងផ្សេងណាមួយ។ មិនដូចនឹងការថតវីដេអូក្នុងថ្នាក់ ហើយបន្ទាប់មកចែកចាយវាទេ ការធ្វើសន្និសីទតាមវីដេអូអនុញ្ញាតឱ្យសិស្សចូលរួមដោយផ្ទាល់ពីចម្ងាយ ដូច្នេះពួកគេអាចសួរសំណួរ និងទាក់ទងជាមួយសិស្សផ្សេងៗទៀតនៅទីកន្លែងផ្សេងគ្នា។

ការធ្វើសន្និសីទតាមវីដេអូលែងត្រូវការបរិក្ខាពិសេសៗទៀតហើយ វាអាចធ្វើបានជាមួយកុំព្យូទ័រដែលមានភ្ជាប់កាមេរ៉ា និងមីក្រូហ្វូន ហើយក្រុមហ៊ុនពាណិជ្ជកម្មផ្តល់កម្មវិធីសម្រាប់ធ្វើសន្និសីទតាមវីដេអូជាមូលដ្ឋានដោយឥតគិតថ្លៃ។ ចំពោះកម្មវិធីស្មុគស្មាញខ្លាំងដែលពាក់ព័ន្ធនឹងការចូលមើលអេក្រង់កុំព្យូទ័ររបស់អ្នកចូលរួមផ្សេងទៀតក្នុងការធ្វើសន្និសីទតាមវីដេអូអាចរកបានដោយទិញ។

## ឃ. អ៊ីមែល និងការផ្ញើសារអត្ថបទ

ចំពោះយុវជនដែលយល់ដឹងអំពីបច្ចេកវិទ្យាអាចពេញចិត្តការប្រាស្រ័យទាក់ទងជាមួយមិត្តភ័ក្តិដោយការផ្ញើសារជាអត្ថបទ សារខ្លី SMS ឬការផ្ញើសារភ្លាមៗរាល់ថ្ងៃ អ៊ីមែលត្រូវបានប្រើសម្រាប់ការប្រាស្រ័យទាក់ទងជាលក្ខណៈអាជីព។ អ៊ីមែលអាចត្រូវបានប្រើប្រាស់សម្រាប់ប្រាស្រ័យទាក់ទង និងសម្របសម្រួលក្នុងចំណោមគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលា ដើម្បីរៀបចំកាលវិភាគប្រជុំ, ចែករំលែកធនធានអប់រំ។ ជាមួយអ៊ីមែលអាចផ្ញើឯកសារភ្ជាប់, គ្រូបង្រៀន និងសិស្សអាចបង្កើតបញ្ជីសំបុត្ររួមដើម្បីបង្កើតជាសហគមន៍សម្រាប់ការចែករំលែក និងការរៀនសូត្រពីគ្នាទៅវិញទៅមក។

ជាមួយនឹងការកើនឡើងយ៉ាងឆាប់រហ័សនៃទូរសព្ទទំនើប គ្រូបង្រៀនជាច្រើនអាចចូលមើលព័ត៌មានយ៉ាងងាយស្រួលពីទូរសព្ទរបស់ពួកគេ ព្រមទាំងប្រើប្រាស់អ៊ីមែលនៅពេលដែលមានការតភ្ជាប់អ៊ីនធឺណិត។ ការផ្ញើសារអត្ថបទក៏អាចជាមធ្យោបាយក្នុងការអប់រំនាពេលអនាគតផងដែរប្រសិនបើវាបញ្ជាក់ថាមានផលប្រយោជន៍សម្រាប់បង្កើនអន្តរកម្មទាក់ទងនឹងការរៀនសូត្រ។



## ង. កម្មវិធីគ្រប់គ្រងសម្រាប់សាលារៀន

កម្មវិធីគ្រប់គ្រងសម្រាប់សាលារៀនត្រូវបានប្រើដើម្បីតាមដានវត្តមានរបស់សិស្ស និងដើម្បីគ្រប់គ្រងការរៀន និងការវាយតម្លៃរបស់សិស្ស។ កម្មវិធីធ្វើការគណនា និងធ្វើរបាយការណ៍ដែលចាំបាច់ទាំងអស់ដោយអនុញ្ញាតឱ្យគ្រូបង្រៀនផ្តោតតែលើការបង្រៀនប៉ុណ្ណោះ។

## ច. ឧបករណ៍អេឡិចត្រូនិកដែលជួយគាំទ្រ

មានឧបករណ៍អេឡិចត្រូនិកផ្សេងៗជាច្រើនដែលអាចធ្វើឱ្យការប្រើប្រាស់បច្ចេកវិទ្យាកាន់តែមានប្រសិទ្ធភាព។ ឧទាហរណ៍រួមមាន ឧបករណ៍បញ្ចាំងស្លាយ LCD ម៉ាស៊ីនបោះពុម្ព ម៉ាស៊ីនស្កេន ក្តារខៀនអន្តរកម្ម និងទូរសព្ទចល័ត។ ឧបករណ៍ LCD ប្រហែលជាផ្នែកសំខាន់បំផុតនៃបរិក្ខានេះ ព្រោះថាវាអនុញ្ញាតចែករំលែកមាតិកាមេរៀនជាមួយសិស្ស។

ទូរសព្ទចល័ត អាចត្រូវបានប្រើប្រាស់ដើម្បីថតរូប, ថតវីដេអូ និងថតសំឡេង។ ធាតុទាំងអស់នេះអាចត្រូវបានបញ្ចូលក្នុងគម្រោងរបស់សាលារៀន។




ក្តារខៀនអន្តរកម្ម គឺជាផ្ទៃបង្ហាញដ៏ធំដែលភ្ជាប់ទៅនឹងជញ្ជាំងដែលតភ្ជាប់ជាមួយកុំព្យូទ័រ។ ឧបករណ៍បញ្ចាំងបង្ហាញផ្ទៃតុកុំព្យូទ័រលើផ្ទៃរបស់ក្តារខៀនអន្តរកម្មដែលអ្នកប្រើគ្រប់គ្រងកុំព្យូទ័រដោយការសរសេរ ឬចង្អុលឧបករណ៍។ អ្វីៗផ្សេងទៀតដែលអាចត្រូវបានធ្វើលើម៉ូនីទ័រកុំព្យូទ័រអាចត្រូវបានចម្លងលើក្តារខៀនអន្តរកម្ម បច្ចេកវិទ្យានេះធ្វើឱ្យមានការប្រើប្រាស់កុំព្យូទ័រយ៉ាងមានអន្តរកម្មសម្រាប់សិស្សក្នុងថ្នាក់រៀន។ ក្តារខៀនអន្តរកម្មត្រូវបានប្រើប្រាស់ភាគច្រើននៅសាកលវិទ្យាល័យ និងការងារពាណិជ្ជកម្មឯកជន។ក្នុងករណីខ្លះពួកវាជំនួសការប្រើប្រាស់ក្តារខៀនដែលសរសេរដោយដីស ឬហ្វឺត។ ប៉ុន្តែវាមានតម្លៃថ្លៃ និងងាយខូច ដែលគ្រូបង្រៀនត្រូវតែបានបណ្តុះបណ្តាលយ៉ាងពិសេសដើម្បីបង្កើតមេរៀនដោយប្រើប្រាស់ពួកបច្ចេកវិទ្យានេះយ៉ាងមានប្រសិទ្ធភាព។

## មេរៀនសង្ខេប

ICT ដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយគ្រូបង្រៀន និងសិស្សសម្រេចបានគោលបំណងសិក្សាកាន់តែប្រសើរថែមទៀត ហើយវាក៏ជួយត្រៀមលក្ខណៈសិស្សសម្រាប់ការងារក្នុងពិភពឌីជីថលផងដែរ។ នៅក្នុងថ្នាក់រៀន ICT សិស្សប្រើប្រាស់កុំព្យូទ័រ និងរៀនតាមរយៈស្លាយជំនួយ និងលំហាត់អន្តរកម្ម។ គ្រូបង្រៀន ICT បន្តអភិវឌ្ឍវិជ្ជាជីវៈរបស់ពួកគេដើម្បីដើរទាន់ការការវិវឌ្ឍនៃបច្ចេកវិទ្យាទំនើប ដើម្បីមានលទ្ធភាពចែករំលែកចំណេះដឹង និងបំណិនថ្មីៗជាមួយសិស្ស។

គ្រូបង្រៀន ICT អនុវត្តគោលវិធីផ្អែកលើចំណេះដឹង គោលវិធីសិស្សមជ្ឈមណ្ឌល និងផ្អែកលើការវាយតម្លៃចំពោះការរៀនរបស់សិស្ស។ នៅពេលពួកគេវាយតម្លៃសិស្ស ពួកគេប្រើទាំងការវាយតម្លៃពេលកំពុងរៀន និងការវាយតម្លៃលទ្ធផលបញ្ចប់ដើម្បីកំណត់កម្រិតនៃការរៀនសូត្រ។

បច្ចុប្បន្នមានឧបករណ៍បច្ចេកវិទ្យាជាច្រើន ដូចជាកម្មវិធីធ្វើបទបង្ហាញ កម្មវិធីពហុមេឌា អ៊ីនធឺណិត អ៊ីមែល និងទូរសព្ទចល័ត។ ការវិវឌ្ឍទៅមុខជារៀងរាល់ថ្ងៃ ធ្វើឱ្យឧបករណ៍បច្ចេកទេសថ្មីៗត្រូវបានបន្តអភិវឌ្ឍផងដែរ និងជួយសម្រួលដល់ការសិក្សា និងជីវិតរស់នៅរបស់យើង។

# លំហាត់

## លំហាត់ ៣

ក្រុមរបស់អ្នកនឹងបង្កើតស្លាយពីរដើម្បីប្រើក្នុងការធ្វើបទបង្ហាញអំពី "ការរៀនបែបសហការ" បន្ទាប់មកអ្នកនឹងបង្ហាញស្លាយរបស់អ្នកដល់ក្រុមផ្សេង។ អ្នកនឹងប្រើកម្មវិធីការិយាល័យ ពិព័រណ៍ដើម្បីបង្កើតស្លាយរបស់អ្នក។ អ្នកអាចប្រើរូបភាព និងក្រាហ្វិក ព្រមទាំងអត្ថបទ។ រក្សាទុកស្លាយរបស់អ្នកក្នុងថតឯកសារក្រុមរបស់អ្នក។

១. ចូរពិភាក្សាសំណួរជាមួយសមាជិកក្រុមរបស់អ្នក និងកត់ត្រាគំនិតផ្សេងៗមុនពេលចាប់ផ្ដើមបង្កើតស្លាយ។ សំណួរត្រូវពិភាក្សាមុនពេលបង្កើតមាន៖
   ក. តើការរៀនជាក្រុមក្នុងមេរៀននេះមានតម្លៃសម្រាប់លំហាត់នៅចុងបញ្ចប់មេរៀនដោយវិធីណា? តើវាធ្វើឱ្យការរៀនកាន់តែមានផលិតភាពដែរឬទេ? កាន់តែមានការច្នៃប្រឌិតដែរឬទេ?
   ខ. តើអ្នកចូលចិត្តអ្វីអំពីការរៀនជាក្រុម? តើការរៀនជាក្រុមលើកទឹកចិត្តអ្នកឱ្យស្វែងយល់បន្ថែមអំពីប្រធានបទដែរឬទេ? ចូរពន្យល់ និងឱ្យឧទាហរណ៍។
   គ. តើពេលវេលាពេលរៀនដោយឯករាជ្យអាចមានប្រសិទ្ធភាពជាងការរៀនជាក្រុមដែរ ឬទេ? ប្រសិនបើមាន នៅពេលណា? ចូរឱ្យឧទាហរណ៍
   ឃ. ប្រសិនបើអ្នកចង់ ចូរបង្កើតសំណួរបន្ថែមដើម្បីជួយអ្នកជាមួយកិច្ចការនេះ។
២. ចូលកម្មវិធីការិយាល័យនៅលើផ្ទៃតុកុំព្យូទ័ររបស់អ្នក ហើយបើកកម្មវិធីធ្វើបទបង្ហាញ។
៣. សម្រេចចិត្តថាតើអត្ថបទ រូបភាព ឬក្រាហ្វិកអ្វីដែលអ្នកចង់ប្រើសម្រាប់ស្លាយទាំងពីររបស់អ្នក។
៤. ចូរបង្កើតស្លាយ១ បន្ទាប់មកបង្កើតស្លាយ២ ។ ចងចាំថាត្រូវធ្វើឱ្យមាតិកាសាមញ្ញដូច្នេះសិស្សផ្សេងទៀតនឹងអាចយល់យ៉ាងច្បាស់អំពីសាររបស់អ្នក។
៥. ចូរបង្ហាញស្លាយទាំងពីររបស់អ្នកដល់ក្រុមផ្សេង។

# សំណួរត្រិះរិះ

១. តើអ្វីជាគោលវិធីទាំងបីរបស់គ្រូបង្រៀន ICT សម្រាប់បង្រៀនសិស្ស? ចូរពន្យល់ពីគោលវិធីនីមួយៗ

២. តើជំនួយបង្ហាញដូចជាការធ្វើបទបង្ហាញតាមរយៈស្លាយលើកកម្ពស់ការរៀនដោយវិធីណា?

៣. តើ ICT អាចត្រូវបានប្រើប្រាស់សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀនដោយវិធីណា?

៤. តើការវាយតម្លៃពេលកំពុងរៀន និងការវាយតម្លៃលទ្ធផលបញ្ចប់ខុសគ្នាយ៉ាងដូចម្ដេច? តើហេតុអ្វីបានជាការវាយតម្លៃនេះមានសារៈសំខាន់?

៥. តើអ្វីជាគំរូបច្ចេកវិទ្យាទាំងប្រាំដែលប្រើប្រាស់សម្រាប់ការអប់រំសព្វថ្ងៃ?

# មេរៀនទី

# ១០

# បំណិនលក់កុំព្យូទ័រ និងការងារ

## នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពី៖

១. យល់ដឹងអំពីការងារនៅក្នុងផ្នែកលក់កុំព្យូទ័រ និងជំនួយបច្ចេកទេសការលក់។

២. កំណត់ និងយល់ដឹងពីតម្រូវការអប់រំ បំណិនបច្ចេកទេស បំណិនទំនាក់ទំនង និងលក្ខណសម្បត្តិផ្សេងៗដែលទាមទារដើម្បីក្លាយជាបុគ្គលិកនៃក្រុមលក់កុំព្យូទ័រដែលពូកែ។

៣. យល់ដឹងពីបរិស្ថានការងារ និងឱកាសការងារក្នុងផ្នែកលក់កុំព្យូទ័រ។

# ផ្នែក ក - ការងារក្នុងផ្នែកលក់ និងថែទាំកុំព្យូទ័រ

## ១. ការណែនាំអំពីទីផ្សារកុំព្យូទ័រ

ចរណៃត្រៀមរួចជាស្រេចដើម្បីធ្វើការជ្រើសរើសការងារក្នុងផ្នែកបច្ចេកវិទ្យាព័ត៌មាន។ នាងបានពិភាក្សារួចហើយជាមួយវិស្វករកុំព្យូទ័រ អ្នកអភិវឌ្ឍកម្មវិធីកុំព្យូទ័រ អ្នករចនា អ្នកគ្រប់គ្រងវេបសាយ អ្នកជំនាញបណ្ដាញសង្គម និងគ្រូបង្រៀន។ អ្នកជំនាញទាំងនោះដែលនាងបានសម្ភាសន៍ជាអ្នកកំពុងធ្វើការនៅក្នុងហាងកុំព្យូទ័រ។

ចរណៃចាំថាផានី ជាក្មេងស្រីដែលបានដំឡើងកុំព្យូទ័រ និងបណ្ដាញកុំព្យូទ័រនៅផ្ទះរបស់នាង ហើយនាងបានរៀបចំពេលដើម្បីពិភាក្សាជាមួយផានី។

ចរណៃ និងផានីជួបគ្នានៅព្រឹកថ្ងៃធ្វើការ នៅពេលដែលហាងស្ងាត់ភ្ញៀវ។ ចរណៃពន្យល់ទៅនាងពីអ្វីដែលនាងកំពុងធ្វើ ហើយផានីសម្រេចថាណែនាំសហសេវិករបស់នាងឱ្យចរណៃស្គាល់។

កំពុងដើរទៅក្នុងហាងបណ្ដើរ ផានីចាប់ផ្ដើមពន្យល់។ "នេះ គឺជាបន្ទប់ដាក់តាំងបង្ហាញ ហាងជាកន្លែងដែលអ្នកលក់ធ្វើការ។" ផានីដើរសំដៅទៅក្រុមអ្នកធ្វើការដែលមានគ្នាបីនាក់អង្គុយតុជុំគ្នាមួយ និងណែនាំពួកគេទៅចរណៃ។ "នេះឈ្មោះលីដា នេះសីណា និងនេះជាពិសិដ្ឋ ពួកគេជាបុគ្គលិកផ្នែកលក់។ នៅពេលអតិថិជនមក ឬហៅមក ពួកគេត្រូវស្ដាប់ដោយយកចិត្តទុកដាក់ដើម្បីយល់ពីអ្វីដែលអតិថិជនចង់បាន និងធ្វើការផ្ដល់យោបល់ ឬណែនាំពីផលិតផល ឬសេវាកម្មដែលនឹងបំពេញតម្រូវការរបស់អតិថិជននោះ។ ប្រសិនបើពួកគេមិនដឹងព័ត៌មានលម្អិតបច្ចេកទេសខ្លះៗទេនោះ ពួកគេនឹងត្រូវសួរនាំព័ត៌មានពីបុគ្គលិកដែលដឹងរឿងនេះដែលនៅជាន់ខាងលើ។ លីដា និងសីណាបានសិក្សាផ្នែកទីផ្សារ ហើយពិសិដ្ឋបានសិក្សាផ្នែកជំនួញ។" ក្រោយមកផានីបាននាំចរណៃទៅជាន់ខាងលើផ្នែកដែលធ្វើការ។ "នេះជាកន្លែងដែលខ្ញុំធ្វើការ។ ខ្ញុំធ្វើការផ្នែកជំនួយបច្ចេកទេស ហើយនេះជាក្រុមការងាររបស់ខ្ញុំ។ យើងជួយអ្នកលក់ឱ្យលក់ផលិតផល ឬសេវាកម្មដែលស្មុគស្មាញ និងបន្ទាប់មកយើងជួយដំឡើងផលិតផលទាំងនោះ ដំឡើងបណ្ដាញ និងធ្វើការងារបច្ចេកទេសផ្សេងៗដែលចាំបាច់សម្រាប់ក្រុមហ៊ុន។"

ធ្វើដំណើរទៅកន្លែងផ្សេងទៀត នាងបន្តទៀតថា "ហើយនេះជាក្រុមជួសជុល។ ពួកគេធ្វើការដោះស្រាយរាល់បញ្ហាកុំព្យូទ័រ និងគ្រឿងកុំព្យូទ័រផ្សេងៗនៅពេលវាខូច"។

ឃើញថាផានីផ្សារភ្ជាប់ទៅនឹងអ្វីដែលនាងបានឃើញទាំងអស់ វាបញ្ជាក់ច្បាស់ថាពួកគេកំពុងធ្វើការជាមួយគ្នាបានល្អខ្លាំងណាស់។ "យើងជាក្រុមតែមួយ" ផានីបាននិយាយ។ "យើងឧស្សាហ៍ទៅក្រៅកម្សាន្តសប្បាយជាមួយគ្នា។ នេះហើយជាកម្លាំងរួមមួយដែលយើងធ្វើការជួយគ្នាទៅវិញទៅមក។ យើងត្រូវជួយអ្នកលក់ដើម្បីឱ្យពួកគេអាចលក់អ្វីដែលក្រុមហ៊ុនផ្ដល់ឱ្យ ដើម្បីអាចឱ្យយើងមានការងារធ្វើគ្រប់គ្រាន់។ យើងតែងតែសួរគ្នាទៅវិញទៅមកដើម្បីរៀនសូត្រពីគ្នា។ រៀងរាល់សប្ដាហ៍យើងតែងតែរៀនពីផលិតផលថ្មីដែលនាំចូលមកក្នុងហាង ហើយយើងត្រូវបង្រៀនបន្តទៅអ្នកលក់តាមដែលអាចធ្វើទៅបាន ត្រូវចាំថាពួកគេមិនមែនជាអ្នកវិទ្យាសាស្ត្រកុំព្យូទ័រទេ។"

"ខ្ញុំចង់ធ្វើការនៅទីនេះ" នាងបន្ថែម។ "ខ្ញុំរៀនអ្វីដែលថ្មីរៀងរាល់ថ្ងៃ និងតែងតែជួបប្រទះការដំឡើងថ្មីៗ បង្រៀនខ្ញុំជានិច្ច។ ជាមួយនឹងអ្វីដែលបានរៀនសូត្រ និងរយៈពេលដែលខ្ញុំធ្វើការនេះ ខ្ញុំសង្ឃឹមថា

នឹងក្លាយជាប្រធានគ្រប់គ្រងបច្ចេកទេស និងជាអ្នកដែលរៀបចំចាត់ចែងការងារសម្រាប់ក្រុម និងធ្វើការសម្រេចចិត្តរឿងបច្ចេកទេសអ្វីមួយជាចម្បង!"។

បន្ទាប់ពីពិភាក្សាគ្នាប៉ុន្មាននាទីទៀតមក ចរណៃត្រូវទៅ ហើយនិយាយថា "អរគុណហើយផានី។ ខ្ញុំពិតជាកោតសរសើរនូវទឹកចិត្តរបស់អ្នកដែលបានពន្យល់ណែនាំខ្ញុំរឿងទាំងអស់នេះ ហើយខ្ញុំចូលចិត្តស្វែងយល់អំពីហាងរបស់អ្នក និងជួបសហសេវិករបស់អ្នក។"

កុំព្យូទ័រត្រូវបានលក់ដោយហាងជំនាញដែលលក់កុំព្យូទ័រ និងគ្រឿងកុំព្យូទ័រភាគច្រើន ក៏ដូចជាគ្រឿងឧបករណ៍បណ្តាញផងដែរ។ ជាទូទៅ ក្រុមហ៊ុនទាំងនេះក៏លក់នូវប្រភេទកម្មវិធីកុំព្យូទ័រ និងជួយដំឡើង និងកំណត់រចនាសម្ព័ន្ធបណ្តាញផងដែរ។

ហាងកុំព្យូទ័រត្រូវតែអាចផ្តល់នូវសេវាកម្មពេញលេញដល់អតិថិជនរបស់ពួកគេ អាចពន្យល់អ្វីមួយលើសពីកម្រិតចំណេះដឹងដែលអតិថិជនមាន និងភាពស្មុគស្មាញនៃគ្រឿងឧបករណ៍អេឡិចត្រូនិកដែលពួកគេកំពុងទិញ។ ចំពោះអតិថិជនដែលទិញកុំព្យូទ័រដំបូងរបស់ពួកគេ អ្នកលក់នឹងត្រូវណែនាំអតិថិជននោះនូវជម្រើសកុំព្យូទ័រនីមួយៗ។ បន្ទាប់មកកម្មវិធីកុំព្យូទ័រកូដចំហដែលពួកគេអាចដំឡើង និងប្រើនៅក្នុងកុំព្យូទ័រថ្មីនោះដោយមិនចាំបាច់ទិញអាជ្ញាប័ណ្ណ ក៏ដូចជាកម្មវិធីកុំព្យូទ័រដែលពួកគេអាចទិញដើម្បីអាចប្រើបាន។ ចំពោះអតិថិជនដែលមានចំណេះដឹងបច្ចេកទេសកម្រិតខ្ពស់ ហាងនឹងផ្តល់នូវគ្រឿងកុំព្យូទ័រដែលពួកគេចង់បាន និងអាចធ្វើការដំឡើងគ្រឿងកុំព្យូទ័រនោះជូនពួកគេតាមអ្វីដែលពួកគេចង់បាន ហើយពួកគេអាចនឹងធ្វើការសម្រេចចិត្តក្នុងការកំណត់គ្រឿងកុំព្យូទ័រនីមួយៗដោយខ្លួនឯង ឬសម្រេចថាត្រូវធ្វើវាដោយខ្លួនឯង។



# ១.១. ផលិតផល និងសេវាកម្ម

ហាងកុំព្យូទ័រមានជំនួញពីរសំខាន់ គឺលក់គ្រឿងកុំព្យូទ័រ និងផ្តល់នូវសេវាកម្មដែលទាក់ទងនឹងគ្រឿងកុំព្យូទ័រទាំងនោះ។ ជាធម្មតា សេវាកម្មមានដូចជាការដំឡើង ការកំណត់រចនាសម្ព័ន្ធ ការជួយគាំទ្រ ថែទាំ និងជួសជុលជាដើម។

## ១.១.១គ្រឿងសម្ភារកុំព្យូទ័រ

កុំព្យូទ័រមានការវិវឌ្ឍជានិច្ច។ រោងចក្រផលិតគ្រឿងស៊ីភីយូ (CPU) អង្គចងចាំ (Memory) ថាសរឹង (Hard Disk) និងគ្រឿងបន្លាស់កុំព្យូទ័រផ្សេងៗតែងតែណែនាំគ្រឿងកុំព្យូទ័រថ្មីៗ និងបច្ចេកវិទ្យាទំនើបដល់ទីផ្សារជាប្រចាំ។ ស៊ីភីយូ (CPU) ថ្មីប្រតិបត្តិលឿនជាង និងប្រើថាមពលអគ្គិសនីតិចជាង ចំណែកឯអង្គចងចាំ (Memory) ត្រូវបានច្នៃជាគ្រឿងតូចមួយ និងអាចផ្ទុកព័ត៌មានបានច្រើន រីឯថាសរឹងវិញអាចផ្ទុកទិន្នន័យបានកាន់តែច្រើនជាងមុនដែរ។ តាមការប៉ាន់ស្មានរៀងរាល់ ១៨ ខែ មនុស្សម្នាក់អាចទិញកុំព្យូទ័រដែលមានល្បឿនលឿនទ្វេដង និងអាចផ្ទុកព័ត៌មានទ្វេដងក្នុងចំនួនទឹកប្រាក់ដូចគ្នាដែលពួកគេទិញពីមុន។

ចំពោះហាងលក់កុំព្យូទ័រវិញការទិញនូវគ្រឿងឧបករណ៍កុំព្យូទ័រថ្មីៗ ធ្វើឡើងស្របពេលដែលការលក់ដាច់បានរហ័សនូវអ្វីដែលពួកគេមានក្នុងឃ្លាំង។ គ្រឿងកុំព្យូទ័រដែលលក់អត់ដាច់ទុកចោលយូរនឹងត្រូវហួសសម័យ ស្របពេលដែលគ្រឿងកុំព្យូទ័រមកថ្មីមានតម្លៃទាបជាង និងល្បឿនលឿនជាង។

ក្រុមលក់ត្រូវតែរៀនជាប្រចាំដើម្បីដឹងពីផលិតផលថ្មីរបស់ហាង និងលក្ខណៈពិសេស និងអត្ថប្រយោជន៍របស់វា។ បុគ្គលិកលក់ត្រូវតែយល់ដឹងពីអ្វីដែលអតិថិជនចង់បាន និងធ្វើការណែនាំនូវគ្រឿងកុំព្យូទ័រ ឬកុំព្យូទ័រដែលសមស្របតាមទឹកប្រាក់ដែលពួកគេមាន។ ពួកគេក៏ត្រូវយល់ដឹងអំពីគ្រឿងតភ្ជាប់កុំព្យូទ័រ និងមូលដ្ឋានគ្រឹះនៃការតភ្ជាប់បណ្តាញក្នុងមូលដ្ឋាន និងមួយណាដែលអតិថិជនត្រូវការ។ សម្រាប់ការលក់កុំព្យូទ័រដែលមានឯកទេសលើរឿងអ្វីមួយ អ្នកលក់នឹងមានការ



ជួយពីបុគ្គលិកបច្ចេកទេស ដែលនឹងកំណត់ថាកុំព្យូទ័រឯកទេសនោះ ឬបណ្ដាញស្មុគស្មាញនោះត្រូវរៀបចំយ៉ាងដូចម្ដេចជាមួយគ្រឿងដែលពួកគេត្រូវការ។

ក្រៅពីកុំព្យូទ័រផ្ទាល់ខ្លួន ហាងលក់កុំព្យូទ័រទ្រង់ទ្រាយធំ ឬឯកទេសនឹងលក់ជាម៉ាស៊ីនមេឯកសារ កុំព្យូទ័រដែលអាចប្រើដើម្បីរក្សាទុកឯកសាររបស់ក្រុមហ៊ុន ម៉ាស៊ីនមេប្រូកស៊ីដើម្បីគ្រប់គ្រងការប្រាស្រ័យទាក់ទងជំនួញ ឬម៉ាស៊ីនមេបណ្ដាញដែលភ្ជាប់ទៅអ៊ីនធឺណិត។ ការកំណត់រចនាសម្ព័ន្ធម៉ាស៊ីនមេគឺមានការស្មុគស្មាញច្រើនជាង ដោយសារវាអាចមានថាសរឹងពីរ ឬបី ឧបករណ៍ផ្គត់ផ្គង់ចរន្តពីរសម្រាប់សុវត្ថិភាព ក៏ដូចជាឧបករណ៍ទំនាក់ទំនងជាក់លាក់សម្រាប់ម៉ាស៊ីនមេ។ ម៉ាស៊ីនមេតែងតែជាកុំព្យូទ័រមានទំហំធំកម្លាំងខ្លាំងដែលអាចត្រូវបានដាក់ជាជង់លើគ្នាក្នុងសំណុំកុំព្យូទ័រមួយដែលគេហៅថា រេក (Rack) ជាទូរដាក់ឧបករណ៍ម៉ាស៊ីនមេ។ រេកត្រូវបានរក្សាទុកនៅក្នុងបន្ទប់ជាពិសេសដែលត្រជាក់ និងស្អាត ជៀសវាងមានធូលី ឬសីតុណ្ហភាពរំខានសកម្មភាពរបស់វា។

## ១.១.២ សេវាកម្ម

ក្រៅពីការលក់គ្រឿងកុំព្យូទ័រ ហាងកុំព្យូទ័រទ្រង់ទ្រាយធំ ឬមធ្យមក៏នឹងផ្ដល់នូវសេវាកម្ម ដែលជាផ្នែកសំខាន់មួយនៃជំនួញរបស់ខ្លួន។

សេវាកម្មជាមូលដ្ឋាន គឺការរចនា និងដំឡើងបណ្ដាញសម្រាប់អតិថិជនពីតូចទៅធំ ដូចជាការិយាល័យ អគារ ឬសណ្ឋាគារជាដើម។ ការងាររួមមានការរៀបចំដំឡើងខ្សែបណ្ដាញទាំងអស់នៅជុំវិញអគារ ដោយសម្រេចថាកន្លែងណាដែលគ្រឿងតភ្ជាប់បណ្ដាញកុំព្យូទ័រត្រូវដាក់ តភ្ជាប់វា និងប្រាកដថាអ្វីគ្រប់យ៉ាងដំណើរការតាមការរំពឹងទុករបស់អតិថិជន។

ខណៈដែលក្រុមហ៊ុនមានអតិថិជនច្រើនមានវិស្វករប្រព័ន្ធខ្លួនឯងដែលអាចជួយដំឡើង និងថែទាំកម្មវិធីកុំព្យូទ័រ រីឯក្រុមហ៊ុនធុនមធ្យម និងតូចដូចជាហាង ផ្សារទំនើបខ្នាតតូច និងការិយាល័យតូចមិនចាំបាច់ត្រូវមានអ្នកឯកទេសកុំព្យូទ័រ និងត្រូវពឹងផ្អែកលើហាងកុំព្យូទ័រ ឬអ្នកឯកទេសដើម្បីជួយពួកគេជួសជុល ឬថែទាំគ្រឿងឧបករណ៍កុំព្យូទ័ររបស់ពួកគេនៅពេលមានបញ្ហាជាមួយកម្មវិធីកុំព្យូទ័រ ឬគ្រឿងឧបករណ៍ផ្នែករឹងណាមួយដែលកើតមានឡើងនោះទេ។ ពួកគេអាចត្រូវការជំនួយ



ខ្លះៗពីហាងដើម្បីរៀនប្រើ កំណត់រចនាសម្ព័ន្ធ ឬដោះស្រាយបញ្ហាជាក់លាក់ណាមួយនៃកម្មវិធី ដែលពួកគេប្រើ ដែលអាចជាអ្វីមួយចាប់ពីការប្រើកម្មវិធីវាយអត្ថបទរហូតដល់កម្មវិធីជំនួញណាមួយ ដូចជាកម្មវិធីដែលបានប្រើដើម្បីជួយសម្រួលដល់ការលក់នៅក្នុងហាង ឬភោជនីយដ្ឋាន។

ការជួសជុលក៏ជាផ្នែកមួយនៃជំនួញកុំព្យូទ័រដែរ។ ជាធម្មតា ហាងកុំព្យូទ័រមានក្រុមការងារបច្ចេកទេសដែលមានសមត្ថភាពរកឃើញបញ្ហា និងដោះស្រាយបញ្ហាដែលកើតមានជាមួយកុំព្យូទ័រលើតុ។ សម្រាប់កុំព្យូទ័រយួរដៃវិញ សមត្ថភាពជួសជុលអាចអាស្រ័យលើគ្រឿងបន្លាស់ដែលមាន និងការជួសជុលអាចត្រូវធ្វើនៅហាងដែលជាអ្នកចែកចាយផ្លូវការនៃកុំព្យូទ័រម៉ាកនោះ ដូចជាកម្មវិធីម៉ាក Apple ត្រូវទៅហាងដែលលក់កុំព្យូទ័រម៉ាកនេះដើម្បីអាចធ្វើវាបាន។ កុំព្យូទ័រខ្លះអាចនៅមានសុពលភាពការធានាពីហាងនោះ ដូច្នេះរាល់ការជួលជុលមិនត្រូវបានគិតថ្លៃទេ។ វាក៏ដូចគ្នាដែរចំពោះករណីម៉ាស៊ីនបោះពុម្ព និងឧបករណ៍ ICT ផ្សេងៗទៀត។



# ២. ការងារនៅក្នុងផ្នែកលក់កុំព្យូទ័រ

ការងារនៅក្នុងផ្នែកនេះត្រូវបានបែងចែកជាពីរក្រុម៖ ការងារលក់ និងបច្ចេកទេស។ ខណៈដែលវាអាចមានអ្នកលក់តាមប្រភេទផ្សេងៗគ្នាអាស្រ័យតាមបទពិសោធន៍របស់ពួកគេ នៅក្នុងមេរៀននេះយើងនឹងសិក្សាតែតួនាទីពីរប៉ុណ្ណោះ៖ អ្នកលក់កុំព្យូទ័រ និងអ្នកគ្រប់គ្រងការលក់កុំព្យូទ័រ។

អ្នកលក់កុំព្យូទ័រត្រូវយល់ពីអតិថិជន និងយកចិត្តទុកដាក់ចំពោះអ្វីដែលអតិថិជនចង់បាន និងបង្ហាញពួកគេ ឬឱ្យយោបល់នូវជម្រើសផ្សេងៗដែលហាងមានសម្រាប់អាចដោះស្រាយតម្រូវការទាំងនោះ ដែលទាក់ទងនឹងផលិតផល និងសេវាកម្ម។ ពេលខ្លះអតិថិជនដឹងច្បាស់ពីអ្វីដែលពួកគេចង់បាន៖ កុំព្យូទ័រដែលមានព័ត៌មានលម្អិតច្បាស់លាស់ ឧទាហរណ៍ កុំព្យូទ័រយួរដៃ ឬម៉ាស៊ីនបោះពុម្ពដែលមានបុគ្គលិកលក្ខណៈច្បាស់លាស់។ ពេលខ្លះអតិថិជនមិនដឹងច្បាស់ពីអ្វីដែលពួកគេចង់ទិញ ប៉ុន្តែពួកគេដឹងច្បាស់ពីអ្វីដែលពួកគេចង់បាន ឬបញ្ហា ដោយសារបំណិនបច្ចេកទេសរបស់ពួកគេមិនគ្រប់គ្រាន់អាចយល់បានពីផលិតផល ឬសេវាកម្មដែលត្រូវដោះស្រាយ។ អ្នកលក់ដែលពូកែអាចលក់ដំណោះស្រាយឱ្យអតិថិជនទាំងនេះ នោះមានន័យថាពួកគេទទួលស្គាល់ និងដឹងពីសំណុំនៃផលិតផល និងសេវាកម្មដែលនឹងអាចដោះស្រាយតម្រូវការ ឬបញ្ហារបស់អតិថិជន។

លក្ខណសម្បត្តិចម្បងរបស់អ្នកលក់គឺមានបំណិនប្រាស្រ័យទាក់ទង និងទំនាក់ទំនងល្អប្រសើរជាមួយចំណេះដឹងច្បាស់ពីផលិតផល និងសេវាកម្មដែលគាត់លក់។ នៅក្នុងបំណិនប្រាស្រ័យទាក់ទងមានជំនាញពីរដែលសំខាន់ជាពិសេស គឺ៖ ការស្តាប់អតិថិជនដោយយកចិត្តទុកដាក់ដើម្បីយល់ច្បាស់ពីអ្វីដែលពួកគេចង់បាន ដោយមិនសន្មតអំពីតម្រូវការរបស់ពួកគេ និងអាចប្រាស្រ័យទាក់ទងជាមួយអតិថិជនម្នាក់ៗពីដំណោះស្រាយរបស់ហាងជាជម្រើសប្រសើរបំផុត ហើយដែលវានឹងពិតជាបំពេញតម្រូវការ ឬអាចដោះស្រាយបញ្ហារបស់ពួកគេបាន។

ជានិច្ចកាល បុគ្គលិកផ្នែកលក់កុំព្យូទ័រមិនមានប្រវត្តិការងារផ្នែកបច្ចេកវិទ្យាព័ត៌មានទេ ប៉ុន្តែពួកគេឆ្លងកាត់តាមរយៈបទពិសោធន៍ និងការបណ្តុះបណ្តាលជានិច្ច ពួកគេទទួលបានព័ត៌មានពីផលិតផល និងជំនាញកុំព្យូទ័រគ្រប់គ្រាន់ក្នុងការលក់ផលិតផល និងសេវាកម្មដែលអាចធ្វើឱ្យអតិថិជនពេញចិត្តតាមតម្រូវការរបស់ពួកគេ។ ខណៈដែលបុគ្គលិកផ្នែកលក់ត្រូវកំណត់ឱ្យយល់ដឹងច្បាស់ពីផលិតផលដែលលក់ វាក៏អាស្រ័យលើកម្រិតបច្ចេកទេសជាក់ស្តែងដែលហួសដែនកំណត់ចំណេះដឹងរបស់ពួកគេ នោះពួកគេត្រូវការជំនួយពីបុគ្គលិកបច្ចេកទេសរបស់ហាងដើម្បីអាចឆ្លើយសំណួររបស់អតិថិជន ឬអាចដោះស្រាយបញ្ហាស្មុគស្មាញរបស់អតិថិជនបាន។ អ្នកលក់ត្រូវតែដឹងច្បាស់ពីដែនកំណត់ចំណេះដឹងរបស់ពួកគេ និងមិនត្រូវផ្តល់ព័ត៌មានដែលពួកគេស្រពិចស្រពិល ដែលនេះអាចធ្វើឱ្យអតិថិជនសំខាន់ៗមានការខឹងសំបារ និងអាចបណ្តាលឱ្យបាត់បង់អតិថិជន ឬឱកាសជំនួញ។



ខណៈដែលអ្នកលក់មិនចាំបាច់ត្រូវមានកម្រិតវប្បធម៌សាកលវិទ្យាល័យ និយោជកពេញចិត្តជួលបុគ្គលិកដែលមានកម្រិតវប្បធម៌បរិញ្ញាបត្រ។ សញ្ញាបត្រក្នុងផ្នែកទីផ្សារ ជំនួញ ឬបច្ចេកវិទ្យាព័ត៌មានច្រើនតែគេចូលចិត្តជួល។ អ្វីដែលនិយោជកចង់បានពីកម្រិតទាំងនេះគឺលក្ខណសម្បត្តិអ្នកលក់ដែលមានការយល់ដឹងពីប្រតិបត្តិការជំនួញ របៀបដែលផលិតផលត្រូវបានបង្កើតឡើង និងដំណើរការរបស់វា ព្រមទាំងសារៈសំខាន់នៃសេវាកម្មអតិថិជន អនុញ្ញាតឱ្យពួកគេយល់ដឹងបានប្រសើរអ្វីដែលអតិថិជនចង់បាន។ គុណតម្លៃរបស់អ្នកលក់អាស្រ័យលើសមត្ថភាពរបស់ពួកគេក្នុងការស្តាប់ទៅអតិថិជន និងបង្ហាញផលិតផលដែលផ្តល់នូវដំណោះស្រាយល្អដល់អតិថិជន។ អតិថិជនដែលពេញចិត្តនឹងត្រឡប់មកហាងវិញនៅពេលពួកគេត្រូវការអ្វីមួយ និងការលក់ដូរដែលកើតឡើងម្តងហើយម្តងទៀតពិតជាមានសារៈសំខាន់ណាស់សម្រាប់ក្រុមហ៊ុនដើម្បីរកប្រាក់ចំណូល និងរីកចម្រើន។

អ្នកគ្រប់គ្រងផ្នែកលក់កុំព្យូទ័រ ទទួលបន្ទុកការលក់ទាំងអស់នៅក្នុងហាង គ្រប់គ្រងក្រុមការងារផ្នែកលក់ ធ្វើឱ្យប្រាកដថាពួកគេទទួលបានការបណ្តុះបណ្តាលប្រសើរ និងមានជំនួយចាំបាច់ចំពោះការលក់របស់ពួកគេ។ អ្នកគ្រប់គ្រងផ្នែកលក់ត្រូវដឹងពីអ្វីដែលអតិថិជនកំពុងត្រូវការ និងប្រាក់ប៉ុន្មានដែលពួកគេនឹងត្រូវចំណាយ ហាងនឹងប្រើចំណេះដឹងទាំងនេះដើម្បីទិញ និងផ្តល់នូវដំណោះស្រាយប្រសើរបំផុតសម្រាប់ពួកគេ។ អ្នកគ្រប់គ្រងផ្នែកលក់ត្រូវតែអាចទស្សន៍ទាយដឹងថាហាងនឹងអាចលក់ផលិតផលនីមួយៗបានចំនួនប៉ុន្មាននៅអំឡុងពេលណាមួយ និងគាត់ជាអ្នកសម្រេចចិត្តថាទំនិញណាត្រូវទិញស្តុក។ ដោយហេតុថាផលិតផល និងគ្រឿងសម្ភារកុំព្យូទ័រតែងតែផ្លាស់ប្តូរជាញឹកញាប់ ការទិញគ្រឿងសម្ភារទាំងនោះស្តុកទុកច្រើនពេកលើសពីតម្រូវការរបស់អតិថិជនក្នុងអំឡុងពេលណាមួយអាចនឹងធ្វើឱ្យទំនិញនោះសល់ក្នុងឃ្លាំងច្រើនហួសតម្រូវការដែលនឹងធ្វើឱ្យលំបាកក្នុងការលក់ចេញ។ ការទិញមិនគ្រប់គ្រាន់ក៏អាចបណ្តាលឱ្យមានស្ថានភាពមួយដែលហាងមិនមានទំនិញលក់គ្រប់គ្រាន់សម្រាប់អតិថិជន ដែលធ្វើឱ្យពួកគេមានអារម្មណ៍មិនល្អ បាត់បង់ឱកាសលក់ផលិតផល និងធ្វើឱ្យអតិថិជនមិនពេញចិត្ត ហើយពួកគេនឹងមិនត្រឡប់មកហាងរបស់យើងម្តងទៀតឡើយ ពួកគេនឹងទៅហាងដែលពួកគេដឹងថាទិញអ្វីដែល




ពួកគេត្រូវការបាន។ ដូច្នេះ អ្នកគ្រប់គ្រងការលក់ត្រូវតែធ្វើការទស្សន៍ទាយការលក់ផលិតផល និងសេវាកម្មនីមួយៗ ដោយប៉ាន់ស្មានថាហាងនឹងលក់បានប៉ុន្មានក្នុងមួយឆ្នាំ។ គាត់ត្រូវតែអាចជួយក្នុងការកំណត់តម្លៃលក់ផលិតផលនីមួយៗ ដោយគិតពិចារណាពីតម្លៃទិញចូល និងតម្លៃដែលត្រូវលក់ចេញឱ្យបានសមរម្យមួយនៅក្នុងទីផ្សារកម្ពុជា ដែលព័ត៌មានទាំងនេះអាចប្រើដើម្បីកំណត់ប្រាក់ចំណេញសម្រាប់ហាង។

ជាធម្មតា អ្នកគ្រប់គ្រងការលក់កុំព្យូទ័រមានកម្រិតវប្បធម៌បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកទីផ្សារ ឬធុរកិច្ច ក៏ដូចជាយ៉ាងហោចណាស់ត្រូវមានបទពិសោធន៍ប្រាំឆ្នាំក្នុងផ្នែកលក់។ ពួកគេជាអ្នកទំនាក់ទំនងដ៏ជំនាញ មានសមត្ថភាពបណ្ដុះបណ្ដាលបុគ្គលិករបស់ពួកគេអំពីរបៀបជួយយកចិត្តទុកដាក់អតិថិជន ស្ដាប់អតិថិជន និងផ្ដល់នូវដំណោះស្រាយត្រឹមត្រូវ ទទួលបានជំនួយពីបុគ្គលិកបច្ចេកទេសនៅពេលចាំបាច់។

ការងារបច្ចេកទេសនៅក្នុងហាងលក់កុំព្យូទ័រមានមុខតំណែងបីផ្សេងៗគ្នា៖ អ្នកជួសជុល អ្នកឯកទេសជំនួយបច្ចេកទេស និងអ្នកគ្រប់គ្រងបច្ចេកទេស។

អ្នកជួសជុលកុំព្យូទ័រទទួលកុំព្យូទ័រ និងគ្រឿងកុំព្យូទ័រទាំងឡាយណាដែលអតិថិជនគិតថាខូច ធ្វើការរកឱ្យឃើញនូវបញ្ហា កំណត់ពេលវេលាដែលត្រូវដោះស្រាយ ឬជួសជុលគ្រឿងសម្ភារនោះ និងអាចគិតពីតម្លៃដែលចំណាយក្នុងការជួសជុល។ ប្រសិនបើអតិថិជនសម្រេចថាការចំណាយលើការជួសជុលនោះប្រសើរជាងប្ដូរកុំព្យូទ័រថ្មី នោះអ្នកជួសជុលនឹងត្រូវធ្វើការជួសជុលគ្រឿងសម្ភារនោះតាមដែលអាចធ្វើទៅបាន។

អ្នកជួសជុលត្រូវតែមានចំណេះដឹងខ្លាំងលើផ្នែកកម្មវិធីកុំព្យូទ័រ និងគ្រឿងឧបករណ៍ផ្នែករឹង ហើយនឹងត្រូវតែមានសមត្ថភាពកំណត់បានពីប្រភពនៃបញ្ហា។ ក្រុមហ៊ុនចូលចិត្តជួលមនុស្សផ្នែកជួសជុលនេះដែលមានកម្រិតវប្បធម៌បរិញ្ញាបត្រក្នុងផ្នែកបច្ចេកវិទ្យាព័ត៌មាន (IT) ព្រោះពួកគេអាចដឹងបានថានិស្សិតផ្នែកនេះនឹងមានសមត្ថភាពយល់ដឹងបានប្រសើរចំពោះដំណើរការកុំព្យូទ័រ។ លក្ខណៈសម្បត្តិចម្បងរបស់អ្នកជួសជុលកុំព្យូទ័រដែលល្អ ត្រូវមានបទពិសោធន៍ជួសជុល សមត្ថភាពរកឃើញបញ្ហាបានលឿន និងសមត្ថភាពដោះស្រាយតាមវិធីត្រឹមត្រូវ។ ពេលខ្លះអ្នកជួសជុលដែលបានរៀនសូត្រដោយខ្លួនឯងតាមរយៈបទពិសោធន៍ជាច្រើនអាចមានសមត្ថភាពជាងអ្នកដែលមានសញ្ញាបត្របរិញ្ញាពីសាកលវិទ្យាល័យទៀត។ អ្នកជួសជុលកុំព្យូទ័រមានបំណងរៀនសូត្រពីអ្នកធ្វើការជាមួយគ្នា ដូច្នេះការធ្វើការជាក្រុមរួមគ្នាពិតជាមានសារៈសំខាន់ណាស់សម្រាប់ស្ថាប័នមួយ ព្រោះវាជាប្រភពចម្បងនៃការបណ្ដុះបណ្ដាល ជាឃ្លាំងចំណេះដែលមិនចេះរីងស្ងួត។ វាក៏អាចធ្វើទៅបានដែរក្នុងការប្រឡូកនៅក្នុងការងារនេះ



ដោយមិនមានបទពិសោធន៍ច្រើន ដោយធ្វើការសាមញ្ញៗនៅពេលចាប់ផ្តើមដំបូង និងបន្ទាប់មកតាមរយៈបទពិសោធន៍ អាចវិវឌ្ឍក្លាយជាអ្នកជួសជុលដ៏ចំណានមួយ។

ក្រៅពីចំណេះដឹងបច្ចេកទេស ជាមូលដ្ឋានគ្រឹះសម្រាប់អ្នកជួសជុលត្រូវមានសេចក្តីប្រាថ្នា និងសមត្ថភាពរៀនសូត្រពីអ្នកផ្សេងៗ និងស្តាប់ដោយយកចិត្តទុកដាក់ដើម្បីយល់ដឹងពីបញ្ហាដែលបានរៀបរាប់ដោយអតិថិជន ដោយមិនធ្វើការសន្មតថាពួកគេតែងតែដឹងបញ្ហាគ្រប់យ៉ាងនោះ។

អ្នកឯកទេសជំនួយផ្នែកបច្ចេកទេស ផ្តល់នូវជំនួយដល់អ្នកលក់ដោយជួយរៀបចំ និងផ្តល់នូវដំណោះស្រាយបច្ចេកទេសសមរម្យចំពោះបញ្ហារបស់អតិថិជន។ ជាផ្នែកនៃការងារនេះពួកគេរៀបចំបណ្តាញ កំណត់រចនាសម្ព័ន្ធគ្រឿងផ្នែករឹងដែលត្រូវដាក់ក្នុងកុំព្យូទ័រ ទៅតាមអ្វីដែលអតិថិជនចង់បាន កំណត់គ្រឿងសម្ភារអ្វីខ្លះដែលចាំបាច់ និងគ្រប់គ្រាន់សម្រាប់តម្រូវការរបស់អតិថិជនតាមស្ថានភាពកម្រិតការងាររបស់ពួកគេ ជួយកំណត់តម្លៃរបស់ផលិតផល និងសេវាកម្ម និងផ្តល់នូវមូលហេតុសមរម្យដល់អតិថិជនថាហេតុអ្វីពួកគេធ្វើការជ្រើសរើសវា។

អ្នកឯកទេសជំនួយផ្នែកបច្ចេកទេសក៏បំពេញកាតព្វកិច្ចដោះស្រាយចំពោះសេវាកម្មដែលហាងលក់ជូនអតិថិជន។ ការងាររបស់ពួកគេរួមមានការដំឡើងកុំព្យូទ័រ ធ្វើតេស្ត៍ ដំឡើងកម្មវិធីកុំព្យូទ័រ និងកំណត់រចនាសម្ព័ន្ធ។ ពួកគេក៏អាចធ្វើការដំឡើងបណ្តាញ ដែលរួមមានការដាក់ក្រាលខ្សែកាបបណ្តាញដែលចាំបាច់នៅក្នុងការិយាល័យ ឬអគារដែលកំពុងតភ្ជាប់បណ្តាញ ជួសជុលគ្រឿងឧបករណ៍បណ្តាញទាំងអស់តភ្ជាប់ និងកំណត់រចនាសម្ព័ន្ធឧបករណ៍ទាំងអស់ និងកុំព្យូទ័រតាមអ្វីដែលអតិថិជនត្រូវការ។

បុគ្គលិកជំនួយផ្នែកបច្ចេកទេសក៏ជួយថែទាំកុំព្យូទ័រ និងបណ្តាញរបស់អតិថិជនផងដែរ នៅពេលអតិថិជនស្នើ ឬតាមរយៈកិច្ចសន្យាថែទាំដែលអតិថិជនចំណាយប្រចាំខែ ឬថ្លៃឈ្នួលជួសជុលប្រចាំឆ្នាំ ហើយបុគ្គលិកជំនួយផ្នែកបច្ចេកទេសត្រូវតែដោះស្រាយបញ្ហាទាំងឡាយណាដែលអាចកើតមាននៅអំឡុងរយៈពេលនៃកិច្ចសន្យានេះ។ ប្រសិនបើអំឡុងកំពុងធ្វើការនេះ ពួកគេរកឃើញផ្នែកនៃឧបករណ៍ណាមួយខូច ពួកគេត្រូវយកវាឱ្យអ្នកជួសជុល។

ខណៈដែលនៅក្នុងហាងធំ អ្នកជួសជុល និងបុគ្គលិកជំនួយបច្ចេកទេសគឺមានតួនាទីខុសគ្នា តែដោយឡែកនៅក្នុងហាងតូចពួកគេជាក្រុមតែមួយ។ នៅក្នុងករណីដែលតួនាទីទាំងពីរនេះខុសគ្នា ពួកគេ



ធ្វើការកាន់តែជិតស្និទ្ធជាមួយគ្នាទាំងជំនាញ និងសមត្ថភាពដែលចាំបាច់ដើម្បីដោះស្រាយបញ្ហារបស់អតិថិជន។

បុគ្គលិកជំនួយផ្នែកបច្ចេកទេសធ្វើការយ៉ាងជិតស្និទ្ធជាមួយអតិថិជន។ ពួកគេត្រូវប្រាកដថាអ្វីដែលអតិថិជនចង់បាន និងតែងតែចងចាំជានិច្ចថាគុណភាពការងាររបស់ពួកគេជាការឆ្លុះបញ្ចាំងពីអ្វីដែលហាងកំពុងផ្តល់ឱ្យអតិថិជន។ ការងារដែលអន់ ឬធ្វេសប្រហែសនឹងបង្កើតរូបភាពអាក្រក់អំពីហាង ដោយឡែកចំពោះការងារដែលសមរម្យ ទៀងពេល និងយកចិត្តទុកដាក់នឹងធ្វើឱ្យហាងមានកេរ្តិ៍ឈ្មោះល្បីល្បាញ។



អ្នកគ្រប់គ្រងផ្នែកបច្ចេកទេសទទួលបន្ទុកការងារប្រតិបត្តិការផ្នែកបច្ចេកទេសទាំងអស់នៅក្នុងហាង និងគ្រប់គ្រងបុគ្គលិកជំនួយផ្នែកបច្ចេកទេស និងជួសជុលទាំងអស់។ ពួកគេត្រូវតែប្រាកដថាបុគ្គលិកបច្ចេកទេសទាំងអស់បន្តរៀនជានិច្ចចំពោះផ្នែកនៃឧបករណ៍ទាំងអស់ដែលហាងលក់ និងពួកគេអាចមានលទ្ធភាពជួសជុលវាផងដែរ។ អ្នកគ្រប់គ្រងផ្នែកបច្ចេកទេសត្រូវតែមានលទ្ធភាពវាយតម្លៃពីតម្រូវការចំនួនបុគ្គលិកប៉ុន្មានដែលត្រូវការក្នុងផ្នែកជួសជុល និងជំនួយបច្ចេកទេស និងថាតើពួកគេត្រូវធ្វើការជាមួយគ្នាយ៉ាងណា។

អ្នកគ្រប់គ្រងផ្នែកបច្ចេកទេសត្រូវតែប្រាកដថាហាងអាចធ្វើការងារបានទាំងអស់ដែលស្នើឱ្យធ្វើ។ ហាងត្រូវតែមានមិនត្រឹមតែបុគ្គលិកដែលចាំបាច់ប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងអាចមានសិទ្ធិចូលប្រើផ្នែកគ្រឿងបន្លាស់ដែលចាំបាច់ដើម្បីអាចជួសជុលកុំព្យូទ័រ ឬដំឡើងបាន។ វាមានសារៈសំខាន់ថានិយោជិតមានគ្រឿងសម្ភារៈទាំងអស់ដែលពួកគេត្រូវការដើម្បីអនុវត្តការងាររបស់ពួកគេដោយជោគជ័យ។

ជាធម្មតា អ្នកគ្រប់គ្រងផ្នែកបច្ចេកទេសនៅក្នុងហាងពីធុនមធ្យមទៅធំមានបទពិសោធន៍យ៉ាងហោចណាស់ប្រាំឆ្នាំក្នុងផ្នែកជំនួយបច្ចេកទេស និងភាគច្រើនមានបទពិសោធន៍ក្នុងការជួសជុលកុំព្យូទ័រ។ ពួកគេត្រូវមានទំនាក់ទំនងជានិច្ចជាមួយផ្នែកលក់ដើម្បីជួយដល់ពួកគេ ផ្តល់នូវបុគ្គលិកជំនួយបច្ចេកទេសនៅពេលណាដែលក្រុមអ្នកលក់ត្រូវការ។ អ្នកគ្រប់គ្រងបច្ចេកទេសក៏ត្រូវតែមានជំនាញគ្រប់គ្រង និងរៀបចំល្អប្រសើរដែរ ដោយការគ្រប់គ្រងធនធានមនុស្សទាំងអស់ដែលត្រូវការដើម្បីធ្វើកិច្ចការសម្រាប់អតិថិជន (ដំឡើងកុំព្យូទ័រ និងកំណត់រចនាសម្ព័ន្ធ) ក៏ដូចជាការងារជួយផ្នែកលក់ និងរៀបចំកំណត់ពេលវេលា និងផ្តល់នូវវគ្គបណ្តុះបណ្តាលបច្ចុប្បន្នភាពសម្រាប់បុគ្គលិកផ្នែកបច្ចេកទេស និងផ្នែកលក់ទាំងអស់។

ដូច្នេះ អ្នកគ្រប់គ្រងផ្នែកបច្ចេកទេសត្រូវតែមានកម្រិតចំណេះដឹងខ្ពស់ផ្នែកបច្ចេកទេស និងក៏ត្រូវមានជំនាញគ្រប់គ្រង និងទំនាក់ទំនងខ្លាំងដើម្បីប្រាកដថាក្រុមការងារបច្ចេកទេសអាចបំពេញការងារបានតាមការរំពឹងទុក។

# ៣. បរិស្ថានការងារនៅក្នុងហាងលក់កុំព្យូទ័រ

ការផ្ដល់នូវផលិតផល និងសេវាកម្មត្រឹមត្រូវ និងបន្តធ្វើឱ្យអតិថិជនពេញចិត្តទាមទារការធ្វើការជាក្រុម។ បុគ្គលិកផ្នែកលក់ត្រូវតែអាចទទួលនូវគំនិតច្បាស់លាស់ពីអ្វីដែលអតិថិជនចង់បាន និងអាចធ្វើការលក់ ដោយមានជំនួយពីបុគ្គលិកបច្ចេកទេសសម្រាប់ដំណោះស្រាយសមរម្យ។ បន្ទាប់មក ប្រសិនបើមានសេវាកម្មរួមផ្សំនឹងការលក់ នោះក្រុមបច្ចេកទេសនឹងត្រូវផ្ដល់នូវសេវាកម្មទាំងនោះឱ្យបានត្រឹមត្រូវ ស្របតាមពេលវេលាដែលបានព្រមព្រៀងជាមួយអតិថិជន។ សមាជិកក្រុមការងារទាំងអស់មានតួនាទីធ្វើឱ្យប្រាកដថាការលក់អាចបំពេញតាមចំណូលចិត្តរបស់អតិថិជន និងអតិថិជននឹងបន្តទិញទំនិញនៅក្នុងហាងរបស់ពួកគេទៀត។

ចំពោះដំណើរការទាំងអស់នេះមានភាពងាយស្រួល និងរហ័ស ត្រូវមានទំនាក់ទំនងល្អរវាងបុគ្គលិកផ្នែកលក់ទាំងអស់ជាមួយក្រុមការងារបច្ចេកទេស ដែលពួកគេម្នាក់ៗដឹងច្បាស់ពីភារកិច្ចរបស់ខ្លួន និងជួយអ្នកផ្សេងទៀតបំពេញគោលដៅការលក់ ឬជួលសេវាកម្ម។ ទោះបីជាក្រុមផ្នែកលក់ធ្វើការនៅក្នុងបន្ទប់តាំងបង្ហាញ និងក្រុមការងារផ្នែកបច្ចេកទេសធ្វើការនៅក្នុងបន្ទប់ផ្សេងកន្លែងដែលធ្វើតេស្ត ជួសជុលឧបករណ៍ក៏ដោយ បុគ្គលិកទាំងអស់នៅក្នុងហាងត្រូវបង្កើតជាក្រុមរួមមួយដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍គ្នាទៅវិញទៅមក។

ក្រុមការងារបច្ចេកទេសត្រូវតែបណ្ដុះបណ្ដាលខ្លួនឯងជាប្រចាំ និងសាកល្បងផលិតផលថ្មីដែលត្រូវលក់ចេញនៅក្នុងហាង។ សមាជិកក្រុមការងារត្រូវបង្រៀនបុគ្គលិកផ្នែកលក់ជាប្រចាំពីបុគ្គលិកលក្ខណៈ និងលទ្ធភាពប្រើបាននៃផលិតផលផ្សេងៗ ដើម្បីសម្រួលដល់ការងារលក់។ ម្យ៉ាងវិញទៀត ក្រុមបុគ្គលិកផ្នែកលក់ដែលទទួលបានមតិរិះគន់ផ្សេងៗពីអតិថិជន នឹងត្រូវតែធ្វើការរាយការណ៍ពន្យល់ប្រាប់ដល់ក្រុមបច្ចេកទេសពីអ្វីដែលអតិថិជនចង់បាន និងស្នើដល់ក្រុមបច្ចេកទេសឱ្យរៀបចំជួយដោះស្រាយអតិថិជននោះ។

ការធ្វើការនៅក្នុងហាងគឺមានការបែងចែកស្មើគ្នារវាងបុគ្គលិក និងមិនមានហេដ្ឋារចនាសម្ព័ន្ធច្រើនដូចនៅតាមស្ថាប័នផ្សេងៗទេ ដូច្នេះទំនាក់ទំនងមានសភាពធូរស្រាល និងជិតស្និទ្ធ។ ខណៈដែលក្រុមបច្ចេកទេសភាគច្រើនជាបុរស ក្រុមការងារផ្នែកលក់ក៏មានស្ត្រីច្រើនដែរ ព្រោះផ្នែកលក់ត្រូវការភាពទាក់ទាញអតិថិជនខ្លាំង។ ការបង្កើនចំនួននិស្សិតស្រីចូលរៀនក្នុងផ្នែកបច្ចេកវិទ្យាព័ត៌មាន ជាការបង្កើនភាគរយអ្នកធ្វើការផ្នែកបច្ចេកវិទ្យាព័ត៌មានជាស្ត្រីតាមការរំពឹងទុកផងដែរ។



# មេរៀនសង្ខេប

ហាងលក់កុំព្យូទ័រមានឯកទេសខាងលក់កុំព្យូទ័រ និងគ្រឿងឧបករណ៍កុំព្យូទ័រផ្សេងៗ។ ពួកគេមានក្រុមការងារផ្នែកលក់ និងក្រុមជំនួយបច្ចេកទេស។ ក្រុមផ្នែកលក់ទទួលសំណើពីអតិថិជនធ្វើការដោះស្រាយនូវបញ្ហាដែលពួកគេអាចធ្វើបាន ចំពោះអ្វីផ្សេងដែលផ្នែកលក់មិនអាចដឹង នោះពួកគេនឹងស្នើសុំជំនួយពីក្រុមការងារផ្នែកបច្ចេកទេស។ ជាធម្មតា បុគ្គលិកផ្នែកលក់ជ្រើសរើសចេញពីអ្នកដែលមិនមែនរៀនផ្នែកបច្ចេកវិទ្យាព័ត៌មានទេ ពួកគេច្រើនជាអ្នករៀនផ្នែកទីផ្សារ ឬធុរកិច្ច ម្យ៉ាងវិញទៀតការធ្វើការក្នុងក្រុមការងារបច្ចេកទេសជាធម្មតាត្រូវមានបរិញ្ញាបត្រផ្នែកបច្ចេកវិទ្យាព័ត៌មាន។ បុគ្គលិកផ្នែកលក់ត្រូវតែមានជំនាញទំនាក់ទំនងប្រសើរ ចេះស្តាប់អ្វីដែលអតិថិជនចង់បាន និងយល់ពីតម្រូវការរបស់ពួកគេ និងធ្វើការដោះស្រាយតាមមធ្យោបាយសមរម្យ។ បុគ្គលិកផ្នែកលក់ត្រូវបានគ្រប់គ្រងដោយអ្នកគ្រប់គ្រងផ្នែកលក់ដែលទទួលបន្ទុករៀបចំផែនការលក់សម្រាប់រយៈពេលមួយឆ្នាំ និងទិញទំនិញស្តុកដែលត្រឹមត្រូវតាមទីផ្សារ។ គាត់ក៏ទទួលបន្ទុកគ្រប់គ្រងបុគ្គលិកផ្នែកលក់ផងដែរ និងធ្វើឱ្យប្រាកដថាពួកគេទទួលបានការបណ្តុះបណ្តាលជានិច្ច។ ក្រុមការងារផ្នែកបច្ចេកទេសត្រូវបានបង្កើតឡើងដោយអ្នកជួសជុលដែលជំនាញខាងរកឃើញបញ្ហា និងជួសជុលកុំព្យូទ័រ និងគ្រឿងឧបករណ៍ផ្សេងៗ អ្នកឯកទេសជំនួយផ្នែកបច្ចេកទេសក៏ផ្តល់នូវសេវាកម្មដូចជារៀបចំតភ្ជាប់បណ្តាញ និងជួយផ្នែកលក់នៅពេលណាមួយដែលពួកគេត្រូវការ រីឯអ្នកគ្រប់គ្រងផ្នែកបច្ចេកទេសជាអ្នកដែលត្រូវតែធ្វើឱ្យប្រាកដថាប្រតិបត្តិការបច្ចេកទេសកើតឡើងតាមការរំពឹងទុក បំពេញចំណូលចិត្តរបស់អតិថិជន។ បុគ្គលិកទាំងអស់នៅក្នុងហាងលក់កុំព្យូទ័រត្រូវតែធ្វើការជាមួយគ្នាជាក្រុមដើម្បីសម្រេចបានគោលបំណងរបស់ហាងក្នុងការលក់ និងធ្វើឱ្យអតិថិជនសប្បាយរីករាយ។ វាជាបរិយាកាសការងារដែលទាមទារទំនាក់ទំនងគ្នា ការចែករំលែក និងរៀនសូត្រជាក្រុម។

# លំហាត់

## លំហាត់ ១

អ្នកសង្ឃឹមថានឹងបើកហាងលក់កុំព្យូទ័រផ្ទាល់ខ្លួននៅថ្ងៃណាមួយ ប៉ុន្តែអ្នកដឹងថាវាមិនអាចទៅរួចទេដើម្បីអាចទទួលជោគជ័យបាន ប្រសិនបើអ្នកមិនមានបទពិសោធន៍ក្នុងផ្នែកនេះទេ។

ពិភាក្សានៅក្នុងក្រុមរបស់អ្នក តើអ្នកគួររៀបចំផែនការការងាររបស់អ្នកយ៉ាងដូចម្តេចដើម្បីថ្ងៃណាមួយអ្នកក្លាយជាម្ចាស់ហាងលក់កុំព្យូទ័រមួយដែលល្បី។ តើបំណិនអ្វីដែលអ្នកត្រូវមានដើម្បីសម្រេចបំណងនេះ? តើប្រសើរដែរឬទេដោយចាប់ផ្តើមដំបូងជាបុគ្គលិកផ្នែកលក់ រួចក្លាយជាអ្នកគ្រប់គ្រងផ្នែកលក់ និងបន្ទាប់មកបង្កើតហាងលក់មួយដោយខ្លួនឯង? ឬតើវាប្រសើរដែរឬទេក្នុងការក្លាយជាបុគ្គលិកផ្នែកបច្ចេកទេស បន្ទាប់មកជាអ្នកគ្រប់គ្រងផ្នែកបច្ចេកទេស និងបន្ទាប់មកបង្កើតហាងលក់មួយ? តើអ្នកត្រូវរៀនផ្នែកទាំងពីរ ឬយ៉ាងណា? តើត្រូវមានកម្រិតវប្បធម៌សាកលវិទ្យាល័យ និង

ឯកទេសអ្វីខ្លះដើម្បីក្លាយជាម្ចាស់ហាង ? តើអ្នកគិតថាការសម្រេចចិត្តអ្វីដែលអ្នកគ្រប់គ្រងផ្នែកលក់ ឬអ្នកគ្រប់គ្រងផ្នែកបច្ចេកទេសមិនអាចសម្រេចបាន ?

## លំហាត់ ២

នៅក្នុងក្រុមការងារដែលមានគ្នាបីនាក់ ម្នាក់ៗត្រូវសន្មតយកតួនាទីមួយ។ អ្នកត្រូវធ្វើជាអតិថិជន ជាអ្នកលក់ និងបុគ្គលិកផ្នែកបច្ចេកទេស។

ដើរតួតាមស្ថានភាពខាងក្រោម៖

អតិថិជនមានក្រុមហ៊ុនអភិវឌ្ឍកម្មវិធីកុំព្យូទ័រថ្មីមួយ និងបានជួលអគារដែលមានពីរជាន់សម្រាប់បុគ្គលិកធ្វើការ ២៥ នាក់។ គាត់រៀបចំផែនការដើម្បីជួលអ្នកអភិវឌ្ឍកម្មវិធី ២០ នាក់ និងអ្នកវិភាគកម្មវិធីធ្វើការនៅក្នុងការិយាល័យ និងវិស្វករប្រព័ន្ធម្នាក់ ហើយក៏មានបុគ្គលិករដ្ឋបាលម្នាក់ផងដែរ។ អតិថិជនគម្រោងមានបន្ទប់ម៉ាស៊ីនមេមួយដែលបំពាក់ដោយម៉ាស៊ីនត្រជាក់ដែលម៉ាស៊ីនមេឯកសារត្រូវដាក់នៅទីនោះ។ គាត់ចង់ដឹងថា ប្រសិនបើគាត់អាចទិញគ្រឿងសម្ភារ និងជួលសេវាកម្មរៀបបណ្តាញទាំងអស់ពីហាង។

អ្នកលក់ពិតជាចង់ឱ្យអតិថិជននេះទិញសម្ភារៈ និងសេវាកម្មពីហាង ដូច្នេះគាត់នឹងធ្វើអ្វីមួយតាមលទ្ធភាពធ្វើបានដើម្បីលក់គ្រឿងសម្ភារ និងសេវាកម្មរបស់ហាង។ ជាដំបូង គាត់នឹងសួរសំណួរជាច្រើនអំពីអ្វីដែលអតិថិជនចង់បាន ដោយកត់ចំណាំរាល់ព័ត៌មានទាំងអស់។

បុគ្គលិកផ្នែកបច្ចេកទេសនឹងជួយអ្នកលក់ ឆ្លើយសំណួរនៅពេលចាំបាច់ និងផ្តល់នូវព័ត៌មាននៅពេលអ្នកលក់មិនអាចឆ្លើយបាន។ ពួកគេទាំងពីរក្រុមត្រូវតែអាចលក់គ្រឿងសម្ភារ និងបណ្តាញដល់អតិថិជននោះ។

## សំណួរត្រិះរិះ

១. តើកម្រិតវប្បធម៌បរិញ្ញាបត្រណាដែលនិយមបំផុតសម្រាប់បុគ្គលិកផ្នែកលក់ ឬផ្នែកបច្ចេកទេសនៅហាងលក់កុំព្យូទ័រ ?
២. តើបំណិនសំខាន់ៗអ្វីខ្លះដែលអ្នកលក់ត្រូវមាន ?
៣. តើហេតុអ្វីបានជាបំណិនស្តាប់ និងទំនាក់ទំនងមានសារៈសំខាន់សម្រាប់អ្នកលក់ ?
៤. តើអ្វីជាបំណិនចាំបាច់របស់បុគ្គលិកផ្នែកបច្ចេកទេស ?
៥. តើបុគ្គលិកផ្នែកលក់ និងផ្នែកបច្ចេកទេសធ្វើការជាមួយគ្នាយ៉ាងដូចម្តេចខ្លះ ?

# ផ្នែក ខ - ការជ្រើសរើសសាកលវិទ្យាល័យ

## ៤. សេចក្តីផ្តើម

នៅក្នុងប្រទេសកម្ពុជាមានសាកលវិទ្យាល័យជាច្រើនដែលផ្តល់ការសិក្សាផ្នែកព័ត៌មានវិទ្យា ទាំងកម្រិតបរិញ្ញាបត្រ និងអនុបណ្ឌិត ហើយមានសាកលវិទ្យាល័យខ្លះផ្តល់ជូនរហូតដល់កម្រិតបណ្ឌិតទៀតផង។ ការជ្រើសរើសសាកលវិទ្យាល័យត្រឹមត្រូវគឺសំខាន់ណាស់សម្រាប់អនាគតរបស់អ្នក ព្រោះវាជះឥទ្ធិពលដល់ការរៀបចំផែនការការងាររបស់អ្នក និងការវាយតម្លៃរបស់និយោជកអំពីភាពគ្រប់គ្រាន់ដែលអ្នកត្រូវបានបណ្តុះបណ្តាល។

សម្រាប់សាកលវិទ្យាល័យល្អ អ្នកមិនមែនគ្រាន់តែចូលរៀនជាមួយសាស្ត្រាចារ្យ ហើយប្រឡងនោះទេ គឺអ្នកនឹងត្រូវបានជជែកដេញដោល ដោយសាស្ត្រាចារ្យរបស់អ្នកដើម្បីធ្វើការងារ ឬគម្រោងជាក់ស្តែងទាំងឡាយរបស់អ្នកផ្ទាល់ និងជាក្រុម។ សាកលវិទ្យាល័យអាចនឹងជួយសម្របសម្រួលដល់ការទាក់ទងសម្រាប់អ្នក ដើម្បីចុះធ្វើកម្មសិក្សានៅតាមក្រុមហ៊ុន ឬស្ថាប័នផ្សេងៗ ដែលអ្នកនឹងទទួលបាននូវបទពិសោធន៍ និងទំនាក់ទំនងសម្រាប់ការងារអនាគតរបស់អ្នក។ សម្រាប់សាកលវិទ្យាល័យដែលបណ្តុះបណ្តាលកម្មវិធីសិក្សាថ្នាក់អនុបណ្ឌិត និងថ្នាក់សិក្សាស្រាវជ្រាវ គឺទាមទារឱ្យនិស្សិតត្រូវធ្វើការងារជាក់ស្តែង និងយល់ដឹងអំពីរបៀបសាកល្បង ហើយបង្ហាញថាការសន្និដ្ឋានរបស់ពួកគេគឺជាការពិត និងដើម្បីរៀបចំអនុវត្តជាមួយការងារជាក់ស្តែង។

និស្សិតទាំងអស់ដឹងច្បាស់ណាស់ថា ពួកគេនឹងទទួលបានសញ្ញាបត្រពីសាកលវិទ្យាល័យ ប៉ុន្តែសញ្ញាបត្រនេះមិនបានបញ្ជាក់ដល់និយោជកថា ពួកគេត្រូវបានត្រៀមរួចរាល់សម្រាប់ការងារជាក់ស្តែងទេ ប្រសិនបើពួកគេគ្រាន់តែទៅចូលរៀន ហើយប្រឡងឱ្យតែជាប់នោះ។ សាកលវិទ្យាល័យផ្តល់ឱកាសដើម្បីឱ្យនិស្សិតសិក្សា ហើយវាគឺអាស្រ័យទៅលើនិស្សិតខ្លួនឯងផ្ទាល់ក្នុងការប្រើប្រាស់ឱកាសនេះ។ ពួកគេរៀនបានច្រើនកម្រិតណា គឺមិនមែនអាស្រ័យលើចំនួនម៉ោងដែលពួកគេរៀនបាននោះទេ ប៉ុន្តែវាគឺអាស្រ័យលើការខិតខំប្រឹងប្រែងផ្ទាល់របស់និស្សិតម្នាក់ៗទៅលើការសិក្សា និងការអនុវត្តនូវអ្វីដែលពួកគេបានសិក្សា។ សាកលវិទ្យាល័យល្អគឺជាសាកលវិទ្យាល័យដែលមិនមែនគ្រាន់តែបង្រៀនប៉ុណ្ណោះទេ ប៉ុន្តែគឺជាសាកលវិទ្យាល័យដែលជួយសម្របសម្រួលដល់ការសិក្សាផ្ទាល់ខ្លួនរបស់និស្សិត និងមានកម្មវិធីសិក្សាល្អ។



# ៥. ការជ្រើសរើសសាកលវិទ្យាល័យ សម្រាប់ជំនាញព័ត៌មានវិទ្យា



ទាំងនេះជាលក្ខខណ្ឌមួយចំនួនដែលត្រូវយកចិត្តទុកដាក់ នៅពេលអ្នកពិចារណាអំពីសាកលវិទ្យាល័យដើម្បីចូលរៀន និងពេលដែលអ្នកចង់សិក្សាកម្រិតបរិញ្ញាបត្រផ្នែកបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT)។ កត្តាចម្បងនៃការជ្រើសរើសគួរតែផ្អែកលើការវិភាគអំពី ថាតើអ្នកនឹងចង់ក្លាយទៅជាអ្វី ហើយចង់បានការងារល្អកម្រិតណា។

១ យល់ដឹងអំពីថាតើការងារព័ត៌មានវិទ្យាមានសារៈសំខាន់ដូចម្ដេចខ្លះ សម្រាប់សាកលវិទ្យាល័យនោះ

មានសាកលវិទ្យាល័យមួយចំនួនផ្ដល់ការសិក្សាបរិញ្ញាបត្រជំនាញព័ត៌មានវិទ្យា ក្នុងចំណោមបរិញ្ញាបត្រជំនាញផ្សេងទៀតជាច្រើន ខណៈដែលសាកលវិទ្យាល័យដទៃគឺបានដាក់ជំនាញនេះជាផ្នែកចម្បងនៅក្នុងការសិក្សា ដោយពួកគេមានដេប៉ាតេម៉ង់ព័ត៌មានវិទ្យារឹងមាំ ហើយផ្ដល់នូវជម្រើសច្រើនសម្រាប់ការសិក្សាក្នុងផ្នែកនេះ។

នៅក្នុងសៀវភៅនេះអ្នកនឹងឃើញអំពីការងារជាច្រើន ដែលអ្នកអាចសម្រេចចិត្តចាប់យកពាក់ព័ន្ធជាមួយនឹងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។ ឥឡូវនេះប្រសិនបើអ្នកបានសម្រេចចិត្តច្បាស់លាស់ហើយថាអ្នកនឹងសិក្សាផ្នែកព័ត៌មានវិទ្យា បន្ទាប់មកអ្នកចាំបាច់ត្រូវតែស្វែងរកសាកលវិទ្យាល័យដែល ផ្ដល់នូវជំនាញឯកទេសអ្នកចង់សិក្សា ហើយដែលមិនមែនគ្រាន់តែជាកម្រិតព័ត៌មានវិទ្យាទូទៅឡើយ។ ឧទាហរណ៍ប្រសិនបើអ្នកចង់ក្លាយទៅជាអ្នកអភិវឌ្ឍកម្មវិធី អ្នកគួរតែពិចារណាជាពិសេស ទៅលើសាកលវិទ្យាល័យដែលផ្ដល់នូវកម្រិតជាក់លាក់ជា អ្នកអភិវឌ្ឍកម្មវិធី ។

ជំនួសឱ្យជំនាញឯកទេស សាកលវិទ្យាល័យមួយចំនួនបានផ្ដល់នូវកម្រិតបរិញ្ញាបត្រព័ត៌មានវិទ្យាទូទៅ ដែលមានជម្រើសឯកទេសអាចជ្រើសរើសបាននៅអំឡុងចុងឆ្នាំទីពីរ ហើយវាគឺជាជម្រើសដ៏ល្អ។

ថ្វីបើអ្នកកំពុងសិក្សាកម្រិតបរិញ្ញាបត្រក៏ដោយ សាកលវិទ្យាល័យនឹងផ្ដល់ឱ្យអ្នកនូវជំនាញឯកទេសតែនៅកម្រិតអនុបណ្ឌិតប៉ុណ្ណោះ ហើយអ្នកអាចរំពឹងថាសាកលវិទ្យាល័យនឹងមានចំណាប់អារម្មណ៍នៅក្នុងប្រធានបទនោះ រួចរៀបចំនិស្សិតទៅតាមជំនាញនោះ។

២

ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់សិក្សាស្រាវជ្រាវ

កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ (អនុបណ្ឌិត) គឺមានភាពជាក់លាក់ជាងកម្មវិធីបរិញ្ញាបត្រ ខុសពីបរិញ្ញាបត្រព័ត៌មានវិទ្យាទូទៅ កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់គឺសិក្សាទៅលើជំនាញឯកទេសដូចជា អ្នកអភិវឌ្ឍកម្មវិធី អ្នករចនា ឬវិស្វករប្រព័ន្ធ ជាដើម។ ពួកគេមួយចំនួនអាចបន្តទៅកម្រិតអនុបណ្ឌិតរបស់ខ្លួនដោយចាប់យកជំនាញឯកទេសដូចជាការអភិវឌ្ឍកម្មវិធីទូរសព្ទ ។ សាកលវិទ្យាល័យដែលផ្តល់ការសិក្សាថ្នាក់អនុបណ្ឌិតព័ត៌មានវិទ្យា គឺផ្តោតយ៉ាងខ្លាំងទៅលើផ្នែកនេះ ហើយនិស្សិតត្រូវតែទទួលបានការងារផ្នែកនេះយ៉ាងពិតប្រាកដ ដូចជាសាកលវិទ្យាល័យត្រូវមានសាស្ត្រាចារ្យដែលមានឯកទេសច្បាស់លាស់ មានបទពិសោធន៍ច្រើន និងមានកម្រិតសញ្ញាបត្រខ្ពស់ជាង។

៣

វិធីសាស្ត្របង្រៀន

ខណៈដែលយើងចាំបាច់ត្រូវអភិវឌ្ឍការយល់ដឹងទៅលើទ្រឹស្តីនៃវិទ្យាសាស្ត្រកុំព្យូទ័រ ការអនុវត្តក៏ត្រូវតែធ្វើផងដែរដើម្បីទទួលបានបទពិសោធន៍។ សាកលវិទ្យាល័យដែលមានប្រព័ន្ធបង្រៀនដោយឱ្យនិស្សិតបញ្ចប់គម្រោងរយៈពេលវែងរបស់ខ្លួន គឺធ្វើឱ្យនិស្សិតមានការយល់ដឹងច្រើនអំពីប្រធានបទ ហើយអាចអភិវឌ្ឍជំនាញដែលមិនមែនគ្រាន់តែទៅសាលា ឬធ្វើលំហាត់ខ្លីៗនោះឡើយ។

សាកលវិទ្យាល័យដែលបណ្តុះបណ្តាលកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ គឺពួកគេតែងតែលើកទឹកចិត្តនិស្សិតរបស់ខ្លួនឱ្យធ្វើការស្រាវជ្រាវ ។ ការស្រាវជ្រាវតម្រូវឱ្យនិស្សិតកំណត់ពីតំបន់ការសិក្សារបស់ខ្លួន ហើយជំរុញសាស្ត្រាចារ្យឱ្យចូលរួមផ្ទាល់ជាមួយនិស្សិតមិនមែនគ្រាន់តែបង្រៀននៅក្នុងថ្នាក់ប៉ុណ្ណោះទេ ប៉ុន្តែគឺដឹកនាំពួកគេឱ្យធ្វើគម្រោង។ តាមរយៈការងារស្រាវជ្រាវ និស្សិតទទួលបានជំនាញបច្ចេកទេស ភាពឯករាជ្យ សន្តិសុខ និងការអភិវឌ្ឍសមត្ថភាពរបស់ខ្លួនដើម្បីបង្ហាញអំពីគំនិត និងលទ្ធផលនៅក្នុងការសរសេរ។

៤

ការទាក់ទងជាមួយក្រុមហ៊ុន និងអង្គការ

សាកលវិទ្យាល័យដែលល្អបំផុត គឺជាសាកលវិទ្យាល័យដែលបានបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយបណ្តាក្រុមហ៊ុន និងអង្គការនានាដែលបម្រើការងារផ្នែកព័ត៌មានវិទ្យា។ ទំនាក់ទំនងទាំងនេះបង្កើតបានជាព័ត៌មានដ៏មានតម្លៃ អំពីប្រភេទ

នៃការងារដែលទីផ្សារត្រូវការ ហើយពួកគេក៏បង្កើតនូវឱកាសធ្វើកម្មសិក្សារបស់និស្សិតទៀតផង។ កម្មសិក្សា គឺជាការបណ្តុះបណ្តាលទៅលើការងារជំនាញដោយទទួលបាន ឬមិនទទួលបានប្រាក់ខែ។ តាមរយៈកម្មសិក្សាទាំងនេះ និស្សិតទទួលបានបទពិសោធន៍នៅក្នុងបរិស្ថានការងារជាក់ស្តែង និងបានស្គាល់ក្រុមហ៊ុនដែលអាចនឹងទទួលយកពួកគេឱ្យនៅធ្វើការបន្ត ពេលពួកគេបានបញ្ចប់កម្មសិក្សារបស់ខ្លួន។

សាកលវិទ្យាល័យល្អគឺអភិវឌ្ឍកិត្យានុភាពក្នុងចំណោមនិយោជកផ្នែកព័ត៌មានវិទ្យាដោយផ្អែកលើសមត្ថភាពដែលពួកគេទទួលបាននៅពេលបញ្ចប់ការសិក្សា ដើម្បីបានក្លាយទៅជាបុគ្គលិកល្អក្នុងរយៈពេលខ្លី បន្ទាប់ពីពួកគេត្រូវបានជ្រើសរើសឱ្យធ្វើការដោយមិនចាំបាច់មានការបណ្តុះបណ្តាលច្រើនឡើយ។ ជាទូទៅកិត្យានុភាពនេះគឺធ្វើឱ្យនិស្សិតទទួលបានប្រាក់ខែខ្ពស់ ដោយសារតែគុណភាពការងារល្អ។ វាគឺមានតម្លៃណាស់សម្រាប់និស្សិតក្នុងការសិក្សាដើម្បីឱ្យដឹងថា តើសាកលវិទ្យាល័យណាមួយដែលត្រូវបានវាយតម្លៃដោយនិយោជកថា ជាសាកលវិទ្យាល័យដែលល្អបំផុតខាងការបណ្តុះបណ្តាលផ្នែកព័ត៌មានវិទ្យា ព្រោះពួកគេនឹងមានផែនការចូលរួមជាមួយសាកលវិទ្យាល័យ ដើម្បីរៀបចំឱ្យពួកគេរកបានការងារល្អៗបន្ទាប់ពីបញ្ចប់ការសិក្សា។

៩ ការទាក់ទងជាមួយសាកលវិទ្យាល័យដទៃ

សាកលវិទ្យាល័យល្អគឺមិនធ្វើការដាច់តែឯងឡើយ ពួកគេមានទំនាក់ទំនងជាមួយសាកលវិទ្យាល័យនៅក្នុងប្រទេសផ្សេង ដើម្បីបង្កើតឱកាសក្នុងការផ្លាស់ប្តូរនិស្សិតគ្នា ក្នុងចំណោមសាកលវិទ្យាល័យទាំងនោះ។ ពួកគេក៏មើលផងដែរទៅលើការផ្តល់មូលនិធិសម្រាប់ការផ្លាស់ប្តូរទាំងនេះ ឬសម្រាប់និស្សិតរបស់ខ្លួនដើម្បីបន្តការសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ឬបណ្ឌិតនៅក្រៅប្រទេស។ ការមានទំនាក់ទំនងជាមួយសាកលវិទ្យាល័យដទៃក៏ជួយគាំទ្រផងដែរដល់កិច្ចការស្រាវជ្រាវរបស់និស្សិត។ អ្នកស្រាវជ្រាវក្នុងប្រទេសកម្ពុជា អាចសហការជាមួយអ្នកស្រាវជ្រាវនៅក្នុងសាកលវិទ្យាល័យនានា ដែលជាដៃគូអន្តរជាតិរបស់ពួកគេ។ ទំនាក់ទំនងទាំងនេះអាចឈានដល់ឱកាសផ្លាស់ប្តូរការទស្សនកិច្ចរបស់សាស្ត្រាចារ្យសម្រាប់ប្រធានបទជាក់លាក់បានទៀតផង។

៦

សមាគម

តាមរយៈសកម្មភាពកម្មវិធីសិក្សាបន្ថែម អ្នកស្រាវជ្រាវ និងក្រុមអ្នកបន្តការសិក្សានៅក្នុងសាកលវិទ្យាល័យដែលល្អបំផុត គឺអាចបង្កើតសមាគមនិស្សិត ឬសមាគមសាស្ត្រាចារ្យបាន។ ការបង្កើតសមាគមន៍នោះគឺជួយឱ្យអ្នកសិក្សាមានភាពរីករាយ និងមានប្រសិទ្ធភាពកាន់តែខ្លាំង ផ្តល់នូវជាជំនួយពេលពួកគេត្រូវការ និងបង្កើតបណ្តាញទំនាក់ទំនងដែលអាចជួយដល់ការរក្សាទំនាក់ទំនងក្នុងជីវិតទៀតផង។ បណ្តាញទំនាក់ទំនងនេះមានសារៈសំខាន់ណាស់ ព្រោះវាអាចជួយឱ្យអ្នកស្វែងរកបាននូវការងារសមរម្យ ដោយផ្តល់ជាឈ្មោះទំនាក់ទំនង ដូច្នេះអ្នកអាចទាក់ទងដាច់ដោយឡែកទៅកាន់ក្រុមហ៊ុន ឬអង្គការទាំងនោះបានយ៉ាងងាយស្រួល។

៧

ទិដ្ឋភាពជាក់ស្តែង៖ ថ្លៃចំណាយ កាលវិភាគ និងទីតាំង

ការពិត ពួកយើងទាំងអស់គ្នាមិនមែនសុទ្ធតែអាចបន្តការសិក្សា នៅសាកលវិទ្យាល័យបានដោយគ្មានការគាំទ្រផ្នែកហិរញ្ញវត្ថុឡើយ។ ដូច្នេះយើងត្រូវតែពិចារណាទៅលើទិដ្ឋភាពជាក់ស្តែងបី សម្រាប់ការជ្រើសរើសសាកលវិទ្យាល័យ គឺ៖

ថ្លៃចំណាយ៖ ថ្លៃចំណាយលើការសិក្សាសម្រាប់ជំនាញព័ត៌មានវិទ្យា គឺខុសគ្នាទៅតាមសាកលវិទ្យាល័យ។ សាកលវិទ្យាល័យខ្លះត្រូវចំណាយថ្លៃជាងគ្នារហូតដល់ទៅដប់ដង ឬច្រើនជាងនេះទៀតក៏មាន។ តាមទ្រឹស្តី ភាពខុសគ្នាខ្លាំងនៃតម្លៃគឺគួរតែផ្តល់នូវការអប់រំ និងសាស្ត្រាចារ្យដែលល្អប្រសើរ ប៉ុន្តែវាមិនដូច្នោះទាំងអស់ឡើយ ជាឧទាហរណ៍ សាកលវិទ្យាល័យសាធារណៈខ្លះដែលមិនមានតម្លៃថ្លៃខ្លាំងពេកទេ ប៉ុន្តែក៏នឹងផ្តល់នូវការបណ្តុះបណ្តាលល្អ ហើយទទួលស្គាល់ដោយនិយោជកថាជាសាកលវិទ្យាល័យ ល្អប្រសើរជាងសាកលវិទ្យាល័យឯកជនទៀតផង។ ជម្រើសរបស់អ្នកអាចត្រូវបានកំណត់ព្រំដែនដោយសារតម្លៃ ប៉ុន្តែកុំគិតថាសាកលវិទ្យាល័យដែលបង់ថ្លៃសិក្សាទាប គឺជាសាកលវិទ្យាល័យដែលមិនល្អ។ ត្រូវចងចាំថាលទ្ធផលនៃការសិក្សារបស់អ្នកគឺអាស្រ័យជាចម្បងទៅលើការចាប់អារម្មណ៍របស់អ្នក និងចំនួនការងារដែលអ្នកបានធ្វើ។

កាលវិភាគ៖ ក្នុងករណីដែលអ្នកត្រូវធ្វើការផង សិក្សាផង ឬអ្នកចង់ធ្វើការជាអ្នកស្ម័គ្រចិត្ត នៅអំឡុងចុងឆ្នាំទីពីរដើម្បីទទួលបានបទពិសោធន៍ អ្នកត្រូវប្រាកដថាសាកលវិទ្យាល័យដែលអ្នកបានជ្រើសរើស មានកាលវិភាគដែលអនុញ្ញាតឱ្យអ្នកអាចសិក្សា និងធ្វើការក្នុងពេលដូចគ្នាបាន។ សាកលវិទ្យាល័យខ្លះផ្តល់ការសិក្សារហូតដល់ទៅបីវេន គឺ ពេលព្រឹក ពេលរសៀល និងពេលយប់ ដែលអនុញ្ញាតឱ្យនិស្សិតធ្វើការពេញម៉ោងអាចសិក្សាបាន។ ចំពោះកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់វិញ ដែលជាទូទៅគឺសម្រាប់អ្នកដែលមានការងារធ្វើរួចហើយ កម្មវិធីនេះភាគច្រើនគឺសិក្សានៅពេលយប់ ឬចុងសប្តាហ៍។

ទីតាំង៖ នៅក្នុងទីក្រុងធំៗមួយចំនួននៃប្រទេសកម្ពុជា មានសាកលវិទ្យាល័យរួច

ទៅហើយដែលនិស្សិតអាចចូលសិក្សាបាន។ ក្នុងករណីខ្លះជម្រើសរបស់អ្នកនឹងត្រូវបានកាត់បន្ថយទៅតាមទីតាំងនៃសាកលវិទ្យាល័យដែលនៅជិតកន្លែងរស់នៅរបស់អ្នក។ ប្រសិនបើអ្នកមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ មានកន្លែងអាចស្នាក់នៅបាន ឬក៏មានការងារធ្វើរួចហើយ អ្នកអាចអាចនឹងស្វែងរកសាកលវិទ្យាល័យដែលល្អប្រសើរសម្រាប់អ្នកបាន។ កុំផាត់ចោលនូវសាកលវិទ្យាល័យក្នុងតំបន់របស់អ្នក រហូតដល់អ្នកបានពិនិត្យមើលតាមលក្ខខណ្ឌខាងលើ។ អ្នកអាចនឹងភ្ញាក់ផ្អើលនៅពេលដែលអ្នករកឃើញថា វាបានគ្រប់គ្រាន់ទៅតាមចំនួនលក្ខខណ្ឌនោះ។
បើទោះបីជាអ្នកនៅក្នុងរាជធានីភ្នំពេញក៏ដោយ មានសាកលវិទ្យាល័យខ្លះអាចនឹងឆ្ងាយពីកន្លែងរស់នៅ ឬកន្លែងការងាររបស់អ្នក។ ក្នុងករណីដែលអ្នកមានជម្រើសច្រើនសម្រាប់សាកលវិទ្យាល័យ អ្នកអាចពិចារណាទៅលើចំណុចមួយដែលផ្តល់នូវផាសុខភាពបំផុតគឺទីតាំង។

# ៦. អនុសាសន៍មួយចំនួន

ក្រៅពីលក្ខខណ្ឌទាំងអស់នេះ មានអនុសាសន៍មួយដែលអ្នកគួរតែពិចារណាមុនពេលចាប់ផ្តើមការសិក្សារបស់អ្នកនៅសាកលវិទ្យាល័យ។

១.- កុំព្យាយាមធ្វើអ្វីគ្រប់យ៉ាង។ ជ្រើសរើសអ្វីមួយដែលអ្នកចង់ធ្វើ។

វាមិនលំបាកឡើយក្នុងការស្វែងរកនិស្សិតនៅកម្ពុជា ដែលទទួលបានការសិក្សាពីរ ឬបីមុខវិជ្ជាក្នុងពេលតែមួយ។ ក្នុងករណីខ្លះមុខវិជ្ជាទាំងនោះគឺគ្រាន់តែជាមុខវិជ្ជាវាស់ស្ទង់សមត្ថភាពភាសាប៉ុណ្ណោះ មិនមែនជាមុខវិជ្ជាដែលបានសិក្សាសម្រាប់ការងារឡើយ ហើយមុខវិជ្ជាផ្សេងទៀតគឺជាមុខវិជ្ជាជំនាញសម្រាប់ការងារ។ ក្នុងករណីផ្សេងទៀត និស្សិតមួយចំនួនបន្តការសិក្សារបស់ខ្លួននូវជំនាញពីរដែលមិនទាក់ទងគ្នា ហើយដោយមិនដឹងពីអ្វីដែលពួកគេចង់ធ្វើនៅពេលអនាគតទៀតផង។

និយោជកសម្រាប់បុគ្គលិកផ្នែកព័ត៌មានវិទ្យា គឺតែងប្រាថ្នាចង់បាននិស្សិតទាំងឡាយណាដែលបានខិតខំប្រឹងប្រែងសិក្សាខ្លាំង នៅអំឡុងពេលសិក្សាថ្នាក់បរិញ្ញាបត្រដើម្បីទទួលបានជំនាញព័ត៌មានវិទ្យា និងនិស្សិតណាដែលមានភាពពិតប្រាកដថា អនាគតរបស់ពួកគេគឺស្ថិតក្នុងផ្នែកព័ត៌មានវិទ្យា។ ពេលពួកគេពិនិត្យមើលប្រវត្តិរូបសង្ខេបរបស់និស្សិត ដែលមានបរិញ្ញាបត្រពីរនៅក្នុងផ្នែកមិនទាក់ទងគ្នា និយោជកនឹងវាយតម្លៃថានិស្សិតនោះគឺមិនមានភាពច្បាស់លាស់ អំពីអ្វីដែលពួកគេចង់ធ្វើនៅពេលអនាគតឡើយ គឺពួកគេត្រូវបានបង្វែចស្មារតីដោយសារការងារផ្សេងទៀតនៅអំឡុងពេលសិក្សាថ្នាក់បរិញ្ញាបត្ររបស់ខ្លួន ហើយមិនបានផ្តោតទៅលើជំនាញព័ត៌មានវិទ្យាច្រើនឡើយ។ និស្សិតទាំងនេះនឹងមានការលំបាកក្នុងការទទួលបានការងារល្អ នៅក្នុងក្រុមហ៊ុនបច្ចេកវិទ្យា។

ជាអនុសាសន៍ និស្សិតគួរតែសម្រេចចិត្តផ្តោតទៅលើអាជីពការងារណាមួយឱ្យច្បាស់លាស់ បន្ទាប់មកធ្វើការអភិវឌ្ឍជំនាញនៅក្នុងផ្នែកនោះ។

សម្រាប់និស្សិតដែលចង់ក្លាយខ្លួនទៅជាអ្នកគ្រប់គ្រងព័ត៌មានវិទ្យា ជាដំបូងពួកគេត្រូវទាមទារឱ្យមានបរិញ្ញាបត្រព័ត៌មានវិទ្យា ហើយបន្ទាប់មកពួកគេត្រូវបន្តទៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ទៀត អាចក្នុងផ្នែកព័ត៌មានវិទ្យា ឬផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ខណៈដែលពួកគេទទួលបានការងារធ្វើរួចហើយ ឬយ៉ាងហោចណាស់បន្ទាប់ពីពួកគេទទួលបានបទពិសោធន៍ការងារខ្លះៗ។

## ២.- ជំហាននៃការសិក្សារបស់អ្នក

ដូចនៅក្នុងជំនាញភាគច្រើនផ្សេងទៀតដែរ ជំនាញព័ត៌មានវិទ្យាគឺមិនអាចសិក្សាឱ្យចេះគ្រប់យ៉ាងទៅលើអ្វីដែលផ្តល់ឱ្យពេលនៅសាលា ហើយបន្ទាប់មកប្រើចំណេះដឹងនោះនៅក្នុងជីវិតការងារទាំងអស់របស់អ្នកឡើយ។ ព័ត៌មានវិទ្យាគឺជាមុខវិជ្ជាមួយដែលបច្ចេកវិទ្យា និងឧបករណ៍ថ្មីៗត្រូវបានបង្កើតឡើងជារៀងរាល់ថ្ងៃ វាគឺទាមទារឱ្យមានការសិក្សាយ៉ាងខ្ជាប់ខ្ជួនចេញពីអ៊ីនធឺណិត ទស្សនាវដ្តី ការបោះពុម្ពផ្សាយផ្សេងទៀត ឬពីសហសេវិករបស់អ្នក។ ខណៈដែលចំណេះដឹងនេះភាគច្រើនត្រូវបានប្រើប្រាស់នៅក្នុងការងារជាក់ស្តែង វានឹងមិនមានអ្វីទាស់ខុសឡើយក្នុងការបង្កើតចំណេះដឹងសាមញ្ញ ហើយទទួលបាននូវទស្សនវិស័យប្រសើរសម្រាប់ពិភពព័ត៌មានវិទ្យា ដោយការសិក្សាយកបរិញ្ញាបត្រជាន់ខ្ពស់នៅក្នុងផ្នែកនេះ។

និស្សិតមួយចំនួននឹងបន្តការសិក្សាបច្ចេកទេសរបស់ខ្លួន ដោយបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅក្នុងផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ឬព័ត៌មានវិទ្យា ដើម្បីធ្វើឱ្យប្រសើរនូវជំនាញ និងកម្រិតបច្ចេកទេស ដែលវាគឺមានប្រយោជន៍យ៉ាងខ្លាំងសម្រាប់មនុស្សជាច្រើន។ អ្នកផ្សេងអាចសម្រេចចិត្តថាពួកគេចង់នៅជាមួយពិភពនៃបច្ចេកវិទ្យា ប៉ុន្តែដោយផ្អែកលើទស្សនវិស័យគ្រប់គ្រង (អ្នកគ្រប់គ្រងគម្រោង ឬអ្នកអ្នកគ្រប់គ្រងព័ត៌មានវិទ្យា) ពួកគេត្រូវស្វែងយល់ឱ្យបានច្រើនអំពីប្រតិបត្តិការពាណិជ្ជកម្ម មុខងារ និងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុនដែលពួកគេធ្វើការ។ ប្រសិនបើពួកគេធ្វើការនៅក្នុងក្រុមហ៊ុនឯកជន ពួកគេអាចធ្វើវាបាន



ដោយការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ដែលនឹងផ្តល់ឱ្យពួកគេនូវទស្សនវិស័យធំទូលាយ អំពីរបៀបប្រតិបត្តិការពាណិជ្ជកម្ម និងរបៀបដែលពួកគេត្រូវបានគាំទ្រដោយបច្ចេកវិទ្យា។ សម្រាប់អ្នកដែលចង់ប្តូរតួនាទីទៅជាអ្នកគ្រប់គ្រងនៅក្នុងអង្គការ ពួកគេគួរតែបន្តយកអនុបណ្ឌិតផ្នែកការអភិវឌ្ឍចីរភាព ឬកម្មវិធីស្រដៀងគ្នាមួយចំនួនទៀតនៅក្នុងផ្នែកអភិវឌ្ឍន៍សង្គម។

ការទទួលបានការងារយ៉ាងហោចពីរ ឬបីឆ្នាំមុនពេលចាប់ផ្តើមសិក្សាថ្នាក់អនុបណ្ឌិត គឺជាដំបូន្មានទូទៅ ព្រោះថាបទពិសោធន៍ការងារនឹងបង្កើនភាពយល់ដឹងរបស់យើង អំពីអ្វីដែលត្រូវសិក្សានៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នោះ។ ការធ្វើការនៅក្នុងក្រុមហ៊ុនគឺជួយឱ្យនិស្សិតដែលទើបបញ្ចប់ការសិក្សា ទទួលបានភាពស៊ាំជាមួយនឹងសភាពពិតនៃការងារប្រចាំថ្ងៃ អភិវឌ្ឍ និងស្វែងយល់អំពីទំនាក់ទំនងរបស់មនុស្សនៅក្នុងបរិស្ថានការងារ ហើយដឹងអំពីតម្លៃនៃការគ្រប់គ្រងដែលមានភាពស្មុគស្មាញ។ អ្នកធ្វើការវ័យក្មេងគឺនឹងមិនមើលឃើញថា និយោជកគ្រាន់តែជាអង្គភាពដែលផ្តល់ប្រាក់ខែឱ្យបុគ្គលិកធ្វើការពី៤ ទៅ ៨ ម៉ោងប៉ុណ្ណោះទេ ប៉ុន្តែពួកគេនឹងមើលឃើញថាជាស្ថាប័ន ឬក្រុមមនុស្សដែលអ្នកទាំងអស់គ្នាសុទ្ធតែមានតួនាទី និងការទទួលខុសត្រូវរៀងៗខ្លួន។

ខណៈដែលការមានបទពិសោធន៍ការងារ នៅមុនពេលចាប់ផ្តើមការសិក្សាកម្រិតខ្ពស់ គឺជារឿងល្អ វាក៏មិនមែនជាការសម្រេចចិត្តខុសដែរ ក្នុងការបន្តការសិក្សាទៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ បន្ទាប់ពីបញ្ចប់ថ្នាក់បរិញ្ញាបត្រនោះ ជាពិសេសថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅក្នុងផ្នែកដូចគ្នា (ដែលក្នុងករណីរបស់យើងនេះគឺផ្នែកព័ត៌មានវិទ្យា)។ សម្រាប់កម្មវិធីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ វាគឺគួរតែច្បាស់លាស់រួចទៅហើយសម្រាប់និស្សិតព័ត៌មានវិទ្យា ដែលពួកគេចង់ធ្វើការទៅលើផ្នែកណាមួយនោះ ហើយពួកគេគួរតែចាប់យកថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅក្នុងផ្នែកជាក់លាក់នោះ។ ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ភ្លាមៗបន្ទាប់ពីបញ្ចប់បរិញ្ញាបត្រនឹងផ្តល់ឱ្យនិស្សិតនូវទិដ្ឋភាពជាសាកលច្រើន និងសិក្សាបានរហ័សជាងអ្វីដែលពួកគេចង់ធ្វើ ប៉ុន្តែពួកគេក៏មិនត្រូវភ្លេចថាដើម្បីទទួលបានជំនាញបច្ចេកទេស គឺពួកគេត្រូវតែអនុវត្ត។ និយោជកអនាគតអាចនឹងមិនពិចារណាទៅលើមនុស្សដែលបញ្ចប់ថ្នាក់អនុបណ្ឌិតដោយគ្មានបទពិសោធន៍ ដូចមនុស្សដែលបានបញ្ចប់ត្រឹមតែថ្នាក់បរិញ្ញាបត្រ ប៉ុន្តែមានបទពិសោធន៍ពីរ ឬ



ច្រើនឆ្នាំឡើយ។ បទពិសោធន៍អនុវត្តន៍គឺមានតម្លៃយ៉ាងខ្លាំងសម្រាប់ផ្នែកបច្ចេកវិទ្យា។ ជម្រើសដែលល្អគឺអ្នកត្រូវធ្វើការ និងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្នុងពេលតែមួយ។

៣.- ការស្រាវជ្រាវដោយខ្លួនឯងនៅសាកលវិទ្យាល័យ

ក្នុងករណីខ្លះព័ត៌មានដែលយើងមានអំពីសាកលវិទ្យាល័យ គឺជាគំនិតសម្រាប់មិត្តភ័ក្តិដែលមិនបានដឹងព័ត៌មានច្រើនដូចយើង។ ការជ្រើសរើសសាកលវិទ្យាល័យគួរតែផ្អែកលើកត្តា និងព័ត៌មានជាក់ស្តែង។ យើងគួរតែព្យាយាមជជែកជាមួយនិស្សិតដែលបានបញ្ចប់ការសិក្សា ឬនិស្សិតដែលបានបញ្ចប់ឆ្នាំទីពីរនៃកម្រិតបរិញ្ញាបត្រ ក្នុងសាកលវិទ្យាល័យដែលអ្នកកំពុងពិចារណាដើម្បីចូលសិក្សា។ ប្រសិនបើយើងមិនមានស្គាល់មនុស្សនៅទីនោះទេ យើងអាចគ្រាន់តែទៅទស្សនាបរិវេណជុំវិញ រួចជជែកទៅកាន់និស្សិត ឬសាស្ត្រាចារ្យដែលយើងជួបនៅទីនោះ។ សាស្ត្រាចារ្យនឹងរីករាយក្នុងការជជែកជាមួយនិស្សិតបម្រុង ដែលមានចំណាប់អារម្មណ៍ពិតប្រាកដសម្រាប់អនាគតរបស់ខ្លួន។ ត្រូវទុកចិត្តលើព័ត៌មានដែលទទួលបានដោយផ្ទាល់។

ទោះបីជាអ្នកមិនទាន់បានចាប់ផ្តើមការសិក្សានៅសាកលវិទ្យាល័យក៏ដោយ អ្នកគួរតែទស្សនាការតាំងពិព័រណ៍ការងារ ដែលនិយោជកនឹងបង្ហាញព័ត៌មានអំពីក្រុមហ៊ុនរបស់ពួកគេ និងប្រភេទនៃការងារដែលពួកគេចង់បាន។ វានឹងផ្តល់ឱ្យអ្នកនូវគំនិតដ៏ប្រសើរអំពីប្រភេទការងារដែលអ្នកចង់បាននៅពេលអនាគត។

# ៧. សេចក្តីសន្និដ្ឋាន

បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍គឺជាវិស័យមួយដែលមានរីកចម្រើនយ៉ាងឆាប់រហ័ស ក៏ដូចជាផ្នែកមួយនៃពិភពលោកដែលផ្តល់នូវការងារគ្រប់គ្រាន់ សម្រាប់អ្នកដែលចង់បានការងារនៅក្នុងផ្នែកនេះ។ វាគឺចាំបាច់សម្រាប់និស្សិតទាំងឡាយដើម្បីដឹងថា ពួកគេគួរតែប្រើពេលវេលាសិក្សានៅសាកលវិទ្យាល័យរបស់ខ្លួនដើម្បីទទួលបានចំណេះដឹង បទពិសោធន៍ និងជំនាញដោះស្រាយបញ្ហាផ្សេងៗ។

នៅក្នុងសៀវភៅនេះយើងបានឃើញអំពីប្រភេទការងារជាច្រើនក្នុងវិស័យព័ត៌មានវិទ្យា ដែលពួកវានីមួយៗមានលក្ខណៈខុសគ្នាទៅតាមបរិស្ថានការងារជាក់ស្តែង ប្រភេទនៃសង្គម និងជំនាញបច្ចេកទេស។ អ្នកគឺអាចស្វែងរកបាននូវការងារផ្នែកព័ត៌មានវិទ្យា ដែលត្រូវគ្នាជាមួយប្រភេទនៃលក្ខណៈការងារនីមួយៗនោះ។



អ្នកអាចនឹងសម្រេចចិត្តជ្រើសយកការងារ នៅក្នុងផ្នែកព័ត៌មានវិទ្យាដែលកំពុងរីកចម្រើននេះ។ មិនថាការសម្រេចចិត្តរបស់អ្នកយ៉ាងណាឡើយ ចំណុចសំខាន់ដែលត្រូវចងចាំគឺថានិយោជកនឹងវិនិច្ឆ័យអ្នកតាមរយៈការងារដែលអ្នកអាចធ្វើបាន មិនមែនតាមរយៈចំនួនសញ្ញាបត្រដែលបានទទួលនោះទេ។ សាកលវិទ្យាល័យនឹងផ្តល់ឱកាសឱ្យអ្នកដើម្បីសិក្សា ប៉ុន្តែវាគឺអាស្រ័យទៅលើខ្លួនអ្នកដែលត្រូវប្រើឱកាសនេះ ដើម្បីក្លាយទៅជាអ្នកជំនាញដែលអ្នកផ្សេងចង់បាន។

# មេរៀនសង្ខេប

ការជ្រើសរើសសាកលវិទ្យាល័យត្រឹមត្រូវដើម្បីសិក្សាផ្នែកព័ត៌មានវិទ្យា គឺសំខាន់ណាស់សម្រាប់អនាគតរបស់អ្នកដែលចង់ចាប់យកជំនាញព័ត៌មានវិទ្យា។ លទ្ធភាពដែលអាចស្វែងរកការងារល្អបាន គឺអាស្រ័យជាចម្បងទៅលើចំនួនការងារផ្ទាល់ខ្លួនដែលអ្នកបានបំពេញ នៅអំឡុងពេលសិក្សានៅសាកលវិទ្យាល័យ  គឺមិនមែនជាអ្វីដែលអ្នកបានរៀននៅក្នុងថ្នាក់ឡើយ។ សាកលវិទ្យាល័យនឹងកាន់តែមានគុណតម្លៃសម្រាប់អ្នក ប្រសិនបើពួកគេមានផ្នែកសិក្សាជាក់លាក់ដែលអ្នកចង់បាន មិនមែនគ្រាន់តែជាកម្រិតព័ត៌មានវិទ្យាទូទៅនោះ។ សាកលវិទ្យាល័យឯកទេសនឹងគាំទ្រដល់ការខិតខំរបស់អ្នកដោយការទាមទារនូវការងារឯករាជ្យ ការសិក្សាដោយខ្លួនឯង និងជាក្រុមដែលបានគាំទ្រដោយការប្រកួតប្រជែងនៅក្នុងថ្នាក់។ អ្នកអាចនឹងពិចារណាទៅលើសាកលវិទ្យាល័យដែលផ្តល់នូវកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬបណ្ឌិត ព្រោះពួកគេនឹងអញ្ជើញសាស្ត្រាចារ្យល្អៗ ហើយតម្រូវឱ្យនិស្សិតធ្វើការស្រាវជ្រាវដោយផ្ទាល់ ដែលជាបទពិសោធន៍ដ៏ចាំបាច់។ វាក៏មានគុណតម្លៃខ្លាំងណាស់ដែរ ក្នុងការចូលរៀនជាមួយសាកលវិទ្យាល័យដែលមានទំនាក់ទំនងជាមួយក្រុមហ៊ុន ឬអង្គការផ្សេងៗ ព្រោះសាកលវិទ្យាល័យបានយល់ដឹងយ៉ាងប្រសើរអំពីទីផ្សារការងារ និងអាចជួយនិស្សិតឱ្យទទួលបានកន្លែងធ្វើកម្មសិក្សា ដើម្បីពួកគេអាចអភិវឌ្ឍជំនាញការងាររបស់ខ្លួន។ ការមានទំនាក់ទំនងជាមួយសាកលវិទ្យាល័យផ្សេងទៀតនៅជុំវិញពិភពលោកក៏សំខាន់ផងដែរ ព្រោះភាពជាដៃគូនេះគឺធ្វើឱ្យមានការបើកចំហសម្រាប់បន្តការសិក្សានៅបរទេស។ ប្រសិនបើអ្នកជ្រើសយកការសិក្សាជំនាញព័ត៌មានវិទ្យា យើងសូមផ្តល់អនុសាសន៍ថាអ្នកត្រូវតែផ្តោតជាសំខាន់ទៅលើព័ត៌មានវិទ្យាសម្រាប់អនាគតរបស់អ្នក ជាជាងការសិក្សាជំនាញផ្សេងដែលមិនពាក់ព័ន្ធក្នុងពេលតែមួយ។ អ្នកគួរតែមើលដោយយកចិត្តទុកដាក់ផងដែរទៅលើកាលវិភាគបង្រៀនរបស់សាលា ជាពិសេសគឺពេលដែលអ្នកធ្វើការផង រៀនផង។ ពេលអ្នកពិចារណាទៅលើការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ អ្នកគួរតែធ្វើការងារបានពីរបីឆ្នាំសិនទើបល្អ ព្រោះបទពិសោធន៍ការងាររបស់អ្នកនឹងធ្វើឱ្យការសិក្សារបស់អ្នកកាន់តែមានតម្លៃសម្រាប់អនាគត។

# លំហាត់

---

## លំហាត់ ៣

ចូរវិភាគអំពីរបៀបស្វែងរកព័ត៌មានរបស់សាកលវិទ្យាល័យ និងវាយតម្លៃថាតើសាកលវិទ្យាល័យណាមួយដែលអ្នកអាចចូលរៀនបាន ប្រសិនបើអ្នកចង់សិក្សាជំនាញព័ត៌មានវិទ្យា។

ពិភាក្សានៅក្នុងក្រុមរបស់អ្នកអំពីសកម្មភាពអ្វីខ្លះដែលអ្នកគួរធ្វើ ដើម្បីស្វែងរកសាកលវិទ្យាល័យដែលសមរម្យបំផុត សម្រាប់ជម្រើសជាក់លាក់នៃការងារ និងស្ថានភាព។

## សំណួរត្រិះរិះ

១. ហេតុអ្វីចាំបាច់ត្រូវចូលរៀននៅសាកលវិទ្យាល័យ ដែលបណ្ដុះបណ្ដាលកម្រិតបរិញ្ញាបត្រជាក់លាក់នៅក្នុងជំនាញដែលអ្នកចង់សិក្សា ?

២. ហេតុអ្វីចាំបាច់ត្រូវចូលរៀននៅសាកលវិទ្យាល័យ ដែលមានការលើកទឹកចិត្តខ្លាំងទៅលើការងារដើមផ្ទាល់ខ្លួន ?

៣. តើវាត្រូវមានគុណតម្លៃអ្វីខ្លះសម្រាប់សាកលវិទ្យាល័យ ដែលផ្ដល់នូវការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត ក្នុងជំនាញដែលអ្នកបានជ្រើស ?

៤. តើវាផ្ដល់នូវគុណតម្លៃដូចម្ដេចខ្លះសម្រាប់សាកលវិទ្យាល័យ ដែលមានទំនាក់ទំនងល្អជាមួយក្រុមហ៊ុននានា ?

៥. តើអ្វីជាគុណតម្លៃនៃការមានដៃគូជាមួយសាកលវិទ្យាល័យនៅជុំវិញពិភពលោក ?

រៀបរៀងដោយក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយ

វិទ្យាស្ថានបើកទូលាយ Open Institute

DEVELOPMENT INNOVATIONS

DW Akademie

ឧបត្ថម្ភការអភិវឌ្ឍដោយ

USAID FROM THE AMERICAN PEOPLE

កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ DEUTSCHE ZUSAMMENARBEIT

ឆ្នាំ ២០១៥